

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សារ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនពីៈ

- ឧបាសិកា កាំង ហ្គិចឈែ (ភ្នំពេញ)
- ឧបាសក ជុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ួច សាវឿង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា យុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជីម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ចែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
 ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ឌីស សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ តន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ខុទ្ទកនិកាយ សុត្តនិបាត
## តតិយភាគ
## ៥៤

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០១

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Itc
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

| | | | | | |
|---|---|---|---|---|---|
| 世話人代表 | 無着　成恭 | 世話人 | 松永　然道 | 有馬　実成 |
| 事務局長 | 篠原　鋭一 | | 伊藤　佳通 | 渡井　奎一 |
| | | | 杉谷　義純 | 茂田　真澄 |
| | | | 前田　利勝 | 中島　教之 |
| | | | 永　六輔 | |

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដក

## ខុទ្ទកនិកាយ សុត្តនិបាត

## តតិយភាគ

## ៥៤

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស សុត្តនិបាតោ

# តតិយោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមោ ឧរគវគ្គោ

### បឋមំ ឧរគសុត្តំ

(១) យោ វេ[១] ឧប្បតិតំ វិនេតិ កោធំ
វិសដំ សប្បវិសំវ ឱសធេហិ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។
យោ រាគមុទច្ឆិទា អសេសំ
ភិសបុប្ផំវ[២] សរោរុហំ វិគយ្ហ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

---

១ ឱ.ម. វេតិ នត្ថិ ។ ២ ឱ.ម. ភិសបុប្ផំ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ សុត្តនិបាត

# តតិយភាគ

---

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

## ឧរគវគ្គ ទី ១

### ឧរគសូត្រ ទី ១

(១) ភិក្ខុណា បន្ទោបង់សេចក្តីក្រោធ ដែលផុសឡើងហើយ ដូចបុគ្គលបន្សាបពិសពស់ ដែលជ្រាបទៅ ដោយឱសថទាំងឡាយ ភិក្ខុនោះឈ្មោះថា លះបង់ត្រើយខាងអាយ(១) ដូចពស់ សកសំណកចាស់គ្រាំគ្រាចេញ ។ ភិក្ខុណា ផ្តាច់បង់រាគៈមិនមានសេសសល់ ដូចគេកាត់ផ្កាឈូក ដែលដុះក្នុងស្រះ ភិក្ខុនោះឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់ សកសំណកចាស់គ្រាំគ្រាចេញ ។

---

១ ពាក្យថា ត្រើយខាងអាយ បានដល់សំយោជនៈ ៥ យ៉ាង ជាចំណែកខាងក្រោម ព្រោះថា សំយោជនៈទាំងនេះ ជាហេតុនាំសត្វឲ្យវកនៅក្នុងសង្សារវដ្ត ។ អដ្ឋកថា ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស សុត្តនិបាតោ

យោ តណ្ហមុទច្ឆិទា អសេសំ
សរិតំ សីឃសរំ វិសោសយិត្វា
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យោ មានមុទព្វធី អសេសំ
នឡសេតុំវ សុទុព្វលំ មហោឃោ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យោ នាជ្ឈគមា ភវេសុ សារំ
វិចិនំ បុប្ផមិវ ឧទុម្ពរេសុ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យស្សន្តរតោ ន សន្តិ កោបា
ឥតិភវាភវតញ្ច វីតិវត្តោ
សោ ភិក្ខុ ជហាតិ ឱរបារំ

ភិក្ខុណា បានផ្តាច់បង់តណ្ហា មិនមានសេសសល់ ញ៉ាំងតណ្ហា ដែលជាកិលេសជាតិ ត្រាច់ទៅ អន្ទោលទៅដោយរហ័ស ឲ្យរីងស្ងួត ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ គ្រាំគ្រាចេញ ។ ភិក្ខុណា កំចាត់មានះ មិនមានសេសសល់ ដូចជំនន់ធំ កំចាត់បង់ នូវស្ពានបបុស ដែលទុព្វលភាព ក្រៃលែង ភិក្ខុនោះឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ គ្រាំគ្រាចេញ ។ ភិក្ខុណា កាលស្វែងរកមិនបាន នូវសារៈ ក្នុងភពទាំងឡាយ ដូចបុគ្គល ស្វែងរក នូវផ្កាល្វដ៏ដើមល្វាទាំងឡាយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ គ្រាំគ្រាចេញ ។ សេចក្តីក្រោធ មិនមានក្នុងសន្តាន នៃភិក្ខុណា មួយទៀត ភិក្ខុណា ប្រព្រឹត្តកន្លង នូវបុណ្យនិងបាប ភិក្ខុនោះ ឈ្មោះថា បានលះបង់ ត្រើយខាងអាយ

សុត្តនិបាតេ ឧរគវគ្គស្ស បឋមំ ឧរគសុត្តំ

ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យស្ស វិតក្កា វិធូបិតា

អជ្ឈត្តំ សុវិកប្បិតា អសេសា

សោ ភិក្ខុ ជហាតិ ឱរបារំ

ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យោ នាច្ចសារី ន បច្ចសារី

សព្វំ អច្ចគមា ឥមំ បបញ្ចំ

សោ ភិក្ខុ ជហាតិ ឱរបារំ

ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យោ នាច្ចសារី ន បច្ចសារី

សព្វំ វិតថមិទន្តិ ញត្វា លោកេ

សោ ភិក្ខុ ជហាតិ ឱរបារំ

ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

ដូចពស់សក សំណកចាស់ ត្រាំត្រាចេញ ។ ភិក្ខុណា កំចាត់បង់ ផ្ដាច់បង់ ឲ្យជ្រះស្រឡះ នូវវិតក្កៈទាំងឡាយ ខាងក្នុងសន្ដាន មិនមាន សេសសល់ ភិក្ខុនោះ ឈ្មោះថា លះបង់ ត្រើយខាងអាយ ដូចពស់សក សំណកចាស់ ត្រាំត្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិន ក្រាញនៅ ប្រព្រឹត្តកន្លងនូវបបញ្ចធម៌ (១) ទាំងអស់ នេះបាន ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាង អាយ ដូចពស់សក សំណកចាស់ ត្រាំត្រាចេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញនៅ ព្រោះដឹង ច្បាស់ថា ធម្មជាត មានខន្ធជាដើម ទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយ ខាងអាយ ដូចពស់សក សំណកចាស់ត្រាំត្រាចេញ ។

---

១ ធម៌នេះមាន ៣ គឺ តណ្ហា ១ មានះ ១ ទិដ្ឋិ ១ ជាធម៌ញុំាងសត្វឲ្យមានដំណើរ យឺតយូរក្នុងសង្សារវដ្ដ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស សុត្តនិបាតោ

យោ នាច្ចសារី ន បច្ចសារី
សព្វំ វិតថមិទន្តិ វីតលោភោ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យោ នាច្ចសារី ន បច្ចសារី
សព្វំ វិតថមិទន្តិ វីតរាគោ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យោ នាច្ចសារី ន បច្ចសារី
សព្វំ វិតថមិទន្តិ វីតទោសោ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

យោ នាច្ចសារី ន បច្ចសារី
សព្វំ វិតថមិទន្តិ វីតមោហោ

ភិក្ខុណា មិនស្ទុះទៅ មិនក្រាញទៅ ជាអ្នកប្រាសចាកលោភៈ ដោយគិតថា ធម្មជាតមានខន្ធជាដើម ទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់ សកសំណកចាស់ ត្រាំត្រាបេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញទៅ ជាអ្នកប្រាសចាករាគៈ ដោយគិតថា ធម្មជាត មានខន្ធជាដើម ទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ ត្រាំត្រាបេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញទៅ ជាអ្នកប្រាសចាកទោសៈ ដោយគិតថា ធម្មជាត មានខន្ធជាដើម ទាំងអស់នេះ មិនទៀងទាត់ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ ត្រាំត្រាបេញ ។ ភិក្ខុណា មិនស្ទុះទៅ មិនក្រាញទៅ ជាអ្នកប្រាសចាកមោហៈ ដោយគិតថា ធម្មជាត មានខន្ធជាដើម ទាំងអស់នេះ មិនទៀងទាត់

## សុត្តនិបាតេ ឧរគវគ្គស្ស បឋមំ ឧរគសុត្តំ

សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។
យស្សានុសយា ន សន្តិ កេចិ
មូលា អកុសលា សមូហតា សេ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។
យស្ស ទរថជា ន សន្តិ កេចិ
ឱរំ អាគមនាយ បច្ចយា សេ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។
យស្ស វនថជា ន សន្តិ កេចិ
វិនិពន្ធាយ ភវាយ ហេតុកប្បា
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណំ ។

ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ គ្រាំគ្រាចេញ ។

អនុស្សយក្កិលេស ណាមួយ មិនមាន ដល់ភិក្ខុណា ឬ អកុសលមូល ដែលភិក្ខុ ដកចេញហើយ ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ គ្រាំគ្រាចេញ ។

ដែលកើតអំពីសេចក្តីក្រវល់

ក្រវាយ

មកកាន់

ត្រើប

ណ

យោ នីវរណេ បហាយ បញ្ច
អនីឃោ តិណ្ណកថង្កថោ វិសល្លោ
សោ ភិក្ខុ ជហាតិ ឱរបារំ
ឧរគោ ជិណ្ណមិវ តចំ បុរាណន្តិ ។

ឧរគសុត្តំ បឋមំ ។

ភិក្ខុណា លះបង់នីវរណៈ ៥ ប្រការ ជាអ្នកមិនតានតឹង ចូលសេចក្ដីងឿងឆ្ងល់ ប្រាសចាកសរគឺកិលេស ភិក្ខុនោះ ឈ្មោះថា លះបង់ត្រើយខាងអាយ ដូចពស់សក សំណកចាស់ គ្រាំគ្រាចេញ ។

ចប់ ឧរគសូត្រទី ១ ។

# ទុតិយំ ធនិយសុត្តំ

[២] បក្កោទនោ ទុទ្ធខីរោហមស្មិ (ឥតិ ធនិយោ គោបោ)

អនុតីរេ មហិយា សមានវាសោ

ឆន្នា កុដិ អាហិតោ គិនិ

អថ ចេ បត្ថយសី បវស្ស ទេវ ។

អក្កោធនោ វិគតខិលោហមស្មិ (ឥតិ ភគវា)

អនុតីរេ មហិយេករត្តិវាសោ(១)

វិវដា កុដិ និព្វុតោ គិនិ

អថ ចេ បត្ថយសី បវស្ស ទេវ ។

អន្ធកមកសា ន វិជ្ជរេ (ឥតិ ធនិយោ គោបោ)

កច្ឆេ រូឡ្ហតិណេ ចរន្តិ គាវោ

វុដ្ឋិម្បិ សហេយ្យុមាគតំ

អថ ចេ បត្ថយសី បវស្ស ទេវ ។

---

១ ម. មហិរេករត្តិវាសោ ។

# ធនិយសូត្រ ទី ២

(២) (សេដ្ឋិបុត្ត ឈ្មោះធនិយគោបៈ ពោលថា) យើងមានបាយចំអិនហើយ មានទឹកដោះរូតហើយ ជាអ្នកនៅ ជាមួយជនបរិស័ទ ទៀបឆ្នេរទន្លេមហី ខ្ទមៈយើង បានប្រក់ហើយ ភ្លើងក៏បង្កាត់ហើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ៗ

(ព្រះមានព្រះភាគត្រាស់ថា) តថាគត មិនមានសេចក្ដីក្រោធ ប្រាសចាកសេចក្ដីរឹងត្អឹងហើយ នៅអស់រាត្រីមួយ ក្បែរឆ្នេរទន្លេមហី ខ្ទមគឺអត្តភាព មានដំបូលបើកចេញហើយ ភ្លើងរលត់ហើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ៗ

(ធនិយគោបៈ ពោលថា) រពោម ក៏មិនមាន គោទាំងឡាយ ក៏ដើរទៅក្នុងប្រែក ដែលមានស្មៅលូតលាស់ល្អ គោទាំងឡាយ ក៏អត់ធន់នូវភ្លៀង ដែលបង្អុរមក ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ៗ

---

១ បានដល់ភ្លើងទាំង ១១ គឺ ភ្លើងគឺរាគៈជាដើម ។ អដ្ឋកថា ។

ពទ្ធា(១) ហិ ភិសី សុសង្ខតា (ឥតិ ភគវា)
តិណ្ណោ បារគតោ វិនេយ្យ ឱឃំ
អត្ថោ ភិសិយា ន វិជ្ជតិ
អថ ចេ បត្ថយសី បវស្ស ទេវ ។

គោបី មម អស្សវា អលោលា (ឥតិ ធនិយោ គោបោ)
ទីឃរត្តំ សំវាសិយា មនាបា
តស្សា ន សុណាមិ កិញ្ចិ បាបំ
អថ ចេ បត្ថយសី បវស្ស ទេវ ។

ចិត្តំ មម អស្សវំ វិមុត្តំ (ឥតិ ភគវា)
ទីឃរត្តំ បរិភាវិតំ សុទន្តំ
បាបំ បន មេ ន វិជ្ជតិ
អថ ចេ បត្ថយសី បវស្ស ទេវ ។

---

១ ឱ. ពទ្ធា ។ ប. ពន្ធា ។

(ព្រះមានព្រះភាគត្រាស់ថា) ក្បូនតថាគតបាន ចង ចាត់ចែងស្រួលហើយ តថាគត បានឆ្លងដល់ត្រើយ កំចាត់បង់ នូវឱឃៈបាន សេចក្តីត្រូវការ ដោយក្បូន មិនមានទៀតទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

(ធនិយគោបៈពោលថា) ប្រពន្ធរបស់យើង ជាអ្នកស្តាប់បង្គាប់ ជាស្ត្រីមិនលេះលោះ ជាទីពេញចិត្ត គួរនៅរួម អស់កាលដ៏វែង យើងមិនដែលឮសំដី ដ៏អាក្រក់តិចតួច របស់ប្រពន្ធនោះឡើយ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

(ព្រះមានព្រះភាគ ត្រាស់ថា) ចិត្តរបស់តថាគត ជាធម្មជាត ស្តាប់បង្គាប់ ជាចិត្តរួចស្រឡះហើយ តថាគត បានអប់រំហើយ ទូន្មានល្អហើយ អស់កាលដ៏វែង បំណែកបាប មិនមាន ដល់តថាគតទៀតទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

## សុត្តនិបាតេ ឧរគវគ្គស្ស ទុតិយំ ធនិយសុត្តំ

អត្តវេត្តនភតោហមស្មិ(១) (ឥតិ ធនិយោ គោបោ)
បុត្តា ច មេ សមានិយា អរោគា
តេសំ ន សុណាមិ កិញ្ចិ បាបំ
អថ ចេ បត្ថយសី បវស្ស ទេវ ។
នាហំ ភតកោស្មិ កស្សចិ (ឥតិ ភគវា)
និព្វិដ្ឋេន ចរាមិ សព្វលោកេ
អត្ថោ ភតិយា ន វិជ្ជតិ
អថ ចេ បត្ថយសី បវស្ស ទេវ ។
អត្ថិ វសា អត្ថិ ធេនុបា (ឥតិ ធនិយោ គោបោ)
គោធរណិយោ បវេណិយោបិ អត្ថិ
ឧសភោបិ គវម្បតី ច អត្ថិ
អថ ចេ បត្ថយសី បវស្ស ទេវ ។

១ ម. អត្តវេត្តនាភតោហមស្មិ ។

សុត្តនិបាត ឧរគវគ្គ ធនិយសូត្រ ទី ២

(ធនិយគោបៈពោលថា) យើងជាអ្នកចិញ្ចឹមជីវិត ដោយថ្លៃឈ្នួល បំពោះខ្លួនឯង ចំណែកខាងកូនទាំងឡាយ របស់យើង មានសេចក្តីមូលមិត្ត ឥតមានរោគទេ យើងមិនដែលឮហេតុអាក្រក់តិចតួច របស់កូននោះឡើយ ម្នាលភ្លៀងឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ៗ

(ព្រះមានព្រះភាគ ត្រាស់ថា) តថាគត មិនមែន ជាអ្នកស៊ីឈ្នួល អ្នកណាមួយទេ តថាគតត្រាច់ទៅ ដោយឥតមានជាប់ចំពាក់ ក្នុងលោកទាំងមូល សេចក្តីត្រូវការ ដោយថ្លៃឈ្នួល មិនមានទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ៗ

(ធនិយគោបៈ ពោលថា) គោជំទង់ ក៏មានកូនគោ កំពុងបៅដោះ ក៏មាន មេគោមានគភ៌ទឹងមេគោកំពុងដោយឈ្មោល ក៏មាន គោឈ្មោលជាគោបា របស់យើង ក៏មាន ម្នាលភ្លៀងឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ៗ

នត្ថិ វសា នត្ថិ ធេនុបា (ឥតិ ភគវា)
គោធរណិយោ បវេណិយោបិ នត្ថិ
ឧសភោបិ គវម្បតី[1] ធ នត្ថិ
អថ ចេ បត្ថយសី បវស្ស ទេវ ។
ខីលា និខាតា អសម្បវេធី[2] (ឥតិ ធនិយោ គោបោ)
ទាមា មុញ្ជមយា នវា សុសណ្ឋានា
ន ហិ សក្ខិន្តិ ធេនុបាបិ ឆេត្តុំ
អថ ចេ បត្ថយសី បវស្ស ទេវ ។
ឧសភោរិវ ឆេត្វា ពន្ធនានិ (ឥតិ ភគវា)
នាគោ បូតិលតំវ ទាលយិត្វា
នាហំ បុន ឧបេស្សំ គព្ភសេយ្យំ
អថ ចេ បត្ថយសី បវស្ស ទេវ ។

---

១ ឱ. គវម្បតីធ ។ ២ ឱ ម. អសម្បវេធិ ។

(ព្រះមានព្រះភាគ ត្រាស់ថា) គោជំទង់ ក៏មិនមាន កូនគោកំពុងបៅដោះ ក៏មិនមាន មេគោមានគភ៌ ទឹងមេគោកំពុងជាយឈ្មោល ក៏មិនមាន គោឈ្មោលជាគោបា របស់តថាគត ក៏មិនមាន ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

(ធនិយគោបៈ ពោលថា) បង្គោលស្នឹង (សម្រាប់ចងគោ) យើងបានបោះមិនរង្គៀតទេ ខ្សែព្រួរទាំងឡាយ ដែលវេញអំពីស្មៅយាប្លង់ក៏នៅថ្មី មានសណ្ឋាននៅល្អ កូនគោកំពុងបៅដោះ មិនអាចទាញផ្តាច់បានទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

(ព្រះមានព្រះភាគ ត្រាស់ថា) តថាគត ផ្តាច់បំណង គឺសំយោជនៈ បំណែកខាងលើក្រៅ ដូចគោឧសភ ផ្តាច់នូវបំណង ទំលាយបំណងគឺ សំយោជនៈក្រៅខាងក្រោម ដូចដំរីទំលាយវល្លិ៍ផោម មិនបានចូលទៅ កាន់ដំណេកក្នុងគភ៌ទៀតទេ ម្នាលភ្លៀង ឥឡូវនេះ បើអ្នកចង់បង្អុរ ចូរបង្អុរមកចុះ ។

និន្នញ្ច ថលញ្ច បូរយន្តោ
មហាមេឃោ បាវស្សិ តាវទេ
សុត្វា ទេវស្ស វស្សតោ
ឥមមត្ថំ ធនិយោ អភាសថ
លាភា វត នោ អនប្បកា
យេ មយំ ភគវន្តំ អទ្ទសាម
សរណំ តំ ឧបេម ចក្ខុម
សត្ថា នោ ហោហិ(១) មហាមុនិ ។
គោបី ច អហញ្ច អស្សវា
ព្រហ្មចរិយំ សុគតេ ចរាមសេ
ជាតិមរណស្ស បារគា(២)
ទុក្ខស្សន្តករា ភវាមសេ ។
នន្ទតិ បុត្តេហិ បុត្តិមា (ឥតិ មារោ បាបិមា)
គោមិកោ(៣) គោហិ តថេវ នន្ទតិ
ឧបធីហិ នរស្ស នន្ទនា
ន ហិ សោ នន្ទតិ យោ និរូបធិ ។

---

១ ឱ. ម. ឯត្តន្តរេ តុវំ អត្ថិ ។ ២ ម. បារគូ ។ ៣ ឱ. គោមិកោ ។ ម. គោបិយោ ។

ខណៈនោះឯង មហាមេឃ បង្អុរភ្លៀងឡើង ពេញ នូវទីទាបនិងទីទួល ធនិយគោបៈ បានឮ សូរភ្លៀងបង្អុរ ក៏ពោល នូវសេចក្ដីនេះ ថា ឱ លាភរបស់យើង មិនមែនតិចទេ ព្រោះយើង បានឃើញ នូវព្រះមានព្រះភាគ បពិត្រព្រះអង្គ មានចក្ខុ យើងសូមដល់ព្រះអង្គ ជាទីពឹង សូម ព្រះមហាមុនី ជាសាស្ដាចារ្យ នៃយើង ។ យើងទាំងឡាយ គឺប្រពន្ធនឹងខ្ញុំព្រះអង្គ ជាអ្នក ស្ដាប់បង្គាប់ សូមប្រព្រឹត្ត នូវព្រហ្មចរិយធម៌ ក្នុងសំណាក់ នៃព្រះសុគត សូមជាអ្នកបានដល់ ត្រើយ នៃជាតិនិងមរណៈ ធ្វើទីបំផុតនៃទុក្ខ ។

(មារមានចិត្តបាប និយាយថា) បុគ្គលមានបុត្ត រមែងត្រេកអរ នឹងបុត្តទាំងឡាយ បុគ្គលមានគោ រមែងត្រេកអរ នឹងគោទាំងឡាយ ដូច្នោះដែរ ការ ត្រេកអរ របស់នរជន រមែងមាន ព្រោះតែឧបធិ ទាំងឡាយ (គ្រឿងជាប់ជំពាក់) បុគ្គលណា មិនមានឧបធិ បុគ្គលនោះ ទើបមិនត្រេកអរ ។

សោចតិ បុត្តេហិ បុត្តិមា (ឥតិ ភគវា)

គោមិកោ គោហិ តថេវ សោចតិ

ឧបធីហិ នរស្ស សោចនា

ន ហិ សោ សោចតិ យោ និរូបធីតិ ។

ធនិយសុត្តំ ទុតិយំ ។

( ព្រះមានព្រះភាគ ត្រាស់ថា ) បុគ្គលមានបុត្ត រមែងសោក នឹងបុត្តទាំងឡាយ បុគ្គលមានគោ រមែងសោក នឹងគោទាំងឡាយ ដូច្នោះដែរ ការសោក របស់នរជន រមែងមាន ព្រោះតែឧបធិទាំងឡាយ លុះតែបុគ្គលណា មិនមានឧបធិ បុគ្គលនោះ ទើបមិនសោក ។

ចប់ ធនិយសូត្រ ទី ២ ។

# តតិយំ ខគ្គវិសាណសុត្តំ

(៣) សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
អវិហេឋយំ អញ្ញតរម្បិ តេសំ
ន បុត្តមិច្ឆេយ្យ កុតោ សហាយំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សំសគ្គជាតស្ស ភវន្តិ ស្នេហា(១)
ស្នេហន្វយំ ទុក្ខមិទំ បហោតិ
អាទីនវំ ស្នេហជំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
មិត្តេ សុហជ្ជេ អនុកម្បមានោ
ហាបេតិ អត្ថំ បដិពទ្ធចិត្តោ
ឯតំ ភយំ សន្ថវេ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---
១ ម. ស្នេហោ ។

# ខគ្គវិសាណសូត្រ ទី ៣

(៣) បុគ្គល ដាក់អាជ្ញាចោលចេញ ចំពោះពួកសត្វ ទាំងអស់ មិនបៀតបៀន នូវសត្វទាំងនោះ សូម្បីសត្វណាមួយ មិនគប្បីប្រាថ្នា នូវបុត្រ តើគប្បីត្រូវការសំឡាញ់ អំពីណា គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

សេចក្តីស្រឡាញ់ តែងមាន ដល់បុគ្គលដែលប្រឡូកប្រឡំ ទុក្ខដែលជាប់តាម ចំពោះសេចក្តីស្រឡាញ់នេះ ក៏តែងកើតឡើង បុគ្គលឃើញទោស ដែលកើត អំពីសេចក្តីស្រឡាញ់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល អ្នកមានចិត្តប្រតិព័ទ្ធ កាលអនុគ្រោះនូវពួកមិត្ត ដែលមានចិត្តល្អ តែងញុំាងប្រយោជន៍ឲ្យសាបសូន្យ បុគ្គលកាលឃើញ នូវភ័យក្នុងការមូលមិត្តគ្នានុ៎ះហើយ គប្បីត្រាច់ទៅតែម្នាក់ឯងដូចកយរមាស ។

វំសោ វិសាលោ វ យថា វិសត្តោ
បុត្តេសុ ទារេសុ ច យា អបេក្ខា
វំសាកឡីរោវ អសជ្ជមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

មិគោ អរញ្ញម្ហិ យថា អពន្ធោ[១]
យេនិច្ឆកំ គច្ឆតិ គោចរាយ
វិញ្ញូ នរោ សេរិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

អាមន្តនា ហោតិ សហាយមជ្ឈេ
វាសេ ឋានេ គមនេ ចារិកាយ
អនភិជ្ឈិតំ សេរិតំ បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---

១ ម. អពទ្ធោ ។

សេចក្តីស្រឡាញ់ ចំពោះកូននឹងប្រពន្ធ ដូចឫស្សី ដែលបែកគុម្ព ជាក់កណ្តាញ់ បុគ្គល កាលមិន ជាប់ជំពាក់ ដូចជាទំពាំងឫស្សី គប្បីត្រាច់ទៅតែ ម្នាក់ឯង ដូចកុយរមាស ។

ម្រឹគក្នុងព្រៃ ជាសត្វមិនជាប់ចំណង ទៅរកចំណី តាមចំណង់ចិត្តបាន យ៉ាងណា វិញ្ញូជន កាល បើឃើញ សេរីភាព[1] (យ៉ាងនោះ) គប្បីត្រាច់ ទៅតែម្នាក់ឯង ដូចកុយរមាស ។

ការហៅរក រមែងមាន ដល់ជនឋិតនៅ ក្នុង កណ្តាល នៃសំឡាញ់ គឺការទៅ ការឈរនឹង ការត្រាច់ចារិក បុគ្គលកាលបើឃើញ សេរីភាព ដែល (ពួកជនពាល) មិនប្រាថ្នា គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

---

១ ការប្រព្រឹត្តតាមចំណង់ចិត្តខ្លួន គឺធ្វើបានតាមឥស្សរៈចិត្ត ឬមិនជាប់ក្នុងអំណាចអ្នកដទៃ ។ អដ្ឋកថា ។

ខិឌ្ឌា រតី ហោតិ សហាយមជ្ឈេ
បុត្តេសុ ច វិបុលំ ហោតិ បេមំ
បិយវិប្បយោគំ វិជិគុច្ឆមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ
សន្តុស្សមានោ ឥតរីតរេន
បរិស្សយានំ សហិតា អឆម្ភី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ទុស្សង្គហា បព្វជិតាបិ ឯកេ
អថោ គហដ្ឋា ឃរមាវសន្តា
អប្បោស្សុក្កោ បរបុត្តេសុ ហុត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ការលេង ការត្រេកអរ ក្នុង (កាមគុណ) រមែងមាន ដល់ជនឋិតនៅ ក្នុងកណ្តាល នៃសំឡាញ់ មួយទៀត សេចក្តីស្រឡាញ់ ដ៏ធំទូលាយ រមែងមានក្នុងបុត្តទាំងឡាយ បុគ្គល កាលបើធុញទ្រាន់ នឹងការព្រាត់ប្រាស ចាកសត្វនឹងសង្ខារ ជាទីស្រឡាញ់ហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល ជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនលំបាក ត្រេកអរ ដោយបរិក្ខារ តាមមាន តាមបាន ជាអ្នកអត់ធន់ ចំពោះអន្តរាយទាំងឡាយ ទាំងជាអ្នកមិនតក់ស្លុត គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បព្វជិតពួកខ្លះ ឬគ្រហស្ថអ្នកគ្រប់គ្រងផ្ទះ គេសង្គ្រោះ បានដោយកម្រ បុគ្គលមិនមានសេចក្តីខ្វល់ខ្វាយ ចំពោះបុត្ត នៃបុគ្គលដទៃ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

ឱរោបយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ យថា កោវិឡារោ
ឆេត្វាន ធីរោ គិហិពន្ធនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។

ធីរបុរស លះបង់ នូវវត្ថុទាំងឡាយ ជាគ្រឿងប្រាកដ នូវភាពជាគ្រហស្ថ កាត់បំណង របស់គ្រហស្ថទាំងឡាយ ដូចជារលួសផ្អុង ជំរុះស្លឹក គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បើបុគ្គលបានអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅដោយប្រពៃ ជាសំឡាញ់ មានប្រាជ្ញាខ្ជាប់ខ្ជួន ត្រាច់ទៅ ជាមួយគ្នា គ្របសង្កត់នូវសេចក្តីអន្តរាយទាំងពួងបាន គប្បីមានចិត្តត្រេកអរ មានស្មារតី ត្រាច់ទៅជាមួយសំឡាញ់នោះទៅចុះ ។

បើបុគ្គល រកអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅដោយប្រពៃ ជាសំឡាញ់ មានប្រាជ្ញាខ្ជាប់ខ្ជួន ត្រាច់ទៅជាមួយគ្នា ពុំបានទេ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចព្រះរាជាលះបង់ នូវដែនដែលព្រះអង្គឈ្នះហើយ ឬដូចដំរីឈ្មោះមាតង្គៈ លះបង់ហ្វូង ត្រាច់ទៅក្នុងព្រៃ ។

អទ្ធា បសំសាម សហាយសម្បទំ
សេដ្ឋា សមា សេវិតព្វា សហាយា
ឯតេ អលទ្ធា អនវជ្ជភោជី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ទិស្វា សុវណ្ណស្ស បភស្សរានិ
កម្មារបុត្តេន សុនិដ្ឋិតានិ
សង្ឃដ្ដមានានិ ទុវេ ភុជស្មឹ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឯវំ ទុតិយេន សហា មមស្ស
វាចាភិលាបោ អភិសជ្ជនា វា
ឯតំ ភយំ អាយតិំ(១) បេក្ខមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
កាមា ហិ ចិត្រា មធុរា មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ

---

១ ម. អាយតឹ ។

តាមពិត យើងសរសើរ នូវការបរិបូណ៌ ដោយសំឡាញ់ហើយ តែសំឡាញ់ មានគុណប្រសើរជាង នឹងសំឡាញ់មានគុណស្មើ បុគ្គលគួរសេពគប់ ពប់រក បើ (កុលបុត្រចង់បានប្រយោជន៍) រកសំឡាញ់ទាំងនុ៎ះ ពុំបានទេ គប្បីជាអ្នកបរិភោគភោជន ដែលមិនមានទោស ហើយត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលឃើញ នូវកងមាសទាំងពីរ ដ៏ភ្លឺផ្លេក ដែលជាងមាស ធ្វើសម្រេចហើយ ដោយល្អ រណ្តំគ្នាក្នុងដៃ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

ការចរចា ដោយពាក្តី ការជាប់ចំពាក់ក្តី ជាមួយនឹងកុមារ ជាគំរប់ពីរ មានដល់អញ យ៉ាងនេះ បុគ្គលកាលបើឃើញ នូវភ័យនុ៎ះ តទៅខាងមុខហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

ពិតណាស់ កាមទាំងឡាយ ដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត តែងញាំញី នូវចិត្ត

អាទីនវំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឦតី ច គណ្ឌោ ច ឧបទ្ទវោ ច
រោគោ ច សល្លញ្ច ភយញ្ច មេតំ
ឯតំ ភយំ កាមគុណេសុ ទិស្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
សីតញ្ច ឧណ្ហញ្ច ខុទំ បិបាសំ
វាតាតបេ ឌំសសរីសបេ ច
សព្វានិបេតានិ អភិសម្ភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
នាគោវ យូថានិ វិវជ្ជយិត្វា
សញ្ជាតខន្ធោ បទុមី ឧឡារោ
យថាភិរន្តំ វិហរំ(១) អរញ្ញេ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---
១ ឱ. វិហរេ ។

ដោយសភាព ដ៏ប្លែក ៗ បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

ចង្រៃ បូស ឧបទ្រព រោគ កិលេស ដូចសរ នឹងភ័យទាំងនុ៎ះ រមែងមានដល់យើង (ព្រោះកាម) បុគ្គលកាលបើឃើញភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលគ្របសង្កត់ នូវសត្វ ទាំងអស់នុ៎ះ គឺត្រជាក់ ក្តៅ ឃ្លាន ស្រេក ខ្យល់ នឹងកំដៅថ្ងៃ របោមនឹងពស់ហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

ដំរី មានខ្លួនសមម្យេ មាំមួន មានសម្បុរ ដូចផ្កាឈូក កាលលះបង់ នូវហ្វូង ហើយនៅក្នុងព្រៃ គួរដល់អធ្យាស្រ័យ យ៉ាងណា បុគ្គលគប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស (យ៉ាងនោះ) ។

សុត្តនិបាតេ ឧរគវគ្គស្ស តតិយំ ខគ្គវិសាណសុត្តំ

អដ្ឋាន តំ សង្គណិការតស្ស
យំ ផុស្សយេ សាមយិកំ វិមុត្តឹ
អាទិច្ចពន្ធុស្ស វចោ និសម្ម
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ទិដ្ឋីវិសូកានិ ឧបាតិវត្តោ
បត្តោ និយាមំ បដិលទ្ធមគ្គោ
ឧប្បន្នញាណោម្ហិ អនញ្ញនេយ្យោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

និល្លោលុបោ និក្កុហោ និប្បិបាសោ
និម្មក្ខោ និទ្ធន្តកសាវមោហោ
និរាសយោ(១) សព្វលោកេ ភវិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

បាបំ សហាយំ បរិវជ្ជយេថ

១ អដ្ឋកថាយំ និរាសំសោតិ ទិស្សតិ ។ និរាសំសោតិ និគ្គហេក្កា ។

បុគ្គលបាននូវវិមុត្តិ ប្រព្រឹត្តទៅ ក្នុងសម័យ គឺលោកិយសមាបត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរ ក្នុងពួកទេ បុគ្គល ពិចារណាពាក្យ របស់ព្រះពុទ្ធ ជាព្រះអាទិច្ចពន្ធុហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលកន្លង នូវទិដ្ឋិអាក្រក់ ដល់នូវធម៌ទៀង មានមគ្គបានហើយ មិនបាច់មានអ្នកដទៃ ដឹកនាំ ព្រោះដឹងថា អាត្មាអញ មានញាណ កើតហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល មិនជាប់ចិត្ត ក្នុងអាហារ មិនកុហក មិនមានសេចក្ដីស្រេកឃ្លាន ជាអ្នកមិនលុបគុណគេ កំចាត់បង់មោហៈ ដូចជាទឹកបត់ចេញបាន មិនមានទីអាស្រ័យ (គឺកិលេស) ក្នុងលោកទាំងមូល គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលគប្បីវៀរ នូវសំឡាញ់ ដ៏អាក្រក់

អនត្ថទស្សិំ វិសមេ និវិដ្ឋំ
សយំ ន សេវេ បសុតំ បមត្តំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ពហុស្សុតំ ធម្មធរំ ភជេថ
មិត្តំ ឧឡារំ បដិភាណវន្តំ
អញ្ញាយ អត្ថានិ វិនេយ្យ កង្ខំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ខិឌ្ឌំ រតឹ កាមសុខញ្ច លោកេ
អនលង្ករិត្វា អនបេក្ខមានោ
វិភូសនដ្ឋានា វិរតោ សច្ចវាទី
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ដែលបញ្ញា នូវអំពើមិនជាប្រយោជន៍ អាស្រ័យនៅក្នុងកម្មមិនស្មើ (គឺទុច្ចរិត) មិនគប្បីសេពគប់នូវសំឡាញ់ ដែលជាប់ចំពាក់ ដែលស្រវឹង (ក្នុងកាមគុណ) ដោយខ្លួនឯង គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលគប្បីគប់រក នូវមិត្តជាពហុស្សូត ទ្រទ្រង់នូវធម៌ប្រកបដោយកម្ម ដ៏ថ្លៃថ្នូរ មានប្រាជ្ញាវាងវៃ លុះដឹងច្បាស់ នូវប្រយោជន៍ ទាំងឡាយហើយ គប្បីបន្ទោបង់ នូវសេចក្តីសង្ស័យចេញត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល មិនតាក់តែង នូវការលេងផង ការត្រេកអរផង កាមសុខផង ក្នុងលោក មិនអាឡោះអាល័យ វៀរចាកទីជាទីស្អិតស្អាង អ្នកពោលពាក្យពិត គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុត្តញ្ច ទារំ បិតរញ្ច មាតរំ
ធនានិ ធញ្ញានិ ច ពន្ធវានិ
ហិត្វាន កាមានិ យថោធិកានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

សង្គោ ឯសោ បរិត្តមេត្ថ សោខ្យំ
អប្បស្សាទោ ទុក្ខមេត្ថ ភិយ្យោ
គណ្ឌោ ឯសោ ឥតិ ញត្វា មតិមា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

សន្ទាលយិត្វាន(១) សំយោជនានិ
ជាលំ វ ភេត្វា សលិលម្ពុចារី
អគ្គីវ ទឌ្ឍំ អនិវត្តមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

---

១ ម. បទាលយិត្វាន ។

បុគ្គលលះបង់កូនផង ប្រពន្ធផង បិតាផង មាតាផង ទ្រព្យទាំងឡាយផង ស្រូវទាំងឡាយផង ផៅពង្សទាំងឡាយផង កាមទាំងឡាយតាមចំណែករៀងខ្លួនផង គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

កាមគុណនេះ ជាគ្រឿងជាប់ចំពាក់ សុខក្នុងកាមគុណនេះ មានប្រមាណតិច កាមគុណមានសេចក្តីត្រេកអរតិច ទុក្ខក្នុងកាមគុណនេះច្រើនក្រៃលែង បុគ្គលអ្នកមានបញ្ញា ដឹងច្បាស់ថាការជាប់ចំពាក់ ក្នុងកាមគុណនុ៎ះ ដូចជាបូស គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលទំលាយ នូវសំយោជនៈ ដូចត្រីក្នុងទឹក ទំលាយបង់ នូវបណ្តាញ មិនត្រឡប់មក (រកសំយោជនៈ) វិញ ដូចជាភ្លើងឆេះ ( មិនត្រឡប់វិលវិញ ) គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

ឱក្ខិត្តចក្ខុ ន ច បាទលោលោ
គុត្តិន្ទ្រិយោ រក្ខិតមានសានោ
អនវស្សុតោ អបរិឌយ្ហមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
ឱហារយិត្វា គិហិព្យញ្ជនានិ
សញ្ឆិន្នបត្តោ(១) យថា បារិឆត្តោ
កាសាយវត្ថោ អភិនិក្ខមិត្វា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
រសេសុ គេធំ អករំ អលោលោ
អនញ្ញបោសី សបទានចារី
កុលេ កុលេ អប្បដិពទ្ធចិត្តោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
បហាយ បញ្ចាវរណានិ ចេតសោ
ឧបក្កិលេសេ ព្យបនុជ្ជ សព្វេ

១ ម. បច្ឆិន្នបត្តោ ។

បុគ្គលមានចក្ខុដាក់ចុះ មានជើង មិនរពឹស (១) មានឥន្ទ្រិយគ្រប់គ្រងល្អ មានចិត្តរក្សាទុក មិនជោកជាំ មិនពេលពល (ដោយកិលេស) គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលលះបង់ នូវវត្ថុជាគ្រឿងប្រាកដ នូវភាពជាគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស មានស្លឹកជ្រុះហើយ គប្បីជាអ្នកមានសំពត់កាសាយៈ ចេញបួស ត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលមិនធ្វើសេចក្តីប្រាថ្នា ក្នុងរសទាំងឡាយ ជាអ្នកមិនល្មោភ (ក្នុងអាហារ) មិនចិញ្ចឹមអ្នកដទៃ ជាអ្នកត្រាច់ទៅតាមច្រក មិនមានចិត្តជាប់ចំពាក់ ក្នុងត្រកូលផ្សេង ៗ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលលះបង់ នូវនីវរណៈទាំង ៥ បន្ទោបង់ នូវឧបក្កិលេស នៃចិត្តទាំងអស់ចេញបាន

១ សំដៅយកការមិនដើរលេង ។ អដ្ឋកថា ។

អនិស្សិតោ ឆេត្វា សិនេហទោសំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
វិបិដ្ឋិកត្វាន សុខំ ទុក្ខញ្ច
បុព្វេវ ច សោមនស្សទោមនស្សំ
លទ្ធានុបេក្ខំ សមថំ វិសុទ្ធំ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
អារទ្ធវីរិយោ បរមត្ថបត្តិយា
អលីនចិត្តោ អកុសីតវុត្តិ
ទឡ្ហនិក្កមោ ថាមពលូបបន្នោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។
បដិសល្លានំ ឈានមរិញ្ចមានោ
ធម្មេសុ និច្ចំ អនុធម្មចារី
អាទីនវំ សម្មសិតា ភវេសុ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ជាអ្នកមិនអាស្រ័យ (ដោយតណ្ហា) កាត់បង់ នូវទោស ដែលកើត អំពីសេចក្តីស្រឡាញ់ហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលបានធ្វើនូវសុខទុក្ខនិងសោមនស្ស ទោមនស្ស ក្នុងកាលមុន ឲ្យនៅពីក្រោយខ្នងហើយ បាននូវឧបេក្ខាសមថ (ក្នុងចតុត្ថជ្ឈាន) ដ៏បរិសុទ្ធហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលមានសេចក្តីព្យាយាមប្រារព្ធ ដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរា អ្នកប្រព្រឹត្ត មិនខ្ជិលច្រអូស មានសេចក្តីប្រឹងប្រែងដ៏មាំ ប្រកបដោយកម្លាំងប្រាជ្ញាហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គល មិនលះបង់នូវឈាន ជាធម្មជាតស្ងប់ស្ងាត់ (ចាកសត្វនិងសង្ខារ) ជាអ្នកប្រព្រឹត្តធម៌ដ៏សមគួរ ក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ពិចារណាឃើញទោស ក្នុងភពទាំងឡាយហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

តណ្ហក្ខយំ បត្ថយំ អប្បមត្តោ
អនេឡមូគោ សុតវា សតីមា
សង្ខាតធម្មោ និយតោ បធានវា
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

សីហោវ សទ្ទេសុ អសន្តសន្តោ
វាតោវ ជាលម្ហិ អសជ្ជមានោ
បទុមំវ តោយេន អលិប្បមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

សីហោ យថា ទាឋពលី បសយ្ហ
រាជា មិគានំ អភិភុយ្យចារី
សេវេថ បន្តានិ សេនាសនានិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

បុគ្គលកាលប្រាថ្នា នូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនឆ្កួត មិនគ ជាអ្នកមានការចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាបុគ្គលទៀង មានសេចក្ដីព្យាយាម គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលមិនតក់ស្លុត (ក្នុងលក្ខណៈ មានមិនទៀងជាដើម) ដូចសីហៈ មិនតក់ស្លុតនឹងសំឡេងទាំងឡាយ មិនបានជាប់ជំពាក់ (ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម) ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនជាប់ (ដោយតណ្ហានឹងលោភៈ) ដូចឈូកមិនទទឹកដោយទឹក គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលគប្បីអាស្រ័យ នូវសេនាសនៈ ដ៏ស្ងាត់ ដូចជាសីហៈ ជាស្ដេចសត្វ មានកំលាំងចង្កូម ត្រាច់ គ្របសង្កត់ កំហែង នូវពួកម្រឹគ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

## សុត្តនិបាតេ ឧរគវគ្គស្ស តតិយំ ខគ្គវិសាណសុត្តំ

មេត្តំ ឧបេក្ខំ ករុណំ វិមុត្តិំ
អាសេវមានោ មុទិតញ្ច កាលេ
សព្វេន លោកេន អវិរុជ្ឈមានោ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

រាគញ្ច ទោសញ្ច បហាយ មោហំ
សន្ទាលយិត្វាន សំយោជនានិ
អសន្តសំ ជីវិតសង្ខយម្ហិ
ឯកោ ចរេ ខគ្គវិសាណកប្បោ ។

ភជន្តិ សេវន្តិ ច ការណត្ថា
និក្ការណា ទុល្លភា អជ្ជ មិត្តា
អត្តដ្ឋបញ្ញា អសុចី មនុស្សា
ឯកោ ចរេ ខគ្គវិសាណកប្បោ (១) ។

ខគ្គវិសាណសុត្តំ តតិយំ ។

---

១ ឱ. ឥតិសវគ្គោ នត្ថិ ។

បុគ្គលកាលចំរើនមេត្តាផង ឧបេក្ខាផង ករុណាផង មុទិតាផង ដែលជាហេតុរួចស្រឡះ (ចាកកិលេស) ក្នុងកាលគួរ មិនថ្នាំងថ្នាក់ចំពោះសត្វលោកទាំងអស់ហើយ គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលលះបង់រាគៈផង ទោសៈផង មោហៈផង ទំលាយនូវសំយោជនៈទាំងឡាយ មិនតក់ស្លុតក្នុងការក្ស័យជីវិត គប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

ពួកមនុស្សមានប្រយោជន៍ជាហេតុ ទើបគប់រកផង បំរើផង ពួកមិត្តសំឡាញ់ទាំងឡាយ ដែលឥតហេតុ រកបានដោយក្រ ក្នុងថ្ងៃនេះ ពួកមនុស្ស (ច្រើនតែ) មានប្រាជ្ញាចំពោះប្រយោជន៍ របស់ខ្លួន ជាអ្នកប្រកបដោយអំពើមិនស្អាត បុគ្គលគប្បីត្រាច់ទៅ តែម្នាក់ឯង ដូចកុយរមាស ។

ចប់ ខគ្គវិសាណសូត្រ ទី ៣ ។

# ចតុត្ថំ កសិភារទ្វាជសុត្តំ

(៤) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មគធេសុ វិហរតិ ទក្ខិណាគិរិស្មឹ ឯកនាឡាយំ ព្រាហ្មណគាមេ ។ តេន ខោ បន សមយេន កសិភារទ្វាជស្ស ព្រាហ្មណស្ស បញ្ចមត្តានិ នង្គ-លសតានិ បយុត្តានិ ហោន្តិ វប្បកាលេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរ-មាទាយ យេន កសិភារទ្វាជស្ស ព្រាហ្មណស្ស កម្មន្តោ តេនុបសង្កមិ ។ តេន ខោ បន សម-យេន កសិភារទ្វាជស្ស ព្រាហ្មណស្ស បរិវេសនា វត្តតិ ។ អថខោ ភគវា យេន បរិវេសនា តេនុ-បសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ អទ្ទសា ខោ កសិភារទ្វាជោ ព្រាហ្មណោ ភគវន្តំ បិណ្ឌាយ ឋិតំ ទិស្វាន ភគវន្តំ ឯតទវោច អហំ ខោ សមណ កសាមិ ច វប្បាមិ ច កសិត្វា ច វបិត្វា ច ភុញ្ជាមិ ។ ត្វម្បិ សមណ កសស្សុ ច វប្បស្សុ ច កសិត្វា ច វបិត្វា ច ភុញ្ជាហីតិ ។

# កសិភារទ្វាជសូត្រ ទី ៤

(៤) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងទក្ខិណាគិរិមហាវិហារ ( អាស្រ័យ ) ក្នុងស្រុកព្រាហ្មណ៍ឈ្មោះ ឯកនាឡា ក្នុងដែនមគធៈ ។ សម័យនោះឯង កសិភារទ្វាជព្រាហ្មណ៍ មាននង្គ័លចំនួន ៥០០ ប្រកបក្នុងកាលសាបព្រោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់យាងសំដៅទៅ ត្រង់កន្លែងការងារ របស់កសិភារទ្វាជព្រាហ្មណ៍ ។ សម័យនោះឯង ការអង្គាសបាយ របស់កសិភារទ្វាជព្រាហ្មណ៍ ក៏កំពុងប្រព្រឹត្តទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ឈៀងចូលទៅកាន់ទីអង្គាសបាយ (របស់កសិភារទ្វាជព្រាហ្មណ៍) លុះចូលទៅដល់ហើយ ក៏ទ្រង់ឈរនៅក្នុងទីដ៏សមគួរ ។ កសិភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគ កំពុងទ្រង់ឈរនៅ ដើម្បីបិណ្ឌបាតហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះសមណៈ ខ្ញុំព្រះអង្គ ភ្ជួររាស់ផង សាបព្រោះផង លុះភ្ជួររាស់សាបព្រោះហើយ ទើបបរិភោគ ។ បពិត្រព្រះសមណៈ ចំណែកព្រះអង្គ ចូរភ្ជួររាស់សាបព្រោះ លុះព្រះអង្គភ្ជួររាស់សាបព្រោះហើយ ចូរបរិភោគចុះ ។

អហម្បិ ខោ ព្រាហ្មណ កសាមិ ច វបាមិ ច កសិត្វា ច វបិត្វា ច ភុញ្ជាមីតិ ។ ន ខោ បន សមណ បស្សាម(១) ភោតោ គោតមស្ស យុគំ វា នង្គលំ វា ផាលំ វា បាចនំ(២) វា ពលិពទ្ទេ វា អថ ច បន ភវំ គោតមោ ឯវមាហ អហម្បិ ខោ ព្រាហ្មណ កសាមិ ច វបាមិ ច កសិត្វា ច វបិត្វា ច ភុញ្ជាមីតិ ។ អថខោ កសិភារទ្វាជោ ព្រាហ្មណោ ភគវន្តំ គាថាយ អជ្ឈភាសិ

(៤) កស្សកោ បដិជានាសិ ន ច បស្សាម តេ កសឹ
កសឹ នោ បុច្ឆិតោ ព្រូហិ យថា ជានេមុ តេ កសឹ ។
សទ្ធា ពីជំ តបោ វុដ្ឋិ បញ្ញា មេ យុគនង្គលំ

---

១. ឱ. ម. ៥ ខោ បន មយំ បស្សាម ។ ២ ម. បាជនំ ។

ម្នាលព្រាហ្មណ៍ តថាគតក៏ភ្ជួររាស់ផង សាបព្រោះផង លុះតថាគតភ្ជួររាស់ សាបព្រោះហើយ ទើបបរិភោគដែរ ។ បពិត្រព្រះសមណៈ យើងខ្ញុំ មិនបានឃើញនឹមក្តី នង្គ័លក្តី ផាលក្តី ជន្លួញក្តី សត្វបំរើក្តី របស់ព្រះគោតម ដ៏ចំរើននោះ ប៉ុន្តែហេតុអ្វីបានជាព្រះគោតមដ៏ចំរើននិយាយយ៉ាងនេះថា ម្នាលព្រាហ្មណ៍ តថាគតភ្ជួររាស់ផង សាបព្រោះផង លុះភ្ជួររាស់សាបព្រោះហើយ ទើបបរិភោគដែរ ។

លំដាប់នោះ កសិភារទ្វាជព្រាហ្មណ៍ បានពោលចំពោះព្រះមានព្រះភាគដោយគាថាដូច្នេះថា

(៤) ព្រះអង្គប្តេជ្ញាថា ជាអ្នកភ្ជួររាស់ ប៉ុន្តែយើង
មិនឃើញ នូវការភ្ជួររាស់ របស់ព្រះអង្គនោះ
យើងសួរ នូវការភ្ជួររាស់ សូមព្រះអង្គប្រាប់ឲ្យ
យើងដឹង នូវការភ្ជួររាស់ របស់ព្រះអង្គ ។

(ព្រះអង្គត្រាស់ថា) តថាគត មានសទ្ធា ជាពូជ មាន
តបធម៌ (១) ជាភ្លៀង មានប្រាជ្ញា ជានឹមនឹងនង្គ័ល

---

១ ពាក្យថា តបធម៌ ក្នុងទីនេះ សំដៅយកសេចក្តីព្យាយាមយ៉ាងឧក្រិដ្ឋ ដោយការសង្រួមឥន្ទ្រិយនិងការកាន់ធុតង្គវត្ត ។ អដ្ឋកថា ។

ហិរី ឦសា មនោ យោត្តំ សតិ មេ ផាលបាចនំ ។
កាយគុត្តោ វចីគុត្តោ អាហារេ ឧទរេ យតោ
សច្ចំ ករោមិ និទ្ទានំ សោរច្ចំ មេ បមោចនំ ។
វីរិយំ មេ ធុរធោរយ្ហំ យោគក្ខេមាធិវាហនំ
គច្ឆតិ អនិវត្តន្តំ(១) យត្ថ គន្ត្វា ន សោចតិ ។
ឯវមេសា(២) កសី កដ្ឋា សា ហោតិ អមតប្ផលា
ឯតំ កសឹ កសិត្វាន សព្វទុក្ខា បមុច្ចតីតិ(៣) ។

(៦) អថខោ កសិភារទ្វាជោ ព្រាហ្មណោ មហតិយា កំសបាតិយា បាយាសំ វឌ្ឍេត្វា ភគវតោ ឧបនាមេសិ ភុញ្ជតុ ភវំ គោតមោ បាយាសំ កស្សកោ ភវំ យញ្ហិ ភវំ គោតមោ អមតប្ផលំ កសឹ កសតីតិ ។

១ ម. អនិវត្តន្តំ ។ ២ អដ្ឋ. ឯវមេសាតិ ទិស្សតិ ។ ៣ ឱ.ម. បមុច្ចតីតិ ។

តថាគត មានហិរិ ជាបង្គោល មានចិត្ត ជាខ្សែ មាន
សតិ ជាផាលនឹងជន្លួញ ។ តថាគត គ្រប់គ្រង
កាយ គ្រប់គ្រងវាចា សង្រួមនូវអាហារក្នុងផ្ទៃ ធ្វើនូវ
ការដម្រះ (នូវស្មៅគឺកិលេស) ដោយសច្ចៈ តថាគត
មានការស្ងប់ស្ងៀម ជាគ្រឿងឈប់សម្រាក ។
វីរិយៈរបស់តថាគត ជាគ្រឿងនាំទៅ នូវធុរៈជាហេតុ
នាំឲ្យបាន នូវព្រះនិព្វានដ៏ក្សេមចាកយោគៈ ទៅកាន់
ទីដែលគេទៅមិនសោកសៅ ជាទីដែលគេមិនត្រឡប់
វិញ ។ ការភ្ជួររាស់ដែលតថាគត ភ្ជួររាស់ហើយយ៉ាង
នេះ ជាគុណជាតិមានផល មិនចេះស្លាប់ទេ បុគ្គល
ធ្វើនូវការភ្ជួររាស់បែបនេះ ទើបរួចចាកទុក្ខទាំងពួង ។

(៦) គ្រានោះឯង កសិភារទ្វាជព្រាហ្មណ៍ ក៏ដោះបាយដាក់ក្នុង
ភាជន៍សំរិត(១) ដ៏ធំ បង្អោនចូលទៅថ្វាយព្រះមានព្រះភាគថា សូមព្រះ
គោតមដ៏ចំរើន សោយបាយាសចុះ ព្រះគោតមដ៏ចំរើន ក៏ជាអ្នកភ្ជួររាស់
ព្រោះថា ព្រះគោតមដ៏ចំរើន រមែងភ្ជួររាស់ចំពោះការភ្ជួររាស់ ដែល
មានផលមិនចេះស្លាប់ ។

---

១ ភាជន៍មាស ថ្លៃ ១ សែនកហាបណៈ ។ អដ្ឋកថា ។

គាថាភិគីតម្មេ អភោជនេយ្យំ

សម្បស្សតំ ព្រាហ្មណ នេស ធម្មោ

គាថាភិគីតំ បនុទន្តិ ពុទ្ធា

ធម្មេ សតី ព្រាហ្មណ វុត្តិរេសា ។

អញ្ញេន ច កេវលិនំ មហេសឹ

ខីណាសវំ កុក្កុច្ចវូបសន្តំ

អន្នេន បានេន ឧបដ្ឋហស្សុ

ខេត្តញ្ហិ តំ បុញ្ញបេក្ខស្ស ហោតីតិ ។

(៧) អថ កស្ស ចាហំ ភោ គោតម ឥមំ បាយាសំ ទម្មីតិ ។ ន ខ្វាហំ តំ ព្រាហ្មណ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យេន(១) សោ បាយាសោ ភុត្តោ សម្មា បរិណាមំ គច្ឆេយ្យ អញ្ញត្រ តថាគតស្ស វា តថាគតសាវកស្ស វា

---

១ ឱ.ម. យស្ស ។

ភោជនដែលតថាគតពោលហើយ ដោយគាថា
ជាវត្ថុមិនគួរ ដល់ការបរិភោគទេ ម្នាលព្រាហ្មណ៍
នេះមិនមែនជាទំនៀម របស់ពួកជនអ្នកឃើញច្បាស់
(នូវអាជីវបារិសុទ្ធិ)ទេ ព្រះពុទ្ធទាំងឡាយតែងបន្ទោបង់
នូវភោជន ដែលពោលហើយ ដោយគាថា ម្នាល
ព្រាហ្មណ៍ កាលបើធម៌មាននៅ ការស្វែងរកនេះ ជា
ការប្រព្រឹត្តចិញ្ចឹមជីវិត ។ អ្នកចូរផ្គត់ផ្គង់ ចំពោះលោក
អ្នកស្វែងរកនូវគុណធំ បរិបូណ៌ដោយគុណ សព្វគ្រប់
មានអាសវៈអស់ហើយ ស្ងប់រម្ងាប់ចាកកុក្កុច្ចៈ ដោយ
វត្ថុដទៃទឹងបាយទឹកផងចុះ ព្រោះថា ការផ្គត់ផ្គង់នោះ
ជាបុញ្ញក្ខេត្ត របស់បុគ្គលអ្នកប្រាថ្នាបុណ្យ ។

(៧) បពិត្រព្រះគោតមដ៏ចំរើន បើដូច្នេះ តើខ្ញុំព្រះអង្គឲ្យ
នូវបាយាសនេះ ដល់បុគ្គលណាវិញ ។ ម្នាលព្រាហ្មណ៍ តថាគតមិន
ឃើញបុគ្គលដែលបរិភោគបាយាស ដល់នូវការសុះឡោយល្អ ក្នុង
លោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ
ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្ស
ដ៏សេសទេ វៀរលែងតែតថាគត ឬសាវ័ក នៃតថាគតចេញ

តេនហិ ត្វំ ព្រាហ្មណ តំ បាយាសំ អប្បហរិតេ វា ឆឌ្ឌេហិ អប្បាណកេ វា ឧទកេ ឱបិលាបេហីតិ ។ អថខោ កសិភារទ្វាជោ ព្រាហ្មណោ តំ បាយាសំ អប្បាណកេ ឧទកេ ឱបិលាបេសិ ។ អថខោ សោ បាយាសោ ឧទកេ បក្ខិត្តោ ចិច្ចិដាយតិ ចិដិចិដាយតិ(១) សន្ធូមាយតិ សម្បធូមាយតិ(២) ។ សេយ្យថាបិ នាម អយោគុឡោ(៣) ទិវសសន្តត្តោ ឧទកេ បក្ខិត្តោ ចិច្ចិដាយតិ ចិដិចិដាយតិ សន្ធូមាយតិ សម្បធូមាយតិ ឯវមេវ សោ បាយាសោ ឧទកេ បក្ខិត្តោ ចិច្ចិដាយតិ ចិដិចិដាយតិ សន្ធូមាយតិ សម្បធូមាយតិ ។

(៨) អថខោ កសិភារទ្វាជោ ព្រាហ្មណោ សំវិគ្គោ លោមហដ្ឋជាតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។

---

១ ម. បិដបិដាយតិ ។ ២ ខ. សន្ធូបាយតិ សម្បធូបាយតិ ។ ម. សន្ទូបាយតិ សម្បធូបាយតិ ។ ៣ ខ.ម. ផាលោ

ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរចាក់បាយាសនោះ ក្នុងទីដែលគ្មានរុក្ខស្រស់ ឬ ទម្លាក់ទៅក្នុងទឹក ដែលគ្មានសត្វទៅចុះ ។ គ្រានោះឯង កសិភារទ្វាជព្រាហ្មណ៍ ក៏ទម្លាក់បាយាសនោះ ទៅក្នុងទឹកដែលគ្មានសត្វ ។ លំដាប់នោះបាយាសនោះដែលព្រាហ្មណ៍ទម្លាក់ចុះទៅក្នុងទឹកហើយ ក៏ឮសំឡេងឆ្ងុរ ៗ ឮសំឡេងឆាវ ៗ ហុយផ្សែងទ្រុប ហុយផ្សែងទ្រលោម ៗ ដុំដែកដែលឆេះក្តៅ អស់មួយថ្ងៃ ដែលគេដាក់ចុះក្នុងទឹក រមែងឮសំឡេងឆ្ងុរ ៗ ឮសំឡេងឆាវ ៗ ហុយផ្សែងទ្រុប ហុយផ្សែងទ្រលោម យ៉ាងណាមិញ បាយាសដែលព្រាហ្មណ៍ ទម្លាក់ទៅក្នុងទឹក ក៏ឮសំឡេងឆ្ងុរ ៗ ឮសំឡេងឆាវ ៗ ហុយផ្សែងទ្រុប ហុយផ្សែងទ្រលោម ក៏យ៉ាងនោះដែរ ។

(៨) គ្រានោះឯង កសិភារទ្វាជព្រាហ្មណ៍ មានចិត្តតក់ស្លុតព្រឺរោម ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបសិរ្សៈទៀបព្រះបាទព្រះមានព្រះភាគ សរសើរព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ ។

សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ
បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ
អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ
រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេ-
កបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ
ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច
ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ
ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។
លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ
លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ កសិភា-
រទ្វាជោ ព្រាហ្មណោ ភគវតោ សន្តិកេ បព្វជ្ជំ
អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ
បនាយស្មា ភារទ្វាជោ ឯកោ វូបកដ្ឋោ អប្បមត្តោ
អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ
កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ

បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើន ទ្រង់ប្រកាសដោយអនេកបរិយាយ យ៉ាងនេះ ( ក្តីច្បាស់ណាស់ ) ដូចមនុស្សផ្ងាររបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ដូចគេប្រាប់នូវផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុទាំងឡាយ ឃើញនូវរូបទាំងឡាយបាន ។ ខ្ញុំព្រះអង្គនុ៎ះ សូមដល់ព្រះគោតមមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផងជាសរណៈ សូមព្រះគោតមដ៏ចំរើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។ ខ្ញុំព្រះអង្គ គប្បីបាននូវបព្វជ្ជា គប្បីបាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះគោតមដ៏ចំរើន ។ កសិភារទ្វាជព្រាហ្មណ៍ ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ លុះព្រះភារទ្វាជៈដ៏មានអាយុ បានឧបសម្បទាមិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង មិនធ្វេសប្រហែស មានសេចក្តីព្យាយាម មានចិត្តស្ងប់ទៅកាន់ព្រះនិព្វាន ពួកកុលបុត្ត ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដោយប្រពៃ

តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា ភារទ្វាជោ អរហតំ អហោសីតិ ។

កសិភារទ្វាជសុត្តំ ចតុត្ថំ ។

ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះដ៏ជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងអត្តភាពនេះ បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះភារទ្វាជដ៏មានអាយុ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។

ចប់ កសិភារទ្វាជសូត្រ ទី ៤ ។

## បញ្ចមំ ចុន្ទសុត្តំ

(៥) បុច្ឆាមិ មុនឹ បហូតបញ្ញំ (ឥតិ ចុន្ទោ កម្មារបុត្តោ)

ពុទ្ធំ ធម្មស្សាមឹ វីតតណ្ហំ

ទិបទុត្តមំ សារថីនំ បវរំ

កតិ លោកេ សមណា តទិង្ឃ ព្រូហិ ។

ចតុរោ សមណា ន បញ្ចមត្ថិ (ចុន្ទាតិ ភគវា)

តេ តេ អាវិករោមិ សក្ខិបុដ្ឋោ

មគ្គជិនោ មគ្គទេសកោ ច

មគ្គេ ជីវតិ យោ ច មគ្គទូសី ។

កំ មគ្គជិនំ វទន្តិ ពុទ្ធា (ឥតិ ចុន្ទោ កម្មារបុត្តោ)

មគ្គជ្ឈាយី(១) អតុល្យោ ហោតិ

---

១ ម. មគ្គក្ខាយី ។

# ចុន្ទសូត្រ ទី ៥

(៥) (ចុន្ទកម្មារបុត្ត ក្រាបទូលសួរព្រះមានព្រះភាគថា) ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ ជាអ្នកប្រាជ្ញ មានបញ្ញាច្រើន ជាព្រះពុទ្ធ ជាម្ចាស់នៃធម៌ ប្រាសចាកតណ្ហា ដ៏ឧត្តមជាទីសត្វដើរទៅ ប្រសើរជាងសារថីទាំងឡាយ តើពួកសមណៈ ក្នុងលោកនេះមានប៉ុន្មាន សូមព្រះអង្គសំដែងប្រាប់ នូវពួកសមណៈនោះឲ្យបាន ៗ

(ព្រះមានព្រះភាគ ត្រាស់ថា ម្នាលចុន្ទ) សមណៈមានត្រឹមតែ ៤ ពួក មិនមានដល់គំរប់ ៥ ទេ កាលបើអ្នកសួរបញ្ជាក់ហើយ តថាគត នឹងប្រាប់នូវសមណៈទាំងនោះ ដល់អ្នក គឺសមណៈ ឈ្នះកិលេសដោយមគ្គ ១ សមណៈ សំដែងប្រាប់ នូវមគ្គ ១ សមណៈរស់នៅក្នុងមគ្គ ១ សមណៈប្រទូស្តនូវមគ្គ ១ ៗ

(ចុន្ទកម្មារបុត្ត ទូលសួរថា) ព្រះពុទ្ធទាំងឡាយ តែងសំដែង នូវសមណៈណា ថាជាសមណៈ ឈ្នះកិលេសដោយមគ្គ សមពកៈ ដុតបំផ្លាញ នូវកិលេសដោយមគ្គ ជាបុគ្គលថ្លឹងមិនបាន

មគ្គេ ជីវតិ មេ ព្រូហា បុដ្ឋោ

អថ មេ អាវិករោហិ មគ្គទូសិំ ។

យោ តិណ្ណកថង្កថោ វិសល្លោ

និព្ពានាភិរតោ អនានុគិទ្ធោ

លោកស្ស សទេវកស្ស នេតា

តាទិំ មគ្គជិនំ វទន្តិ ពុទ្ធា ។

បរមំ បរមន្តិ យោធ ញត្វា

អក្ខាតិ វិភជតិ ឥធេវ ធម្មំ

តំ កង្ខច្ឆិទំ មុនិំ អនេជំ

ទុតិយំ ភិក្ខុនមាហុ មគ្គទេសិំ ។

យោ ធម្មបទេ សុទេសិតេ

មគ្គេ ជីវតិ សញ្ញតោ សតីមា

អនវជ្ជបទានិ សេវមានោ

រស់នៅក្នុងមគ្គ ខ្ញុំសួរហើយ សូមព្រះអង្គសំដែងប្រាប់ឲ្យបាន មួយទៀត សូមព្រះអង្គប្រាប់ នូវសមណៈអ្នកប្រទូស្តនូវមគ្គ ដល់ខ្ញុំព្រះអង្គ ។

(ព្រះមានព្រះភាគ ត្រាស់ថា) សមណៈណា កន្លងផុតនូវសេចក្តីសង្ស័យ ប្រាសចាកសរគឺកិលេស ត្រេកអរក្នុងព្រះនិព្វាន មិនជាប់ចំពាក់ដោយតណ្ហា ជាអ្នកណែនាំសត្វលោក ព្រមទាំងទេវលោក ព្រះពុទ្ធទាំងឡាយសំដែង នូវសមណៈបែបនោះ ថាជាអ្នកឈ្នះកិលេសដោយមគ្គ ។ សមណៈណា ក្នុងសាសនានេះ ដឹងនូវព្រះនិព្វាន ថាជាគុណជាត ឧត្តមក្រៃលែង ហើយសំដែងបែក នូវនិព្វានធម៌ ក្នុងលោកនេះ អ្នកប្រាជ្ញទាំងឡាយ ហៅសមណៈ ដែលជាអ្នកកាត់បង់ នូវសេចក្តីសង្ស័យ ជាអ្នកប្រាជ្ញមិនមានសេចក្តីញាប់ញ័រនោះថាជាអ្នកសំដែងប្រាប់មគ្គ ជាសមណៈ ទី ២ នៃភិក្ខុទាំងឡាយ ។ សមណៈណា មានស្មារតីសង្រួមហើយសេពនូវគន្លង មិនមានទោស រស់នៅក្នុងមគ្គ ជាផ្លូវនៃធម៌គឺព្រះនិព្វាន ដែលព្រះពុទ្ធ សំដែងប្រពៃហើយ

តតិយំ ភិក្ខុនមាហុ មគ្គជីវិំ ។

ឆទនំ កត្វាន សុព្វតានំ

បក្ខន្ទី កុលទូសកោ បគព្ភោ

មាយាវី អសញ្ញតោ បលាបោ

បតិរូបេន ចរំ ស មគ្គទូសី ។

ឯតេ ច បដិវិជ្ឈិ យោ គហដ្ឋោ

សុតវា អរិយសាវកោ សបញ្ញោ

សព្វេ នេតាទិសាតិ ញត្វា

ឥតិ ទិស្វា ន ហាបេតិ តស្ស សទ្ធា

កថញ្ហិ ទុដ្ឋេន អសម្បទុដ្ឋំ

សុទ្ធំ អសុទ្ធេន សមំ ករេយ្យាតិ ។

ចុន្ទសុត្តំ បញ្ចមំ ។

អ្នកប្រាជ្ញទាំងឡាយ ហៅសមណៈនោះ ថាជាអ្នករស់នៅក្នុងមគ្គ ជាសមណៈទី ៣ នៃភិក្ខុទាំងឡាយ ។ សមណៈណា ធ្វើខ្លួនគេ របស់ពួកអ្នកមានវត្តល្អ ឲ្យជាគ្រឿងបិទបាំង ជាអ្នកស្ទុះស្ទា អ្នកប្រទូស្តត្រកូល មានឫកពារឃ្មើសឃ្មង មានកលមាយា មិនសង្រួម ពោលពាក្យ (១) លេះលោះ ប្រព្រឹត្តបន្ទំ សមណៈនោះឈ្មោះថាជាអ្នកប្រទូស្តនូវមគ្គ ។ គ្រហស្ថណា ជាអ្នកចេះដឹង ជាអរិយសាវ័ក ប្រកបដោយប្រាជ្ញា ស្គាល់ច្បាស់នូវសមណៈទាំងនុ៎ះ សទ្ធារបស់គ្រហស្ថនោះរមែងមិនសាបសូន្យទេ ព្រោះដឹងថា ពួកសមណៈទាំងអស់មិនដូច្នោះទេ ព្រោះឃើញដូច្នេះ គប្បីប្រៀបនូវសមណៈ មិនអាក្រក់ ឲ្យស្មើដោយសមណៈអាក្រក់ ឬ គប្បីប្រៀបនូវសមណៈបរិសុទ្ធ ឲ្យស្មើដោយសមណៈមិនបរិសុទ្ធដូចម្ដេចកើត ។

ចប់ ចុន្ទសូត្រទី ៥ ។

---

១ បណោះបោព្រៃថាជាអ្នកប្រហែលនឹងសំដីត្រូវ, ព្រោះគ្មានសារៈខាងក្នុង ។ អដ្ឋកថា ។

# ឆដ្ឋំ បរាភវសុត្តំ

(១០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈ-ភាសិ ។

(១១) បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ
ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។
សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។

# បរាភវសូត្រ ទី ៦

(១០) ខ្ញុំបានស្ដាប់មកហើយនេះ ។ សម័យមួយ ព្រះមាន-ព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ទេវតា ១ អង្គ កាលដែលរាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាងហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតក្នុងទីសមគួរ ។ លុះទេវតានោះ ឋិតនៅ ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដោយគាថាដូច្នេះថា ។

(១១) យើងទាំងឡាយ មកដើម្បីសួរព្រះគោតម
ដ៏ចំរើន (ដោយគិតថា) យើងទាំងឡាយសូមសួរ
អំពីបុរសបុគ្គល ដែលមានសេចក្ដីវិនាស ចុះអ្វីជា
ប្រធាននៃសេចក្ដីវិនាស ។

(ព្រះមានព្រះភាគត្រាស់ថា) បុរសដែលចំរើន
ជាបុគ្គលគឺបណ្ឌិតដឹងបានដោយងាយ បុរសដែលវិនាស
ជាបុគ្គលគឺបណ្ឌិតដឹងបានដោយងាយដែរ បុគ្គលអ្នក
ប្រាថ្នាធម៌ រមែងចំរើន អ្នកស្អប់ធម៌ រមែងវិនាស ។

## សុត្តនិបាតេ ឧរគវគ្គស្ស ឆដ្ឋំ បរាភវសុត្តំ

ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ
ទុតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។
អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ
អសតំ ធម្ម រោចេតិ តំ បរាភវតោ មុខំ ។
ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ
តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។
និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ
អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។
ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ
ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។
យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្ដីវិនាសទី ១ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ២ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

បុគ្គលមានពួកអសប្បុរស ជាទីស្រឡាញ់ មិនធ្វើសេចក្ដីស្រឡាញ់ចំពោះពួកសប្បុរស ពេញចិត្តចំពោះធម៌របស់ពួកអសប្បុរស នោះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្ដីវិនាសទី ២ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែង នូវហេតុទី ៣ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

ជនអ្នកដេកលក់ច្រើនក្ដី និយាយច្រើនក្ដី មិនខ្មីឃ្មាតក្ដី ខ្ជិលច្រអូសក្ដី ប្រាកដតែខាងក្រោធក្ដី នោះជាប្រធាន នៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្ដីវិនាសទី ៣ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែង នូវហេតុទី ៤ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

បុគ្គលជាអ្នកស្ដុកស្ដម្ភ តែមិនចិញ្ចឹមមាតាក្ដី បិតាក្ដី ដែលចាស់មានវ័យកន្លងហើយ នោះជាប្រធាននៃសេចក្ដីវិនាស ។

ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ
បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។
យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វណិព្វកំ
មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។
ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ
ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។
បហូតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ
ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។
ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ
សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។
ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ
សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុះថា នោះជាសេចក្តីវិនាសទី ៤ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ៥ អ្វីជាប្រធាន នៃសេចក្តីវិនាស ។

បុគ្គលបញ្ឆោតព្រាហ្មណ៍ក្តី សមណៈក្តី ឬអ្នកសូមដទៃក្តី ដោយពាក្យកុហក នោះជាប្រធាននៃសេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់ នូវហេតុនុះថា នោះជាសេចក្តីវិនាសទី ៥ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែង នូវហេតុទី ៦ អ្វីជាប្រធាននៃសេចក្តីវិនាស ។

បុរសបុគ្គល មានទ្រព្យជាគ្រឿងត្រេកអរច្រើន មានប្រាក់ សម្បូណ៌ភោជន បរិភោគនូវភោជនមានរសឆ្ងាញ់តែម្នាក់ឯង នោះជាប្រធាននៃ សេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុះថា នោះជាសេចក្តីវិនាសទី ៦ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ៧ អ្វីជាប្រធាននៃសេចក្តីវិនាស ។

ជនដែលរឹងត្អឹង ដោយអាងជាតិក្តី រឹងត្អឹង ដោយអាងទ្រព្យក្តី រឹងត្អឹងដោយអាងគោត្រក្តី ហើយមើលងាយញាតិរបស់ខ្លួន នោះជាប្រធាននៃសេចក្តីវិនាស ។

### សុត្តនិបាតេ ឧរគវគ្គស្ស ឆដ្ឋំ បរាភវសុត្តំ

ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ

អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ

លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។

ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ

នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ

ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។

ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ

ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្ដីវិនាសទី ៧ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែង នូវហេតុទី ៨ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

ជនជាអ្នកលេងស្រីក្ដី លេងសុរាក្ដី លេងល្បែងភ្នាល់ក្ដី រមែងញុំាងទ្រព្យ ដែលខ្លួនបានហើយ បានហើយ ឲ្យវិនាសទៅ នោះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្ដីវិនាសទី ៨ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែង នូវហេតុទី ៩ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

ជនមិនត្រេកអរ នឹងប្រពន្ធរបស់ខ្លួនទៅខូច បំពោះពួកស្រីពេស្យា ឬខូច បំពោះប្រពន្ធ នៃបុគ្គលដទៃ នោះជាប្រធាននៃសេចក្ដីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់ នូវហេតុនុ៎ះថា នោះជាសេចក្ដីវិនាសទី ៩ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែង នូវហេតុទី ១០ អ្វីជាប្រធាននៃសេចក្ដីវិនាស ។

អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ

តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។

ឥតិ ហេតំ វិជានាម នវមោ សោ បរាភវោ

ទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

ឥត្ថីសោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ

ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ ។

ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ

ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ

សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។

បុរសមានវ័យកន្លងហើយ នាំយកស្ត្រី (ក្មេង) ដែលមានដោះក្បុំដូចជាផ្លែទន្លាប់ រមែងដេកមិនលក់ ព្រោះសេចក្តីប្រច័ណ្ឌចំពោះស្ត្រីនោះ នោះជាប្រធាននៃសេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី ១០ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ១១ អ្វីជាប្រធាននៃសេចក្តីវិនាស ។

បុរសបុគ្គល តាំងស្ត្រីអ្នកលេងខ្ជះខ្ជាយ ឬបុរសបែបនោះដែរ ក្នុងឋានៈជាធំ នោះជាប្រធាននៃសេចក្តីវិនាស ។

យើងទាំងឡាយ ដឹងច្បាស់នូវហេតុនុ៎ះថា នោះជាសេចក្តីវិនាសទី ១១ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែងនូវហេតុទី ១២ អ្វីជាប្រធាននៃសេចក្តីវិនាស ។

បុគ្គលដែលកើតក្នុងខត្តិយត្រកូល មានភោគៈតិច តែមានសេចក្តីប្រាថ្នាធំ តោ់ប្រាថ្នារជ្ជសម្បត្តិ នោះជាប្រធាននៃសេចក្តីវិនាស ។

ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ

អរិយោ ទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។

បរាភវសុត្តំ ឆដ្ឋំ ។

បុគ្គលជាបណ្ឌិត បរិបូណ៌ ដោយការឃើញដ៏ប្រសើរ ពិចារណាឃើញច្បាស់ នូវសេចក្ដីវិនាសទាំងនុ៎ះ ក្នុងលោក បណ្ឌិតនោះ រមែងគប់រកនូវលោក ដែលមានសេចក្ដីសុខដ៏ក្សេមក្សាន្ត (១) ។

ចប់ បរាភវសូត្រ ទី ៦ ។

---

១ បាលីថា សិវំ ក្នុងទីឯទៀត ៗ បានដល់ព្រះនិព្វាន តែក្នុងទីនេះ អដ្ឋកថាប្រាប់ថា បានដល់សេចក្ដីសុខក្សេមក្សាន្ត ក្នុងមនុស្សនិងទេវតា ។

# សត្តមំ វសលសុត្តំ

(១២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិ ។ តេន ខោ បន សមយេន អគ្គិកភារទ្វាជស្ស ព្រាហ្មណស្ស និវេសនេ អគ្គិ បជ្ជលិតោ ហោតិ អាហុតិ បគ្គហិតា ។ អថខោ ភគវា សាវត្ថិយំ សបទានំ បិណ្ឌាយ ចរមានោ យេន អគ្គិកភារទ្វាជស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ។ អទ្ទសា ខោ អគ្គិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច អត្រេវ មុណ្ឌក អត្រេវ សមណក អត្រេវ វសលក តិដ្ឋាហីតិ ។

ឯវំ វុត្តេ ភគវា អគ្គិកភារទ្វាជំ ព្រាហ្មណំ ឯតទវោច ជានាសិ បន ត្វំ ព្រាហ្មណ វសលំ វា វសលករណេ វា ធម្មេ ។

# វសលសូត្រ ទី ៧

(១៤) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ៗ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ យាងទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ សម័យនោះឯង អគ្គិកភារទ្វាជព្រាហ្មណ៍ (ព្រាហ្មណ៍ឈ្មោះភារទ្វាជៈ អ្នកបង្កាត់ភ្លើង) កំពុងបង្កាត់ភ្លើង ផ្គងគ្រឿងបូជាក្នុងលំនៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់ទៅកាន់លំដាប់ប្រក(ផ្ទះ) ដើម្បីបិណ្ឌបាត នឹងចូលទៅត្រង់លំនៅ របស់អគ្គិកភារទ្វាជព្រាហ្មណ៍ ។ អគ្គិកភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគ យាងមកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលទ្រគោះទៅរកព្រះមានព្រះភាគថា នែស្រមណ៍កំណោរ អ្នកចូរឈប់ក្នុងទីនេះសិន នែសមណៈ អ្នកចូរឈប់ក្នុងទីនេះសិន នែអ្នកជាថោកទាប អ្នកចូរឈប់ក្នុងទីនេះសិន ៗ

កាលដែលអគ្គិកភារទ្វាជព្រាហ្មណ៍ និយាយយ៉ាងនេះហើយ ព្រះមានព្រះភាគ ត្រាស់តបនឹងអគ្គិកភារទ្វាជព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ អ្នកស្គាល់បុគ្គលជាថោកទាប ឬធម៌ដែលធ្វើឲ្យជាថោកទាបដែរឬ ។

ន ខ្វាហំ ភោ គោតម ជានាមិ វសលំ វា វសលការណេ វា ធម្មេ សាធុ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថាហំ ជានេយ្យំ វសលំ វា វសលការណេ វា ធម្មេតិ ។ តេនហិ ព្រាហ្មណ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ អគ្គិកភារទ្វាជោ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច

(១៣) កោធនោ ឧបនាហី ច បាបមក្ខី ច យោ នរោ
វិបន្នទិដ្ឋិ មាយាវី តំ ជញ្ញា វសលោ ឥតិ ។
ឯកជំ វា ទ្វិជំ វា បិ យោធ បាណំ(១) វិហឹសតិ
យស្ស បាណេ ទយា នត្ថិ តំ ជញ្ញា វសលោ ឥតិ ។

១ ម. បាណានិ ហឹសតិ ។

បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំមិនទាន់ស្គាល់បុគ្គលថោកទាប ឬធម៌ដែលធ្វើឲ្យថោកទាបទេ សូមព្រះគោតមដ៏ចំរើន សំដែងធម៌ដែលជាហេតុឲ្យខ្ញុំ ស្គាល់បុគ្គលថោកទាប ឬធម៌ដែលធ្វើឲ្យថោកទាបផង ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយល្អចុះ តថាគតនឹងសំដែងប្រាប់ ។ អគ្គិកភារទ្វាជព្រាហ្មណ៍ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគសំដែងសេចក្តីនេះថា

(១៣) បុគ្គលណា មានសេចក្តីក្រោធ ចងសេចក្តី
ក្រោធទុក (គំនុំ) ជាបុគ្គលបាប លុបគុណគេ ប្រាស
ចាកសម្មាទិដ្ឋិ មានមាយា អ្នកចូរដឹងបុគ្គលនោះ ថា
ជាបុគ្គលថោកទាប ។

បុគ្គលណា ក្នុងលោកនេះ បៀតបៀនទូវសត្វ
ដែលមានកំណើតម្តង ឬមានកំណើតពីរដង(១) ឬ
បុគ្គលណា មិនមានសេចក្តីអាណិតចំពោះសត្វ អ្នក
ចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

---

១ សត្វមានកំណើតម្តងនោះ គឺសត្វដែលកើតពីញើសក្អែលអំពីទឹកក្រុកសម្ភុៈ នឹងឧបបាតិកៈ ។ សត្វមានកំណើតពីរដងនោះ គឺសត្វដែលកើតអំពីពង មានមាន់នឹងទាជាដើម ហៅថា អណ្ឌជៈ ។ អដ្ឋកថា ។

យោ ហន្តិ ឧបរុន្ធេតិ គាមានិ និគមានិ ច
និគ្គាហកោ សមញ្ញាតោ តំ ជញ្ញា វសលោ ឥតិ ។
គាមេ វា យទិ វារញ្ញេ យំ បរេសំ មមាយិតំ
ថេយ្យា អទិន្នំ អាទេតិ តំ ជញ្ញា វសលោ ឥតិ ។
យោ ហវេ ឥណមាទាយ ចុជ្ជមានោ បលាយតិ
ន ហិ តេ ឥណមត្ថីតិ តំ ជញ្ញា វសលោ ឥតិ ។
យោ វេ កិញ្ចិក្ខកម្យតា បន្ថស្មឹ វជន្តំ ជនំ
ហន្ត្វា(១) កិញ្ចិក្ខមាទេតិ តំ ជញ្ញា វសលោ ឥតិ ។
យោ អត្តហេតុ បរហេតុ ធនហេតុ ច យោ នរោ
សក្ខិបុដ្ឋោ មុសា ព្រូតិ(១) តំ ជញ្ញា វសលោ ឥតិ ។
យោ ញាតីនំ សខីនំ វា ទារេសុ បដិទិស្សតិ

---

១ ឱម. ហត្វា ។ ២ ម. ព្រូហិ ។

បុគ្គលណា សម្លាប់ ឬឡោម រឹបជាន់នូវអ្នកស្រុកឬ អ្នកនិគម ដែលអ្នកផង ដឹងច្បាស់ថា ជាអ្នកសង្កត់សង្កិនគេ អ្នកប្បីដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា គាស់យកទ្រព្យក្នុងស្រុក ឬក្នុងព្រៃដែល បុគ្គលប្រកាន់ ថាជារបស់អញ ជាទ្រព្យដែលគេមិនឲ្យ ដោយអាការលួច អ្នកប្បីដឹងបុគ្គលនោះ ថាជាបុគ្គល ថោកទាប ។

បុគ្គលណា បុលទ្រព្យគេ យកមកប្រើប្រាស់ ហើយ គេបកែថា (អញ) មិនបំពាក់បំណុលអ្នកទេ អ្នកប្បីដឹង បុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា សម្លាប់អ្នកផង ដែលដើរក្នុងផ្លូវ ដោយ ប្រាថ្នាទ្រព្យរបស់ណាមួយ ដណ្ដើមយកទ្រព្យរបស់ណា មួយ អ្នកប្បីដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា គេសួរជាបន្ទាល់និយាយកុហក ព្រោះ ហេតុនៃខ្លួនក្ដី ព្រោះហេតុនៃបុគ្គលដទៃក្ដី ព្រោះហេតុនៃ ទ្រព្យក្ដី អ្នកប្ប:ដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ប្រព្រឹត្តខុប ចំពោះប្រពន្ធ របស់ពួកញាតិ

## សុត្តនិបាតេ ខុទ្ទកវគ្គស្ស សត្តមំ វសលសុត្តំ

សហសា សម្បិយេន វា តំ ជញ្ញា វសលោ ឥតិ ។

យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ

បហុ សន្តោ ន ភរតិ តំ ជញ្ញា វសលោ ឥតិ ។

យោ មាតរំ វា បិតរំ វា ភាតរំ ភគិនិំ(១) សសុំ

ហន្តិ រោសេតិ វាចាយ តំ ជញ្ញា វសលោ ឥតិ ។

យោ អត្ថំ បុច្ឆិតោ សន្តោ អនត្ថមនុសាសតិ

បដិច្ឆន្នេន មន្តេតិ តំ ជញ្ញា វសលោ ឥតិ ។

យោ កត្វា បាបកំ កម្មំ មា មំ ជញ្ញាតិ ឥច្ឆតិ

យោ បដិច្ឆន្នកម្មន្តោ តំ ជញ្ញា វសលោ ឥតិ ។

យោ វេ បរកុលំ គន្ត្វា ភុត្វាន សុចិភោជនំ

អាគតំ ន បដិបូជេតិ តំ ជញ្ញា វសលោ ឥតិ ។

---

១ ម. ភគិនីសសុំ ។

ឬបំឡាញ់ដោយការកំហែង ឬដោយការស្រឡាញ់ស្ម័គ្រចិត្ត អ្នកគួរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជាអ្នកស្ដុកស្ដម្ភ តែមិនចិញ្ចឹមមាតា ឬបិតាដែលចាស់ជរា មានវ័យកន្លងហើយ អ្នកគួរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ប្រហារមាតា ឬបិតា បងប្អូនប្រុស បងប្អូនស្រី ឬម្ដាយក្មេក ឬក៏ជេរប្រទេចដោយវាចា អ្នកគួរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា កាលដែលគេសួរចំពោះហេតុមានប្រយោជន៍ ហើយពន្យល់ប្រាប់ហេតុដែលគ្មានប្រយោជន៍ បង្ហាញដោយពាក្យបិទបាំង អ្នកគួរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា បានធ្វើបាបកម្ម ហើយប្រាថ្នាថា អ្នកដទៃកុំគប្បីដឹងនូវអញ បុគ្គលណា មានការលាក់បិទបាំង អ្នកគួរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ទៅកាន់ត្រកូលញាតិមិត្តដទៃ ទាំងបានបរិភោគភោជនដ៏ស្អាត ហើយមិនបានបូជាគេដែលមកកាន់ផ្ទះរបស់ខ្លួនវិញ អ្នកគួរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វនិព្វកំ
មុសាវាទេន វញ្ចេតិ តំ ជញ្ញា វសលោ ឥតិ ។
យោ ព្រាហ្មណំ វា សមណំ វា ភត្តកាលេ ឧបដ្ឋិតេ
រោសេតិ វាចា ន ច ទេតិ តំ ជញ្ញា វសលោ ឥតិ ។
អសតំ យោធ បព្រូតិ មោហេន បលិគុណ្ឋិតោ
កិញ្ចិក្ខំ និជិគីសានោ តំ ជញ្ញា វសលោ ឥតិ ។
យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ
និហីនោ សេន មានេន តំ ជញ្ញា វសលោ ឥតិ ។
រោសកោ កទរិយោ ច បាបិច្ឆោ មច្ឆរី សឋោ
អហិរិកោ អនោត្តប្បី តំ ជញ្ញា វសលោ ឥតិ ។

បុគ្គលណា បញ្ឆោតព្រាហ្មណ៍ក្តី សមណៈក្តី ឬអ្នកសូមឯទៀតក្តី ដោយពាក្យកុហក អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជេរសមណៈឬព្រាហ្មណ៍ដោយវាចាក្តី មិនឲ្យភោជនក្នុងវេលាភត្តកាល ដែលគួរទំនុកបំរុងក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ក្នុងលោកនេះ ត្រូវមោហៈរួបរឹតហើយ កាលប្រាថ្នានូវកេរបំពោះទ្រព្យណាមួយ ក៏និយាយបោកប្រាស ដោយពាក្យមិនពិត (ទីងស្តី) អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា លើកតំកើងខ្លួនឯង ឬបន្ទះបង្អាប់ពួកជនដទៃ តែខ្លួនជាអ្នកសាបសូន្យ (ចាកគុណវឌ្ឍិ) ព្រោះការតំកើងនឹងការបន្ទះបង្អាប់របស់ខ្លួន អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា កោងកាចក្តី ស្វាកទ្រឹសក្តី មានសេចក្តីប្រាថ្នាអាក្រក់ក្តី កំណាញ់ក្តី អន្ទួតក្តី មិនអៀនខ្មាសក្តី មិនខ្លាចបាបក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

## សុត្តនិបាតេ ឧរគវគ្គស្ស សត្តមំ វសលសុត្តំ

យោ ពុទ្ធំ បរិភាសតិ អថ វា តស្ស សាវកំ
បរិព្វាជកំ គហដ្ឋំ វា តំ ជញ្ញា វសលោ ឥតិ ។
យោ វេ អនរហំ សន្តោ អរហំ បដិជានតិ
(១)
ចោរោ សព្រហ្មកេ លោកេ ឯសោ ខោ វសលាធមោ ។
ឯតេ ខោ វសលា វុត្តា មយា យេ តេ(២)បកាសិតា
ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ
កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ ។
តទមិនាបិ ជានាថ យថា មេទំ និទស្សនំ
ចណ្ឌាលបុត្តោ សោបាកោ មាតង្គោ ឥតិ វិស្សុតោ
សោ យសប្បរមប្បត្តោ មាតង្គោ យំ សុទុល្លភំ
អាគញ្ឆុំ តស្សុបដ្ឋានំ ខត្តិយា ព្រាហ្មណា ពហូ ។

---
១ ម. វសលោ ធម្មោ ។ ២ ខ. មយា ភោ យេ ។

បុគ្គលណា ជេរប្រទេចព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ឬបរិព្វាជក ឬគ្រហស្ថ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា មិនមែនជាអរហន្តទេ តែប្តេជ្ញា (ខ្លួន) ថាជាអរហន្ត បុគ្គលនោះ ជាចោរក្នុងលោក ព្រមទាំងព្រហ្មលោក នេះឯងជាបុគ្គលថោកទាបបំផុត ។

បុគ្គលថោកទាប ទាំងនេះឯង តថាគតបានប្រកាសហើយ បុគ្គលមិនមែនថោកទាប ព្រោះជាតិ មិនមែនជាព្រាហ្មណ៍ព្រោះជាតិទេ បុគ្គលថោកទាប ព្រោះកម្ម ជាព្រាហ្មណ៍ ក៏ព្រោះកម្ម ។

អ្នកទាំងឡាយ ចូរដឹងនូវសេចក្តីនោះ ដោយពាក្យនេះចុះ ដូចឧទាហរណ៍នេះឯង កូនរបស់មនុស្សចណ្ឌាល មានឈ្មោះប្រាកដថា សោបាកមាតង្គៈ មាតង្គកុមារនោះ បាននូវយសដ៏ប្រសើរ ដែលគេបានដោយក្រៃក្រៃលែង ពួកក្សត្រព្រាហ្មណ៍ជាច្រើន តែងមកកាន់ទីបំរើរបស់កុមារនោះ ។

សោ ទេវយានំ អភិរុយ្ហ វិរជំ សោ មហាបថំ

កាមរាគំ វិរាជេត្វា ព្រហ្មលោកូបគោ អហុ ។

ន នំ ជាតិ និវារេសិ ព្រហ្មលោកូបបត្តិយា ។

អជ្ឈាយកកុលេ ជាតា ព្រាហ្មណា មន្តពន្ធវា

តេ ច បាបេសុ កម្មេសុ អភិណ្ហមុបទិស្សរេ

ទិដ្ឋេវ ធម្មេ គារយ្ហា សម្បរាយេ ច ទុគ្គតិ

ន នេ ជាតិ និវារេតិ ទុគ្គច្ចា គរហាយ វា ។

ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ

កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោតិ ។

មាតង្គកុមារនោះ ឡើងកាន់យានគឺសមាបត្តិ ៨ អាចឲ្យទៅកាន់ទេវលោក ប្រាសចាកធូលីគឺកិលេស ជាផ្លូវធំ នឿយណាយនូវកាមរាគ ហើយទៅកើតក្នុងព្រហ្មលោក ។

ជាតិមិនមែនឃាត់មាតង្គៈនោះ ចាកការកើតក្នុងព្រហ្មលោកទេ ។ ពួកព្រាហ្មណ៍ជាផៅពង្សព្រោះមន្ត កើតក្នុងត្រកូលអ្នករៀនមន្ត ពួកព្រាហ្មណ៍ទាំងនោះ រមែងប្រាកដក្នុងបាបកម្មទាំងឡាយរឿយ ៗ ទុគ្គតិដែលអ្នកផងគួរតិះដៀលក្នុងបច្ចុប្បន្នក៏មាន ក្នុងបរលោកក៏មាន ( ព្រោះបាបកម្មជាបច្ច័យ ) ។

ជាតិមិនមែនឃាត់ពួកព្រាហ្មណ៍ទាំងនោះ ចាកទុគ្គតិ ឬចាកការតិះដៀលទេ ។ បុគ្គលមិនមែនជាអ្នកថោកទាប ព្រោះជាតិ មិនមែនជាព្រាហ្មណ៍ ព្រោះជាតិទេ បុគ្គលជាអ្នកថោកទាប ព្រោះកម្ម ជាព្រាហ្មណ៍ ក៏ព្រោះកម្មដែរ ។

## សុត្តនិបាតេ ឧរគវគ្គស្ស សត្តមំ វសលសុត្តំ

(១៦) ឯវំ វុត្តេ អគ្គិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ(១) និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ អនេកបរិយាយេន ភោតា គោតមេន ធម្មោ បកាសិតោ ឯសាហំ ភគវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

វសលសុត្តំ សត្តមំ ។

---

១ ម. ឆិក្កត្តរេ ភោ គោតម ។

( ១៤ ) ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ អគ្គិកភារទ្វាជព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចំរើន ភ្លឺច្បាស់ណាស់ ធម៌ដែលព្រះគោតមដ៏ចំរើន ទ្រង់សំដែងហើយ ដោយអនេកបរិយាយ យ៉ាងនេះ ដូចគេផ្ងារនូវរបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញ របស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោតដូចគេបំភ្លឺប្រទីបប្រេងក្នុងទីងងឹតដោយគិតថា មនុស្សអ្នកមានចក្ខុ មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចំរើន ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះទៅ ។

ចប់ វសលសូត្រ ទី ៧ ។

# អដ្ឋមំ មេត្តសុត្តំ

(១៥) ករណីយមត្ថកុសលេន

យន្តំ សន្តំ បទំ អភិសមេច្ច

សក្កោ ឧជូ ច សុហុជូ ច

សុវចោ ចស្ស មុទុ អនតិមានី ។

សន្តុស្សកោ ច សុភរោ ច

អប្បកិច្ចោ ច សល្លហុកវុត្តិ

សន្តិន្ទ្រិយោ ច និបកោ ច

អប្បគព្ភោ កុលេសុ អននុគិទ្ធោ ។

ន ច ខុទ្ទំ សមាចរេ កិញ្ចិ

យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។

សុខិនោ វា ខេមិនោ ហោន្តុ

សព្ពេ សត្តា ភវន្តុ សុខិតត្តា

# មេត្តសូត្រទី ៨

(១៩) កិច្ចណា ដែលអរិយបុគ្គល បានត្រាស់ដឹងនូវចំណែកនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ កុលបុត្រអ្នកឈ្លាសក្នុងប្រយោជន៍ គួរធ្វើ (កុលបុត្រនោះ) គួរជាអ្នកអាចហ៊ានផង មានកាយវាចាត្រង់ផង មានចិត្តត្រង់ល្អផង ជាបុគ្គលប្រដៅងាយផង មានសភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង ។ ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង មិនមានកិច្ចកង្វល់ផង ប្រព្រឹត្តស្រាលព្រមផង មានឥន្ទ្រិយស្ងប់ផង មានប្រាជ្ញាចាស់ផង មិនឆ្គាំឆ្គងផង មិនជាប់ចំពាក់ក្នុងត្រកូលទាំងឡាយផង ។ វិញ្ញូជនទាំងឡាយ គប្បីតិះដៀលនូវជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច (ហើយគប្បីផ្សាយមេត្តាចិត្តចំពោះ ពួកសត្វថា) សូមឲ្យពួកសត្វទាំងពួងមានសេចក្តីសុខ មានសេចក្តីក្សេមក្សាន្ត មានខ្លួនដល់នូវសេចក្តីសុខចុះ

## សុត្តនិបាតេ ឧរគវគ្គស្ស អដ្ឋមំ មេត្តសុត្តំ

យេ កេចិ បាណភូតត្ថិ
តសា វា ថាវរា វា អនវសេសា
ទីឃា វា យេ មហន្តា វា
មជ្ឈិមា រស្សកា អណុកថូលា
ទិដ្ឋា វា យេ ច អទិដ្ឋា
យេ ច ទូរេ វសន្តិ អវិទូរេ
ភូតា វា សម្ភវេសី វា
សព្វេ សត្តា ភវន្តុ សុខិតត្តា ។
ន បរោ បរំ និកុព្វេថ
នាតិមញ្ញេថ កត្ថចិ នំ កញ្ចិ
ព្យារោសនា បដិឃសញ្ញា
នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ ។
មាតា យថា និយំ បុត្តំ
អាយុសា ឯកបុត្តមនុរក្ខេ
ឯវម្បិ សព្វភូតេសុ
មានសំ ភាវយេ អបរិមាណំ

សុត្តនិបាត ឧរគវគ្គ មេត្តសូត្រ ទី ៨

ពួកសត្វដែលមានជីវិត ឥតមានសេសសល់ ទោះសត្វជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួនគឺឥតមានតណ្ហាក្តី ពួកសត្វដែលមានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី ស្គមក្តី ធាត់ក្តី ពួកសត្វដែលយើងឃើញក្តី មិនឃើញក្តី ពួកសត្វដែលនៅ ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី កើតរួចហើយក្តី កំពុងស្វែងរកកំណើតក្តី សូមឲ្យសត្វទាំងអស់ (នោះ) មានខ្លួនដល់នូវសេចក្តីសុខចុះ ។ សត្វដទៃមិនគួរកំហែងបៀតបៀនសត្វដទៃឡើយ មិនគួរមើលងាយគេតិចតួចក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្តីទុក្ខ ដល់គ្នានឹងគ្នា ដោយសេចក្តីក្រេវក្រោធ ដោយសេចក្តីចង្អៀតចង្អល់ចិត្តឡើយ ។ មាតាថ្នមរក្សាបុត្រ ដែលកើតអំពីខ្លួន ជាបុត្រតែមួយដោយអាយុ គឺថាសូម្បីជីវិតក៏ហ៊ានលះបង់ ក្នុងការរក្សានូវបុត្របាន យ៉ាងណាមិញ បុគ្គលគួរចំរើនមេត្តាចិត្តមិនមានប្រមាណ ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង

មេត្តញ្ច សព្វលោកស្មឹ

មានសម្ភាវយេ អបរិមាណំ

ឧទ្ធំ អធោ ច តិរិយញ្ច

អសម្ពាធំ អវេរំ អសបត្តំ

តិដ្ឋញ្ចរំ និសិន្នោ វា

សយានោ វា យាវតស្ស វិគតមិទ្ធោ ។

ឯតំ សតឹ អធិដ្ឋេយ្យ

ព្រហ្មមេតំ វិហារំ ឥធមាហុ ។

ទិដ្ឋិញ្ច អនុបគម្ម សីលវា

ទស្សនេន សម្បន្នោ

កាមេសុ វិនេយ្យ គេធំ

ន ហិ ជាតុ គព្ភសេយ្យំ បុនរេតីតិ ។

មេត្តសុត្តំ អដ្ឋមំ ។

បុគ្គលគួរចំរើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌ មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុងលោកទាំងអស់ ទាំងខាងលើខាងក្រោម ទាំងទទឹង គឺត្រង់កណ្តាលផង ( បុគ្គលអ្នកចំរើនមេត្តាចិត្តនោះ ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់អស់កាលត្រឹមណា គួរដំកល់នូវមេត្តានុស្សតិនុ៎ះ ( អស់កាលត្រឹមណោះ ) ។ បណ្ឌិតទាំងឡាយពោលនូវដំណើរនុ៎ះ ថាជាព្រហ្មវិហារ ក្នុងសាសនានេះ ។ ( បុគ្គលដែលមានមេត្តាព្រហ្មវិហារ ) មិនអាស្រ័យនូវទិដ្ឋិ ជាអ្នកមានសីល ប្រកបដោយទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្តីត្រេកអរ ក្នុងកាមទាំងឡាយ ដោយសកទាគាមិមគ្គ នឹងអនាគាមិមគ្គ រមែងមិនមកកាន់គព្ភសេយ្យាសទ៍ គឺថា មិនមកកើតក្នុងគភ៌ទៀតឡើយ ។

ចប់ មេត្តសូត្រ ទី ៨ ។

# ធម៌ ហេមវតសុត្តំ

(១៦) អជ្ជ បណ្ណរសោ ឧបោសថោ (ឥតិ សាតាគិរោ
យក្ខោ) ទិព្វា រត្តិ ឧបដ្ឋិតា
អនោមនាមំ សត្ថារំ ហន្ទ បស្សាម គោតមំ ។
កច្ចិ មនោ សុបណិហិតោ (ឥតិ ហេមវតោ យក្ខោ)
សព្វភូតេសុ តាទិនោ
កច្ចិ ឥដ្ឋេ អនិដ្ឋេ ច សង្កប្បស្ស វសីកតា ។
មនោ ចស្ស សុបណិហិតោ (ឥតិ សាតាគិរោ យក្ខោ)
សព្វភូតេសុ តាទិនោ
អថោ ឥដ្ឋេ អនិដ្ឋេ ច សង្កប្បស្ស វសីកតា ។
កច្ចិ អទិន្នំ នាទិយតិ (ឥតិ ហេមវតោ យក្ខោ)
កច្ចិ បាណេសុ សញ្ញតោ
២
កច្ចិ អារា បមាទម្ហា កច្ចិ ឈានំ ន រិញ្ចតិ ។

# ហេមវតសូត្រ ទី ៩

(១៦) (សាតាគិរយក្សពោលថា) ថ្ងៃនេះ ជាថ្ងៃឧបោសថ ទី ១៥ រាត្រីទិព្វប្រាកដហើយ ណ្ហើយចុះ យើងទាំងឡាយនឹងទៅគាល់ព្រះគោតម ជាសាស្តា មានព្រះនាម មិនថោកថយ ។

(ហេមវតយក្សសួរថា) ព្រះហឫទ័យ (របស់ព្រះគោតម) តាំងនៅល្អ នឹងធឹង ក្នុងសត្វទាំងអស់ឬ តម្រិះរបស់ព្រះអង្គ បានធ្វើឲ្យស្ទាត់ជំនាញ ក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ហើយឬ ។

(សាតាគិរយក្សពោលថា) ព្រះហឫទ័យរបស់ព្រះគោតមនោះ តាំងនៅល្អ នឹងធឹង ក្នុងពួកសត្វទាំងអស់ មួយទៀត តម្រិះព្រះអង្គ បានធ្វើឲ្យស្ទាត់ជំនាញ ក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ហើយ ។

(ហេមវតយក្សសួរថា) ព្រះគោតម មិនកាន់យកវត្ថុដែលគេមិនបានឲ្យទេឬ ព្រះអង្គសង្រួមក្នុងពួកសត្វឬ ឆ្ងាយចាកសេចក្តីប្រមាទឬ មិនលះបង់ចោលឈានទេឬ ។

ន សោ អទិន្នំ អាទិយតិ (ឥតិ សាតាគិរោ យក្ខោ)

អថោ បាណេសុ សញ្ញតោ

អថោ អារា បមាទម្ហា ពុទ្ធោ ឈានំ ន រិញ្ចតិ ។

កច្ចិ មុសា ន ភណតិ (ឥតិ ហេមវតោ យក្ខោ)

កច្ចិ ន ខីណព្យប្បថោ

កច្ចិ វេភូតិយំ នាហ កច្ចិ សម្ផំ ន ភាសតិ ។

មុសា ច សោ ន ភណតិ (ឥតិ សាតាគិរោ យក្ខោ)

អថោ ន ខីណព្យប្បថោ

អថោ វេភូតិយំ នាហ មន្តា អត្ថំ ច ភាសតិ ។

កច្ចិ ន រជ្ជតិ កាមេសុ (ឥតិ ហេមវតោ យក្ខោ)

កច្ចិ ចិត្តំ អនាវិលំ

កច្ចិ មោហំ អតិក្កន្តោ កច្ចិ ធម្មេសុ ចក្ខុមា ។

(សាតាគិរយក្ស ពោលថា) ព្រះគោតមនោះ មិនកាន់យកវត្ថុ ដែលគេមិនបានឲ្យទេ មួយទៀត ព្រះអង្គសង្រួម ក្នុងពួកសត្វ ទាំងឆ្ងាយចាកសេចក្តីប្រមាទហើយ ជាព្រះពុទ្ធ មិនបោះបង់ឈានពោល ឡើយ ។

(ហេមវតយក្ស សួរថា) ព្រះសមណគោតម មិនពោលពាក្យកុហកទេឬ មានគន្ទងនៃពាក្យមិនអស់ទេឬ (មិនពោលផរុសវាចា) មិនពោលពាក្យញុះញង់ទេឬ មិនពោលពាក្យឥតប្រយោជន៍ទេឬ ។

(សាតាគិរយក្ស ពោលថា) ព្រះសមណគោតមនោះ មិនពោលពាក្យកុហកទេ មួយទៀត មានគន្ទងនៃពាក្យមិនបេះអស់ ទាំងមិនបេះពោលពាក្យញុះញង់ទេ តែងពោលពាក្យមានប្រយោជន៍ ដោយបញ្ញា ។

(ហេមវតយក្ស សួរថា) ព្រះពុទ្ធមិនត្រេកអរក្នុងកាមទេឬ ព្រះហឫទ័យមិនល្អក់ទេឬ ព្រះអង្គកន្លងបង់នូវមោហៈហើយឬ មានបញ្ញាចក្ខុក្នុងធម៌ទាំងឡាយឬ ។

ន សោ រជ្ជតិ កាមេសុ (ឥតិ សាតាគិរោ យក្ខោ)
អថោ ចិត្តំ អនាវិលំ
សព្វមោហំ អតិក្កន្តោ ពុទ្ធោ ធម្មេសុ ចក្ខុមា ។
កច្ចិ វិជ្ជាយ សម្បន្នោ (ឥតិ ហេមវតោ យក្ខោ)
កច្ចិ សំសុទ្ធចារណោ
កច្ចិស្ស អាសវា ខីណា កច្ចិ នត្ថិ បុនព្ភវោ ។
វិជ្ជាយ ចេវ សម្បន្នោ (ឥតិ សាតាគិរោ យក្ខោ)
អថោ សំសុទ្ធចារណោ
សព្វស្ស អាសវា ខីណា នត្ថិ តស្ស បុនព្ភវោ ។
សម្បន្នំ មុនិនោ ចិត្តំ កម្មុនា ព្យប្បថេន ច
វិជ្ជាចរណសម្បន្នំ ហន្ទ បស្សាម គោតមំ(១) ។

---

១ ឱ. ម. សម្បន្នំ មុនិនោ ចិត្តំ កម្មុនា ព្យប្បថេន ច
វិជ្ជាចរណសម្បន្នំ ធម្មតោ ទំ បសំសសិ ។
សម្បន្នំ មុនិនោ ចិត្តំ កម្មុនា ព្យប្បថេន ច
វិជ្ជាចរណសម្បន្នំ ធម្មតោ អនុមោទសិ ។
សម្បន្នំ មុនិនោ ចិត្តំ កម្មុនា ព្យប្បថេន ច
វិជ្ជាចរណសម្បន្នំ ហន្ទ បស្សាម គោតមំ ។

(សាតាគិរយក្ស ពោលថា) ព្រះពុទ្ធនោះ មិនត្រេកអរតេក្នុងកាមទាំងឡាយទេ ទាំងព្រះហឫទ័យសោតក៏មិនល្អក់ ព្រះអង្គកន្លងបង់នូវមោហៈទាំងអស់ ជាព្រះពុទ្ធ មានបញ្ញាចក្ខុ ក្នុងធម៌ទាំងឡាយ ។

(ហេមវតយក្ស សួរថា) ព្រះពុទ្ធ បរិបូណ៌ដោយវិជ្ជាឬ មានចរណៈដ៏បរិសុទ្ធប្រពៃឬ អាសវៈទាំងឡាយ របស់ព្រះអង្គអស់ហើយឬ ការកើតក្នុងភពថ្មីទៀត មិនមានទេឬ ។

(សាតាគិរយក្ស ពោលថា) ព្រះគោតមបរិបូណ៌ដោយវិជ្ជា ទាំងមានចរណៈដ៏បរិសុទ្ធប្រពៃ អាសវៈទាំងអស់របស់ព្រះអង្គអស់ហើយ ភពថ្មីរបស់ព្រះអង្គមិនមានទៀតឡើយ ។ ព្រះហឫទ័យ របស់ព្រះមុនីបរិបូណ៌ ដោយកម្មផង ដោយគន្លងនៃពាក្យផង ណ្ហើយចុះ យើងទាំងទៅគាល់ព្រះគោតម ដែលបរិបូណ៌ដោយវិជ្ជានិងចរណៈ ។

ឯណិជង្ឃំ កិសំ វីរំ អប្បាហារំ អលោលុបំ

មុនឹ វនស្មឹ ឈាយន្តំ ឯហិ បស្សាម គោតមំ ។

សីហំ ឯកចរំ នាគំ កាមេសុ អនបេក្ខិនំ

ឧបសង្កម្ម បុច្ឆាម មច្ចុបាសប្បមោចនំ ។

អក្ខាតារំ បវត្តារំ សព្វធម្មាន បារគុំ

ពុទ្ធំ វេរភយាតីតំ មយំ បុច្ឆាម គោតមំ ។

កិស្មឹ លោកោ សមុប្បន្នោ (ឥតិ ហេមវតោ យក្ខោ)

កិស្មឹ កុព្វតិ សន្ថវំ

កិស្ស លោកោ ឧបាទាយ កិស្មឹ លោកោ វិហញ្ញតិ ។

ឆសុ លោកោ សមុប្បន្នោ (ហេមវតាតិ ភគវា)

ឆសុ កុព្វតិ សន្ថវំ

ឆន្នមេវ ឧបាទាយ ឆសុ លោកោ វិហញ្ញតិ ។

អ្នកចូរមក យើងនឹងទៅគាល់ព្រះគោតម ដែលមានព្រះជង្ឃាដូចជាស្មងនៃសត្វទ្រាំង មានព្រះកាយស្គម ជាអ្នកប្រាជ្ញ មានអាហារតិច មិនល្មេះល្មោភ(១) ជាអ្នកស្ងប់ស្ងៀម ដុតកំដៅកិលេសក្នុងព្រៃ ។

យើងនឹងចូលទៅគាល់ ហើយសួរនូវការរួចចាកអន្ទាក់នៃមច្ចុ ចំពោះព្រះអង្គជាអ្នកប្រសើរ ត្រាច់ទៅតែម្នាក់ឯង ដូចជាសត្វសីហៈ មិនអាឡោះអាល័យក្នុងកាមទាំងឡាយ ។ យើងនឹងសួរនូវព្រះគោតមជាអ្នកប្រាប់ចង្អុលបង្ហាញ ជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង ជាព្រះពុទ្ធ កន្លងបង់នូវពៀរនិងភ័យ ។

(ហេមវតយក្ស សួរថា) សត្វលោកកើតឡើងព្រោះអ្វី ធ្វើសេចក្តីស្និទ្ធស្នាលព្រោះអ្វី សត្វលោកប្រកាន់នូវអ្វី សត្វលោកលំបាកព្រោះអ្វី ។

(ព្រះមានព្រះភាគត្រាស់ថា ម្នាលហេមវតៈ) សត្វលោកកើតឡើងព្រោះវត្ថុ ៦ ធ្វើសេចក្តីស្និទ្ធស្នាលព្រោះវត្ថុ ៦ សត្វលោកប្រកាន់មាំនូវវត្ថុ ៦ សត្វលោកលំបាក ព្រោះវត្ថុ ៦ ។

---

១ មិនលោភក្នុងអាហារដោយឆន្ទរាគៈ ។

កតមន្តំ ឧបាទានំ យត្ថ លោកោ វិហញ្ញតិ
និយ្យានំ បុច្ឆិតោ ព្រូហិ កថំ ទុក្ខា បមុញ្ចតិ ៗ

បញ្ច កាមគុណា លោកេ មនោឆដ្ឋា បវេទិតា
ឯត្ថ ឆន្ទំ វិរាជេត្វា ឯវំ ទុក្ខា បមុញ្ចតិ ៗ

ឯតំ លោកស្ស និយ្យានំ អក្ខាតំ វោ យថាតថំ
ឯតំ វោ អហមក្ខាមិ ឯវំ ទុក្ខា បមុញ្ចតិ ៗ

កោសូធ តរតិ ឱឃំ កោធ តរតិ អណ្ណវំ
អប្បតិដ្ឋេ អនាលម្ពេ កោ គម្ភីរេ ន សីទតិ ៗ

ខ្ញុំព្រះអង្គទូលសួរ នូវផ្លូវជាទីនាំទៅ សូមព្រះអង្គប្រាប់ ការប្រកាន់មាំ ដែលនាំឲ្យសត្វលោកលំបាក តើដូចម្តេច សត្វលោក តែងរួចស្រឡះចាកទុក្ខ ដោយប្រការដូចម្តេច ។

កាមគុណ៥ មានមនោជាគំរប់៦ក្នុងលោក ដែលតថាគតសំដែងហើយ សត្វលោកកំចាត់បង់ហើយ នូវឆន្ទះក្នុងកាមគុណនុ៎ះ តែងរួចស្រឡះចាកទុក្ខ យ៉ាងនេះឯង ។ ផ្លូវជាទីនាំទៅនូវសត្វលោកនុ៎ះ តថាគតបានប្រាប់ហើយដល់អ្នកទាំងឡាយតាមពិត តថាគតនឹងប្រាប់នូវផ្លូវនុ៎ះដល់អ្នកទាំងឡាយ សត្វលោកតែងរួចស្រឡះចាកទុក្ខយ៉ាងនេះ ។

ក្នុងលោកនេះ នរណាហ្ន៎ ឆ្លងអន្លង់បួនបាន ក្នុងលោកនេះ នរណាហ្ន៎ ឆ្លងនូវសមុទ្រគឺសង្សារបាន នរណាហ្ន៎ មិនលិចចុះក្នុងជំរៅ គឺសង្សារ ដែលមិនមានទីពឹង មិនមានទីតោង ។

សព្វទា សីលសម្បន្នោ បញ្ញវា សុសមាហិតោ
អជ្ឈត្តសញ្ញី(១) សតិមា ឱឃំ តរតិ ទុត្តរំ
វិរតោ កាមសញ្ញាយ សព្វសំយោជនាតិគោ
នន្ទិភវបរិក្ខីណោ សោ គម្ភីរេ ន សីទតិ ។

គម្ភីរបញ្ញំ និបុណត្ថទស្សឹ
អកិញ្ចនំ កាមភវេ អសត្តំ
តំ បស្សថ សព្វធិ វិប្បមុត្តំ
ទិព្វេ បថេ កមមានំ មហេសឹ
អនោមនាមំ និបុណត្ថទស្សឹ
បញ្ញាទទំ កាមាលយេ អសត្តំ
តំ បស្សថ សព្វវិទុំ សុមេធំ
អរិយេ បថេ កមមានំ មហេសឹ ។

---

១. អជ្ឈត្តចិន្តី ។

បុគ្គលបរិបូណ៌ដោយសីល មានបញ្ញា មានចិត្តជាសមាធិ ជាអ្នកសំគាល់នូវត្រៃសិក្ខាក្នុងសន្តាន មានស្មារតីសព្វកាល រមែងឆ្លងអន្លង់ដែលឆ្លងបានដោយក្រ ( បុគ្គលណា ) វៀរចាកកាមសញ្ញា កន្លងផុតសំយោជនៈទាំងអស់ មានសេចក្តីត្រេកអរក្នុងភពអស់ហើយ បុគ្គលនោះមិនលិចចុះក្នុងទីជ្រៅគឺសង្សារ ។ អ្នកទាំងឡាយ ចូរមើលបុគ្គលនោះ មានប្រាជ្ញាជ្រាលជ្រៅ ឃើញនូវប្រយោជន៍ដ៏ល្អិត មិនមានកង្វល់ មិនជាប់ចំពាក់ក្នុងកាមភព ផុតស្រឡះចាកកិលេសទាំងពួង អ្នកស្វែងរកប្រយោជន៍ដ៏ធំចំពោះកុសលកម្មទាំងឡាយ ក្នុងផ្លូវដ៏ជាទិព្យ អ្នកទាំងឡាយ ចូរមើលបុគ្គលនោះ ជាអ្នកមានឈ្មោះមិនថយថោក ឃើញនូវប្រយោជន៍ដ៏ល្អិត ឲ្យនូវប្រាជ្ញា មិនជាប់ក្នុងសេចក្តីអាឡោះអាល័យ ក្នុងកាម ជាអ្នកប្រាជ្ញ ដឹងហេតុសព្វគ្រប់ ស្វែងរកប្រយោជន៍ដ៏ធំ ចំពោះកុសលកម្មទាំងឡាយ ក្នុងផ្លូវដ៏ប្រសើរ ។

## សុត្តនិបាតេ ឧរគវគ្គស្ស នវមំ ហេមវតសុត្តំ

សុខិដ្ឋំ វត ភោ អជ្ជ សុប្បភាតំ សុហុដ្ឋិតំ
យំ អទ្ទសាម សម្ពុទ្ធំ ឱឃតិណ្ណមនាសវំ ។
ឥមេ ទសសតយក្ខា ឥទ្ធិមន្តោ យសស្សិនោ
សព្វេ តំ សរណំ យន្តិ ត្វំ នោ សត្ថា អនុត្តរោ ។
តេ មយំ វិចរិស្សាម គាមាគាមំ នគានគំ
នមស្សមានា សម្ពុទ្ធំ ធម្មស្ស ច សុធម្មតន្តិ ។

ហេមវតសុត្តំ នវមំ ។

## សុត្តនិបាត ឧរគវគ្គ ហេមវតសូត្រ ទី ៩

ឱហ្ន៎ ថ្ងៃនេះ យើងបានឃើញល្អ ជាពេលភ្លឺស្វាង ល្អ ជាពេលនៃអរុណល្អ ពួកយើងបានឃើញព្រះសម្ពុទ្ធ ដែលព្រះអង្គឆ្លងអន្លង់បានហើយ មិនមានអាសវៈ ។ ពួកយក្សទាំងមួយពាន់នាក់នេះ ជាអ្នកមានឫទ្ធិ មានយស ទាំងអស់គ្នា បានដល់នូវព្រះសម្ពុទ្ធនោះជាសរណៈ ព្រះអង្គជាសាស្តាដ៏ប្រសើរ របស់យើងខ្ញុំទាំងឡាយ ។ យើងខ្ញុំទាំងនោះនឹងត្រាច់ទៅកាន់ស្រុកតូច(១)ស្រុកធំ ភ្នំតូច ភ្នំធំ ក្រាបថ្វាយបង្គំព្រះសម្ពុទ្ធផង នូវសភាពដ៏ល្អ របស់ព្រះធម៌ផង ។

ចប់ ហេមវតសូត្រ ទី ៩ ។

---

១ ទេវព្រាម ទេវបព៌ត ។ អដ្ឋកថា ។

# ទសមំ អាឡវកសុត្តំ

(១៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អាឡវិយំ វិហរតិ អាឡវកស្ស យក្ខស្ស ភវនេ ។ អថខោ អាឡវកោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច និក្ខម សមណាតិ ។ សាធាវុសោតិ ភគវា និក្ខមិ ។ បវិស សមណាតិ ។ សាធាវុសោតិ ភគវា បាវិសិ ។ ទុតិយម្បិ ខោ អាឡវកោ យក្ខោ ភគវន្តំ ឯតទវោច និក្ខម សមណាតិ ។ សាធាវុសោតិ ភគវា និក្ខមិ ។ បវិស សមណាតិ ។ សាធាវុសោតិ ភគវា បាវិសិ ។ តតិយម្បិ ខោ សោ អាឡវកោ យក្ខោ ភគវន្តំ ឯតទវោច និក្ខម សមណាតិ ។ សាធាវុសោតិ ភគវា និក្ខមិ ។

# អាឡវកសូត្រ ទី ១០

(១៧) ខ្ញុំបានស្តាប់មក យ៉ាងនេះ ៗ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងលំនៅរបស់អាឡវកយក្ស ក្បែរក្រុងអាឡវី ៗ គ្រានោះឯង អាឡវកយក្សចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ពោលនឹងព្រះមានព្រះភាគដូច្នេះថា នែសមណៈ ចូរចេញទៅ ៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចេញទៅ ៗ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចូលមក ៗ អាឡវកយក្ស ពោលនឹងព្រះមានព្រះភាគ ដូច្នេះទៀតជាគំរប់ ២ ដងថា នែសមណៈ ចូរចេញទៅ ៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ រួចក៏ស្តេចចេញទៅ ៗ អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចូលមក ៗ អាឡវកយក្សនោះពោលនឹងព្រះមានព្រះភាគដូច្នេះទៀត ជាគំរប់ ៣ ដងថា នែសមណៈ ចូរចេញទៅ ៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយ អាវុសោ ហើយក៏ស្តេចចេញទៅ ៗ

បវិស សមណាតិ ។ សាធាវុសោតិ ភគវា បាវិសិ ។
ចតុត្ថម្បិ ខោ អាឡវកោ យក្ខោ ភគវន្តំ ឯតទវោច
និក្ខម សមណាតិ ។ ន ខ្វាហំ(១) អាវុសោ និក្ខ-
មិស្សាមិ យន្តេ ករណីយំ តំ ករោហីតិ ។ បញ្ហំ
សមណ បុច្ឆិស្សាមិ សចេ មេ ន ព្យាករិស្សសិ
ចិត្តំ វា តេ ខិបិស្សាមិ ហទយំ វា តេ ផាលេស្សាមិ
បាទេសុ វា គហេត្វា បារគង្គាយ ខិបិស្សាមីតិ ។
ន ខ្វាហន្តំ អាវុសោ បស្សាមិ សទេវកេ លោកេ
សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា
បជាយ សទេវមនុស្សាយ យោ មេ ចិត្តំ វា
ខិបេយ្យ ហទយំ វា ផាលេយ្យ បាទេសុ វា
គហេត្វា បារគង្គាយ ខិបេយ្យ អបិ ច ត្វំ អាវុសោ
បុច្ឆ យទាកង្ខសីតិ ។ អថខោ អាឡវកោ យក្ខោ
ភគវន្តំ គាថាយ អជ្ឈភាសិ

---

១ ឱ.ម. ន ខ្វាហន្តំ ។

អាឡវកយក្សពោលថា នែសមណៈ ចូរចូលមកវិញ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ប្រពៃហើយអាវុសោ ហើយក៏ស្ដេចចូលមកវិញ ។ អាឡវកយក្សពោលនឹងព្រះមានព្រះភាគ ដូច្នេះទៀតជាគំរប់ ៤ ដងថា នែសមណៈ ចូរចេញទៅ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអាវុសោ តថាគតនឹងមិនចេញទៅទេ អំពើណាដែលអ្នកត្រូវធ្វើ ចូរអ្នកធ្វើអំពើនោះចុះ ។ នែសមណៈ ខ្ញុំនឹងសួរប្រស្នាចំពោះលោក បើលោកមិនដោះស្រាយឲ្យយើងទេ យើងនឹងធ្វើចិត្តលោកឲ្យរវើរវាយ ឬហែកហឫទ័យរបស់លោក ឬក៏ចាប់ជើង គ្រវែងចោលទៅត្រើយម្ខាងទន្លេគង្គា ។ ម្នាលអាវុសោ តថាគតមិនឃើញអ្នកណាដែលធ្វើចិត្តនៃតថាគតឲ្យរវើរវាយបាន ឬហែកហឫទ័យ ឬក៏ចាប់ជើងគ្រវែងចោលទៅត្រើយម្ខាងទន្លេ-គង្គា ក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឡើយ ម្នាលអាវុសោ អ្នកប្រាថ្នានឹងសួរយ៉ាងណា ចូរសួរមកចុះ ។ គ្រានោះឯង អាឡវកយក្ស បានពោលនឹងព្រះមានព្រះភាគដោយគាថា ដូច្នេះថា

(១៨) កឹសូធ វិត្តំ បុរិសស្ស សេដ្ឋំ
កឹសុ សុចិណ្ណំ សុខមាវហាតិ
កឹសុ ហវេ សាធុតរំ រសានំ
កថំជីវឹ ជីវិតមាហុ សេដ្ឋំ ។
សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
សច្ចំ ហវេ សាធុតរំ រសានំ
បញ្ញាជីវឹ ជីវិតមាហុ សេដ្ឋំ ។
កថំ សុ តរតី ឱឃំ កថំ សុ តរតិ អណ្ណវំ
កថំ សុ ទុក្ខមច្ចេតិ កថំ សុ បរិសុជ្ឈតិ ។
សទ្ធាយ តរតី ឱឃំ អប្បមាទេន អណ្ណវំ
វីរិយេន ទុក្ខមច្ចេតិ បញ្ញាយ បរិសុជ្ឈតិ ។

(១៨) ក្នុងលោកនេះ អ្វីជាទ្រព្យដ៏ប្រសើររបស់បុរស អ្វីដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្តីសុខមកឲ្យ អ្វីមានរសឆ្ងាញ់ពិសាជាងរសទាំងឡាយ បណ្ឌិតហៅជីវិតនៃអ្នករស់នៅបែបណា ថាជាជីវិតប្រសើរ ។

(ព្រះមានព្រះភាគត្រាស់ថា) ក្នុងលោកនេះ សទ្ធាជាទ្រព្យដ៏ប្រសើរ របស់បុរស ធម៌ដែលគេប្រព្រឹត្តល្អហើយ តែងនាំសេចក្តីសុខមកឲ្យ ពាក្យសត្យ មានរសឆ្ងាញ់ពិសា ជាងរសទាំងឡាយ បណ្ឌិតហៅជីវិតនៃអ្នករស់នៅ ដោយបញ្ញា ថាជាជីវិតប្រសើរ ។

បុគ្គលឆ្លងអន្លង់បានដោយអ្វី ឆ្លងមហាសមុទ្របានដោយអ្វី កន្លងសេចក្តីទុក្ខបានដោយអ្វី បរិសុទ្ធបានដោយអ្វី ។

បុគ្គលឆ្លងអន្លង់បានដោយសទ្ធា ឆ្លងមហាសមុទ្របាន ដោយសេចក្តីមិនប្រមាទ កន្លងសេចក្តីទុក្ខបានដោយព្យាយាម បរិសុទ្ធបានដោយប្រាជ្ញា ។

សុត្តនិបាតេ ឧរគវគ្គស្ស ទសមំ អាឡវកសុត្តំ

កឹសុ លភតេ បញ្ញំ   កឹសុ វិន្ទតេ ធនំ

កឹសុ កិត្តឹ បប្បោតិ   កឹ មិត្តានិ គន្ថតិ

អស្មា លោកា បរំ លោកំ   កឹ បេច្ច ន សោចតិ ។

សទ្ទហានោ អរហតំ   ធម្មំ និព្វានបត្តិយា

សុស្សូសំ លភតេ បញ្ញំ   អប្បមត្តោ វិចក្ខណោ

បតិរូបការី ធុរវា   ឧដ្ឋាតា វិន្ទតេ ធនំ

សច្ចេន កិត្តឹ បប្បោតិ   ទទំ មិត្តានិ គន្ថតិ ។

យស្សេតេ ចតុរោ ធម្មា   សទ្ធស្ស ឃរមេសិនោ

សច្ចំ ធម្មោ ធិតិ ចាគោ   ស វេ បេច្ច ន សោចតិ ។

សុត្តនិបាត ឧរគវគ្គ អាឡវកសូត្រ ទី ១០

បុគ្គលបាននូវប្រាជ្ញាដោយអ្វី បាននូវទ្រព្យដោយអ្វី ដល់នូវសេចក្ដីសរសើរដោយអ្វី ចងនូវមិត្តទាំងឡាយបានដោយអ្វី បុគ្គលចេញចាកលោកនេះ ទៅកាន់លោកខាងមុខ ហើយមិនសោយសោកក្នុងលោកខាងមុខដោយអ្វី ។

បុគ្គលជឿធម៌របស់ព្រះអរហន្ត ស្ដាប់ដោយគោរព ជាអ្នកមិនប្រមាទ មានបញ្ញាពិចារណា រមែងបាននូវប្រាជ្ញា(១) ដើម្បីដល់ព្រះនិព្វាន, បុគ្គលមានការងារដ៏សមគួរ មានធុរៈ(២) មានព្យាយាមប្រឹងប្រែង(៣) រមែងបាននូវទ្រព្យ បុគ្គលដល់នូវសេចក្ដីសរសើរដោយសច្ចៈ បុគ្គលកាលឲ្យ រមែងចងនូវមិត្តទាំងឡាយបាន ។

ធម៌ទាំង ៤ នេះ គឺសច្ចៈ១ ធម្មៈ (បញ្ញា)១ ធិតិ (ព្យាយាម)១ ចាគៈ (ការបរិច្ចាគ)១ របស់បុគ្គលណា មានសទ្ធានៅគ្រប់គ្រងផ្ទះ បុគ្គលនោះឯង រមែងមិនសោយសោក ក្នុងលោកខាងមុខ ។

---

១ ហេតុឲ្យបានបញ្ញា ៤ យ៉ាងគឺ ១– សទ្ធា, ២– ស្ដាប់ដោយគោរព, ៣ អប្បមាទ ៤– វិចក្ខណៈ ការពិចារណា ។ ២ ព្យាយាមផ្លូវចិត្ត ។ ៣ ព្យាយាមផ្លូវកាយ ។ អដ្ឋកថា ។

ឥង្ឃ អញ្ញេបិ បុច្ឆស្សុ បុថូ សមណព្រាហ្មណេ
យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ ។
កថំ នុ ទានិ បុច្ឆេយ្យំ បុថូ សមណព្រាហ្មណេ
យោហំ អជ្ជ បជានាមិ យោ អត្ថោ សម្បរាយិកោ
អត្ថាយ វត មេ ពុទ្ធោ វាសាយាឡវិមាគមា ។
យោហំ អជ្ជ បជានាមិ យត្ថ ទិន្នំ មហប្ផលំ
សោ អហំ វិចរិស្សាមិ គាមា គាមំ បុរា បុរំ
នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតន្តិ ។

អាឡវកសុត្តំ ទសមំ ។

អញ្ជើញអ្នក ទៅសួរពួកសមណព្រាហ្មណ៍ជាច្រើន ដទៃទៀតចុះ បើមានធម៌ដទៃទៀត ក្នុងលោកនេះ ឲ្យក្រៃលែងជាងសច្ចៈ ទមៈ ចាគៈ ខន្តិ ទៅទៀត ។

ឥឡូវនេះ ខ្ញុំពាំបាច់សួរពួកសមណព្រាហ្មណ៍ ជាច្រើនធ្វើអ្វីទៀត (ព្រោះ) ក្នុងថ្ងៃនេះ ខ្ញុំដឹងប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខច្បាស់ហើយ ព្រះពុទ្ធទ្រង់ស្តេចមកកាន់ដែនអាឡវី ដើម្បីគង់នៅ ជាប្រយោជន៍ដល់ខ្ញុំព្រះអង្គហើយ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គដឹងច្បាស់ហើយថា ទានដែលបុគ្គលឲ្យហើយ ចំពោះព្រះសម្ពុទ្ធណា ថាជាទានមានផលច្រើន ខ្ញុំព្រះអង្គនឹងត្រាច់ទៅអំពីស្រុក ទៅកាន់ស្រុក អំពីបុរីទៅកាន់បុរី សូមថ្វាយបង្គំនូវព្រះសម្ពុទ្ធ (នោះ) ផង នូវសភាពដ៏ល្អរបស់ព្រះធម៌ផង ។

ចប់ អាឡវកសូត្រ ទី ១០ ។

# ឯកាទសមំ វិជយសុត្តំ

(១៩) ចរំ វា យទិ វា តិដ្ឋំ  និសិន្នោ ឧទ(១) វា សយំ
សម្មិញ្ជេតិ បសារេតិ  ឯសា កាយស្ស ឥញ្ជនា ។
អដ្ឋិន្ហារុសំយុត្តោ  តចមំសាវលេបនោ
ឆវិយា កាយោ បដិច្ឆន្នោ  យថាភូតំ ន ទិស្សតិ
អន្តបូរោ ឧទរបូរោ  យកបេឡស្ស វត្ថិនោ
ហទយស្ស បប្ផាសស្ស  វក្កស្ស បិហកស្ស ច
សិង្ឃាណិកាយ ខេឡស្ស  សេទស្ស ច មេទស្ស ច
លោហិតស្ស លសិកាយ  បិត្តស្ស ច វសាយ ច ។

---
១ ម. យទិ ។

# វិជយសុត្ត ទី ១១

(១៩) ជាបើបុគ្គល ដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី រមែងបត់ចូល លាចេញ នេះជាការកំរើកកាយ ។

កាយប្រកបដោយឆ្អឹងនឹងសរសៃទាំងឡាយ គ្របដណ្តប់ដោយស្បែកនឹងសាច់ បិទបាំងដោយសម្បុរថ្ងៃ មិនប្រាកដតាមពិត ។

កាយពេញដោយពោះវៀនផង ពេញដោយអាហារថ្មីផង ដោយដុំថ្លើមផង ដោយក្រពះនោមផង ដោយបេះដូងផង ដោយសួតផង ដោយតាបផង ដោយក្រពះបាយផង ដោយទឹកសំបោរផង ដោយទឹកមាត់ផង ដោយញើសផង ដោយខ្លាញ់ខាប់ផង ដោយឈាមផង ដោយទឹករំអិលផង ដោយទឹកប្រមាត់ផង ដោយខ្លាញ់រាវផង ។

អថស្ស នវហិ សោតេហិ អសុចី សវតិ សព្វទា

អក្ខិម្ហា អក្ខិគូថកោ    កណ្ណម្ហា កណ្ណគូថកោ

សិង្ឃាណិកា ច នាសតោ    មុខេន វមតេកទា

បិត្តំ សេម្ហំ ច វមតិ    កាយម្ហា សេទជល្លិកា ។

អថស្ស សុសិរំ សីសំ    មត្ថលុង្គស្ស បូរិតំ

សុភតោ នំ មញ្ញតិ ពាលោ អវិជ្ជាយ បុរក្ខតោ ។

យទា ច សោ មតោ សេតិ ឧទ្ធុមាតោ វិនីលកោ

អបវិទ្ធោ សុសានស្មឹ អនបេក្ខា ហោន្តិ ញាតយោ ។

ខាទន្តិ នំ សុវាណា(១) ច សិង្គាលា ច វកា កិមី

កាកា គិជ្ឈា ច ខាទន្តិ យេ ចញ្ញេ សន្តិ បាណិនោ ។

---

១ ឱ. សុបាណា ។

មួយទៀត វត្ថុមិនស្អាត រមែងហូរចេញតាមរន្ធទាំង ៩ របស់កាយនោះសព្វកាល គឺព្រៀកភ្នែក ហូរចេញអំពីភ្នែក មូលត្រចៀក ហូរចេញអំពីត្រចៀក ទឹកសំបោរ ហូរចេញអំពីច្រមុះ ជួនណាចេញតាមមាត់ ប្រមាត់នឹងស្លេស្ម ក៏ខ្ជុរចេញតាមមាត់ដែរ ញើសនឹងក្អែល ហូរចេញអំពីកាយ ។

មួយទៀត កាយនោះមានក្បាលប្រហោង ពេញដោយខួរក្បាល ជនពាលត្រូវអវិជ្ជារួបរឹតហើយ រមែងសំគាល់កាយនោះថាល្អ ។ កាលណាកាយនោះ ស្លាប់ទៅ ដេកនៅហើមប៉ោង មានពណ៌ខៀវ ត្រូវគេបោះចោលទៅ ក្នុងព្រៃស្មសានហើយ កាលណោះ ជនទាំងឡាយជាញាតិ ក៏លែងរមិល ស្វាន ចចក ឆ្កែ ដង្កូវ ដណ្តែងស៊ីកាយស្លាប់នោះ បំណែកពួកសត្វដទៃ មានក្អែកត្មាតជាដើម ក៏ចឹកស៊ីនូវកាយស្លាប់នោះដែរ ។

## សុត្តនិបាតេ ឧរគវគ្គស្ស ឯកាទសមំ វិជយសុត្តំ

សុត្វាន ពុទ្ធវចនំ ភិក្ខុ បញ្ញាណវា ឥធ
សោ ខោ នំ បរិជានាតិ យថាភូតញ្ហិ បស្សតិ ។
យថា ឥទំ តថា ឯតំ យថា ឯតំ តថា ឥទំ
អជ្ឈត្តញ្ច ពហិទ្ធា ច កាយេ ឆន្ទំ វិរាជយេ ។
ឆន្ទរាគវិរត្តោ សោ ភិក្ខុ បញ្ញាណវា ឥធ
អជ្ឈគា អមតំ សន្តិំ និព្ពានបទមច្ចុតំ ។
ទិបាទកោយំ អសុចិ ទុគ្គន្ធោ បរិហរតិ(១)
នានាកុណបបរិបូរោ វិស្សវន្តោ តតោ តតោ ។
ឯតាទិសេន កាយេន យោ មញ្ញេ ឧណ្ណាមេតវេ
បរំ វា អវជានេយ្យ កិមញ្ញត្រ អទស្សនាតិ ។

វិជយសុត្តំ ឯកាទសមំ ។

---

១ ម. បរិហោរតិ ។

សុត្តនិបាត ឧរគវគ្គ វិជយសូត្រ ទី ១១

ភិក្ខុណាក្នុងសាសនានេះ ជាអ្នកមានបញ្ញា បានស្តាប់នូវពុទ្ធវចនៈហើយ ភិក្ខុនោះ រមែងកំណត់ដឹងនូវកាយនោះ ព្រោះឃើញច្បាស់តាមពិត ។ សរីរៈរស់នេះយ៉ាងណា សរីរៈស្លាប់នុ៎ះក៏យ៉ាងនោះ សរីរៈស្លាប់នុ៎ះយ៉ាងណា សរីរៈរស់នេះក៏យ៉ាងនោះ ភិក្ខុគប្បីរំសាយនូវសេចក្តីប្រាថ្នាក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅ ក្នុងសាសនានេះ ភិក្ខុនោះ មានបញ្ញាប្រាសចាកឆន្ទរាគ ដល់នូវបទគឺព្រះនិព្វាន ជាធម្មជាតមិនស្លាប់ ចេញចាកវានៈគឺតណ្ហា ជាធម្មជាតស្ងប់ មិនច្យុត ។ កាយមានជើងពីរនេះ មិនស្អាត មានក្លិនអសោចិ៍ ពេញដោយសាកសពផ្សេង ៗ ហូរចេញអំពីទ្វារនោះ ៗ ។

បុគ្គលណា មានកាយមានសភាពដូច្នេះ ហើយលើកដំកើងខ្លួនឯងមើលងាយបុគ្គលដទៃ ( បុគ្គលនោះ ) គ្មានធម្មជាតអ្វី ក្រៅអំពីការមិនឃើញ ( នូវអរិយ-សច្ចៈ៤ ) ។

ចប់ វិជយសូត្រ ទី ១១ ។

## ទ្វាទសមំ មុនិសុត្តំ

(៦០) សន្ថវាតោ ភយំ ជាតំ និកេតា ជាយតេ រជោ

អនិកេតមសន្ថវំ ឯតំ វេ មុនិទស្សនំ ។

យោ ជាតមុច្ឆិជ្ជ ន រោបយេយ្យ

ជាយន្តមស្ស នានុប្បវេច្ឆេ

តមាហុ ឯកំ មុនិនំ ចរន្តំ

អទក្ខិ សោ សន្តិបទំ មហេសិ ។

សង្ខាយ វត្ថូនិ បមាយ ពីជំ

សិនេហមស្ស នានុប្បវេច្ឆេ

ស វេ មុនិ ជាតិក្ខយន្តទស្សី

តក្កំ បហាយ ន ឧបេតិ សង្ខំ ។

# មុនិសូត្រ ទី ១២

(២០) ភ័យកើតអំពីសេចក្ដីស្និទ្ធស្នាល ធូលីគឺរាគៈជាដើម កើតអំពីលំនៅ គឺរូបនិមិត្តជាដើម ការមិនមានលំនៅ និងការមិនមានសេចក្ដីស្និទ្ធស្នាលនុ៎ះឯង ជាការឃើញរបស់មុនី (អ្នកប្រាជ្ញ) ។

បុគ្គលណា បានផ្ដាច់បង់នូវកិលេសដែលកើតហើយ មិនបណ្ដុះកិលេសដែលកំពុងកើត មិនប្រមូលមក (នូវបច្ច័យ) នៃកិលេសនោះ អ្នកប្រាជ្ញហៅបុគ្គលនោះ ថាជាបុគ្គលមានប្រយោជន៍ ប្រសើរក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយកំពុងប្រព្រឹត្ត បុគ្គលនោះ ស្វែងរក (នូវខន្ធមានសីលក្ខន្ធជាដើម) បានឃើញហើយ នូវចំណែកនៃសន្តិភាព ។

បុគ្គលណា ពិចារណាឃើញទីកើត (នៃកិលេស) ទាំងឡាយ ហើយលះបង់ពូជ មិនប្រមូលមកនូវជ័រគឺតណ្ហា និងទិដ្ឋិ បុគ្គលនោះឯងជាមុនីឃើញនូវទីបំផុតនៃការអស់ជាតិ លះបង់នូវអកុសលវិតក្ក មិនដល់នូវកិរិយារាប់ (ថាជាអ្នកត្រេកអរ ឬប្រទូស្តឡើយ) ។

អញ្ញាយ សព្វានិ និវេសនានិ
អនិកាមយំ អញ្ញតរម្បិ តេសំ
ស វេ មុនិ វីតគេធោ អគិទ្ធោ
នាយូហតី បារគតោ ហិ ហោតិ ។

សព្វាភិភុំ សព្វវិទុំ សុមេធំ
សព្វេសុ ធម្មេសុ អនូបលិត្តំ
សព្វញ្ជហំ តណ្ហក្ខយេ វិមុត្តំ
តំ វាបិ ធីរា មុនិ វេទយន្តិ ។

បញ្ញាពលំ សីលវតូបបន្នំ
សមាហិតំ ឈានរតំ សតីមំ
សង្គា បមុត្តំ អខិលំ អនាសវំ
តំ វាបិ ធីរា មុនិ វេទយន្តិ ។

ឯកំ ចរន្តំ មុនិ អប្បមត្តំ
និន្ទាបសំសាសុ អវេធមានំ

បុគ្គលណា ដឹងច្បាស់នូវលំនៅ គឺភពទាំងអស់ មិនប្រាថ្នាលំនៅទាំងនោះទៀត សូម្បីលំនៅណាមួយ បុគ្គលនោះជាមុនី មានសេចក្តីប្រាថ្នាទៅប្រាសហើយ ជាអ្នកលែងប្រាថ្នា មិនប្រមូលមក ( នូវកម្មជាកុសលឬ អកុសល ) ព្រោះជាអ្នកដល់នូវត្រើយគឺព្រះនិព្វាន ។

អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់នូវបុគ្គលនោះអ្នកគ្របសង្កត់នូវធម៌ទាំងពួង ដឹងច្បាស់នូវធម៌ទាំងពួងមានបញ្ញាល្អ មិនជាប់ក្នុងពួកធម៌ទាំងពួង លះបង់នូវធម៌ទាំងពួង រួចស្រឡះព្រោះអស់ទៅនៃតណ្ហា ថាជា មុនី ។

អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់ នូវបុគ្គលនោះ អ្នកមានកំឡាំងគឺប្រាជ្ញា ប្រកបដោយសីលវ័ត មានចិត្តដំកល់មាំ ត្រេកអរក្នុងឈាន មានស្មារតី រួចចាកធម៌ជាគ្រឿងជាប់ មិនរឹងរូស មិនមានអាសវៈ ថាជា មុនី ។

អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់ នូវបុគ្គលនោះ ជាបុគ្គលឯក ត្រាច់ទៅ ជាអ្នកស្ងៀម (១) មិនប្រមាទ មិនញាប់ញ័រ ក្នុងសេចក្តីនិន្ទានិងសរសើរ

១. ព្រោះប្រកបមោនេយ្យធម៌ ។

សីហំវ សទ្ទេសុ អសន្តសន្តំ
វាតំវ ជាលម្ហិ អសជ្ជមានំ
បទុមំវ តោយេន អលិម្បមានំ
នេតារមញ្ញេសមនញ្ញនេយ្យំ
តំ វាបិ ធីរា មុនិំ វេទយន្តិ ។
យោ ឱគហណេ ថម្ភោរិវាភិជាយតិ
យស្មឹ បរេ វាចាបរិយន្តំ វទន្តិ
តំ វីតរាគំ សុសមាហិតិន្ទ្រិយំ
តំ វាបិ ធីរា មុនិំ វេទយន្តិ ។
យោ វេ ឋិតត្តោ តសរំវ ឧជ្ជុ
ជិគុច្ឆតិ កម្មេហិ បាបកេហិ
វីមំសមានោ វិសមំ សមញ្ច
តំ វាបិ ធីរា មុនិំ វេទយន្តិ ។
យោ សញ្ញតត្តោ ន ករោតិ បាបំ
ទហរោ ច មជ្ឈោ ច មុនី យតត្តោ

ដូចជាសត្វសីហៈ មិនតក់ស្លុតព្រោះសំឡេង មិនជាប់ក្នុងសំណាញ់ គឺតណ្ហានិងទិដ្ឋិ ដូចជាខ្យល់មិនជាប់ក្នុងសំណាញ់ មិនប្រឡាក់ដោយលោក ព្រោះគ្រឿងប្រឡាក់គឺតណ្ហានិងទិដ្ឋិ ដូចផ្កាឈូកមិនប្រឡាក់ដោយទឹក ជាអ្នកដឹកនាំគេ មនុស្សដទៃមិនគប្បីនាំទៅបាន ថាជា មុនី ។

ជនទាំងឡាយដទៃ តែងពោលនូវវាចាមានទីបំផុតដោយជុំវិញ ចំពោះវត្ថុណា បុគ្គលណា (មិនដល់នូវសេចក្តីត្រេកអរឬតូចចិត្តក្នុងវត្ថុនោះ) ដូចជាសសរ ដែលបុគ្គលជាប់ចុះក្នុងកំពង់សម្រាប់ងូត អ្នកប្រាជ្ញទាំងឡាយដឹងច្បាស់នូវបុគ្គលនោះ អ្នកមានរាគៈទៅប្រាសហើយ មានឥន្ទ្រិយតម្កល់មាំល្អហើយ ថាជា មុនី ។ បុគ្គលណា មានខ្លួនបិតនៅត្រង់ដូចជាខ្នារ កាលពិចារណាឃើញការពុំបសាទនិងការពេបសា តែងខ្ពើមកម្មទាំងឡាយដ៏លាមក អ្នកប្រាជ្ញទាំងឡាយ ដឹងបុគ្គលនោះថាជា មុនី ។

បុគ្គលណា មានខ្លួនសង្រួមហើយមិនធ្វើបាប ទោះនៅក្មេងក្តីកណ្តាលក្តី ជាមុនីមានខ្លួនវៀរចាកបាបហើយ

សុត្តនិបាតេ ឧរគវគ្គស្ស ទ្វាទសមំ មុនិសុត្តំ

អរោសនេយ្យោ ន រោសេតិ កញ្ចិ
តំ វាបិ ធីរា មុនិំ វេទយន្តិ ។
យទគ្គតោ មជ្ឈតោ សេសតោ វា
បិណ្ឌំ លភេថ បរទត្តូបជីវី
នាលំ ថុតុំ នោបិ និបច្ចវាទី
តំ វាបិ ធីរា មុនិំ វេទយន្តិ ។
មុនឹ ចរន្តំ វិរតំ មេថុនស្មា
យោ យោព្វនេ ន ឧបនិពជ្ឈតេ(១)ក្វចិ
មទប្បមាទា វិរតំ វិប្បយុត្តំ
តំ វាបិ ធីរា មុនិំ វេទយន្តិ ។
អញ្ញាយ លោកំ បរមត្ថទស្សឹ
ឱឃំ សមុទ្ទំ អតិតរិយ តាទឹ
តំ ឆិន្នគន្ថំ អសិតំ អនាសវំ
តំ វាបិ ធីរា មុនិំ វេទយន្តិ ។

---

១ ខុ. ន ឧបនិពជ្ឈតេ ។ ម. នោបនិពជ្ឈតេ ។

ជាបុគ្គលមិនមានការបៀតបៀន មិនប្រទូស្តនូវបុគ្គលណាមួយ អ្នកប្រាជ្ញទាំងឡាយ រមែងដឹងច្បាស់នូវបុគ្គលនោះថាជា មុនី ។

បុគ្គលណា បិញ្ចឹមជីវិតដោយបុគ្គលដទៃឲ្យ បាននូវដុំបាយណា ទោះដើមក្តី កណ្តាលក្តី សេសសល់ក្តី មិនសរសើរ មិនបន្តុះបង្អាប់ អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់នូវបុគ្គលនោះថាជា មុនី ។

បុគ្គលណា មិនជាប់នៅក្នុងវ័យណាមួយ អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់នូវបុគ្គលនោះ ដែលជាអ្នកស្ងៀម ប្រព្រឹត្តវៀរមេថុនធម្ម វៀរស្រឡះចាកសេចក្តីស្រវឹងនឹងសេចក្តីប្រមាទ រួចចាកបំណង គឺកិលេស ថាជា មុនី ។

អ្នកប្រាជ្ញទាំងឡាយ ដឹងច្បាស់ នូវបុគ្គលនោះ អ្នកឃើញនូវបរមត្ថ ព្រោះដឹងច្បាស់នូវលោក ប្រព្រឹត្តកន្លងនូវអន្លង់នឹងសមុទ្រ មិនញាប់ញ័រ កាត់ផ្តាច់នូវគ្រឿងចាក់ស្រែះ មិនអាស្រ័យនូវតណ្ហានិងទិដ្ឋិ មិនមានអាសវៈ ថាជា មុនី ។

អសមា ឧភោ ទូរវិហារវុត្តិនោ
គិហី ទារបោសី អមមោ ច សុព្វតោ
បរបាណរោធាយ គិហី អសញ្ញតោ
និច្ចំ មុនី រក្ខតិ បាណិនេ យតោ ។
សិខី យថា នីលគីវោ វិហង្គមោ
ហំសស្ស នោបេតិ ជវំ កុទាចនំ
ឯវំ គិហី នានុករោតិ ភិក្ខុនោ
មុនិនោ វិវិត្តស្ស វនម្ហិ ឈាយតោតិ ។

មុនិសុត្តំ ទ្វាទសមំ ។

ឧរគវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ឧរគោ ធនិយោ ខគ្គ- វិសាណោ កសិ ចុន្ទ ច
បរាភវេ វសលោ មេត្ត ហេមវតាឡវកោ អថ
វិជយំ មុនី ឧរគ វគ្គំ វឌ្ឍិ ពារស(១) ។

---

១ ឱ. ឧរគោ ធនិយោ ចេវ វិសាណញ្ច តថា កសិ
ចុន្ទោ បរាភវោ ចេវ វសលោ មេត្តភាវនា
សាតាគិរោ អាឡវកោ វិជយោ ច តថា មុនិ
ទ្វាទសេតានិ សុត្តានិ ឧរគវគ្គោតិ វុច្ចតីតិ ។

ជនទាំងពីរនោះ មានការនៅនិងការចិញ្ចឹមជីវិត ឆ្ងាយគ្នា មិនស្មើគ្នាទេ គឺគ្រហស្ថជាអ្នកចិញ្ចឹមប្រពន្ធ ១ អ្នកបួសមិនប្រកាន់ខ្លួន ជាអ្នកមានវត្តល្អ ១ គ្រហស្ថមិនបានសង្រួមក្នុងការបៀតបៀនជីវិតសត្វដទៃ មុនីសង្រួម រក្សានូវពួកសត្វអស់កាលជានិច្ច ។ ដូចជាសត្វក្ងោកមានករខៀវ ហើរតាមអាកាស មិនដល់នូវសន្ទុះរបស់ហង្ស ក្នុងកាលណា ៗ ឡើយ គ្រហស្ថក៏យ៉ាងនោះដែរ នឹងធ្វើតាមភិក្ខុជាមុនី អ្នកស្ងប់ស្ងាត់ អ្នកចំរើនឈានក្នុងព្រៃ មិនបាន ។

ចប់ មុនិសូត្រទី ១២ ។

ចប់ ឧរគវគ្គ ទី ១ ។

## ឧទ្ទាននៃឧរគវគ្គនោះគឺ

និយាយអំពីការប្រៀបដោយសត្វពស់ ១ ធនិយគោបាល ១ បុគ្គលប្រៀបដោយកុយរមាស ១ កសិភារទ្វាជព្រាហ្មណ៍ ១ ចុន្ទ ១ សេចក្តីវិនាស ១ បុគ្គលថោកទាប ១ មេត្តា ១ ហេមវតយក្ស ១ អាឡវកយក្ស ១ អំពីការលះ ១ មុនី ១ រួមជា ១២ ហៅថា ឧរគវគ្គ ។

## ទុតិយោ ចូឡវគ្គោ

### បឋមំ រតនសុត្តំ

(២១) យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ វ អន្តលិក្ខេ
សព្វេវ ភូតា សុមនា ភវន្តុ
អថោបិ សក្កច្ច សុណន្តុ ភាសិតំ ។
តស្មា ហិ ភូតា និសាមេថ សព្វេ
មេត្តំ ករោថ មានុសិយា បជាយ
ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ
តស្មា ហិ នេ រក្ខថ អប្បមត្តា ។
យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា
សគ្គេសុ វា យំ រតនំ បណីតំ
ន នោ សមំ អត្ថិ តថាគតេន
ឥទម្បិ ពុទ្ធេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។

# ចូឡវគ្គ ទី ២

## រតនសូត្រ ទី ១

(៤១) ពួកភូត (១) ណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅក្នុងអាកាសក្តី ដែលមកប្រជុំ ក្នុងទីនេះ សូមពួកសត្វទាំងអស់នោះ មានចិត្តល្អ មួយទៀត ចូរស្តាប់នូវភាសិតដោយគោរព ។ ព្រោះហេតុនោះ អ្នកទាំងឡាយ ជាភូតទាំងអស់ ចូរស្តាប់ ចូរផ្សាយនូវមេត្តាចិត្ត ក្នុងពួកសត្វជាមនុស្សជាតិ ពួកមនុស្សណា នាំនូវពលិកម្ម ក្នុងវេលាថ្ងៃឬវេលាយប់ ព្រោះហេតុនោះ សូមអ្នកទាំងឡាយកុំប្រហែស ចូររក្សានូវមនុស្សទាំងនោះ ។ ទ្រព្យជាទីគាប់ចិត្តណាមួយ ក្នុងលោកនេះ ឬក្នុងលោកដទៃ រតនៈដ៏ឧត្តមណាក្នុងស្ថានសួគ៌ក្តី (ទ្រព្យនិងរតនៈទាំងនោះ) ស្មើដោយព្រះតថាគតមិនមានឡើយ រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

---

១- ចូរមើលតាមនយលក្ខណៈ ត្រង់សម្មាទិដ្ឋិសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសក - បឋមភាគ ២០ ។

ខយំ វិរាគំ អមតំ បណីតំ
យទជ្ឈគា សក្យមុនី សមាហិតោ
ន តេន ធម្មេន សមត្ថិ កិញ្ចិ
ឥទម្បិ ធម្មេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យម្ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ
សមាធិមានន្តរិកញ្ញមាហុ
សមាធិនា តេន សមោ ន វិជ្ជតិ
ឥទម្បិ ធម្មេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យេ បុគ្គលា អដ្ឋសតំ បសដ្ឋា(១)
ចត្តារិ ឯតានិ យុគានិ ហោន្តិ
តេ ទក្ខិណេយ្យា សុគតស្ស សាវកា
ឯតេសុ ទិន្នានិ មហប្ផលានិ
ឥទម្បិ សង្ឃេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។

---

១ ម. បសត្ថា ។

ព្រះសក្យមុនី មានព្រះហឫទ័យដម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ណា ជាគ្រឿងក្ស័យកិលេស ប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ឧត្តម របស់អ្វីមួយស្មើដោយព្រះធម៌នោះមិនមានឡើយ រតនៈគឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ៗ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ៗ

ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរនូវសមាធិណា ថាជាសមាធិស្អាត បណ្ឌិតទាំងឡាយ ពោលនូវសមាធិណា ថាជាធម៌ ឲ្យនូវផលដោយលំដាប់ សមាធិដទៃស្មើដោយសមាធិនោះមិនមានឡើយ រតនៈគឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ៗ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ៗ

បុគ្គលទាំងឡាយណា ៨ពួក ដែលសប្បុរសទាំងឡាយសរសើរហើយ រាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវ័ករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយ ដែលបុគ្គលឲ្យហើយ ចំពោះបុគ្គលទាំងនោះ ជាទានមានផលច្រើន រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ៗ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ៗ

សុត្តនិបាតេ ទុតិយស្ស ចូឡវគ្គស្ស បឋមំ រតនសុត្តំ

យេ សុប្បយុត្តា មនសា ទឡ្ហេន
និក្ខាមិនោ គោតមសាសនម្ហិ
តេ បត្តិបត្តា អមតំ វិគយ្ហ
លទ្ធា មុធា និព្វុតឹ ភុញ្ជមានា
ឥទម្បិ សង្ឃេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យថិន្ទខីលោ បថវឹ សិតោ សិយា
ចតុព្ភិ វាតេភិ អសម្បកម្បិយោ
តថូបមំ សប្បុរិសំ វទាមិ
យោ អរិយសច្ចានិ អវេច្ច បស្សតិ
ឥទម្បិ សង្ឃេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យេ អរិយសច្ចានិ វិភាវយន្តិ
គម្ភីរបញ្ញេន សុទេសិតានិ

អរិយបុគ្គលទាំងឡាយណា ក្នុងសាសនា នៃព្រះគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន មិនមានសេចក្តីប្រាថ្នា អរិយបុគ្គលទាំងឡាយនោះ ដល់ហើយនូវព្រះអរហត្តផល ហើយចូលទៅកាន់ព្រះនិព្វាន បាននូវការរលត់កិលេសដោយទទេ គឺឥតមានទិញដូរឡើយ ហើយសោយ (នូវផល) រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

សសរខឿន ដែលគេបោះភ្ជាប់ទីនឹងផែនដី ជារបស់មិនកម្រើកដោយខ្យល់ព្យុះដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ បុគ្គលណាពិចារណាឃើញជាក់នូវអរិយសច្ចទាំងឡាយ តថាគតហៅអ្នកនោះថាជាសប្បុរស (មិនញាប់ញ័រ) ក៏យ៉ាងនោះដែរ រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

អរិយបុគ្គលទាំងឡាយណា ធ្វើឲ្យជាក់ច្បាស់នូវអរិយ-សច្ច ដែលព្រះតថាគត មានប្រាជ្ញាដ៏ជ្រៅ សំដែងល្អហើយ

កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា
ន តេ ភវំ អដ្ឋមមាទិយន្តិ
ឥទម្បិ សង្ឃេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
សហាវស្ស ទស្សនសម្បទាយ
តយស្សុ ធម្មា ជហិតា ភវន្តិ
សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច
សីលព្វតំ វាបិ យទត្ថិ កិញ្ចិ
ចតូហបាយេហិ ច វិប្បមុត្តោ
ឆ ចាភិឋានានិ(១) អភព្វោ កាតុំ
ឥទម្បិ សង្ឃេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ
កាយេន វាចាយុទ ចេតសា វា
អភព្វោ សោ តស្ស បដិច្ឆទាយ
អភព្វតា ទិដ្ឋបទស្ស វុត្តា

---
១ ម. ឆច្ចាភិឋានានិ ។

អរិយបុគ្គលទាំងនោះ ទុកជាប្រមាទដ៏លើសលប់ ក៏ដោយ អរិយបុគ្គលទាំងនោះ នឹងមិនកាន់យកនូវភពជាគំរប់ ៨ (គឺមិនកើតទៀតហួសពី៧ជាតិឡើយ) រតនៈគឺព្រះសង្ឃនេះឯងជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ធម៌ ៣ គឺ សក្កាយទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាស, ឬការប្រព្រឹត្តតាមណាមួយ ដែលសោតាបន្នបុគ្គលនោះបានលះបង់ហើយ ជាមួយនឹងទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ មួយវិញទៀតសោតាបន្នបុគ្គលបានរួចស្រឡះចាកអបាយទាំង ៤ហើយ មិនគួរធ្វើនូវអភិឋាន៦គឺអនន្តរិយកម្ម៥នឹងការងាកចិត្ត ទៅកាន់សាសនាដទៃឡើយ រតនៈគឺព្រះសង្ឃនេះឯងជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ទុកជាសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្ម ដោយកាយវាចាឬក៏ដោយចិត្ត (ព្រោះសេចក្តីភ្លាំងភ្លាត់) សោតា·បន្នបុគ្គលនោះ មិនគួរបិទបាំងនូវបាបកម្មនោះឡើយ ព្រោះភាពនៃបុគ្គលដែលឃើញនូវព្រះនិព្វានហើយ ជាបុគ្គលមិនគួរបិទបាំងនូវបាបកម្ម ដែលព្រះពុទ្ធទាំងឡាយសំដែងហើយ

សុត្តនិបាតេ ទុតិយស្ស ចូឡវគ្គស្ស បឋមំ រតនសុត្តំ

ឥទម្បិ សង្ឃេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
វនប្បគុម្ពេ យថា ផុស្សិតគ្គេ
គិម្ហានមាសេ បឋមស្មឹ គិម្ហេ
តថូបមំ ធម្មវរំ អទេសយិ
និព្វានគាមឹ បរមំ ហិតាយ
ឥទម្បិ ពុទ្ធេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
វរោ វរញ្ញូ វរទោ វរាហរោ
អនុត្តរោ ធម្មវរំ អទេសយិ
ឥទម្បិ ពុទ្ធេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
ខីណំ បុរាណំ នវំ នត្ថិ សម្ភវំ
វិរត្តចិត្តាយតិកេ(១) ភវស្មឹ
តេ ខីណពីជា អវិរុឡ្ហិច្ឆន្ទា
និព្វន្តិ ធីរា យថាយម្បទីបោ

---

១ ឱ វិរត្តចិត្តា អាយតិកេ ។

រតនៈគឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យ
សច្ចៈនេះ សូមសួស្តីកើតមាន ។

គុម្ពឈើក្នុងព្រៃមានត្រួយលូតលាស់ ក្នុងខាងដើមគិម្ហៈ
រដូវគឺខែក្តៅយ៉ាងណាមិញ ព្រះពុទ្ធបានសំដែងហើយនូវធម៌ដ៏
ប្រសើរ ជាធម៌អាចញុំាងសត្វទាំងឡាយ ឲ្យដល់នូវព្រះនិព្វាន
ដើម្បីប្រយោជន៍ដ៏ឧត្តម ក៏យ៉ាងនោះឯង រតនៈគឺព្រះពុទ្ធនេះឯង
ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ
ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ ព្រះអង្គ
ប្រសើរ មិនមានអ្នកណាជាង ទ្រង់សំដែងនូវធម៌ដ៏ប្រសើរ
រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យ
សច្ចៈនេះ សូមសួស្តីកើតមាន ។

កម្មចាស់ អស់ហើយ កម្មថ្មី រមែងមិនកើតប្រាកដ
អរិយបុគ្គលទាំងឡាយណា មានចិត្តនឿយណាយ ក្នុងភព
តទៅ អរិយបុគ្គលទាំងនោះមានពូជអស់ហើយ មានឆន្ទៈ
គឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះឡើងឡើយ ជាអ្នកមាន
ប្រាជ្ញាតែងរលត់ទៅ ដូចជាប្រទីប ( ដែលរលត់ )

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស សុត្តនិបាតោ

ឥទម្បិ សង្ឃេ រតនំ បណីតំ ។
ឯតេន សច្ចេន សុវត្ថិ ហោតុ ។
យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិវ អន្តលិក្ខេ
តថាគតំ ទេវមនុស្សបូជិតំ
ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ ។
យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិវ អន្តលិក្ខេ
តថាគតំ ទេវមនុស្សបូជិតំ
ធម្មំ នមស្សាម សុវត្ថិ ហោតុ ។
យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិវ អន្តលិក្ខេ
តថាគតំ ទេវមនុស្សបូជិតំ
សង្ឃំ នមស្សាម សុវត្ថិ ហោតូតិ ។

រតនសុត្តំ ចប់ ។

តេនៈគឺព្រះសង្ឃនេះឯង ជាតេនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណាឋិតនៅក្នុងអាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការទៅព្រះពុទ្ធ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតានិងមនុស្ស បូជាហើយ សូមសួស្តីកើតមាន ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណា ឋិតនៅក្នុងអាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការទៅព្រះធម៌ ដែលមានមកហើយដូចគ្នា ដែលទេវតានិងមនុស្ស បូជាហើយ សូមសួស្តីកើតមាន ។

ពួកភូតណា ឋិតនៅលើផែនដីក្តី ពួកភូតណាឋិតនៅក្នុងអាកាសក្តី ដែលមកប្រជុំគ្នា ក្នុងទីនេះ យើងទាំងឡាយ សូមនមស្ការទៅព្រះសង្ឃ ដែលមានមកហើយដូចគ្នា ដែលទេវតានិងមនុស្ស បូជាហើយ សូមសួស្តីកើតមាន ។

ចប់ រតនសូត្រ ទី ១ ។

# ទុតិយំ អាមគន្ធសុត្តំ

(២២) សាមាកចិង្គូលកចីនកានិ(១) ច
បត្តប្ផលំ មូលប្ផលំ គវិប្ផលំ
ធម្មេន លទ្ធំ សតមស្នមានា(២)
ន កាមកាមា អលិកំ ភណន្តិ ។
យទស្នមានោ(៣) សុកតំ សុនិដ្ឋិតំ
បរេហិ ទិន្នំ បយតំ បណីតំ
សាលីនមន្នំ បរិភុញ្ជមានោ
សោ ភុញ្ជសី កស្សប អាមគន្ធំ ។
ន អាមគន្ធោ មម កប្បតីតិ
ឥច្ចេវ ត្វំ ភាសសិ ព្រហ្មពន្ធុ
សាលីនមន្នំ បរិភុញ្ជមានោ
សកុន្តមំសេហិ សុសង្ខតេហិ ។

---

១ ឱ. ចិង្គុលក ។ ២ ឱ. សតមញ្ញមានា ។ ម. សតមស្នមានា ។ ៣ ឱ. យទញ្ញមានោ ។ ម. យទស្នមានោ ។

# អាមគន្ធសូត្រ ទី ២

(២២) សប្បុរស កាលបរិភោគនូវស្រូវស្រងែ ស្រូវកន្ទុយដ៏ទៃទៀតសណ្តែកព្រៃ បត្តផល(១) មូលផល(២)និងគរិផល(៣) ដែលបានមកដោយធម៌ មិនពោលពាក្យកុហក ព្រោះសេចក្តីប្រាថ្នានូវកាមទេ ។

បពិត្រកស្សបៈ លោកនោះ កាលបរិភោគនូវសាច់ណាមួយ ដែលបុគ្គលធ្វើហើយដោយល្អ សម្រេចហើយដោយល្អ តាក់តែងហើយដ៏ឧត្តម ដែលជនទាំងឡាយដទៃឲ្យហើយ កាលបរិភោគនូវបាយស្រូវសាលី ឈ្មោះថា បរិភោគនូវវត្ថុមានក្លិនឆ្អាប ។

ម្នាលព្រហ្មពន្ធុ លោកកាលបរិភោគនូវបាយនៃស្រូវសាលីទាំងឡាយ ដោយសាច់នៃសត្វស្លាប ដែលបុគ្គលតាក់តែងល្អហើយ ពោលយ៉ាងនេះថា វត្ថុមានក្លិនឆ្អាបមិនគួរដល់អាត្មាអញ ។

---

១ សំដៅយកផ្លែឈើទុំ ។ ២ សំដៅយកមើមនឹងផ្លែឈើវល្លិ ។ ៣ សំដៅយកផ្លែឈើដែលជ្រុះក្នុងទឹកមានក្រហាប់ផាដើម ។ (អដ្ឋកថា) ។

បុច្ឆាមិ តំ កស្សប ឯតមត្ថំ
កថំ បការោ តវ អាមគន្ធោ ។
បាណាតិបាតោ វធឆេទពន្ធនំ
ថេយ្យំ មុសាវាទោ និកតិវញ្ចនានិ ច
អជ្ឈេនកុត្តំ(១) បរទារសេវនា
ឯសាមគន្ធោ ន ហិ មំសភោជនំ ។
យេ ឥធ កាមេសុ អសញ្ញតា ជនា
រសេសុ គិទ្ធា អសុចីភាវមស្សិតា(២)
នត្ថីកទិដ្ឋី វិសមា ទុរន្នយា
ឯសាមគន្ធោ ន ហិ មំសភោជនំ ។
យេ លូខសា(៣) ទារុណា(៤) បិដ្ឋិមំសិកា
មិត្តទ្ទុនោ(៥) និក្ករុណាតិមានិនោ
អទានសីលា ន ច ទេន្តិ កស្សចិ
ឯសាមគន្ធោ ន ហិ មំសភោជនំ ។

១ ឱ. អជ្ឈេន កុជ្ជំ ។ ២ ម. អសុចិភាវមស្សិតា ។ ៣ ម. លូខរសា ។ ៤ ឱ. ម. ទារុណា ។
៥ អដ្ឋ. មិត្តទ្ទុតិនោ ។

បពិត្រព្រះកស្សប ខ្ញុំនឹងសួរនូវសេចក្តីនុ៎ះនឹងលោក វត្ថុមានក្លិនឆ្អាបរបស់លោកមានប្រការដូចម្តេច ។ ការសម្លាប់សត្វ វាយ កាត់ ចង លួច ពោលពាក្យកុហក បោកប្រាស បញ្ឆោត រៀនក្បួនឥតប្រយោជន៍ សេពភរិយារបស់បុគ្គលដទៃ នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ជនទាំងឡាយណា ក្នុងលោកនេះ មិនសង្រួមក្នុងកាមទាំងឡាយ ជាអ្នកប្រាថ្នា ញ៉ាមជ្រប់ក្នុងរស ច្របូកច្របល់ ដោយភាពមិនស្អាតគឺមិច្ឆាជីវៈ ជានត្ថិកទិដ្ឋិ មានកាយកម្មជាដើម មិនរាបសា ឲ្យដឹងបានដោយក្រ នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ជនទាំងឡាយណា ជាអ្នកប្រាថ្នាចំពោះវត្ថុដ៏សៅហ្មង ជាអ្នករឹងរូស ស៊ីសាច់ខ្នង (១) ទ្រុស្តមិត្ត មិនមានអាណិត ប្រកាន់ខ្លួន មិនឲ្យទានជាប្រក្រតី មួយទៀតមិនដែលឲ្យវត្ថុអ្វីដល់អ្នកណាមួយ នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។

---

១ ចំពោះមុខល្អ កំបាំងមុខអាក្រក់ ។

សុត្តនិបាតេ ទុតិយស្ស ចូឡវគ្គស្ស ទុតិយំ អាមគន្ធសុត្តំ

កោធោ មទោ ថម្ភោ បច្ចុដ្ឋាបនា ច
មាយា ឧសូយា ភស្សសមុស្សយោ ច
មានាតិមានោ ច អសព្ភិ សន្ថវោ
ឯសាមគន្ធោ ន ហិ មំសភោជនំ ។
យេ បាបសីលា ឥណឃា ច(១)សូចកា
វោហារកូដា ឥធ បាដិរូបិកា
នរាធមា យេធ ករោន្តិ កិព្ពិសំ
ឯសាមគន្ធោ ន ហិ មំសភោជនំ ។
យេ ឥធ បាណេសុ អសញ្ញតា ជនា
បរេសមាទាយ វិហេសមុយ្យុតា
ទុស្សីលលុទ្ទា ផរុសា អនាទរា
ឯសាមគន្ធោ ន ហិ មំសភោជនំ ។

១ ម. ឥណឃាតសូចកា ។

សេចក្តីក្រោធ ស្រវឹង រឹងត្អឹង បង្កហេតុ បិទបាំងទោស ប្រណែន លើកខ្លួន ប្រកាន់ខ្លួន មើលងាយគេ ស្និទ្ធស្នាលដោយពួកអសប្បុរស នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ពួកជនណា មានបាបជាប្រក្រតី ចំពាក់បំណុលគេ និយាយចាក់ដោតគេ កោងដោយវោហារ ទ្រុស្តសីល ក្នុងសាសនានេះ ជាជនអាក្រក់ ជនណាធ្វើអំពើអាក្រក់ ក្នុងលោកនេះ នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ ពួកជនណា ក្នុងលោកនេះ ជាអ្នកមិនសង្រួម ក្នុងសត្វទាំងឡាយ កាន់យកទ្រព្យនៃបុគ្គលដទៃ ប្រកបខាងការបៀតបៀន ជាអ្នកទ្រុស្តសីល ជាព្រាន សំដីអាក្រក់ មិនអើពើ នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។ សត្វទាំងឡាយណា ជាប់ចំពាក់ក្នុងពួកសត្វទាំងនេះ ជាអ្នកខឹង អ្នកសម្លាប់ ប្រកបក្នុងអកុសលជានិច្ច លះលោកនេះ ទឹងទៅកាន់លោកងងឹត មានក្បាលសំយុងចុះទៅនរក នេះហៅថា វត្ថុមានក្លិនឆ្អាប មិនសំដៅយកការបរិភោគសាច់ទេ ។

ឯតេសុ គិទ្ធា វិរុទ្ធាតិបាតិនោ
និច្ចុយ្យុតា បេច្ច តមំ វជន្តិ យេ
បតន្តិ សត្តា និរយំ អវំសិរា
ឯសាមគន្ធោ ន ហិ មំសភោជនំ ។
ន មច្ឆមំសំ នានាសកត្តំ (១)
ន នគ្គិយំ (ន មុណ្ឌិយំ ជដា ជល្លំ
ខរាជិនានិ) នាគ្គិហុត្តស្សុបសេវនា (២)
យេ វាបិ លោកេ អមរា ពហូ តបា
មន្តាហុតី យញ្ញមុតូបសេវនា
សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។
យោ តេសុ គុត្តា វិទិតិន្ទ្រិយោ ចរេ (៣)
ធម្មេ ឋិតោ អជ្ជវមទ្ទវេ រតោ
សង្គាតិគោ សព្វទុក្ខប្បហីនោ
ន លិម្បតិ ទិដ្ឋសុតេសុ ធីរោ ។

---

១ ម. ន មច្ឆមំសា ន នាសកត្តំ ។ ២ ឱ. ន នគ្គិយំ មុណ្ឌិយំ ជដា ជល្លំ ខរាជិនានិ វា នាគ្គិហុត្តស្សុបសេវនា វា យា ។ ម. ន នគ្គិយំ ន មុណ្ឌិយំ ជដា រជោ ជល្លំ ខារាជិនានិ អគ្គិហុត្តស្សុបសេវនា ។ ៣ ឱ. វិជិតិន្ទ្រិយោ ។

ការមិនស៊ីត្រីនិងសាច់ មិនស៊ីបាយ អាក្រាត (កោរសក់ បួងសក់ លាបដោយភក់ ស្លៀកស្បែកខ្លាឃ្មុំ) សេពខាងការបំរើភ្លើង មួយទៀត អមរតបៈទាំងឡាយដ៏ច្រើន(១)ដែលមានក្នុងលោក វេទមន្ត ការបូជាភ្លើង បូជាយញ្ញ (មានអស្សមេធៈ) ជាដើម នឹងការសេព (នូវទីក្តៅក្នុងគិម្ហរដូវជាដើម) ទាំងនេះញុំាងសត្វដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យឲ្យស្អាតមិនបានទេ ។ បុគ្គលណាគ្រប់គ្រងក្នុងឥន្ទ្រិយទាំង ៦ នោះ ដឹងច្បាស់ឥន្ទ្រិយទាំង ៦ ហើយ គប្បីប្រព្រឹត្ត តាំងនៅក្នុងធម៌ ត្រេកអរ ក្នុងការទៀងត្រង់ នឹងសេចក្តីទន់ភ្លន់ កន្លងផុតគ្រឿងជំពាក់ លះបង់ទុក្ខទាំងអស់ មានប្រាជ្ញា មិនជាប់នៅ ក្នុងអារម្មណ៍ដែលខ្លួនឃើញដែលឮ ។

---

១– ការប្រព្រឹត្តិកំដៅសរីរៈដ៏ច្រើនប្រភេទមានព្យាយាមអង្គុយប្រហោងជាដើមដែលនាំឲ្យលំបាកកាយទទេ ប្រព្រឹត្តទៅព្រោះប្រាថ្នានូវភាពជាទេវតា ។ អដ្ឋកថា ។

ឥច្ចេតមត្ថំ ភគវា បុនប្បុនំ
អក្ខាសិ នំ វេទយិ មន្តបារគូ
ចិត្រាហិ គាថាហិ មុនិប្បកាសយិ
និរាមគន្ធោ អសិតោ ទុរន្នយោ ។
សុត្វាន ពុទ្ធស្ស សុភាសិតំ បទំ
និរាមគន្ធំ សព្វទុក្ខប្បនូទនំ
នីចមនោ វន្ទិ តថាគតស្ស
តត្ថេវ បព្វជ្ជមរោចយិត្ថាតិ ។

អាមគន្ធសុត្តំ ទុតិយំ ។

## តតិយំ ហិរិសុត្តំ

(២៣) ហិរិំ តរន្តំ វិជិគុច្ឆមានំ
សខាហមស្មិ(១) ឥតិ ភាសមានំ
សយ្ហានិ កម្មានិ អនាទិយន្តំ
នេសោ មមន្តិ ឥតិ នំ វិជញ្ញា ។

១ ម. តវាហមស្មិ ។

ព្រះមានព្រះភាគ បានត្រាស់សេចក្ដីនេះហើយ ៗ ដូច្នេះហើយ តិស្សព្រាហ្មណ៍អ្នកដល់នូវត្រើយនៃមន្ត ក៏ដឹងនូវសេចក្ដីនោះ ព្រះមុនីជាអ្នកមិនមានក្លិនឆ្អាបគឺកិលេស មិនអាស្រ័យតណ្ហាទិដ្ឋិ ឥតអ្នកណាមួយដឹកនាំឲ្យអាក្រក់បាន ទ្រង់ប្រកាសដោយគាថាទាំងឡាយ ដ៏វិចិត្រ ៗ ព្រាហ្មណ៍បានស្ដាប់បទសុភាសិត ដែលមិនមានក្លិនឆ្អាប ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងពួង របស់ព្រះពុទ្ធហើយ ក៏មានចិត្តទន់ទន លំទោន ថ្វាយបង្គំព្រះតថាគត សូមបព្វជ្ជាក្នុងទីនេះឯង ៗ

ចប់ អាមគន្ធសូត្រទី ២ ។

# ហិរិសូត្រ ទី ៣

[២៣] បណ្ឌិតបុរស គប្បីដឹងនូវបុគ្គលនោះ ដែលមិនមានសេចក្ដីអៀនខ្មាស មិនមានសេចក្ដីខ្ពើមរអើម និយាយថា ខ្ញុំជាសំឡាញ់(របស់អ្នក) មិនអើពើនឹងការងារទាំងឡាយ (របស់សំឡាញ់) ដែលខ្លួនអាចធ្វើបានថា បុគ្គលនោះមិនមែនជាមិត្តរបស់អញទេ ។

អនន្វយំ(១) បិយំ វាចំ យោ មិត្តេសុ បកុព្វតិ
អករោន្តំ ភាសមានំ បរិជានន្តិ បណ្ឌិតា ។

ន សោ មិត្តោ យោ សទា អប្បមត្តោ
ភេទាសង្កី រន្ធមេវានុបស្សី
យស្មិំ ច សេតិ ឧរសីវ(២) បុត្តោ
ស វេ មិត្តោ យោ បរេហិ អភេជ្ជោ ។

បាមុជ្ជករណំ ឋានំ បសំសាវហនំ សុខំ
ផលានិសំសោ ភាវេតិ វហន្តោ បោរិសំ ធុរំ ។
បវិវេករសំ បិត្វា រសំ ឧបសមស្ស ច
និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវន្តិ ។

ហិរិសុត្តំ តតិយំ ។

១ ម. អត្ថន្វយំ ។ ២ ម. ឧរសេវ ។

សុត្តនិបាត ចូឡវគ្គ ទី ២ ហិរិសូត្រ ទី ៣

បុគ្គលណា ពោលពាក្យជាទីស្រឡាញ់ ដែលខ្លួនមិនប្រព្រឹត្តតាម ចំពោះមិត្ត បណ្ឌិតទាំងឡាយ កំណត់ដឹង (នូវបុគ្គលនោះ) ថា គ្រាន់តែជាអ្នកនិយាយ តែមិនធ្វើ ។

បុគ្គលណា មិនប្រមាទសព្វកាល មានសេចក្តីរង្កៀស ក្នុងការបែកបាក់គ្នា ជាអ្នកឃើញរឿយៗនូវទោស បុគ្គលនោះមិនហៅថា មិត្តទេ លុះតែបុគ្គលណា ដែលបុគ្គលដទៃ បំបែកមិនបាន ដេកនៅ (ឥតរង្កៀស) ក្នុងមិត្តណា បុគ្គលនោះឯង ទើបហៅថាជាមិត្ត ។

បុគ្គលជាអ្នកប្រាថ្នានូវផល កាលនាំមកនូវធុរៈ ជារបស់បុរស រមែងញុំាងឋានៈ គឺព្យាយាម ជាទីធ្វើឲ្យកើតបាមោជ្ជៈ នាំមកនូវសេចក្តីសរសើរ ជាសុខ ឲ្យចំរើន បុគ្គលក្រេបផឹកនូវរស នៃសេចក្តីស្ងប់រម្ងាប់ផង នូវរសនៃព្រះនិព្វានជាទីចូលទៅរម្ងាប់ផង ផឹកនូវរសនៃបីតិ ដែលកើតអំពីអរិយធម៌ហើយ រមែងជាអ្នកមិនមានសេចក្តីក្រវល់ក្រវាយ មិនមានបាប ។

ចប់ ហិរិសូត្រ ទី ៣ ។

# បតុត្ថំ មង្គលសុត្តំ

(២៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ

(២៨) ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។
អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។

# មង្គលសូត្រ ទី ៤

(២៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះ-មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថ-បិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

គ្រានោះឯង ទេវតាអង្គ១ កាលវេលាពត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏រុងរឿង ញុំាំងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាង ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរនៅក្នុងទីសមគួរ ។ លុះទេវតានោះឈរ ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

(២៩) ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់សំដែងនូវមង្គលដ៏ឧត្តម ។

( ព្រះមានព្រះភាគទ្រង់សំដែងថា ) ការមិនសេពគប់បុគ្គលពាលទាំងឡាយ ១ ការសេពគប់បណ្ឌិតទាំងឡាយ ១ ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ (ទាំង ៣ ) នេះ ជាមង្គលដ៏ឧត្តម ។

បដិរូបទេសវាសោ ច   បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណិធិ ច   ឯតម្មង្គលមុត្តមំ ។
ពាហុសច្ចញ្ច សិប្បញ្ច   វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា   ឯតម្មង្គលមុត្តមំ ។
មាតាបិតុឧបដ្ឋានំ   បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា   ឯតម្មង្គលមុត្តមំ ។
ទានញ្ច ធម្មចរិយា ច   ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ   ឯតម្មង្គលមុត្តមំ ។
អារតី វិរតី បាបា   មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ   ឯតម្មង្គលមុត្តមំ ។
គារវោ ច និវាតោ ច   សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ   ឯតម្មង្គលមុត្តមំ ។

ការនៅក្នុងប្រទេសដ៏សមគួរ ១ ភាពនៃបុគ្គលបាន ធ្វើបុណ្យទុកក្នុងកាលមុន ១ ការដំកល់ខ្លួនដោយប្រពៃ ១ (ទាំង ៣) នេះ ជាមង្គលដ៏ឧត្តម ។

ពាហុសច្ចៈ ១ សិល្បសាស្ត្រ ១ វិន័យដែលសិក្សា ដោយប្រពៃ ១ វាចាដែលពោលត្រឹមត្រូវ ១ (ទាំង៤) នេះ ជាមង្គលដ៏ឧត្តម ។

ការបំរើមាតាបិតា១ សេចក្ដីសង្គ្រោះបុត្រនឹងភរិយា១ ការងារ ទាំងឡាយមិនច្របូកច្របល់១ (ទាំង៣) នេះ ជាមង្គលដ៏ឧត្តម ។

ទាន ១ ការប្រព្រឹត្តធម៌ ១ ការសង្គ្រោះពួកញាតិ ១ ការ ងារមិនមានទោស ១ (ទាំង ៤) នេះ ជាមង្គលដ៏ឧត្តម ។

ការមិនត្រេកអរ ក្នុងបាបនឹងការវៀរចាកបាប ១ សេចក្ដីសង្រួមចាកកិរិយាផឹកទឹកស្រវឹង ១ សេចក្ដីមិនប្រមាទ ក្នុងធម៌ទាំងឡាយ ១ (ទាំង៣) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ១ ការប្រ-ព្រឹត្តបន្ទាបខ្លួន ១ សេចក្ដីត្រេកអរចំពោះរបស់ដែលមាន ១ ភាពនៃបុគ្គលអ្នកដឹងឧបការគុណដែលអ្នកដទៃធ្វើដល់ខ្លួន ១ ការស្ដាប់ធម៌តាមកាល ១ (ទាំង ៥) នេះ ជាមង្គលដ៏ឧត្តម ។

ខន្តី ច សោវចស្សតា សមណានញ្ច ទស្សនំ

កាលេន ធម្មសាកច្ឆា ឯតំ មង្គលមុត្តមំ ។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ

និព្វានសច្ឆិកិរិយា ច ឯតំ មង្គលមុត្តមំ ។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ

អសោកំ វិរជំ ខេមំ ឯតំ មង្គលមុត្តមំ ។

ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា

សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។

មង្គលសុត្តំ ចតុត្ថំ ។

សេចក្ដីអត់ធន់ ១ ភាពនៃបុគ្គលដែលប្រដៅងាយ ១ ការបានឃើញ បានជួបសមណៈទាំងឡាយ ១ ធម្មសាកច្ឆាតាមកាល ១ (ទាំង ៤) នេះ ជាមង្គលដ៏ឧត្តម ។

សេចក្ដីព្យាយាមដុតបាបធម៌ ១ ការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ ការឃើញនូវអរិយសច្ចទាំងឡាយ ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ (ទាំង ៤) នេះ ជាមង្គលដ៏ឧត្តម ។

ចិត្តនៃបុគ្គលណា ដែលលោកធម៌ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធូលីគឺរាគៈ ទៅប្រាសហើយ ១ ចិត្តក្សេមក្សាន្ត ១ (ទាំង ៤) នេះ ជាមង្គលដ៏ឧត្តម ។

ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ ក្នុងទីទាំងពួង តែងដល់នូវសួស្ដីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្ស ទាំងអម្បាលណោះ ជាមង្គលដ៏ឧត្តម ។

ចប់ មង្គលសូត្រ ទី ៤ ។

# បញ្ចមំ សូចិលោមសុត្តំ

(៦៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា គយាយំ វិហរតិ ដង្កិតមញ្ចេ សូចិលោមយក្ខស្ស ភវនេ ។ តេន ខោ បន សមយេន ខរោ ច យក្ខោ សូចិលោមោ ច យក្ខោ ភគវតោ អវិទូរេ អតិក្កមន្តិ ។ អថខោ ខរោ យក្ខោ សូចិលោមំ យក្ខំ ឯតទវោច ឯសោ សមណោតិ ។ នេសោ សមណោ សមណកោ ឯសោ យាវ អហំ ជានាមិ យទិ វា សមណោ យទិ វា សមណកោតិ ។ អថខោ សូចិលោមោ យក្ខោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ កាយំ ឧបនាមេសិ ។ អថខោ ភគវា កាយំ អបនាមេសិ ។ អថខោ សូចិលោមោ យក្ខោ ភគវន្តំ ឯតទវោច ភាយសិ មំ សមណាតិ ។ ន ខ្វាហំ តាវុសោ ភាយាមិ អបិ ច តេ សម្ផស្សោ បាបកោតិ ។

# សូចិលោមសូត្រ ទី ៥

(៦៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់លើគ្រែថ្ម ជាលំនៅនៃសូចិលោមយក្ស ទៀបគយាគ្រាម ។ សម័យនោះឯង ខរយក្សនឹងសូចិលោមយក្ស នាំគ្នាដើរទៅជិតព្រះមានព្រះភាគ ។ លំដាប់នោះ ខរយក្សបាននិយាយនឹងសូចិលោមយក្សថា នុ៎ះ ព្រះសមណៈ ។ សូចិលោមយក្សឆ្លើយថា នុ៎ះ មិនមែនព្រះសមណៈទេ នុ៎ះ គ្រាន់តែប្រហែលនឹងព្រះសមណៈ ចាំខ្ញុំសង្កេតឲ្យដឹងថា ជាព្រះសមណៈ ឬប្រហែលនឹងព្រះសមណៈសិន ។ វេលានោះ សូចិលោមយក្ស ក៏ចូលទៅជិតព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បន្ទន់កាយ ទៅរកព្រះមានព្រះភាគ ។ ចំណែកព្រះមានព្រះភាគ ឆៀកព្រះកាយចេញ ។ លំដាប់នោះ សូចិលោមយក្ស ទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះសមណៈ ខ្លាចខ្ញុំឬ ។ ម្នាលអាវុសោ តថាគតមិនខ្លាចអ្នកទេ តែសម្ផស្សរបស់អ្នកឯងអាក្រក់ ។

បញ្ហំ សមណ បុច្ឆិស្សាមិ សចេ មេ ន ព្យាកាសិ(១)
ចិត្តំ វា តេ ខិបិស្សាមិ ហទយំ វា តេ ផាលេ-
ស្សាមិ បាទេសុ វា គហេត្វា បារគង្គាយ ខិបិស្សា-
មីតិ ។ ន ខ្វាហន្តំ អាវុសោ បស្សាមិ សទេវកេ
លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្ម-
ណិយា បជាយ សទេវមនុស្សាយ យោ មេ ចិត្តំ
វា ខិបេយ្យ ហទយំ វា ផាលេយ្យ បាទេសុ វា
គហេត្វា បារគង្គាយ ខិបេយ្យ អបិ ច ត្វំ អាវុសោ
បុច្ឆ យទាកង្ខសីតិ ។ អថខោ សូចិលោមោ
យក្ខោ ភគវន្តំ គាថាយ អជ្ឈភាសិ

(២៧) រាគោ ច ទោសោ ច កុតោនិទានា
អរតី រតី លោមហំសោ កុតោជា
កុតោ សមុដ្ឋាយ មនោវិតក្កា
កុមារកា ធង្កមិវោស្សជន្តិ(២) ។

---

១ ឱ, ព្យាករិស្សសិ ។ ម. ព្យាករិស្សសិ ។ ២ ឱ, វំកមិវោស្សជន្តិ ។

ព្រះសមណៈ យើងនឹងសួរប្រស្នាចំពោះលោក បើលោកមិនឆ្លើយប្រាប់យើង យើងនឹងធ្វើចិត្តរបស់លោកឲ្យរវើរវាយ ឬនឹងហែកហឫទ័យលោក ឬក៏នឹងចាប់ជើង បោះទៅត្រើយម្ខាងទន្លេគង្គា ។ ម្នាលអាវុសោ បុគ្គលណា គប្បីញុំាងចិត្តតថាគតឲ្យរាយមាយក្តី ហែកហឫទ័យតថាគតក្តី គប្បីចាប់ជើងតថាគត គ្រវែបោះទៅត្រើយម្ខាងទន្លេគង្គាក្តី តថាគត មិនឃើញបុគ្គលនោះ ទោះបីក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឡើយ ម្នាលអាវុសោ មួយទៀត អ្នកប្រាថ្នា (នឹងសួរ) ប្រស្នាណា ចូរសួរប្រស្នានោះមកចុះ ។ លំដាប់នោះ សូចិលោមយក្ស បានពោលទៅនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

(៤៧) រាគៈនិងទោសៈ មានអ្វីជាហេតុ សេចក្តីមិនត្រេកអរ សេចក្តីត្រេកអរនិងការព្រឺរោម កើតមកអំពីអ្វី មនោវិតក្កៈ កើតមកអំពីអ្វី ដែលគួរលះបង់ចោល ដូចជាពួកក្មេងលែងក្អែកចោល ។

រាគោ ច ទោសោ ច កុតោនិទានា

អរតី រតី លោមហំសោ កុតោជា

កុតោ សមុដ្ឋាយ មនោ វិតក្កា

កុមារកា ធង្កមិវោស្សជន្តិ ។

ស្នេហជា អត្តសម្ភូតា និគ្រោធស្សេវ ខន្ធជា

បុថូ វិសត្តា កាមេសុ មាលុវា វិតតា វនេ ។

យេ នំ បជានន្តិ យតោនិទានំ

តេ នំ វិនោទេន្តិ សុណោហិ យក្ខ

តេ ទុត្តរំ ឱឃមិមំ តរន្តិ

អតិណ្ណបុព្វំ អបុនព្ភវាយាតិ ។

សូចិលោមសុត្តំ បញ្ចមំ ។

សុត្តនិបាត ចូឡវគ្គ សូចិលោមសូត្រ ទី ៥

រាគៈ ទោសៈ មានអត្តភាពនេះជាហេតុ សេចក្ដីមិនត្រេកអរ សេចក្ដីត្រេកអរ នឹងការព្រឺរោម កើតមកអំពីអត្តភាពនេះ មនោវិតក្កៈ កើតមកអំពីអត្តភាពនេះ ដែលគេលះបង់ចោល ដូចជាពួកក្មេង លែងក្អែកចោល (១) ។

កិលេសទាំងឡាយ កើតមកអំពីសេចក្ដីស្នេហាគឺតណ្ហា ក៏កើតអំពីខ្លួន ដូចជាញ្ញើជ្រៃ ដែលកើតអំពីដើមជ្រៃ កិលេសដ៏ច្រើន ជាប់ចំពាក់ ក្នុងវត្ថុកាមទាំងឡាយ ដូចជាវល្លិ៍ព័ទ្ធ (?) ឈើចាក់ស្រែះក្នុងព្រៃ ។

ពួកជនណា ដឹងនូវកិលេសនោះ ថាកើតអំពីហេតុណា ពួកជននោះ តែងបន្ទោបង់នូវហេតុនោះចេញ ម្នាលយក្ស ចូរអ្នកស្ដាប់ចុះ ពួកជនទាំងនោះ តែងឆ្លងនូវអន្លង់នេះ ដែលគេឆ្លងបានដោយក្រ ដែលខ្លួនមិនធ្លាប់ឆ្លង ដើម្បីដល់ព្រះនិព្វានដែលជាទីមិនកើតទៀត ។

ចប់ សូចិលោមសូត្រ ទី ៥ ។

---

១ - រាគៈក្ដី ទោសៈក្ដី អកុសលវិតក្កៈមានកាមវិតក្កៈជាដើមក្ដី កើតមកអំពីអត្តភាពទាំងអស់ កាលបើធម៌ទាំងនោះកើតឡើងហើយ ក៏លះបង់នូវកុសលចិត្តស្រឡះ ដូចជាពួកក្មេងអ្នកស្រុកយកខ្សែចងជើងក្អែកហើយក្រវែងចោលទៅ ។ អដ្ឋកថា ។

## ឆដ្ឋំ ធម្មចរិយសុត្តំ

(៦៨) ធម្មចរិយំ ព្រហ្មចរិយំ ឯតទាហុ វសុត្តមំ
បព្វជិតោបិ ចេ ហោតិ អគារស្មា អនគារិយំ ។
សោ ចេ មុខរជាតិកោ វិហេសាភិរតោ មគោ
ជីវិតំ តស្ស(១) បាបិយោ រជំ វឌ្ឍេតិ អត្តនោ ។
កលហាភិរតោ ភិក្ខុ មោហធម្មេន អាវុតោ(២)
អក្ខាតម្បិ ន ជានាតិ ធម្មំ ពុទ្ធេន ទេសិតំ ។
វិហេសំ ភាវិតត្តានំ អវិជ្ជាយ បុរក្ខតោ
សង្កិលេសំ ន ជានាតិ មគ្គំ និរយគាមិនំ ។
វិនិបាតំ សមាបន្នោ គព្ភា គព្ភំ តមា តមំ
ស វេ តាទិសកោ ភិក្ខុ បេច្ច ទុក្ខំ និគច្ឆតិ ។

---

១ ឱ. អាវដោ ។ ២ អដ្ឋ. តស្ស ។

# ធម្មបរិយសូត្រ ទី ៦

(២៨) ព្រះអរិយៈទាំងឡាយ តែងពោលនូវធម្មចរិយៈ (១) និងព្រហ្មចរិយៈ (២) នេះ ថាជារតនៈដ៏ឧត្តម ប្រសិនបើបុគ្គលចេញចាកផ្ទះ ទៅបួសក្នុងធម្មវិន័យ ។

បើបុគ្គលនោះ ជាអ្នកមានមាត់រឹង ត្រេកអរក្នុងការបៀតបៀន ដូចជាសត្វម្រឹគ ជីវិតរបស់បុគ្គលនោះជាជីវិតអាក្រក់ក្រៃលែង បុគ្គលនោះ តែងញុំាងធូលីគឺកិលេសឲ្យចំរើនឡើងដល់ខ្លួន ។

ភិក្ខុអ្នកត្រេកអរ ក្នុងជម្លោះ ត្រូវមោហធម៌ពាក់ស្រែះហើយ ក៏លែងដឹងធម៌ដែលពួកភិក្ខុបានប្រាប់ហើយផង ដែលព្រះពុទ្ធទ្រង់សំដែងផង ភិក្ខុម្នកត្រូវអវិជ្ជារួបរឹត ហើយបៀតបៀន នូវព្រះខីណាស្រពទាំងឡាយ ដែលជាអ្នកមានខ្លួនអប់រំហើយ រមែងមិនស្គាល់នូវសេចក្ដីសៅហ្មង ជាផ្លូវទៅកាន់នរក ហើយចូលទៅកាន់អបាយ ៤ ចេញចាកគភ៌ទៅកាន់គភ៌ ចេញចាកអសុរកាយ ទៅកាន់អសុរកាយ ភិក្ខុនោះ រមែងដល់នូវសេចក្ដីទុក្ខ ក្នុងបរលោក ។

---

១ បានដល់កាយសុចរិតជាដើម ។ ២ បានដល់មគ្គព្រហ្មចារ្យគឺអដ្ឋង្គិកមគ្គ ។

គូថកូតោ(១) យថា អស្ស សម្បុណ្ណោ គណវស្សិកោ

យោ ច ឯវរូបោ អស្ស ទុព្វិសោធោ ហិ សង្គណោ ។

យំ ឯវរូបំ ជានាថ ភិក្ខវោ គេហនិស្សិតំ

បាបិច្ឆំ បាបសង្កប្បំ បាបអាចារគោចរំ ។

សព្វេ សមគ្គា ហុត្វាន អភិនិព្វជ្ជិយាថ នំ

ការណ្ដវំ(២) (៣) និទ្ធមថ កសម្ពុំ អវកស្សថ

តតោ បលាបេ វាហេថ អស្សមណេ សមណមានិនេ ។

និទ្ធមិត្វាន បាបិច្ឆេ បាបអាចារគោចរេ

សុទ្ធា សុទ្ធេហិ សំវាសំ កប្បយវ្ហោ បតិស្សតា(៤)

តតោ សមគ្គា និបកា ទុក្ខស្សន្តំ ករិស្សថាតិ ។

ធម្មចរិយសុត្តំ ឆដ្ឋំ ។

---

១ ឱ. ម. គូថកូបោ ។ ២ ឱ. ការណ្ឌវំ ។ ៣ ឱ. បលាបេ ។ ៤ ម. បដិស្សុតា ។

មួយទៀត បុគ្គលដែលមានសភាពយ៉ាងនេះ ជាអ្នកប្រកបដោយកិលេស ដូចទីទួល លាងជំរះបានដោយកម្រ ដូចជារណ្ដៅលាមក ពេញប្រៀបអ្នករាប់កប់ឆ្នាំ (ដែលគេលាងសំអាតបានដោយកម្រ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរដឹងនូវបុគ្គល ដែលអាស្រ័យនូវផ្ទះ គឺកាមគុណ ជាអ្នកមានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីត្រិះរិះអាក្រក់ មានអាចារៈនិងគោចរៈអាក្រក់បែបនេះ ។ អ្នកពល់គ្នា គប្បីជាអ្នកព្រមព្រៀងគ្នា បៀសវាងនូវបុគ្គលនោះចេញ ចូរបោះបង់ចោល ដូចជាគេបោសសម្រាមចោល ចូរទាញចេញនូវបុគ្គលអ្នកប្រព្រឹត្តក្រខ្វក់ តពីនោះទៅ គប្បីបណ្ដេញ នូវពួកបុគ្គលដែលដូចជាសំដីស្រូវ មិនមែនជាសមណៈ ប្រកាន់ថា ខ្លួនជាសមណៈចេញ ។ លុះអ្នកទាំងឡាយ បណ្ដេញបុគ្គលអ្នកប្រាថ្នាអាក្រក់ មានអាចារៈនិងគោចរៈអាក្រក់បានហើយ ជាអ្នកបរិសុទ្ធ សម្រេចការនៅ ជាមួយនឹងបុគ្គលបរិសុទ្ធ អ្នកមានសេចក្ដីគោរព គោរពក្រែងគ្នា តទៅនឹងជាអ្នកព្រមព្រៀងគ្នា មានប្រាជ្ញាចាស់ក្លា ធ្វើនូវទីបំផុតនៃទុក្ខបាន ។

ចប់ ធម្មចរិយសូត្រ ទី ៦ ។

# សត្តមំ ព្រាហ្មណធម្មិកសុត្តំ

(២៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សម្ពហុលា កោសលកា ព្រាហ្មណមហាសាលា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោអនុប្បត្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ព្រាហ្មណមហាសាលា ភគវន្តំ ឯតទវោចុំ សន្ទិស្សន្តិ នុ ខោ ភោ គោតម ឯតរហិ ព្រាហ្មណា បោរាណានំ ព្រាហ្មណានំ ព្រាហ្មណធម្មេតិ ។ ន ខោ ព្រាហ្មណា សន្ទិស្សន្តិ ឯតរហិ ព្រាហ្មណា បោរាណានំ ព្រាហ្មណានំ ព្រាហ្មណធម្មេតិ ។

# ព្រាហ្មណធម្មិកសូត្រ ទី ៧

(២៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ពួកព្រាហ្មណមហាសាល ជាច្រើននាក់ នៅក្នុងដែនកោសល ជាមនុស្សចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុកំដ្រលចូលមក ក្នុងបច្ឆិមវ័យហើយ បាននាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណមហាសាលទាំងនោះ អង្គុយក្នុងទីសមគួរហើយបានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ឥឡូវនេះ ពួកព្រាហ្មណ៍ប្រាកដ ក្នុងព្រាហ្មណធម៌ របស់ពួកព្រាហ្មណ៍ជាន់ចាស់ដែរឬ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ទាំងឡាយ ឥឡូវនេះពួកព្រាហ្មណ៍ មិនប្រាកដក្នុងព្រាហ្មណធម៌របស់ពួកព្រាហ្មណ៍ជាន់ចាស់ទេ ។

សាធុ នោ ភវំ គោតមោ ព្រាហ្មណានំ ព្រាហ្មណធម្មំ ភាសតុ សចេ ភោតោ គោតមស្ស អគរូតិ ។ តេនហិ ព្រាហ្មណា សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ តេ ព្រាហ្មណមហាសាលា ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច

(៣០) ឥសយោ បុព្វកា អាសុំ សញ្ញតត្តា តបស្សិនោ
បញ្ច កាមគុណេ ហិត្វា អត្តទត្ថមចារិសុំ(១) ។
ន បសូ ព្រាហ្មណានាសុំ ន ហិរញ្ញំ ន ធានិយំ
សជ្ឈាយធនធញ្ញាសុំ ព្រហ្មំ និធិមបាលយុំ ។
យំ នេសំ បកតំ(២) អាសិ ទ្វារភត្តំ ឧបដ្ឋិតំ
សទ្ធាបកតមេសានំ ទាតវេ តទមញ្ញិសុំ ។

---

១ ឱ. ម. អត្តទត្ថមចារិសុំ ។ ២ ម. សទេសំ បកតំ អស្សុំ ។

បើព្រះគោតមដ៏ចំរើន មិនធ្ងន់ព្រះទ័យទេ សូមព្រះគោតមដ៏ចំរើន សំដែងព្រាហ្មណធម៌ របស់ពួកព្រាហ្មណ៍ជាន់ចាស់ ដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។ ម្នាលព្រាហ្មណ៍ទាំងឡាយបើដូច្នោះ អ្នកទាំងឡាយ ចូរស្ដាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង ។ ព្រាហ្មណមហាសាលទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា

(៣០) ពួកឥសីជាន់មុន ជាអ្នកមានចិត្តសង្រួមហើយ មានតបៈ គឺឥន្ទ្រិយសំវរៈ លះបង់កាមគុណទាំង ៥ ធ្វើប្រយោជន៍បម្រុងខ្លួន ។

ពួកព្រាហ្មណ៍ មិនមានសត្វចិញ្ចឹម មិនមានប្រាក់ មិនមានស្រូវសន្សំទុក មានតែទ្រព្យនឹងស្រូវគឺការស្វាធ្យាយ រក្សាតែព្រហ្មវិហារជាកំណប់ទ្រព្យ ។

ពួកទាយក តាក់តែងភត្តណាដាក់ទៀបទ្វារផ្ទះ ដើម្បីពួកព្រាហ្មណ៍ទាំងនោះ ពួកទាយកបានសំគាល់នូវភត្តនោះ ដើម្បីឲ្យដល់ពួកព្រាហ្មណ៍ កាលស្វែងរកនូវភត្តដែលគេបានតែងដោយសទ្ធា ។

នានារត្តេហិ វត្ថេហិ សយនេហាវសថេហិ ច

ផីតា ជនបទា រដ្ឋា តេ នមស្សឹសុ ព្រាហ្មណេ ។

អវជ្ឈា ព្រាហ្មណា អាសុំ អជេយ្យា ធម្មរក្ខិតា

ន នេ កោចិ និវារេសិ កុលទ្វារេសុ សព្វសោ

អដ្ឋចត្តាឡីសំ វស្សានិ (កោមារ) ព្រហ្មចរិយំ ចរឹសុ តេ

វិជ្ជាចរណបរិយេដ្ឋឹ អចរុំ ព្រាហ្មណា បុរេ ។

ន ព្រាហ្មណា អញ្ញមគមុំ នបិ ភរិយំ កិណឹសុ តេ

សម្បិយេនេវ សំវាសំ សង្គន្ត្វា សមរោចយុំ ។

អញ្ញត្រ តម្ហា សមយា ឧតុវេរមណឹ បតិ

អន្តរា មេថុនំ ធម្មំ នាស្សុ គច្ឆន្តិ ព្រាហ្មណា ។

ព្រហ្មចរិយញ្ច សីលញ្ច អជ្ជវំ មទ្ទវំ តបំ

សោរច្ចំ អវិហឹសញ្ច ខន្តិញ្ចាបិ អវណ្ណយុំ ។

ពួកអ្នកជនបទនឹងអ្នកដែន ជាមនុស្សសម្បូរ ដោយសំពត់ជ្រលក់ដោយពណ៌ផ្សេងៗ ដោយទីដេកនឹងទីនៅអាស្រ័យទាំងឡាយ តែងថ្វាយបង្គំពួកព្រាហ្មណ៍ទាំងនោះ ។

ពួកព្រាហ្មណ៍ជាអ្នកមិនត្រូវគេបៀតបៀន មិនត្រូវគេសង្កត់សង្កិន ព្រោះធម៌រក្សា ជនទីមួយ មិនហាមឃាត់ពួកព្រាហ្មណ៍ទាំងនោះក្នុងទ្វារផ្ទះនៃត្រកូល ដោយប្រការទាំងពួងឡើយ ។

ព្រាហ្មណ៍ទាំងនោះ បានប្រព្រឹត្តព្រហ្មចរិយៈ (តាំងអំពីក្មេង) អស់ ៤៨ ឆ្នាំ ពួកព្រាហ្មណ៍ បានប្រព្រឹត្តនូវការស្វែងរកវិជ្ជានឹងចរណៈមុន ។

ព្រាហ្មណ៍ទាំងនោះ មិនបានទៅកាន់ផ្ទះនៃបុគ្គលដទៃ នឹងមិនទិញភរិយា យកបកនៅព្រមសង្វាសគ្នា ដោយសេចក្តីស្រឡាញ់ទេ ។

ពួកព្រាហ្មណ៍ មិនប្រព្រឹត្តមេថុនធម្មក្នុងចន្លោះដែលដល់នូវការវៀរចាករដូវ វៀរលែងតែសម័យគួរនោះ ។

ពួកព្រាហ្មណ៍តែងសរសើរព្រហ្មចរិយៈ (១) សីល សេចក្តីទៀងត្រង់ សេចក្តីទន់ក្លន់ តបៈគឺឥន្ទ្រិយសំវរៈ សេចក្តីស្លូតបូត សេចក្តីមិនបៀតបៀន នឹងសេចក្តីអត់ធន់ ។

---

១– មេថុនវិរតិ

យោ នេសំ បរមោ អាសិ ព្រហ្មា ទឡ្ហបរក្កមោ
ស វាបិ មេថុនំ ធម្មំ សុបិនន្តេន(១) នាគមា ។
តស្ស វត្តមនុសិក្ខន្តា ឥធេកេ វិញ្ញុជាតិកា
ព្រហ្មចរិយញ្ច សីលញ្ច ខន្តិញ្ចាបិ អវណ្ណយុំ ។
តណ្ឌុលំ សយនំ វត្ថំ សប្បិតេលញ្ច យាចិយ
ធម្មេន សមោធានេត្វា តតោ យញ្ញមកប្បយុំ ។
ឧបដ្ឋិតស្មិំ យញ្ញស្មិំ នាស្សុ គាវោ ហនិំសុ តេ ។
យថា មាតា បិតា ភាតា អញ្ញេ វាបិ ច ញាតកា
គាវោ នោ បរមា មិត្តា យាសុ ជាយន្តិ ឱសថា ។
អន្នទា ពលទា ចេតា វណ្ណទា សុខទា តថា
ឯតមត្ថវសំ ញត្វា នាស្សុ គាវោ ហនិំសុ តេ ។

---

១ ម. សុបិនន្តេបិ នាគមា ។

ព្រាហ្មណ៍ស្មើដោយព្រហ្ម ជាអ្នកមានព្យាយាមមាំមួន ខ្ពង់ខ្ពស់ជាងពួកព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍ស្មើដោយព្រហ្មនោះ សូម្បីតែយល់សប្តិឃើញសេពមេថុនធម្មក៏មិនដែលមានៗ

មនុស្សមួយពួកក្នុងលោកនេះ ជាអ្នកចេះដឹង កាលសិក្សាតាមវត្តរបស់ព្រាហ្មណ៍ស្មើដោយព្រហ្មនោះ បានសរសើរព្រហ្មចរិយ សីល និងខន្តិធម៌ ។

ព្រាហ្មណ៍ទាំងនោះសូម អង្ករ ទីដេក សំពត់ ទឹកដោះថ្លា និងប្រេង តាមធម៌ ប្រមូលមកសម្រេចនូវយញ្ញៈអំពីវត្ថុនោះ កាលបើយញ្ញៈ ប្រាកដឡើងហើយ ក៏មិនបានសម្លាប់គោទាំងឡាយឡើយ ។

ឱសថគឺបញ្ចគោរស កើតក្នុងគោទាំងឡាយណា គោទាំងនោះ ជាមិត្តដ៏ប្រសើរ របស់ពួកយើង ដូចជាមាតាបិតា បងប្អូននិងពួកញាតិដទៃៗ ។

គោទាំងនោះ ជាអ្នកឲ្យបាយ ឲ្យកំឡាំង ឲ្យពណ៌សម្បុរ ឲ្យសេចក្តីសុខដូច្នោះ ព្រាហ្មណ៍ទាំងនោះ លុះបានដឹងនូវអំណាចនៃប្រយោជន៍នុ៎ះហើយ ក៏មិនដែលសម្លាប់គោទាំងឡាយឡើយ ។

សុខុមាលា មហាកាយា វណ្ណវន្តោ យសស្សិនោ
ព្រាហ្មណា សេហិ ធម្មេហិ កិច្ចាកិច្ចេសុ ឧស្សុកា
យាយ(១) លោកេ អវត្តិំសុ សុខមេធិត្ថយម្បជា ។
តេសំ អាសិ វិបល្លាសោ ទិស្វាន អណុតោ អណុំ
រាជិនោ ច វិយាការំ នារិយោ ច សមលង្កតា
រថេ ចាជញ្ញសំយុត្តេ សុកតេ ចិត្តសិព្វនេ
និវេសនេ និវេសេ ច វិភត្តេ ភាគសោ មិតេ
គោមណ្ឌលបរិព្យូឡ្ហំ(២) នារីវរគណាយុតំ
ឧឡារំ មានុសំ ភោគំ អភិជ្ឈាយិំសុ ព្រាហ្មណា ។
តេ តត្ថ មន្តេ គន្ថេត្វា ឱក្កាកំ តទុបាគមុំ
បហូតធនធញ្ញោសិ (យជស្សុ ពហុ តេ វិត្តំ)
យជស្សុ ពហុ តេ ធនំ ។

១ ឱ. ម. យាវ ។ ២ ឱ. បរិព្យូឡ្ហំ ។ ឱ. បរិព្រូឡ្ហំ ។

ពួកព្រាហ្មណ៍ជាអ្នកមានអវយវៈទន់ភ្លន់ មានកាយប្រសើរ មានសម្បុរល្អ មានយស ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចតូចធំតាមធម៌របស់ខ្លួន បានប្រព្រឹត្តក្នុងលោកត្រឹមណា ពួកសត្វនេះក៏បានសេចក្តីសុខ (ត្រឹមណោះ) ។

ព្រាហ្មណ៍ទាំងនោះ មានសេចក្តីវិបល្លាស ព្រោះឃើញកាមសុខមានប្រមាណតិច ដែលកើតអំពីកាមគុណ មានប្រមាណតិចផង នូវសម្បត្តិរបស់ស្តេចផង នូវនារីទាំងឡាយតាក់តែងគ្រឿងប្រដាប់ផង នូវរថដែលទឹមដោយសេះអាជានេយ្យដែលធ្វើល្អ ពាសដោយស្បែក ដ៏វិចិត្រផង នូវទីផ្ទះនិងផ្ទះដែលគេចែកកប់ជាចំណែក ៗ ផង ពួកព្រាហ្មណ៍តែងចង់បាននូវសម្បត្តិ ជារបស់មនុស្សដ៏លើសលុប ដេរដាសដោយហ្វូងគោ និងប្រកបដោយពួកនារីដ៏ប្រសើរ ។

ព្រាហ្មណ៍ទាំងនោះតែងមន្តព្រោះចង់បានទ្រព្យនោះ បានចូលទៅរកព្រះបាទឧក្កាកៈក្នុងវេលានោះថា (ព្រះអង្គបូជា នូវទ្រព្យដ៏វិចិត្រជាច្រើន របស់ព្រះអង្គ) សូមព្រះអង្គបូជា នូវធនសម្បត្តិជាច្រើន របស់ព្រះអង្គ និងបាននូវទ្រព្យនិងស្រូវជាច្រើន ។

តតោ ច រាជា សញ្ញត្តោ ព្រាហ្មណេហិ រថេសភោ

អស្សមេធំ បុរិសមេធំ (សម្មាបាសំ) វាជបេយ្យំ និរគ្គឡំ ។

ឯតេ យាគេ យជិត្វាន ព្រាហ្មណានំ អទា ធនំ

គាវោ សយនញ្ច វត្ថញ្ច នារិយោ ច សមលង្កតា

រថេ ចាជញ្ញសំយុត្តេ សុកតេ ចិត្រសិព្វនេ

និវេសនានិ រម្មានិ សុវិភត្តានិ ភាគសោ

នានាធញ្ញស្ស បូរេត្វា ព្រាហ្មណានំ អទា ធនំ ។

តេ ច តត្ថ ធនំ លទ្ធា សន្និធឹ សមរោចយុំ

តេសំ ឥច្ឆាវតិណ្ណានំ ភិយ្យោ តណ្ហា បវឌ្ឍថ

តេ តត្ថ មន្តេ គន្ថេត្វា ឱក្កាកំ តទុបាគមុំ ។

គ្រានោះ ពួកព្រាហ្មណ៍បានពន្យល់ព្រះរាជា អ្នកមិនញាប់ញ័រ ដូចគោឧសភក្នុងរថ (ឲ្យធ្វើយញ្ញៈ ៥ យ៉ាង) គឺ អស្សមេធៈ (យញ្ញៈជាទីបៀតបៀនសេះ) ១ បុរិសមេធៈ (យញ្ញៈ ជាទីបៀតបៀនបុរស) ១ សម្មាបាសៈ (យញ្ញៈ ជាទីបោះទៅនូវកាំទឹម) ១ វាជបេយ្យៈ (យញ្ញ ជាទីផឹកនូវទឹកដោះថ្លានឹងទឹកឃ្មុំ ដែលគេតាក់តែងឲ្យជាដើមនៃមន្ត) ១ និរគ្គឡៈ (យញ្ញៈមិនមានសន្ទះទ្វារ) ១ ។

លុះព្រាហ្មណ៍ទាំងនោះ បានបូជានូវការបូជាទាំងនោះរួចហើយ ក៏បានឲ្យទ្រព្យដល់ពួកព្រាហ្មណ៍ ឲ្យគោ ទីដេក សំពត់ និងនារីដែលមានគ្រឿងប្រដាប់តាក់តែង រថទឹមដោយសេះអាជានេយ្យដែលធ្វើល្អ ពាសដោយស្បែក ដ៏វិចិត្រ លំនៅជាទីត្រេកអរ ដែលគេចាត់ចែងដោយសព្វគ្រប់ ផ្ទុកទ្រព្យផ្សេងៗពេញហើយ ឲ្យទ្រព្យ ដល់ពួកព្រាហ្មណ៍ ។

លុះព្រាហ្មណ៍ទាំងនោះ បានទ្រព្យក្នុងទីនោះហើយក៏សន្សំគរទុក ព្រាហ្មណ៍ទាំងនោះត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ហើយ តណ្ហាក៏ចំរើនឡើងក្រៃលែង ព្រាហ្មណ៍ទាំងនោះតែងមន្តក្នុងទីនោះហើយចូលទៅគាល់ព្រះបាទឧក្កាកៈទៀត ។

យថា អាបោ ច បថវី ច ហិរញ្ញំ ធនធានិយំ

ឯវំ គាវោ មនុស្សានំ បរិក្ខារោ សោ ហិ បាណិនំ

យជស្សុ ពហុ តេ វិត្តំ យជស្សុ ពហុ តេ ធនំ ។

តតោ ច រាជា សញ្ញត្តោ ព្រាហ្មណេហិ រថេសភោ

នេកា សតសហស្សិយោ គាវោ យញ្ញេ អឃាតយិ ។

ន បាទា ន វិសាណេន នាស្សុ ហិំសន្តិ កេនចិ

គាវោ ឯឡកសមានា សោរតា កុម្ភទូហនា

តា វិសាណេ គហេត្វាន រាជា សត្ថេន ឃាតយិ ។

តតោ ច ទេវា បិតរោ ឥន្ទោ អសុររក្ខសា

អធម្មោ ឥតិ បក្កន្ទុំ យំ សត្ថំ និបតី គវេ ។

ទឹក ដី ប្រាក់ ទ្រព្យនិងស្រូវ យ៉ាងណា គោទាំងឡាយ សម្រាប់ប្រកបកិច្ចការរបស់មនុស្ស ក៏យ៉ាងនោះដែរ ព្រោះថា វត្ថុមានទឹកដោះជាដើមនោះ ជាបរិក្ខាររបស់ពួកសត្វមានជីវិត សូមព្រះអង្គបូជានូវទ្រព្យដ៏វិចិត្រជាច្រើនរបស់ព្រះអង្គ សូមព្រះអង្គបូជានូវធនសម្បត្តិដ៏ច្រើនរបស់ព្រះអង្គ ។

លំដាប់នោះព្រះរាជា ដូចជាគោឧសភក្នុងរថ ត្រូវពួកព្រាហ្មណ៍ពន្យល់ហើយ ក៏បានសម្លាប់គោរាប់សែនជាច្រើន ក្នុងការបូជាយញ្ញៈ ។

គោស្មើគ្នានឹងចៀមជាសត្វស្លូត រូតទឹកដោះដាក់ឆ្នាំងបាន មិនចេះបៀតបៀនគេដោយជើង មិនចេះបៀតបៀនគេដោយស្នែងនិងដោយអវយវៈណាមួយឡើយ ព្រះរាជាទ្រង់ចាប់គោទាំងនោះត្រង់ស្នែង ហើយសម្លាប់ដោយគ្រឿងសស្ត្រា ។

លំដាប់នោះ ពួកទេវតាក្តី ពួកព្រហ្មជាបិតាក្តី ព្រះឥន្ទក្តី អសុរនឹងរាក្ខសក្តី ក៏កន្ទក់កន្ទេញថា ស្តេចគ្មានធម៌ ដូច្នេះ ព្រោះព្រះរាជាសម្លាប់គោ ដោយគ្រឿងសស្ត្រា ។

តយោ រោគា បុរេ អាសុំ ឥច្ឆា អនសនញ្ជរា

បសូនញ្ច សមារម្ភា អដ្ឋានវុតិមាគមុំ ។

ឯសោ អធម្មោ ទណ្ឌានំ ឱក្កន្តោ បុរាណោ អហុ

អទូសិកាយោ ហញ្ញន្តិ ធម្មា ធំសន្តិ យាជកា ។

ឯវមេសោ អនុធម្មោ បោរាណោ វិញ្ញុគរហិតោ

យត្ថ ឯទិសកំ បស្សតិ យជកំ(១) គរហតី ជនោ ។

ឯវំ ធម្មេ វិយាបន្នេ វិភិន្នា សុទ្ទវេស្សិកា

បុថូ វិភិន្នា ខត្តិយា បតឹ ភរិយា អវមញ្ញថ ។

ខត្តិយា ព្រហ្មពន្ធូ ច យេ ចញ្ញេ គោត្តរក្ខិតា

ជាតិវាទំ និរង្កត្វា កាមានំ វសមុបាគុន្តិ(២) ។

---

១ ឱ.ម. យាជកំ ។ ២ ម. វសមាគមុន្តិ ។

ក្នុងបុរី មានរោគ ៣ យ៉ាង គឺសេចក្ដីប្រាថ្នា ១ ការគ្មានស៊ី ១ សេចក្ដីគ្រាំគ្រា ១ ចំរើនឡើងដល់ ៩៨ (មានរោគក្អកជាដើម) ព្រោះបម្លាប់នូវសត្វចិញ្ចឹម ។

នេះជាអធម៌ នៃពួកខណ្ឌៈប្រព្រឹត្តយូរហើយ អ្នកបូជាទាំងឡាយ តែងបៀតបៀន នូវគោទាំងឡាយ) ជាសត្វមិនប្រទូស្ត រមែងសាបសូន្យចាកធម៌ ។

នេះឯង ជាធម៌ថោកទាប មានមកតាំងពីកាលមុន ដែលអ្នកប្រាជ្ញតិះដៀលហើយ យ៉ាងនេះ វិញ្ញូជនឃើញនូវអំពើដូច្នេះ ក្នុងបុគ្គលអ្នកបូជាណា តែងតិះដៀលនូវបុគ្គលអ្នកបូជានោះ ។

កាលបើព្រាហ្មណធម៌ វិនាសយ៉ាងនេះហើយ ពួកសុទ្ទៈ នឹងវេស្សៈក៏បែកគ្នា ពួកខត្តិយៈជាច្រើនក៏បែកគ្នា ទាំងភរិយាក៏មើលងាយប្ដី ។

ពួកក្សត្រក្ដី ពួកជនជាផៅពង្សនៃព្រហ្មក្ដី ទាំងពួកជនដទៃ អ្នកដែលគោត្ររក្សក្ដី ក៏លែងប្រកាន់ពាក្យពោលអំពីជាតិ លុះក្នុងអំណាចនៃកាមទាំងឡាយ ។

(៣១) ឯវំ វុត្តេ តេ ព្រាហ្មណមហាសាលា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេតិ ។

ព្រាហ្មណធម្មិកសុត្តំ សត្តមំ ។

## អដ្ឋមំ នាវាសុត្តំ

(៣២) យស្មា ហិ ធម្មំ បុរិសោ វិជញ្ញា

(៣១) កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណមហាសាលទាំងនោះ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចគេផ្ងារនូវរបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬដូចគេទ្រោលប្រទីបប្រេងក្នុងទីងងឹតដោយគិតថា បុរសអ្នកមានចក្ខុ ឃើញនូវរូបទាំងឡាយបាន ខ្ញុំព្រះអង្គទាំងនេះសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង សូមព្រះគោតមដ៏ចំរើន ជ្រាបនូវខ្ញុំព្រះអង្គទាំងឡាយ ថាជាឧបាសកអ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

ចប់ ព្រាហ្មណធម្មិកសូត្រ ទី ៧ ។

## នាវាសូត្រ ទី ៨

(៣២) បុរសបានដឹងធម៌ អំពីសំណាក់អាចារ្យណា

ឥន្ទំវ នំ ទេវតា បូជយេយ្យ
សោ បូជិតោ តស្មិ បសន្នចិត្តោ
ពហុស្សុតោ បាតុករោតិ ធម្មំ ។
តទដ្ឋិកត្វាន និសម្ម ធីរោ
ធម្មានុធម្មំ បដិបជ្ជមានោ
វិញ្ញូ វិភាវី និបុណោ ច ហោតិ
យោ តាទិសំ ភជតិ អប្បមត្តោ ។
ខុទ្ទញ្ច ពាលំ ឧបសេវមានោ
អនាគតត្ថញ្ច ឧសុយ្យកញ្ច
ឥធេវ ធម្មំ អវិភាវយិត្វា
អវិតិណ្ណកង្ខោ មរណំ ឧបេតិ ។
យថា នរោ អាបគំ ឱតរិត្វា
មហោទកំ សលិលំ សីឃសោតំ
សោ វុយ្ហមានោ អនុសោតគាមី
កឹ សោ បរេ សក្កតិ តារយេតុំ ។

គប្បីបូជាអាចារ្យនោះ ដូចជាទេវតាបូជាព្រះឥន្ទ្រ អាចារ្យអ្នកចេះដឹងច្រើន ដែលមានសិស្សបានបូជាហើយនោះ ជាអ្នកមានចិត្តជ្រះថ្លាក្នុងសិស្សនោះ រមែងធ្វើធម៌ឲ្យជាក់ច្បាស់ ។ សិស្សនោះ កាលបើបានធ្វើធម៌នោះ ឲ្យតាំងនៅហើយ បានពិចារណា ជាធីរជន ប្រតិបត្តិធម៌សមគួរតាមធម៌ រមែងជាអ្នកដឹង ជាអ្នកធ្វើឲ្យជាក់ច្បាស់ ទាំងជាអ្នកមានបញ្ញាល្អិត បុគ្គលដែលមិនប្រមាទ រមែងសេពគប់អ្នកប្រាជ្ញបែបនោះ ។ សិស្សកាលបើសេពគប់នឹងអាចារ្យ ជាអ្នកទន់ទាប ល្ងង់ខ្លៅ មានប្រយោជន៍មិនទាន់សម្រេច មានតែសេចក្តីច្រណែនគេ រមែងមិនបានធ្វើឲ្យជាក់ច្បាស់ នូវធម៌ក្នុងសាសនានេះ មិនបានឆ្លងផុតសេចក្តីសង្ស័យ ដល់នូវមរណៈ ។ ជនចុះកាន់ទន្លេមានទឹកច្រើន លំហាចហូរខ្លាំង ជននោះកាលរសាត់អណ្តែតទៅតាមខ្សែទឹក ធ្វើម្តេច នឹងអាចចម្លងពួកជនឯទៀតបាន យ៉ាងណាមិញ ។

តថេវ ធម្មំ អវិភាវយិត្វា
ពហុស្សុតានំ អនិសាមយត្ថំ
សយំ អជានំ អវិតិណ្ណកង្ខោ
កឹ សោ បរេ សក្ខតិ និជ្ឈបេតុំ ។
យថាបិ នាវំ ទឡ្ហមារុហិត្វា
បិយេនរិត្តេន(១) សមង្គិភូតោ
សោ តារយេ តត្ថ ពហូបិ អញ្ញេ
តត្រូបយញ្ញូ កុសលោ មុតីមា
ឯវម្បិ យោ វេទគុ ភាវិតត្តោ
ពហុស្សុតោ ហោតិ អវេធធម្មោ
សោ ខោ បរេ និជ្ឈបយេ បជានំ
សោតាវធានូបនិសូបបន្នេ ។
តស្មា ហវេ សប្បុរិសំ ភជេថ
មេធាវិនញ្ចេវ ពហុស្សុតញ្ច
អញ្ញាយ អត្ថំ បដិបជ្ជមានោ
វិញ្ញាតធម្មោ ស សុខំ លភេថាតិ ។

នាវាសុត្តំ អដ្ឋមំ ។

---

១ អដ្ឋ. ផិយេន ។

បុគ្គលណា មិនបានធ្វើឲ្យជាក់ច្បាស់ នូវធម៌ មិនបានស្តាប់សេចក្តី ( ក្នុងសំណាក់ ) នៃពួកពហុស្សូត មិនទាន់យល់ដោយខ្លួនឯង ជាអ្នកមិនទាន់អស់សេចក្តីសង្ស័យ ធ្វើម្តេច នឹងអាចញុំាងជនឯទៀតឲ្យយល់បាន ក៏យ៉ាងនោះដែរ ។ បុគ្គលឡើងជិះទូកដ៏មាំ បរិបូណ៌ដោយចែវនឹងជ្អោល ជាអ្នកដឹងឧបាយក្នុងការទូកនោះ ជាអ្នកឈ្លាសវៃ មានគំនិត គប្បីចម្លងពួកជនដទៃជាច្រើន ក្នុងទូកនោះបាន យ៉ាងណាមិញ ចំណែកបុគ្គលណា ជាអ្នកដល់នូវវេទ មានចិត្តបានអប់រំហើយ ជាពហុស្សូត មិនញាប់ញ័រ ( ក្នុងលោកធម៌ ) បុគ្គលនោះឯង ជាអ្នកចេះដឹង ញុំាងពួកជនដទៃ ដែលជាអ្នកបរិបូណ៌ដោយការត្រងត្រាប់នឹងឧបនិស្ស័យ ឲ្យចេះដឹងបាន ក៏យ៉ាងនោះឯង ។

ព្រោះហេតុនោះ បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមានប្រាជ្ញា ទាំងជាពហុស្សូត បុគ្គលនោះកាលដឹងសេចក្តីហើយ ប្រតិបត្តិតាម ជាអ្នកដឹងធម៌ច្បាស់ រមែងបាននូវសេចក្តីសុខ ។

ចប់ នាវាសូត្រ ទី ៨ ។

# នវមំ កឹសីលសុត្តំ

(៣៣) កឹសីលោ កឹសមាចារោ កានិ កម្មានិ ព្រូហយំ

នរោ សម្មានិវិដ្ឋស្ស ឧត្តមត្ថញ្ច បាបុណេ ។

វុឌ្ឍាបចាយី អនុសុយ្យកោ សិយា

កាលញ្ញូ ចស្ស គរូនំ ទស្សនាយ

ធម្មឹ កថំ ឯរយិតំ ខណញ្ញូ

សុណេយ្យ សក្កច្ច សុភាសិតានិ ។

កាលេន គច្ឆេ គរូនំ សកាសំ

ថម្ភំ និរង្កត្វា និវាតវុត្តិ

អត្ថំ ធម្មំ សំយមំ ព្រហ្មចរិយំ

អនុស្សរេ ចេវ សមាចរេ ច ។

# កិំសីលសូត្រ ទី ៩

(៣៣) (ព្រះសារីបុត្តដ៏មានអាយុ ក្រាបទូលសួរថា) នរជន មានសីល ដូចម្តេច មានមារយាទ ដូចម្តេច បំរើននូវអំពើទាំងឡាយ ដូចម្តេច គប្បីជាបុគ្គលប្រតិស្ឋានមាំល្អ (ក្នុងសាសនា) ផង ដល់នូវប្រយោជន៍ខ្ពង់ខ្ពស់ គឺអរហត្តផលផង ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) បុគ្គលត្រូវប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលដែលបំរើន ជាអ្នកមិនមានសេចក្តីច្រណែន ស្គាល់កាលគួរជួបនឹងគ្រូ ស្គាល់ខណៈ ស្តាប់ធម្មកថាដែលលោកពោល គប្បីស្តាប់សុភាសិតឯទៀតដោយគោរព ។

បុគ្គលគួរធ្វើការរឹងត្អឹង ឲ្យជ្រះស្រឡះ ប្រព្រឹត្តបន្ទាបខ្លួន ហើយចូលទៅកាន់សំណាក់គ្រូតាមកាលគួរ គប្បីរលឹករឿយៗ ទាំងប្រព្រឹត្តដោយប្រពៃនូវអត្ថនៃ (ភាសិត) ធម៌ សីល នឹងព្រហ្មចារ្យ (ដ៏សេសដែលគ្រូសំដែងហើយ) ។

ធម្មារាមោ ធម្មរតោ
ធម្មេ ឋិតោ ធម្មវិនិច្ឆយញ្ញូ
នេវាចរេ ធម្មសន្ទោសវាទំ
តច្ឆេហិ នីយេថ សុភាសិតេហិ ។
ហស្សំ ច ជប្បំ បរិទេវំ បទោសំ
មាយាកតំ កុហនំ គិទ្ធិមានំ
សារម្ភកក្កស្សកសាវមុច្ឆំ (១)
ហិត្វា ចរេ វីតមទោ ឋិតត្តោ ។
វិញ្ញាតសារានិ សុភាសិតានិ
សុតញ្ច វិញ្ញាត សមាធិសារំ
ន តស្ស បញ្ញា ច សុតញ្ច វឌ្ឍតិ
យោ សាហសោ ហោតិ នរោ បមត្តោ

១ ម. សារម្ភំ កក្កស្សំ កសាវំ ច មុច្ឆំ ។

បុគ្គលគួរជាអ្នកមានធម៌ជាទីត្រេកអរ ត្រេកអរ ក្នុងធម៌ ឋិតនៅក្នុងធម៌ ចេះវិនិច្ឆ័យនូវធម៌ មិនគួរប្រព្រឹត្តនូវពាក្យដែលប្រទូស្តចំពោះធម៌ គប្បីញុំាងកាល ឲ្យអស់ទៅដោយសុភាសិតទាំងឡាយដែលពិតៗ ។

បុគ្គលគួរលះបង់នូវការសើច រីករាយ ការបេរចាឥតប្រយោជន៍ ការខ្សឹកខ្សួល ការប្រទុស្ត ការធ្វើនូវមាយា ការកុហក ការជាប់ចិត្ត ការប្រកាន់ ការប្រណាំងប្រជែង សំដីអាក្រក់ ទឹកអម្ចត់គឺកតាទក្កិលេស នឹងការជ្រប់នៅដោយតណ្ហា គប្បីជាបុគ្គលប្រាសចាកសេចក្តីស្រវឹង មានចិត្តឋិតនៅមាំ ។

សុភាសិតទាំងឡាយ (ដែលប្រកបដោយសមថវិបស្សនា) គឺអ្នកប្រាជ្ញដឹងច្បាស់ថាមានសារៈ ឯញាណសំរេចអំពីសុតៈ គឺអ្នកប្រាជ្ញដឹងច្បាស់ថាមានសមាធិជាសារៈ បញ្ញានឹងសុតៈ រមែងមិនចំរើន ដល់នរជនដែលជាអ្នកមានចិត្តហ៊ាស ជាអ្នកធ្វេសប្រហែស ។

ធម្មេ ច យេ អរិយប្បវេទិតេ រតា

អនុត្តរា តេ វចសា មនសា កម្មុនា ច

តេ សន្តិសោរច្ចសមាធិសណ្ឋិតា

សុតស្ស បញ្ញាយ ច សារមជ្ឈគូតិ ។

កឹសីលសុត្តំ នវមំ ។

## ទសមំ ឧដ្ឋានសុត្តំ

(៣៤) ឧដ្ឋហថ និសីទថ កោ អត្ថោ សុបិតេន វោ

អាតុរានំ ហិ កា និទ្ទា សល្លវិទ្ធាន រុប្បតំ ។

ឧដ្ឋហថ និសីទថ ទឡ្ហំ សិក្ខថ សន្តិយា

មា វោ បមត្តេ វិញ្ញាយ (មច្ចុរាជា) អមោហយិត្ថ វសានុគេ ។

មួយទៀត ជនពួកណា ត្រេកអរក្នុងធម៌ដែលអរិយបុគ្គលសំដែងហើយ ជនពួកនោះ រមែងប្រសើរដោយវចីកម្ម មនោកម្ម និងកាយកម្ម ជនពួកនោះ រមែងឋិតនៅ ក្នុងសេចក្តីស្ងប់ស្ងាត់ ស្ងប់ស្ងៀម និងសមាធិ ហើយបានដល់នូវខ្លឹមនៃការស្តាប់ផង នៃប្រាជ្ញាផង ។

ចប់ កឹសីលសូត្រ ទី ៩ ។

## ឧដ្ឋានសូត្រ ទី ១០

(៣៤) ( ព្រះមានព្រះភាគទ្រង់ត្រាស់នឹងពួកភិក្ខុយ៉ាងនេះថា ) អ្នកទាំងឡាយចូរក្រោក (ចូរអង្គុយចំរើនកម្មដ្ឋាន) ប្រយោជន៍អ្វី ដោយការដេកលក់របស់អ្នកទាំងឡាយ ព្រោះថា អ្នកទាំងឡាយ ឈឺជានិច្ច ត្រូវសរគឺរាគាទិក្កិលេសបាក់ដោតហើយ កំពុងតែលំបាក ម្តេចក៏នៅដេកលក់ ។

អ្នកទាំងឡាយ ចូរក្រោកអង្គុយ ចូរសិក្សាឲ្យមាំមួនដើម្បីសេចក្តីស្ងប់ កុំឲ្យមច្ចុរាជ បានដឹងនូវអ្នកទាំងឡាយ ថាជាអ្នកប្រមាទហើយធ្វើឲ្យវង្វេង លុះក្នុងអំណាចនៃខ្លួនឡើយ ។

យាយ ទេវា មនុស្សា ច សិតា តិដ្ឋន្តិ អត្ថិកា
តរថេតំ វិសត្តិកំ ខណោ វោ(១) មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។
បមាទោ រជោ បមាទោ បមាទានុបតិតោ រជោ
អប្បមាទេន វិជ្ជាយ អព្វូឡ្ហេ(២) សល្លមត្តនោតិ

ឧដ្ឋានសុត្តំ ទសមំ ។

# ឯកាទសមំ រាហុលសុត្តំ

(៣៩) កច្ចិ អភិណ្ហសំវាសា នាវជានាសិ បណ្ឌិតំ
ឧក្កាធារោ មនុស្សានំ កច្ចិ(៣)អបចិតោ តយា ។

---

១ ខុ.ម. ខណោ វេ ។ ២ ខុ. អព្វហេ ។ ម. អព្ពុយេ ។ ៣ ម. កិញ្ចិ ។

ពួកទេវតានិងមនុស្ស ត្រូវការនឹងអារម្មណ៍ជាដើមអាស្រ័យជាប់នៅ ( ក្នុងអារម្មណ៍នោះ ) ព្រោះតណ្ហាណា អ្នកទាំងឡាយចូរឆ្លងនូវតណ្ហាជាគ្រឿងផ្សាយទុំ កុំឲ្យខណៈកន្លងផុតនូវអ្នកទាំងឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្លងហើយ រមែងសោកណែនណាន់ក្នុងនរក ។

សេចក្តីប្រមាទជាធូលី ធូលីធ្លាក់ចុះតាមសេចក្តីប្រមាទ ព្រោះតែសេចក្តីប្រមាទ កុលបុត្រដកចោល នូវសរគឺរាគាទិក្កិលេសរបស់ខ្លួនបាន ដោយវិជ្ជាគឺអាសវក្ខយញ្ញាណ ព្រោះតែសេចក្តីមិនប្រមាទ ។

ចប់ ឧដ្ឋានសូត្រ ទី ១០ ។

## រាហុលសូត្រ ទី ១១

(៣៤) (ព្រះមានព្រះភាគត្រាស់សួរថា) អ្នកមិនមើលងាយអ្នកប្រាជ្ញ ព្រោះតែនៅរួមគ្នារឿយៗទេឬ បុគ្គលអ្នកច្រាលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស អ្នកកោតក្រែងដែរឬ ។

នាហំ អភិណ្ហសំវាសា អវជានាមិ បណ្ឌិតំ

ឧក្កាធារោ មនុស្សានំ និច្ចំ អបចិតោ មយា ។

បញ្ច កាមគុណេ ហិត្វា បិយរូបេ មនោរមេ

សទ្ធាយ ឃរា និក្ខម្ម ទុក្ខស្សន្តករោ ភវ ។

មិត្តេ ភជស្សុ កល្យាណេ បន្តញ្ច សយនាសនំ

វិវិត្តំ អប្បនិគ្ឃោសំ មត្តញ្ញូ ហោហិ ភោជនេ ។

ចីវរេ បិណ្ឌបាតេ ច បច្ចយេ សយនាសនេ

ឯតេសុ តណ្ហមាកាសិ មា លោកំ បុនរាគមិ ។

សំវុតោ បាតិមោក្ខស្មឹ ឥន្ទ្រិយេសុ ច បញ្ចសុ

សតិ កាយគតា ត្យត្ថុ និព្វិទាពហុលោ ភវ ។

(ព្រះរាហុលដ៏មានអាយុក្រាបទូលថា) ខ្ញុំព្រះអង្គមិនមើលងាយអ្នកប្រាជ្ញព្រោះតែនៅរួមគ្នារឿយៗទេ បុគ្គលអ្នកទ្រោលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស ខ្ញុំព្រះអង្គគោរពក្រែងជានិច្ច។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) អ្នកចូរលះនូវកាមគុណ ៥ មានសភាពជាទីស្រឡាញ់ ជាទីត្រេកអរនៃចិត្ត ចេញចាកផ្ទះមកបួសដោយសទ្ធា ហើយធ្វើនូវទីបំផុតទុក្ខចុះ។

អ្នកចូរគប់រកនូវកល្យាណមិត្ត និងទីដេក ទីអង្គុយដ៏ស្ងាត់ ស្ងប់ស្ងាត់ មិនមានសំឡេងគឹកកង ចូរជាអ្នកស្គាល់ប្រមាណក្នុងភោជន ។

អ្នកកុំធ្វើបំណង ក្នុងបច្ច័យទាំងនេះ គឺចីវរបច្ច័យ បិណ្ឌបាតបច្ច័យ សេនាសនបច្ច័យ និងគិលានបច្ច័យឡើយ កុំត្រឡប់មកកាន់លោកទៀតឡើយ ។

អ្នកចូរសង្រួម ក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ចូរមានស្មារតី ប្រព្រឹត្តទៅក្នុងកាយ ចូរជាបុគ្គលច្រើនដោយសេចក្តីនឿយណាយ ។

និមិត្តំ បរិវជ្ជេហិ សុភំ រាគូបសញ្ហិតំ
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ
អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ
តតោ មានាភិសមយា ឧបសន្តោ ចរិស្សសីតិ ។
ឥត្ថំ សុទំ ភគវា អាយស្មន្តំ រាហុលំ ឥមាហិ
គាថាហិ អភិណ្ហំ ឱវទតីតិ ។

រាហុលសុត្តំ ឯកាទសមំ ។

## ទ្វាទសមំ វង្គីសសុត្តំ

(៣៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ តេន ខោ បន សមយេន អាយស្មតោ វង្គីសស្ស ឧបជ្ឈាយោ និគ្រោធកប្បោ នាម ថេរោ អគ្គាឡវេ ចេតិយេ អចិរបរិនិព្វុតោ ហោតិ ។ អថខោ

អ្នកចូរលះនូវសុភនិមិត្ត ដែលប្រកបដោយរាគៈ ចូរចំរើនចិត្តដោយអសុភ ឲ្យជាចិត្តមូលតែមួយ តាំងមាំដោយប្រពៃ មួយទៀត ចូរចំរើន នូវអនិមិត្តវិបស្សនា ចូរលះនូវអនុស័យគឺមានះ លំដាប់តអំពីនោះ អ្នកនឹងប្រព្រឹត្តស្ងប់រម្ងាប់ ព្រោះលះបង់មានះ ។

ព្រះមានព្រះភាគ ទ្រង់ទូន្មានព្រះរាហុល ដ៏មានអាយុជារឿយៗ ដោយគាថាទាំងនេះ ដោយប្រការយ៉ាងនេះឯង ។

ចប់ រាហុលសូត្រ ទី ១១ ។

## វង្គីសសូត្រទី ១២

(៣៦) ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអគ្គាឡវចេតិយវិហារ ជិតក្រុងអាឡវី ។ សម័យនោះឯង ព្រះថេរៈឈ្មោះ និគ្រោធកប្បៈ ជាឧបជ្ឈាយ៍ របស់ព្រះវង្គីសៈមានអាយុ ទើបតែបរិនិព្វានថ្មីៗ ក្នុងអគ្គាឡវចេតិយវិហារ ។ គ្រានោះ

អាយស្មតោ វង្គីសស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ បរិនិព្វុតោ នុ ខោ មេ ឧបជ្ឈាយោ ឧទាហុ នោ បរិនិព្វុតោតិ ។ អថខោ អាយស្មា វង្គីសោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា វង្គីសោ ភគវន្តំ ឯតទវោច ឥធ មយ្ហំ ភន្តេ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ បរិនិព្វុតោ នុ ខោ មេ ឧបជ្ឈាយោ ឧទាហុ នោ បរិនិព្វុតោតិ ។ អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

ព្រះវង្គីសៈដ៏មានអាយុ នៅក្នុងទីស្ងាត់ គេចចេញចាកការម្មណ៍ សម្ងំនៅ កើតមានសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះ ថាព្រះឧបជ្ឈាយ៍របស់អាត្មាអញ បរិនិព្វានហើយ ឬ មិនទាន់បរិនិព្វានទេ ។ លំដាប់នោះ ព្រះវង្គីសៈដ៏មានអាយុ ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅ គាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ ព្រះវង្គីសៈដ៏មានអាយុ លុះអង្គុយ ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គ នៅក្នុងទីស្ងាត់ ពួនសម្ងំនៅក្នុងអគ្គាឡវចេតិយវិហារនេះ កើតមានសេចក្តីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា ព្រះឧបជ្ឈាយ៍របស់អាត្មាអញបរិនិព្វានហើយ ឬ មិនទាន់បរិនិព្វានទេ ។

លំដាប់នោះ ព្រះវង្គីសៈដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសួរ ចំពោះព្រះមានព្រះភាគ ដោយគាថាថា

(៣៧) បុច្ឆាម សត្ថារំ អនោមបញ្ញំ
ទិដ្ឋេវ ធម្មេ យោ វិចិកិច្ឆានំ
ឆេត្តា អគ្គាឡវេ កាលមកាសិ ភិក្ខុ
ញាតោ យសស្សី អភិនិព្វុតត្តោ
និគ្រោធកប្បោ ឥតិ តស្ស នាមំ
តយា កតំ ភគវា ព្រាហ្មណស្ស
សោ តំ នមស្សំ អចរី(១) មុត្យបេក្ខោ
អារទ្ធវីរិយោ ទឡ្ហធម្មទស្សី ។
តំ សាវកំ សក្ក មយម្បិ សព្វេ
អញ្ញាតុមិច្ឆាម សមន្តចក្ខុ
សមវដ្ឋិតា នោ សវនាយ សោតា
តុវំ នោ សត្ថា ត្វមនុត្តរោសិ ។
ឆិន្ទេវ នោ វិចិកិច្ឆំ ព្រូហិ មេតំ
បរិនិព្វុតំ វេទយ ភូរិបញ្ញ

---

១ ឱ. ម. អចរិ ។

(៣៧) ពួកខ្ញុំព្រះអង្គ សូមសួរព្រះសាស្ដាព្រះអង្គមានបញ្ញា មិនខ្សោយខ្សោកថោកទាប ភិក្ខុណាជាអ្នកកាត់ផ្ដាច់នូវសេចក្ដីសង្ស័យក្នុងបច្ចុប្បន្ន មានកេរ្តិ៍ឈ្មោះ មានយស មានចិត្តត្រជាក់ បានធ្វើមរណកាលក្នុងអគ្គាឡវចេតិយវិហារ ។ បពិត្រព្រះមានព្រះភាគ ឈ្មោះរបស់ភិក្ខុជាព្រាហ្មណ៍នោះ ព្រះអង្គទ្រង់ប្រោសប្រទានហើយថា និគ្រោធកប្បភិក្ខុនោះ កាលនមស្ការនូវព្រះអង្គ ជាអ្នកប្រាថ្នានូវការផុតស្រឡះ (ចាកកិលេស) បានប្រារព្ធព្យាយាម ឃើញនូវធម៌ដ៏មាំ ។ បពិត្រព្រះសក្យៈ មានចក្ខុជុំវិញគឺសព្វញ្ញុតញ្ញាណ ពួកខ្ញុំព្រះអង្គទាំងអស់គ្នា ចង់ដឹងនូវសាវ័កនោះ ពួកខ្ញុំព្រះអង្គបានប្រុងត្រចៀកនឹងស្ដាប់ ជាស្រេចហើយ ព្រះអង្គជាគ្រូរបស់ពួកខ្ញុំព្រះអង្គ ព្រះអង្គជាបុគ្គលប្រសើរលើស ។ បពិត្រព្រះអង្គអ្នកមានប្រាជ្ញាក្រាស់ដូចជាផែនដី សូមព្រះអង្គកាត់បង់នូវសេចក្ដីសង្ស័យ របស់ពួកខ្ញុំព្រះអង្គ សូមទ្រង់សំដែងនូវសេចក្ដីនុ៎ះ ដល់ខ្ញុំព្រះអង្គ សូមទ្រង់ត្រាស់ប្រាប់នូវភិក្ខុដែលបរិនិព្វានហើយ ។

មជ្ឈេ ច នោ ភាស សមន្តចក្ខុ
សក្កោវ ទេវានំ សហស្សនេត្តោ ។

យេ កេចិ គន្ថា ឥធ មោហមគ្គា
អញ្ញាណបក្ខា វិចិកិច្ឆដ្ឋានា
តថាគតំ បត្វា ន តេ ភវន្តិ
ចក្ខុំ ហិ ឯតំ បរមំ នរានំ ។

នោ ចេ ហិ ជាតុ បុរិសោ កិលេសេ
វាតោ យថា អព្ភឃនំ វិហានេ
តមោវស្ស និវុតោ សព្វលោកោ
ន ជោតិមន្តោបិ នរា តបេយ្យុំ ។

ធីរា ច បជ្ជោតករា ភវន្តិ
តំ តំ អហំ វីរ តថេវ មញ្ញេ

បពិត្រព្រះអង្គអ្នកមានចក្ខុជុំវិញ សូមព្រះអង្គទ្រង់ប្រកាសក្នុង កណ្តាលពួកខ្ញុំព្រះអង្គ ដូចជាព្រះឥន្ទ ជាសហស្សនេត្រ (ទ្រង់ប្រកាសក្នុងកណ្តាល) ពួកទេវតា ។ គន្ថកិលេសណាមួយ ដែលជាផ្លូវនៃមោហៈ ជាពួកនៃកិរិយាមិនដឹង ជាទីតាំងនៃសេចក្តីសង្ស័យ ក្នុងលោកនេះ គន្ថកិលេសទាំងនោះ មានដល់នូវព្រះតថាគត រមែងមិនមាន ព្រោះព្រះអង្គមានភ្នែកដ៏ឧត្តម ជាងនរជនទាំងឡាយ ។ ក៏ប្រសិនបើ ព្រះមានព្រះភាគ ជាវិញ្ញុបុរស មិនកំចាត់បង់កិលេស ដូចជាខ្យល់កំចាត់នូវពពកទេ លោកទាំងអស់ ដែលមោហៈរួបរឹតហើយ ក៏នៅជាងងឹតសូន្យ សូម្បីពួកនរជនដែលមានពន្លឺ ក៏មិនគប្បីភ្លឺច្បាស់បាន ។ មួយទៀត ពួកអ្នកប្រាជ្ញជាអ្នកធ្វើនូវពន្លឺរុងរឿង គឺបញ្ញា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ព្រោះហេតុនោះ បានជា ខ្ញុំព្រះអង្គសំគាល់នូវព្រះអង្គថាជា យ៉ាងនោះឯង

វិបស្សិនំ ជានមុបាគមម្ហា

បរិសាសុ នោ អាវិករោហិ កប្បំ ។

ខិប្បំ គិរំ ឯរយ វគ្គុ វគ្គុំ

ហំសោវ បគ្គយ្ហ សណិំ និកូជ(១)

ពិន្ទុស្សរេន សុវិកប្បិតេន

សព្វេវ តេ ឧជ្ជុគតា សុណោម ។

បហីនជាតិមរណំ អសេសំ

និគ្គយ្ហ ធោនំ វទេស្សាមិ ធម្មំ

ន កាមការោ ហិ បុថុជ្ជនានំ

សង្ខេយ្យការោ ច តថាគតានំ ។

---

១ ម. សណិកំ និកូជិ ។

ពួកខ្ញុំព្រះអង្គដឹងថា ព្រះអង្គជាអ្នកឃើញតាមពិត ទើបនាំគ្នាចូលមកគាល់ព្រះអង្គ សូមព្រះអង្គទ្រង់សំដែង ឲ្យប្រាកដនូវនិគ្រោធកប្បត្ថេរ ចំពោះពួកខ្ញុំព្រះអង្គ ក្នុងពួកបរិស័ទ បពិត្រព្រះអង្គមានព្រះសូរសៀងដ៏ពីរោះ សូមព្រះអង្គទ្រង់ត្រាស់ នូវព្រះវាចាជាទីគាប់ចិត្តជាឆាប់ សូមព្រះអង្គទ្រង់បញ្ចេញព្រះសូរសៀងសន្សឹមៗ ដោយព្រះសូរសៀងមូលពីរោះ ដែលសន្ធារតាក់តែងទុកដោយល្អ ដូចហង្ស ផ្គង់ស្រែកសម្រែកបន្តិច ៗ ខ្ញុំព្រះអង្គទាំងអស់គ្នា តាំងចិត្តត្រង់ នឹងប្រុងស្តាប់ព្រះអង្គ ។ ខ្ញុំព្រះអង្គ នឹងសូមទទូចអារាធនាព្រះអង្គអ្នកមានជាតិនឹងមរណៈលះបង់ហើយ មិនសេសសល់ កំចាត់បង់ (នូវបាបទាំងពួង) ឲ្យទ្រង់សំដែងនូវធម៌ ព្រោះថា ការធ្វើបានតាមប្រាថ្នា មិនមានដល់បុថុជ្ជនឡើយ ចំណែកខាងការពិចារណា ហើយធ្វើបានតាមប្រាថ្នា រមែងមាន ដល់ព្រះតថាគតទាំងឡាយ ។

សម្បន្នវេយ្យាករណំ ត្វយិទំ

សមុជ្ជុបញ្ញស្ស សមុគ្គហិតំ

អយមញ្ជលី បច្ឆិមោ សុប្បណាមិតោ

មា មោហយី ជានមនោមបញ្ញ

បរោវរំ អរិយធម្មំ វិទិត្វា

មា មោហយី ជានមនោមវីរ

វារឹ យថា ឃម្មនិ ឃម្មតត្តោ

វាចាភិកង្ខាមិ សុតស្ស វស្ស ។

យទត្ថិកំ ព្រហ្មចរិយំ អចរិ

កប្បាយនោ កច្ចិស្ស(១) តំ អមោឃំ

និព្វាយិ សោ អាទុ សឧបាទិសេសោ

យថា វិមុត្តោ អហុ តំ សុណោម ។

---

១ ឱ. កប្បិស្ស ។

សម្បន្នវេយ្យាករណ៍ (ការព្យាករណ៍ដ៏ត្រឹមត្រូវ) នេះគឺព្រះអង្គមានបញ្ញារុងរឿងបានត្រាស់ប្រពៃហើយ អញ្ជលីជាទីបំផុតនេះ ខ្ញុំព្រះអង្គបានប្រណម្យហើយដោយប្រពៃ បពិត្រព្រះអង្គមានប្រាជ្ញា មិនទន់ទាប កាលព្រះអង្គទ្រង់ជ្រាប (នូវគតិនៃព្រះនិគ្រោធកប្បៈ) កុំឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ។ បពិត្រព្រះអង្គ មានព្យាយាម មិនទន់ទាប ព្រះអង្គបានជ្រាបច្បាស់នូវអរិយសច្ចធម៌ដ៏ប្រសើរក្រៃលែង កាលព្រះអង្គទ្រង់ជ្រាប នូវញេយ្យធម៌ទាំងពួង កុំឲ្យខ្ញុំព្រះអង្គវង្វេងឡើយ ខ្ញុំព្រះអង្គប្រាថ្នានូវព្រះវាចា (របស់ព្រះអង្គ) ដូចជាបុគ្គលក្តៅដោយកំដៅថ្ងៃក្នុងរដូវក្តៅប្រាថ្នារកទឹក សូមព្រះអង្គបង្អុរនូវព្រះសូរសៀង ។ និគ្រោធកប្បភិក្ខុ បានប្រព្រឹត្តព្រហ្មចរិយធម៌ដ៏មានប្រយោជន៍ណា ព្រហ្មចរិយធម៌នោះ របស់លោកមិនឥតប្រយោជន៍តិចតួចឡើយ លោកនោះបាននិព្វានដូចជាអសេក្ខបុគ្គលដែលមានចិត្តផុតហើយ ឬជាសឧបាទិសេសៈ (ដូចជាសេក្ខបុគ្គល) ពួកខ្ញុំព្រះអង្គ ប្រុងស្តាប់នូវព្រះបន្ទូលរបស់ព្រះអង្គនោះ ។

អច្ឆេច្ឆិ(១) តណ្ហំ ឥធ នាមរូបេ [ឥតិ ភគវា]
កណ្ហស្ស សោតំ ទីឃរត្តានុសយិតំ
អតារិ ជាតឹ មរណំ អសេសំ
ឥច្ចព្រវី ភគវា បញ្ចសេដ្ឋោ ។
ឯស សុត្វា បសីទាមិ វចោ តេ ឥសិសត្តម
អមោឃំ កិរ មេ បុដ្ឋំ ន មំ វញ្ចេសិ ព្រាហ្មណោ ។
យថាវាទី តថាការី អហុ ពុទ្ធស្ស សាវកោ
អច្ឆិទា មច្ចុនោ ជាលំ តតំ មាយាវិនោ ទឡ្ហំ ។
អទ្ទស ភគវា អាទឹ ឧបាទានស្ស កប្បិយោ
អច្ចគា វត កប្បាយនោ មច្ចុធេយ្យំ សុទុត្តរន្តិ ។

វង្គីសសុត្តំ ទ្វាទសមំ ។

១ ម. អច្ឆេជ្ជិ ។

(ព្រះមានព្រះភាគទ្រង់ព្យាករថា) និគ្រោធកប្បភិក្ខុបានកាត់ផ្តាច់នូវតណ្ហា ក្នុងនាមរូបនេះ ជាខ្សែធម៌ខ្មៅគឺកិលេសមារ ដែលដេកត្រាំអស់កាលជាអង្វែង បានឆ្លងផុតការកើតនិងការស្លាប់ មិនមានសេសសល់ ព្រះមានព្រះភាគប្រសើរជាងបញ្ចវគ្គិយភិក្ខុ បានត្រាស់ព្យាករដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គជាឥសីគំរប់៧(១) ខ្ញុំព្រះអង្គនោះ បានស្តាប់ព្រះបន្ទូលព្រះអង្គ ហើយជ្រះថ្លា ព្រោះប្រស្នាដែលខ្ញុំព្រះអង្គក្រាបទូលសួរ មិនឥតអំពើទេ ព្រះអង្គជាព្រាហ្មណ៍មិនបានបញ្ឆោតខ្ញុំព្រះអង្គទេ ។ សាវ័ករបស់ព្រះពុទ្ធនិយាយយ៉ាងណា ធ្វើយ៉ាងនោះ បានកាត់ផ្តាច់នូវបណ្តាញ គឺតណ្ហាដ៏មាំរបស់មច្ចុមារ ដែលមានមាយាច្រើន ដែលផ្សាយទៅ (ក្នុងតេភូមិកវដ្តៈ) នោះ ។ បពិត្រព្រះមានព្រះភាគ និគ្រោធកប្បភិក្ខុ បានឃើញហេតុជាខាងដើមនៃឧបាទាន នហ្ន៉ និគ្រោធកប្បភិក្ខុ បានប្រព្រឹត្តកន្លងនូវ (តេភូ-មិកវដ្តៈ) ជាទីទ្រទ្រង់នៅនៃមច្ចុមារ ដែលគេឆ្លងបានដោយកម្រក្រពេក ។

ចប់ វង្គីសសូត្រ ទី ១២ ។

---

១– យកឥសី ៦ គឺវិបស្សី សិខី វេស្សភូ កកុសន្ធៈ កោនាគមនៈ កស្សបៈ រួមនឹងព្រះអង្គ ត្រូវជា ឥសី ៧ គឺព្រះអង្គជាឥសីទី ៧ ។ អដ្ឋកថា ។

## តេរសមំ សម្មាបរិព្វាជនិយសុត្តំ

(៣៨) ពុច្ឆាមិ មុនឹ បហូតបញ្ញំ

តិណ្ណំ (បារគតំ) បរិនិព្វុតំ ឋិតត្តំ

និក្ខម្ម ឃរា បនុជ្ជ កាមេ

កថំ (ភិក្ខុ) សម្មា សោ លោកេ បរិព្វជេយ្យ ។

យស្ស មង្គលា សមូហតា (ឥតិ ភគវា)

ឧប្បាតា សុបិនា ច លក្ខណា ច

ស មង្គលទោសវិប្បហីនោ

(ភិក្ខុ) សម្មា សោ លោកេ បរិព្វជេយ្យ ។

រាគំ វិនយេថ មានុសេសុ

ទិព្វេសុ កាមេសុ ចាបិ ភិក្ខុ

អតិក្កម្ម ភវំ សមេច្ច ធម្មំ

សម្មា សោ លោកេ បរិព្វជេយ្យ ។

# សម្មាបរិព្វាជនិយសូត្រ ទី ១៣

(៣៨) (ព្រះពុទ្ធនិម្មិតទ្រង់សួរថា) ខ្ញុំសូមសួរនូវព្រះមុនីដែលមានប្រាជ្ញាច្រើន បានឆ្លងចាកឱឃៈ (ដល់នូវត្រើយគឺព្រះនិព្វាន) បានរំលត់ហើយ មានព្រះទ័យតាំងនៅមាំ ភិក្ខុបន្ទោបង់នូវកាមទាំងឡាយ ហើយចេញចាកផ្ទះ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃក្នុងលោក តើដោយប្រការ ដូចម្តេច ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ភិក្ខុណាបាន គាស់រំលើង នូវមង្គលផង នូវការប្រកាន់ឧប្បាត (១) (មានផ្ទុះបាញ់ជាដើម) ផង នូវការប្រកាន់យល់សប្តិផង នូវការប្រកាន់លក្ខណៈផង ភិក្ខុនោះ ឈ្មោះថា បានលះបង់ស្រឡះ នូវមង្គលជាទោស ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុបន្ទោបង់នូវតម្រេក ក្នុងកាមទាំងឡាយ ជារបស់មនុស្សផង របស់ទេវតាផង កន្លងនូវភព បានត្រាស់ដឹងនូវធម៌ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

---

១ ការបណ្តាលធម្មជាតិ ដូចជាដុំភ្លើងហោះ ផ្ទុះបាញ់ ។

វិបិដ្ឋកត្វា(១) បេសុណានិ

កោធំ កទរិយំ ជហេយ្យ ភិក្ខុ

អនុរោធវិរោធវិប្បហីនោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

ហិត្វាន បិយញ្ច អប្បិយញ្ច

អនុបាទាយ អនិស្សិតោ កុហិញ្ចិ

សំយោជនិយេហិ វិប្បមុត្តោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

ន សោ ឧបធីសុ សារមេតិ

អាទានេសុ វិនេយ្យ ឆន្ទរាគំ

សោ អនិស្សិតោ អនញ្ញនេយ្យោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

---

១ ម. វិបីតី កត្វាន ។

ភិក្ខុធ្វើចិត្តមិនឲ្យត្រេកអរ លះនូវពាក្យញុះញង់ទាំងឡាយ នូវសេចក្ដីក្រោធនិងសេចក្ដីកំណាញ់ លះនូវរាគៈនិងទោសៈ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុលះបង់នូវសេចក្ដីស្រឡាញ់និងស្អប់ មិនប្រកាន់មាំ មិនអាស្រ័យ ក្នុងសភាវៈតិចតួច (ដោយតណ្ហានិងទិដ្ឋិ) ឡើយ មានចិត្តផុតស្រឡះហើយ ចាកសំយោជនិយធម៌ទាំងឡាយ ( ធម៌ជាអារម្មណ៍នៃសំយោជនៈ ) ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុនោះ បន្ទោបង់នូវឆន្ទរាគ ក្នុងខន្ធជាគ្រឿងប្រកាន់ មិនដល់ ( នូវការឃើញ ) ថា មានខ្លឹមក្នុងឧបធិ គឺខន្ធទាំងឡាយនោះ ជាបុគ្គលមិនអាស្រ័យ (ដោយឆន្ទៈនិងរាគៈ) មិនបាច់មានបុគ្គលដទៃណែនាំឡើយ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

វចសា មនសា ច កម្មុនា ច
អវិរុទ្ធោ សម្មា វិទិត្វា ធម្មំ
និព្វានបទាភិបត្ថយានោ
សម្មា សោ លោកេ បរិព្វជេយ្យ ។
យោ វន្ទតិ មន្តិ ន ឧណ្ណមេយ្យ
អក្កុដ្ឋោបិ ន សន្ធិយេថ ភិក្ខុ
លទ្ធា បរភោជនំ ន មជ្ជេ
សម្មា សោ លោកេ បរិព្វជេយ្យ ។
លោភញ្ច ភវញ្ច វិប្បហាយ
វិរតោ ឆេទនពន្ធនតោ ភិក្ខុ
សោ តិណ្ណកថង្កថោ វិសល្លោ
សម្មា សោ លោកេ បរិព្វជេយ្យ ។
សារុប្បមត្តនោ វិទិត្វា
ន ច ភិក្ខុ ហឹសេយ្យ កញ្ចិ លោកេ
យថាតថំ ធម្មំ វិទិត្វា
សម្មា សោ លោកេ បរិព្វជេយ្យ ។

ភិក្ខុមិនក្លាត់ខុស ដោយកាយ វាចានឹងចិត្ត ដឹងច្បាស់នូវធម៌ដោយប្រពៃ ប្រាថ្នាយកនូវបទគឺព្រះនិព្វាន ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុណា មិនក្រអឺតក្រទុង ដោយគិតថា គេថ្វាយបង្គំអញ សូម្បីគេជេរក៏មិនតបត បាននូវភោជនរបស់អ្នកដទៃឡើយ ក៏មិនស្រវឹង ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុលះបង់សេចក្តីលោភនឹងភព វៀរចាកការកាប់កាត់ នឹងការចង (សត្វដទៃ) ភិក្ខុនោះ ជាអ្នកឆ្លងផុតចាកសេចក្តីងឿងឆ្ងល់ ប្រាសចាកសរ គឺសេចក្តីសោក ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុណា បានដឹងច្បាស់នូវសេចក្តីប្រព្រឹត្ត ដ៏សមគួររបស់ខ្លួនផង មិនបៀតបៀនជនដទៃណាមួយ ក្នុងលោកផង ដឹងច្បាស់នូវធម៌ តាមសេចក្តីពិត ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

យស្សានុសយា ន សន្តិ កេចិ

មូលា អកុសលា សមូហតាសេ

សោ និរាសសោ(១) អនាសសានោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

អាសវខីណោ បហីនមានោ

សព្វំ រាគបថំ ឧបាតិវត្តោ

ទន្តោ បរិនិព្វុតោ ឋិតត្តោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

សទ្ធោ សុតវា និយាមទស្សី

វគ្គគតេសុ ន វគ្គសារី

ធីរោ លោភំ ទោសំ វិនេយ្យ បដិឃំ

សម្មា សោ លោកេ បរិព្វជេយ្យ ។

---

១. ឱ. និរាសយោ ។ ម. និរាសោ ។

អនុស័យទាំងឡាយណាមួយ មិនមានដល់ភិក្ខុណា អកុសលមូលទាំងឡាយ ភិក្ខុណាបានដកចោលហើយ ភិក្ខុនោះ ជាអ្នកមិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីអាឡោះអាល័យ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុអ្នកអស់អាសវៈហើយ លះបង់នូវមានះ កន្លងផុតនូវធម៌ ជាគន្លងនៃរាគៈទាំងអស់ ទូន្មានខ្លួន សម្រេចនូវព្រះនិព្វាន មានចិត្តតាំងនៅមាំ ភិក្ខុនោះ ឈ្មោះថាវៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុអ្នកមានសទ្ធា ប្រកបដោយសុតៈ ប្រព្រឹត្តទៅក្នុងបរមត្ថ បានឃើញសម្មត្តនិយាមគឺមគ្គ កាលពួកសត្វប្រព្រឹត្តទៅដោយទិដ្ឋិ ៦២ ក៏មិនប្រព្រឹត្តទៅដោយពួក ជាអ្នកប្រាជ្ញអាចបន្ទោបង់នូវលោភៈ ទោសៈនឹងសេចក្តីថ្នាំងថ្នាក់ ភិក្ខុនោះឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

សំសុទ្ធជិនោ វិវដច្ឆទោ

ធម្មេសុ វសី បារគូ អនេជោ

សង្ខារនិរោធញាណកុសលោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

អតីតេសុ អនាគតេសុ ចាបិ

កប្បាតីតោ អតិច្ចសុទ្ធិបញ្ញោ

សព្វាយតនេហិ វិប្បមុត្តោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

អញ្ញាយ បទំ សមេច្ច ធម្មំ

វិវដំ ទិស្វាន បហានមាសវានំ

សព្វុបធីនំ បរិក្ខយា នោ

សម្មា សោ លោកេ បរិព្វជេយ្យ ។

ភិក្ខុបានឈ្នះកិលេស ដោយអរហត្តមគ្គដ៏បរិសុទ្ធ បើកចេញនូវកិលេសជាគ្រឿងប្រក់ ជាអ្នកស្ទាត់ក្នុងចតុសច្ចធម៌ ដល់នូវត្រើយគឺព្រះនិព្វាន មានសន្តានមិនរំភើបដោយតណ្ហា ជាអ្នកឈ្លាសវៃ ក្នុងអរិយមគ្គ គ្រឿងដឹងនូវធម៌ជាទីរលត់នៃសង្ខារ ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃក្នុងលោក ។

ភិក្ខុកន្លងនូវកប្បៈ(១)គឺតណ្ហា និងទិដ្ឋិ ក្នុងខន្ធទាំងឡាយ ដែលជាអតីតនិងអនាគត ជាអ្នកមានប្រាជ្ញាដ៏បរិសុទ្ធ ព្រោះកន្លងផុត (នូវអទ្ធា ៣(២)) មានចិត្តផុតស្រឡះចាកអាយតនៈទាំងពួង ភិក្ខុនោះ ឈ្មោះថាវៀរដោយប្រពៃ ក្នុងលោក ។

ភិក្ខុកំណត់ដឹង នូវបទគឺសច្ចៈមួយ ៗ ហើយត្រាស់ដឹងនូវសច្ចធម៌ ឃើញនូវព្រះនិព្វាន មិនមានគ្រឿងដោតក្រង ជាទីលះបង់ នូវអាសវៈទាំងឡាយ ព្រោះអស់ទៅនៃឧបធិកិលេសទាំងពួង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ។

---

១ ការប្រកាន់ខ្ជាប់ថា អញ របស់អញ ក៏បាន ។ ២ អទ្ធា ៣ គឺ អតីតទ្ធា បានដល់អវិជ្ជាសង្ខារ, អនាគតទ្ធា បានដល់ ជាតិជរាមរណៈ, បច្ចុប្បន្នទ្ធា បានដល់ វិញ្ញាណជាខាងដើម ភវៈជាទីបំផុត ។ អដ្ឋកថា ។

អទ្ធា ហិ ភគវា តថេវ ឯតំ
យោ សោ ឯវំវិហារី ទន្តោ ភិក្ខុ
សព្វសំយោជនិយេ វីតិវត្តោ
សម្មា សោ លោកេ បរិព្វជេយ្យាតិ ។

សម្មាបរិព្វាជនិយសុត្តំ តេរសមំ ។

# ចុទ្ទសមំ ធម្មិកសុត្តំ

(៣៩) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ធម្មិកោ ឧបាសកោ បញ្ចហិ ឧបាសកសតេហិ សទ្ធិំ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ធម្មិកោ ឧបាសកោ ភគវន្តំ គាថាយ អជ្ឈភាសិ

(ព្រះនិម្មិតពុទ្ធពោលសរសើរថា) សេចក្តីពិតថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធដីកាយ៉ាងនេះ មានសេចក្តីបែបនោះដដែលថា ភិក្ខុណា មានការនៅយ៉ាងនេះ ជាអ្នកទូន្មានខ្លួន ប្រព្រឹត្តកន្លងនូវសំយោជនធម៌ទាំងពួង ភិក្ខុនោះ ឈ្មោះថា វៀរដោយប្រពៃ ក្នុងលោក ៚

ចប់ សម្មាបរិព្វាជនិយសូត្រ ទី ១៣ ។

## ធម្មិកសូត្រ ទី ១៤

(៣៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ធម្មិកឧបាសក បានចូលទៅគាល់ព្រះមានព្រះភាគ ជាមួយនឹងពួកឧបាសក ប្រមាណ ៥០០ នាក់ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ ធម្មិកឧបាសក លុះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

(៤០) បុច្ឆាមិ តំ គោតម ភូរិបញ្ញ
កថង្ករោ សាវកោ សាធុ ហោតិ
យោ វា អគារា អនគារមេតិ
អគារិនោ វា បនុបាសកាសេ ។
តុវញ្ហិ លោកស្ស សទេវកស្ស
គតឹ បជានាសិ បរាយនញ្ច
ន ចត្ថិ(១) តុល្យោ និបុណត្ថទស្សី
តុវញ្ហិ ពុទ្ធំ បវរំ វទន្តិ ។
សព្វំ តុវំ ញាណមវេច្ច ធម្មំ
បកាសេសិ សត្តេ អនុកម្បមានោ
វិវដច្ឆទោសិ សមន្តចក្ខុ
វិរោចសិ វិមលោ សព្វលោកេ ។
អគច្ឆិ តេ សន្តិកេ នាគរាជា
ឯរាវណោ នាម ជិនោតិ សុត្វា
សោបិ តយា មន្តយិត្វាជ្ឈគមា
សាធូតិ សុត្វាន បតីតរូបោ ។

---

១ ម. ន បត្ថិ ។

(៤០) បពិត្រព្រះគោតម ទ្រង់មានព្រះបញ្ញាដូចផែនដី ខ្ញុំសូមក្រាបទូលសួរព្រះអង្គ បុគ្គលដែលចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្តី ឬក៏ពួកឧបាសកមានផ្ទះក្តី ប្រតិបត្តិដូចម្តេច ទើបហៅថា សាវកល្អ ។

ព្រោះព្រះអង្គជ្រាបច្បាស់នូវគតិផង នូវដំណើរទៅខាងនាយ (ចាកគតិ) ផង របស់សត្វលោកព្រមទាំងទេវលោក បុគ្គលជាអ្នកឃើញសេចក្តីល្អិត ស្មើដោយព្រះអង្គ មិនមានឡើយ អ្នកប្រាជ្ញទាំងឡាយ តែងពោលសរសើរព្រះអង្គថា ជាព្រះពុទ្ធដ៏ប្រសើរ ។

ព្រះអង្គបានត្រាស់ដឹងហើយ ទ្រង់អនុគ្រោះពួកសត្វ ទ្រង់ប្រកាសញាណនិងធម៌ទាំងពួង បពិត្រព្រះអង្គទ្រង់មានចក្ខុ គឺប្រាជ្ញាជុំវិញ ព្រះអង្គជាបុគ្គលមានកិលេសគ្រឿងប្រក់បើកចេញហើយ មិនមានមន្ទិល រុងរឿង ក្នុងលោកទាំងពួង ។

ស្តេចដំរីឈ្មោះឯរាវ័ណ បានឮថា ព្រះមានព្រះភាគ ទ្រង់ឈ្នះនូវបាបធម៌ហើយ ក៏ទៅក្នុងសំណាក់នៃព្រះអង្គ ស្តេចដំរីនោះ ប្រឹក្សានឹងព្រះអង្គ ហើយបានសម្រេចមគ្គផល បានស្តាប់ធម៌មានចិត្តត្រេកអរ (អនុមោទនា) ថា សាធុ ៗ

សុត្តនិបាតេ ទុតិយស្ស ចូឡវគ្គស្ស ចុទ្ទសមំ ធម្មិកសុត្តំ

រាជាបិ តំ វេស្សវណោ កុវេរោ
ឧបេតិ ធម្មំ បរិបុច្ឆមានោ
តស្សាបិ ត្វំ បុដ្ឋោ ព្រាវីសិ
សោ ចាបិ សុត្វាន បតីតរូបោ ។
យេ កេចិមេ តិត្ថិយា វាទសីលា
អាជីវកា វា យទិ វា និគណ្ឋា
បញ្ញាយ តំ នាតិតរន្តិ សព្វេ
ឋិតោ វជន្តំ វិយ សីឃគាមី ។
យេ កេចិមេ ព្រាហ្មណា វាទសីលា
វុឌ្ឍា បិ ព្រាហ្មណា សន្តិ កេចិ
សព្វេ តយី អត្ថពទ្ធា ភវន្តិ
យេ ចាបិ អញ្ញេ វាទិនោ មញ្ញមានា ។

សូម្បីស្តេច ឈ្មោះវេស្សវណកុវេរៈ ចូលទៅរកព្រះអង្គ ក៏សាកសួរនូវធម៌ លុះស្តេចនោះសួរហើយ ព្រះអង្គក៏បាន ព្យាករ ស្តេចនោះ លុះបានស្តាប់ ក៏មានចិត្តត្រេកអរ ។

ពួកតិរ្ថិយណាមួយ ទោះបើជាអាជីវក ឬនិគ្រន្ថ មានការ ពោល (អួត) ជាប្រក្រតី ពួកតិរ្ថិយទាំងអស់នោះក៏មិនកន្លង ព្រះអង្គដោយប្រាជ្ញាបាន ដូចជាបុគ្គលឈរមិនអាចនឹងកន្លង នូវបុរសដែលកំពុងស្ទុះទៅយ៉ាងរហ័ស បានដូច្នោះដែរ ។

ពួកព្រាហ្មណ៍ណាមួយ ដែលមានការ (អួត) ជាប្រក្រតី ឬពួកព្រាហ្មណ៍ណាមួយ ទោះបើជាព្រឹទ្ធាចារ្យ ពុំនោះសោត ពួកជនឯទៀតណា ដែលមានសេចក្តីសំគាល់ថា ពួកយើងក៏ជា អ្នកមានវាទៈដែរ ពួកព្រាហ្មណ៍ជាដើមទាំងអស់នោះ សុទ្ធ តែជាអ្នកជាប់ជំពាក់ដោយសេចក្តី ចំពោះព្រះអង្គ គឺប្រាថ្នា ឲ្យព្រះអង្គកាត់សេចក្តីឲ្យ ។

អយញ្ហិ ធម្មោ និបុណោ សុខោ ច
យោយំ តយា ភគវា សុប្បវុត្តោ
តមេវ សព្វេ មយំ សុស្សូសមានា(១)
តំ នោ(២) វទ បុច្ឆិតោ ពុទ្ធសេដ្ឋ ។

សព្វេបិមេ ភិក្ខវោ សន្និសិន្នា
ឧបាសកា ចាបិ តថេវ សោតុំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ
សុភាសិតំ វាសវស្សេវ ទេវា ។

សុណាថ មេ ភិក្ខវោ សាវយាមិ(៣) វោ
ធម្មំ ធុតំ តញ្ច(៤) ចរាថ សព្វេ
ឥរិយាបថំ បព្វជិតានុលោមិកំ
សេវេថ នំ អត្ថទស្សី មតិមា ។

---

១ ឱ. សុស្សូសមានា ។ ម. វិសុស្សូសមានា ។ ២ ឱ. ត្វន្នោ ។ ម. ត្វំ នោ ។
៣ ម. សារយិស្សាមិ ។ ៤ ម. ធុតង្គញ្ច ។

បពិត្រព្រះមានព្រះភាគ ធម៌ណាដែលព្រះអង្គសំដែងដោយប្រពៃហើយ ធម៌នេះឯង ជាធម៌ដ៏ល្អិតផង ជាធម៌នាំមកនូវសេចក្ដីសុខផង ពួកខ្ញុំព្រះអង្គទាំងអស់គ្នា ចង់ស្ដាប់នូវធម៌នោះឯង បពិត្រព្រះអង្គ ជាព្រះពុទ្ធដ៏ប្រសើរ កាលបើពួកខ្ញុំព្រះអង្គ ទូលសួរហើយ សូមព្រះអង្គ សំដែងនូវធម៌នោះឲ្យបាន ។

ពួកភិក្ខុនឹងពួកឧបាសក ទាំងអស់នេះ ក៏បានអង្គុយប្រជុំគ្នា ដើម្បីស្ដាប់ក្នុងទីនោះដែរ បានស្ដាប់នូវធម៌ដែលព្រះពុទ្ធមិនមានមន្ទិល ត្រាស់ដឹងហើយ ដូចជាពួកទេវតា (អង្គុយប្រជុំគ្នា ដើម្បីស្ដាប់)នូវសុភាសិតរបស់ព្រះឥន្ទ ។

(ព្រះមានព្រះភាគ ត្រាស់ថា) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរស្ដាប់ពាក្យតថាគតចុះ តថាគតនឹងញុំាងអ្នកទាំងឡាយ ឲ្យស្ដាប់ នូវធម៌ជាគ្រឿងកំចាត់បង់នូវកិលេស អ្នកទាំងអស់គ្នា ចូរប្រព្រឹត្តធម៌ជាគ្រឿងកំចាត់បង់នូវកិលេសនោះ បុគ្គលអ្នកមានប្រាជ្ញា ឃើញនូវប្រយោជន៍ គប្បីសេពគប់នូវឥរិយាបថ ដ៏សមគួរដល់ឋានៈបព្វជិតនោះ ។

នោ វេ វិកាលេ វិចរេយ្យ ភិក្ខុ
គាមេ ច បិណ្ឌាយ ចរេយ្យ កាលេ
អកាលចារឹ ហិ សជន្តិ សង្គា
តស្មា វិកាលេ ន ចរន្តិ ពុទ្ធា ។
រូបា ច សទ្ទា ច រសា ច គន្ធា
ផស្សា ច យេ សម្មទយន្តិ សត្តេ
ឯតេសុ ធម្មេសុ វិនេយ្យ ឆន្ទំ
កាលេន សោ បវិសេ បាតរាសំ
បិណ្ឌំ ច ភិក្ខុ សមយេន លទ្ធា
ឯកោ បដិក្កម្ម រហោ និសីទេ
អជ្ឈត្តចិន្តី ន មនោ ពហិទ្ធា
និច្ឆារយេ សង្គហិតត្តភាវោ ។
សចេបិ សោ សល្លបេ សាវកេន
អញ្ញេន វា កេនចិ ភិក្ខុនា វា
ធម្មំ បណីតំ តមុទាហរេយ្យ
ន បេសុណំ នោបិ បរូបវាទំ ។

ភិក្ខុមិនគប្បីត្រាច់ទៅ ក្នុងកាលខុស ត្រូវតែត្រាច់ទៅបិណ្ឌបាត ក្នុងស្រុក ក្នុងកាលគួរ គឺពេលព្រឹកទល់ថ្ងៃត្រង់ ព្រោះថា កិលេសជាគ្រឿងជាប់ជំពាក់ទាំងឡាយ រមែងជាប់នូវបុគ្គលអ្នកត្រាច់ទៅ ក្នុងកាលមិនគួរ ព្រោះហេតុនោះ ព្រះពុទ្ធទាំងឡាយ មិនទៅក្នុងកាលខុសឡើយ ។

ធម៌ទាំងឡាយណា គឺរូប សម្លេង ក្លិន រស ផ្សព្វ តែងញុំាងពួកសត្វ ឲ្យស្រវឹង ភិក្ខុនោះបន្ទោបង់នូវសេចក្តីពេញចិត្ត ក្នុងធម៌ទាំងឡាយនុ៎ះ ហើយគប្បីចូលទៅបិណ្ឌបាតក្នុងកាលគួរ លុះបានបិណ្ឌបាតក្នុងកាលគួរហើយ ត្រូវបៀសចេញទៅតែម្នាក់ឯង អង្គុយសម្ងំក្នុងទីស្ងាត់ គិតនូវខ្លួនសន្តានខាងក្នុង គ្រប់គ្រងចិត្តបានល្អហើយ មិនគប្បីនាំចិត្តចេញទៅខាងក្រៅឡើយ ។ បើភិក្ខុនោះ បរោ ជាមួយនឹងសាវកក្តី អន្យតិរ្ថិយណាមួយក្តី ភិក្ខុក្តី គួរពោលឡើងនូវធម៌ដ៏ឧត្តមនោះ មិនគួរពោលពាក្យញុះញង់ ផង មិនគួរពោលពាក្យតិះដៀលអ្នកដទៃ ផង ។

វាទញ្ហិ ឯកេ បដិសេនិយន្តិ
ន តេ បសំសាម បរិត្តបញ្ញេ
តតោ តតោ នេ បសជន្តិ សង្គា
ចិត្តញ្ហិ តេ តត្ថ គមេន្តិ ទូរេ ។
បិណ្ឌំ វិហារំ សយនាសនញ្ច
អាបញ្ច សង្ឃាដិរជូបវាហនំ
សុត្វាន ធម្មំ សុគតេន ទេសិតំ
សង្ខាយ សេវេ វរបញ្ញសាវកោ ។
តស្មា ហិ បិណ្ឌេ សយនាសនេ ច
អាបេ ច សង្ឃាដិរជូបវាហនេ
ឯតេសុ ធម្មេសុ អនូបលិត្តោ
ភិក្ខុ យថា បោក្ខរេ វារិពិន្ទុ ។
គហដ្ឋវត្តំ បន វោ វទាមិ
យថាការោ សាវកោ សាធុ ហោតិ
ន ហេស លព្ភា សបរិគ្គហេន
ផស្សេតុំ យោ កេវលោ ភិក្ខុធម្មោ ។

ព្រោះមោឃបុរសពួកមួយ តែងពោលក្លាត់នូវការនិយាយ (ប្រណាំងប្រជែង) តថាគត មិនសរសើរនូវពួកជនដែលមានប្រាជ្ញាតិចទាំងនោះឡើយ ការជាប់ចំពាក់ (ដោយវិវាទតាំងឡើង) អំពីគន្លងនៃពាក្យនោះ ៗ តែងជាប់ចំពាក់នឹងជនទាំងនោះ ព្រោះជនទាំងនោះ រមែងញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងការនិយាយនោះ ដ៏ឆ្ងាយ (អំពីសមថៈនិងវិបស្សនា) ។ សាវ័កអ្នកមានប្រាជ្ញាដ៏ប្រសើរ ស្តាប់ធម៌ ដែលព្រះសុគតទ្រង់សំដែងហើយ គប្បីពិចារណា ហើយសឹមសេព នូវបិណ្ឌបាតផង វិហារផង ទីដេក ទីអង្គុយផង ទឹកសម្រាប់លាងធូលីជាប់នឹងសង្ឃាដិផង ។ ព្រោះហេតុនោះ ភិក្ខុមិនជាប់ចិត្តក្នុងធម៌ទាំងនុ៎ះ គឺបិណ្ឌបាត សេនាសនៈ និងទឹកសម្រាប់លាងធូលីជាប់នឹងសង្ឃាដិ ដូចដំណក់ទឹក មិនជាប់លើស្លឹកឈូក ។ ម្យ៉ាងទៀត តថាគត សំដែងនូវវត្តរបស់គ្រហស្ថ ដល់អ្នកទាំងឡាយ សាវ័កអ្នកធ្វើយ៉ាងណា ទើបឈ្មោះថាជាអ្នកល្អ ព្រោះថា ធម៌របស់ភិក្ខុទាំងអស់ណា (ដែលតថាគតពោលក្នុងកាលមុន) ធម៌នុ៎ះ គឺបុគ្គលប្រកបដោយសេចក្តីហួងហែង មិនបានសម្រេចឡើយ ។

សុត្តនិបាតេ ទុតិយស្ស ចូឡវគ្គស្ស ចុទ្ទសមំ ធម្មិកសុត្តំ

បាណំ ន ហានេ ន ច ឃាតយេយ្យ
ន ចានុជញ្ញា ហនតំ បរេសំ
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
យេ ថាវរា យេ ច តសា សន្តិ លោកេ ។
តតោ អទិន្នំ បរិវជ្ជយេយ្យ
កិញ្ចិ ក្វចិ សាវកោ ពុជ្ឈមានោ
ន ហារយេ ហរតំ នានុជញ្ញា
សព្វំ អទិន្នំ បរិវជ្ជយេយ្យ ។
អព្រហ្មចរិយំ បរិវជ្ជយេយ្យ
អង្គារកាសុំ ជលិតំវ វិញ្ញូ
អសម្ភុណន្តោ បន ព្រហ្មចរិយំ
បរស្ស ទារំ នាតិក្កមេយ្យ ។
សភគ្គតោ វា បរិសគ្គតោ វា
ឯកស្ស វេកោ ន មុសា ភណេយ្យ
ន ភាណយេ ភណតំ នានុជញ្ញា
សព្វំ អភូតំ បរិវជ្ជយេយ្យ ។

បុគ្គលមិនគប្បីសម្លាប់សត្វ ដោយខ្លួនឯង មិនគប្បីប្រើអ្នកដទៃឲ្យសម្លាប់ មិនគប្បីពេញចិត្តនឹងពួកជនដទៃ ដែលសម្លាប់ ពួកសត្វណាមានសន្តានចិត្តខ្ជាប់ខ្ជួនក្តី ពួកសត្វណាមានចិត្តតក់ស្លុតក្តី តែងមាននៅក្នុងលោក បុគ្គលគប្បីដាក់ចុះនូវអាជ្ញាក្នុងសត្វទាំងអស់នោះ ៗ លំដាប់ពីនោះ សាវ័កកាលដឹង គប្បីវៀរបង់នូវទ្រព្យ ដែលគេមិនបានឲ្យ មិនគប្បីលួចយកទ្រព្យតិចតួច ក្នុងទីណាមួយឡើយ មិនគប្បីពេញចិត្តនឹងពួកជន ដែលលួចទ្រព្យគេឡើយ គប្បីវៀរបង់នូវទ្រព្យទាំងពួងដែលគេមិនបានឲ្យ ៗ វិញ្ញូជន គួរវៀរបង់នូវអព្រហ្មចរិយៈ ដូចជាបុគ្គលវៀររណ្តៅរងើកភ្លើង កំពុងឆេះរន្ទាល កាលបើមិនអាចប្រព្រឹត្តព្រហ្មចរិយៈទេ ក៏កុំគប្បីប្រព្រឹត្តកន្លងនូវប្រពន្ធរបស់ជនដទៃ ៗ បុគ្គលណាមួយ ចូលទៅក្នុងរោងប្រជុំក្តី ចូលទៅក្នុងកណ្តាលបរិសទ្យក្តី មិនគប្បីពោលពាក្យកុហក ចំពោះជនណាមួយ មិនគប្បីឲ្យអ្នកដទៃនិយាយកុហក មិនគប្បីពេញចិត្តនឹងពួកជន ដែលនិយាយកុហកឡើយ គប្បីវៀរនូវពាក្យមិនពិតទាំងពួង ៗ

មជ្ជញ្ច បានំ ន សមាចរេយ្យ
ធម្មំ ឥមំ រោចយេ យោ គហដ្ឋោ
ន បាយយេ បិវតំ នានុជញ្ញា
ឧម្មាទនន្តំ ឥតិ នំ វិទិត្វា ។

មទា ហិ បាបានិ ករោន្តិ ពាលា
ការេន្តិ ចញ្ញេបិ ជនេ បមត្តេ
ឯតំ អបុញ្ញាយតនំ វិវជ្ជយេ
ឧម្មាទនំ មោហនំ ពាលកន្តំ ។

បាណំ ន ហនេ ន ចាទិន្នមាទិយេ
មុសា ន ភាសេ ន ច មជ្ជបោ សិយា
អព្រហ្មចរិយា វិរមេយ្យ មេថុនា
រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ

មាលំ ន ធារេ ន ច គន្ធមាចរេ
មញ្ចេ ឆមាយំ វ សយេថ សន្ថតេ

បុគ្គលមិនគប្បីប្រព្រឹត្តផឹកនូវទឹកស្រវឹង គប្បីពេញចិត្តនឹងធម៌គឺកិរិយាវៀរចាកការផឹកនោះ គ្រហស្ថណា បានដឹងនូវកិរិយាផឹកនោះ ថា មានការឆ្កួតជាបំផុត គ្រហស្ថនោះមិនគប្បីផឹក មិនគប្បីពេញចិត្តនឹងបុគ្គល ដែលផឹកឡើយ ។ បុគ្គលពាលទាំងឡាយ ធ្វើនូវអំពើបាប ដោយខ្លួនឯងក្តី ឲ្យជនដែលមានសេចក្តីប្រមាទឯទៀតធ្វើក្តី ក៏ព្រោះតែសេចក្តីស្រវឹង (ហេតុនោះ) បុគ្គលគួរលះនូវការផឹកនូវទឹកស្រវឹងជាគ្រឿងបណ្តាល ឲ្យកើតបាប នាំឲ្យឆ្កួត នាំឲ្យវង្វេងទាំងនាំឲ្យល្ងង់ទុះចេញ ។ បុគ្គលមិនគប្បីសម្លាប់សត្វផងមិនគប្បីកាន់យកទ្រព្យ ដែលគេមិនបានឲ្យផង មិនគប្បីនិយាយពាក្យកុហកផង មិនគប្បីផឹកនូវទឹកស្រវឹងផង គប្បីវៀរចាកការប្រព្រឹត្ត មិនប្រសើរ គឺមេថុនធម្ម ផងមិនគប្បីបរិភោគភោជន ក្នុងវេលាយប់ មិនគប្បីបរិភោគភោជន ក្នុងកាលខុស គឺថ្ងៃរសៀលផង មិនគប្បីទ្រទ្រង់នូវកម្រងផ្កាផង មិនគប្បីលាបនូវគ្រឿងក្រអូបផងគប្បីដេកលើគ្រែដ៏គួរ ឬកម្រាលដែលក្រាលលើផែនដីផង

សុត្តនិបាតេ ទុតិយស្ស ចូឡវគ្គស្ស ចុទ្ទសមំ ធម្មិកសុត្តំ

ឯតំ ហិ អដ្ឋង្គិកមាហុបោសថំ
ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ ។
តតោ ច បក្ខស្សុបវស្សុបោសថំ
ចាតុទ្ទសី បញ្ចទសី អដ្ឋមី
បាដិហារិកបក្ខញ្ច បសន្នមានសោ
អដ្ឋង្គុបេតំ សុសមត្តរូបំ ។
តតោ ច បាតោ ឧបវុដ្ឋុបោសថោ
អន្នេន បានេន ច ភិក្ខុសង្ឃំ
បសន្នចិត្តោ អនុមោទមានោ
យថារហំ សំវិភជេថ វិញ្ញូ ។
ធម្មេន មាតាបិតរោ ភរេយ្យ
បយោជយេ ធម្មិកំ សោ វណិជ្ជំ
ឯតំ គិហី វត្តយមប្បមត្តោ
សយម្បភេ នាម ឧបេតិ ទេវេតិ ។

ធម្មិកសុត្តំ ចុទ្ទសមំ ។

ចូឡវគ្គោ ទុតិយោ ។

ព្រោះអ្នកប្រាជ្ញ បានពោល នូវឧបោសថប្រកបដោយអង្គប្រាំបីនុ៎ះ ថាជាឧបោសថ ដែលព្រះពុទ្ធ ព្រះអង្គទ្រង់ដល់នូវទីបំផុតនៃទុក្ខ ប្រកាសហើយ ។

ព្រោះហេតុនោះ អ្នកគួរមានចិត្តជ្រះថ្លា រក្សាឧបោសថ ដែលប្រកបដោយអង្គប្រាំបី ឲ្យមានសភាពពេញលេញល្អ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃ ទី ៨ នៃបក្ខផង អស់បាដិហារិកបក្ខផង (១) ។

ន័យមួយទៀត វិញ្ញូជនដែលបានរក្សាឧបោសថ អំពីព្រឹកហើយ គួរមានចិត្តជ្រះថ្លា រីករាយ អង្គាសភិក្ខុសង្ឃ ដោយបាយនឹងទឹកតាមសមគួរ ។

វិញ្ញូជននោះ គួរចិញ្ចឹមមាតាបិតាដោយធម៌ គួរប្រកបជំនួញ ដែលប្រកបដោយធម៌ គ្រហស្ថអ្នកមិនប្រមាទ ប្រព្រឹត្តវត្តបែបនេះ រមែងទៅកើត ក្នុងពួកទេវតាឈ្មោះថា សយម្បភា ( ទេវតាមានពន្លឺផ្សាយចេញអំពីខ្លួន ) ។

ចប់ ធម្មិកសូត្រ ទី ១៤ ។

ចប់ ចូឡវគ្គ ទី ២ ។

---

១ រវាង៥ខែគឺតាំងពីខែអាសាឍ ដល់ខែកត្តិក ហៅថា បាដិហារិកបក្ខ ។ អដ្ឋកថា ។

## តស្សុទ្ទានំ[១]

រតនាមគន្ធោ ហិរិ ច មង្គលំ សូចិលោមេន
កបិលោ ព្រាហ្មណាបិ ច នាវា កិំសីលឧដ្ឋានោ
រាហុលោ បុន វង្គីសោ បរិព្វាជនិយោ តថា
ធម្មិកញ្ច វិទុនោ អហុ ចូឡវគ្គន្តិ ចុទ្ទសាតិ ។

---

១ ឱ. តស្ស វគ្គស្ស ឧទ្ទានំ

រតនំ អាមគន្ធញ្ច ហិរិញ្ច មង្គលុត្តមំ
សូចិលោមោ ធម្មចរិយា បុន ព្រាហ្មណធម្មិកំ
នាវា ច សុត្តំ កិំសីលំ ឧដ្ឋានំ អថ រាហុលោ
កប្បោ ច បរិព្វាជោ ធម្មិកោ ច បុនាបរំ
ចុទ្ទសេតានិ សុត្តានិ ចូឡវគ្គោតិ វុច្ចតិ ។

## ឧទ្ទាននៃចូឡវគ្គនោះគឺ

រតនសូត្រ ១ អាមគន្ធសូត្រ ១ ហិរិសូត្រ ១ មង្គលសូត្រ ១ សូចិលោមសូត្រ ១ កបិលសូត្រ ឬ ធម្មចរិយសូត្រ ១ ព្រាហ្មណធម្មិកសូត្រ ១ នាវាសូត្រ ១ កឹសីលសូត្រ ១ ឧដ្ឋានសូត្រ ១ រាហុលសូត្រ ១ វង្គីសសូត្រ ១ សម្មាបរិព្វាជនិយសូត្រ ១ ធម្មិកសូត្រ ១ អ្នកប្រាជ្ញទាំងឡាយ បាន ពោលនូវចូឡវគ្គថា មានសូត្រ ១៤ ដូច្នេះឯង ។

# សុត្តនិបាតេ តតិយោ មហាវគ្គោ

## បឋមំ បព្វជ្ជាសុត្តំ

(៤១) បព្វជ្ជំ កិត្តយិស្សាមិ យថា បព្វជិ ចក្ខុមា

យថា វីមំសមានោ សោ បព្វជ្ជំ សមរោចយិ ។

សម្ពាធោយំ ឃរាវាសោ រជស្សាយតនំ ឥតិ

អព្ភោកាសោ ច បព្វជ្ជា ឥតិ ទិស្វាន បព្វជិ ។

បព្វជិត្វាន កាយេន បាបកម្មំ វិវជ្ជយិ

វចីទុច្ចរិតំ ហិត្វា អាជីវំ បរិសោធយិ ។

អគមា រាជគហំ ពុទ្ធោ មគធានំ គិរិព្វជំ

បិណ្ឌាយ អភិហារេសិ អាកិណ្ណវរលក្ខណោ ។

តមទ្ទសា ពិម្ពិសារោ បាសាទស្មិំ បតិដ្ឋិតោ

ទិស្វា លក្ខណសម្បន្នំ ឥមមត្ថំ អភាសថ

# សុត្តនិបាត មហាវគ្គ ទី ៣

## បព្វជ្ជាសូត្រ ទី ១

(៤១) (ព្រះអានន្ទដ៏មានអាយុ ពោលថា) ខ្ញុំនឹងសំដែងនូវបព្វជ្ជា ដែលព្រះពុទ្ធមានចក្ខុនោះ បានទ្រង់ព្រះផ្នួសហើយ ដោយប្រការយ៉ាងណា ទ្រង់ពិចារណាឃើញយ៉ាងណា ទើបទ្រង់ពេញព្រះហឫទ័យនឹងបព្វជ្ជា ។ ព្រះអង្គទ្រង់ឃើញថា ឃរាវាសនេះ ចង្អៀតចង្អល់ ជាទីកើតនៃធូលីគឺកិលេស មួយទៀត ទ្រង់ឃើញថា បព្វជ្ជាមានឱកាសទូលាយ ទើបទ្រង់ព្រះផ្នួស ។ លុះព្រះអង្គទ្រង់ព្រះផ្នួសហើយ វៀរចាកបាបកម្ម ដោយកាយ លះបង់ការប្រព្រឹត្តអាក្រក់ ដោយវាចា ជំរះអាជីវៈឲ្យបរិសុទ្ធ ។ ព្រះពុទ្ធមានព្រះលក្ខណៈដ៏ប្រសើរបរិបូណ៌ ទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះ មានភ្នំព័ទ្ធជុំវិញ ដូចជាក្រោល របស់ពួកអ្នកមគធៈទ្រង់យាងបិណ្ឌបាត ។ ព្រះរាជាពិម្ពិសារទ្រង់ឋិតលើប្រាសាទ បានទតឃើញនូវព្រះពុទ្ធនោះ លុះទ្រង់ឃើញព្រះពុទ្ធបរិបូណ៌ ដោយលក្ខណៈហើយ ទើបត្រាស់សេចក្ដីនេះ ( ចំពោះអមាត្យទាំងឡាយ ) ថា

ឥមំ ភោន្តោ និសាមេថ អភិរូបោ ព្រហ្មា(១)សុចិ

ចរណេន ចេវ សម្បន្នោ យុគមត្តញ្ច បេក្ខតិ

ឱក្ខិត្តចក្ខុ សតិមា នាយំ នីចកុលាមិវ

រាជទូតាភិធាវន្តុ កុហឹ ភិក្ខុ គមិស្សតិ ។

តេ បេសិតា រាជទូតា បិដ្ឋិតោ អនុពន្ធិសុំ(២)

កុហឹ គមិស្សតិ ភិក្ខុ កត្ថ វាសោ ភវិស្សតិ ។

សបទានំ ចរមានោ គុត្តទ្វារោ សុសំវុតោ

ខិប្បំ(៣) បត្តំ អបូរេសិ សម្បជានោ បតិស្សតោ ។

ស បិណ្ឌចារំ ចរិត្វា និក្ខម្ម នគរា មុនិ

បណ្ឌវំ អភិហារេសិ ឯត្ថ វាសោ ភវិស្សតិ ។

---

១ ខ. ព្រហា ។ ២ ម. អនុពន្ធិសុ ។ ៣ ខិត្តំ ។

នែអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយ ចូរមើលសមណៈនេះ (សមណៈនេះ) មានរូបល្អ បរិបូណ៌ ដោយកំពស់នឹងទំហំ មានសម្បុរស្អាត ទាំងបរិបូណ៌ ដោយដំណើរដ៏សមរម្យ ក្រឡេកមើលត្រឹមមួយជួរទឹម មានចក្ខុក្រឡេកចុះក្រោម មានស្មារតី សមណៈនេះ ដូចជាមិនមែនចេញចាកត្រកូលថោកទាបមក (បួស) ទេ ពួករាជទូតចូរប្រុះតាមទៅ (ឲ្យដឹងថា) ភិក្ខុ (នេះ) នឹងទៅកន្លែងណា ៗ រាជទូតទាំងនោះ ដែលព្រះរាជាទ្រង់បញ្ជូនទៅហើយ ក៏ដើរប្រកិតទៅតាមក្រោយ (ដើម្បីឲ្យដឹងថា) ភិក្ខុ (នេះ) នឹងទៅកន្លែងណា ការនៅនឹងមានកន្លែងណា ៗ (ព្រះពោធិសត្វ) ទ្រង់ត្រាច់ទៅកាន់ទីសព្វប្រក ទ្រង់គ្រប់គ្រងទ្វារ សង្រួមល្អ ព្រះអង្គមានសម្បជញ្ញៈ មានស្មារតី បានញុំាងបាត្រឲ្យពេញជាឆាប់ គឺទ្រង់ទទួលតែល្មម ៗ ព្រះពោធិសត្វ ជាអ្នកប្រាជ្ញនោះ លុះទ្រង់ត្រាច់បិណ្ឌបាតហើយ ក៏ស្តេចចេញអំពីនគរ យាងឡើងកាន់ភ្នំបណ្ឌវៈ ដោយគិតថា ការនៅនឹងមានកន្លែងទីនុះ + ៗ

ទិស្វាន វាសូបគតំ តយោ(១) ទូតា ឧបាវិសុំ
ឯកោ ច ទូតោ អាគន្ត្វា(២) រាជិនោ បដិវេទយិ
ឯស ភិក្ខុ មហារាជ បណ្ឌវស្ស បុរត្ថតោ
និសិន្នោ ព្យគ្ឃុសភោវ សីហោវ គិរិគព្ភរេ ។
សុត្វាន ទូតវចនំ ភទ្ទយានេន ខត្តិយោ
តរមានរូបោ និយ្យាសិ យេន បណ្ឌវបព្វតោ ។
ស យានភូមិំ យាយិត្វា យានា ឱរុយ្ហ ខត្តិយោ
បត្តិកោ ឧបសង្កម្ម អាសជ្ជ នំ ឧបាវិសិ ។
និសជ្ជ រាជា សម្មោទិ កថំ សារណីយំ តតោ
កថំ សោ វីតិសារេត្វា ឥមមត្ថំ អភាសថ
យុវា ច ទហរោ ចាសិ បឋមុប្បត្តិកោ សុសូ(៣)
វណ្ណារោហេន សម្បន្នោ ជាតិមា វិយ ខត្តិយោ

---

១ ឱ. តតោ ។ ២ ម. តេសុ ឯកោវ អាគន្ត្វា ។ ៣ ឱ. ចាសិ បឋមុប្បត្តិកោ សុសុ ។

ពួកទូត ៣ នាក់ លុះបានឃើញហើយ ក៏ចូលទៅរកព្រះអង្គដែលទៅគង់ក្នុងទីនោះ ចំណែកទូតម្នាក់បានមកក្រាបទូលស្តេចថា បពិត្រមហារាជ ភិក្ខុនោះ អង្គុយក្នុងញកភ្នំបណ្ឌវៈ បែរមុខទៅខាងកើត (ឥតរន្ធត់) ដូចខ្លាធំ គោឧសភ និងសីហៈ ៗ លុះព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្តាប់ពាក្យរាជទូតហើយ ទ្រង់ប្រញាប់រួសរាន់យាងចេញទៅកាន់ភ្នំបណ្ឌវៈ ដោយព្រះរាជយានដ៏ប្រសើរ ៗ ព្រះមហាក្សត្រិយ៍នោះ លុះទ្រង់យាងផុតទី ដែលទៅដោយយានហើយ ក៏ចុះចាកយាន ស្តេចចូលទៅដោយព្រះបាទ បានដល់ហើយក៏ចូលទៅរកព្រះពោធិសត្វ ៗ ព្រះរាជាទ្រង់គង់ហើយ ទ្រង់ថ្លែងសំណេះសំណាល ដោយព្រះបន្ទូលគួររឭក លុះទ្រង់បញ្ចប់ព្រះបន្ទូលនោះហើយត្រាស់សេចក្តីនេះថា ខ្លួនលោក នៅកំពុងពេញវ័យ នៅក្មេងកំឡោះ ជំទង់ ទើបកើតឡើងបានត្រឹមតែបឋមវ័យ នៅជំទង់បរិបូណ៌ដោយសម្បុរទឹងកំពស់ ដូចជាមានជាតិជាក្សត្រិយ៍

សោភយន្តោ អនីកគ្គំ នាគសង្ឃបុរក្ខតោ

ទទាមិ ភោគេ ភុញ្ជស្សុ ជាតឹ(1) អក្ខាហិ បុច្ឆិតោ ។

ឧជុំ ជនបទោ រាជ ហិមវន្តស្ស បស្សតោ

ធនវីរិយេន សម្បន្នោ កោសលស្ស(2) និកេតិនោ

អាទិច្ចា(3) នាម គោត្តេន សាកិយា នាម ជាតិយា

តម្ហា កុលា បព្វជិតោ (ម្ហិ)(4) ន កាមេ អភិបត្ថយំ

កាមេស្វាទីនវំ ទិស្វា នេក្ខម្មំ ទដ្ឋុ ខេមតោ

បធានាយ គមិស្សាមិ ឯត្ថ មេ រញ្ជតី មនោ ។

បព្វជ្ជាសុត្តំ បឋមំ ។

---

១ ឱ. ជាតឹ ប ។ ២ ឱ. កោសលេសុ ។ ៣ ម. អាទិច្ចោ ។ ៤ ឱ. កុលា បព្វជិតោម្ហិ រាជ ។

លោកចូរញ៉ាំងជន ជាប្រធាននៃសេនា (មេទាហាន) ឲ្យរុងរឿង ហើយចូរជាបុគ្គលមានពួកជន អ្នកមិនធ្វើអំពើអាក្រក់ជាបរិវារ ចូរបរិភោគនូវភោគៈទាំងឡាយចុះ ខ្ញុំឲ្យដល់លោក កាលបើខ្ញុំសួរហើយ លោកចូរប្រាប់ជាតិដល់ខ្ញុំ ។

(ព្រះពោធិសត្វត្រាស់ថា) បពិត្រមហារាជ ត្រង់ទៅ មានជនបទមួយ នៅប្របភ្នំហិមវន្ត ជាជនបទ បរិបូណ៌ដោយទ្រព្យ និងជនអ្នកមានព្យាយាម អាស្រ័យនៅនឹងដែនកោសល (មានជនមួយពួក) មានគោត្រជាអាទិច្ចគោត្រ មានជាតិជាសាកិយៈ អាត្មាភាពបានចេញចាកត្រកូលនោះមកបួស អាត្មាភាពមិនត្រូវការដោយកាមទាំងឡាយឡើយ អាត្មាភាពបានឃើញទោសក្នុងកាមទាំងឡាយ បានឃើញនូវការចេញចាកកាមថាជាគ្រឿងក្សេម នឹងទៅ ប្រឹងប្រែកបព្យាយាម ចិត្តរបស់អាត្មាភាព ត្រេកអរក្នុងព្យាយាមនុ៎ះ ។

ចប់ បព្វជ្ជាសូត្រ ទី ១ ។

# ទុតិយំ បធានសុត្តំ

(៦២)តំ មំ បធានបហិតត្តំ នទឹ នេរញ្ជរម្បតិ

វិបរក្កម្ម ឈាយន្តំ យោគក្ខេមស្ស បត្តិយា

នមុចី ករុណំ វាចំ ភាសមានោ ឧបាគមិ

កិសោ ត្វមសិ ទុព្វណ្ណោ សន្តិកេ មរណំ តវ ។

សហស្សភាគោ មរណស្ស ឯកំសោ តវ ជីវិតំ

ជីវ ភោ ជីវិតំ សេយ្យោ ជីវំ បុញ្ញានិ កាហសិ ។

ចរតោ ច តេ ព្រហ្មចរិយំ អគ្គិហុតញ្ច ជូហតោ

បហូតំ ចីយតេ បុញ្ញំ កឹ បធានេន កាហសិ ។

ទុគ្គោ មគ្គោ បធានាយ ទុក្ករោ ទុរភិសម្ភវោ

ឥមា គាថា ភណំ មារោ អដ្ឋា ពុទ្ធស្ស សន្តិកេ ។

# បធានសូត្រទី ២

(៤២) (ព្រះមានព្រះភាគទ្រង់ត្រាស់ថា) មារ កាលពោលនូវពាក្យប្រកបដោយសេចក្តីអាណិត ចូលទៅជិតតថាគតនោះ ដែលមានចិត្តស្ទុងទៅរកព្យាយាម បានទៅដល់ស្ទឹងនេរញ្ជរា កំពុងតែសង្កាត់ដុតបំផ្លាញកិលេស ដើម្បីសម្រេចនូវធម៌ជាទីក្សេមចាកយោគៈថា អ្នកស្គាំងស្គមហើយ មានសម្បុរអាក្រក់ សេចក្តីស្លាប់កាន់តែជិតអ្នកហើយ ។

អ្នកមានសេចក្តីស្លាប់មួយពាន់ភាគហើយ នៅរស់តែមួយភាគទេ បើអ្នកមានជីវិតរស់នៅ ប្រសើរជាង ព្រោះកាលអ្នករស់នៅ គង់នឹងបានធ្វើបុណ្យទាំងឡាយ ។

កាលអ្នកប្រព្រឹត្តព្រហ្មចារ្យ នឹងបូជាភ្លើង គង់សន្សំបុណ្យបានច្រើន អ្នកនឹងធ្វើអ្វីកើត ដោយការព្យាយាម ។

ផ្លូវទៅរកព្យាយាម ជាផ្លូវទៅបានដោយក្រ ធ្វើបានក៏ដោយក្រ ឲ្យសម្រេចបានដោយក្រ មារបានឈរពោលគាថាទាំងឡាយនេះ ក្នុងសំណាក់នៃព្រះពុទ្ធ ។

តំ តថាវាទិនំ មារំ   ភគវា ឯតទព្រវិ

បមត្តពន្ធុ បាបិម(១)   យេនត្ថេន ឥធាគតោ

អណុមត្តោបិ(២) បុញ្ញេន   អត្ថោ មយ្ហំ ន វិជ្ជតិ

យេសញ្ច អត្ថោ បុញ្ញេន   តេ មារោ វត្តុមរហតិ ។

អត្ថិ សទ្ធា តតោ វិរិយំ   បញ្ញា ច មម វិជ្ជតិ

ឯវំ មំ បហិតត្តម្បិ   កឹ ជីវមនុបុច្ឆសិ ។

នទីនម្បិ សោតានិ   អយំ វាតោ វិសោសយេ

កិញ្ច មេ បហិតត្តស្ស   លោហិតំ នូបសុស្សយេ ។

លោហិតេ សុស្សមានម្ហិ   បិត្តំ សេម្ហញ្ច សុស្សតិ

មំសេសុ ខីយមានេសុ   ភិយ្យោ ចិត្តំ បសីទតិ

ភិយ្យោ សតិ ច បញ្ញា ច   សមាធិ មម តិដ្ឋតិ ។

---

១ ឱ. បាបិមា ។ ២ ឱ. អណុមត្តេនបិ ។

ព្រះមានព្រះភាគ បានត្រាស់នឹងមារនោះ ដែលមកនិយាយដូច្នោះយ៉ាងនេះថា ម្នាលមារមានចិត្តបាប អ្នកមានសេចក្ដីប្រមាទជាផៅពង្ស តថាគតមកក្នុងទីនេះ ព្រោះសេចក្ដីត្រូវការ(ដោយបុណ្យ)ណា សេចក្ដីត្រូវការដោយបុណ្យនោះ សូម្បីបន្តិចបន្តួច មិនមានដល់តថាគតឡើយ ពួកជនណាត្រូវការដោយបុណ្យ ទើបមារគួរនិយាយ (យ៉ាងនេះ) នឹងពួកជននោះចុះ ។

សទ្ធាផង តបៈផង វីរិយៈផង បញ្ញាផង រមែងមានដល់តថាគត កាលបើយ៉ាងនេះ ហេតុអ្វី ក៏អ្នកមកសួរនូវការរស់នៅនឹងតថាគត ដែលមានចិត្តសូន្យទៅកាន់ព្រះនិព្វាន ។

សូម្បីខ្យល់នេះ ដែលអាចញុំាងខ្សែទឹកស្ទឹងទាំងឡាយឲ្យរីងស្ងួតបាន ក៏មិនអាចញុំាងឈាម របស់តថាគត ដែលមានចិត្តសូន្យទៅកាន់ព្រនិព្វាន ឲ្យរីងស្ងួតបានតិចតួចឡើយ ។

កាលបើឈាមរីងស្ងួតហើយ ប្រមាត់នឹងស្លេស្មក៏រីងស្ងួត កាលបើសាច់អស់ហើយ ចិត្តតថាគតរឹងរឹតតែជ្រះថ្លា សតិផង បញ្ញាផង សមាធិផង របស់តថាគត រឹងរឹតតែតាំងនៅមាំ ។

តស្ស មេវំ វិហរតោ បត្តស្សុត្តមវេទនំ

កាមេ(១) នាបេក្ខតេ ចិត្តំ បស្ស សត្តស្ស សុទ្ធតំ ។

កាមា តេ បឋមា សេនា ទុតិយា រតិ វុច្ចតិ

តតិយា ខុប្បិបាសា តេ ចតុត្ថី តណ្ហា បវុច្ចតិ(២)

បញ្ចមំ(៣) ថីនមិទ្ធំ តេ ឆដ្ឋា ភីរូ បវុច្ចតិ

សត្តមី វិចិកិច្ឆា តេ មក្ខោ ថម្ភោ តេ អដ្ឋមោ

លាភោ សិលោកោ សក្ការោ មិច្ឆាលទ្ធោ ច យោ យសោ

យោ ចត្តានំ សមុក្កំសេ បរេ ច អវជានតិ

ឯសា នមុចិ តេ សេនា កណ្ហស្សាភិប្បហារិណី(៤)

ន នំ អសូរោ ជិនាតិ ជេត្វា ច លភតេ សុខំ ។

---

១ ឱ. ម. កាមេសុ ។ ២ ម. ចតុត្ថី និកន្តិ វុច្ចតិ ។ ៣ ឱ. បញ្ចមី ។ ៤ ឱ. កណ្ហស្សា-ភិប្បហារិនី ។

ចិត្តរបស់តថាគតនោះ កាលសម្រាកសម្រាន្តនៅយ៉ាងនេះ ដល់នូវទុក្ខវេទនាដ៏ក្លៀវក្លា ក៏មិនទឹកនានូវកាមទាំងឡាយឡើយ អ្នកចូរមើលសេចក្តីបរិសុទ្ធិរបស់សត្វចុះ ។

កាមទាំងឡាយ ជាសេនាទី ១ របស់អ្នក សេចក្តីអផ្សុក ជាសេនាទី ២ សេចក្តីឃ្លាននឹងស្រេក ជាសេនាទី ៣ របស់អ្នក តណ្ហា ជាសេនាទី ៤ ថីនមិទ្ធៈ ជាសេនាទី ៥ សេចក្តីតក់ស្លុត ជាសេនាទី ៦ សេចក្តីសង្ស័យ ជាសេនាទី ៧ របស់អ្នក ការមើលគុណនឹងសេចក្តីរឹងត្អឹងជាសេនាទី ៨ របស់អ្នក លាភ សេចក្តីសរសើរ សក្ការៈនឹងយស ដែលបានដោយពាំអើខុស បុគ្គលណា លើកដំកើងខ្លួនឯងផង បង្អាប់បង្អោនពួកជនដទៃផង ម្នាលមារ នេះជាសេនារបស់អ្នក ជាសេនាសម្រាប់ប្រហាររបស់មារ បុគ្គលមិនក្លៀវក្លា មិនឈ្នះនូវសេនានោះទេ លុះតែឈ្នះសេនានោះទើបបាននូវសេចក្តីសុខ ។

ឯស មុញ្ជំ បរិហរេ ធិរត្ថុ(១) មម ជីវិតំ

សង្គាមេ មេ មតំ សេយ្យោ យញ្ចេ ជីវេ បរាជិតោ ។

បគាឡ្ហា ឯត្ថ ន ទិស្សន្តិ ឯកេ សមណព្រាហ្មណា

តញ្ច មគ្គំ ន ជានន្តិ យេន គច្ឆន្តិ សុព្វតា ។

សមន្តា ធជិនឹ ទិស្វា យុត្តំ មារំ សវាហនំ

យុទ្ធាយ បច្ចុគ្គច្ឆាមិ មា មំ ឋានា អចាវយិ ។

យន្តេ តំ នប្បសហតិ សេនំ លោកោ សទេវកោ

តន្តេ បញ្ញាយ វេច្ឆាមិ អាមំ បត្តំវ អម្ហនា(២) ។

វសឹ ករិត្វា សង្កប្បំ សតិញ្ច សុបតិដ្ឋិតំ

រដ្ឋា រដ្ឋំ វិចរិស្សំ សាវកេ វិនយំ បុថុ ។

---

១ ឱ. ម. ធិរត្ថុ តិធ ។ ២ ឱ. គច្ឆាមិ អាមំ បត្តំវ អម្ហនា ។

តថាគតទុ៎ះគួររក្សាទុក នូវស្មៅយ៉ាប្លង (ដូចទង់ជ័យ) តថាគតខ្ពើមជីវិតរបស់តថាគត (ដែលចាញ់សេនាមារ) ការស្លាប់របស់តថាគត ក្នុងសង្គ្រាមប្រសើរជាង តថាគតចាញ់សេនាមារ ហើយរស់នៅមិនប្រសើរសោះឡើយ ។

សមណព្រាហ្មណ៍ពួកមួយ ដែលលិចលង់ក្នុងកាមទាំងនុ៎ះ រមែងមិនប្រាកដ ដោយ (សីលាទិគុណ) ឡើយ ពួកជនអ្នកមានវត្តល្អ រមែងទៅ (កាន់ព្រះនិព្វាន) តាមផ្លូវណា មារក៏មិនដឹងនូវផ្លូវនោះទេ ។

តថាគតបានឃើញនូវសេនាព័ទ្ធជុំវិញ ហើយក៏បែរមុខឆ្ពោះទៅដើម្បីតយុទ្ធនូវមារ ដែលលើកពួលមកព្រមទាំងពាហនៈ ដោយគិតថា អ្នកកុំញុំាងតថាគត ឲ្យឃ្លាតចាកទីឡើយ លោកព្រមទាំងទេវលោកមិនអាចគ្របសង្កត់នូវសេនារបស់អ្នកណា តថាគតអាចគ្របសង្កត់នូវសេនារបស់អ្នកនោះ ដោយប្រាជ្ញា ដូចជាយកថ្មមកសង្កត់នូវភាជន៍ដីឆ្អិនបាន ។

តថាគតនឹងធ្វើនូវសម្មាសង្កប្បៈ ឲ្យស្ងាត់ផង ធ្វើស្មារតីឲ្យតាំងនៅមាំផង នឹងទូន្មានពួកសាវ័កជាច្រើន ចេញអំពីដែនមួយ ទៅកាន់ដែនមួយ ។

តេ អប្បមត្តា បហិតត្តា  មម សាសនការកា

អកាមស្ស តេ គមិស្សន្តិ  យត្ថ គន្ត្វា ន សោចរេ ។

សត្ត វស្សានិ ភគវន្តំ  អនុពន្ធិំ បទាបទំ

ឱតារំ នាធិគច្ឆិស្សំ  សម្ពុទ្ធស្ស សតីមតោ

មេទវណ្ណំវ បាសាណំ  វាយសោ អនុបរិយគា

អបេត្ថ មុទុំ វិន្ទេម  អបិ អស្សាទនា សិយា ។

អលទ្ធា តត្ថ អស្សាទំ  វាយសេត្តោ អបក្កមិ

កាកោវ សេលមាសជ្ជ  និព្ពិជ្ជាបេម គោតមំ ។

តស្ស សោកបរេតស្ស  វីណា កច្ឆា អភស្សថ

តតោ សោ ទុម្មនោ យក្ខោ  តត្ថេវន្តរធាយថាតិ ។

បធានសុត្តំ ទុតិយំ ។

ពួកសាវ័កនោះ មិនប្រមាទ មានចិត្តសុងទៅកាន់ព្រះនិព្វាន ជាអ្នកធ្វើតាមពាក្យប្រដៅតថាគត អ្នកមិនប្រាថ្នា (នូវកាម) ពួកសាវ័កនោះ ទឹងទៅក្នុងទីណា ហើយ មិនសោក ក៏ទៅក្នុងទីនោះ ។

(មារបានបន្ថែមថា) អាត្មាអញ បានជាប់ប្រកិតតាមព្រះមានព្រះភាគ អស់ ៧ ឆ្នាំហើយ មិនបាននូវចន្លោះគឺទោស របស់ព្រះសម្ពុទ្ធអ្នកមានសិរីសោះ ។

ដូចសត្វក្អែក បានហើរចឹកដុំវិញថ្មដែលមានពណ៌ដូចខ្លាញ់ខាប់ ដោយគិតថា អាត្មាអញគង់បាន របស់ទន់ក្នុងកន្លែងនុះខ្លះ គ្រឿងឆ្ងាញ់ពិសា គង់មាន ក្នុងកន្លែងនុះខ្លះមិនលែង ។

អាត្មាអញ តាមយាយីព្រះសមណគោតម ដូចគ្នានឹងក្អែក (ដែលប្រឹងចឹក) ថ្មកំ ហើយមិនបានវត្ថុឆ្ងាញ់ពិសា ក៏ហើរចេញទៅ ។

កាលមារនោះ ត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ពិណក៏របូតចេញចាកក្លៀក តពីនោះមក មារនោះ មានចិត្តអាក់អន់ហើយក៏បាត់ទៅចាកទីនោះឯង ។

ចប់ បធានសូត្រទី ២ ។

# តតិយំ សុភាសិតសុត្តំ

[៤៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ចតូហិ ភិក្ខវេ អង្គេហិ សមន្នាគតា វាចា សុភាសិតា ហោតិ ន ទុព្ភាសិតា អនវជ្ជា ច អននុវជ្ជា ច វិញ្ញូនំ ។ កតមេហិ ចតូហិ ។ ឥធ(១) សុភាសិតញ្ញេវ ភាសតិ នោ ទុព្ភាសិតំ ធម្មញ្ញេវ ភាសតិ នោ អធម្មំ បិយញ្ញេវ ភាសតិ នោ អប្បិយំ សច្ចញ្ញេវ ភាសតិ នោ អលិកំ ។

---

១ ឱ. ម. ឥធ ភិក្ខវេ ភិក្ខុ ។

# សុភាសិតសូត្រ ទី ៣

(៤៣) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៤ ឈ្មោះថាជាសុភាសិត មិនមែនជាទុព្ភាសិតឡើយ ជាវាចាមិនមានទោសផង ដែលពួកវិញ្ញូជន មិនគប្បីតិះដៀលផង ។ ប្រកបដោយអង្គ ៤ តើដូចម្តេច ។ គឺបុគ្គលក្នុងលោកនេះ និយាយតែវាចាជាសុភាសិត មិននិយាយវាចា ជាទុព្ភាសិត ១ និយាយវាចាជាធម៌តែម្យ៉ាង មិននិយាយវាចា មិនមែនជាធម៌ ១ និយាយតែវាចាគួរស្រឡាញ់ មិននិយាយវាចា ដែលមិនគួរស្រឡាញ់ ១ និយាយតែវាចាពិត មិននិយាយវាចាលេះលោះ ១ ។

ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតា
វាចា សុភាសិតា ហោតិ ន ទុព្ភាសិតា អនវជ្ជា ច
អននុវជ្ជា ច វិញ្ញូនន្តិ ។

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ
អថាបរំ ឯតទវោច សត្ថា

សុភាសិតំ ឧត្តមមាហុ សន្តោ
ធម្មំ ភណេ ន អធម្មំ តំ ទុតិយំ
បិយំ ភណេ ន អប្បិយំ តំ តតិយំ
សច្ចំ ភណេ នាលិកន្តំ ចតុត្ថន្តិ ។

(៨៨) អថខោ អាយស្មា វង្គីសោ ឧដ្ឋាយាសនា
ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា

ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ នេះឯង ឈ្មោះថាជាសុភាសិត មិនមែនជាទុព្ភាសិតឡើយ ជាវាចាមិនមានទោសផង ដែលពួកវិញ្ញូជនមិនគប្បីតិះដៀលផង ។

ព្រះមានព្រះភាគ បានត្រាស់នូវសូត្រនេះ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់នូវសូត្រនេះហើយ ទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលំដាប់តទៅថា

ពួកសប្បុរសបានពោល នូវវាចាជាសុភាសិតដ៏ឧត្តម
(នោះជាទី ១) ពោលនូវវាចាជាធម៌ មិនពោលនូវវាចា
មិនមែនជាធម៌ នោះជាទី ២ ពោលវាចាគួរស្រឡាញ់
មិនពោលវាចាដែលមិនគួរស្រឡាញ់ នោះជាទី ៣
ពោលពាក្យពិត មិនពោលពាក្យលេះលោះ នោះ
ជាទី ៤ ។

(៤៤) លំដាប់នោះឯង ព្រះវង្គីសៈដ៏មានអាយុ ក្រោកចាកអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ហើយប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ រួចក្រាបបង្គំទូល

ភគវន្តំ ឯតទវោច បដិភាតិ មំ ភគវា បដិភាតិ មំ សុគតាតិ ។ បដិភាតុ តំ វង្គីសាតិ ភគវា អវោច ។ អថខោ អាយស្មា វង្គីសោ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវិ

តមេវ វាចំ ភាសេយ្យ យាយត្តានំ ន តាបយេ
បរេ ច ន វិហឹសេយ្យ សា វេ វាចា សុភាសិតា ។
បិយវាចមេវ ភាសេយ្យ យា វាចា បដិនន្ទិតា
យំ អនាទាយ បាបានិ បរេសំ ភាសតេ បិយំ ។
សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ
សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា ។

ព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសំដែងធម៌ បពិត្រព្រះសុគត ខ្ញុំព្រះអង្គសូមសំដែងធម៌ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវង្គីសៈ អ្នកចូរសំដែងធម៌ចុះ ។ លំដាប់នោះ ព្រះវង្គីសៈ ដ៏មានអាយុ បានសរសើរ ដោយគាថាទាំងឡាយ ដ៏សមគួរ ក្នុងទីចំពោះព្រះភក្ត្រថា

បុគ្គល មិនញុំាងខ្លួនឲ្យក្តៅក្រហាយ មិនបៀតបៀនពួកជនដទៃ ដោយវាចាណា បុគ្គលគួរពោលវាចានោះឯង វាចានោះ ឈ្មោះថាជាសុភាសិត ។ វាចាណា ដែលគួរត្រេកត្រអាល (ឬ) បុគ្គលមិនប្រកាន់ នូវពាក្យអាក្រក់ ហើយពោលវាចាណាជាទីស្រឡាញ់ នៃពួកជនដទៃ បុគ្គលគួរពោលវាចាជាទីស្រឡាញ់នោះឯង ។ វាចាពិត ជាវាចាមិនស្លាប់ នេះជាធម៌មានមកយូរហើយ ពួកសប្បុរសបានតាំងនៅក្នុងអត្ថផង ក្នុងធម៌ផង ព្រោះសច្ចៈ ។

យំ ពុទ្ធោ ភាសតិ វាចំ ខេមំ និព្វានបត្តិយា
ទុក្ខស្សន្តកិរិយាយ សា វេ វាចានមុត្តមាតិ ។

សុភាសិតសុត្តំ តតិយំ ។

# ចតុត្ថំ សុន្ទរិកសុត្តំ

(៤៨) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ វិហរតិ សុន្ទរិកាយ នទិយា តីរេ ។ តេន ខោ បន សមយេន សុន្ទរិកភារទ្វាជោ ព្រាហ្មណោ សុន្ទរិកាយ នទិយា តីរេ អគ្គឹ ជុហតិ អគ្គិហុត្តំ បរិចរតិ ។ អថខោ សុន្ទរិក-ភារទ្វាជោ ព្រាហ្មណោ អគ្គឹ ជុហិត្វា អគ្គិហុត្តំ បរិចរិត្វា ឧដ្ឋាយាសនា សមន្តា ចតុទ្ទិសា អនុវិលោ-កេសិ កោ នុ ខោ ឥមំ ហព្យសេសំ ភុញ្ជេយ្យាតិ ។

ព្រះពុទ្ធទ្រង់ត្រាស់ នូវព្រះគាថាណា ជាគ្រឿងក្សេម
ដើម្បីដល់ នូវព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ
គាថានោះឯង ឈ្មោះថាជាគាថាដ៏ឧត្តម ។

ចប់ សុភាសិតសូត្រ ទី ៣ ។

## សុន្ទរិកសូត្រទី ៤

(៤៩) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ប្របឆ្នេរស្ទឹងឈ្មោះ សុន្ទរិកា ក្នុងកោសលជនបទ ។ សម័យនោះឯង សុន្ទរិកភារទ្វាជព្រាហ្មណ៍ បូជាភ្លើង បំរើការបូជាភ្លើង ប្របឆ្នេរស្ទឹងសុន្ទរិកា ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍ លុះបូជាភ្លើង បំរើការបូជាភ្លើងរួចហើយ ក៏ក្រោកចាកអាសនៈ ក្រឡេកមើលសព្វទិសទាំង ៤ ជុំវិញ ដោយគិតថា អ្នកណាហ្ន៎ គួរបរិភោគរបស់ជាសំណល់អំពីយញ្ញនេះ ។

អទ្ទសា ខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ សសីសំ បារុតំ និសិន្នំ ទិស្វាន វាមេន ហត្ថេន សេសកំ គហេត្វា ទក្ខិណេន ហត្ថេន កមណ្ឌលុំ(១) យេន ភគវា តេនុបសង្កមិ ។ អថខោ ភគវា សុន្ទរិកភារទ្វាជស្ស ព្រាហ្មណស្ស បទសទ្ទេន សីសំ វិវរិ ។ អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ មុណ្ឌោ អយំ ភវំ មុណ្ឌកោ អយំ ភវន្តិ តតោ(២) បុន និវត្តិតុកាមោ អហោសិ ។ អថខោ សុន្ទរិកភារទ្វាជស្ស ព្រាហ្មណស្ស ឯតទហោសិ មុណ្ឌាបិ ហិធេកច្ចេ ព្រាហ្មណា ភវន្តិ យន្នូនាហំ ឧបសង្កមិត្វា ជាតឹ បុច្ឆេយ្យន្តិ ។ អថខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច កឹជច្ចោ ភវន្តិ ។

---

១ ម. កមណ្ឌលុំ គហេត្វា ។ ២ ម. តតោវ ។

សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានឃើញព្រះមានព្រះភាគគង់ ផ្ដាប់ព្រះកាយព្រមទាំងព្រះសិរ្ស ប្របគល់ឈើមួយដើម ក្នុងទីជិត លុះឃើញហើយ ក៏កាន់យករបស់ជាសំណល់អំពីយ័ញ្ញដោយដៃឆ្វេង កាន់យកល័ក្កតាន់ដោយដៃស្ដាំ ចូលទៅរកព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បើកព្រះសិរ្ស ដោយ (ឮ) សូរជើង នៃសុន្ទរិកភារ-ទ្វាជព្រាហ្មណ៍ ។ លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ មានប្រាថ្នាត្រឡប់ អំពីទីនោះមកវិញ ដោយគិតថា យីអើ អ្នកដ៏ចំរើននេះ ជាអ្នកកំណោរទេតើ យីអើ អ្នកដ៏ចំរើននេះ ជាអ្នកកំណោរទេតើ ។ លំដាប់នោះ សុន្ទរិក-ភារទ្វាជព្រាហ្មណ៍ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ សូម្បីជាអ្នកកំណោរក៏មាន បើដូច្នោះ មានតែអាត្មាអញ ចូលទៅសួរនូវជាតិចុះ ។ លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា អ្នកដ៏ចំរើនមានជាតិជាអ្វី ។

អថខោ ភគវា សុន្ទរិកភារទ្វាជំ ព្រាហ្មណំ គាថាយ អជ្ឈភាសិ

(៤៦) ន ព្រាហ្មណោ នោម្ហិ ន រាជបុត្តោ
ន វេស្សាយនោ ឧទ កោចិ នោម្ហិ
គោត្តំ បរិញ្ញាយ បុថុជ្ជនានំ
អកិញ្ចនោ មន្ត ចរាមិ លោកេ
សង្ឃាដិវាសី អគហោ[1] ចរាមិ
និវុត្តកេសោ អភិនិព្វុតត្តោ
អលិម្បមានោ[2] ឥធ មាណវេហិ
អកល្លំ មំ (ព្រាហ្មណ) បុច្ឆសិ គោត្តបញ្ហំ ។
បុច្ឆន្តិ វេ ភោ[3] ព្រាហ្មណា ព្រាហ្មណេហិ
សហ ព្រាហ្មណោ នោ ភវន្តិ ។
ព្រាហ្មណោ ចេ ត្វំ ព្រូសិ មញ្ច ព្រូសិ អព្រាហ្មណំ

---

១ ឱ. អគិហោ ។ ម. អគតោ ។ ២ ឱ. អលិប្បមានោ ។ ៣. ម. វេទេហ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ នឹងសុន្ទរិក-ភារទ្វាជព្រាហ្មណ៍ ដោយគាថា ដូច្នេះថា

(៤៦) តថាគតមិនមែនជាព្រាហ្មណ៍ មិនមែនជារាជបុត្ត មិនមែនជាវេស្សៈ ឬជាវណ្ណៈ ណាមួយក៏មិនមែន តថាគត បានកំណត់ដឹង នូវគោត្ររបស់ពួកបុថុជ្ជន ហើយជាអ្នកមិនមានកង្វល់ ប្រព្រឹត្តទៅដោយប្រាជ្ញាក្នុងលោក តថាគតជាអ្នកអាស្រ័យនៅ នឹងសង្ឃាដិ មិនមានសេចក្ដីប្រកាន់ ប្រាសចាកសក់ មានចិត្តត្រជាក់ មិនជាប់ចំពាក់នឹងពួកមនុស្ស ក្នុងលោក (ម្នាលព្រាហ្មណ៍ ថ្វីក៏) អ្នកមកសាកសួរប្រស្នាចំពោះគោត្រ ដ៏មិនសមគួរនឹងតថាគត ។

(ព្រាហ្មណ៍ក្រាបទូលថា) បពិត្រអ្នកដ៏ចំរើន ពួកព្រាហ្មណ៍តែងសាកសួរជាមួយនឹងពួកព្រាហ្មណ៍ថា អ្នកដ៏ចំរើន ជាព្រាហ្មណ៍ ឬមិនមែនទេ ។

( ព្រះអានព្រះភាគ ទ្រង់ត្រាស់ថា) បើអ្នកនិយាយថា ខ្លួនអ្នកជាព្រាហ្មណ៍ ហើយនិយាយថា តថាគត មិនមែនជាព្រាហ្មណ៍ទេ ។ ព្រោះហេតុនោះ

តំ តំ សាវិត្តឹ បុច្ឆាមិ តិបទំ ចតុវីសតក្ខរំ ។

កឹ និស្សិតា ឥសយោ មនុជា

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្បយឹសុ(១) បុថូធ លោកេ ។

យទន្តគូ វេទគូ យញ្ញកាលេ

យស្សាហុតឹ លភេ តស្សិជ្ឈេតិ ព្រូមិ ។

អទ្ធា ហិ តស្ស ហុតមិជ្ឈេ (ឥតិ ព្រាហ្មណោ)

យំ តាទិសំ វេទគុំ អទ្ទសាម

តុម្ហាទិសានញ្ហិ អទស្សនេន

អញ្ញោ ជនោ ភុញ្ជតិ បូរឡាសំ ។

---

១ ឱ. ប. យញ្ញមកប្បយើសុ ។

តថាគតសូមសួរនូវសាវិត្តិសាស្ត្រ ដែលមានបទ ៣ មានអក្ខរៈ ២៤ នឹងអ្នក ។

(ព្រាហ្មណ៍ក្រាបទូលសួរថា) ពួកឥសី មនុស្ស ក្សត្រិយ៍ នឹងព្រាហ្មណ៍ ជាច្រើន ក្នុងលោកនេះ អាស្រ័យហេតុដូចម្តេច ទើបតាក់តែងនូវគ្រឿងយញ្ញ បំពោះពួកទេវតា ។

(ព្រះមានព្រះភាគត្រាស់ថា) តថាគតពោលថា បុគ្គលណា ដល់នូវទីបំផុតនៃវដ្តទុក្ខ ដល់នូវវេទ (បុគ្គលនោះ) គប្បីបាននូវគ្រឿងបូជារបស់ជនណា ក្នុងកាលជាទីបូជា គ្រឿងបូជារបស់ជននោះ រមែងសម្រេច គឺមានផលច្រើន ។

(ព្រាហ្មណ៍ក្រាបទូលថា) ខ្ញុំព្រះអង្គបើឃើញបុគ្គលណាមួយ ជាអ្នកដល់នូវវេទ ប្រហែលនឹងព្រះអង្គ គ្រឿងបូជារបស់ខ្ញុំព្រះអង្គនោះគង់សម្រេច ដោយពិត ព្រោះមកពីខ្ញុំព្រះអង្គ មិនបានជួបប្រទះនឹងពួកជនប្រហែលនឹងព្រះអង្គ ទើបជនឯទៀតបរិភោគនូវនំឈ្មោះបុរោឡាសៈ របស់ខ្ញុំព្រះអង្គ ។

តស្មាតិហ ត្វំ ព្រាហ្មណ អត្ថេន

អត្ថិកោ ឧបសង្កម្ម បុច្ឆ

សន្តំ វិធូមំ អនីឃំ និរាសំ

អប្បេវិធ អភិវិន្ទេ សុមេធំ ។

យញ្ញេ រតោហំ(១)[ភោ គោតម]យញ្ញំ យិដ្ឋុកាមោ(២)

នាហំ បជានាមិ អនុសាសតុ មំ ភវំ

យត្ថ ហុតំ ឥជ្ឈតេ ព្រូហិ មេតំ ។

តេន ហិ ត្វំ ព្រាហ្មណ ឱទហស្សុ សោតំ

ធម្មំ តេ ទេសិស្សាមិ

មា ជាតឹ បុច្ឆ ចរណញ្ច បុច្ឆ

កដ្ឋា ហវេ ជាយតិ ជាតវេទោ

នីចាកុលីនោបិ មុនី ធិតិមា

អាជានីយោ ហោតិ ហិរីនិសេធោ ។

---

១ ឱ. ម. រតាហំ ។ ២ ឱ. យដ្ឋុកាមោ ។ ម. យិដ្ឋុកាមោ ។

(ព្រះមានព្រះភាគត្រាស់ថា) ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះឯង អ្នកត្រូវការដោយប្រយោជន៍គួរអ្នកចូលទៅសួរនូវបុគ្គលអ្នកស្ងប់រម្ងាប់ ប្រាសចាកផ្សែងគឺសេចក្ដីក្រោធ មិនមានទុក្ខ មិនមានសេចក្ដីប្រាថ្នា អ្នកមុខជាទឹងប្ហានលោកអ្នកមានប្រាជ្ញាល្អក្នុងសាសនានេះមិនខាន ។

(ព្រាហ្មណ៍ក្រាបទូលថា) បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គត្រេកអរនឹងគ្រឿងយញ្ញ ចង់បូជាគ្រឿងយញ្ញ ខ្ញុំព្រះអង្គមិនដឹង សូមព្រះអង្គដ៏ចំរើន ប្រៀនប្រដៅខ្ញុំ ការបូជាចំពោះបុគ្គលណាមានផលច្រើន សូមព្រះអង្គប្រាប់បុគ្គលនុ៎ះ ដល់ខ្ញុំព្រះអង្គ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រុងសោតប្បសាទ តថាគតនឹងសំដែងធម៌ដល់អ្នក អ្នកកុំសួរជាតិ សួរតែក្រិត្យគ្រឿងប្រព្រឹត្តចុះ ភ្លើងតែងកើតអំពីអុស ព្រះខីណាសវមុនិសម្បីជាអ្នកមានត្រកូលថោកទាប រមែងជាអ្នកទ្រទ្រង់គុណជាអាជានិយៈ ហាមឃាត់ទោសដោយហិរិបានដែរ ។

សច្ចេន ទន្តោ ទមសា ឧបេតោ
វេទន្តគូ វុសិតព្រហ្មចរិយោ
កាលេន តម្ហិ ហព្យំ បវេច្ឆេ
យោ ព្រាហ្មណោ បុញ្ញបេក្ខោ យជេថ ។
យេ កាមេ ហិត្វា អគិហា ចរន្តិ
សុសញ្ញតត្តា តសរំវ ឧជ្ជុំ
កាលេន តេសុ ហព្យំ បវេច្ឆេ
យោ ព្រាហ្មណោ បុញ្ញបេក្ខោ យជេថ ។
យេ វីតរាគា សុសមាហិតិន្ទ្រិយា
ចន្ទោវ រាហុគ្គហណា បមុត្តា
កាលេន តេសុ ហព្យំ បវេច្ឆេ(១) ។
អសជ្ជមានា វិចរន្តិ លោកេ
សទា សតា ហិត្វា មមាយិតានិ
កាលេន តេសុ ហព្យំ បវេច្ឆេ(២) ។

---

១-២-ម. កាលេន តេសុ ហព្យំ បវេច្ឆេ យោ ព្រាហ្មណោ បុញ្ញបេក្ខោ យជេថ ។

(បុគ្គលណា) បានទូន្មានខ្លួនដោយបរមត្ថសច្ចៈប្រកប
ដោយការទូន្មានឥន្ទ្រិយ ជាអ្នកដល់នូវមគ្គញាណទី៤
ជាទីបំផុតនៃវេទ បានប្រព្រឹត្តមគ្គព្រហ្មចរិយៈ ចប់
ហើយ ព្រាហ្មណ៍ណា ប្រាថ្នាបុណ្យ ហើយបូជា
(ព្រាហ្មណ៍នោះ) គួរឲ្យទេយ្យធម៌ ចំពោះបុគ្គលនោះ
តាមកាលគួរ ។ ពួកជនណា បានលះបង់កាមទាំង
ឡាយ មិនមានសេចក្តីប្រកាន់ មានចិត្តសង្រួមគ្រន់
ល្អដូចខ្នារ ព្រាហ្មណ៍ណា ប្រាថ្នាបុណ្យហើយបូជា
គួរឲ្យទក្ខិណាទានចំពោះពួកជននោះ ក្នុងកាលគួរ ។
ពួកជនណា ប្រាសចាកតម្រេក មានឥន្ទ្រិយតាំងមាំ
ល្អដូចជាព្រះចន្ទ្រផុតចាកពហុគ្រោះ ព្រាហ្មណ៍គួរឲ្យ
ទក្ខិណាទាន ចំពោះពួកជននោះ ក្នុងកាលគួរ ។
ពួកជនណា មិនជាប់ចំពាក់ ត្រាច់ទៅក្នុងលោក មាន
ស្មារតីសព្វកាល លះបង់នូវសេចក្តីប្រកាន់ ព្រាហ្មណ៍
គួរឲ្យទក្ខិណាទានចំពោះពួកជននោះ ក្នុងកាលគួរ ។

សុត្តនិបាតេ តតិយស្ស មហាវគ្គស្ស ចតុត្ថំ សុន្ទរិកសុត្តំ

យោ កាមេ ហិត្វា អភិភុយ្យចារី
យោ វេទិ ជាតីមរណស្ស អន្តំ
បរិនិព្ពុតោ ឧទករហទោវ សីតោ
តថាគតោ អរហតិ បូរឡាសំ ។

សមោ សមេហិ វិសមេហិ ទូរេ
តថាគតោ ហោតិ អនន្តបញ្ញោ
អនូបលិត្តោ ឥធ វា ហុរំ វា
តថាគតោ អរហតិ បូរឡាសំ ។

យម្ហិ ន មាយា វសតី ន មានោ
យោ វីតលោភោ អមមោ និរាសោ
បនុណ្ណកោធោ អភិនិព្ពុតត្តោ
យោ ព្រាហ្មណោ សោកមលំ អហាសិ
តថាគតោ អរហតិ បូរឡាសំ ។

ព្រះតថាគតណា បានលះបង់នូវកិលេសកាម ជាអ្នកប្រព្រឹត្តគ្របសង្កត់ នូវវត្ថុកាម ឬក៏ព្រះតថាគតណា ដឹងច្បាស់នូវទីបំផុត នៃជាតិមរណៈ បានបរិនិព្វាន មានចិត្តត្រជាក់ដូចអន្លង់ទឹក ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជាឈ្មោះបុរោឡាសៈ ។ ព្រះតថាគតស្មើដោយព្រះសម្ពុទ្ធទាំងឡាយ ដែលមានគុណស្មើគ្នា ឆ្ងាយអំពីពួកជនដែលមានគុណមិនស្មើ ទ្រង់មានប្រាជ្ញាមិនមានទីបំផុត មានព្រះទ័យមិនជាប់ចំពាក់ក្នុងលោកនេះនិងលោកខាងមុខ ព្រះតថាគត ទើបគួរទទួលគ្រឿងបូជាឈ្មោះបុរោឡាសៈ ។ មាយានឹងមានះមិនមាននៅក្នុងព្រះតថាគតណា ព្រះតថាគតណា ប្រាសចាកសេចក្តីលោភ មិនមានសេចក្តីប្រកាន់ មិនមានសេចក្តីប្រាថ្នា បានបន្ទោបង់នូវសេចក្តីក្រោធ មានចិត្តត្រជាក់ ឬថាព្រះតថាគតណា ជាអ្នកបណ្តេតបោលនូវបាប បានលះបង់មន្ទិលគឺសេចក្តីសោក ព្រះតថាគតនោះ ទើបគួរទទួលនូវគ្រឿងបូជាឈ្មោះបុរោឡាសៈ ។

និវេសនំ យោ មនសោ អហាសិ

បរិគ្គហា យស្ស ន សន្តិ កេចិ

អនុបាទិយានោ ឥធ វា ហុរំ វា

តថាគតោ អរហតិ បូរឡាសំ ។

សមាហិតោ យោ ឧទតារិ ឱឃំ

ធម្មញ្ច ញាសិ បរមាយ ទិដ្ឋិយា

ខីណាសវោ អន្តិមទេហធារី

តថាគតោ អរហតិ បូរឡាសំ ។

ភវាសវា យស្ស វចី ខរា ច

វិធូបិតា អត្ថគតា ន សន្តិ

ស វេទគូ សព្វធិ វិប្បមុត្តោ

តថាគតោ អរហតិ បូរឡាសំ ។

ព្រះតថាគតណា បានលះបង់នូវកិលេស ជាគ្រឿង
អាស្រ័យនៅនៃចិត្ត គឺតណ្ហានិងទិដ្ឋិ ឬជាសេចក្តី
ប្រកាន់ណាមួយ ក៏មិនមាន ដល់ព្រះតថាគតណា
ព្រះតថាគតនោះ ជាអ្នកមិនមានសេចក្តីប្រកាន់ ក្នុង
លោកនេះនិងលោកខាងមុខ ទើបគួរទទួលគ្រឿងបូជា
ឈ្មោះបុរោឡាសៈ ។ ព្រះតថាគតណា ជាអ្នក
មានចិត្តតាំងមាំ បានឆ្លងឱឃៈ បានដឹងធម៌ដោយទិដ្ឋិ
ដ៏ឧត្តម ជាអ្នកអស់អាសវៈ ទ្រទ្រង់រាងកាយជាទីបំផុត
ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះ
បុរោឡាសៈ ។ កងអាសវៈទាំងឡាយផង វាចាអាក្រក់
ផង ដែលព្រះតថាគតណា កំចាត់បង់ហើយ ដល់
នូវការតាំងនៅមិនបាន គឺថាមិនមាន ព្រះតថាគតនោះ
ជាអ្នកបាននូវវេទ មានចិត្តផុតចាកធម៌ មានខន្ធជា
ដើមទាំងអស់ ទើបគួរទទួលគ្រឿងបូជាឈ្មោះបុរោឡាសៈ ។

សង្គាតិគោ យស្ស ន សន្តិ សង្គា
យោ មានសត្តេសុ អមានសត្តោ
ទុក្ខំ(១) បរិញ្ញាយ សខេត្តវត្ថុំ
តថាគតោ អរហតិ បូរឡាសំ ។

អាសំ អនិស្សាយ វិវេកទស្សី
បរវេទិយំ ទិដ្ឋិមុបាតិវត្តោ
អារម្មណា យស្ស ន សន្តិ កេចិ
តថាគតោ អរហតិ បូរឡាសំ ។

បរោបរា(២) យស្ស សមេច្ច ធម្មា
វិធូបិតា អត្ថគតា ន សន្តិ
សន្តោ ឧបាទានក្ខយេ វិមុត្តោ
តថាគតោ អរហតិ បូរឡាសំ ។

---

១ ម. ទុក្ខ២ ។ ២. បរោវរា ។

កិលេស ជាគ្រឿងជាប់ចំពាក់ទាំងឡាយ មិនមានដល់ព្រះតថាគតណា ព្រះតថាគតណា កន្លងផុតនូវកិលេសជាគ្រឿងជាប់ចំពាក់ កាលពួកសត្វជាប់ ដោយមានះ ព្រះអង្គក៏មិនជាប់ ដោយមានះ បានកំណត់ដឹងនូវទុក្ខព្រមទាំងខេត្តវត្ថុ គឺហេតុនឹងបច្ច័យ ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបុរោឡាសៈ ។ ព្រះតថាគតណា មិនអាស្រ័យ នូវសេចក្តីប្រាថ្នា ឃើញនូវព្រះនិព្វានជាធម៌ស្ងប់ស្ងាត់ ប្រព្រឹត្តកន្លងនូវមិច្ឆាទិដ្ឋិដែលជនឯទៀតគប្បីឲ្យដឹង ធម៌ទាំងឡាយណាមួយជាអារម្មណ៍គឺជាបច្ច័យ មិនមានដល់ព្រះតថាគតណា ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជា ឈ្មោះបុរោឡាសៈ ។ ធម៌ទាំងឡាយ ទាំងខាងក្នុងនឹងខាងក្រៅ មិនមាន ដែលព្រះតថាគតណា បានគ្រាស់ដឹង កំចាត់បង់ហើយ ជាធម៌ដល់នូវកិរិយាតាំងនៅមិនបាន គឺថាមិនមាន ព្រះតថាគតនោះ ជាអ្នកមានចិត្តស្ងប់មានចិត្តផុតស្រឡះ ព្រោះអស់ទៅនៃឧបាទាន ទើបគួរទទួលគ្រឿងបូជាឈ្មោះបុរោឡាសៈ ។

សំយោជនំ ជាតិខយន្តទស្សី

យោ បានុទិ រាគបថំ អសេសំ

សុទ្ធោ និទ្ទោសោ វិមលោ អកាមោ (១)

តថាគតោ អរហតិ បូរឡាសំ ។

យោ អត្តនាត្តានំ នានុបស្សតិ

សមាហិតោ ឧជុគតោ ឋិតត្តោ

ស វេ អនេជោ អខិលោ អកង្ខោ

តថាគតោ អរហតិ បូរឡាសំ ។

មោហន្តរា យស្ស ន សន្តិ កេចិ

សព្វេសុ ធម្មេសុ ច ញាណទស្សី

សរីរញ្ច អន្តិមំ ធារេតិ

បត្តោ ច សម្ពោធិមនុត្តរំ សិវំ

ឯត្តាវតា យក្ខស្ស សុទ្ធិ

---

១ ឱ. ម. អកាចោ ។

ព្រះតថាគតណា បានឃើញនូវធម៌ ជាទីអស់ទៅនៃសំយោជនៈផង ឃើញនូវធម៌ ជាទីអស់ទៅនៃជាតិផង បានបន្ទោបង់នូវគន្លងនៃភពៈ មិនមានសេសសល់ ជាអ្នកបរិសុទ្ធ មិនមានទោស ប្រាសចាកមន្ទិល ទាំងមិនមានសេចក្តីប្រាថ្នា ព្រះតថាគតនោះ ទើបគួរទទួលគ្រឿងបូជាឈ្មោះបុរោឡាសៈ ។ ព្រះតថាគតណាមិនឃើញខ្លួន(១) ដោយខ្លួនឯង ជាអ្នកមានចិត្តតាំងមាំ មានចិត្តប្រព្រឹត្តទៅត្រង់ មានចិត្តនឹងធឹង ព្រះតថាគតនោះ មានព្រះទ័យមិនរំភើប មិនរឹងរូស មិនសង្ស័យ ទើបគួរទទួលគ្រឿងបូជាឈ្មោះបុរោឡាសៈ ។ សភាវធម៌ទាំងឡាយ ដែលមានមោហៈ ជាហេតុណាមួយ មិនមានដល់ព្រះតថាគតណា ព្រះតថាគតណា បានឃើញដោយប្រាជ្ញា ក្នុងធម៌ទាំងឡាយទាំងពួង ហើយទ្រទ្រង់នូវសរីរៈជាទីបំផុតទាំងសម្រេចនូវសម្ពោធិញ្ញាណ ជាគ្រឿងក្សេមយ៉ាងប្រសើរ ព្រះអង្គមានសេចក្តីបរិសុទ្ធិ យ៉ាងអស់ដើម ត្រឹមប៉ុណ្ណោះ

---

១ ឃើញតែត្រឹមខន្ធតែប៉ុណ្ណោះ ។

(តថាគតោ អរហតិ បូរឡាសំ) ។

ហុតញ្ច មយ្ហំ ហុតមត្ថុ សច្ចំ

យំ តាទិសំ វេទគុំ អលត្ថំ

ព្រហ្មា ហិ សក្ខិ បដិគណ្ហាតុ មេ ភគវា

ភុញ្ជតុ មេ ភគវា បូរឡាសំ ។

គាថាភិគីតំ មេ អភោជនេយ្យំ

សម្បស្សតំ ព្រាហ្មណ នេស ធម្មោ

គាថាភិគីតំ បនុទន្តិ ពុទ្ធា

ធម្មេ សតិ ព្រាហ្មណ វុត្តិរេសា ។

អញ្ញេន ច កេវលិនំ មហេសឹ

ខីណាសវំ កុក្កុច្ចវូបសន្តំ

អន្នេន បានេន ឧបដ្ឋហស្សុ

ខេត្តញ្ហិ តំ បុញ្ញបេក្ខស្ស ហោតិ ។

( ព្រះតថាគតនោះ ទើបគួរទទួល នូវគ្រឿងបូជា ឈ្មោះបុរោឡាសៈ ) ។

( ព្រាហ្មណ៍ក្រាបទូលថា) ការបូជារបស់ខ្ញុំព្រះអង្គ ជាការបូជាមានផលពិត ១ ព្រោះខ្ញុំព្រះអង្គបានបុគ្គល អ្នកដល់នូវវេទ ប្រហែលនឹងព្រះអង្គ ហេតុនេះសូមព្រះមានព្រះភាគ ជាបន្ទាល់ដ៏ប្រសើរ ទទួលគ្រឿងបូជារបស់ខ្ញុំព្រះអង្គ សូមព្រះមានព្រះភាគ សោយគ្រឿងបូជា ឈ្មោះបុរោឡាសៈ របស់ខ្ញុំព្រះអង្គ ។

( ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ) តថាគតមិនគួរបរិភោគភោជន ដែលបានមកអំពីការពោលគាថាទេ ម្នាលព្រាហ្មណ៍ នេះមិនមែនជាធម្មតារបស់ពួកបុគ្គលអ្នកឃើញ (ធម៌)ទេ ព្រះពុទ្ធទាំងឡាយតែងបន្ទោបង់នូវអាហារ ដែលពោលគាថា ម្នាលព្រាហ្មណ៍ កាលបើធម៌មានហើយ នេះឯងជាគ្រឿងចិញ្ចឹមជីវិត ។ អ្នកចូរទំនុកបម្រុង បុគ្គលជាខីណាស្រព មានគុណដ៏បរិបូណ៌ អ្នកស្វែងរកនូវគុណដ៏ធំ អ្នករម្ងាប់សេចក្ដីពិសពោយបាយនឹងទឹកដទៃ ព្រោះថា នោះជាខេត្ត របស់បុគ្គលអ្នកប្រាថ្នាបុណ្យ ។

សាធាហំ ភគវា តថា វិជញ្ញំ
យោ ទក្ខិណំ ភុញ្ជេយ្យ មាទិសស្ស
យំ យញ្ញកាលេ បរិយេសមានោ
បប្បុយ្យ[1] តវ សាសនំ ។

សារម្ភា យស្ស វិគតា ចិត្តំ យស្ស អនាវិលំ
វិប្បមុត្តោ ច កាមេហិ ថីនំ យស្ស បនូទិតំ
សីមន្តានំ វិនេតារំ ជាតិមរណកោវិទំ
មុនឹ មោនេយ្យសម្បន្នំ តាទិសំ យញ្ញមាគតំ
ភកុដឹ វិនយិត្វាន បញ្ជលិកា នមស្សថ
បូជេថ អន្នបានេន ឯវំ ឥជ្ឈន្តិ ទក្ខិណា ។

---

១ ម. បព្រុ ។

(ព្រាហ្មណ៍ក្រាបទូលថា) បពិត្រព្រះមានព្រះភាគ សូមទ្រង់ព្រះមេត្តាប្រោស ទក្ខិណេយ្យបុគ្គលណា គួរបរិភោគទក្ខិណាទានរបស់បុគ្គលដូចជាខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គបានដល់នូវសាសនានៃព្រះអង្គស្វែងរកទក្ខិណេយ្យ-បុគ្គលណា ទីងទំនុកបម្រុងក្នុងកាលដែលបូជា ខ្ញុំព្រះអង្គដឹងច្បាស់ (នូវទក្ខិណេយ្យបុគ្គលនោះ) ដោយប្រការដូចម្តេច ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) សេចក្តីប្រណាំងប្រជែង របស់បុគ្គលណា ទៅប្រាសហើយផង ឬចិត្តរបស់បុគ្គលណា មិនល្អក់ផងបុគ្គលណាផុតស្រឡះចាកកាមទាំងឡាយផង សេចក្តីលោភផង ដែលបុគ្គលណាបន្ទោបង់ហើយផង អ្នកទាំងឡាយ ចូរបំបាត់នូវការក្រញូវមុខ ហើយផ្គងអញ្ជលីនមស្ការ បូជាបុគ្គលអ្នកខ្ទាន់នូវពួកបព្វជិត នឹងសេក្ខបុគ្គលអ្នកដឹងច្បាស់ នូវជាតិនឹងមរណៈ ជាអ្នកប្រាជ្ញ បរិបូណ៌ ដោយប្រាជ្ញា ព្រោកដូច្នោះ មកកាន់ទីជាទីបូជានោះ ដោយម្ហូបចំណីនឹងទឹកកាលបើយ៉ាងនេះទក្ខិណាទានទាំងឡាយ រមែងសម្រេចៗ

ពុទ្ធោ ភវំ អរហតិ បូរឡាសំ បុញ្ញក្ខេត្តមនុត្តរំ
អាយាគោ សព្វលោកស្មឹ(១) ភោតោ ទិន្នំ មហប្ផលន្តិ ។

(៤៧) អថ ខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ សុន្ទរិកភារទ្វាជោ ព្រាហ្មណោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ បេ ។ អញ្ញតរោ ខោ បនាយស្មា សុន្ទរិកភារទ្វាជោ អរហតំ អហោសីតិ ។

សុន្ទរិកសុត្តំ ចតុត្ថំ ។

---

១ ឱ. ម. សព្វលោកស្ស ។

(ព្រាហ្មណ៍ក្រាបទូលថា) ព្រះពុទ្ធដ៏ចំរើន ព្រះអង្គ
ជាបុញ្ញក្ខេត្តដ៏ប្រសើរ គួរទទួលគ្រឿងបូជា ឈ្មោះបូ-
ឡាសៈ ជាការបូជា ក្នុងលោកទាំងអស់ ទានដែល
បុគ្គលឲ្យហើយចំពោះព្រះពុទ្ធដ៏ចំរើន មានផលច្រើន ។

(៤៧) លំដាប់នោះ សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើនសំដែងហើយ ដោយអនេកបរិយាយ ដូចជាគេផ្ងារនូវរបស់ដែលផ្កាប់ ឬបើកបង្ហាញនូវរបស់ដែលកំបាំង ពុំនោះសោតដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេងផ្លូវ ឬដូចជាគេទ្រោលប្រទីបប្រេងបំភ្លឺក្នុងទីងងឹត ដោយគិតថា ឲ្យពួកមនុស្សមានភ្នែកមើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គនោះ សូមដល់ព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ខ្ញុំព្រះអង្គ គួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់ព្រះគោតមដ៏ចំរើន ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍ បានបព្វជ្ជា បានឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ។បេ។ បណ្ដាព្រះអរហន្តទាំងឡាយ ព្រះសុន្ទរិកភារទ្វាជៈដ៏មានអាយុ ក៏ជាព្រះអរហន្តមួយដែរ ។

ចប់ សុន្ទរិកភារទ្វាជសូត្រទី ៤ ។

# បញ្ចមំ មាឃសុត្តំ

(៤៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ មាឃោ មាណវោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មាឃោ មាណវោ ភគវន្តំ ឯតទវោច អហញ្ហិ ភោ គោតម ទាយកោ ទានបតិ វទញ្ញូ យាចយោគោ ធម្មេន ភោគេ បរិយេសាមិ ធម្មេន ភោគេ បរិយេសិត្វា ធម្មលទ្ធេហិ ភោគេហិ ធម្មាធិគតេហិ ឯកស្សបិ ទទាមិ ទ្វិន្នម្បិ ទទាមិ តិណ្ណម្បិ ទទាមិ ចតុន្នម្បិ ទទាមិ បញ្ចន្នម្បិ ទទាមិ ឆន្នម្បិ ទទាមិ សត្តន្នម្បិ ទទាមិ អដ្ឋន្នម្បិ ទទាមិ នវន្នម្បិ ទទាមិ ទសន្នម្បិ ទទាមិ វីសាយបិ ទទាមិ តឹសាយបិ ទទាមិ

# មាឃសូត្រ ទី ៥

(៤៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅនាភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ មាឃមាណព បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបបង្គំទូលសំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយ គួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ មាឃមាណព លុះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គជាទាយក ជាទានបតី អ្នកដឹងនូវពាក្យពេចន៍ (របស់សូម) អ្នកគួរគេសូមបាន ស្វែងរកនូវភោគៈទាំងឡាយតាមធម៌ លុះខ្ញុំព្រះអង្គស្វែងរកភោគៈទាំងឡាយតាមធម៌បានហើយ (ក៏យក) នូវភោគទាំងឡាយ ដែលបានមកតាមធម៌ សម្រេចមកតាមធម៌នោះ ឲ្យដល់បុគ្គលម្នាក់ខ្លះ ឲ្យដល់បុគ្គលពីរនាក់ខ្លះ ឲ្យដល់បុគ្គល ៣ នាក់ខ្លះ ឲ្យដល់បុគ្គល ៤ នាក់ខ្លះ ឲ្យដល់បុគ្គល ៥ នាក់ខ្លះ ឲ្យដល់បុគ្គល ៦ នាក់ខ្លះ ឲ្យដល់បុគ្គល ៧ នាក់ខ្លះ ឲ្យដល់បុគ្គល ៨ នាក់ខ្លះ ឲ្យដល់បុគ្គល ៩ នាក់ខ្លះ ឲ្យដល់បុគ្គល ១០ នាក់ខ្លះ ឲ្យដល់បុគ្គល ២០ នាក់ខ្លះ ឲ្យដល់បុគ្គល ៣០ នាក់

ចត្តាឡីសាយបិ ទទាមិ បញ្ញាសាយបិ ទទាមិ សតស្សបិ ទទាមិ ភិយ្យោបិ ទទាមិ កច្ចាហំ ភោ គោតម ឯវំ ទទន្តោ ឯវំ យជេន្តោ(១) ពហុំ បុញ្ញំ បសវាមីតិ ។ តគ្ឃ ត្វំ មាណវ ឯវំ ទទន្តោ ឯវំ យជេន្តោ ពហុំ បុញ្ញំ បសវសិ ។ យោ ខោ មាណវ ទាយកោ ទានបតិ វទញ្ញូ យាចយោគោ ធម្មេន ភោគេ បរិយេសតិ ធម្មេន ភោគេ បរិយេសិត្វា ធម្មលទ្ធេហិ ភោគេហិ ធម្មាធិគតេហិ ឯកស្សបិ ទទាតិ ។ បេ ។ សតស្សបិ ទទាតិ ភិយ្យោបិ ទទាតិ ពហុំ សោ បុញ្ញំ បសវតីតិ ។ អថខោ មាឃោ មាណវោ ភគវន្តំ គាថាយ អជ្ឈភាសិ

(៤៩) បុច្ឆាមហំ គោតមំ(២) វទញ្ញុំ (ឥតិ មាឃោ មាណវោ)

កាសាយវាសឹ អគហំ ចរន្តំ

---

១ ឧ. ម. យជន្តោ ។ ២ ឧ. បុច្ឆាមហំ ភោ គោតមំ ។

ខ្លះ ឲ្យដល់បុគ្គល ៨០ នាក់ខ្លះ ឲ្យដល់បុគ្គល ៩០ នាក់ខ្លះ ឲ្យដល់បុគ្គលមួយរយនាក់ខ្លះ ឲ្យដល់បុគ្គលច្រើនជាងនោះខ្លះ បពិត្រព្រះគោតមដ៏ចំរើន កាលខ្ញុំព្រះអង្គឲ្យយ៉ាងនេះ បូជាយ៉ាងនេះ តើបានបុណ្យច្រើនដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើមាណព កាលបើអ្នក ឲ្យយ៉ាងនេះ បូជាយ៉ាងនេះ រមែងបានបុណ្យច្រើន ។ ម្នាលមាណព បើទាយក ទានបតី អ្នកដឹងនូវពាក្យពេចន៍ (របស់សូម) អ្នកគួរគេសូមបាន ដែលស្វែងរកភោគៈទាំងឡាយតាមធម៌ លុះស្វែងរកភោគៈទាំងឡាយតាមធម៌ហើយ (ក៏យក) ភោគៈទាំងឡាយតាមធម៌ សម្រេចមកតាមធម៌នោះ ឲ្យដល់បុគ្គលម្នាក់ខ្លះ ។ បេ ។ ឲ្យដល់បុគ្គលមួយនាក់ខ្លះ ឲ្យដល់បុគ្គលច្រើនជាងនោះខ្លះ ទាយកនោះ រមែងបានបុណ្យច្រើន ។ លំដាប់នោះ មាឃមាណព បានក្រាបបង្គំទូលព្រះមានព្រះភាគដោយគាថាដូច្នេះថា

(៨៩) ខ្ញុំសូមទូលសួរព្រះគោតម ព្រះអង្គ
ទ្រង់ជ្រាបនូវពាក្យពេចន៍ ទ្រង់អាស្រ័យនៅដោយ
សំពត់កាសាយៈ មិនមានផ្ទះ ត្រាច់ទៅផ្សេង ៗ
គ្រហស្ថណា ជាម្ចាស់ទាន គួរគេសូមបាន

យោ យាចយោគោ ទានបតី គហដ្ឋោ

បុញ្ញត្ថិកោ យជតិ បុញ្ញបេក្ខោ

ទទំ បរេសំ ឥធ អន្នបានំ

កថំ ហុតំ យជមានស្ស សុជ្ឈេ ។

(យោ) យាចយោគោ ទានបតី គហដ្ឋោ (មាឃាតិ ភគវា)

បុញ្ញត្ថិកោ យជតិ បុញ្ញបេក្ខោ

ទទំ បរេសំ ឥធ អន្នបានំ

អារាធយេ ទក្ខិណេយ្យេហិ តាទិ ។

(យោ) យាចយោគោ ទានបតី គហដ្ឋោ (ឥតិ មាឃោ

មាណវោ)

បុញ្ញត្ថិកោ យជតិ បុញ្ញបេក្ខោ

ទទំ បរេសំ ឥធ អន្នបានំ

អក្ខាហិ មេ ភគវា ទក្ខិណេយ្យេ ។

ជាអ្នកត្រូវការដោយបុណ្យ ប្រាថ្នាបុណ្យ កាលឲ្យនូវបាយទឹក បូជាដល់ពួកជនដទៃក្នុងលោកនេះ ការបូជារបស់បុគ្គលដែលបូជានោះ តើបរិសុទ្ធដូចម្តេច ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ម្នាលមាណព គ្រហស្ថ (ណា) ជាម្ចាស់ទាន គួរគេសូមបាន ជាអ្នកត្រូវការ ដោយបុណ្យ ប្រាថ្នាបុណ្យ កាលឲ្យ នូវបាយនិងទឹក បូជាដល់ពួកជនដទៃក្នុងលោកនេះ គ្រហស្ថបោកដូច្នោះ គប្បីញ៉ាំងទក្ខិណេយ្យបុគ្គលទាំងឡាយឲ្យត្រេកអរបាន ។

(មាឃមាណព ក្រាបទូលថា) គ្រហស្ថ (ណា) ជាម្ចាស់ទាន គួរគេសូមបាន ជាអ្នកត្រូវការដោយបុណ្យ ប្រាថ្នាបុណ្យ កាលឲ្យនូវបាយនិងទឹក បូជាដល់ពួកជនដទៃក្នុងលោកនេះ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គប្រាប់នូវទក្ខិណេយ្យបុគ្គលទាំងឡាយ (របស់គ្រហស្ថនោះ) ចំពោះខ្ញុំព្រះអង្គ ។

យេ វេ អលត្តា(១) វិចរន្តិ លោកេ

អកិញ្ចនា កេវលិនោ យតត្តា

កាលេន តេសុ ហព្យំ បវេច្ឆេ

យោ ព្រាហ្មណោ បុញ្ញបេក្ខោ យជេថ ។

យេ សព្វសំយោជនពន្ធនច្ឆិទា

ទន្តា វិមុត្តា អនីឃា និរាសា

កាលេន តេសុ ហព្យំ បវេច្ឆេ

យោ ព្រាហ្មណោ បុញ្ញបេក្ខោ យជេថ ។

យេ សព្វសញ្ញោជនវិប្បមុត្តា

ទន្តា វិមុត្តា អនីឃា និរាសា

កាលេន តេសុ ហព្យំ បវេច្ឆេ ។

---

១ ឱ. ម. អសត្តា ។

សុត្តនិបាត មហាវគ្គ ទី ៣ មាឃសូត្រ ទី ៥

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ពួកជនណា មិនមានចិត្តជាប់ចំពាក់ក្នុងលោក មិនមានកង្វល់ មានកិច្ចសម្រេចហើយ ជាអ្នកគ្រប់គ្រងចិត្ត ព្រាហ្មណ៍ណា ប្រាថ្នាបុណ្យហើយបូជា ព្រាហ្មណ៍នោះ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះតាមកាលគួរ ៗ

ពួកជនណា បានផ្តាច់ចំណងគឺសំយោជនៈ ទាំងពួង ជាអ្នកបានទូន្មាននូវឥន្ទ្រិយ មានចិត្តផុតស្រឡះ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ព្រាហ្មណ៍ណា ប្រាថ្នានូវបុណ្យហើយបូជា ព្រាហ្មណ៍នោះគប្បី បរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ៗ ពួកជនណា ផុតស្រឡះ ចាកសំយោជនៈ ទាំងពួង ជាអ្នកទូន្មាននូវឥន្ទ្រិយ មានចិត្តផុតស្រឡះ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ៗ

រាគញ្ច ទោសញ្ច បហាយ មោហំ

ខីណាសវា វុសិតព្រហ្មចរិយា

កាលេន តេសុ ហព្យំ បវេច្ឆេ ។

យេសុ ន មាយា វសតិ ន មានោ

ខីណាសវា វុសិតព្រហ្មចរិយា

កាលេន តេសុ ហព្យំ បវេច្ឆេ ។

យេ វីតលោភា អមមា និរាសា

ខីណាសវា វុសិតព្រហ្មចរិយា

កាលេន តេសុ ហព្យំ បវេច្ឆេ ។

យេ វេ ន តណ្ហាសុ ឧបាតិបន្នា

វិតរេយ្យ ឱឃំ អមមា ចរន្តិ

កាលេន តេសុ ហព្យំ បវេច្ឆេ ។

(ពួកជនណា) បានលះបង់រាគៈផង ទោសៈផង មោហៈផង មានអាសវៈអស់ហើយ មានមគ្គព្រហ្មចារ្យប្រព្រឹត្តរួចហើយ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ការបិទបាំងទោសខ្លួន នឹងការប្រកាន់ មិនមាននៅ ក្នុងពួកជនណា ដែលមានអាសវៈអស់ហើយ មានមគ្គព្រហ្មចារ្យប្រព្រឹត្តរួចហើយ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា ប្រាសចាកសេចក្ដីលោភ មិនប្រកាន់ មិនមានសេចក្ដីប្រាថ្នា មានអាសវៈអស់ហើយ មានមគ្គព្រហ្មចារ្យ ប្រព្រឹត្តរួចហើយ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា មិនដល់នូវការធ្លាក់ចុះ ក្នុងតណ្ហាទាំងឡាយ មិនប្រកាន់ហើយឆ្លងអន្លង់បាន ព្រាហ្មណ៍គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

សុត្តនិបាតេ តតិយស្ស មហាវគ្គស្ស បញ្ចមំ មាឃសុត្តំ

យេសំ តណ្ហា នត្ថិ កុហិញ្ចិ លោកេ
ភវាភវាយ ឥធ វា ហុរំ វា
កាលេន តេសុ ហព្យំ បវេច្ឆេ ៗ
យេ កាមេ ហិត្វា អគហា ចរន្តិ
សុសញ្ញតត្តា តសរំវ ឧជ្ជុំ
កាលេន តេសុ ហព្យំ បវេច្ឆេ ៗ
យេ វីតរាគា សុសមាហិតិន្ទ្រិយា
ចន្ទោវ រាហុគហណា បមុត្តា
កាលេន តេសុ ហព្យំ បវេច្ឆេ ៗ
សមិតាវិនោ វីតរាគា អកោបា
យេសំ គតី នត្ថិ ឥធ វិប្បហាយ
កាលេន តេសុ ហព្យំ បវេច្ឆេ ៗ
ជហេត្វា ជាតិមរណំ អសេសំ
កថង្កថំ(១) សព្វមុបាតិវត្តា
កាលេន តេសុ ហព្យំ បវេច្ឆេ ៗ

---

១ ម. កំកថី ៗ

តណ្ហារបស់ពួកជនណា ដើម្បីកើតមាន ទៅទៀត ក្នុងលោកនេះ ឬលោកខាងមុខណាមួយ មិនមានទេ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណាបានលះបង់កាមទាំងឡាយ ជាអ្នកមិនមានសេចក្ដីប្រកាន់ សង្រួម ចិត្តត្រង់ល្អដូចខ្នារ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា ប្រាសចាកពកៈ មានឥន្ទ្រិយតម្កល់មាំល្អ ដូចព្រះចន្ទ្រដែលផុតស្រឡះចាករាហុគ្រាះ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណាជាអ្នកស្ងប់ចាកកិលេស ប្រាសចាកពកៈ មិនមានសេចក្ដីក្រោធ គតិរបស់ជនណាមិនមាន ព្រោះលះបង់ (នូវខន្ធ) ក្នុងលោកនេះ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទានចំពោះជននោះ តាមកាលគួរ ។

ពួកជនណា លះបង់ជាតិនិងមរណៈ មិនមានសេសសល់ ឆ្លងផុតសេចក្ដីងឿងឆ្ងល់គ្រប់យ៉ាង ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទានចំពោះពួកជននោះ តាមកាលគួរ ។

យេ អត្តទីបា វិចរន្តិ លោកេ
អកិញ្ចនា សព្វធិ វិប្បមុត្តា
កាលេន តេសុ ហព្យំ បវេច្ឆេ ។
យេ ហេត្ថ ជានន្តិ យថាតថា ឥទំ
អយមន្តិមា នត្ថិ បុនព្ភវោតិ
កាលេន តេសុ ហព្យំ បវេច្ឆេ ។
យោ វេទគូ ឈានរតោ សតីមា
សម្ពោធិបត្តោ សរណំ ពហុន្នំ
កាលេន តេសុ(១) ហព្យំ បវេច្ឆេ
យោ ព្រាហ្មណោ បុញ្ញបេក្ខោ យជេថ ។
អទ្ធា អមោឃា មម បុច្ឆនា អហុ
អក្ខាសិ មេ ភគវា ទក្ខិណេយ្យំ

---

១ ឱ. ប. តម្ហិ ។

ពួកជនណា មានខ្លួនជាទីពឹង ត្រាច់ទៅក្នុងលោក មិនមានកង្វល់ ផុតស្រឡះចាកសភាវធម៌ទាំងពួង ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ពួកជនណា ដឹងក្នុងសភាវធម៌នុ៎ះ តាមសេចក្តីពិតថា ជាតិនេះជាជាតិបំផុតហើយ ភពថ្មីមិនមានតទៅទៀតឡើយ ព្រាហ្មណ៍ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

ជនណា បានដល់នូវវេទ ត្រេកអរក្នុងឈាន ជាអ្នកមានស្មារតី បានសម្រេចនូវសម្ពោធិញាណ ជាទីពឹងរបស់ជនច្រើន ព្រាហ្មណ៍ណា ជាអ្នកប្រាថ្នានូវបុណ្យ ហើយបូជា ព្រាហ្មណ៍នោះ គួរបរិច្ចាគទក្ខិណាទាន ចំពោះពួកជននោះ តាមកាលគួរ ។

( មាឃមាណព ក្រាបបង្គំទូលថា ) បពិត្រព្រះមានព្រះភាគ ការក្រាបទូលសួរ របស់ខ្ញុំព្រះអង្គ មិនមែនជាការឥតអំពើដោយពិត ព្រះអង្គបានសំដែងប្រាប់ទក្ខិណេយ្យបុគ្គលទាំងឡាយ ចំពោះខ្ញុំព្រះអង្គ

ត្វំ ហេត្ថ ជានាសិ យថាតថា ឥទំ

តថា ហិ តេ វិទិតោ ឯស ធម្មោ ។

(យោ) យាចយោគោ ទានបតី គហដ្ឋោ

(ឥតិ មាឃោ មាណវោ)

បុញ្ញត្ថិកោ យជតិ បុញ្ញបេក្ខោ

ទទំ បរេសំ ឥធ អន្នបានំ

អក្ខាហិ មេ ភគវា យញ្ញសម្បទំ ។

យជស្សុ យជមានោ មាឃាតិ ភគវា

សព្វត្ថ ច វិប្បសាទេហិ ចិត្តំ

អារម្មណំ យជមានស្ស យញ្ញោ(១)

ឯត្ថ បតិដ្ឋាយ ជហាតិ ទោសំ

សោ វីតរាគោ ច វិនេយ្យ ទោសំ

មេត្តចិត្តំ ភាវយំ អប្បមាណំ

រត្តិន្ទិវំ សតតំ អប្បមត្តោ

សព្វា ទិសា ផរតេ អប្បមញ្ញំ ។

---

១ ឱ. ម. បេញ្ញំ ។

ទើបខ្ញុំព្រះអង្គបានដឹងសេចក្តីនុ៎ះ តាមពិត ធម៌ព្រះអង្គទ្រង់ជ្រាបពិត យ៉ាងនោះហើយ ។

(មាឃមាណព ក្រាបទូលថា) គ្រហស្ថ (ណា) ជាម្ចាស់ទាន អ្នកគួរគេសូមបាន ជាអ្នកត្រូវការដោយបុណ្យ ប្រាថ្នានូវបុណ្យ កាលឲ្យបាយនឹងទឹក បូជាដល់ពួកជនដទៃ ក្នុងលោកនេះ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គ ទ្រង់សំដែងប្រាប់នូវយញ្ញសម្បទា (របស់គ្រហស្ថនោះ) ដល់ខ្ញុំព្រះអង្គ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាឃៈ អ្នកចូរបូជាចុះ កាលដែលអ្នកបូជា ចូរញុំាងចិត្តឲ្យជ្រះថ្លាក្នុងកាលទាំងពួង (ព្រោះ) គ្រឿងយ័ញ្ញជាអារម្មណ៍របស់អ្នកបូជា បុគ្គលដែលបានប្រតិស្ឋាន ក្នុងគ្រឿងយ័ញ្ញនុ៎ះហើយ រមែងលះបង់នូវទោសបាន លុះបុគ្គលនោះប្រាសចាករាគៈ បន្ទោបង់នូវទោសៈហើយ រមែងចំរើននូវមេត្តាចិត្ត មិនមានប្រមាណ ជាបុគ្គលមិនធ្វេសប្រហែសជានិច្ច អស់យប់នឹងថ្ងៃ ផ្សាយនូវមេត្តាចិត្ត មិនមានប្រមាណ ក្នុងទិសទាំងពួង ។

កោ សុជ្ឈតី មុច្ចតិ ពជ្ឈតី ច

កេនត្តនា(១) គច្ឆតិ ព្រហ្មលោកំ

អជានតោ មេ មុនិ ព្រូហិ បុដ្ឋោ

ភគវា ហិ មេ សក្ខិ ព្រហ្មជ្ជ ទិដ្ឋោ

ត្វញ្ហិ នោ ព្រហ្មសមោសិ(២) សច្ចំ

កថំ ឧបបជ្ជតិ ព្រហ្មលោកំ (ជុតិម) ។

យោ យជតិ តិវិធំ យញ្ញសម្បទំ

(មាឃាតិ ភគវា)

អារាធយេ ទក្ខិណេយ្យេហិ តាទិ

ឯវំ យជិត្វា សម្មា យាចយោគោ

ឧបបជ្ជតិ ព្រហ្មលោកន្តិ ព្រូមីតិ ។

---

១ ម. កេនត្តា ។ ២ ឱ ព្រហ្មសមោតិ ។

(មាឃមាណព ក្រាបទូលថា) បុគ្គលដូចម្តេចបរិសុទ្ធ បុគ្គលដូចម្តេចរួច បុគ្គលដូចម្តេចជាប់នៅ បុគ្គលទៅកាន់ព្រហ្មលោកបាន ដោយហេតុដូចម្តេច បពិត្រព្រះអង្គ ជាអ្នកប្រាជ្ញ កាលបើខ្ញុំព្រះអង្គ ជាអ្នកមិនដឹង ក្រាបទូលសួរហើយ សូមព្រះអង្គទ្រង់សំដែង បពិត្រព្រះអង្គ ជាព្រហ្ម ដ្បិតក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គ បានឃើញព្រះអង្គ ជាបន្ទាល់ហើយ ព្រោះព្រះអង្គពិតជាស្មើគ្នានឹងព្រហ្ម របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គ ទ្រង់មានសេចក្តីរុងរឿង បុគ្គលទៅកាន់ព្រហ្មលោកបាន ដោយប្រការដូចម្តេច ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលមាឃៈ) តថាគតពោលថា បុគ្គលណា បូជានូវយញ្ញសម្បទា ៣ ប្រការ បុគ្គលបែបនោះ ញុំាងពួកទក្ខិណេយ្យបុគ្គល ឲ្យត្រេកអរបាន លុះបូជាយ៉ាងនេះហើយ ជាអ្នកគួរគេសូមបាន ដោយប្រពៃ រមែងចូលទៅកាន់ព្រហ្មលោក ។

(៥០) ឯវំ វុត្តេ មាឃោ មាណវោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម ។បេ។ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

មាឃសុត្តំ បញ្ចមំ ។

## ឆដ្ឋំ សភិយសុត្តំ

(៥១) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន សភិយស្ស បរិព្វាជកស្ស បុរាណសាលោហិតាយ ទេវតាយ បញ្ហា ឧទ្ទិដ្ឋា ហោន្តិ យោ តេ សភិយ សមណោ វា ព្រាហ្មណោ វា ឥមេ បញ្ហេ បុដ្ឋោ ព្យាករោតិ តស្ស សន្តិកេ ព្រហ្មចរិយំ ចរេយ្យាសីតិ ។ អថ ខោ សភិយោ បរិព្វាជកោ តស្សា ទេវតាយ សន្តិកេ បញ្ហេ ឧគ្គហេត្វា

(៩០) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មារមានបាប ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ពេកណាស់ ។ បេ ។ ថាជាអ្នកដល់នូវព្រះគោតមដ៏ចំរើន ជាសរណៈ ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

ចប់ មាឃសូត្រ ទី ៥ ។

# សភិយសូត្រទី ៦

(៩១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ទេវតាជាសាលោហិតពីដើម របស់បរិព្វាជកឈ្មោះសភិយៈ បានសំដែងឡើងនូវប្រស្នាទាំងឡាយថា ម្នាលសភិយៈ សមណៈឬព្រាហ្មណ៍ណា ដែលអ្នកសួរប្រស្នាទាំងនេះ ហើយឆ្លើយរួច អ្នកត្រូវប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់នៃសមណៈឬព្រាហ្មណ៍នោះចុះ ។ គ្រានោះ សភិយបរិព្វាជក រៀនប្រស្នាទាំងឡាយ ក្នុងសំណាក់ទេវតានោះ

យេ តេ សមណព្រាហ្មណា សង្ឃិនោ គណិនោ គណា-
ចរិយា ញាតា យសស្សិនោ តិត្ថករា សាធុសម្មតា
ពហុជនស្ស សេយ្យថីទំ បូរណោ កស្សបោ
មក្ខលិ គោសាលោ អជិតោ កេសកម្ពលោ បកុធោ
កច្ចាយនោ សញ្ជយោ វេឡដ្ឋបុត្តោ និគណ្ឋោ
នាដបុត្តោ តេ ឧបសង្កមិត្វា តេ បញ្ហេ
បុច្ឆតិ ។ តេ សភិយេន បរិព្វាជកេន បញ្ហេ
បុដ្ឋា ន សម្បាយន្តិ អសម្បាយន្តា កោបញ្ច
ទោសញ្ច អប្បច្ចយញ្ច បាតុករោន្តិ អបិ ច ស-
ភិយំ បរិព្វាជកំ បដិបុច្ឆន្តិ ។ អថខោ សភិយស្ស
បរិព្វាជកស្ស ឯតទហោសិ យេ ខោ តេ ភោន្តោ
សមណព្រាហ្មណា សង្ឃិនោ គណិនោ គណាចរិយា
ញាតា យសស្សិនោ តិត្ថករា សាធុសម្មតា ពហុជ-
នស្ស សេយ្យថីទំ បូរណោ កស្សបោ ។ បេ ។ និគណ្ឋោ
នាដបុត្តោ តេ មយា បញ្ហេ បុដ្ឋា ន សម្បាយន្តិ

ទើបចូលទៅរកពួកសមណព្រាហ្មណ៍ ជាអ្នកមានពួក មានក្រុម (ប្ដេជ្ញាខ្លួនថាជាសព្វញ្ញូសាស្ដា ) ជាគណាចារ្យ (១) ដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស (២) ធ្វើនូវកំពង់គឺទិដ្ឋិ ដែលជនច្រើនគ្នា សន្មតថាជាសប្បុរស គឺគ្រូឈ្មោះបូរណកស្សប ឈ្មោះមក្ខលិគោសាល ឈ្មោះអជិតកេសកម្ពល ឈ្មោះបកុទ្ធកច្ចាយនៈ ឈ្មោះសញ្ជយវេលដ្ឋបុត្ត ឈ្មោះនិគន្ថនាដបុត្ត ហើយសួរប្រស្នាទាំងនោះ ៗ គ្រូទាំងនោះ លុះត្រូវសភិយបរិព្វាជក សួរប្រស្នាទាំងឡាយ ក៏ឆ្លើយមិនរួច កាលបើឆ្លើយមិនរួចក៏ធ្វើនូវសេចក្ដីក្រោធ ប្រទូស្ដ អាក់អន់ចិត្ត ឲ្យប្រាកដឡើង រួចក៏សួរត្រឡប់ទៅរកសភិយបរិព្វាជកវិញ ។ គ្រានោះ សភិយបរិព្វាជក មានសេចក្ដីត្រិះរិះយ៉ាងនេះថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនណា ជាអ្នកមានពួក មានក្រុម ជាគណាចារ្យ ដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស ធ្វើនូវកំពង់គឺទិដ្ឋិ ដែលជនច្រើនគ្នាសន្មតថាជាសប្បុរស គឺគ្រូឈ្មោះបូរណកស្សប ។ បេ ។ ឈ្មោះនិគន្ថនាដបុត្ត សមណព្រាហ្មណ៍ទាំងនោះ លុះត្រូវអញសួរប្រស្នាទាំងឡាយហើយ ក៏ឆ្លើយមិនរួច

---

១ ជាអាចារ្យនៃពួកបរិព្វាជកនឹងគ្រហស្ថៈដោយអំណាចនៃឧទ្ទេសនឹងបរិបុច្ឆា ។

២ បរិបូណ៌ដោយលាភនឹងបរិវារ ។ អដ្ឋកថា ។

អសម្បាយន្តា កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុ-
ករោន្តិ អបិ ច មញ្ញេវេត្ថ បដិបុច្ឆន្តិ យន្នូនាហំ
ហីនាយាវត្តិត្វា កាមេ បរិភុញ្ជេយ្យន្តិ ។ អថខោ
សភិយស្ស បរិព្វាជកស្ស ឯតទហោសិ អយំ ខោ[១]
សមណោ គោតមោ សង្ឃី ចេវ គណី ច គណាចរិយា
ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុ-
ជនស្ស យន្នូនាហំ សមណំ គោតមំ ឧបសង្កមិត្វា
ឥមេ បញ្ហេ បុច្ឆេយ្យន្តិ ។ អថ ខោ សភិយស្ស
បរិព្វាជកស្ស ឯតទហោសិ យេ[២] ខោ តេ
ភោន្តោ សមណព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា
អទ្ធគតា វយោអនុប្បត្តា ថេរា រត្តញ្ញូ ចិរបព្វជិតា
សង្ឃិនោ គណិនោ គណាចរិយា ញាតា យសស្សិនោ
តិត្ថករា សាធុសម្មតា ពហុជនស្ស សេយ្យថីទំ
បូរណោ កស្សបោ ។ បេ ។ និគណ្ឋោ នាដបុត្តោ
តេបិ មយា បញ្ហេ បុដ្ឋា ន សម្បាយន្តិ

---

១ ឱ. អយំ បិ ។ ម. អយំបិខោ ។ ២ ម. យំខោ ។

កាលបើឆ្លើយមិនរួច ក៏ធ្វើនូវសេចក្តីក្រោធ ប្រទូស្ត អាក់អន់ចិត្ត ឲ្យប្រាកដឡើង រួចក៏សួរត្រឡប់មករកអញ ក្នុងប្រស្នាទាំងនុ៎ះវិញ បើដូច្នោះគួរតែអាត្មាអញ ត្រឡប់មកកាន់ភេទថោកទាប គឺភេទគ្រហស្ថ បរិភោគកាមវិញចុះ ។ លំដាប់នោះ សភិយបរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតមនេះឯង ក៏ជាអ្នកមានពួក មានក្រុមជាគណាចារ្យ ដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស ធ្វើនូវកំពង់គឺទិដ្ឋិ ដែលជនច្រើនគ្នា សន្មតថាជាសប្បុរសដែរ បើដូច្នោះគួរតែអាត្មាអញ ចូលទៅរកព្រះសមណគោតម ហើយសួរប្រស្នាទាំងនេះ ។ លំដាប់នោះ សភិយបរិព្វាជក មានសេចក្តីត្រិះរិះយ៉ាងនេះទៀតថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនណា ដែលចាស់គ្រាំគ្រាជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ជាអ្នកខ្ជាប់ខ្ជួន (ក្នុងសមណធម៌) ស្គាល់រាត្រីច្រើន បួសយូរយារហើយ ជាអ្នកមានពួក មានក្រុមជាគណាចារ្យ ដែលអ្នកផងធ្លាប់ស្គាល់ ជាអ្នកមានយស ធ្វើនូវកំពង់គឺទិដ្ឋិ ដែលជនច្រើនគ្នា សន្មតថាជាសប្បុរស គឺគ្រូឈ្មោះបូរណកស្សប ។ បេ ។ ឈ្មោះនិគន្ថនាដបុត្ត សមណព្រាហ្មណ៍ទាំងនោះសោត លុះត្រូវអញសួរប្រស្នាទាំងឡាយហើយ ក៏ឆ្លើយមិនរួច

អសម្បាយន្តា កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោន្តិ អបិ ច មញ្ញេវេត្ថ បដិបុច្ឆន្តិ ។ កឹ បន មេ សមណោ គោតមោ ឥមេ បញ្ហេ បុដ្ឋោ ព្យាករិស្សតិ ។ សមណោ ហិ គោតមោ ទហរោ ចេវ ជាតិយា នវោ ច បព្វជ្ជាយាតិ ។ អថខោ សភិយស្ស បរិព្វាជកស្ស ឯតទហោសិ សមណោ ខោ គោតមោ ទហរោតិ ន ឧញ្ញាតព្វោ ន បរិភោតព្វោ ទហរោបិ ចេ សមណោ ហោតិ សោ ច មហិទ្ធិកោ ហោតិ មហានុភាវោ(១) ។ យន្នូនាហំ សមណំ គោតមំ ឧបសង្កមិត្វា ឥមេ បញ្ហេ បុច្ឆេយ្យន្តិ ។ អថខោ សភិយោ បរិព្វាជកោ យេន រាជគហំ តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន រាជគហំ វេឡុវនំ កលន្ទកនិវាបោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

---

១ ម. ទហរោបិ ចេ សមណោ គោតមោ មហិទ្ធិកោ ហោតិ មហានុភាវោ ។

កាលបើឆ្លើយមិនរួច ក៏ធ្វើនូវសេចក្ដីក្រោធ ប្រទូស្ដ អាក់អន់ចិត្តឲ្យប្រាកដឡើង រួចក៏សួរត្រឡប់មកអញ នូវប្រស្នាទាំងនុ៎ះវិញ ៗ ចុះព្រះសមណគោតម កាលបើត្រូវអញសួរប្រស្នាទាំងនេះហើយ តើនឹងឆ្លើយយ៉ាងណាទៅអេះ ៗ ព្រោះថា ព្រះសមណគោតម ក្មេងដោយជាតិផង ថ្មីដោយផ្នួសផង ៗ លំដាប់នោះ សភិយបរិញ្វាជក មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតម អញមិនត្រូវមើលងាយ មិនត្រូវពេបជ្រាយថា ក្មេងទេ ទោះបីព្រះអង្គជាសមណៈក្មេងក៏ពិត ប៉ុន្តែព្រះអង្គជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ៗ បើដូច្នោះ គួរតែអញចូលទៅរកព្រះសមណគោតម ហើយសួរប្រស្នាទាំងនេះ ៗ គ្រានោះ សភិយបរិញ្វាជក ក៏ចៀសចេញទៅកាន់ចារិក សំដៅទៅក្រុងរាជគ្រឹះ កាលដើរទៅកាន់ចារិកតាមលំដាប់ ក៏បានចូលទៅរកព្រះមានព្រះភាគឯវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្នុងក្រុងរាជគ្រឹះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរីករាយ ស្មោះសរ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ៗ

ឯកមន្តំ និសិន្នោ ខោ សភិយោ បរិព្វាជកោ
ភគវន្តំ គាថាយ អជ្ឈភាសិ

(៥២) កង្ខី វេចិកិច្ឆី អាគមំ (ឥតិ សភិយោ)
បញ្ហេ បុច្ឆិតុំ អភិកង្ខមានោ
តេសន្តករោ ភវាហិ បញ្ហេ មេ[១] បុដ្ឋោ
អនុបុព្វំ អនុធម្មំ ព្យាករោហិ មេ ។
ទូរតោ អាគតោសិ[២] (សភិយាតិ ភគវា)
បញ្ហេ បុច្ឆិតុំ អភិកង្ខមានោ
តេសន្តករោ ភវាមិ បញ្ហេ តេ[៣] បុដ្ឋោ
អនុបុព្វំ អនុធម្មំ ព្យាករោមិ តេ ។
បុច្ឆ[៤] មំ សភិយ បញ្ហំ យំ កិញ្ចិ មនសិច្ឆសិ
តស្ស តស្សេវ បញ្ហស្ស អហំ អន្តំ ករោមិ តេតិ ។

---

១ ឱ. តេសន្តករោ ភវាហិ មេ បញ្ហេ មេ ។ ម. តេសន្តករោ ភវ ភវាហិ បញ្ហេ មេ ។
២ ម. អាគតោសិធ ។ ៣ ឱ. តេសន្តករោ ភវាមិ តេ បញ្ហេ តេ ។ ម. តេសមន្តករោមិ តេ បញ្ហេ ។ ៤ ម. បុច្ឆសិ ។

សភិយបរិព្វាជក លុះអង្គុយ ក្នុងទីដ៏សមគួរហើយ បានពោលចំពោះព្រះមានព្រះភាគ ដោយគាថា

(៥២) (សភិយបរិព្វាជកពោលថា) ខ្ញុំព្រះអង្គ មានសេចក្តីងឿងឆ្ងល់សង្ស័យ ទើបមក ប៉ុនប៉ងនឹងសួរប្រស្នាទាំងឡាយ (ហេតុនេះ) ព្រះអង្គ កាលបើខ្ញុំព្រះអង្គសួរប្រស្នាទាំងឡាយហើយ សូមធ្វើនូវទីបំផុត នៃប្រស្នាទាំងនោះ សូមព្រះអង្គ សំដែងធម៌តាមសមគួរដល់សេចក្តី ជាលំដាប់លំដោយ ដល់ខ្ញុំព្រះអង្គ ឲ្យបាន ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ) អ្នកមកអំពីចម្ងាយ ប៉ុនប៉ងនឹងសួរប្រស្នាទាំងឡាយ តថាគត កាលបើអ្នកសួរប្រស្នាទាំងឡាយហើយ នឹងធ្វើនូវទីបំផុត នៃប្រស្នាទាំងនោះ តថាគតនឹងដោះស្រាយនូវធម៌ដ៏សមគួរដល់សេចក្តី ជាលំដាប់លំដោយ ដល់អ្នក ។ ម្នាលសភិយៈ អ្នកប៉ងក្នុងចិត្តចំពោះប្រស្នាណាមួយ ចូរសួរប្រស្នានោះ មកតថាគតចុះ តថាគតនឹងធ្វើនូវទីបំផុតនៃប្រស្នានោះ ៗ ដល់អ្នក ។

(៨៣) អថខោ សភិយស្ស បរិព្វាជកស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ យំ វតាហំ អញ្ញេសុ សមណព្រាហ្មណេសុ ឱកា-សកម្មមត្តម្បិ(១) នាលត្ថំ តម្មេ(២) ឥទំ សមណេន គោតមេន ឱកាសកម្មំ កតន្តិ អត្តមនោ បមុទិតោ ឧទគ្គោ បីតិសោមនស្សជាតោ ភគវន្តំ បញ្ហំ អបុច្ឆិ

កឹបត្តិនមាហុ ភិក្ខុនំ (ឥតិ សភិយោ)
សោរតំ កេន កថញ្ច ទន្តមាហុ
ពុទ្ធោតិ កថំ បវុច្ចតិ
បុដ្ឋោ មេ ភគវា ព្យាករោហិ ។
បជ្ជេន កតេន អត្តនា (សភិយាតិ ភគវា)
បរិនិព្វានគតោ វិតិណ្ណកង្ខោ

១ ឱ. ឱកាសមត្តម្បិ ។ ២ ម. តយិទំ ។

(៩៣) គ្រានោះ សភិយបរិព្វាជក គិតយ៉ាងនេះថា យីអើ អស្ចារ្យណាស់ យីអើ ចំឡែកណាស់ អញមិនដែលបាន សូម្បីត្រឹមតែកម្មឱកាស ក្នុងសំណាក់នៃសមណព្រាហ្មណ៍ទាំងឡាយដទៃ ដោយហេតុណា ហេតុនោះ ព្រះសមណគោតម បានធ្វើកម្មឱកាសនោះដល់អញហើយ ។ គាត់ត្រេកអរ រីករាយ មានចិត្តអណ្តែតឡើង កើតបីតិសោមនស្ស ហើយសួរប្រស្នានឹងព្រះមានព្រះភាគ

(សភិយបរិព្វាជកសួរថា) បណ្ឌិតទាំងឡាយ ហៅ
បុគ្គល អ្នកបានគុណវិសេសដូចម្តេច ថាជាភិក្ខុ បណ្ឌិត
ទាំងឡាយ ហៅបុគ្គលអ្នកស្ងប់ស្ងាប់ ដោយធម៌ល្អ
ដោយហេតុដូចម្តេច បុគ្គលដែលមានខ្លួនទូន្មានហើយ
ដោយប្រការដូចម្តេច អ្នកដទៃតែងហៅថា ព្រះពុទ្ធ
តើដោយប្រការដូចម្តេច បពិត្រព្រះមានព្រះភាគ ព្រះ
អង្គ កាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យបាន ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសភិយៈ)
បុគ្គលណា បានដល់នូវការរំលត់ទុក្ខ ដោយមគ្គដែល
ខ្លួនបានចំរើនហើយ ឆ្លងផុតសេចក្តីសង្ស័យហើយ

វិភវញ្ច ភវញ្ច វិប្បហាយ

វុសិតវា ខីណបុនព្ភវោ ស ភិក្ខុ ។

សព្វត្ថ ឧបេក្ខកោ សតិមា

ន សោ ហឹសតិ សព្វលោកេ

តិណ្ណោ សមណោ អនាវិលោ

ឧស្សទា យស្ស ន សន្តិ សោរតោ សោ

យស្សិន្ទ្រិយានិ ភាវិតានិ

អជ្ឈត្តំ ពហិទ្ធា ច សព្វលោកេ

និព្វិជ្ឈិមំ(១) បរញ្ច លោកំ

កាលំ កង្ខតិ ភាវិតោ ស ទន្តោ ។

កប្បានិ វិចេយ្យ កេវលានិ

---

១ ឱ. ម. និព្វិជ្ឈ ឥមំ ។

លះបង់ នូវសេចក្ដីវិនាសនឹងសេចក្ដីចំរើន មានមគ្គប្រព្រឹត្តគ្រប់គ្រាន់ហើយ មានភពថ្មីអស់ហើយ បុគ្គលនោះឈ្មោះថាជាភិក្ខុ ។ បុគ្គលណា ជាអ្នកព្រងើយកន្ដើយ ក្នុងអារម្មណ៍ទាំងពួង មានស្មារតី បុគ្គលនោះមិនបៀតបៀន (សត្វណាមួយ) ក្នុងលោកទាំងពួង ជាអ្នកឆ្លងអន្លង់រួចហើយ ជាអ្នករម្ងាប់បាប មានចិត្តមិនល្អក់ ចំហាយគឺកិលេសមិនមានដល់បុគ្គលណា បុគ្គលនោះឈ្មោះថា អ្នកស្ងប់ស្ងាប់ដោយល្អ បុគ្គលណាបានចំរើន នូវឥន្ទ្រិយទាំងឡាយ ទាំងខាងក្នុងនឹងខាងក្រៅ ក្នុងលោកទាំងអស់ ដឹងច្បាស់នូវលោកនេះនឹងលោកដទៃ ទន្ទឹងតែមរណកាល បុគ្គលនោះមានឥន្ទ្រិយអប់រំហើយ (យ៉ាងនេះ) ឈ្មោះថា មានខ្លួនទូន្មានហើយ ។ បុគ្គលណាពិចារណានូវកប្បៈ(១) ទាំងអស់

១ តណ្ហានិងទិដ្ឋិ ហៅថា កប្បៈ ព្រោះសម្រេចដូច្នោះ ៗ បាន ។ អដ្ឋកថា ។

សំសារំ ទុភយំ(១) ចុតូបបាតំ

វិគតរជមនង្គណំ វិសុទ្ធំ

បត្តំ ជាតិក្ខយំ តមាហុ ភិក្ខុន្តិ ។

(៥៤) អថខោ សភិយោ បរិព្វាជកោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អត្តមនោ បមុទិតោ ឧទគ្គោ បីតិសោមនស្សជាតោ ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ

កឹបត្តិនមាហុ ព្រាហ្មណំ (ឥតិ សភិយោ)

សមណំ កេន កថញ្ច ន្ហាតកោ

នាគោតិ កថំ បវុច្ចតិ

បុដ្ឋោ មេ ភគវា ព្យាករោហិ ។

---

១ ម. សំសារ ឥទុភយំ ។

នឹងសង្ខារ (១) ចុតិ និងបដិសន្ធិ ទាំងពីរ បណ្ឌិត
ទាំងឡាយហៅបុគ្គល ដែលមានធូលីគឺកិលេសទៅ
ប្រាសហើយ អ្នកមិនមានទីទួលគឺកិលេស ស្អាត
ដោយវិសេស ដល់នូវព្រះនិព្វាន ជាគ្រឿងក្សយនៃ
ជាតិនោះ ថាជាព្រះពុទ្ធ ។

(៥៤) គ្រានោះ សភិយបរិព្វាជក មានចិត្តត្រេកអរខ្ពស់ឡើង កើតបីតិសោមនស្ស ត្រេកអរ រីករាយ ចំពោះភាសិតព្រះមានព្រះភាគ ហើយសួរប្រស្នានឹងព្រះមានព្រះភាគ តទៅ

(សភិយបរិព្វាជក សួរថា) បណ្ឌិតទាំងឡាយ
ហៅបុគ្គល អ្នកបានគុណវិសេសដូចម្តេច ថាជា
ព្រាហ្មណ៍ ថាជាសមណៈ ដោយហេតុដូចម្តេច អ្នក
ផងតែងហៅថាជាអ្នកងូតលាង (កិលេស) ដោយ
ប្រការដូចម្តេច ហៅថានាគ តើដោយប្រការដូចម្តេច
បពិត្រព្រះមានព្រះភាគ ព្រះអង្គ កាលបើខ្ញុំព្រះ
អង្គសួរហើយ សូមឆ្លើយ ឲ្យបាន ។

---

២ លំដាប់ខន្ធ ធាតុ អាយតនៈ ។ ន័យមួយទៀតថា ពិចារណាកប្ប គឺសំវដ្តកប្ប វិវដ្តកប្ប នេះជាបុព្វេនិវាសានុស្សតិញ្ញាណ សំសារ គឺចុតិបដិសន្ធិសត្វ នេះជាចុតូបបាតញ្ញាណ អស់ធូលីគឺទីទួល អស់ជាតិ នេះជាអាសវក្ខយញ្ញាណ ។

បាហេត្វា សព្វបាបកានិ (សភិយាតិ ភគវា)
វិមលោ សាធុសមាហិតោ ឋិតត្តោ
សំសារមតិច្ច កេវលី សោ
អនិស្សិតោ[១] តាទិ បវុច្ចតេ ស ព្រហ្មា ។
សមិតាវិ បហាយ បុញ្ញបាបំ
វិរជោ ញត្វា ឥមំ បរញ្ច លោកំ
ជាតិមរណំ ឧបាតិវត្តោ
សមណោ តាទិ បវុច្ចតេ តថត្តា ។
និន្ហាយ សព្វបាបកានិ
អជ្ឈត្តញ្ច ពហិទ្ធា ច សព្វលោកេ
ទេវមនុស្សេសុ កប្បិយេសុ
កប្បំ នេតិ តមាហុ ន្ហាតកោ ។

---
១ ឱ. ម. អសិតោ ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាល សភិយៈ) បុគ្គលណា បន្សាត់បង់នូវបាបទាំងពួង ប្រាសចាកមន្ទិល មានចិត្តតាំងនៅល្អ មានចិត្តខ្ជាប់ខ្ជួន កន្លងផុតនូវសង្សារ មានកិច្ចសម្រេចហើយ បុគ្គលនោះ ជាអ្នកមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) ជាអ្នកនឹងធឹង បុគ្គលនោះ តថាគតហៅថា ព្រាហ្មណ៍ ។ បុគ្គលណា រម្ងាប់(កិលេសដោយអរិយមគ្គ) លះបុណ្យនិងបាប ប្រាសចាកធូលីគឺកិលេស ដឹងច្បាស់នូវលោកនេះនិងលោកខាងមុខ ប្រព្រឹត្តកន្លងនូវជាតិនិងមរណៈ បុគ្គលនោះជាអ្នកនឹងធឹងមានសភាពដូច្នោះ តថាគតហៅថា សមណៈ ។ បុគ្គលណា លាងបាបទាំងពួង ទាំងខាងក្នុងនិងខាងក្រៅ ក្នុងលោកទាំងមូល មិនដល់នូវកប្បៈគឺតណ្ហានិងទិដ្ឋិ ក្នុងពួកទេវតានិងមនុស្ស ដែលគួរដល់កប្បៈ បណ្ឌិតទាំងឡាយ ហៅបុគ្គលនោះ ថាជាអ្នកជូតលាងនូវកិលេស ។

អាគុំ ន ករោតិ កិញ្ចិ លោកេ
សព្វសំយោគេ វិសជ្ជ ពន្ធនានិ
សព្វត្ថ ន សជ្ជតី វិប្បមុត្តោ(១)
នាគោ តាទិ បវុច្ចតេ តថត្តាតិ ។

(៥៥) អថខោ សភិយោ បរិព្វាជកោ ។ បេ ។
ភគវន្តំ ឧត្តរិំ បញ្ហំ អបុច្ឆិ

កំ ខេត្តជិនំ វទន្តិ ពុទ្ធា (ឥតិ សភិយោ)
កុសលំ កេន កថំ បណ្ឌិតោតិ
មុនិ នាម កថំ បវុច្ចតិ
បុដ្ឋោ មេ ភគវា ព្យាករោហិ ។
ខេត្តានិ វិចេយ្យ កេវលានិ (សភិយាតិ ភគវា)
ទិព្វំ មានុសកញ្ច ព្រហ្មខេត្តំ

១ ឱ. ម. សជ្ជតិ វិមុត្តោ ។

បុគ្គលណា មិនបានធ្វើបាបណាមួយ ក្នុងលោក លះបង់នូវគ្រឿងប្រកបសត្វទុកទាំងពួង នូវកិលេសជាគ្រឿងចង មិនជាប់ក្នុងគ្រឿងជាប់ទាំងពួង (មានខន្ធជាដើម) ជាអ្នករួចស្រឡះ បុគ្គលជាអ្នកនឹងធឹង មានសភាពដូច្នោះនោះ គេហៅថា នាគ ។

[៥៥] គ្រានោះ សភិយបរិព្វាជក ។ បេ ។ សួរនូវប្រស្នានឹងព្រះមានព្រះភាគ តទៅ

(សភិយបរិព្វាជក សួរថា) ព្រះពុទ្ធទាំងឡាយ ហៅបុគ្គលណា ថាជាអ្នកឈ្នះនូវខេត្ត គឺអាយតនៈ ហៅបុគ្គលអ្នកច្រូតកាត់នូវស្រោមគឺកម្ម ដោយហេតុដូចម្តេច ហៅថា បណ្ឌិត តើដោយហេតុដូចម្តេច ហៅថា មុនិ តើដោយហេតុដូចម្តេច បពិត្រព្រះមានព្រះភាគ ព្រះអង្គ កាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យបាន ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ) បុគ្គលណា ពិចារណានូវខេត្តគឺអាយតនៈទាំងអស់ គឺខេត្តជាទិព្វ ខេត្តជារបស់មនុស្ស ខេត្តជារបស់ព្រហ្ម

(សព្វ) ខេត្តមូលពន្ធនា បមុត្តោ
ខេត្តជិនោ តាទិ បវុច្ចតេ តថត្តា ។
កោសានិ វិចេយ្យ កេវលានិ
ទិព្វំ មានុសកញ្ច ព្រហ្មកោសំ
(សព្វ) កោសមូលពន្ធនា បមុត្តោ
កុសលោ តាទិ បវុច្ចតេ តថត្តា ។
ទុភយានិ វិចេយ្យ បណ្ឌរានិ
អជ្ឈត្តំ ពហិទ្ធា ច សុទ្ធិបញ្ញោ
កណ្ហាសុក្កំ(១) ឧបាតិវត្តោ
បណ្ឌិតោ តាទិ បវុច្ចតេ តថត្តា ។
អសតញ្ច សតញ្ច ញត្វា ធម្មំ
អជ្ឈត្តំ ពហិទ្ធា ច សព្វលោកេ
ទេវមនុស្សេហិ បូជិយោ សោ(១)
សង្គំជាលមតិច្ច សោ មុនីតិ ។

---

១ ឱ. កណ្ហាសុក្កំ ។

រួបស្រឡះ ចាកបំណង (គឺអវិជ្ជានិងតណ្ហាជាដើម) ជាឫសគល់នៃខេត្ត (ទាំងអស់) បុគ្គលនឹងធឹងមានសភាពដូច្នោះនោះ ឈ្មោះថា អ្នកឈ្នះនូវខេត្តគឺអាយតនៈ ព្រោះមានចិត្តទៀងទាត់ ។ បុគ្គលណា ពិចារណា ឃើញនូវស្រោម គឺកម្ម ទាំងអស់ គឺស្រោមជាទិព្វ ជារបស់មនុស្ស នឹងស្រោមជារបស់ព្រហ្ម រួបស្រឡះចាកបំណង (គឺអវិជ្ជានិងតណ្ហាជាដើម) ជាឫសគល់ នៃស្រោមទាំងអស់ បុគ្គលនឹងធឹងមានសភាពដូច្នោះនោះ ឈ្មោះថាជាអ្នកប្រួតកាត់នូវស្រោមគឺកម្ម ។ បុគ្គលណា មានបញ្ញាស្អាត ពិចារណាឃើញ នូវធម្មជាតិស្អាត គឺអាយតនៈ ទាំងពីរ ទាំងខាងក្នុងខាងក្រៅ កន្លងនូវធម៌ខ្មៅ នឹងធម៌ស គឺបាបនឹងបុណ្យ បុគ្គលនឹងធឹងមានសភាពដូច្នោះនោះ ឈ្មោះថាជាបណ្ឌិត ។ បុគ្គលណា ដឹងច្បាស់ធម៌របស់ពួកអសប្បុរសនឹងសប្បុរស ក្នុងលោកទាំងមូល ទាំងខាងក្នុង ទាំងខាងក្រៅ កន្លងបង់នូវគ្រឿងជាប់ជំពាក់ដោយបណ្ដាញ បុគ្គលនោះ គួរទេវតានឹងមនុស្សបូជា បុគ្គលនោះឈ្មោះថា មុនី ។

(៥៦) អថខោ សភិយោ បរិព្វាជកោ ។ បេ ។

ភគវន្តំ ឧត្តរិំ បញ្ហំ អបុច្ឆិ

កិំបត្តិនមាហុ វេទគុំ (ឥតិ សភិយោ)

អនុវិទិតំ កេន កថញ្ច វីរិយវាតិ

អាជានិយោ កិន្តិ នាម ហោតិ

បុដ្ឋោ មេ ភគវា ព្យាករោហិ ។

វេទានិ វិចេយ្យ កេវលានិ (សភិយាតិ ភគវា)

សមណានំ យានិធត្ថិ ព្រាហ្មណានំ

សព្វវេទនាសុ វីតរាគោ

សព្វំ វេទមតិច្ច វេទគូ សោ ។

អនុវិច្ច បបញ្ចនាមរូបំ

អជ្ឈត្តំ ពហិទ្ធា ច រោគមូលំ

---

១ ម. ព្រូហិតោ ហោ ។

(៥៦) គ្រានោះ សភិយបរិព្វាជក ។បេ។ បានសួរប្រស្នា នឹងព្រះមានព្រះភាគ តទៅ

(សភិយបរិព្វាជកសួរថា) បណ្ឌិតទាំងឡាយហៅ បុគ្គល អ្នកបានគុណវិសេសដូចម្តេច ថាជាអ្នក ដល់នូវវេទ ហៅថា អ្នកត្រាស់ដឹងតាម តើដោយ ហេតុដូចម្តេច ហៅថា អ្នកមានព្យាយាម តើដោយ ប្រការដូចម្តេច ហៅថា អាជានេយ្យ តើព្រោះហេតុ ដូចម្តេច បពិត្រព្រះមានព្រះភាគ ព្រះអង្គ កាលបើ ខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយ ឲ្យទាន ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសភិយៈ) បុគ្គលណា ពិចារណាឃើញនូវវេទទាំងអស់ ដែល ជាវេទរបស់ពួកសមណព្រាហ្មណ៍ ប្រាសចាកតម្រេក ក្នុងវេទនាទាំងពួង កន្លងបង់នូវវេទទាំងអស់ បុគ្គល នោះឈ្មោះថា ដល់នូវវេទ ។

បុគ្គលណា ពិចារណារឿយៗ នូវបបញ្ចធម៌នឹង នាមរូប ជាឫសគល់នៃរោគ ទាំងខាងក្នុង ទាំងខាងក្រៅ

(សព្វ) រោគមូលពន្ធនា បមុត្តោ

អនុវិទិតោ តាទិ បវុច្ចតេ តថត្តា ។

វិរតោ(១) សព្វបាបកេហិ

និរយទុក្ខមតិច្ច វីរិយវា សោ

សោ វីរិយវា បធានវា

ធីរោ តាទិ បវុច្ចតេ តថត្តា ។

យស្សស្សុ លូតានិ(២) ពន្ធនានិ

អជ្ឈត្តំ ពហិទ្ធា ច សង្គមូលំ

សព្វសង្គមូលពន្ធនា បមុត្តោ

អាជានិយោ តាទិ បវុច្ចតេ តថត្តា(៣) ។

(៤៧) អថខោ សភិយោ បរិព្វាជកោ ។ បេ ។

ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ

---

១ ឱ. ម. វិរតោ ឥធ ។ ២ ឱ. លុតានិ ។ ៣ ឱ. ម. តថត្តាតិ ។

រួចស្រឡះចាកចំណង គឺអវិជ្ជានិងតណ្ហាជាដើម ជាឫសគល់នៃភពទាំងអស់ បុគ្គលអ្នកនឹងធឹងមានសភាពដូច្នោះនោះ ហៅថា អ្នកត្រាស់ដឹងតាម ។

បុគ្គលណា វៀរចាកបាបទាំងពួង កន្លងបង់និរយទុក្ខ បុគ្គលនោះ ឈ្មោះថា អ្នកមានព្យាយាម បុគ្គលអ្នកមានព្យាយាមមាំ ជាធីរជន (អាចកំចាត់បង់កិលេសជាដើម) ជាអ្នកនឹងធឹងមានសភាពដូច្នោះនោះ ហៅថា អ្នកមានព្យាយាម ។

បុគ្គលណា ប្រូតកាត់នូវចំណង (គឺសំយោជនៈ) នឹងឫសគល់នៃគ្រឿងជាប់ចំពាក់ ទាំងខាងក្នុង ទាំងខាងក្រៅ ជាអ្នករួចស្រឡះចាកឫសគល់ នៃគ្រឿងជាប់ចំពាក់ គឺចំណង (គឺសំយោជនៈ) ទាំងអស់ បុគ្គលអ្នកនឹងធឹងមានសភាពដូច្នោះនោះ ហៅថា អាជានេយ្យបុរស ។

(៩៧) គ្រានោះ សភិយបរិព្វាជក ។ បេ ។ បានសួរប្រស្នានឹងព្រះមានព្រះភាគ តទៅ

កឹ បត្តិនមាហុ សោត្តិយំ(១) (ឥតិ សភិយោ)

អរិយំ កេន កថញ្ច ចរណវាតិ

បរិព្វាជកោ កិន្តិ នាម ហោតិ

បុដ្ឋោ មេ ភគវា ព្យាករោហិ ។

សុត្វាន(២) សព្វធម្មំ អភិញ្ញាយ លោកេ (សភិយាតិ ភគវា)

សាវជ្ជានវជ្ជំ យទត្ថិ កិញ្ចិ

អភិភុំ អកថង្កថឹ វិមុត្តំ(៣)

អនីឃំ សព្វធិមាហុ សោត្តិយោតិ ។

ឆេត្វា អាលយានិ អាសវានិ

វិទ្វា សោ ន ឧបេតិ គព្ភសេយ្យំ

សញ្ញំ តិវិធំ បនុជ្ជ បង្កំ

---

១ ម. សោត្ថិយំ ។ ២ ខ. ម. សុត្វា ។ ៣ ម. អកថំ កថីវិមុត្តំ ។

(សភិយបរិព្វាជក សួរថា) បណ្ឌិតទាំងឡាយ ហៅបុគ្គល អ្នកបាននូវគុណវិសេសដូចម្តេច ថាជា សោត្ថិយបុគ្គល ហៅថាអរិយៈ ដោយហេតុដូចម្តេច ហៅថា អ្នកមានចរណៈ ដោយប្រការដូចម្តេច ហៅថា បរិព្វាជក ព្រោះហេតុដូចម្តេច បពិត្រព្រះមានព្រះភាគ ព្រះអង្គ កាលបើខ្ញុំព្រះអង្គសួរហើយ សូមឆ្លើយឲ្យទានៗ

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសភិយៈ) បុគ្គលណា បានស្តាប់ ហើយដឹងច្បាស់នូវធម៌ទាំងពួង នូវអំពើមានទោសនិងមិនមានទោស ណាមួយក្នុងលោក បណ្ឌិតទាំងឡាយហៅបុគ្គលអ្នកគ្របសង្កត់ (ធម៌ជាទីតាំងនៃកិលេស) មិនមានសេចក្តីងឿងឆ្ងល់ រួចស្រឡះ (ចាកចំណងគឺកិលេស) មិនមានសេចក្តីបង្អៀតបង្អល់ ក្នុងធម៌ទាំងពួងនោះថា ជាសោត្ថិយបុគ្គល ។

បុគ្គលណា កាត់បង់នូវអាល័យ និងអាសវៈ ជាអ្នកប្រាជ្ញ បុគ្គលនោះ មិនចូលទៅកាន់ដំណេកក្នុងគភ៌ បុគ្គលណា បន្ទោបង់នូវសញ្ញា ៣ ប្រការ(១) និងភក់ (គឺកាម)

១ កាមសញ្ញា ១ អាហារសញ្ញា ១ ជីវិតសញ្ញា ១ ។ អដ្ឋកថា ។

កប្បំ នេតិ តមាហុ អរិយោតិ ។

យោ ឥធ ចរណេសុ បត្តិបត្តោ
កុសលោ សព្វទា អជានិ ធម្មំ
សព្វត្ថ ន សជ្ជតិ វិមុត្តចិត្តោ(១)
បដិឃា យស្ស ន សន្តិ ចរណវា សោ ។

ទុក្ខវេបក្កំ យទត្ថិ កម្មំ
ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ
បរិវជ្ជយិត្វា(២) បរិញ្ញចារី
មាយំ មានមថោបិ លោភកោធំ
បរិយន្តមកាសិ នាមរូបំ
តំ បរិព្វាជកមាហុ បត្តិបត្តន្តិ ។

---

១ ឱ. វិមុត្តោ ។ ២ ឱ. បរិវជ្ជយិតា ។

មិនដល់នូវកប្បៈ គឺតណ្ហាទិដ្ឋិ បណ្ឌិតទាំងឡាយ ហៅបុគ្គលនោះថា អរិយៈ ។

បុគ្គលណា ក្នុងសាសនានេះ បានដល់នូវអរហត្តដែលគេគប្បីដល់ ព្រោះចរណធម៌ទាំងឡាយ បុគ្គលនោះ ជាអ្នកឈ្លាសវៃ បានដឹងធម៌គ្រប់កាលទាំងពួង មិនជាប់នៅ ក្នុងធម៌ទាំងពួង មានចិត្តរួចស្រឡះហើយ បុគ្គលណា មិនមានសេចក្ដីថ្នាំងថ្នាក់ចិត្ត បុគ្គលនោះឈ្មោះថា មានចរណធម៌ ។

បុគ្គលណា កំចាត់បង់នូវកម្មដែលឲ្យផលជាទុក្ខ ទាំងអតីត ទាំងអនាគត ទាំងបច្ចុប្បន្ន ទាំងកម្មជាចន្លោះកណ្ដាលនៃកាល ជាអ្នកប្រព្រឹត្ត ដោយប្រាជ្ញាមួយទៀត គេបាន (លះបង់) មាយា មានះ លោភៈ ក្រោធៈ ទឹងធ្វើនាមរូបឲ្យមានទីបំផុត បណ្ឌិតទាំងឡាយ ហៅបុគ្គលអ្នកដល់នូវគុណសម្បត្តិដែលគេគប្បីដល់នោះថាជា បរិព្វាជក ។

(៤៨) អថខោ សភិយោ បរិព្វាជកោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា អត្តមនោ ឧទគ្គោ បមុទិតោ បីតិសោមនស្សជាតោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវិ

យានិ ច តីណិ យានិ ច សដ្ឋិ
សមណប្បវាទនិស្សិតានិ(១) ភូរិបញ្ញ
សញ្ញក្ខរសញ្ញនិស្សិតានិ(២)
ឱសរណានិ វិនេយ្យ ឱឃតមគា ។
អន្តគូសិ បារគូសិ ទុក្ខស្ស

១ ម. សមណប្បវាទសិតានិ ។ ២ ម. បញ្ញក្ខរសញ្ញនិស្សិតានិ ។

(៥៨) គ្រានោះ សភិយបរិព្វាជក ត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ជាអ្នកមានចិត្តត្រេកអរ មានចិត្តអណ្ដែតឡើង រីករាយ កើតបីតិនិងសោមនស្ស ហើយក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ សរសើរព្រះមានព្រះភាគ ចំពោះព្រះភក្ត្រ ដោយគាថាទាំងឡាយដ៏សមគួរថា

បពិត្រព្រះអង្គ ជាបុគ្គលមានប្រាជ្ញា ស្មើដោយផែនដី ទិដ្ឋិទាំងឡាយ ៣ ណា និង ទិដ្ឋិទាំងឡាយ ៦០ ណា ដែលអាស្រ័យ នៅដោយពាក្យសាស្ត្រ របស់សមណៈ (ជាអន្យតិរ្ថិយ) អាស្រ័យនៅនឹងពាក្យ (ជាស្ត្រី-បុរស) នឹងសញ្ញា (ខុសរបស់មនុស្សពាល ) ជាកំពង់ជាទីចុះរបស់សត្វ ព្រះមានព្រះភាគ បានកំចាត់ចោល ( នូវទិដ្ឋិទាំងនោះ ) បាន កន្លងផុតនូវងងឹតគឺ ឱឃៈ ។ ព្រះអង្គជាអ្នកដល់នូវទីបំផុត ជាអ្នកដល់នូវត្រើយនៃទុក្ខ គឺព្រះនិព្វាន

អរហាសិ (សម្មាសម្ពុទ្ធោ) ខីណាសវំ តំ មញ្ញេ

ជុតិមា មុតិមា បហូតបញ្ញោ

ទុក្ខស្សន្តករំ អតារេសិ មំ ។

យំ មេ កង្ខិតមញ្ញាសិ វិចិកិច្ឆំ មំ អតារយិ[1]

នមោ តេ (មុនិ) មោនបថេសុ បត្តិបត្ត

អខិលាទិច្ចពន្ធុ សោរតោសិ ។

យា មេ កង្ខា បុរេ អាសិ តម្មេ ព្យាកាសិ ចក្ខុមា

អទ្ធា មុនីសិ សម្ពុទ្ធោ នត្ថិ នីវរណា តវ ។

ឧបាយាសា ច តេ សព្វេ វិទ្ធស្តា[2] វិនឡីកតា

---

១ ឱ. វិចិកិច្ឆំ មំ អតារេសិ ។ ម. វិចិកិច្ឆា តារេសិ ។ ២ ម. វិធស្តា ។

ព្រះអង្គជាអរហន្ត (សម្មាសម្ពុទ្ធ) ខ្ញុំព្រះអង្គសំគាល់ព្រះអង្គថាជាព្រះខីណាស្រព ព្រះអង្គមានសេចក្ដីរុងរឿង មានយោបល់ មានប្រាជ្ញាច្រើន ធ្វើនូវទីបំផុតនៃទុក្ខ បានចំឡងខ្ញុំព្រះអង្គ (ចាកសេចក្ដីសង្ស័យ) ។

ព្រះអង្គជ្រាប នូវសេចក្ដីសង្ស័យណា ដែលខ្ញុំព្រះអង្គសង្ស័យហើយ បានចំឡងខ្ញុំព្រះអង្គឲ្យរួចចាកសង្ស័យ (នោះ) (បពិត្រព្រះអង្គជាអ្នកប្រាជ្ញ) ខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ ជាអ្នកដល់នូវគុណសម្បត្តិ ដែលគួរដល់ ដោយគន្លងនៃអ្នកប្រាជ្ញទាំងឡាយ ព្រះអង្គជាអាទិច្ចពង្ស មិនរឹងត្អឹង ជាអ្នកស្ងួតបូត ។ សេចក្ដីសង្ស័យណា របស់ខ្ញុំមានមកក្នុងកាលមុន ព្រះអង្គជាអ្នកមានចក្ខុ បានដោះស្រាយហើយ នូវសេចក្ដីសង្ស័យ របស់ខ្ញុំព្រះអង្គនោះ ព្រះអង្គជាអ្នកប្រាជ្ញ ត្រាស់ដឹងហើយ ដោយពិត ព្រះអង្គមិនមាននីវរណៈទាំងឡាយឡើយ ។

សេចក្ដីចង្អៀតចង្អល់ ទាំងអស់ ដែលព្រះអង្គកំចាត់បង់ហើយ បានធ្វើឲ្យត្រជាក់ស្រឡះហើយ

សីតិភូតោ ទមប្បត្តោ ធិតិមា សច្ចនិក្កមោ ។
តស្ស តេ នាគនាគស្ស មហាវីរស្ស ភាសតោ
សព្វេ ទេវា អនុមោទន្តិ ឧភោ នារទបព្វតា ។
នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ ។
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារភិភូ(១) មុនិ
តុវំ អនុសយេ ឆេត្វា តិណ្ណោ តារេសិមំ បជំ ។
ឧបធី តេ សមតិក្កន្តា អាសវា តេ បទាលិតា
សីហោសិ អនុបាទានោ បហីនភយភេរវោ ។

---

១ ម. មាយាភិភូ ។

ព្រះអង្គ ជាបុគ្គលត្រជាក់ ដល់នូវការទូន្មានឥន្ទ្រិយ មានប្រាជ្ញា មានព្យាយាមដោយទៀងទាត់ ។

កាលព្រះអង្គជាមហាវីរបុរសដ៏ប្រសើរក្រៃលែង នោះកំពុងសំដែង ពួកទេវតាទាំងពួង រមែងអនុមោទនា ទាំងទេវតាពីរពួក គឺនារទៈនិងបព្វតៈក៏អនុមោទនា ។

បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំព្រះអង្គសូមនមស្ការព្រះអង្គ ព្រះអង្គមិនមានបុគ្គលប្រៀបផ្ទឹមក្នុងលោកព្រមទាំងទេវលោក ។

ព្រះអង្គជាអ្នកត្រាស់ដឹង ព្រះអង្គជាសាស្តា ព្រះអង្គជាអ្នកប្រាជ្ញ គ្របសង្កត់នូវមារ (ទាំងបួន) ព្រះអង្គកាត់បង់នូវអនុសយកិលេស ឆ្លងបានហើយ ទើបបំឆ្លងពួកសត្វទាំងនេះ ។

ព្រះអង្គបានកន្លងឧបធិហើយ ព្រះអង្គបានទំលាយអាសវៈហើយ ព្រះអង្គជាបុគ្គលដូចសីហៈ មិនមានឧបាទាន បានលះភ័យនិងសេចក្តីស្ញប់ស្ញែងហើយ ។

បុណ្ឌរីកំ យថា វគ្គុ តោយេ ន[1] ឧបលិម្បតិ
ឯវំ បុញ្ញេ ច បាបេ ច ឧភយេ ត្វំ ន លិម្បសិ
បាទេ វីរ បសារេហិ សភិយោ វន្ទតិ សត្ថុនោតិ ។

(៥៩) អថខោ សភិយោ បរិព្វាជកោ ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ យោ ខោ សភិយ អញ្ញតិត្ថិយបុព្វោ ឥមស្មឹ ធម្មវិនយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ

---

១ ម. តោយេន ។

ផ្កាឈូកសដ៏ល្អ មិនជាប់ក្នុងទឹក យ៉ាងណាមិញ ព្រះអង្គមិនជាប់ក្នុងអំពើទាំងពីរ គឺបុណ្យនិងបាប ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គជាវីរបុរស សូមព្រះអង្គសណ្ដូកព្រះបាទ សភិយបរិព្វាជកថ្វាយបង្គំ (ព្រះបាទ) ព្រះសាស្ដា ។

(៤៩) គ្រានោះ សភិយបរិព្វាជក ឱនសិរ្សៈទៀបព្រះបាទទាំងគូរ របស់ព្រះមានព្រះភាគហើយ សរសើរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចំរើន ច្បាស់ណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះមានព្រះភាគសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ក៏ច្បាស់ណាស់) ដូចជាគេផ្ងាររបស់ដែលផ្កាប់ចុះ ពុំនោះដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះសោតដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាគេទ្រោលប្រទីបប្រេង បំភ្លឺក្នុងទីងងឹត ឲ្យមនុស្សមានចក្ខុ មើលឃើញនូវរូបទាំងឡាយបាន ខ្ញុំព្រះអង្គនុ៎ះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។ ម្នាលសភិយៈ អ្នកណាធ្លាប់ជាអន្យតិត្ថិយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះ

សោ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ
អច្ចយេន បរិវុដ្ឋបរិវាសំ អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ
ឧបសម្បាទេន្តិ ភិក្ខុភាវាយ(១) អបិ ចេត្ថ(២) បុគ្គល-
វេមត្តតា វិទិតាតិ ។ សចេ ភន្តេ អញ្ញតិត្ថិយបុព្វា
ឥមស្មឹ ធម្មវិនយេ អាកង្ខន្តា បព្វជ្ជំ អាកង្ខន្តា
ឧបសម្បទំ ចត្តារោ មាសេ បរិវសន្តិ ចតុន្នំ មាសានំ
អច្ចយេន បរិវុដ្ឋបរិវាសេ អារទ្ធចិត្តា ភិក្ខូ បព្វា-
ជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវាយ ។ អហំ
ចត្តារិ វស្សានិ បរិវសាមិ(៣) ចតុន្នំ វស្សានំ អច្ចយេន
បរិវុដ្ឋបរិវាសំ អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧបសម្បា-
ទេន្តុ ភិក្ខុភាវាយាតិ ។ អលត្ថ ខោ សភិយោ
បរិព្វាជកោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ
ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា
សភិយោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី

---

១ ម. ភិក្ខុភាវាយាតិ ។ ២ ឱ. ម. អបិច មេត្ថ ។ ៣ ឱ. ម. បរិវសិស្សាមិ ។

អ្នកនោះនៅបរិវាសអស់ ៤ ខែសិន លុះអំណើះ ៤ ខែហើយ ភិក្ខុទាំងឡាយ អ្នកមានចិត្តប្រោសប្រាណ ទើបញ៉ាំងបុគ្គលអ្នកនៅបរិវាសហើយឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីឲ្យបានជាភិក្ខុ តែថាសេចក្តីផ្សេងនៃបុគ្គលក្នុងកិច្ចបរិវាសនោះ តថាគតដឹងច្បាស់ហើយ ។ បពិត្រព្រះអង្គដ៏ចំរើន បើពួកដទៃដែលធ្លាប់ជាអន្យតិរ្ថិយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទា ក្នុងធម្មវិន័យនេះ នៅបរិវាសអស់ ៤ ខែសិន លុះអំណើះ ៤ ខែហើយ ភិក្ខុទាំងឡាយ អ្នកមានចិត្តប្រោសប្រាណ ញ៉ាំងពួកកុលបុត្តអ្នកនៅបរិវាសរួចហើយឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីឲ្យបានជាភិក្ខុ ។ ខ្ញុំព្រះអង្គសូមនៅបរិវាសអស់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំ ហើយ សូមឲ្យភិក្ខុទាំងឡាយ អ្នកមានចិត្តប្រោសប្រាណ ញ៉ាំងខ្ញុំព្រះអង្គអ្នកនៅបរិវាសរួចហើយ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីឲ្យបានជាភិក្ខុ ។ សភិយ-បរិព្វាជក ក៏បានបព្វជ្ជា បានឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ។ ព្រះសភិយៈដ៏មានអាយុ បានឧបសម្បទា មិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង មិនធ្វេសប្រហែស មានព្យាយាមដុតកំដៅកិលេស

បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា សភិយោ អរហតំ អហោសីតិ ។

សភិយសុត្តំ ឆដ្ឋំ ។

## សត្តមំ សេលសុត្តំ

(៦០) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា អង្គុត្តរាបេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធិំ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ យេន អាបណំ នាម អង្គុត្តរាបានំ និគមោ តទវសរិ ។ អស្សោសិ ខោ កេណិយោ ជដិលោ សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ អង្គុត្តរាបេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធិំ

មានចិត្តស្ទុងទៅ (កាន់ព្រះនិព្វាន) កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួស ដោយត្រឹមត្រូវ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន (លោក) ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះ មានព្រហ្មចរិយធម៌ជាទីបំផុត ដោយប្រាជ្ញាដ៏ប្រសើរ របស់ខ្លួនឯងក្នុងបច្ចុប្បន្ន បានដឹងថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញប្រព្រឹត្តចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ សភិយៈដ៏មានអាយុ បានជាព្រះអរហន្ត ១ អង្គដែរ ។

ចប់ សភិយសូត្រ ទី ៦ ។

## សេលសូត្រ ទី ៧

(៦០) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរ ទៅកាន់ចារិក ក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប (១២៥០) យាងសំដៅទៅនិគមឈ្មោះអាបណៈ របស់ពួកអ្នកអង្គុត្តរាបជនបទ ។ កេណិយជដិល បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស កំពុងធ្វើពុទ្ធដំណើរ មកកាន់ចារិក ក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប

អឌ្ឍតេឡសេហិ ភិក្ខុសតេហិ អាបណំ អនុប្បត្តោ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា(១) សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណិំ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

---

១ ម. ភគវាតិ ។

គឺភិក្ខុមួយពាន់ពីររយហាសិប មកដល់និគមឈ្មោះអាបណៈហើយ ៗ កិត្តិសព្ទដ៏ពីរោះ របស់ព្រះគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយសុះសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះដឹងនិងក្រិត្យ ដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះមានព្រះភាគនោះ ព្រះអង្គបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្ដមដោយព្រះអង្គ ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ឲ្យត្រាស់ដឹងផង ព្រះអង្គទ្រង់សំដែងធម៌ពីរោះបទដើម បទកណ្ដាល និងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរបានឃើញបានជួបនិងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក ៗ

អថខោ កេណិយោ ជដិលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កេណិយំ ជដិលំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ កេណិយោ ជដិលោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។

(៦១) ឯវំ វុត្តេ ភគវា កេណិយំ ជដិលំ ឯតទវោច មហា ខោ កេណិយ ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ ត្វញ្ច ព្រាហ្មណេសុ អភិប្បសន្នោតិ ។ ទុតិយម្បិ ខោ កេណិយោ ជដិលោ ភគវន្តំ ឯតទវោច កិញ្ចាបិ ភោ គោតម មហា ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ អហញ្ច ព្រាហ្មណេសុ អភិប្បសន្នោ

គ្រានោះ កេណិយជដិល ចូលសំដៅទៅត្រង់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះកេណិយជដិល អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់សំដែង ពន្យល់ណែនាំ ធ្វើឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ កេណិយជដិល ដែលព្រះមានព្រះភាគពន្យល់ ណែនាំ ធ្វើឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រាបទូលនិមន្តព្រះមានព្រះភាគយ៉ាងនេះថា សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែកឲ្យបាន ។

(៦១) កាលដែលកេណិយជដិល ក្រាបទូល យ៉ាងនេះហើយ ព្រះអង្គទ្រង់ត្រាស់នឹងកេណិយជដិលដូច្នេះថា ម្នាលកេណិយៈ ភិក្ខុសង្ឃច្រើនណាស់ គឺភិក្ខុមួយពាន់ពីររយហាសិប អ្នកសោតក៏ជាប់ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ហើយ ។ កេណិយជដិល ទូលព្រះមានព្រះភាគ អស់វារៈពីរជងយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ភិក្ខុសង្ឃច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប ខ្ញុំព្រះអង្គសោតជាអ្នកជាប់ជ្រះថ្លាក្នុងពួកព្រាហ្មណ៍ក៏ពិតមែន

អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ ទុតិយម្បិ ខោ ភគវា កេណិយំ ជដិលំ ឯតទវោច មហា ខោ កេណិយ ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ ត្វញ្ច[1] ព្រាហ្មណេសុ អភិប្បសន្នោតិ ។ តតិយម្បិ ខោ កេណិយោ ជដិលោ ភគវន្តំ ឯតទវោច កិញ្ចាបិ ភោ គោតម មហា ភិក្ខុសង្ឃោ អឌ្ឍតេឡសានិ ភិក្ខុសតានិ អហញ្ច ព្រាហ្មណេសុ អភិប្បសន្នោ អធិវាសេតុ មេ[2] ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ កេណិយោ ជដិលោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា យេន សកោ អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា មិត្តាមច្ចេ ញាតិសាលោហិតេ អាមន្តេសិ

---

១ ឱ. ត្វញ្ច ភោ ។ ២ ម. អធិវាសេត្វេវ មេ ។

តែថា សូមព្រះគោតមដ៏ចំរើនព្រមទាំងភិក្ខុសង្ឃ ទទួលបង្ហាន់របស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកឲ្យបាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងកេណិយជដិលអស់វារៈ ពីរដងយ៉ាងនេះថា ម្នាលកេណិយៈ ភិក្ខុសង្ឃច្រើន គឺភិក្ខុមួយពាន់ពីរយហាសិប អ្នកះសោតជាអ្នកធ្លាប់ជ្រះថ្លា ក្នុងពួកព្រាហ្មណ៍ហើយ ។ កេណិយជដិល ទូលព្រះមានព្រះភាគអស់វារៈ ៣ ដងយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ភិក្ខុសង្ឃច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប ខ្ញុំព្រះអង្គសោត ជាអ្នកធ្លាប់ជ្រះថ្លា ក្នុងពួកព្រាហ្មណ៍ក៏ពិតមែន តែថាសូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលបង្ហាន់របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែក ឲ្យបាន ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្ត ដោយតុណ្ហីភាព ។ លំដាប់នោះ កេណិយជដិលដឹងច្បាស់ នូវការទទួលនិមន្តន៍ របស់ព្រះមានព្រះភាគហើយ ក៏ក្រោកចាកអាសនៈ ចូលសំដៅទៅត្រង់អាស្រមរបស់ខ្លួន លុះចូលទៅដល់ហើយ ក៏ប្រាប់ពួកមិត្រអមាត្យ នឹងញាតិសាលោហិតថា

សុណន្តុ មេ ភោន្តោ មិត្តាមច្ចា ញាតិសាលោហិតា សមណោ មេ គោតមោ និមន្តិតោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេន យេន មេ កាយវេយ្យាវដិកំ ករេយ្យាថាតិ ។ ឯវំ ភោតិ ខោ កេណិយស្ស ជដិ-លស្ស មិត្តាមច្ចា ញាតិសាលោហិតា កេណិយស្ស ជដិលស្ស បដិស្សុត្វា អប្បេកច្ចេ ឧទ្ធនានិ ខណន្តិ អប្បេកច្ចេ កដ្ឋានិ ផាលេន្តិ អប្បេកច្ចេ ភាជនានិ ធោវន្តិ អប្បេកច្ចេ ឧទកមណិកំ បតិដ្ឋាបេន្តិ អប្បេ-កច្ចេ អាសនានិ បញ្ញបេន្តិ កេណិយោ បន ជដិលោ សាមំ យេវ មណ្ឌលមាឡំ បដិយាទេតិ ។

(៦៤) តេន ខោ បន សមយេន សេលោ ព្រាហ្ម-ណោ អាបណេ បដិវសតិ តិណ្ណំ វេទានំ បារគូ សនិ-ឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិស-លក្ខណេសុ អនវយោ តីណិ ច មាណវកសតានិ មន្តេ វាចេតិ ។ តេន ខោ បន សមយេន កេណិយោ ជដិលោ សេលេ ព្រាហ្មណេ អភិប្បសន្នោ ហោតិ ។

ពួកមិត្រអមាត្យ និងញាតិសាលោហិតដ៏ចំរើន ចូរស្តាប់ពាក្យខ្ញុំ ព្រោះខ្ញុំបាននិមន្តព្រះសមណគោតម ព្រមទាំងភិក្ខុសង្ឃ ដើម្បីឆាន់ ក្នុងថ្ងៃស្អែក អ្នកទាំងឡាយ ត្រូវជួយធ្វើការខ្វល់ខ្វាយ ដោយកាយដល់ខ្ញុំ ។ ពួកមិត្រអមាត្យ និងញាតិសាលោហិត របស់កេណិយជដិល ក៏ទទួលស្តាប់ពាក្យកេណិយជដិលថា អើលោក ពួកខ្លះជីកចង្ក្រានជីកគុក ពួកខ្លះ ពុះឧស ពួកខ្លះ លាងភាជន៍ ពួកខ្លះដម្កល់ពាងទឹក ពួកខ្លះក្រាលអាសនៈ ឯកេណិយជដិល ក៏ចាត់ចែងបារាំ ដោយខ្លួនឯង ។

(៦២) សម័យនោះឯង សេលព្រាហ្មណ៍នៅអាស្រ័យ ក្នុងនិគមឈ្មោះអាបណៈ ជាអ្នកដល់នូវត្រើយនៃវេទ ៣ ព្រមទាំងគម្ពីរឈ្មោះនិឃណ្ឌុ និងគម្ពីរឈ្មោះកេដុភៈ និងអក្ខរប្បភេទ មានគម្ពីរឈ្មោះឥតិហាសជាគំរប់ ៥ ជាអ្នករៀននូវបទ ចេះព្យាករណ៍ មិនទើសទាល់ ក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណសាស្ត្រ បង្រៀនមន្តទាំងឡាយ ដល់មាណពបីរយនាក់ ។ សម័យនោះឯង កេណិយជដិល ក៏ជាអ្នកជាប់ជ្រះថ្លា ក្នុងសេលព្រាហ្មណ៍ដែរ ។

អថខោ សោ ព្រាហ្មណោ តីហិ មាណវកសតេហិ បរិវុតោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន កេណិយស្ស ជដិលស្ស អស្សមោ តេនុបសង្កមិ ។ អទ្ទសា ខោ សោ ព្រាហ្មណោ កេណិយស្ស ជដិលស្ស អស្សមេ(១) អប្បេកច្ចេ ឧទ្ធនានិ ខណន្តេ ។បេ។ អប្បេកច្ចេ អាសនានិ បញ្ញាបេន្តេ កេណិយំ បន ជដិលំ សាមំយេវ មណ្ឌលមាលំ បដិយាទេន្តំ ទិស្វាន កេណិយំ ជដិលំ ឯតទវោច កឹ នុ ខោ ភោតោ កេណិយស្ស អាវាហោ វា ភវិស្សតិ វិវាហោ វា ភវិស្សតិ មហាយញ្ញោ វា បច្ចុបដ្ឋិតោ រាជា វា មាគធោ សេនិយោ ពិម្ពិសារោ និមន្តិតោ ស្វាតនាយ សទ្ធឹ ពលកាយេនាតិ ។ ន មេ ភោ សេល អាវាហោ វា ភវិស្សតិ នបិ វិវាហោ ភវិស្សតិ នបិ រាជា មាគធោ សេនិយោ ពិម្ពិសារោ និមន្តិតោ ស្វាតនាយ សទ្ធឹ ពលកាយេន ។ អបិ ច ខោ មេ មហាយញ្ញោ បច្ចុបដ្ឋិតោ អត្ថិ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ

---

១ ម. កេណិយស្សមិយេ ជដិលេ ។

ព្រាហ្មណ៍ មានមាណពបីរយហែហម ត្រាច់ដើរទៅមកសម្រាកស្ងួន រួចក៏ចូលសំដៅទៅ គ្រប់អាស្រមកេណិយជដិល ៗ សេលព្រាហ្មណ៍ បានឃើញមនុស្សពួកខ្លះ កំពុងដីកចង្ក្រានដីកគុកទៀបអាស្រមកេណិយ-ជដិល ៗ បេ ៗ មនុស្សពួកខ្លះ កំពុងក្រាលអាសនៈ ទាំងកេណិយ-ជដិល ក៏កំពុងចាត់ចែងបារំ ដោយខ្លួនឯង លុះឃើញហើយក៏សួរកេណិយជដិល យ៉ាងនេះថា កេណិយៈដ៏ចំរើន ទឹងមានកិច្ចអាវាហៈឬវិវាហៈ ឬរៀបចំមហាយញ្ញ ឬក៏អញ្ជើញព្រះបាទពិម្ពិសារមាគធសេនិយព្រមទាំងពួកពល ដើម្បីជប់លៀងក្នុងថ្ងៃស្អែកឬហ្ន៎ ៗ បពិត្រសេល-ព្រាហ្មណ៍ដ៏ចំរើន អាត្មាមិនមានកិច្ចអាវាហៈ មិនមានកិច្ចវិវាហៈទេ ទាំងមិនបានអញ្ជើញព្រះបាទពិម្ពិសារមាគធសេនិយៈ ព្រមទាំងពួកពល ដើម្បីជប់លៀងក្នុងថ្ងៃស្អែកទេ ៗ ប៉ុន្តែអាត្មាមានការរៀបចំមហាយញ្ញ ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស

សុត្តនិបាតេ តតិយស្ស មហាវគ្គស្ស សត្តមំ សេលសុត្តំ

អង្គុត្តរាបេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធិំ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ អាបណំ អនុប្បត្តោ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា ។បេ។ ពុទ្ធោ ភគវាតិ ។ សោ មេ និមន្តិតោ ស្វាតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ ពុទ្ធោតិ ភោ កេណិយ វទេសិ ។ ពុទ្ធោតិ ភោ សេល វទាមិ ។ ពុទ្ធោតិ ភោ កេណិយ វទេសិ ។ ពុទ្ធោតិ ភោ សេល វទាមីតិ ។ អថខោ សេលស្ស ព្រាហ្មណស្ស ឯតទ-ហោសិ ឃោសោបិ ខោ ឯសោ ទុល្លភោ លោកស្មិំ យទិទំ ពុទ្ធោតិ ។ អាគតានិ ខោ បន អម្ហាកំ មន្តេសុ ទ្វត្តិំស(១) មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេវ គតិយោ ភវន្តិ អនញ្ញា(២) សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តី ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី

---

១ ម. បនស្មាកំ មន្តេសុ ទត្តិំស ។ ២ ម. អនញ្ញា ។

ធ្វើពុទ្ធដំណើរ មកកាន់ចារិកក្នុងអង្គុត្តរាបជនបទ ជាមួយនឹងភិក្ខុសង្ឃ ជាច្រើនរូប គឺភិក្ខុមួយពាន់ពីររយហាសិប យាងមកដល់អាបណនិគម ហើយ កិត្តិសព្ទដ៏ពីរោះ របស់ព្រះគោតម ដ៏ចំរើននោះ ឮខ្ចរខ្ចាយ សុះសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ៗ បេ ៗ ព្រះអង្គបានត្រាស់ដឹង នូវសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ៗ អាត្មាបាននិមន្តព្រះសមណគោតមនោះ ព្រមទាំងភិក្ខុសង្ឃ ដើម្បីបង្ហាន់ក្នុងថ្ងៃស្អែក ៗ បពិត្រកេណិយៈដ៏ចំរើន លោកនិយាយថា ព្រះពុទ្ធ ៗ ម្នាលសេលព្រាហ្មណ៍ដ៏ចំរើន អាត្មានិយាយថា ព្រះពុទ្ធ ៗ បពិត្រកេណិយៈដ៏ចំរើន លោកនិយាយថា ព្រះពុទ្ធ ៗ ម្នាលសេលព្រាហ្មណ៍ដ៏ចំរើន អាត្មានិយាយថា ព្រះពុទ្ធ ៗ គ្រានោះ សេលព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា សំឡេងគឺពាក្យថា ពុទ្ធៈនេះ គេរកបានដោយក្រក្នុងលោក ៗ មហាបុរិសលក្ខណៈ ៣២ ប្រការ មានមកហើយ ក្នុងមន្តទាំងឡាយរបស់យើង មហាបុរសដែលប្រកបដោយមហាបុរិសលក្ខណៈទាំងនោះ រមែងមានគតិពីរយ៉ាង មិនប្លែកអំពីនេះទេ គឺនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ ព្រះអង្គជាធម្មិកធម្មរាជ ជាឥស្សរៈ លើផែនដី ប្រដាប់ដោយរតនៈ ៧ មានសមុទ្រទាំង ៤ ជាទីបំផុត ទ្រង់មានជ័យជំនះ

ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្តរតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថិរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ ។ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ។ សោ ឥមំ បថវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសតិ ។ សចេ ខោ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដ្ដច្ឆទោ ។ កហំ បន ភោ កេណិយ ឯតរហិ សោ ភវំ គោតមោ វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។

(៦៣) ឯវំ វុត្តេ កេណិយោ ជដិលោ ទក្ខិណំ ពាហំ[១] បគ្គហេត្វា សេលំ ព្រាហ្មណំ ឯតទវោច យេនេសា ភោ សេល នីលវនរាជីតិ ។ អថ ខោ សេលោ ព្រាហ្មណោ តីហិ មាណវកសតេហិ សទ្ធឹ យេន ភគវា តេនុបសង្កមិ ។

១ ម. ពាហុំ ។

ខាងក្នុងនិងខាងក្រៅ ដល់នូវការមាំមួនក្នុងជនបទ ទ្រង់បរិបូណ៌ដោយរតនៈ ៧ ប្រការ ឯរតនៈ ៧ ប្រការ របស់ស្តេចចក្រពត្តិនោះគឺ ចក្ករតនៈ ១ ហត្ថិរតនៈ ១ អស្សរតនៈ ១ មណិរតន ១ ឥត្ថីរតនៈ ១ គហបតិរតនៈ ១ បរិណាយករតនៈ ១ រួមត្រូវជា ៧ ប្រការ ឯស្តេចចក្រពត្តិនោះ មានព្រះរាជបុត្រច្រើនពាន់ ប្រកបដោយជាតិដ៏ថ្លៃថ្លា សូរសឹងតែក្លៀវក្លា មានរូបឆោមល្អ អាចសង្កត់សង្កិន នូវសេនារបស់ស្តេចដទៃបាន ។ ស្តេចចក្រពត្តិនោះ ទ្រង់ត្រួតត្រាគ្រប់គ្រងផែនដីនេះ មានសាគរជាព្រំប្រទល់ ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធ(នេះ ១) ។ ប្រសិនបើចេញចាកព្រះរាជដំណាក់ទៅទ្រង់ព្រះផ្នួស នឹងបានជាអរហន្ត-សម្មាសម្ពុទ្ធ ក្នុងលោក មានដំបូលគឺកិលេសបើកហើយ (១) ។ សេលព្រាហ្មណ៍ បានសួរថា ម្នាលកេណិយៈដ៏ចំរើន ចុះឥឡូវនេះព្រះគោតមដ៏ចំរើន ជាអរហន្តសម្មាសម្ពុទ្ធនោះ ព្រះអង្គគង់នៅក្នុងទីណា ។

[៦៣] កាលសេលព្រាហ្មណ៍ និយាយយ៉ាងនេះ កេណិយជដិលក៏លើកដៃខាងស្តាំនិយាយនឹងសេលព្រាហ្មណ៍យ៉ាងនេះថា ម្នាលសេល-ព្រាហ្មណ៍ដ៏ចំរើន ជួរព្រៃខៀវ ៗ នុ៎ះ មានក្នុងទិសណា (ព្រះអង្គគង់ក្នុងទិសនោះ) ។ លំដាប់នោះ សេលព្រាហ្មណ៍ព្រមទាំងមាណព ៣០០ នាក់ ចូលសំដៅទៅត្រង់កន្លែងដែលព្រះមានព្រះភាគគង់ ។

អថខោ សេលោ ព្រាហ្មណោ តេ មាណវកេ អាមន្តេសិ អប្បសទ្ទា ភោន្តោ អាគច្ឆន្តុ បទេ បទំ និក្ខិបន្តា ទុរាសទា ហិ តេ ភវន្តោ សីហាវ ឯកៈចរា យទា ចាហំ ភោ សមណេន គោតមេន សទ្ធឹ មន្តេយ្យំ មា មេ ភោន្តោ[១] អន្តរន្តរា កថំ ឱបាតេថ កថាបរិយោសានំ[២] មេ ភវន្តោ អាគមេន្តូតិ ។ អថខោ សេលោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សេលោ ព្រាហ្មណោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ សម្មន្នេសិ ។ អទ្ទសា ខោ សេលោ ព្រាហ្មណោ ភគវតោ កាយេ ទ្វត្តឹស មហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ

១ ម. ភោន្តោបិ ។ ២ ម. កថាបរិយោសានេ ។

លំដាប់នោះ សេលព្រាហ្មណ៍ ប្រាប់ពួកមាណពទាំងនោះថា អ្នកដ៏ចំរើនទាំងឡាយ ចូរនិយាយគ្នាតិចៗ ចូរដើរដាក់ជើងជិតជើង (ដើរសន្សឹម) ព្រោះលោកដ៏ចំរើនទាំងនោះមកអំពីចម្ងាយ ដើរតែម្នាក់ឯង ដូចសីហៈ ម្នាលអ្នកដ៏ចំរើនទាំងឡាយ ទម្រាំអញប្រឹក្សានឹងព្រះសមណគោតមសិន ម្នាលអ្នកដ៏ចំរើនទាំងឡាយ អ្នកទាំងឡាយកុំស្កាត់សំដីអញ ត្រង់ចន្លោះៗ ឡើយ អ្នកដ៏ចំរើនទាំងឡាយ ចូររង់ចាំនូវទីបំផុតនៃពាក្យអញសិន ។ លំដាប់នោះ សេលព្រាហ្មណ៍ ចូលសំដៅទៅត្រង់កន្លែងដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ សេលព្រាហ្មណ៍ លុះអង្គុយក្នុងទីសមគួរហើយ ក៏ពិនិត្យមើលមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយ របស់ព្រះមានព្រះភាគ ។ សេលព្រាហ្មណ៍ បានឃើញនូវមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយ របស់ព្រះមានព្រះភាគ ដោយច្រើន លើកលែងតែមហាបុរិសលក្ខណៈ ពីរប្រការ ក៏សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនយល់ច្បាស់

កោសោហិតេ ច វត្ថគុយ្ហេ បហុតជិវ្ហតាយ ច ។
អថខោ ភគវតោ ឯតទហោសិ បស្សតិ ខោ មេ
អយំ សេលោ ព្រាហ្មណោ ទ្វត្តឹស មហាបុរិសលក្ខ-
ណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខ-
ណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ
កោសោហិតេ ច វត្ថគុយ្ហេ បហុតជិវ្ហតាយ ចាតិ ។
អថខោ ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ[១]
យថា អទ្ទស សេលោ ព្រាហ្មណោ ភគវតោ
កោសោហិតំ វត្ថគុយ្ហំ ។ អថខោ ភគវា ជិវ្ហំ
និន្នាមេត្វា ឧភោបិ កណ្ណសោតានិ អនុមសិ បដិ-
មសិ ឧភោបិ នាសិកសោតានិ អនុមសិ បដិមសិ
កេវលម្បិ នលាដមណ្ឌលំ ជិវ្ហាយ ឆាទេសិ ។
អថខោ សេលស្ស ព្រាហ្មណស្ស ឯតទហោសិ
សមន្នាគតោ ខោ សមណោ គោតមោ ទ្វត្តឹសាយ
មហាបុរិសលក្ខណេហិ បរិបុណ្ណេហិ នោ អបរិបុណ្ណេ-
ហិ នោ ច ខោ នំ ជានាមិ ពុទ្ធោ វា នោ វា ។

---
១ ម. អភិសង្ខាសិ ។

ក្នុងមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថគុយ្ហប្រទេស ដែលស្រោបដោយស្រោម ១ ព្រះជិវ្ហាល្វន់ល្វៃ ១ ។ គ្រានោះ ព្រះមានព្រះភាគ មានព្រះតម្រិះយ៉ាងនេះថា សេលព្រាហ្មណ៍ ឃើញតែមហាបុរិសលក្ខណៈ ៣២ ប្រការ របស់តថាគត ដោយច្រើន លើកលែងតែមហាបុរិសលក្ខណៈ ២ ប្រការ ក៏សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនយល់ច្បាស់ ក្នុងមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថគុយ្ហប្រទេស ដែលស្រោបដោយស្រោម ១ ព្រះជិវ្ហាល្វន់ល្វៃ ១ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់និម្មិតរូប ដែលតាក់តែងដោយឫទ្ធិ មានទំនងល្មមឲ្យសេលព្រាហ្មណ៍ឃើញបាន នូវគុយ្ហប្រទេស ដែលស្រោបដោយស្រោមរបស់ព្រះអង្គ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់លៀនព្រះជិវ្ហា ហើយមូរស៊កតាមរន្ធនៃព្រះកាណ៌ទាំងពីរផង មូរស៊កតាមរន្ធនៃព្រះនាសិកទាំងពីរផង បិទបាំងនូវមណ្ឌលនៃនលាដទាំងអស់ ដោយព្រះជិវ្ហាផង ។ លំដាប់នោះ សេលព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះសមណគោតម ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការគ្រប់គ្រាន់ មិនមែនមិនគ្រប់គ្រាន់ទេ ប៉ុន្តែអញមិនទាន់ស្គាល់ នូវលោកថាជាព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធ ។

សុតំ ខោ បនេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យេ តេ ភវន្តោ(១) អរហន្តោ សម្មាសម្ពុទ្ធា តេ សកេ វណ្ណេ ភញ្ញមានេ អត្តានំ បាតុករោន្តីតិ យន្នូនាហំ សមណំ គោតមំ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវេយ្យន្តិ ។ អថខោ សេលោ ព្រាហ្មណោ ភគវន្តំ សម្មុខា សារុប្បាហិ គាថាហិ អភិត្ថវិ

បរិបុណ្ណកាយោ សុរុចិ សុជាតោ ចារុទស្សនោ
សុវណ្ណវណ្ណោសិ ភគវា សុសុក្កទាឋោសិ(២) វីរិយវា
នរស្ស ហិ សុជាតស្ស យេ ភវន្តិ វិយញ្ជនា
សព្វេ តេ តវ កាយស្មឹ មហាបុរិសលក្ខណា ។
បសន្ននេត្តោ សុមុខោ ព្រហា ឧជុ បតាបវា
មជ្ឈេ សមណសង្ឃស្ស អាទិច្ចោវ វិរោចសិ ។
កល្យាណទស្សនោ ភិក្ខុ កញ្ចនសន្និភត្តចោ

១ ឱ. ភវន្តិ ។ ២ ឱ. ម. សុសុក្កទាឋោសិ ។

ប៉ុន្តែអញបានឮពាក្យរបស់ព្រាហ្មណ៍ចាស់ៗ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យនិយាយថា ពួកជនណា ជាអរហន្តសម្មាសម្ពុទ្ធមានព្រះភាគ ពួកជននោះ កាលបើគេនៅតែថ្លែងគុណជារបស់ខ្លួន រមែងសំដែងខ្លួនឲ្យប្រាកដ បើដូច្នោះ គួរតែអញសរសើរព្រះសមណគោតម ក្នុងទីចំពោះព្រះភក្ត្រ ដោយសារុប្បគាថាចុះ ។ លំដាប់នោះ សេលព្រាហ្មណ៍សរសើរព្រះមានព្រះភាគ ក្នុងទីចំពោះព្រះភក្ត្រដោយសារុប្បគាថាដូច្នេះថា

ព្រះអង្គជាបុគ្គលមានព្រះកាយបរិបូណ៌ មានពន្លឺសរីរៈល្អ មានព្រះជាតិល្អ (១) មានការមៀងមើលល្អ (២) ព្រះមានព្រះភាគមានសម្បុរដូចជាមាស មានព្រះទាឋា សសុទ្ធ មានព្យាយាម ព្រោះថា មហាបុរិសលក្ខណៈ ទាំងអស់នោះ មានប្រាកដក្នុងព្រះកាយរបស់ព្រះអង្គ ដែលជាជនមានកំណើតល្អ ៗ ព្រះអង្គមានព្រះនេត្រថ្លា មានព្រះភក្ត្រល្អ មានព្រះកាយសមរម្យ (ទាំងកំពស់ទីងទំហំ) មានព្រះកាយត្រង់ មានរស្មីរុងរឿង ក្នុងកណ្ដាលនៃពួកសមណៈដូចព្រះអាទិត្យ ៗ ព្រះអង្គជាភិក្ខុអ្នកមៀងមើលល្អ មានព្រះតចោភ្លឺថ្លាដូចមាស

---

១ កើតមកល្អស្រាប់ ដោយការដល់ព្រមដោយកំពស់ ទំហំ និងសណ្ឋាន ។

២ អាចារ្យខ្លះថា ព្រះអង្គមានព្រះនេត្រល្អ ។ អដ្ឋកថា ។

កិន្តេ(១) សមណភាវេន ឯវំ ឧត្តមវណ្ណិនោ ។

រាជា អរហសិ ភវិតុំ ចក្កវត្តី រថេសភោ

ចាតុរន្តោ វិជិតាវី ជម្ពុសណ្ឌស្ស(២) ឥស្សរោ

ខត្តិយា ភោជរាជានោ(៣) អនុយន្តា(៤) ភវន្តិ តេ

រាជាភិរាជា មនុជិន្ទោ រជ្ជំ ការេហិ គោតម ។

(៦៤) រាជាហមស្មិ (សេលាតិ ភគវា) ធម្មរាជា អនុត្តរោ

ធម្មេន ចក្កំ វត្តេមិ ចក្កំ អប្បតិវត្តិយំ ។

សម្ពុទ្ធោ បដិជានាសិ (ឥតិ សេលោ ព្រាហ្មណោ)

ធម្មរាជា អនុត្តរោ

ធម្មេន ចក្កំ វត្តេមិ ឥតិ ភាសសិ គោតម

កោ នុ សេនាបតិ ភោតោ សាវកោ សត្ថុរន្វយោ(៥)

កោ តេ ឥមំ អនុវត្តេតិ(៦) ធម្មចក្កំ បវត្តិតំ(៧) ។

---

១ ម. កិន្តេន ។ ២ ម. ជម្ពុមណ្ឌស្ស ។ ៣ ម. ភោគិរាជានោ ។ ៤ ឱ. អនុយុត្តា ។
៥ ឱ. សត្ថុទន្វយោ ។ ម. សត្ថុអន្វយោ ។ ៦ ម. កោ តេ តមនុវត្តេតិ ។ ៧ ម. វត្តិយំ ។

ប្រយោជន៍អ្វីដោយភាពជាសមណៈ ដល់ព្រះអង្គដែលមានសម្បុរដ៏ឧត្តមយ៉ាងនេះ ។ ព្រះអង្គគួរជាស្តេចចក្រពត្តិដូចជាឧសភក្នុងរថ ជាឥស្សរៈលើផែនដីប្រដាប់ដោយទ្វីប ៤ មានសមុទ្រទាំង ៤ ជាទីបំផុត មានជ័យជំនះទាំងខាងក្នុងនិងខាងក្រៅ ជាឥស្សរៈរបស់ជម្ពូទ្វីប ក្សត្រទាំងឡាយ ជាស្តេចបំរើចុះចូលព្រះអង្គ បពិត្រព្រះគោតម ព្រះអង្គជាស្តេចដែលពួកស្តេចគោរពបូជា ជាធំជាងពួកមនុស្ស សូមសោយរាជ្យទៅវិញ ។

(៦៤) (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ម្នាលសេលៈ តថាគតជាស្តេច ធម្មរាជ ជាបុគ្គលប្រសើរ ញុំាងចក្រឲ្យប្រព្រឹត្តទៅដោយធម៌ ជាចក្រដែលអ្នកណាមួយឲ្យប្រព្រឹត្តទៅមិនបាន ។

(សេលព្រាហ្មណ៍និយាយថា) ព្រះអង្គប្តេជ្ញាជាព្រះសម្ពុទ្ធ ជាធម្មរាជ ជាបុគ្គលប្រសើរ បពិត្រព្រះគោតមដ៏ចំរើន ព្រះអង្គត្រាស់ថា តថាគតញុំាងចក្រ ឲ្យប្រព្រឹត្តទៅដោយធម៌ចុះ សាវ័កណា ជាសេនាបតី ជាអ្នកប្រព្រឹត្តតាមព្រះសាស្តាដ៏ចំរើន សាវ័កណា ញុំាងធម្មចក្រជា កេរ្តិ៍ដំណែលរបស់ព្រះអង្គនេះ ឲ្យប្រព្រឹត្តទៅបាន ។

មយា បវត្តិតំ ចក្កំ (សេលាតិ ភគវា) ធម្មចក្កំ អនុត្តរំ

សារីបុត្តោ អនុវត្តេតិ អនុជាតោ តថាគតំ ។

អភិញ្ញេយ្យំ អភិញ្ញាតំ ភាវេតព្វញ្ច ភាវិតំ

បហាតព្វំ បហីនំ មេ តស្មា ពុទ្ធោស្មិ ព្រាហ្មណ

វិនយស្សុ មយិ កង្ខំ អធិមុញ្ចស្សុ(១) ព្រាហ្មណ

ទុល្លភំ ទស្សនំ ហោតិ សម្ពុទ្ធានំ អភិណ្ហសោ ។

យស្ស វេ ទុល្លភោ លោកេ បាតុភាវោ អភិណ្ហសោ

សោហំ ព្រាហ្មណ សម្ពុទ្ធោ សល្លកត្តោ អនុត្តរោ ។

ព្រហ្មភូតោ អតិតុលោ មារសេនប្បមទ្ទនោ

សព្វាមិត្តេ វសីកត្វា មោទាមិ អកុតោភយោ ។

---

១ ខ. ម. អធិមុច្ចស្សុ ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសេលៈ) សារីបុត្ត ជាអនុជាត ញុំាងធម្មចក្រ ជាចក្រដ៏ប្រសើរដែលតថាគត ឲ្យប្រព្រឹត្តទៅហើយ (នោះ) ឲ្យប្រព្រឹត្តតាមតថាគត ។ វិជ្ជានិងវិមុត្តិដែលគប្បីដឹងច្បាស់ តថាគតដឹងច្បាស់ហើយ មគ្គសច្ច ដែលគប្បីចំរើន តថាគតបានចំរើនហើយ សមុទយសច្ច ដែលគប្បីលះ តថាគតលះបង់ហើយ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ ទើបតថាគតឈ្មោះជាពុទ្ធៈ ម្នាលព្រាហ្មណ៍ អ្នកចូរកំចាត់សេចក្ដីសង្ស័យ ចូរជឿស៊ប់ចំពោះតថាគតចុះ ការបានចួបប្រទះនឹងព្រះសម្ពុទ្ធទាំងឡាយរឿយៗ ជាការបានដោយក្រ ។

ការកើតឡើងនៃព្រះសម្ពុទ្ធក្នុងលោករឿយៗ ជាការបានដោយក្រ ម្នាលព្រាហ្មណ៍ តថាគតនោះជាអ្នកត្រាស់ដឹងជាអ្នកកាត់នូវសរគឺកគាទិកិលេស ជាបុគ្គលប្រសើរ ។

តថាគត ជាបុគ្គលប្រសើរ កន្លងនូវសេចក្ដីប្រៀបផ្ទឹម ញាំញីនូវមារសេនា ឥតមានភ័យអំពីណាឡើយ រមែងរីករាយ ព្រោះបានធ្វើសត្រូវទាំងអស់ ឲ្យលុះក្នុងអំណាច ។

ឥមំ ភោន្តោ និសាមេថ យថា ភាសតិ ចក្ខុមា
សល្លកត្តោ មហាវីរោ សីហោវ នទតី វនេ ។
ព្រហ្មភូតំ អតិតុលំ មារសេនប្បមទ្ទនំ
កោ ទិស្វា នប្បសីទេយ្យ អបិ កណ្ហាភិជាតិកោ ។
យោ មំ ឥច្ឆតិ អន្វេតុ យោ វា និច្ឆតិ គច្ឆតុ
ឥធាហំ បព្វជិស្សាមិ វរប្បញ្ញស្ស សន្តិកេ
ឯតំ ចេ រុច្ចតិ(១) ភោតោ សម្មាសម្ពុទ្ធសាសនំ(២)
មយម្បិ បព្វជិស្សាម វរប្បញ្ញស្ស សន្តិកេ ។
ព្រាហ្មណា តិសតា ឥមេ យាចន្តិ បញ្ជលីកតា
ព្រហ្មចរិយំ ចរិស្សាម ភគវា តវ សន្តិកេ ។

---

១ ឱ. ឯតញ្ចេ រុច្ចតី ។ ២ ម. សម្មាសម្ពុទ្ធសាសនេ ។

(សេលព្រាហ្មណ៍និយាយថា) ម្នាលអ្នកដ៏ចំរើនទាំងឡាយ ព្រះពុទ្ធអ្នកមានចក្ខុ ទ្រង់កាត់នូវសរគឺរាគាទិក្កិលេស ជាមហាវីរបុរស ដូចជាសីហៈបន្លឺក្នុងព្រៃ សំដែងយ៉ាងណា អ្នកទាំងឡាយចូរស្តាប់ នូវពាក្យនេះ យ៉ាងនោះចុះ ។

បុគ្គលណា ឃើញព្រះសម្ពុទ្ធជាបុគ្គលប្រសើរ កន្លងនូវសេចក្តីប្រៀបផ្ទឹម ញាំញីនូវមារសេនា ហើយមិនគប្បីជ្រះថ្លា សូម្បីកណ្ហាភិជាតិកជន (ជនកើតក្នុងត្រកូលថោកទាប មានត្រកូលចណ្ឌាលជាដើម ក៏ជ្រះថ្លាដែរ) ។

អ្នកណាចង់ (បួស) ចូរមកតាមខ្ញុំ អ្នកណាមិនចង់ចូរទៅវិញចុះ ខ្ញុំនឹងបួសក្នុងសំណាក់ព្រះពុទ្ធ មានប្រាជ្ញាដ៏ប្រសើរ ក្នុងទីនេះ ។

(ពួកមាណពនិយាយថា) បើលោកដ៏ចំរើនគាប់ចិត្តនឹងសាសនារបស់ព្រះសម្មាសម្ពុទ្ធយ៉ាងនេះ ពួកយើងក៏នឹងបួសក្នុងសំណាក់ព្រះពុទ្ធ មានប្រាជ្ញាដ៏ប្រសើរដែរ ។

(សេលព្រាហ្មណ៍និយាយថា) ពួកព្រាហ្មណ៍ទាំង ៣ រយនាក់ទាំងនេះ ប្រណម្យអញ្ជលីសូម (បួស) មពិត្រព្រះមានព្រះភាគ ពួកយើងនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់ព្រះអង្គ ។

ស្វាក្ខាតំ ព្រហ្មចរិយំ (សេលាតិ ភគវា)
សន្ទិដ្ឋិកំ អកាលិកំ
យត្ថ អមោឃា បព្វជ្ជា អប្បមត្តស្ស សិក្ខតោតិ ។

(៦៥) អលត្ថ ខោ សេលោ ព្រាហ្មណោ សបរិសោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អថខោ កេណិយោ ជដិលោ តស្សា រត្តិយា អច្ចយេន សកេ អស្សមេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន កេណិយស្ស ជដិលស្ស អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ កេណិយោ ជដិលោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសេល:)
បព្វជ្ជារបស់កុលបុត្ត អ្នកមិនធ្វេសប្រហែសកាលសិក្សា
ជាគុណជាតិ មិនឥតអំពើ ក្នុងព្រហ្មចរិយធម៌ណា
ព្រហ្មចរិយធម៌នោះ តថាគត សំដែងទុកល្អហើយ
ជាគុណឲ្យផលជាក់ច្បាស់ មិនកំណត់កាល ។

(៦៥) សេលព្រាហ្មណ៍ ព្រមទាំងបរិសទ្យ ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ លំដាប់នោះ លុះកន្លងរាត្រីនោះហើយ កេណិយជដិល ក៏ឲ្យតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ក្នុងអាស្រមរបស់ខ្លួន ហើយឲ្យក្រាបទូលកត្តកាល ដល់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់យាងសំដៅចូលទៅ ឯអាស្រមកេណិយជដិល លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលថ្វាយ ព្រមទាំងភិក្ខុសង្ឃ ។ គ្រានោះ កេណិយជដិល បានអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ទាល់តែហាមឃាត់ ។

អថខោ កេណិយោ ជដិលោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កេណិយំ ជដិលំ ភគវា ឥមាហិ គាថាហិ អនុមោទិ

អគ្គិហុត្តមុខា យញ្ញា សាវិត្តី ឆន្ទសោ មុខំ
រាជា មុខំ មនុស្សានំ នទីនំ សាគរោ មុខំ ។
នក្ខត្តានំ មុខំ ចន្ទោ អាទិច្ចោ តបតំ មុខំ
បុញ្ញ[១]មាកង្ខមានានំ សង្ឃោ វេ យជតំ មុខន្តិ ។

(៦៦) អថខោ ភគវា កេណិយំ ជដិលំ ឥមាហិ គាថាហិ អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។

លំដាប់នោះ កេណិយជដិល ( បានចូលទៅគាល់ ) ព្រះមានព្រះភាគ ដែលទ្រង់សោយភត្តរួចហើយ មានព្រះហស្ត ដាក់ចេញពីបាត្រហើយ រួចក៏កាន់យកអាសនៈ ១ ដ៏ទាប អង្គុយក្នុងទីសមគួរ ។ កាលដែល កេណិយជដិល អង្គុយស៊ប់ក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ អនុមោទនា ដោយគាថាទាំងនេះថា

ការបូជាទាំងឡាយ មានការបូជាភ្លើង ជាប្រធាន
គម្ពីរសាវិត្តិសាស្ត្រ ជាប្រធាន នៃគម្ពីរឆន្ទសាស្ត្រ
ព្រះរាជា ជាប្រធាន នៃមនុស្សទាំងឡាយ
សាគរជាប្រធាន នៃទន្លេទាំងឡាយ ។ ព្រះចន្ទ្រ
ជាប្រធាន នៃផ្កាយទាំងឡាយ ព្រះអាទិត្យ
ជាប្រធាន នៃកំដៅទាំងឡាយ (យ៉ាងណាមិញ)
ព្រះសង្ឃ ជាប្រធាន នៃជនទាំងឡាយ កាល
បូជាប្រាថ្នានូវបុណ្យ ក៏យ៉ាងនោះដែរ ។

[៦៦] គ្រានោះ ព្រះមានព្រះភាគ លុះទ្រង់អនុមោទនាចំពោះកេណិយ-ជដិល ដោយគាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈ យាងចៀស-

អថខោ អាយស្មា សេលោ សបរិសោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា សេលោ សបរិសោ អរហតំ អហោសិ ។ អថខោ អាយស្មា សេលោ សបរិសោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ គាថាយ អជ្ឈភាសិ

ចេញទៅ ៗ លំដាប់នោះ ព្រះសេលៈដ៏មានអាយុ ព្រមទាំងបរិសទ្យ គេចចេញទៅ (ចាកពួក) តែម្នាក់ឯង ១ ជាអ្នកមិនប្រមាទ មានព្យាយាម មានចិត្តស្ងុនទៅ (កាន់ព្រះនិព្វាន) កុលបុត្រទាំងឡាយ ចេញចាកផ្ទះបួស កាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរយារ ប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះ ជាទីបំផុតនៃ ព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ប្រសើរដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដឹង ច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញ ប្រព្រឹត្តចប់ហើយ សោឡសកិច្ចដែលគួរធ្វើ អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ច ដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ៗ បណ្ដា ព្រះអរហន្តទាំងឡាយ ព្រះសេលៈដ៏មានអាយុ ព្រមទាំងបរិសទ្យក៏រាប់ ថាជាព្រះអរហន្តមួយរូបដែរ ៗ គ្រានោះ ព្រះសេលៈដ៏មានអាយុ ព្រមទាំងបរិសទ្យ ចូលសំដៅទៅត្រង់ទី ដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ធ្វើចីវរឆៀងស្មាម្ខាង រួចប្រណម្យអញ្ជលីទៅ ត្រង់ទីដែលព្រះមានព្រះភាគគង់ ហើយបានទូលព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

យន្តំ សរណាគម្ម ឥតោ អដ្ឋមិ ចក្ខុមា
សត្តរត្តេន ភគវា ទន្តម្ហា តវ សាសនេ ។
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆេត្វា តិណ្ណោ តារេសិមំ បជំ
ឧបធី តេ សមតិក្កន្តា អាសវា តេ បទាលិតា
សីហោសិ អនុបាទានោ បហីនភយភេរវោ
ភិក្ខវោ តិសតា ឥមេ តិដ្ឋន្តិ បញ្ជលីកតា
បាទេ វីរ បសារេហិ នាគា វន្ទន្តុ សត្ថុនោតិ ។

សេលសុត្តំ សត្តមំ ។

## អដ្ឋមំ សល្លសុត្តំ

(៦៧) អនិមិត្តមនញ្ញាតំ មច្ចានំ ឥធ ជីវិតំ
កសិរញ្ច បរិត្តញ្ច តញ្ច ទុក្ខេន សញ្ញុតំ ។

បពិត្រព្រះមានព្រះភាគ ទ្រង់មានចក្ខុ ពួកយើងបានដល់នូវព្រះអង្គជាទីពឹង ក្នុងថ្ងៃទី ៨ អំពីថ្ងៃនេះ ជាបុគ្គលរៀបរយហើយក្នុងសាសនា របស់ព្រះអង្គ ដោយកាលត្រឹមតែ ៧ រាត្រី ។ ព្រះអង្គជាអ្នកត្រាស់ដឹង ព្រះអង្គជាសាស្ដាចារ្យ ព្រះអង្គជាអ្នកគ្របសង្កត់នូវមារ ជាអ្នកប្រាជ្ញ ព្រះអង្គកាត់បង់អនុសយក្កិលេស ឆ្លងចាកកិលេសបានហើយចំឡងពួកសត្វនេះ ព្រះអង្គបានកន្លងផុតឧបធិហើយ ព្រះអង្គបានទំលាយអាសវៈហើយ ព្រះអង្គជាបុគ្គលដូចសីហៈ មិនមានឧបាទាន បានលះបង់ភ័យនិងសេចក្ដីស្ញប់ស្ញែងហើយ បពិត្រព្រះអង្គជាវីរបុរស ពួកភិក្ខុទាំង ៣០០ រូបនេះធ្វើអញ្ជលី (ចំពោះព្រះអង្គ) សូមព្រះអង្គសណ្ដូកព្រះបាទទាំងគូ ពួកភិក្ខុដ៏ប្រសើរ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសាស្ដា ។

ចប់ សេលសូត្រ ទី ៧ ។

## សល្លសូត្រ ទី ៨

(៦៧) (សេចក្ដីថា ព្រះមានព្រះភាគទ្រង់សំដែងសល្លសូត្រនេះ) ថា ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ មិនមានកំណត់ មិនមានអ្នកណាមួយអាចដឹងបាន ជីវិតនោះជារបស់ក្រផង តិចផង ប្រកបដោយសេចក្ដីទុក្ខផង ។

ន ហិ សោ ឧបក្កមោ អត្ថិ យេន ជាតា ន មិយ្យរេ
ជរម្បិ បត្វា មរណំ ឯវំធម្មា ហិ បាណិនោ ។
ផលានមិវ បក្កានំ បាតោ(១) បបតនា ភយំ
ឯវំ ជាតាន មច្ចានំ និច្ចំ មរណតោ ភយំ ។
យថាបិ កុម្ភការស្ស កតា មត្តិកភាជនា
សព្វេ ភេទនបរិយន្តា ឯវំ មច្ចាន ជីវិតំ ។
ទហរា ច មហន្តា ច យេ ពាលា យេ ច បណ្ឌិតា
សព្វេ មច្ចុវសំ យន្តិ សព្វេ មច្ចុបរាយណា ។
តេសំ មច្ចុបរេតានំ គច្ឆតំ បរលោកតោ
ន បិតា តាយតេ បុត្តំ ញាតី វា បន ញាតកេ ។

---

១ ម. និច្ចំ ។

ពួកសត្វដែលកើតហើយ រមែងមិនស្លាប់ ដោយសេចក្ដីព្យាយាមណា សេចក្ដីព្យាយាមនោះ មិនមានឡើយ ការដល់នូវសេចក្ដីគ្រាំគ្រាហើយស្លាប់តែងមាន ព្រោះពួកសត្វទាំងឡាយ មានយ៉ាងនេះជាធម្មតា ។ ផ្លែឈើទាំងឡាយដែលទុំហើយ តែងមានភ័យអំពីការជ្រុះ ក្នុងពេលព្រឹកយ៉ាងណាមិញ សត្វទាំងឡាយ ដែលកើតហើយ តែងមានសេចក្ដីភ័យ អំពីសេចក្ដីស្លាប់ អស់កាលជានិច្ច យ៉ាងនោះដែរ ។ ភាជន៍ដីទាំងឡាយ ដែលស្មូនធ្វើហើយភាជន៍ទាំងអស់នោះ សុទ្ធតែមានកិរិយាបែកជាទីបំផុត យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។ ពួកជនណា ក្មេងក្ដី ចាស់ក្ដី ពាលក្ដី បណ្ឌិតក្ដី ពួកជនទាំងអស់នោះ តែងលុះក្នុងអំណាចនៃមច្ចុ ពួកជនទាំងអស់ មានមច្ចុទៅស្នាក់ខាងមុខ ។ កាលពួកជនទាំងនោះត្រូវមច្ចុគ្របសង្កត់ហើយ កាលទៅក្នុងបរលោក បិតា ការពារបុត្រ មិនបាន ឬពួកញាតិក៏ការពារញាតិមិនបាន ។

បេក្ខតំ យេវ ញាតីនំ បស្ស លាលប្បតំ បុថុ
ឯកមេកោវ មច្ចានំ គោវជ្ឈោ វិយ និយ្យតិ
ឯវមព្ភាហតោ លោកោ មច្ចុនា ច ជរាយ ច
តស្មា ធីរា ន សោចន្តិ វិទិត្វា លោកបរិយាយំ ។
យស្ស មគ្គំ ន ជានាសិ អាគតស្ស គតស្ស វា
ឧភោ អន្តេ អសម្បស្សំ និរត្ថំ បរិទេវសិ
បរិទេវយមានោ ចេ កិញ្ចិ អត្ថំ(១) ឧទព្វហេ
សម្មុឡ្ហោ ហឹសមត្តានំ កយិរា ចេនំ វិចក្ខណោ ។
ន ហិ រុណ្ណេន សោកេន សន្តិំ បប្បោតិ ចេតសោ
ភិយ្យស្សុប្បជ្ជតេ ទុក្ខំ សរីរំ ចុបហញ្ញតិ(២) ។
កិសោ វិវណ្ណោ ភវតិ ហឹសមត្តានមត្តនា(៣)
ន តេន បេតា បាលេន្តិ និរត្ថា បរិទេវនា ។

---

១ ឱ.ម. ទត្ថំ ។ ២ ឱ. សរីរំ ឧបហញ្ញតិ ។ ៣ ម. ហឹសមត្តានមត្តនា ។

អ្នកចូរមើល នូវការរៀបចាប់ជាច្រើន របស់ពួកញាតិដែលកំពុងអាឡោះអាល័យ បណ្តាសត្វទាំងឡាយ សត្វតែម្នាក់ ៗ ដែលត្រូវមច្ចុនាំទៅ ដូចជាគោ ត្រូវគេសំឡាប់ សត្វលោក ត្រូវមច្ចុនិងជរាគ្របសង្កត់ហើយយ៉ាងនេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ រមែងមិនសោកស្តាយឡើយ ព្រោះដឹងច្បាស់នូវបរិយាយនៃសត្វលោក ។ អ្នកមិនស្គាល់ផ្លូវរបស់សត្វណា ដែលមកឬទៅ មិនឃើញជាក់លាក់នូវចំណែកទាំងពីរ របស់សត្វនោះ អ្នកខ្សឹកខ្សួលឥតអំពើទេ បើបុគ្គល វង្វេងវង្វាន់ ខ្សឹកខ្សួល ផ្តួលខ្លួនហើយបាននូវប្រយោជន៍តិចតួច ម៉្លេះសមអ្នកប្រាជ្ញឈ្លាសវៃគប្បីធ្វើ នូវសេចក្តីខ្សឹកខ្សួលនោះដែរ ។ បុគ្គលមិនមែនដល់នូវការស្ងប់រម្ងាប់ចិត្ត ព្រោះការយំ ការសោកទេ ទុក្ខកើតឡើង ដោយក្រៃលែង ដល់បុគ្គលកាលយំសោកនោះ ទាំងសរីរៈ ក៏លំបាក ។ បុគ្គលដែលផ្តួលខ្លួន ដោយខ្លួនឯង តែងជាអ្នកស្គម អាប់សម្បុរ អ្នកចែកឋានទាំងឡាយ រមែងមិនរស់វិញបាន ដោយការខ្សឹកខ្សួលនោះទេ ការខ្សឹកខ្សួល ជាការឥតអំពើ ។

សោកមប្បជហំ ជន្តុ ភិយ្យោ ទុក្ខំ និគច្ឆតិ
អនុត្ថុនន្តោ កាលកតំ សោកស្ស វសមន្វគូ ។
អញ្ញេបិ បស្ស គមិនេ យថាកម្មូបគេ នរេ
មច្ចុនោ វសមាគម្ម ផន្ទន្តេវិធ បាណិនោ(១) ។
យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថា
ឯតាទិសោ វិនាភាវោ បស្ស លោកស្ស បរិយាយំ ។
អបិ វស្សសតំ(២) ជីវេ ភិយ្យោ វា បន មាណវោ
ញាតិសង្ឃា វិនា ហោតិ ជហាតិ ឥធ ជីវិតំ ។
តស្មា អរហតោ សុត្វា វិនេយ្យ បរិទេវិតំ
បេតំ កាលកតំ ទិស្វា នេសោ(៣) លព្ភា មយា ឥតិ ។
យថា សរណមាទិត្តំ វារិនា បរិនិព្វយេ(៤)
ឯវម្បិ ធីរោ សប្បញ្ញោ បណ្ឌិតោ កុសលោ នរោ

---

១ ឱ·ម. បាណិនេ ។ ២ ឱ. អបិ បេ វស្សសតំ ។ ៣ ឱ. នសោ ។ ៤ ម. បរិនិព្វុតោ ។

សត្វកាលប៉ូរស្តាយបុគ្គល ដែលធ្វើមរណកាល លុះអំណាចសេចក្ដីសោក មិនលះបង់សេចក្ដីសោកចេញទេ រមែងដល់នូវទុក្ខជាយ៉ាងក្រៃលែង ៗ អ្នកចូរមើលសត្វទាំងឡាយមានជីវិតឯទៀតក្នុងលោកនេះ ដែលអន្ទោលទៅតាមកម្មហៀបនឹងទៅ (កាន់បរលោក) បម្រះនទៀល ព្រោះលុះអំណាចនៃមច្ចុ ៗ ពួកសត្វតែងសំគាល់ (ថានឹងមានអាយុវែង ) ដោយអាការណា ៗ ការសំគាល់នោះ រមែងផ្សេងអំពីអាការនោះ ៗ ការព្រាត់និកសប្រុកជដូច្នោះ អ្នកចូលមើលបរិយាយរបស់សត្វលោកចុះ ៗ ទោះបីសត្វដែលរស់នៅអស់មួយរយឆ្នាំ ឬលើសជាង សេចក្ដីព្រាត់ប្រាសចាកពួកញាតិ រមែងមាន (ព្រោះថា) សត្វក្នុងលោកនេះ រមែងលះបោលជីវិត ៗ ព្រោះហេតុនោះ បុគ្គលបានស្ដាប់ (ធម្មទេសនា) របស់ព្រះអរហន្តហើយឃើញអ្នកដែលចែកឋានធ្វើមរណកាលទៅហើយ គប្បីបន្ទោបង់សេចក្ដីខ្សឹកខ្សួលថា អ្នកចែកឋានទៅនុ៎ះ អាត្មាអញឃាត់មិនបានទេ ៗ បុគ្គលគប្បីលត់ផ្ទះដែលភ្លើងឆេះដោយទឹក យ៉ាងណាមិញ នរជនជាអ្នកប្រាជ្ញ ប្រកបដោយប្រាជ្ញា ជាបណ្ឌិតឆ្លៀវឆ្លាស

ខិប្បមុប្បតិតំ សោកំ វាតោ តូលំវ ធំសយេ ។
បរិទេវំ បជប្បញ្ច(១) ទោមនស្សញ្ច អត្តនោ
អត្តនោ សុខមេសានោ អព្ពុឡ្ហេ សល្លមត្តនោ
អព្ពុឡ្ហសល្លោ អសិតោ សន្តឹ បប្បុយ្យ ចេតសោ
សព្ពំ សោកំ អតិក្កន្តោ អសោកោ ហោតិ និព្ពុតោតិ ។

សល្លសុត្តំ អដ្ឋមំ ។

## ៩ វាសេដ្ឋសុត្តំ

(៦៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា(២) ព្រាហ្មណមហាសាលា ឥច្ឆានង្គលេ បដិវសន្តិ សេយ្យថីទំ ចង្កី ព្រាហ្មណោ តារុក្ខោ ព្រាហ្មណោ បោក្ខរសាតិ ព្រាហ្មណោ ជាណុស្សោណិ ព្រាហ្មណោ តោទេយ្យព្រាហ្មណោ អញ្ញេ ច អភិញ្ញាតា ព្រាហ្មណមហាសាលា ។

១ ម. វិជប្បញ្ច ។ ២ ម. ឱ. អភិញ្ញាតា អភិញ្ញាតា ។

គប្បីកំចាត់បង់នូវឆាប់ហ័សនូវសេចក្តីសោក ដែលកើតឡើង ដូចខ្យល់បំប៉ើងប៉ុយគរ ក៏យ៉ាងនោះដែរ ។ បុគ្គលកាល ស្វែងរកសេចក្តីសុខចម្រើនខ្លួន គប្បីដកចេញនូវសរ គឺសេចក្តី ខ្សឹកខ្សួលរបស់ខ្លួន តាំងតណ្ហានិងទោមនស្សរបស់ខ្លួនចេញ បុគ្គលមានសរដកហើយ មិនអាស្រ័យ (ដោយតណ្ហានិង ទិដ្ឋិ) គប្បីដល់នូវសេចក្តីស្ងប់នៃចិត្ត កន្លងផុតសេចក្តីសោក ទាំងអស់ ហើយជាអ្នកមិនមានសោក ជាអ្នករលត់ទុក្ខ ។

ចប់ សល្លសូត្រ ទី ៨ ។

## វាសេដ្ឋសូត្រ ទី ៩

(៦៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងដងព្រៃឈ្មោះឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈ ។ សម័យនោះឯង ពួកព្រាហ្មណមហាសាលជាច្រើនមានឈ្មោះល្បីល្បាញ អាស្រ័យនៅក្នុងស្រុកឈ្មោះឥច្ឆានង្គលៈ គឺចង្កីព្រាហ្មណ៍ តារុក្ខព្រាហ្មណ៍ បោក្ខរសាតិព្រាហ្មណ៍ ជាណុស្សោណិព្រាហ្មណ៍ តោទេយ្យព្រាហ្មណ៍ និងពួកព្រាហ្មណមហាសាលឯទៀត ដែលមានឈ្មោះល្បីល្បាញ ។

អថខោ វាសេដ្ឋភារទ្វាជានំ មាណវានំ ជង្ឃាវិហារំ អនុចង្កមន្តានំ អនុវិចរន្តានំ(១) អយមន្តរាកថា ឧទបាទិ កថំ ភោ ព្រាហ្មណោ ហោតីតិ ។ ភារទ្វាជោ មាណវោ ឯវមាហ យតោ ខោ ភោ ឧភតោ សុជាតោ មាតិតោ(២) ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឯត្តាវតា ខោ(៣) ព្រាហ្មណោ ហោតីតិ ។ វាសេដ្ឋោ មាណវោ ឯវមាហ យតោ ខោ ភោ សីលវា ច ហោតិ វត្តសម្បន្នោ ច ឯត្តាវតា ខោ ភោ ព្រាហ្មណោ ហោតីតិ ។ នេវ ខោ អសក្ខិ ភារទ្វាជោ មាណវោ វាសេដ្ឋំ មាណវំ សញ្ញាបេតុំ ន បន អសក្ខិ វាសេដ្ឋោ មាណវោ ភារទ្វាជំ មាណវំ សញ្ញាបេតុំ ។ អថខោ វាសេដ្ឋោ មាណវោ ភារទ្វាជំ មាណវំ អាមន្តេសិ អយំ ភោ(៤) ភារទ្វាជ សមណោ គោតមោ

១ ឱ. អនុចង្កមមានានំ អនុវិចរមានានំ ។ ២ ឱ. សុ. ជាតោ ហោតិ មាតិតោ ។ ៣ ឱ. ម. ឯត្តាវតា ខោ ។ ៤ ឱ. អយំ ខោ ។

គ្រានោះ វាសេដ្ឋមាណព និងភារទ្វាជមាណព កំពុងដើរទៅ ដើរមក សម្រាកស្មង ក៏កើតអន្តរាកថានេះឡើងថា ម្នាលគ្នាយើង បុគ្គលឈ្មោះថាជាព្រាហ្មណ៍ តើដោយប្រការដូចម្តេច ។ ភារទ្វាជមាណពនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន បុគ្គលដែលមានកំណើតល្អ ទាំងពីរចំណែក គឺខាងមាតានិងខាងបិតា ជាអ្នកកើតក្នុងផ្ទៃ របស់ព្រាហ្មណីដែលបរិសុទ្ធ ដរាបអំពីគូទៃជីដូនជីតា ៧ ជំណាមក មិនមានអ្នកណាពោលទោសតិះដៀល ដោយការពោលអំពីជាតិបាន ម្នាលអ្នកដ៏ចំរើន បុគ្គលបានឈ្មោះថាព្រាហ្មណ៍ ដោយហេតុប៉ុណ្ណេះឯង ។ វាសេដ្ឋមាណព និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន លុះតែបុគ្គលមានសីលផង បរិបូណ៌ដោយវត្តផង ម្នាលអ្នកដ៏ចំរើន បុគ្គលនោះទើបហៅថាព្រាហ្មណ៍ ដោយហេតុប៉ុណ្ណេះឯង ។ ភារទ្វាជមាណព មិនអាចញ៉ាំងវាសេដ្ឋមាណព ឲ្យយល់ឃើញបាន ទាំងវាសេដ្ឋមាណព ក៏មិនអាចញ៉ាំងភារទ្វាជមាណព ឲ្យយល់ឃើញបាន ។ គ្រានោះ វាសេដ្ឋមាណព ហៅភារទ្វាជមាណពថា ម្នាលភារទ្វាជៈដ៏ចំរើន ព្រះសមណគោតមនេះ

សក្យបុត្តោ សក្យកុលា បព្វជិតោ ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា ។ បេ ។ ពុទ្ធោ ភគវាតិ អាយាម(១) ភារទ្វាជ យេន សមណោ គោតមោ តេនុបសង្កមិស្សាម ឧបសង្កមិត្វា ឯតមត្ថំ(២) បុច្ឆិស្សាម យថា នោ សមណោ គោតមោ ព្យាករិស្សតិ តថា នំ ធារេស្សាមាតិ ។ ឯវំ ភោតិ ខោ ភារទ្វាជោ មាណវោ វាសេដ្ឋស្ស មាណវស្ស បច្ចស្សោសិ ។ អថ ខោ វាសេដ្ឋភារទ្វាជមាណវា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ វាសេដ្ឋោ មាណវោ ភគវន្តំ គាថាហិ អជ្ឈភាសិ

---

១ ឱ. អាយាម ភោ ។ ២ ឱ. ឧបសង្កមិត្វា សមណំ គោតមំ ឯតមត្ថំ ។ ម. ឧបសង្កមិត្វា សមណំ គោតមំ ឯតំ ។

ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស (ឥឡូវនេះ) គង់នៅក្នុងដងព្រៃឥច្ឆានង្គលៈ ជិតស្រុកឈ្មោះឥច្ឆានង្គលៈ កិត្តិស័ព្ទដ៏ពីរោះរបស់ព្រះគោតមដ៏ចំរើននោះ ខ្ចរខ្ចាយសុះសាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គត្រាស់ដឹងចតុរារិយសច្ច ព្រះអង្គលែងត្រឡប់មកកើតក្នុងភពថ្មីទៀត ម្នាលភារទ្វាជៈ មកទៅ យើងនឹងចូលសំដៅទៅត្រង់ទីដែលព្រះសមណគោតមគង់ លុះចូលទៅដល់ហើយនឹងសួរសេចក្តីនេះ ព្រះសមណគោតមនឹងដោះស្រាយឲ្យយើងយ៉ាងណា យើងនឹងចាំទុកនូវសេចក្តីនោះយ៉ាងនោះ ។ ភារទ្វាជមាណព ទទួលស្តាប់ពាក្យរបស់វាសេដ្ឋមាណពថា អើអ្នក ។ គ្រានោះ វាសេដ្ឋ-មាណពនឹងភារទ្វាជមាណព ចូលសំដៅទៅត្រង់កន្លែងដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួរឲ្យរលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ វាសេដ្ឋមាណព លុះអង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា

(២៩)អនុញ្ញាតប្បដិញ្ញាតា តេវិជ្ជា មយមស្សុ ភោ
អហំ បោក្ខរសាតិស្ស តារុក្ខស្សាយ មាណវោ ។
តេវិជ្ជានំ យទក្ខាតំ តត្រ កេវលិនោស្មសេ
បទកស្មា វេយ្យាករណា ជប្បេ អាចរិយសាទិសា ។
តេសន្នោ ជាតិវាទម្ហិ វិវាទោ អត្ថិ គោតម
ជាតិយា ព្រាហ្មណោ ហោតិ ភារទ្វាជោ ឥតិ ភាសតិ
អហញ្ច កម្មុនា ព្រូមិ ឯវំ ជានាហិ ចក្ខុម ។
តេ ន សក្កោម សញ្ញាតុំ(១) អញ្ញមញ្ញំ មយំ ឧភោ
ភវន្តំ បុដ្ឋុមាគម្មា សម្ពុទ្ធំ ឥតិ វិស្សុតំ
ចន្ទំ យថា ខយាតីតំ បេច្ច បញ្ជលិកា ជនា
(២)
វន្ទមានា នមស្សន្តិ ឯវំ លោកស្មិំ គោតម ។

---

១ ឱ. សញ្ញាតុំ ។ ម. សញ្ញាបេតុំ ។ ២ ឱ. លោកស្មិំ គោតមំ ។

(៦៩)បពិត្រព្រះអង្គដ៏ចំរើន យើងជាអ្នកមានត្រៃវិជ្ជា ដែលអាចារ្យអនុញ្ញាតនឹងប្តេជ្ញាហើយ ដោយពិត ខ្ញុំព្រះអង្គជាសិស្សបោក្ខរសាតិព្រាហ្មណ៍ មាណពនេះ ជាសិស្សរបស់តារុក្ខព្រាហ្មណ៍ ។ ពាក្យណារបស់អ្នកមានត្រៃវិជ្ជាទាំងឡាយ ដែលអាចារ្យបានប្រាប់ហើយ ពួកយើងជាអ្នកសម្រេចក្នុងពាក្យនោះហើយ យើងទាំងឡាយជាអ្នកចេះបទ ចេះវេយ្យាករណ៍ក្នុងវេទ ប្រហែលនឹងអាចារ្យ ។ បពិត្រព្រះគោតម ពួកយើងនោះមានការជជែកគ្នាក្នុងការពោលអំពីជាតិ ភារទ្វាជមាណពនិយាយថា បុគ្គល ជាព្រាហ្មណ៍ ព្រោះជាតិ ។ ឯខ្ញុំព្រះអង្គនិយាយថា បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះកម្ម បពិត្រព្រះអង្គ ជាបុគ្គលមានចក្ខុ សូមព្រះអង្គជ្រាបយ៉ាងនេះ ។ យើងទាំងពីរនាក់នោះ មិនអាចញ៉ាំងគ្នានឹងគ្នាឲ្យយល់ឃើញបានទេ ( ព្រោះហេតុនោះ ) ទើបយើងទាំងឡាយមក ដើម្បីសួរព្រះអង្គដ៏ចំរើន ដែលល្បីល្បាញថាជាអ្នកត្រាស់ដឹងឯង បពិត្រព្រះគោតម ពួកជន ផ្គងអញ្ជលី ចូលទៅ កាលថ្វាយបង្គំ ក៏ថ្វាយបង្គំព្រះចន្ទ្រ ដែលកន្លងនូវការអស់ទៅនៃងងឹត (ព្រះចន្ទពេញវង្ស) យ៉ាងណាមិញ ពួកជនក្នុងលោក (ក៏ថ្វាយបង្គំព្រះអង្គ) យ៉ាងនោះដែរ ។

ចក្ខុំ លោកេ សមុប្បន្នំ មយំ បុច្ឆាម គោតមំ
ជាតិតោ(១) ព្រាហ្មណោ ហោតិ ឧទាហុ ភវតិ កម្មុនា
អជានតំ នោ បព្រូហិ យថា ជានេមុ ព្រាហ្មណំ ។
តេសំ វោហំ ព្យក្ខិស្សំ (វាសេដ្ឋាតិ ភគវា)
អនុបុព្វំ យថាតថំ
ជាតិវិភង្គំ បាណានំ អញ្ញមញ្ញា ហិ ជាតិយោ ។
តិណរុក្ខេបិ ជានាថ ន ចាបិ បដិជានរេ
លិង្គំ ជាតិមយំ តេសំ អញ្ញមញ្ញា ហិ ជាតិយោ ។
តតោ កីដេ បដង្គេ ច យាវ កុន្ថកិបិល្លិកេ
លិង្គំ ជាតិមយំ តេសំ អញ្ញមញ្ញា ហិ ជាតិយោ ។
ចតុប្បទេបិ ជានាថ ខុទ្ទកេ ច មហល្លកេ
លិង្គំ ជាតិមយំ តេសំ អញ្ញមញ្ញា ហិ ជាតិយោ ។

---

១ ឱ. ម. ជាតិយា ។

ពួកយើង សូមសួរព្រះគោតម ដែលមានចក្ខុកើតហើយក្នុងលោក បុគ្គលឈ្មោះថាព្រាហ្មណ៍ ព្រោះជាតិឬព្រោះកម្ម សូមព្រះអង្គសំដែងប្រាប់ពួកយើង ដែលជាអ្នកមិនទាន់ស្គាល់ឲ្យទាល់តែពួកយើងស្គាល់ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ) បើដូច្នោះ តថាគតនឹងសំដែងឲ្យពិស្តារអំពីជាតិ របស់សត្វទាំងឡាយ តាមពិត ដោយលំដាប់ ដល់អ្នកទាំងឡាយនោះ ធម្មតា សត្វទាំងឡាយរមែងមានជាតិផ្សេង ៗ គ្នា ។ អ្នកទាំងឡាយស្គាល់ស្មៅនិងឈើ (ឬទេ) ឬក៏មិនដែលប្តេជ្ញាថាស្មៅនិងឈើទេ លិង្គគឺភេទរបស់ស្មៅនិងឈើទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះជាសត្វទាំងឡាយមានជាតិផ្សេងៗគ្នា ។ លិង្គគឺភេទតាំងអំពីកណ្តូបនិងមមង់រហូតដល់ស្រមោចខ្មៅ និងស្រមោចក្រហម ទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះជាសត្វទាំងឡាយមានជាតិផ្សេងៗគ្នា ។ អ្នកទាំងឡាយស្គាល់ពួកសត្វមានជើងបួន ទាំងតូចទាំងធំ (ឬទេ) លិង្គគឺភេទរបស់សត្វទាំងនោះតែងសម្រេចអំពីជាតិ ព្រោះជាសត្វទាំងឡាយមានជាតិផ្សេងៗគ្នា ។

សុត្តនិបាតេ តតិយស្ស មហាវគ្គស្ស នវមំ វាសេដ្ឋសុត្តំ

បាទូទរេបិ ជានាថ ឧរគេ ទីឃបិដ្ឋិកេ
លិង្គំ ជាតិមយំ តេសំ អញ្ញមញ្ញា ហិ ជាតិយោ ។
តតោ មច្ឆេបិ ជានាថ ឱទកេ(១) វារិគោចរេ
លិង្គំ ជាតិមយំ តេសំ អញ្ញមញ្ញា ហិ ជាតិយោ ។
តតោ បក្ខីបិ ជានាថ បត្តយានេ វិហង្គមេ
លិង្គំ ជាតិមយំ តេសំ អញ្ញមញ្ញា ហិ ជាតិយោ ។
យថា ឯតាសុ ជាតីសុ លិង្គំ ជាតិមយំ បុថុ
ឯវំ នត្ថិ មនុស្សេសុ លិង្គំ ជាតិមយំ បុថុ ។
ន កេសេហិ ន សីសេហិ(២) ន កណ្ណេហិ ន អក្ខិហិ

---
១ ម. ឧទកេ ។ ២ ម. ប. សីសេន ។

អ្នកទាំងឡាយ ស្គាល់ពស់មានទ្រូងជាជើង មានខ្នងវែង (ឬទេ) លិង្គគឺភេទរបស់ពស់ទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេង ៗ គ្នា ។

លំដាប់អំពីនោះ អ្នកទាំងឡាយ ស្គាល់ពួកត្រីក្នុងទឹក មានទឹកជាគោចរ (ឬទេ) លិង្គគឺភេទរបស់ត្រីទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថាសត្វទាំងឡាយមានជាតិផ្សេងៗគ្នា ។

លំដាប់អំពីនោះ អ្នកទាំងឡាយ ស្គាល់ពួកសត្វស្លាប មានស្លាបជាយាន ដែលហើរឯអាកាស (ឬទេ) លិង្គគឺភេទរបស់សត្វស្លាបទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗគ្នា ។

លិង្គគឺភេទក្នុងជាតិទាំងឡាយនោះ សម្រេចអំពីជាតិជាច្រើន យ៉ាងណាមិញ លិង្គគឺភេទ ក្នុងមនុស្សទាំងឡាយ សម្រេចអំពីជាតិមិនច្រើនយ៉ាងនោះទេ ។ លិង្គគឺភេទមិនហៅព្រោះសក់ទាំងឡាយ មិនហៅព្រោះក្បាលទាំងឡាយ មិនហៅព្រោះត្រចៀកទាំងឡាយ មិនហៅព្រោះភ្នែកទាំងឡាយ

ន មុខេន ន នាសាយ ន ឱដ្ឋេហិ ភមូហិ វា

ន គីវាយ ន អំសេហិ ន ឧទរេន ន បិដ្ឋិយា

ន សោណិយា ន ឧរសា ន សម្ពាធា ន មេថុនា(១)

ន ហត្ថេហិ ន បាទេហិ ន អង្គុលីហិ នខេហិ វា

ន ជង្ឃាហិ ន ឩរូហិ ន វណ្ណេន សរេន វា

លិង្គំ ជាតិមយំ នេវ យថា អញ្ញាសុ ជាតិសុ ។

បច្ចត្តំ សសរីរេសុ មនុស្សេស្វេតំ ន វិជ្ជតិ

វោការញ្ច(២) មនុស្សេសុ សមញ្ញាយ បវុច្ចតិ ។

---

១ ឱ. ន សម្ពាធេ ន មេថុនេ ។ ២ ម. វោហារញ្ច ។

មិនហៅ ព្រោះប្រមាត់ មិនហៅ ព្រោះប្រមុះ មិនហៅ ព្រោះបបូរមាត់ទាំងឡាយ មិនហៅ ព្រោះចិញ្ចើមទាំងឡាយ មិនហៅព្រោះក មិនហៅព្រោះស្មាទាំងឡាយ មិនហៅព្រោះពោះ មិនហៅព្រោះខ្នង មិនហៅ ព្រោះត្រគាក មិនហៅ ព្រោះទ្រូង មិនហៅព្រោះទីបង្អៀត មិនហៅ ព្រោះមេថុន មិនហៅ ព្រោះដៃទាំងឡាយ មិនហៅ ព្រោះជើងទាំងឡាយ មិនហៅ ព្រោះម្រាមទាំងឡាយ មិនហៅ ព្រោះក្រចកទាំងឡាយ មិនហៅ ព្រោះស្មងទាំងឡាយ មិនហៅព្រោះភ្លៅទាំងឡាយ មិនហៅព្រោះពណ៌ មិនហៅព្រោះសំឡេងទេ លិង្គគឺភេទរបស់មនុស្ស សម្រេចអំពីជាតិ មិនដូចជាភេទក្នុងជាតិទាំងឡាយឯទៀតៗ ទេ ៗ លិង្គគឺភេទផ្សេងដោយសណ្ឋានមានសក់ជាដើមដូចជាលិង្គគឺភេទតិរច្ឆាននុ៎ះ មិនមានប្រាកដក្នុងសរីរៈ របស់ខ្លួនទាំងឡាយ ក្នុងពួកមនុស្សទេ ពាក្យសម្រាប់ហៅ (ថាព្រាហ្មណ៍ជាដើម) គេតែងហៅតាមឈ្មោះ ក្នុងមនុស្សទាំងឡាយ ៗ

សុត្តនិបាតេ តតិយស្ស មហាវគ្គស្ស នវមំ វាសេដ្ឋសុត្តំ

យោ ហិ កោចិ មនុស្សេសុ គោរក្ខំ ឧបជីវតិ
ឯវំ វាសេដ្ឋ ជានាហិ កស្សកោ សោ ន ព្រាហ្មណោ ។

យោ ហិ កោចិ មនុស្សេសុ បុថុសិប្បេន ជីវតិ
ឯវំ វាសេដ្ឋ ជានាហិ សិប្បិកោ សោ ន ព្រាហ្មណោ ។

យោ ហិ កោចិ មនុស្សេសុ វោហារំ ឧបជីវតិ
ឯវំ វាសេដ្ឋ ជានាហិ វាណិជោ សោ ន ព្រាហ្មណោ ។

យោ ហិ កោចិ មនុស្សេសុ បរបេស្សេន ជីវតិ
ឯវំ វាសេដ្ឋ ជានាហិ បេស្សិកោ សោ ន ព្រាហ្មណោ ។

យោ ហិ កោចិ មនុស្សេសុ អទិន្នំ ឧបជីវតិ
ឯវំ វាសេដ្ឋ ជានាហិ ចោរោ ឯសោ ន ព្រាហ្មណោ ។

បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការរក្សាស្រែចំការ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកភ្ជួររាស់ មិនមែនព្រាហ្មណ៍ទេ ។ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយសិល្បៈច្រើនយ៉ាង ម្នាលវា-សេដ្ឋ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកចិញ្ចឹមជីវិតដោយសិល្បៈ មិនមែនព្រាហ្មណ៍ទេ ។ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការជួញប្រែ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាពាណិជ មិនមែនព្រាហ្មណ៍ទេ ។ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការបំរើអ្នកដទៃ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកបំរើ មិនមែនព្រាហ្មណ៍ទេ ។ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការលួចទ្រព្យគេ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាចោរ មិនមែនព្រាហ្មណ៍ទេ ។

យោ ហិ កោចិ មនុស្សេសុ ឥស្សត្ថំ ឧបជីវតិ
ឯវំ វាសេដ្ឋ ជានាហិ យោធាជីវោ ន ព្រាហ្មណោ ។
យោ ហិ កោចិ មនុស្សេសុ បោរោហិច្ចេន ជីវតិ
ឯវំ វាសេដ្ឋ ជានាហិ យាជកោ សោ ន ព្រាហ្មណោ ។
យោ ហិ កោចិ មនុស្សេសុ គាមំ រដ្ឋញ្ច ភុញ្ជតិ
ឯវំ វាសេដ្ឋ ជានាហិ រាជា ឯសោ ន ព្រាហ្មណោ ។
ន ចាហំ ព្រាហ្មណំ ព្រូមិ យោនិជំ មត្តិកាសម្ភវំ(១)
ភោវាទិ នាម សោ ហោតិ សចេ ហោតិ សកិញ្ចនោ
អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។
សព្វសំយោជនំ ឆេត្វា យោ វេ ន បរិតស្សតិ
សង្គាតិគំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ឱ. ម. មត្តិសម្ភវំ ។

បណ្ដាមនុស្សទាំងឡាយ ណាមួយ ចិញ្ចឹមជីវិតដោយភាពជាអ្នកកាន់អាវុធ ( ទាហាន ) ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាអ្នកចិញ្ចឹមជីវិតដោយភាពជាទាហាន មិនមែនព្រាហ្មណ៍ទេ ។ បណ្ដាមនុស្សទាំងឡាយ ណាមួយ ចិញ្ចឹមជីវិតដោយភាពជាបុរោហិត ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះ ជាអ្នកបូជា មិនមែនព្រាហ្មណ៍ទេ ។ បណ្ដាមនុស្សទាំងឡាយ ណាមួយ បរិភោគនូវធរណីផលដែលកើតអំពីស្រុក ឬដែន (ស្ដេច) ប្រើប្រាស់ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាស្ដេច មិនមែនព្រាហ្មណ៍ទេ ។ តថាគតមិនហៅបុគ្គលដែលមានកំណើតកើតអំពីមាតា ថាជាព្រាហ្មណ៍ទេ បុគ្គលនោះ ឈ្មោះថា ភោវាទី បុគ្គលនោះប្រកប ដោយគ្រឿងកង្វល់ តថាគតហៅបុគ្គល ដែលមិនមានគ្រឿងកង្វល់ មិនមានកំណាន់នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា កាត់សំយោជនៈទាំងអស់ហើយ មិនតក់ស្លុត តថាគត ហៅបុគ្គលអ្នកកន្លងសង្គហធម៌ ប្រាសចាកយោគៈ ទាំង ៤ នោះ ថាជាព្រាហ្មណ៍ ។

ឆេត្វា នន្ទឹ វរត្តញ្ច សន្ទានំ សហនុក្កមំ
ឧក្ខិត្តបលិឃំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។
អក្កោសំ វធពន្ធញ្ច អទុដ្ឋោ យោ តិតិក្ខតិ
ខន្តីពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ ។
អក្កោធនំ វត្តវន្តំ(១) សីលវន្តំ អនុស្សទំ
ទន្តំ អន្តិមសារីរំ តមហំ ព្រូមិ ព្រាហ្មណំ ។
វារិ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ
យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។
យោ ទុក្ខស្ស បជានាតិ ឥធេវ ខយមត្តនោ
បន្នភារំ វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

១ ឧ. ម. វតវន្តំ ។

បុគ្គលណា កាត់ខ្សែជ្រោមគឺសេចក្តីក្រោធផង ព្រ័ត្រគឺតណ្ហាផង ទីតគឺមិច្ឆាទិដ្ឋិ ព្រមទាំងអនុសយក្កិលេសផង ជាអ្នកបានដករនុកគឺអវិជ្ជា ត្រាស់ដឹងសច្ចធម៌ ៤ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនប្រទូស្ត បេះអត់ធ្មត់ចំពោះពាក្យជេរផង ការវាយនិងការចងផង តថាគតហៅបុគ្គល អ្នកមានខន្តិធម៌ជាកំឡាំង មានខន្តិធម៌ជាហែ៍ពលនោះ ថាជាព្រាហ្មណ៍ ។

តថាគត ហៅបុគ្គលមិនខឹង ជាអ្នកមានវត្ត មានសីលធម៌ មិនមានចំហាយគឺតណ្ហា មានឥន្ទ្រិយបានទូន្មាន មានសរីរៈកើតក្នុងទីបំផុតនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនជាប់ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងនៃដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដឹងច្បាស់ នូវការអស់ទៅនៃសេចក្តីទុក្ខរបស់ខ្លួន ក្នុងលោកនេះ តថាគតហៅបុគ្គល អ្នកដាក់ភារៈចុះហើយ ប្រាសចាកយោគៈនោះ ថាជាព្រាហ្មណ៍ ។

គម្ភីរបញ្ញំ មេធាវឹ មគ្គាមគ្គស្ស កោវិទំ
ឧត្តមត្ថំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

អសំសដ្ឋំ គហដ្ឋេហិ អនាគារេហិ ចូភយំ
អនោកសារឹ អប្បិច្ឆំ(១) តមហំ ព្រូមិ ព្រាហ្មណំ ។

និធាយ ទណ្ឌំ ភូតេសុ តសេសុ ថាវរេសុ ច
យោ ន ហន្តិ ន ឃាតេតិ តមហំ ព្រូមិ ព្រាហ្មណំ ។

អវិរុទ្ធំ វិរុទ្ធេសុ អត្តទណ្ឌេសុ និព្វុតំ
សាទានេសុ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

យស្ស រាគោ ច ទោសោ ច មានោ មក្ខោ ច បាតិតោ
សាសបោរិវ អារគ្គា តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ម. អនោកសារឹមប្បិច្ឆំ ។

តថាគតហៅបុគ្គល មានប្រាជ្ញាជ្រាលជ្រៅ មានប្រាជ្ញាធ្លុះធ្លាយ ឆ្លៀវឆ្លាសក្នុងមគ្គនិងមិនមែនមគ្គ បានសម្រេចប្រយោជន៍ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល អ្នកមិនច្រឡូកច្រឡំ ដោយបុគ្គលពីរពួក គឺគ្រហស្ថ ១ បព្វជិត ១ ដែលត្រាច់ទៅដោយមិនប្រកាន់លំនៅ មិនមានសេចក្ដីប្រាថ្នានោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា ដាក់ចេញនូវអាជ្ញា ក្នុងពួកសត្វអ្នកតក់ស្លុត នឹងពួកសត្វនឹងនួន មិនសម្លាប់ មិនបៀតបៀនសត្វ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គល អ្នកមិនមានគំនុំ ក្នុងពួកជនដែលមានគំនុំ អ្នកមានចិត្តត្រជាក់ ចំពោះអាជ្ញារបស់ខ្លួន ជាអ្នកមិនប្រកាន់ក្នុងពួកជនដែលប្រកប ដោយអំពើគួរប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា បានទំលាក់ចោលចេញនូវរាគៈ ទោសៈ មានះ នឹងមក្ខៈ ដូចគ្រាប់ស្ពៃ ដែលធ្លាក់អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

សុត្តនិបាតេ តតិយស្ស មហាវគ្គស្ស នវមំ វាសេដ្ឋសុត្តំ

អកក្កសំ វិញ្ញាបនិំ គិរំ សច្ចំ ឧទីរយេ
យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។
យោ ច ទីឃំវ រស្សំ វា អណុំថូលំ សុភាសុភំ
លោកេ អទិន្នំ នាទិយតិ តមហំ ព្រូមិ ព្រាហ្មណំ ។
អាសា យស្ស ន វិជ្ជន្តិ អស្មឹ លោកេ បរម្ហិ ច
និរាសយំ(១) វិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
យស្សាលយា ន វិជ្ជន្តិ អញ្ញាយ អកថង្កថី
អមតោគធំ អនុប្បត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។
យោ ច បុញ្ញញ្ច បាបញ្ច ឧភោ សង្គំ ឧបច្ចគា
អសោកំ វិរជំ សុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ម. និរាសាសំ ។

បុគ្គលណា ពោលវាចាមិនគ្រគោះ វាចាញុំាងគេឲ្យស្គាល់ច្បាស់នូវប្រយោជន៍ ជាសំដីពិត ដែលមិនញុំាងគេឲ្យបំពាក់ចិត្តតិចតួច (ដោយអំណាចញុំាងគេឲ្យខឹង) តថាគត ហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនកាន់យកទ្រព្យដែលគេមិនបានឲ្យ ទោះជាទ្រព្យវែងក្តី ខ្លីក្តី តូចក្តី ធំក្តី ល្អនឹងមិនល្អក្តី ក្នុងលោក តថាគត ហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនមានសេចក្តីប៉ុនប៉ង ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី តថាគតហៅបុគ្គល អ្នកមិនមានសេចក្តីប៉ុនប៉ង ប្រាសចាកកិលេសនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនមានសេចក្តីអាល័យ មិនមានការងឿងឆ្ងល់ ព្រោះដឹងច្បាស់ តថាគតហៅបុគ្គល អ្នកដល់នូវធម៌ជាគ្រឿងឈមទៅរកព្រះនិព្វានឈ្មោះអមតៈនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា (កាត់បង់) អំពើទាំងពីរ គឺបុណ្យ១ បាប១ កន្លងផុតនូវសង្គធម៌ តថាគតហៅបុគ្គល អ្នកមិនមានសេចក្តីសោក ប្រាសចាកធូលីគឺរាគៈជាដើម ជាបុគ្គលបរិសុទ្ធនោះ ថាជាព្រាហ្មណ៍ ។

ចន្ទំវ វិមលំ សុទ្ធំ វិប្បសន្នមនាវិលំ
នន្ទីភវបរិក្ខីណំ(១) តមហំ ព្រូមិ ព្រាហ្មណំ ។
យោមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា
តិណ្ណោ បារគតោ ឈាយី អនេជោ អកថង្កថី
អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។
យោធ កាមេ បហាត្វាន អនាគារោ បរិព្វជេ
កាមភវបរិក្ខីណំ(២) តមហំ ព្រូមិ ព្រាហ្មណំ ។
យោធ តណ្ហំ បហាត្វាន អនាគារោ បរិព្វជេ
តណ្ហាភវបរិក្ខីណំ តមហំ ព្រូមិ ព្រាហ្មណំ ។
ហិត្វា មានុសកំ យោគំ ទិព្វំ យោគំ ឧបច្ចគា
សព្វយោគវិសំយុត្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ម. នន្ទិភវបរិក្ខីណំ ។ ២ ឱ. ម. កាមភវបរិក្ខីណំ ។

តថាគត ហៅអ្នកស្អាត ដូចព្រះចន្ទ្រ ប្រាសចាកមន្ទិល មានចិត្តថ្លា មិនល្អក់ដោយកិលេស មានតណ្ហា ក្នុងភពអស់ហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណាកន្លងនូវផ្លូវវាងគឺរាគៈ នូវផ្លូវទុគ៌មគឺកិលេស នូវសង្សារវដ្ត នូវមោហៈ ជាអ្នកឆ្លង ( នូវឱឃៈទាំង ៤ ) បានដល់ត្រើយគឺព្រះនិព្វាន ជាអ្នកមានឈាន មិនមានសេចក្តីញាប់ញ័រ មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេស តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា លះកាមទាំងឡាយក្នុងលោកនេះ ជាអ្នកមិនមានផ្ទះ បួស តថាគតហៅបុគ្គល អ្នកមានកាមរាគៈអស់ហើយនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា បានលះតណ្ហាក្នុងលោកនេះ ជាអ្នកមិនមានផ្ទះតថាគតហៅបុគ្គលដែលមានតណ្ហានិងភពអស់ហើយនោះថាជាព្រាហ្មណ៍ ។

បុគ្គលណា លះយោគៈ (១) ជារបស់មនុស្ស កន្លងផុតនូវយោគៈ (២) របស់ទិព្វ តថាគតហៅបុគ្គល ដែលប្រាសចាកយោគៈទាំងអស់នោះ ថាជាព្រាហ្មណ៍ ។

---

១-២ អាយុនឹងកាមគុណប្រាំ ។ អដ្ឋកថា ។

ហិត្វា រតិញ្ច អរតិញ្ច សីតិភូតំ និរូបធឹ

សព្វលោកាភិភុំ វីរំ តមហំ ព្រូមិ ព្រាហ្មណំ ។

ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ

អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

យស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា

ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។

យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ

អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។

ឧសភំ បវរំ ធីរំ(១) មហេសឹ វិជិតាវិនំ

អនេជំ ន្ហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ ។

---

១ ឱ. វីរំ ។

តថាគតហៅបុគ្គល អ្នកលះសេចក្តីត្រេកអរ (ក្នុងកាមគុណ) នឹងសេចក្តីអផ្សុក មានចិត្តត្រជាក់ មិនមានឧបធិ គ្របសង្កត់នូវលោកទាំងអស់ ជាអ្នកមានព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា បានដឹងច្បាស់នូវចុតិនឹងបដិសន្ធិ របស់សត្វទាំងឡាយ ដោយសព្វគ្រប់ តថាគតហៅបុគ្គល អ្នកមិនជាប់ចំពាក់ មានដំណើរល្អ ត្រាស់ដឹងសច្ចធម៌នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វនឹងមនុស្សទាំងឡាយ មិនដឹងគតិ របស់បុគ្គលណា តថាគតហៅបុគ្គល ដែលអស់អាសវៈហើយ ឆ្ងាយចាកកិលេសនោះ ថាជាព្រាហ្មណ៍ ។

បុគ្គលណា មិនមានសេចក្តីកង្វល់គឺកិលេស មានរាគៈជាដើម ក្នុងអតីតក្ខន្ធ អនាគតក្ខន្ធ នឹងបច្ចុប្បន្នក្ខន្ធ តថាគតហៅបុគ្គល ដែលមិនមានគ្រឿងកង្វល់ មិនមានការប្រកាន់ស្អិតនោះ ថាជាព្រាហ្មណ៍ ។

តថាគតហៅបុគ្គលអ្នកអង់អាចដូចគោឧសភ អ្នកប្រសើរ មានប្រាជ្ញា ស្វែងរកគុណដ៏ធំ មានជ័យជំនះ មិនមានសេចក្តីញាប់ញ័រ ងូតលាង (នូវកិលេស) ត្រាស់ដឹងសច្ចធម៌នោះ ថាជាព្រាហ្មណ៍ ។

បុព្វេនិវាសំ យោ វេទិ   សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ   តមហំ ព្រូមិ ព្រាហ្មណំ ។
សមញ្ញា ហេសា លោកស្មឹ   នាមគោត្តំ បកប្បិតំ
សម្មុច្ចា(១) សមុទាគតំ   តត្ថ តត្ថ បកប្បិតំ ។
ទីឃរត្តមនុសយិតំ   ទិដ្ឋិគតមជានតំ

អជានន្តា នោ បព្រូហន្តិ(២) ជាតិយា ហោតិ ព្រាហ្មណោ ។
ន ជច្ចា ព្រាហ្មណោ ហោតិ ន ជច្ចា ហោតិ អព្រាហ្មណោ ។
កម្មុនា ព្រាហ្មណោ ហោតិ កម្មុនា ហោតិ អព្រាហ្មណោ ។
កស្សកោ កម្មុនា ហោតិ សិប្បិកោ ហោតិ កម្មុនា
វាណិជោ កម្មុនា ហោតិ បេស្សិកោ ហោតិ កម្មុនា ។

---

១ ម. សមញ្ញា ។ ២ ខ. បព្រុវន្តិ ។

បុគ្គលណា ដឹងច្បាស់នូវបុព្វេនិវាសផង ឃើញឋានសួគ៌ផង អបាយផង ទាំងដល់នូវធម៌ជាទីក្ស័យនៃជាតិ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

នាមនិងគោត្រណា ដែលគេបានកំណត់ទុកហើយ (ថាព្រាហ្មណ៍ ក្សត្រិយ៍) នេះគ្រាន់តែជាឈ្មោះ (ជាបញ្ញត្តិវោហារ) ក្នុងលោក (ព្រោះនាមនិងគោត្រនោះ) គឺពួកញាតិសាលោហិត បានផ្សំផ្គុំកំណត់ទុកហើយ ក្នុងកាលដែលកើតមកនោះៗ ។

ទិដ្ឋិរបស់ពួកជនដែលមិនដឹង តែងដេកត្រាំ អស់កាលអង្វែង ពួកជនដែលមិនដឹងហ្នឹងឯង តែងនាំគ្នានិយាយថា បុគ្គលឈ្មោះថាព្រាហ្មណ៍ ព្រោះជាតិ ។

បុគ្គលមិនមែនឈ្មោះថាព្រាហ្មណ៍ ព្រោះជាតិទេ បុគ្គលមិនមែនព្រាហ្មណ៍ ក៏មិនមែនព្រោះជាតិដែរ បុគ្គលឈ្មោះថាព្រាហ្មណ៍ ព្រោះកម្ម (ការធ្វើ) ឈ្មោះថាមិនមែនព្រាហ្មណ៍ ក៏ព្រោះកម្ម ។

បុគ្គលឈ្មោះថាអ្នកភ្ជួររាស់ ព្រោះកម្ម ឈ្មោះថាអ្នកមានសិល្បសាស្ត្រ ក៏ព្រោះកម្ម ឈ្មោះថាអ្នកជំនួញក៏ព្រោះកម្ម ឈ្មោះថាអ្នកបំរើ ក៏ព្រោះកម្ម ។

សុត្តនិបាតេ តតិយស្ស មហាវគ្គស្ស នវមំ វាសេដ្ឋសុត្តំ

ចោរោបិ កម្មុនា ហោតិ យោធាជីវោបិ កម្មុនា

យាជកោ កម្មុនា ហោតិ រាជាបិ ហោតិ កម្មុនា ។

ឯវមេតំ យថាភូតំ កម្មំ បស្សន្តិ បណ្ឌិតា

បដិច្ចសមុប្បាទទស្សា កម្មវិបាកកោវិទា ។

កម្មុនា វត្តតី លោកោ កម្មុនា វត្តតី បជា

កម្មនិពន្ធនា សត្តា រថស្សាណីវ យាយតោ ។

តបេន ព្រហ្មចរិយេន សញ្ញមេន ទមេន ច

ឯតេន ព្រាហ្មណោ ហោតិ ឯតំ ព្រាហ្មណមុត្តមំ

តីហិ វិជ្ជាហិ សម្បន្នោ សន្តោ ខីណបុនព្ភវោ

ឯវំ វាសេដ្ឋ ជានាហិ ព្រហ្មា សក្កោ វិជានតន្តិ ។

បុគ្គលឈ្មោះថាចោរ ព្រោះកម្ម ឈ្មោះថាយោធាជីវៈ ក៏ព្រោះកម្ម ឈ្មោះថាយាជកៈ (អ្នកបូជា) ក៏ព្រោះកម្ម ឈ្មោះថាស្តេច ក៏ព្រោះកម្ម ។

បណ្ឌិតទាំងឡាយ អ្នកឃើញបដិច្ចសមុប្បាទ (ថាវត្ថុយ៉ាងនេះ កើតឡើងដោយបច្ច័យនេះ) ឈ្លាសវៃក្នុងកម្មនិងវិបាក រមែងឃើញកម្មនុ៎ះ តាមសេចក្តីពិតយ៉ាងនេះ ។

លោករមែងប្រព្រឹត្តទៅ ព្រោះកម្ម ប្រជាជន ក៏ប្រព្រឹត្តទៅ ព្រោះកម្ម ពួកសត្វជាប់ចំពាក់ ដោយកម្ម (ទើបប្រព្រឹត្តទៅបាន) ដូចស្នៀនៃរថដែលវិលទៅ ។

បុគ្គលឈ្មោះថាព្រាហ្មណ៍បាន ដោយកម្មនេះ គឺតបធម៌ (ការសង្រួមឥន្ទ្រិយ) ១ ព្រហ្មចរិយៈ (ការប្រព្រឹត្តិប្រសើរ) ១ សញ្ញមៈ (ការសង្រួមក្នុងសីល) ១ ទមៈ (ការទូន្មាន) ១ កម្មដ៏ឧត្តមនេះឯងដែលធ្វើឲ្យទៅជាព្រាហ្មណ៍ បុគ្គលអ្នកបរិបូណ៌ ដោយវិជ្ជា ៣ ប្រការ ជាអ្នកស្ងប់ មានភពថ្មីអស់ហើយ ទើបឈ្មោះថាព្រះព្រហ្ម ឈ្មោះថាព្រះឥន្ទ្រ របស់អ្នកប្រាជ្ញទាំងឡាយ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ ។

(៧០) ឯវំ វុត្តេ វាសេដ្ឋភារទ្វាជា មាណវា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណង្គតេតិ ។

វាសេដ្ឋសុត្តំ នវមំ ។

## ទសមំ កោកាលិកសុត្តំ

(៧១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថ ខោ កោកាលិកោ(១) ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច បាបិច្ឆា ភន្តេ សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសង្គតាតិ ។

---

១ ឱ. ម. កោកាលិយោ ។

(៧០) កាលដែលព្រះមានព្រះភាគ សំដែងយ៉ាងនេះហើយ វាសេដ្ឋមាណព និងភារទ្វាជមាណព ក៏សរសើរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ចាំនូវពួកយើង ថាជាឧបាសក អ្នកដល់សរណគមន៍ស្មើដោយជីវិត ក្នុងកាលតាំងអំពីថ្ងៃនេះជាដើមតរៀងទៅ ។

ចប់ វាសេដ្ឋសូត្រ ទី ៩ ។

## កោកាលិកសូត្រ ទី ១០

(៧១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ កោកាលិកភិក្ខុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ កោកាលិកភិក្ខុ លុះអង្គុយក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សារីបុត្តនិងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។

(៧២) ឯវំ វុត្តេ ភគវា កោកាលិកំ ភិក្ខុំ ឯតទវោច មា ហេវំ កោកាលិក មា ហេវំ កោកាលិក បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។ ទុតិយម្បិ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច កិញ្ចាបិ មេ ភន្តេ ភគវា សទ្ធាយិកោ បច្ចយិកោ អថខោ បាបិច្ឆា វ សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសង្គតាតិ ។ ទុតិយម្បិ ខោ ភគវា កោកាលិកំ ភិក្ខុំ ឯតទវោច មា ហេវំ កោកាលិក មា ហេវំ កោកាលិក បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។ តតិយម្បិ ខោ កោកាលិកោ ភិក្ខុ ភគវន្តំ ឯតទវោច កិញ្ចាបិ មេ ភន្តេ ភគវា សទ្ធាយិកោ បច្ចយិកោ អថខោ បាបិច្ឆា វ សារីបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសង្គតាតិ ។

(៧២) លុះកោកាលិកភិក្ខុក្រាបបង្គំទូលយ៉ាងនេះហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់នឹងកោកាលិកភិក្ខុដូច្នេះថា នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកចូរធ្វើចិត្តឲ្យជ្រះថ្លាក្នុងសារីបុត្តនឹងមោគ្គល្លានចុះ ដ្បិតសារីបុត្តនឹងមោគ្គល្លានមានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគំរប់ពីរដងទៀតដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ គួរខ្ញុំព្រះអង្គជឿ គួរខ្ញុំព្រះអង្គចូលចិត្ត ពិតមែន តែថា សារីបុត្តនឹងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះអំណាចនៃសេចក្តីប្រាថ្នាលាមក ។ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងកោកាលិកភិក្ខុ ជាគំរប់ពីរដងទៀតដូច្នេះថា នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកចូរធ្វើចិត្តឲ្យជ្រះថ្លា ក្នុងសារីបុត្តនឹងមោគ្គល្លានចុះ ដ្បិតសារីបុត្តនឹងមោគ្គល្លានមានសីលជាទីស្រឡាញ់ ។ កោកាលិកភិក្ខុ ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគំរប់បីដងទៀតដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ គួរខ្ញុំព្រះអង្គជឿ គួរខ្ញុំព្រះអង្គចូលចិត្ត ពិតមែន តែថា សារីបុត្តនឹងមោគ្គល្លាន ជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះអំណាចនៃសេចក្តីប្រាថ្នាលាមក ។

តតិយម្បិ ខោ ភគវា កោកាលិកំ ភិក្ខុំ ឯតទវោច មា ហេវំ កោកាលិក មា ហេវំ កោកាលិក បសាទេហិ កោកាលិក សារីបុត្តមោគ្គល្លានេសុ ចិត្តំ បេសលា សារីបុត្តមោគ្គល្លានាតិ ។ អថ ខោ កោកាលិកោ ភិក្ខុ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អចិរបក្កន្តស្ស កោកាលិកស្ស ភិក្ខុនោ សាសបមត្តាហិ បិឡកាហិ សព្វោ កាយោ ផុដ្ឋោ អហោសិ ។ សាសបមត្តិយោ ហុត្វា មុគ្គមត្តិយោ អហេសុំ ។ មុគ្គមត្តិយោ ហុត្វា កឡាយមត្តិយោ អហេសុំ ។ កឡាយមត្តិយោ ហុត្វា កោឡដ្ឋិមត្តិយោ អហេសុំ ។ កោឡដ្ឋិមត្តិយោ ហុត្វា កោឡមត្តិយោ អហេសុំ ។ កោឡមត្តិយោ ហុត្វា អាមលកមត្តិយោ អហេសុំ ។ អាមលកមត្តិយោ ហុត្វា ពេឡុវសលាដុកមត្តិយោ អហេសុំ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ នឹងកោកាលិកភិក្ខុ ជាគំរប់បីដងទៀត ដូច្នេះថា នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក អ្នកកុំពោលយ៉ាងនេះឡើយ នែកោកាលិក ចូរអ្នកធ្វើចិត្តឲ្យជ្រះថ្លាក្នុងសារីបុត្តនឹងមោគ្គល្លានចុះ ដ្បិតសារីបុត្តនឹងមោគ្គល្លាន មានសីលជាទីស្រឡាញ់ ។ គ្រានោះ កោកាលិកភិក្ខុ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ កាលកោកាលិកភិក្ខុ ចៀសចេញទៅមិនយូរប៉ុន្មាន ស្រាប់តែពងកាយទាំងមូល មានពកប្រមាណប៉ុនគ្រាប់ស្ពៃជុះជោរឡើង ។ ពកប្រមាណប៉ុនគ្រាប់ស្ពៃ ក៏ធំឡើងប៉ុនគ្រាប់សណ្តែកបាយ ។ ពកប្រមាណប៉ុនគ្រាប់សណ្តែកបាយ ក៏ធំឡើងប៉ុនគ្រាប់សណ្តែកខៀវ ។ ពកប្រមាណប៉ុនគ្រាប់សណ្តែកខៀវ ក៏ធំឡើងប៉ុនគ្រាប់ផ្លែពុទ្រា ។ ពកប្រមាណប៉ុនគ្រាប់ផ្លែពុទ្រា ក៏ធំឡើងប៉ុនផ្លែពុទ្រា ។ ពកប្រមាណប៉ុនផ្លែពុទ្រា ក៏ធំឡើងប៉ុនផ្លែសម៉ ។ ពកប្រមាណប៉ុនផ្លែសម៉ ក៏ធំឡើងប៉ុនក្តិបល្ពៅ ។

វេឡុវសលាដុកមត្តិយោ ហុត្វា ពិល្វមត្តិយោ អហេសុំ ។ ពិល្វមត្តិយោ ហុត្វា បភិជ្ជឹសុ ។ បុព្វញ្ច លោហិតញ្ច បគ្ឃរឹសុ ។ អថខោ កោកាលិកោ ភិក្ខុ តេនេវាពាធេន កាលមកាសិ ។ កាលកតោ ច កោកាលិកោ ភិក្ខុ បទុមំ និរយំ ឧបបជ្ជិ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វា ។ អថខោ ព្រហ្មា សហម្បតិ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ព្រហ្មា សហម្បតិ ភគវន្តំ ឯតទវោច កោកាលិកោ ភន្តេ ភិក្ខុ កាលកតោ កាលកតោ ច ភន្តេ កោកាលិកោ ភិក្ខុ បទុមំ និរយំ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ។ ឥទមវោច ព្រហ្មា សហម្បតិ ឥទំ វត្វា បទក្ខិណំ(១) កត្វា តត្ថេវន្តរធាយិ ។

---

១ ឱ. ឥទំ វត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ ។ ម. ឥទំ វត្វា ភគវន្តំ បទក្ខិណំ ។

ពកប្រមាណប៉ុនក្តីបព្នៅ ក៏ធំឡើងប៉ុនផ្លែព្នៅ ។ ពកប្រមាណប៉ុនផ្លែព្នៅ ក៏បែក (ពេញទាំងសរីរៈ) ។ ខ្ទុះនិងឈាម ក៏ហូរហៀរចេញ ។ លំដាប់នោះ កោកាលិកភិក្ខុក៏ធ្វើមរណៈដោយអាពាធនោះឯង ។ កោកាលិកភិក្ខុ លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងបទុមនរក ព្រោះចងចិត្តអាឃាតក្នុងព្រះសារីបុត្តនិងព្រះមោគ្គល្លាន ។ គ្រានោះ កាលបឋមយាមកន្លងទៅ សហម្បតីព្រហ្ម មានរស្មីរុងរឿង បណ្តាលវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺព្រាល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ សហម្បតីព្រហ្ម លុះឋិតនៅក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កោកាលិកភិក្ខុធ្វើមរណកាលហើយ បពិត្រព្រះអង្គដ៏ចំរើន កោកាលិកភិក្ខុ លុះធ្វើមរណកាលហើយ ក៏ទៅកើត ក្នុងបទុមនរក ព្រោះចងចិត្តអាឃាត ក្នុងព្រះសារីបុត្តនិងព្រះមោគ្គល្លាន ។ សហម្បតីព្រហ្ម ក្រាបបង្គំទូលសេចក្តីនេះរួចហើយ លុះពោលពាក្យនេះហើយ ធ្វើប្រទក្សិណរួចក៏បាត់ទៅក្នុងទីនោះឯង ។

អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាម-
ន្តេសិ ឥមំ ភិក្ខវេ រត្តឹ ព្រហ្មា សហម្បតិ អភិក្កន្តាយ
រត្តិយា ។ បេ ។ ឥទមវោច ភិក្ខវេ ព្រហ្មា សហម្បតិ
ឥទំ វត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

(៧៣) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ
ឯតទវោច កីវទីឃំ នុ ខោ ភន្តេ បទុមេ និរយេ
អាយុប្បមាណន្តិ ។ ទីឃំ ខោ ភិក្ខុ បទុមេ និរយេ
អាយុប្បមាណំ តំ ន សុករំ សង្ខាតុំ ឯត្តកានិ
វស្សានិ ឥតិ វា ឯត្តកានិ វស្សសតានិ ឥតិ វា
ឯត្តកានិ វស្សសហស្សានិ ឥតិ វា ឯត្តកានិ
វស្សសតសហស្សានិ ឥតិ វាតិ ។ សក្កា បន ភន្តេ
ឧបមំ(១) កាតុន្តិ ។ សក្កា ភិក្ខូតិ ភគវា អវោច

---

១ ឱ. ឱបមា ។

គ្រានោះ លុះកន្លងរាត្រីនោះទៅ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុ ថា ម្នាលភិក្ខុទាំងឡាយ យប់មិញនេះ នារាត្រីបឋមយាម កន្លងទៅ ហើយ សហម្បតីព្រហ្ម ។បេ។ ម្នាលភិក្ខុទាំងឡាយ សហម្បតីព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ធ្វើប្រទក្សិណរួចក៏បាត់ ទៅក្នុងទីនោះឯង ។

(៧៣) កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ភិក្ខុ ១ រូប ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ប្រមាណនៃ អាយុក្នុងបទុមនរក តើយូរអង្វែងយ៉ាងណាទៅ ។ ម្នាលភិក្ខុ ប្រមាណនៃ អាយុក្នុងបទុមនរក យូរអង្វែងណាស់ ប្រមាណនោះបុគ្គលមិនងាយនឹង រាប់បានថា ប៉ុណ្ណេះឆ្នាំ ឬប៉ុណ្ណោះរយឆ្នាំ ប៉ុណ្ណេះពាន់ឆ្នាំ ឬប៉ុណ្ណោះសែន ឆ្នាំឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចនឹងធ្វើសេចក្តីឧបមាបាន ដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ តថាគតអាចនឹងធ្វើបាន

សេយ្យថាបិ ភិក្ខុ វីសតិខារិកោ កោសល-
កោ តិលវាហោ តតោ បុរិសោ វស្សសតស្ស
វស្សសហស្សស្ស វស្សសតសហស្សស្ស(១) អច្ចយេន
ឯកមេកំ តិលំ ឧទ្ធរេយ្យ ខិប្បតរំ ខោ សោ
ភិក្ខុ វីសតិខារិកោ កោសលកោ តិលវាហោ
ឥមិនា ឧបក្កមេន បរិយាទានំ គច្ឆេយ្យ ន ត្វេវ ឯកោ
អព្ពុទោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អព្ពុទា
និរយា ឯវមេកោ និរព្ពុទោ និរយោ សេយ្យថាបិ ភិក្ខុ
វីសតិ និរព្ពុទា និរយា ឯវមេកោ អពពោ និរយោ

---

១ ឱ. បុរិសោ វស្សសតស្ស វស្សសតស្សាតិ បាឋោ ទិស្សតិ ។ ម. បុរិសោ វស្សសត វស្សសតស្សាតិ បាឋោ ទិស្សតិ ។

ម្នាលភិក្ខុ ដូចរទេះសម្រាប់ផ្ទុកគ្រាប់ល្ងរបស់អ្នកដែនកោសល មានចំណុះ ២០ ខារី(១) មានបុរសម្នាក់ លុះកន្លងទៅ ១ រយឆ្នាំ ១ ពាន់ឆ្នាំ ១ សែនឆ្នាំ ទើបរើសគ្រាប់ល្ង ម្តងមួយគ្រាប់ ៗ អំពីរទេះនោះ ម្នាលភិក្ខុ រទេះសម្រាប់ផ្ទុកគ្រាប់ល្ង របស់អ្នកដែនកោសល ចំណុះ ២០ ខារីនោះ ដល់នូវការអស់ទៅដោយព្យាយាមនេះ ឆាប់ជាង ឯកាលយូរអង្វែងរបស់អព្វុទនរកមួយ(២) មិនងាយនឹងដល់នូវការអស់បានឡើយ ម្នាលភិក្ខុ អព្វុទនរក(៣) ២០ ដង (យូរ) យ៉ាងណា និរព្វុទនរកតែមួយ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុ និរព្វុទនរក ២០ ដងយូរយ៉ាងណា អពពនរកតែមួយ ក៏យ៉ាងនោះដែរ

---

១ រាប់តាមលំដាប់យ៉ាងនេះ ៤ នាឡិអ្នកស្រុកមគធៈ ជា ១ នាឡិនៃអ្នកស្រុកកោសល, ៤ នាឡិអ្នកស្រុកកោសល ជា ១ អាឡ្ហក, ៤ អាឡ្ហក គឺ ១៦ នាឡិ ជា ១ ទោណ, ៤ ទោណ គឺ ៦៤ នាឡិ ជា ១ មានិកា, ៤ មានិកា គឺ ២៥៦ នាឡិ ជា ១ ខារី ១ អម្រែក; ២០ ខារី គឺ ៥១២០ នាឡិ ជា ១ តិលវាហៈ (១រទេះ) ។

២ ជាឈ្មោះរបស់នរក ១ រណ្តៅ ដែលសត្វត្រូវរងទុក្ខយូរអង្វែងរាប់ដោយរយសែនពិន្ទុ (ឆ្នាំ) បើរាប់តាមសំខ្យា មានចំនួន ៥៦ ពិន្ទុ ទើបជាអព្វុទៈ ១ ( ប្រហែល ៨ កោដិឆ្នាំ) ។ អដ្ឋកថា អភិធាន កច្ចាយនូបត្ថម្ភកៈ (តទ្ធិត) ។

៣ តាំងអំពីត្រឹមអព្វុទៈរៀងទៅ យក ២០ គុណ ជាបង្គល់នរកឈ្មោះបន្ទាប់នោះ ។ (បាលី ទាំងអដ្ឋកថា កច្ចាយនូបត្ថម្ភកៈ) ។

សេយ្យថាបិ ភិក្ខុ វីសតិ អពពា និរយា ឯវមេកោ អហហោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អហហា និរយា ឯវមេកោ អដដោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ អដដា និរយា ឯវមេកោ កុមុទោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ កុមុទា និរយា ឯវមេកោ សោគន្ធិកោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ សោគន្ធិកា និរយា ឯវមេកោ ឧប្បលកោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ ឧប្បលកា និរយា ឯវមេកោ បុណ្ឌរីកោ និរយោ សេយ្យថាបិ ភិក្ខុ វីសតិ បុណ្ឌរីកា និរយា ឯវមេកោ បទុមោ និរយោ បទុមំ ខោ បន ភិក្ខុ និរយំ កោកាលិកោ ភិក្ខុ ឧបបន្នោ សារីបុត្តមោគ្គល្លានេសុ ចិត្តំ អាឃាតេត្វាតិ ។

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

ម្នាលភិក្ខុ អព្ពុទនរក ២០ ដង ស្មើដោយណា អហហនរកតែមួយ ក៏ស្មើដោយនោះដែរ ម្នាលភិក្ខុ អហហនរក ២០ ដង (ស្មើ) ដោយណា អដដនរកតែមួយ ក៏ស្មើដោយនោះដែរ ម្នាលភិក្ខុ អដដនរក ២០ ដង (ស្មើ) ដោយណា កុមុទនរកតែមួយ ក៏ស្មើដោយនោះដែរ ម្នាលភិក្ខុ កុមុទនរក ២០ ដង (ស្មើ) ដោយណា សោគន្ធិកនរកតែមួយ ក៏ស្មើដោយនោះដែរ ម្នាលភិក្ខុ សោគន្ធិកនរក ២០ ដង (ស្មើ) ដោយណា ឧប្បលនរកតែមួយ ក៏ស្មើដោយនោះដែរ ម្នាលភិក្ខុ ឧប្បលនរក ២០ ដង (ស្មើ) ដោយណា បុណ្ឌរីកនរកតែមួយ ក៏ស្មើដោយនោះដែរ ម្នាលភិក្ខុ បុណ្ឌរីកនរក ២០ ដង (ស្មើ) ដោយណា បទុមនរកតែមួយ ក៏ស្មើដោយនោះដែរ ម្នាលភិក្ខុ ឯកោកាលិកភិក្ខុ ចូលទៅកើត ក្នុងបទុមនរក (នោះ) ព្រោះចងចិត្តអាឃាត ក្នុងសារីបុត្តនិងមោគ្គល្លាន ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះ ព្រះសុគតជាសាស្តា លុះទ្រង់ត្រាស់ ព្រះពុទ្ធដីកានេះរួចហើយ ទើបទ្រង់ត្រាស់គាថា-ព័ន្ធ តទៅទៀតថា

(៧៤) បុរិសស្ស ហិ ជាតស្ស កុឋារី(១) ជាយតេ មុខេ

យាយ ឆិន្ទតិ អត្តានំ ពាលោ ទុព្ភាសិតំ ភណំ ។

យោ និន្ទិយំ បសំសតិ

តំ វា និន្ទតិ យោ បសំសិយោ

វិចិនាតិ មុខេន សោ កលឹ

កលិនា តេន សុខំ ន វិន្ទតិ ។

អប្បមត្តោ អយំ កលិ

យោ អក្ខេសុ ធនបរាជយោ

(សព្វស្សាបិ សហាបិ អត្តនា)

អយមេវ មហន្តរោ កលិ

យោ សុគតេសុ មនំ បទោសយេ ។

សតំ សហស្សានំ និរព្វុទានំ

ឆត្តឹស ច បញ្ច ច អព្វុទានិ

យមរិយគរហី និរយំ ឧបេតិ

វាចំ មនញ្ច បណិធាយ បាបកំ ។

---

១ ម. កុធារី ។

(៧៤) បុគ្គលពាលពោលពាក្យទុព្ភាសិត រមែងកាត់នូវឫសគល់នៃខ្លួន (កុសលមូល) ដោយផរុសវាចាណា វាចា (នោះ) ដូចជាដឹងចាំងកើតក្នុងមាត់នៃបុរស (នោះ) ។ បុគ្គលណា សរសើរនូវបុគ្គលដែលគួរនិន្ទា ឬនិន្ទានូវបុគ្គលដែលគួរសរសើរវិញ បុគ្គលនោះឈ្មោះថាសន្សំនូវទោសកំហុសដោយមាត់ មិនបាននូវសេចក្ដីសុខ ដោយទោសកំហុសនោះទេ ។ កិរិយាចាញ់ដោយទ្រព្យ ទាំងអស់ឬជាមួយនឹងខ្លួនផង ព្រោះល្បែងភ្នាល់ទាំងឡាយណា ការចាញ់នេះ ជាទោសកំហុស មានប្រមាណតិចទេ បុគ្គលណា ធ្វើចិត្តប្រទូស្តក្នុងព្រះសុគត គឺព្រះសម្មាសម្ពុទ្ធ បច្ចេកពុទ្ធ ពុទ្ធសាវ័ក ការប្រទូស្តនេះឯង ជាទោសកំហុសធំជាង ។

បុគ្គលតិះដៀលព្រះអរិយៈ ដំកល់វាចាចិត្តលាមក រមែងចូលទៅកាន់បទុមនរក អស់កាលណា កាលនោះ កំណត់ ១ សែននិរព្វុទៈ ៣៦ និង ៥ អព្វុទនរកទៀត ។

អភូតវាទី និរយំ ឧបេតិ
យោ វាបិ កត្វា ន ករោមិច្ចាហ
ឧភោបិ តេ បេច្ច សមា ភវន្តិ
និហីនកម្មា មនុជា ហិ(១) បរត្ថ ។
យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ ។
យោ លោភគុណោ(២) អនុយុត្តោ
សោ វចសា បរិភាសតិ អញ្ញេ
អស្សទ្ធោ កទរិយោ អវទញ្ញូ
មច្ឆរិ បេសុណិយស្មឹ អនុយុត្តោ ។
មុខទុគ្គ វិភូតមនរិយ
ភូនហត(៣) បាបក ទុក្កដការិ

---

១ ឱ. ប. ហិសទ្ទោ នត្ថិ ។ ២ ម. លោភគុណេ ។ ៣ ឱ. ភូនហុ ។

បុគ្គលណា ពោលពាក្យមិនពិត ឬបុគ្គលណា ធ្វើហើយ និយាយថា អាត្មាអញមិនធ្វើវិញ រមែងទៅនរក បុគ្គលទាំងពីរពួកនោះ ជាមនុស្សមានកម្ម ដ៏ថោកទាប លុះលះអត្តភាពនេះទៅ រមែងស្មើគ្នា ក្នុងលោកខាងមុខ ។

បុគ្គលណា ប្រទូស្តចំពោះជនដែលមិនប្រទូស្ត ជាបុរសបរិសុទ្ធ មិនមានកិលេស បាបរមែងត្រឡប់ត្រូវបុគ្គលពាលនោះវិញ ដូចជាធូលីដ៏ល្អិតដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់ ។

បុគ្គលណា ប្រកបរឿយ ៗ ក្នុងលោភគុណ (តណ្ហា) បុគ្គលនោះមិនមានសទ្ធា មានតែសេចក្ដីកំណាញ់ស្អិតស្អាញ មិនស្គាល់ពាក្យទូន្មាន ជាអ្នកកំណាញ់ ប្រកបរឿយ ៗ ក្នុងបិសុណាវាចា រមែងតិះដៀលនូវបុគ្គលដទៃដោយពាក្យ ។

ម្នាលអ្នកមានមាត់អាក្រក់ ពោលពាក្យគ្មានពិត មិនប្រសើរ បំផ្លាញនូវសេចក្ដីចំរើន ជាមនុស្សលាមក ធ្វើអំពើអាក្រក់

បុរិសន្ត កលិ អវជាត
មា ពហុភាណិធ នេរយិកោសិ ។
រជមាកិរសិ អហិតាយ
សន្តេ គរហសិ កិព្ពិសការី
ពហូនិ(១) ទុច្ចរិតានិ ចរិត្វា
គច្ឆសិ(២) ខោ បបតំ ចិររត្តំ ។
ន ហិ នស្សតិ កស្សចិ កម្មំ
ឯតិ ហ តំ លភតេវ សុវាមិ
ទុក្ខំ មន្ទោ បរលោកេ
អត្តនិ បស្សតិ កិព្ពិសការី ។
អយោសង្កុសមាហតដ្ឋានំ(៣)
តិណ្ហធារំ អយសូលមុបេតិ
អថ តត្តំ អយោគុឡសន្និភំ
ភោជនមត្ថិ តថា បតិរូបំ ។

---

១ ឱ. ពហូនិ ច ។ ២ ឱ. គញ្ឆិសិ ។ ម. គច្ឆតិ ។ ៣ ម. អយសំកុសមាហតដ្ឋានំ ។

ជាបុរសថោកទាប បុរសឥតបុណ្យ មានកំណើតថោកទាប អ្នកឯងដូចជាសត្វនរក អ្នកកុំនិយាយច្រើនក្នុងទីនេះឡើយ ។ អ្នករោយចុះនូវធូលីលើខ្លួន ដើម្បីមិនជាប្រយោជន៍ អ្នកតិះដៀលពួកសប្បុរស ធ្វើអំពើអាក្រក់ ប្រព្រឹត្តទុច្ចរិតច្រើនប្រការ អ្នកនឹងទៅកាន់នរកអស់កាលយូរអង្វែង ។ កម្មរបស់សត្វនីមួយ ៗ មិនវិនាសទេ សត្វជាម្ចាស់ រមែងបាននូវកម្មនោះ សត្វល្ងង់ខ្លៅ អ្នកធ្វើកម្មអាក្រក់ ឃើញនូវទុក្ខបំពោះខ្លួន ក្នុងលោកខាងមុខ ។ អ្នកធ្វើអំពើអាក្រក់ តែងចូលទៅកាន់ចំរូងដែកដ៏មុត ជាទីដែលនាយនិរយបាល ចាក់នឹងដែកស្រួច ទាំងដុំដែកមានសណ្ឋាន ប្រហែលផ្លែត្នោត ដ៏ក្តៅ សមគួរដល់កម្មនោះ ជាភោជន ( របស់សត្វទាំងនោះ ) ។

ន ហិ វគ្គុ វទន្តិ វទន្តា
នាភិជវន្តិ ន តាណមុបេន្តិ
អង្គារេ សន្ថតេ សេន្តិ(១)
អគ្គិនិសមំ បជ្ជលិតំ(២) បវិសន្តិ ។
ជាលេន ច ឱនហិយានា
តត្ថ ហនន្តិ អយោមយកូដេហិ(៣)
អន្ធំវ តិមិសមាយន្តិ
តំ វិតតំ(៤) យថា មហិកាយោ ។
អថ លោហមយំ បន កុម្ភឹ
អគ្គិនិសមំ បជ្ជលិតំ បវិសន្តិ
បច្ចន្តិ ហិ តាសុ ចិររត្តំ
អគ្គិនិសមាសុ សមុប្បិលវាសា(៥) ។

១ ម. សយន្តិ ។ ២ ខ. អគ្គិនិសមំ ជលិតំ ។ ម. គិនិសម្បជ្ជលិតំ ។ ៣ ម. អយោមយ-យដ្ឋិភិ ។ ៤ ខ. វតតំ ហិ ។ ៥ ឌ. សមុប្បិលវាសោ ។ ម. សម្បិលវាតេ ។

ពួកនាយនិរយបាល កាលនឹងពោល មិនពោលពាក្យពីរោះឡើយ មិនស្ទុះទៅដោយមុខរីករាយ មិនមែនចូលទៅឲ្យជាទីពឹងបានទេ ឲ្យដេកលើគម្រាលរងើកភ្លើង បញ្ចូលទៅកាន់អណ្តាតភ្លើងដែលឆេះសន្ធោសន្ធៅ ៗ ពួកនាយនិរយបាល ព័ទ្ធដោយសំណាញ់ វាយដោយញញួរដែក ក្នុងទីនោះ សត្វនរក ដើរទៅកាន់នរក(ឈ្មោះធូមរោរុព) ងងឹតឈ្លប់ ដែលធ្វើឲ្យខ្វាក់ នរកនោះ ធំទូលាយដូចជាផ្ទៃផែនដី ៗ មួយវិញទៀត សត្វនរក ចូលទៅកាន់លោហកុម្ភីនរក ដែលមានអណ្តាតភ្លើងឆេះសន្ធោសន្ធៅ ជាសត្វលិចអណ្តែត ៗ ឆេះនៅក្នុងលោហកុម្ភីនោះ ដែលមានភ្លើងឆេះជុំវិញ អស់កាលយូរអង្វែង ៗ

អថ បុព្វលោហិតមិស្សេ
តត្ថ កឹ បច្ចតិ កិព្វិសការី
យំ យន្ទិសតំ(១) អធិសេតិ
តត្ថ កិលិស្សតិ សម្ផុស្សមានោ ។
បុឡវាវសថេ សលិលស្មឹ
តត្ថ កឹ បច្ចតិ កិព្វិសការី
គន្តុំ ន ហិ តីរមបត្ថិ
សព្វសមា ហិ សមន្តកបល្លា ។
អសិបត្តវនំ បន តិណ្ហំ
តំ បវិសន្តិ សមុច្ឆិន្នគត្តា(២)
ជិវ្ហំ ពឡិសេន គហេត្វា
អារជយារជយា វិហនន្តិ ។

---

១ ឱ. យញ្ញទិសតំ ។ ម. យំ យំ ទិសកំ ។ ២ ឱ. សមច្ឆិទគត្តា ។ ម. សមុច្ឆិន្នគត្តា

បុគ្គលធ្វើកម្មអាក្រក់ តែងឆេះទៅក្នុងលោហកុម្ភីនរកនោះ ប្រឡំ
ដោយខ្ទះទង់ឈាម តើដូចម្តេច សត្វនរកទៅកាន់ទិសណា ៗ
សឹងប៉ះពាល់ដោយខ្ទះទង់ឈាម ប្រឡូកប្រឡាក់ ក្នុងទិសនោះៗ ។
បុគ្គលធ្វើកម្មអាក្រក់ តែងរងផលកម្ម ក្នុងទឹក (ទង់ដែង) ជាទី
នៅរបស់ដង្កូវ ក្នុងគូថនរកនោះ តើដូចម្តេច ទីដម្រាលគឺច្រាំង
អាចទឹងឡើងចុះបានពុំមានឡើយ ព្រោះថា រណ្តៅនរក (នោះ)
មានសំបែងពោតស្មើជុំវិញទាំងអស់ ។ មួយវិញទៀត សត្វ
នរក ចូលទៅកាន់ព្រៃឈើមានស្លឹកជាដាវដ៏មុត មានខ្លួនមុតដាច់
សព្វអទ្វើដោយដាវនោះ នាយនិរយបាល ក៏ច្ពក់ទាញអណ្តាត
ដោយផ្លែសន្ទូច ហើយកាប់សំឡាប់ ហើយសំឡាប់ទៀត ។

អថ វេត្តរណឹ បន ទុគ្គំ
តិណ្ហធារំ ខុរធារមុបេន្តិ
តត្ថ មន្ទា បបតន្តិ
បាបករា បាបានិ កត្វា(១) ។
ខាទន្តិ ហិ តត្ថ រុទន្តេ
សាមា សពលា កាកោលគណា ច
សោណា សិង្គាលា បដិគិជ្ឈា(២)
កុលលា វាយសា ច វិតុទន្តិ ។
កិច្ឆា(៣) វតាយំ ឥធ វុត្តិ
យំ ជនោ បស្សតិ កិព្វិស្សការី
តស្មា ឥធ ជីវិតសេសេ
កិច្ចករោ សិយា នរោ ន ច មជ្ជេ ។

---

១ ឱ. បាបករា បាបានិ ករិត្វា ។ ម. បាបករា បាបានិធ កត្វា ។ ២ ឱ. សិគាលា បដិគិជ្ឈា ។ ម. យិង្គាលបដិគិទ្ធា ។ ៣ ម. អច្ឆា ។

គពីនោះ សត្វនរកស្ទុះចូលទៅកាន់ស្ទឹងទឹកជ្សា (ទឹកក្រុត) ដែល សត្វហែលទៅបានដោយកម្រ ឬស្ទុះចូលទៅកាន់មុខកាំបិតគោរ មានមុខដ៏មុត សត្វល្ងង់ខ្លៅ ជាអ្នកធ្វើអំពើលាមក លុះធ្វើ អំពើលាមកទាំងឡាយហើយ រមែងធ្លាក់ទៅ ក្នុងនរកនោះ ៗ ហ្វូងក្អែកខ្មៅ ហ្វូងឆ្កែ សម្បុរលឿង សម្បុរពព្រះ ហ្វូងចចក ហ្វូង ត្មាត ហ្វូងតាជក់ ហ្វូងក្អែក-ស តែងចឹកជញ្ជែងស៊ីរូង (ពួកសត្វ នរក) ដែលកំពុងស្រែកយំ ក្នុងនរកនោះ ៗ ជនអ្នកធ្វើនូវ កម្មអាក្រក់ ឃើញនូវសេចក្ដីប្រព្រឹត្តិណា សេចក្ដីប្រព្រឹត្តិក្នុងនរក នេះ ជាការលំបាកមែន ព្រោះហេតុនោះ កាលបើមានជីវិតរស់ នៅក្នុងលោកនេះ នរជន គប្បីធ្វើកិច្ចកុំប្រមាទឡើយ ៗ

តេ គណិតា វិទូហិ តិលវាហា
យេ បទុមេ និរយេ ឧបនីតា
នហុតានិ ហិ កោដិយោ បញ្ច ភវន្តិ
ទ្វាទស កោដិសតានិ បុនញ្ញា ។
យាវ ទុក្ខា និរយា ឥធ វុត្តា
តត្ថបិ តាវ ចិរំ វសិតព្វំ
តស្មា សុចិបេសលសាធុគុណេសុ
វាចំ មនំ បកាតំ[១] បរិរក្ខេ ។

កោកាលិកសុត្តំ ទសមំ ។

# ឯកាទសមំ នាលកសុត្តំ

(៧៩) អានន្ទជាតេ តិទសគណេ បតីតេ[២]
សក្កញ្ច ឥន្ទំ សុចិវសនេ ច ទេវេ
ទុស្សំ គហេត្វា អតិរិវ ថោមយន្តេ
អសិតោ ឥសិ អទ្ទស ទិវាវិហារេ ។

---

១ ឱ. ម. សតតំ ។ ២ ម. បណីតេ ។

ពួកសត្វណា ចូលទៅកើតក្នុងបទុមនរក អស់១នហុត (មួយរយសែនកោដិបព្វកោដិ) នឹង ៥ កោដិឆ្នាំទៀត បួអស់ ១២ រយកោដិផងទៀត ពួកសត្វនរកទាំងនោះ អ្នកប្រាជ្ញទាំងឡាយរាប់ហើយដោយអនេះល្ ។ សេចក្តីទុក្ខក្នុងនរក ដែលលោកពោលហើយក្នុងទីនេះយូរត្រឹមណា កោកាលិកភិក្ខុគប្បីនៅ ក្នុងនរកនោះ អស់កាលយូរត្រឹមនោះ ព្រោះហេតុនោះ បុគ្គលគប្បីរក្សាវាចាចិត្តឲ្យល្អជាប្រក្រតី ក្នុងគុណដ៏ប្រពៃ គឺសេចក្តីស្អាតនឹងសីលជាទីស្រឡាញ់ចុះ ។

ចប់ កោកាលិកសូត្រ ទី ១០ ។

## នាឡកសូត្រ ទី ១១

(៧៥) អសិតឥសី សម្រាកនៅក្នុងទិវាវិហារ បានឃើញនូវពួកទេវតាជាន់តាវត្តិង្ស មានសេចក្តីសោមនស្ស រីករាយផង នូវសក្កទេវរាជ ជាធំជាងទេវតាផង នូវពួកទេវតាដែលស្លៀកសំពត់ស្អាតផង កាន់នូវសំពត់ហើយសរសើរក្រៃពេក ។

ទិស្វាន ទេវេ បមុទិតមនេ(១) ឧទគ្គេ
ចិត្តិំ ករិត្វា ឥទមវោច(២) តត្ថ
កិំ ទេវសង្ឃោ អតិរិវ កល្យរូបោ
ទុស្សំ គហេត្វា រមយថ(៣) កិំ បដិច្ច ។
យទាបិ អាសិ អសុរេហិ សង្គមោ
ជយោ សុរានំ អសុរា បរាជិតោ(៤)
តទាបិ នេតាទិសោ លោមហំសនោ
កិមព្ភុតំ ទដ្ឋុ មរូ បមោទិតា ។
សេឡេន្តិ គាយន្តិ ច វាទយន្តិ
ភុជានិ ផោដេន្តិ ច នច្ចយន្តិ ច
បុច្ឆាមិ វោហំ មេរុមុទ្ធវាសិនេ
ធុនាថ មេ សំសយំ ខិប្បំ មារិសា ។
សោ ពោធិសត្តោ រតនវរោ អតុល្យោ
មនុស្សលោកេ ហិតសុខតាយ ជាតោ
សក្យាន គាមេ ជនបទេ លុម្ពិនេយ្យេ

១ ខ. មុទិតមនេ ។ ២ ខ. ឥទមវោចាសិ ។ ៣ ខ. គហេត្វា អរមយថ ។ ម. គហេត្វា ន រមយថ ។ ៤ ខ. ម. បរាជិតា ។

លុះឃើញទេវតា (ទាំងនោះ) មានចិត្តរីករាយ មានចិត្តខ្ពស់ឡើង ក៏ធ្វើនូវសេចក្តីអើពើ សួរដូច្នេះថា ពួកទេវតាក្នុងជាន់តាវត្តិង្សនោះ មានសភាព រីករាយក្រៃពេក ព្រោះហេតុអ្វី អ្នកទាំងឡាយ កាន់សំពត់ត្រេកអរ ព្រោះអាស្រ័យហេតុអ្វី ៗ (អសិតឥសីដឹងថា) ក្នុងវេលាណា មានសង្គ្រាមជាមួយពួកអសុរ ជ័យជំនះ មានដល់ពួកទេវតា ពួកអសុរចាញ់ ក្នុងវេលានោះ ពួកទេវតាក៏មិនមានការព្រឺរោមព្រាកដូច្នោះឡើយ ពួកទេវតាត្រេកអររីករាយ ព្រោះឃើញ នូវហេតុចំឡែកដូចម្តេច ៗ ពួកទេវតាហួចផង ច្រៀងផង ប្រគំផង ទះដៃទាំងសងខាងផង រាំផងថា នែទេវតាទាំងឡាយ ជាបុគ្គលនិរទុក្ខ ខ្ញុំសួរអ្នកទាំងឡាយដែលនៅលើកំពូលភ្នំមេរុ គឺជាន់តាវត្តិង្ស (នេះ) សូមអ្នកទាំងឡាយបន្ទោបង់សេចក្តីសង្ស័យ របស់ខ្ញុំដោយឆាប់ ៗ (ពួកទេវតាតបថា) ពោធិសត្វនោះ ដូចជាកែវដ៏ប្រសើរ ឥតមានអ្វីទឹងផ្ទឹមបាន ទ្រង់កើត ក្នុងព្រៃលុម្ពិនីវ័ន ក្នុងជនបទ ជាស្រុករបស់ពួកសក្យៈ ក្នុងមនុស្សលោក ដើម្បីជាប្រយោជន៍និងសេចក្តីសុខ

តេនម្ហ តុដ្ឋា អតិរិវ កល្យរូបា ។
សោ សព្វសត្តុត្តមោ អគ្គបុគ្គលោ
នរាសភោ សព្វបជានមុត្តមោ
វត្តេស្សតិ ចក្កំ ឥសិវ្ហយេ វនេ
នទំវ សីហោ ពលវា មិគាភិភូ ។
តំ សទ្ទំ សុត្វា តុរិតមវំសរី(១) សោ
សុទ្ធោទនស្ស (តទ) ភវនំ ឧបាវិសិ
និសជ្ជ តត្ថ ឥទមវោចាសិ សក្យេ
កុហឹ កុមារោ អហមបិ ទដ្ឋុកាមោ ។
តតោ កុមារំ ជលិតមិវ សុវណ្ណំ
ឧក្កាមុខេវ សុកុសលសម្បហដ្ឋំ(២)
ទទ្ទល្លមានំ សិរិយា អនោមវណ្ណំ
ទស្សេសុ(៣) បុត្តំ អសិតវ្ហយស្ស សក្យា ។
ទិស្វា កុមារំ សិខិមិវ បជ្ជលន្តំ

---

១ ឱ. តុរិតមវសរី ។ ២ ម. សុកុសលេន សម្បហដ្ឋំ ។ ៣ ម. ទស្សឹសុ ។

ព្រោះហេតុនោះ បានជាយើងខ្ញុំមានសេចក្ដីត្រេកអរ មានសភាព រីករាយក្រៃពេក ៗ ពោធិសត្វនោះ ប្រសើរជាងសព្វសត្វ (ទេវតានឹងមនុស្ស) ជាអគ្គបុគ្គល ជានរៈអង់អាច ឧត្តមជាង ពួកសត្វទាំងអស់ អាចញុំាងចក្រឲ្យប្រព្រឹត្តទៅ ក្នុងព្រៃឥសិបតន-មិគទាយវ័ន ដូចសត្វសីហៈ ជាសត្វមានកំឡាំងគ្របសង្កត់នូវពួកម្រឹគ បន្លឺសីហនាទដែរ ៗ អសិតឥសីនោះ លុះឮសំឡេងនោះហើយ ទើបចុះមកដោយរួសកន់ ចូលសំដៅទៅកាន់ព្រះដំណាក់របស់ព្រះបាទសុទ្ធោទនៈ ក្នុងកាលណោះ លុះអង្គុយនៅក្នុងព្រះដំណាក់ហើយ ក៏សួរពួកសក្យៈដូច្នេះថា ព្រះរាជកុមារនៅឯណា អាត្មាភាពត្រូវការចង់ឃើញ ៗ គ្រានោះ ពួកសក្យ បង្ហាញព្រះរាជ-កុមារ ជារាជឱរស មានសម្បុររុងរឿង ដូចមាសត្រង់មុខបាវដែលជាងមាសអ្នកឈ្លាសវៃ ឲ្យដំហើយថ្មី ៗ មានសម្បុរ-សដ៏រុងរឿងដោយសិរី មានសម្បុរមិនខុនថយ ដល់អសិតឥសី ៗ អសិត-ឥសី លុះឃើញព្រះរាជកុមារ មានសម្បុររុងរឿងដូចអណ្ដាតភ្លើង

តារាសភំវ នភសិគមំ វិសុទ្ធំ
សុរិយន្តបន្តំ សារទិវព្ភមុត្តំ
អានន្ទជាតោ វិបុលមលត្ថ បីតឹ ។
អនេកសាខញ្ច សហស្សមណ្ឌលំ
ឆត្តំ មរូ ធារយុមន្តលិក្ខេ
សុវណ្ណទណ្ឌា វីតិបតន្តិ ចាមរា
ន ទិស្សរេ ចាមរឆត្តគាហកា ។
ទិស្វា ជដី កណ្ហសិរិវ្ហយោ ឥសី
សុវណ្ណនិក្ខំ វិយ បណ្ឌុកម្ពលេ
សេតញ្ច ឆត្តំ ធារយន្តមុទ្ធនិ
ឧទគ្គចិត្តោ សុមនោ បដិគ្គហេ ។
បដិគ្គហេត្វា បន សក្យបុង្គវំ
ជិគីសកោ លក្ខណមន្តបារគូ
បសន្នចិត្តោ គិរមព្ភុទីរយិ
អនុត្តរាយំ ទ្វិបទានមុត្តមោ ។

ដូចព្រះចន្ទដ៏រុងរឿង ក្នុងកណ្ដាលហ្វូងផ្កាយ ឋិតនៅក្នុងអាកាស បរិសុទ្ធ ដូចព្រះអាទិត្យ ផុតអំពីពពក រុងរឿងក្នុងសារទៈរដូវ មានសេចក្ដីរីករាយ បាននូវបីតិដ៏ទូលាយ ។ ពួកទេវតាបាំងឆ័ត្រ-ស មានឆ្អឹងច្រើន មានមណ្ឌលមួយពាន់ (សំរេចអំពីមាសឆ្អិន) នាកណ្ដាលអាកាស ចាមរទាំងឡាយ មានដងជាវិការៈនៃមាស សំយុងចុះ ពួកទេវតាអ្នកកាន់ចាមរនិងឆ័ត្រក៏មិនប្រាកដឡើយ ។ ជដិល ជាឥសីឈ្មោះកណ្ហសិរី លុះឃើញព្រះរាជកុមារមានរស្មី រុងរឿងដូចដុំមាស លើកម្រាលសំពត់បណ្ឌុកម្ពល ដែលពួកទេវតាបាំងស្វេតឆត្រលើព្រះសិរហើយ ក៏មានចិត្តអំណរខ្ពស់ឡើង មានចិត្តរីករាយហើយទទួលយក (ព្រះរាជកុមារនោះ) ។ តាបសនោះជាអ្នកត្រិះរិះ រំពឹងនូវកាលជាអនាគត ជាអ្នកចេះចប់នូវមន្តសម្រាប់ស្គាល់នូវលក្ខណៈ លុះទទួលព្រះរាជកុមារដ៏ប្រសើរ របស់ពួកសក្យៈហើយ មានចិត្តរីករាយ បញ្ចេញសំណើបថា ព្រះរាជកុមារនេះប្រសើរឧត្ដមជាងពួកសត្វមានជើងពីរ គឺទេវតានិងមនុស្ស ។

អថត្តនោ គមនមនុស្សរន្តោ
អកល្យរូបោ គឡយតិ(១) អស្សុកានិ
ទិស្វាន សក្យា ឥសិមវោចុំ រុទន្តំ
នោ ចេ កុមារេ ភវិស្សតិ អន្តរាយោ ។
ទិស្វាន សក្យេ ឥសិមវោច អកល្យេ
នាហំ កុមារេ អហិតមនុស្សរាមិ
ន ចាបិមស្ស ភវិស្សតិ អន្តរាយោ
ន ឱរកាយំ អធិមនសា ភវាថ ។
សម្ពោធិយគ្គំ ផុសិស្សតាយំ កុមារោ
សោ ធម្មចក្កំ បរមវិសុទ្ធទស្សី
វត្តេស្សតាយំ ពហុជនហិតានុកម្បី
វិត្ថារិកស្ស ភវិស្សតិ ព្រហ្មចរិយំ ។
មមញ្ច អាយុ ន ចិរមិធាវសេសោ
អថន្តរា មេ ភវិស្សតិ កាលកិរិយា
សោហំ ន សោស្សំ អសមធុរស្ស ធម្មំ

---

១ ម. គឡេតិ ។

លំដាប់នោះ កណ្ហសិរី រឭកឃើញដំណើររបស់ខ្លួន ក៏មានសភាពមិនរីករាយ ទើបយំសម្រក់ទឹកភ្នែកវិញ ពួកសក្យៈឃើញហើយ ក៏សួរឥសីដែលកំពុងយំថា សេចក្តីអន្តរាយនឹងមានដល់ព្រះរាជកុមារនៃយើងឬ ។ ឥសីលុះឃើញពួកសក្យៈមិនរីករាយហើយ ទើបពោលថា អាត្មាមិនបានរឭក នូវអំពើមិនមែនជាប្រយោជន៍ចំពោះព្រះរាជកុមារឡើយ មួយទៀត សេចក្តីអន្តរាយនឹងមិនមានដល់ព្រះរាជកុមារទេ ព្រះរាជកុមារនេះមិនថោកថយឡើយ សូមអ្នកទាំងឡាយមានចិត្តរីករាយចុះ ។ ព្រះរាជកុមារនេះ នឹងបានត្រាស់ដឹងនូវសម្ពោធិញ្ញាណដ៏ប្រសើរ ព្រះរាជកុមារនេះ ជាអ្នកឃើញនូវព្រះនិព្វានដ៏បរិសុទ្ធក្រៃលែង ព្រះរាជកុមារនេះ ជាអ្នកអនុគ្រោះនូវប្រយោជន៍ដល់ជនច្រើន នឹងញុំាងព្រះធម្មចក្រ ឲ្យប្រព្រឹត្តទៅ ព្រហ្មចរិយៈគឺសាសនារបស់ព្រះរាជកុមារនេះនឹងសាយភាយទៅ ។ ឯអាយុរបស់អាត្មាមិនបានតាំងនៅយូរ ក្នុងមនុស្សនេះទេ កាលកិរិយារបស់អាត្មានឹងមានក្នុងរវាង(នេះ)ឯង អាត្មានឹងមិនបានស្តាប់ធម៌របស់ព្រះរាជកុមារអ្នកមានព្យាយាម មិនមានអ្នកណាស្មើឡើយ

តេនម្ហិ អដ្ដោ(១) ព្យសនគតោ អឃាវី ។
សោ សាកិយានំ វិបុលំ ជនេត្វាន បីតឹ
អន្តេបុរម្ហា និគ្គមា ព្រហ្មចារី
សោ ភាគិនេយ្យំ សយំ អនុកម្បមានោ
សមាទបេសិ អសមធុរស្ស ធម្មេ
ពុទ្ធោតិ ឃោសំ យទិ បរតោ សុណាសិ
សម្ពោធិបត្តោ វិវរតិ(២) ធម្មមគ្គំ
គន្ត្វាន តត្ថ សមយំ(៣) បរិបុច្ឆមានោ
ចរស្សុ តស្មឹ ភគវតិ ព្រហ្មចរិយំ ។
តេនានុសិដ្ឋោ ហិតមនេន(៤) តាទិនា
អនាគតេ បរមវិសុទ្ធទស្សិនា
សោ នាឡកោ ឧបចិតបុញ្ញសញ្ចយោ
ជិនំ បតិក្ខំ បរិវសិ រក្ខិតិន្ទ្រិយោ ។
សុត្វាន ឃោសំ ជិនវរចក្កវត្តនេ

---

១ ម. អដ្ឋោ ។ ២ ឱ. វិវរតី ។ ៣ ឱ. ម. សមយំ ។ ៤ ឱ. ហិតមនេន ។

ព្រោះហេតុនោះ បានជាអាត្មាស្តាយក្រោយ ព្រួយចិត្តកើតទុក្ខ ។ តាបសអ្នកមានព្រហ្មចារិយធម៌នោះ ញុំាងបីតិដ៏ធំទូលាយ ឲ្យកើតឡើងដល់ពួកសក្យៈ ហើយក៏ចៀសចេញ អំពីបរមរាជវាំងទៅ តាបសនោះ មានសេចក្តីអនុគ្រោះចំពោះក្មួយរបស់ខ្លួន ក៏បបួលឲ្យកាន់យកធម៌ របស់មហាបុរស អ្នកមានព្យាយាម មិនមានអ្នកណាស្មើ ថាបើ អ្នកបានឮសំឡេងថា ពុទ្ធោ អំពីសំណាក់បុគ្គលដទៃហើយ (ត្រូវដឹងថា) មហាបុរសដល់នូវការត្រាស់ដឹងហើយ បើកផ្លូវទៅកាន់ព្រះនិព្វានហើយ អ្នកគប្បីចូលទៅសាកសួរលទ្ធិ ក្នុងសំណាក់នៃមហាបុរសនោះ ហើយប្រព្រឹត្តព្រហ្មចារិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគនោះចុះ ។ នាឡកកុមារនោះ ជាបុគ្គលមានបុណ្យសន្សំទុកហើយ ដែលឥសីនោះ មានចិត្តប្រកបដោយប្រយោជន៍មិនញាប់ញ័រ ឃើញថា ព្រះនិព្វានបរិសុទ្ធក្រៃលែង ក្នុងអនាគត ប្រៀនប្រដៅហើយ ក៏នៅរង់ចាំព្រះជិនស្រី រក្សាសាតិន្ទ្រិយ បួសដោយភេទនៃខ្លួនជាតាបស ។ នាឡកតាបស លុះឮសំឡេងគឹកកង (ដែលទេវតាទាំងឡាយធ្វើហើយ) ក្នុងកាលដែលព្រះជិនស្រី ញុំាងចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ

គន្ត្វាន ទិស្វា ឥសិនិសភំ បសន្នោ

មោនេយ្យសេដ្ឋំ មុនិវរំ អបុច្ឆិ

សមាគតេ អសិតវ្ហយស្ស សាសនេតិ ។

វត្ថុគាថា និដ្ឋិតា ។

(៧៦) អញ្ញាតមេតំ វចនំ អសិតស្ស យថាតថំ

តំ តំ គោតម បុច្ឆាមិ(១) សព្វធម្មាន បារគុំ

អនាគារិយុបេតស្ស ភិក្ខាចរិយំ ជិគីសតោ

មុនិ បព្រូហិ(២) មេ បុដ្ឋោ មោនេយ្យំ ឧត្តមំ បទំ ។

មោនេយ្យន្តេ ឧបញ្ញិស្សន្តិ (ភគវា) ទុក្ករំ ទុរភិសម្ភវំ

ហន្ទ តេ នំ បវក្ខាមិ សន្ថម្ភស្សុ ទឡ្ហោ ភវ ។

---

១ ឱ. បុច្ឆាម ។ ២ ម. មារិស ព្រូហិ ។

ក៏ទៅ ( កាន់ទីនោះ ) លុះទៅដល់ហើយ ឃើញព្រះមានព្រះភាគដូចឥសី ក៏មានចិត្តជ្រះថ្លា បានសាកសួរនូវមោនេយ្យវត្ត គឺមគ្គញាណដ៏ប្រសើរ នឹងព្រះពុទ្ធជាមុនីវិសេស តាមពាក្យប្រៀនប្រដៅរបស់អសិតឥសីនោះហើយ ។

ចប់ វត្ថុកថា ។

(៧៦) នាឡកតាបស សួរថា បពិត្រព្រះគោតម នេះជាពាក្យពិតរបស់អសិតតាបស ដែលខ្ញុំព្រះអង្គដឹងហើយ ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ អ្នកដល់ត្រើយនៃធម៌ទាំងពួង កាលបើខ្ញុំព្រះអង្គសួរហើយ សូមព្រះអង្គសំដែងប្រាប់នូវមោនេយ្យប្បដិបទា ជាវត្តដ៏ឧត្តមរបស់អ្នកប្រាជ្ញ (ដើម្បីជាវត្ត) របស់អ្នកបួសស្វែងរកភិក្ខាចារ (ដល់ខ្ញុំព្រះអង្គ) ។

( ព្រះមានព្រះភាគ ) ទ្រង់ត្រាស់ថា តថាគតនឹងបញ្ញត្តមោនេយ្យប្បដិបទា ដែលជាវត្តធ្វើបានដោយកម្រ អត់ធន់បានដោយកម្រ ដល់អ្នក បើដូច្នោះ តថាគតនឹងសំដែងមោនេយ្យប្បដិបទានោះ ដល់អ្នក ត្រូវអ្នកផ្គងព្យាយាមឲ្យមាំមួនចុះ ។

សមានការំ(១) កុព្វេថ គាមេ អក្កុដ្ឋវន្ទិតំ
មនោបទោសំ រក្ខេយ្យ សន្តោ អនុណ្ណតោ ចរេ(២) ។
ឧច្ចាវចា និច្ឆរន្តិ ទាយេ អគ្គិសិខូបមា
នារិយោ មុនឹ បលោភេន្តិ តា សុ តំ មា បលោភយុំ(៣) ។
វិរតោ មេថុនា ធម្មា ហិត្វា កាមេ វរាវរេ(៤)
អវិរុទ្ធោ អសារត្តោ បាណេសុ តសថាវរេ ។
យថា អហំ តថា ឯតេ យថា ឯតេ តថា អហំ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។
ហិត្វា ឥច្ឆញ្ច លោភញ្ច យត្ថ សត្តោ បុថុជ្ជនោ
ចក្ខុមា បដិបជ្ជេយ្យ តរេយ្យ នរកំ ឥមំ ។

---

១ ម. សមានភាគំ ។ ២ ឱ. ម. អនុណ្ណតោចរេ ។ ៣ ឱ. ម. បលោភយុំ ។ ៤ ឱ. បរោវរេ ។ ម. បរោបរេ ។

បុគ្គលត្រូវធ្វើខ្លួនឲ្យមានភាពស្មើ ចំពោះបុគ្គលអ្នកជេរនិងអ្នកថ្វាយបង្គំក្នុងស្រុក បុគ្គល (បើគេជេរ) ត្រូវរក្សាសេចក្ដីប្រទូស្តក្នុងចិត្ត (បើគេថ្វាយបង្គំ) ត្រូវស្ងប់កុំប៉ោងតាមអារម្មណ៍ ។ អារម្មណ៍ខ្ពស់និងទាបទាំងឡាយ (អារម្មណ៍ល្អនិងអាក្រក់) តែងផ្សាយចេញមក (កាន់វង់បក្ខជាដើម) ឧបមាដូចអណ្តាតភ្លើងដែលឆេះក្នុងព្រៃ នារីទាំងឡាយតែងប្រលោមនូវអ្នកប្រាជ្ញ នារីទាំងឡាយនោះ កុំគប្បីប្រលោមអ្នកបានឡើយ ។ បុគ្គលវៀរហើយចាកមេថុនធម្ម លះកាមដែលល្អនិងអាក្រក់ទាំងឡាយ កុំទោមនស្ស កុំត្រេកអរ ចំពោះសត្វដែលតក់ស្លុតនិងសត្វដែលមាំមួន (មិនតក់ស្លុត) ក្នុងសត្វទាំងឡាយ ។ គប្បីប្រៀបខ្លួនឯងថា អាត្មាអញយ៉ាងណា សត្វទាំងឡាយនុ៎ះ ក៏យ៉ាងនោះដែរ សត្វទាំងឡាយនុ៎ះយ៉ាងណា អាត្មាអញ ក៏យ៉ាងនោះដែរ ហើយមិនត្រូវសំឡាប់ មិនត្រូវប្រើគេឲ្យសំឡាប់ឡើយ ។ បុថុជ្ជនជាប់ចំពាក់ក្នុងបច្ច័យណា បុរសអ្នកមានបញ្ញាចក្ខុ ត្រូវតែលះបោលនូវសេចក្ដីប្រាថ្នាផង នូវសេចក្ដីលោភផង(ក្នុងបច្ច័យនោះ) ហើយប្រតិបត្តិ នូវមោនេយ្យប្បដិបទា ត្រូវតែប្រឆាំង នូវតណ្ហាដែលបំពេញ បានដោយកម្រនេះ ។

ឩនោទរោ(១) មិតាហារោ អប្បិច្ឆស្ស អលោលុបោ
សទា(២) ឥច្ឆាយ និច្ឆាតោ អនិច្ឆា ហោតិ និព្វុតោ ។
ស បិណ្ឌចារំ ចរិត្វា វនន្តមភិហារយេ
ឧបដ្ឋិតោ រុក្ខមូលស្មឹ អាសនូបគតោ មុនិ ។
ស ឈានបសុតោ ធីរោ វនន្តេ រមិតោ សិយា
ឈាយេថ រុក្ខមូលស្មឹ អត្តានមភិតោសយំ ។
តតោ រត្យា វិវសនេ គាមន្តមភិហារយេ
អវ្ហានំ នាភិនន្ទេយ្យ អភិហារញ្ច គាមតោ ។
ន មុនី គាមមាគម្ម កុលេសុ សហសា ចរេ(៣)
ឃាសេសនំ ឆិន្នកថោ ន វាចំ បយុត្តំ ភណេ ។
អលត្ថំ យទិទំ សាធុ នាលត្ថំ កុសលាមិតិ
ឧភយេនេវ សោ តាទី រុក្ខំវ ឧបាតិវត្តតិ(៤) ។

---

១ ឱ. ឧនូទរោ ។ ម. ឧរោទរោ ។ ២ ឱ. សរេ ។ ៣ ម. កុលេសុ សតិសោ ចរេ ។ ៤ ឱ. ម. ឧបនិវត្តតិ ។

បុគ្គលគួរមានពោះតូច មានអាហារកំណត់ មានប្រាថ្នាតិច មិនលោភ បុគ្គលមិនឃ្លានដោយសេចក្តីប្រាថ្នាសព្វៗ កាល ជាអ្នកមិនមានសេចក្តីប្រាថ្នា រមែងរលត់សេចក្តីក្តៅក្រហាយ ព្រោះកិលេស (ដោយមិនមានសេចក្តីប្រាថ្នា) ។ ភិក្ខុអ្នកប្រតិបត្តិមោនេយ្យប្បដិបទានោះ ប្រព្រឹត្តនូវបិណ្ឌបាតចារិកវត្តរួចហើយគប្បីប្រញាប់ចូលទៅកាន់ព្រៃហើយចូរឋិតនៅក្រោមម្លប់ឈើ រួចចូលទៅកាន់អាសនៈ ។ អ្នកប្រាជ្ញនោះ គួរខ្វល់ខ្វាយក្នុងឈាន គួរត្រេកអរក្នុងព្រៃ គួរត្រេកអរនឹងខ្លួនឯង ហើយគប្បីចំរើនឈាន ក្រោមម្លប់ឈើ ។ តអំពីនោះ លុះកន្លងរាត្រីទៅ គប្បីចូលទៅកាន់ស្រុក មិនគួរត្រេកអរនឹងការនិមន្តផង មិនគួរទទួលនូវភោជនដែលគេនាំចេញអំពីស្រុកផង ។ មុនីចូលទៅកាន់ស្រុក មិនគួរត្រាច់ទៅដោយការរួសរាន់ ក្នុងត្រកូលទាំងឡាយឡើយ គួរជាអ្នកកាត់បង់នូវកថា (ពាក្យពោល) មិនគួរពោលពាក្យផ្សៃផ្សំ ស្វែងរកស៊ីឡើយ ។ មុនីនោះជាតាទិបុគ្គល ដោយហេតុទាំងពីរប្រការ គឺអាត្មាអញបាននេះ ជាការប្រពៃ អាត្មាអញមិនបានក៏ជាការល្អ ហើយក៏ចូលទៅកាន់ត្រកូលដូចអ្នករកផ្លែឈើ ចូលទៅកាន់ឈើ ។

សបត្តបាណី ចរន្តោ(១) អមូគោ មូគសម្មតោ
អប្បំ ទានំ ន ហីឡេយ្យ ទាតារំ នាវជានិយា ។
ឧច្ចាវចា ហិ បដិបទា សមណេន បកាសិតា
ន បារំ ទិគុណំ យន្តិ នយិទំ ឯកគុណំ មុតំ ។
យស្ស ច វិសតា នត្ថិ ឆិន្នសោតស្ស ភិក្ខុនោ
កិច្ចាកិច្ចប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។
មោនេយ្យន្តេ ឧបញ្ញិស្សន្តិ (ភគវា) ខុរធារូបមោ ភវេ
ជិវ្ហាយ តាលុំ អាហច្ច ឧទរេ សញ្ញតោ សិយា ។
អលីនចិត្តោ ច សិយា ន ចាបិ ពហុ ចិន្តយេ
និរាមគន្ធោ អសិតោ ព្រហ្មចរិយបរាយនោ
ឯកាសនស្ស សិក្ខេថ សមណោបាសនស្ស ច

---
១ ឱ. ម. វិចរន្តោ ។

មុនីមានបាត្រក្នុងដៃត្រាច់ទៅ មិនគ សន្មតថា ដូចគ មិនគួរពោល ប្រជាយទីងទានដែលមានប្រមាណតិច មិនគួរមើលងាយនូវបុគ្គល អ្នកឲ្យទាន ៗ ឯបដិបទាដែលខ្ពស់ទីងទាប សមណៈបានប្រ-កាសហើយ ធម្មតាព្រះអរិយបុគ្គល មិនដែលទៅកាន់ត្រើយខាង នាយ គឺព្រះនិព្វានដល់ពីរដងឡើយ ព្រះនិព្វាននេះ មិនគួរបាន ដោយគុណតែមួយទេ ៗ ភិក្ខុណា មិនមានតណ្ហាសេចក្តីក្រហល់ ក្រហាយ ទីងមិនមានដល់ភិក្ខុនោះ ជាអ្នកមានខ្សែកិលេសកាត់ ហើយ អ្នកលះបោលនូវកិច្ចតូចទីងកិច្ចធំហើយ ៗ

(ព្រះមានព្រះភាគ) ទ្រង់ត្រាស់ថា តថាគតទីងបញ្ញត្តនូវមោ-នេយ្យប្បដិបទាដល់អ្នក ភិក្ខុអ្នកប្រព្រឹត្តនូវមោនេយ្យប្បដិបទា គប្បី ប្រៀបធៀបខ្លួនដូចមុខកាំបិតកោរ គប្បីទល់ពិតានដោយអណ្តាត ហើយសង្រួមផ្ទៃ (ដោយការមិនសេពបច្ច័យដែលកើតឡើងដោយ ផ្លូវសៅហ្មង) ៗ ភិក្ខុនោះមិនមានចិត្តខ្ជិលផង កុំគិតច្រើនផង ជា អ្នកមិនមានកិលេសផង មិនអាស្រ័យតណ្ហាផង មានសាសនព្រហ្ម-ចរិយៈជាខាងមុខផង គួរសិក្សាបម្រុងទីងសេពនូវអាសនៈស្ងាត់ម្នាក់ ឯងផង បម្រុងសេពអារម្មណ៍ ដែលសមណៈគប្បីចូលទៅជិតផង

ឯកត្តំ មោនមក្ខាតំ(១) ឯកោ ចេ(២) អភិរមិស្សសិ ។

(៣)
(អថ ភាសិហិ ទស ទិសា)

សុត្វា ធីរានំ និគ្ឃោសំ ឈាយីនំ កាមចាគិនំ

តតោ ហិរិញ្ច សទ្ធញ្ច ភិយ្យោ កុព្វេថ មាមកោ ។

តំ នទីហិ(៤) វិជានាថ សោព្ភេសុ បទរេសុ ច

សណន្តា យន្តិ កុសោព្ភា តុណ្ហី យន្តិ(៥) មហោទធិ ។

យទូនកំ តំ សណតិ យំ បូរំ សន្តមេវ តំ(៦)

(៧)
អឌ្ឍកុម្ភូបមោ ពាលោ រហទោ បូរោវ បណ្ឌិតោ ។

យំ សមណោ ពហុ ភាសតិ ឧបេតំ អត្ថសញ្ហិតំ

ជានំ សោ ធម្មំ ទេសេតិ ជានំ សោ ពហុ ភាសតិ ។

---

១ ម. មោនមក្ខាតិ ។ ២ ឱ. ម. ឯកោ ចេ ។ ៣ ម. អថ ភាហិសិ ទស ទិសា ។
៤ ម. នទីតិ ។ ៥ ឱ. កុសោព្ភា តុណ្ហី យាតិ ។ ៦ ម. តំ ។ ៧ ម. អឌ្ឍកុម្ភូបមោ ។

អ្នកជាបុគ្គលម្នាក់ឯង តាំងត្រេកអរនូវមោនេយ្យប្បដិបទាជាចំណែកមួយ ដែលតថាគត សំដែងហើយដោយពិត ។ (អ្នកនឹងល្បីឮខ្ចរខ្ចាយទៅក្នុងទិសទាំង ១០ ក្នុងកាលជាខាងក្រោយ) អ្នកឮសំឡេងល្បី (អំពីសំណាក់) អ្នកប្រាជ្ញទាំងឡាយ ជាអ្នកមានឈាន លះបង់កាម គប្បីធ្វើដោយក្រៃលែងនូវហិរិផង នូវសទ្ធាផង ក្នុងកាលនោះ ទើបឈ្មោះថាជាសាវ័ករបស់តថាគត ។ អ្នកត្រូវដឹងបរិយាយនោះ ដោយសេចក្ដីឧបមា ដោយទន្លេទាំងឡាយ ( ត្រូវដឹងបរិយាយដទៃទៀត ) ចំពោះបឹងនឹងស្ទឹងទាំងឡាយថា ស្ទឹងតូចទាំងឡាយ តែងធ្វើសំឡេង ហូរទៅ ឯស្ទឹងធំ តែងហូរទៅស្ងៀម ៗ ។ ទឹកណា ដែលខ្វះ ទឹកនោះតែងឮសូរ ទឹកណា ដែលពេញ ទឹកនោះតែងស្ងប់ ជនពាលមានឧបមាដូចទឹកខ្វះក្អម ជនបណ្ឌិតមានឧបមាដូចអន្លង់ទឹកដ៏ពេញ ។ សមណៈគឺព្រះពុទ្ធ តែងសំដែងនូវធម៌ដែលប្រកបដោយប្រយោជន៍ដ៏ច្រើន សមណៈនោះជ្រាបប្រាកដ ទើបសំដែងនូវធម៌ សមណៈនោះជ្រាបប្រាកដ ទើបសំដែងដោយច្រើន ។

យោ ច ជានំ សំយតត្តោ ជានំ ន ពហុ ភាសតិ
ស មុនិ មោនមរហតិ ស មុនិ មោនមជ្ឈគាតិ(១) ។

នាឡកសុត្តំ ឯកាទសមំ ។

## ទ្វាទសមំ ទ្វយតានុបស្សនាសុត្តំ

(៧៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។ អថខោ ភគវា តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ យេ តេ ភិក្ខវេ កុសលា ធម្មា អរិយា និយ្យានិកា សម្ពោធិគាមិនោ(២)

---

១ ម. ស មុនិ មុនមជ្ឈគាតិ ភគវាតិ ។ ២ ខ.ម. សម្ពោធគាមិនោ ។

មួយទៀត មុនីណា ជ្រាបប្រាកដនូវធម៌ មានចិត្តសង្រួមហើយ ជ្រាបប្រាកដនូវធម៌ មិននិយាយច្រើន មុនីនោះ គួរដល់មោនេយ្យប្បដិបទា មុនីនោះ បានដល់នូវអរហត្តមគ្គញាណ ។

ចប់ នាឡកសូត្រ ទី ១១ ។

## ទ្វយតានុបស្សនាសូត្រ ទី ១២

(៧៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងបុព្វារាម មិគារមាតុប្រាសាទ ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម គង់ក្នុងវេលារាត្រីពេញបូណ៌មី ក្នុងថ្ងៃឧបោសថទី ១៥ នោះ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ឈ្វេងមើលនូវភិក្ខុសង្ឃ ដែលស្ងៀមស្ងាត់ហើយ ទ្រង់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយណា ជាអរិយធម៌ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសម្ពោធិញាណ

តេសំ វោ ភិក្ខវេ កុសលានំ ធម្មានំ អរិយានំ និយ្យានិកានំ សម្ពោធគាមីនំ កា ឧបនិសា សវនាយាតិ ឥតិ ចេ ភិក្ខវេ បុច្ឆិតារោ អស្សុ តេ ឯវមស្សុ វចនីយា យាវទេវ ទ្វយតានំ ធម្មានំ យថាភូតំ ញាណាយាតិ(១) កិញ្ច ទ្វយតំ វទេថ ឥទំ ទុក្ខំ អយំ ទុក្ខសមុទយោតិ អយមេកានុបស្សនា អយំ ទុក្ខនិរោធោ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ អយំ ទុតិយានុបស្សនា ឯវំ សម្មាទ្វយតានុបស្សិនោ(២) ភិក្ខវេ ភិក្ខុនោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

---

១ ម. ភាណាយាតិ ។ ២ ឱ. ម. សម្មា ទ្វយតានុបស្សិនោ ហោ ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ មានគេសួរអ្នកទាំងឡាយថា ប្រយោជន៍អ្វីដល់អ្នកទាំងឡាយ ក្នុងកិរិយាស្ដាប់នូវកុសលធម៌ទាំងឡាយនោះ ដែលជាអរិយធម៌ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសម្ពោធិញ្ញាណ ម្នាលភិក្ខុទាំងឡាយ អ្នកពល់គ្នា គួរពោលយ៉ាងនេះទៅនឹងជនទាំងនោះវិញថា ប្រយោជន៍ដើម្បីដឹងតាមពិតនូវសភាពនៃធម៌ជាគូនឹងគ្នាជាកំណត់ អ្នកពល់គ្នាពោលនូវសភាពនៃធម៌ ដែលគូនឹងគ្នា តើដូចម្ដេច (គប្បីពោល) ថា នេះជាទុក្ខ នេះជាហេតុនាំឲ្យកើតទុក្ខ នេះជាអនុបស្សនា ទី ១ នេះជាទីរលត់ទុក្ខ នេះជាបដិបទាទៅកាន់ទីរលត់ទុក្ខ នេះជាអនុបស្សនា ទី ២ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុពិចារណាឃើញរឿយៗ នូវសភាពនៃធម៌ជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បណ្ដាផលទាំងពីរប្រការ ផលណាមួយនឹងប្រាកដ គឺនឹងបាននូវអរហត្តផលក្នុងបច្ចុប្បន្ន ឬមួយបើខន្ធដ៏សេស ដែលគប្បីកើតតទៅទៀតនៅមាន នឹងបានដល់នូវអនាគាមិផល ។ ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះ លុះព្រះសុគត ជាសាស្ដា ទ្រង់ត្រាស់ពាក្យនេះហើយ ទើបទ្រង់ត្រាស់គាថាព័ន្ធ តទៅទៀតថា

(៧៨) យេ ទុក្ខំ នប្បជានន្តិ អថោ ទុក្ខស្ស សម្ភវំ
យត្ថ ច សព្វសោ ទុក្ខំ អសេសំ ឧបរុជ្ឈតិ
តញ្ច មគ្គំ ន ជានន្តិ ទុក្ខូបសមគាមិនំ
ចេតោវិមុត្តិហីនា តេ អថោ បញ្ញាវិមុត្តិយា
អភព្វា តេ អន្តកិរិយាយ តេ វេ ជាតិជរូបគា ។
យេ ច ទុក្ខំ បជានន្តិ អថោ ទុក្ខស្ស សម្ភវំ
យត្ថ ច សព្វសោ ទុក្ខំ អសេសំ ឧបរុជ្ឈតិ
តញ្ច មគ្គំ បជានន្តិ ទុក្ខូបសមគាមិនំ
ចេតោវិមុត្តិសម្បន្នា អថោ បញ្ញាវិមុត្តិយា
ភព្វា តេ អន្តកិរិយាយ ន តេ ជាតិជរូបគាតិ ។

(៧៩) សិយា អញ្ញេនបិ បរិយាយេន សម្មាទ្វយតានុបស្សនាតិ ឥតិ ចេ ភិក្ខវេ បុច្ឆិតារោ អស្សុ សិយាតិស្សុ វចនីយា កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ ឧបធិប្បច្ចយាតិ អយមេកានុបស្សនា ឧបធីនំ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា

(៧៨) ពួកជនណា មិនដឹងច្បាស់នូវទុក្ខ ទាំងនូវហេតុនាំឲ្យកើតទុក្ខ នូវព្រះនិព្វានជាទីរំលត់ទុក្ខ មិនសេសសល់ដោយសព្វគ្រប់ ទាំងមិនដឹងនូវផ្លូវ ទៅកាន់ទីរម្ងាប់ទុក្ខនោះ ពួកជននោះ សាបសូន្យហើយចាកចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ពួកជននោះ មិនគួរ ដើម្បីនឹងធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃវដ្តទុក្ខបាន ពួកជននោះ ចូលទៅកាន់ជាតិនិងជរាតែម្យ៉ាង ។ ពួកជនណា ដឹងច្បាស់នូវទុក្ខ នូវហេតុនាំឲ្យកើតទុក្ខ នូវព្រះនិព្វាន ជាទីរំលត់ទុក្ខ ឥតសេសសល់ ដោយសព្វគ្រប់ ទាំងដឹងច្បាស់នូវផ្លូវដែលទៅកាន់ទីរម្ងាប់ទុក្ខនោះ ពួកជននោះ បរិបូណ៌ដោយចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ពួកជននោះ ទើបគួរនឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃវដ្តទុក្ខបាន ពួកជននោះ មិនចូលទៅកាន់ជាតិនិងជរាឡើយ ។

(៧៩) ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ គេសួរថា ការពិចារណានូវសភាពនៃធម៌ដែលជាគូនឹងគ្នាដោយប្រពៃ ដោយបរិយាយដទៃទៀតមានដែរឬ អ្នកពល់គ្នាគួរប្រាប់ថា មាន តើមានដូចម្តេច (គួរប្រាប់ថា) ទុក្ខនីមួយទាំងអស់តែងកើតឡើង ព្រោះឧបធិជាបច្ច័យ នេះជាអនុបស្សនាទី ១ មួយទៀត ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេកមិនសេសសល់នៃពួកឧបធិធម៌គឺកម្ម នេះជាអនុបស្សនាទី ២

ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

ឧបធិនិទានា បភវន្តិ(១) ទុក្ខា
យេ កេចិ លោកស្មឹ អនេករូបា
យោ វេ អវិទ្វា ឧបធឹ ករោតិ
បុនប្បុនំ ទុក្ខមុបេតិ មន្ទោ
តស្មា បជានំ ឧបធឹ ន កយិរា
ទុក្ខស្ស ជាតិប្បភវានុបស្សីតិ ។

(៩០) សិយា អញ្ញេនបិ បរិយាយេន សម្មាទ្វយតានុបស្សនាតិ ឥតិ ចេ ភិក្ខវេ បុច្ឆិតារោ អស្សុ សិយាតិស្សុ វចនីយា កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អាហារបច្ចយាតិ អយមេកានុបស្សនា អាហារានំ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មាទ្វយតានុបស្សិនោ ។ បេ ។

---

១ ម. ភវន្តិ ។

ភិក្ខុអ្នកពិចារណាឃើញនូវសភាពនៃធម៌ ដែលជាគូនឹងគ្នា ដោយប្រពៃ យ៉ាងនេះ ។ បេ ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

ទុក្ខទាំងឡាយ រមែងកើតឡើង ព្រោះមានឧបធិ (កម្ម) ជា
បច្ច័យ ពួកសត្វណានីមួយក្នុងលោក មានរូបច្រើនប្រការ (រមែង
ទទួលនូវទុក្ខនោះ) បុគ្គលពាលណា មិនស្គាល់ច្បាស់ហើយ
ធ្វើនូវឧបធិ បុគ្គលពាល (នោះ) តែងបាននូវទុក្ខរឿយៗ ព្រោះ
ហេតុនោះ អ្នកប្រាជ្ញពិចារណាឃើញនូវឧបធិ ជាហេតុឲ្យកើតទុក្ខ
កាលស្គាល់ច្បាស់ មិនគប្បីធ្វើនូវឧបធិឡើយ ។

(៨០) ម្នាលភិក្ខុទាំងឡាយ ប្រសិនបើមានគេសួរថា ការពិចារណានូវសភាពនៃធម៌ ដែលជាគូនឹងគ្នាដោយប្រពៃ ដោយបរិយាយដទៃទៀត មានដែរឬ អ្នកពល់គ្នាគប្បីតបថា មាន តើមានដូចម្ដេច (ត្រូវប្រាប់ថា) ទុក្ខទីមួយ ទាំងអស់តែងកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ នេះជាអនុបស្សនាទី ១ មួយទៀត ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃអវិជ្ជា នេះជាអនុបស្សនាទី២ ភិក្ខុពិចារណាឃើញនូវសភាពនៃធម៌ ដែល ជាគូនឹងគ្នាដោយប្រពៃយ៉ាងនេះ ។ បេ ។

អថាបរំ ឯតទវោច សត្ថា

ជាតិមរណសំសារំ យេ វជន្តិ បុនប្បុនំ(១)

ឥត្ថភាវញ្ញថាភាវំ អវិជ្ជាយេវ សា គតិ ។

អវិជ្ជា ហាយំ មហាមោហោ យេនិទំ សំសរិតំ(២) ចិរំ(៣)

វិជ្ជាគតា យេវ សត្តា ន តេ គច្ឆន្តិ បុនព្ភវន្តិ ។

(៨១) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ សង្ខារប្បច្ចយាតិ អយមេកានុបស្សនា សង្ខារានំ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ សង្ខារបច្ចយា

សង្ខារានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ ។

១ ម. ជាតិមរណសំសារំ ភវន្តិច បុនប្បុនំ ។ ២ ខ. យេនិទំ សំសិតំ ។ ម. យេទិទំ សំសិតំ ។ ៣ ខ. វិជ្ជាគតា ច យេ សត្តា នាគច្ឆន្តិ បុនព្ភវន្តិ ។ ម. វិជ្ជាគតា ច យេ សត្តា ន តេ គច្ឆន្តិ បុនព្ភវន្តិ ។

ព្រះសាស្តា ទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

ពួកសត្វ រមែងទៅកាន់ជាតិមរណៈ និងការអន្ទោលទៅកាន់ភពថ្មី រឿយៗ (ដោយអវិជ្ជាគតិណា) អវិជ្ជាគតិនោះ មិនដឹងនូវ សភាព ជាមនុស្សនេះផង និងភាពនៃនិកាយដទៃផង ។ ការ អន្ទោលទៅ (កាន់ភព) អស់កាលដ៏វែងនេះ ក៏ព្រោះតែអវិជ្ជា គឺមោហៈធំនេះឯង ពួកសត្វណាដែលមានវិជ្ជាគតិ ពួកសត្វនោះ រមែងមិនទៅកាន់ភពថ្មីទៀតឡើយ ។

(៨១) ដោយបរិយាយ ដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្តេច (គប្បីប្រាប់ថា) ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះសង្ខារជាបច្ច័យ នេះជាអនុបស្សនាទី១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃសង្ខារ នេះ ជាអនុបស្សនាទី២ ភិក្ខុអ្នកពិចារណាឃើញនូវសភាព នៃធម៌ដែលជាគូ និងគ្នាដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្តាទ្រង់ត្រាស់ គាថាព័ន្ធដទៃ តទៅទៀតថា

ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះសង្ខារជាបច្ច័យ ការ កើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ទៅនៃសង្ខារទាំងឡាយ ។

ឯតមាទីនវំ ញត្វា ទុក្ខំ សង្ខារបច្ចយា
សព្វសង្ខារសមថា សញ្ញានំ(១) ឧបរោធនា
ឯវំ ទុក្ខក្ខយោ ហោតិ ឯតំ ញត្វា យថាតថំ ។
សម្មទ្ទសា វេទគុនោ សម្មទញ្ញាយ បណ្ឌិតា
អភិភុយ្យ មារសំយោគំ ន គច្ឆន្តិ បុនព្ភវន្តិ ។

(៨២) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កិញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ វិញ្ញាណប្បច្ចយាតិ អយមេកានុបស្សនា វិញ្ញាណស្ស ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ វិញ្ញាណបច្ចយា
វិញ្ញាណស្ស និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ ។
ឯតមាទីនវំ ញត្វា ទុក្ខំ វិញ្ញាណបច្ចយា
វិញ្ញាណូបសមា ភិក្ខុ និច្ឆាតោ បរិនិព្វុតោតិ ។

---

១ ឱ. សញ្ញាយ ។

អ្នកប្រាជ្ញជ្រាបនូវទោសនុ៎ះថា ទុក្ខកើតឡើង ព្រោះសង្ខារជាបច្ច័យ ព្រោះរម្ងាប់នូវសង្ខារទាំងពួង ព្រោះរំលត់ទៅនៃកាមសញ្ញាជាដើមបាន ព្រោះជ្រាបនូវកងទុក្ខនុ៎ះតាមពិត ។ បណ្ឌិតទាំងឡាយអ្នកដល់នូវវេទ ឃើញដោយប្រពៃ ជ្រាបដោយប្រពៃ គ្របសង្កត់នូវមារសំយោគ គឺវដ្ដៈក្នុងភូមិទាំង ៣ ហើយ រមែងមិនត្រឡប់មកកាន់ភពថ្មីទៀតឡើយ ។

(៨២) ដោយបរិយាយ ដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្ដេច (ត្រូវប្រាប់ថា) ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ នេះជាអនុបស្សនា ទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃវិញ្ញាណ នេះជាអនុបស្សនា ទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយ ៗ នូវសភាពនៃធម៌ ដែលជាគូនឹងគ្នាដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់វិញ្ញាណ ។ អ្នកប្រាជ្ញដឹងនូវទោសនេះថា ទុក្ខ (កើតឡើង) ព្រោះវិញ្ញាណជាបច្ច័យ ភិក្ខុមិនមានតណ្ហា បានបរិនិព្វាន ព្រោះរម្ងាប់បង់នូវវិញ្ញាណ ។

(៨៣) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ ផស្សបច្ចយាតិ អយមេកានុបស្សនា ផស្សស្ស ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

តេសំ ផស្សបរេតានំ ភវសោតានុសារិនំ
កុម្មគ្គំ បដិបន្នានំ អារា សំយោជនក្ខយោ[១] ។
យេ ច ផស្សំ បរិញ្ញាយ បញ្ញាយ[២] ឧបសមេ រតា
តេ វេ[៣] ផស្សាភិសមយា និច្ឆាតា បរិនិព្វុតាតិ ។

(៨៤) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ វេទនាបច្ចយាតិ អយមេកានុបស្សនា វេទនានំ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា

---

១ ម. សំយោជនក្ខយា ។ ២ ឱ. ម. អញ្ញាយ ។ ៣ ឱ. តេ វេ ។

(៨៣) ដោយបរិយាយដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្តេច (គួរប្រាប់ថា) ទុក្ខទីមួយទាំងអស់តែងកើតឡើង ព្រោះផស្សៈជាបច្ច័យ នេះជាអនុបស្សនាទី១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃផស្សៈ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញហើយ ។ នូវសភាពធម៌ដែលជាគូនឹងគ្នាយ៉ាងនេះឯង ។ បេ ។ ព្រះសាស្តា ទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ការអស់សំយោជនៈជាធម៌ឃ្លាត របស់ពួកជនទាំងនោះ ដែលមានផស្សៈគ្របសង្កត់ហើយ ប្រព្រឹត្តតាមខ្សែតណ្ហាក្នុងភព ជាអ្នកប្រតិបត្តិតាមផ្លូវខុស ។ ពួកជនណា កំណត់ដឹងនូវផស្សៈគ្រប់អង្គ ព្រោះនិព្វានជាទីរម្ងាប់ (សង្ខារទាំងពួង) ដោយបញ្ញា ពួកជននោះ មិនមានតណ្ហា រមែងបរិនិព្វាន ព្រោះរលត់បង់នូវផស្សៈ ។

(៨៤) ដោយបរិយាយដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្តេច (គួរប្រាប់ថា) ទុក្ខទីមួយទាំងអស់ តែងកើតឡើងព្រោះវេទនាជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃវេទនា នេះជាអនុបស្សនាទី ២

ឯវំ សម្មាទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

សុខំ វា យទិ វា ទុក្ខំ អទុក្ខមសុខំ សហ(១)
អជ្ឈត្តញ្ច ពហិទ្ធា ច យំ កិញ្ចិ អត្ថិ វេទិតំ
ឯតំ ទុក្ខន្តិ ញត្វាន មោសធម្មំ បលោកិនំ
ផុស្ស ផុស្ស វយំ បស្សំ ឯវំ តត្ថ វិជានតិ(២) ។
វេទនានំ ខយា យេវ នត្ថិ ទុក្ខស្ស សម្ភវោតិ(៣) ។

(៨៤) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ តណ្ហាបច្ចយាតិ អយមេកានុបស្សនា តណ្ហាយ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មាទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

---

១ ឱ. សហា ។ ២ ឱ. វិរជ្ជតិ ។ ម. វិជានាតិ ។ ៣ ឱ. ម. វេទនានំ ខយា ភិក្ខុ និច្ឆាតោ បរិនិព្វុតោតិ ។

ភិក្ខុអ្នកពិចារណាឃើញរឿយ ៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្តា ទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

អ្នកប្រាជ្ញប្រាប់ថា ធម្មជាតនីមួយ ទោះបីជាសុខឬជាទុក្ខ ព្រមទាំងមិនទុក្ខមិនសុខ ដែលមានខាងក្នុងក្តី ខាងក្រៅក្តី ដែលសត្វទទួលហើយ ធម្មជាតនុ៎ះសុទ្ធតែជាទុក្ខ បានពាល់ត្រូវសំរេចនូវធម៌សម្រាប់វិនាសនឹងធម៌សម្រាប់ទ្រុឌទ្រោម (ដោយឧទយព្វយញាណ) ឃើញនូវការសូន្យទៅ ដឹងច្បាស់វេទនានោះដោយប្រការដូច្នេះ ។ ការកើតឡើងនៃទុក្ខមិនមាន ព្រោះអស់ទៅនៃវេទនាទាំងឡាយ ។

(៨៩) ដោយបរិយាយ ដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្តេច (គួរប្រាប់ថា) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះតណ្ហាជាបច្ច័យ នេះជាអនុបស្សនា ទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃតណ្ហា នេះជាអនុបស្សនា ទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយ ៗ នូវសភាពធម៌ ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

តណ្ហាទុតិយោ បុរិសោ ទីឃមទ្ធាន សំសរំ
ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ ។
ឯតមាទីនវំ ញត្វា តណ្ហា ទុក្ខស្ស សម្ភវំ
វីតតណ្ហោ អនាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

(១៦) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ ឧបាទានប្បច្ចយាតិ អយមេកានុបស្សនា ឧបាទានស្ស ត្វេវ(១) អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

ឧបាទានបច្ចយា ភវោ ភូតោ ទុក្ខំ និគច្ឆតិ
ជាតស្ស មរណំ ហោតិ ឯសោ ទុក្ខស្ស សម្ភវោ ។

---

១ ម. ឧបាទានេត្វេវ ។

បុរសដែលមានតណ្ហាជាគំរប់ពីរ (នឹងខ្លួន) រមែងអន្ទោលទៅកាន់អត្តភាពនេះនឹងអត្តភាពដទៃ អស់កាលយូរអង្វែង មិនអាចនឹងប្រព្រឹត្តកន្លងសង្សារបានឡើយ ។ ភិក្ខុលុះដឹងទោសនៃតណ្ហានុ៎ះជាហេតុឲ្យកើតទុក្ខ គប្បីជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្ដីប្រកាន់ មានសតិវៀរចេញ (ចាកតណ្ហាឧបាទាន) ។

(៨៦) ដោយបរិយាយដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្ដេច (គួរប្រាប់ថា) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះឧបាទានជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនសេសសល់នៃឧបាទាន នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយ ៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្ដាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ សត្វដែលកើតហើយ
រមែងបាននូវទុក្ខ មរណៈក៏កើតមាន ដល់សត្វដែលកើតហើយ
ដែរ នេះជាសភាវៈ កើតឡើងព្រមនៃទុក្ខ ។

តស្មា ឧបាទានក្ខយា សម្មទញ្ញាយ បណ្ឌិតា
ជាតិក្ខយំ អភិញ្ញាយ ន គច្ឆន្តិ បុនព្ភវន្តិ ។

(៨៧) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារម្ភប្បច្ចយាតិ(១) អយមេកានុបស្សនា អារម្ភានំ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មាទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អារម្ភបច្ចយា
អារម្ភានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ ។
ឯតមាទីនវំ ញត្វា ទុក្ខំ អារម្ភបច្ចយា

១ ម. អារម្ភប្បច្ចយោតិ ។

ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ មិនត្រឡប់មកកាន់ភពថ្មីវិញទៀត ព្រោះអស់ឧបាទាន ព្រោះដឹងត្រូវ ព្រោះជ្រាបច្បាស់នូវព្រះនិព្វាន ជាទីអស់ទៅនៃជាតិ ៗ

(៨៧) ដោយបរិយាយដទៃទៀត មានដែរឬ ៗ បេ ៗ តើមានដូចម្តេច (គួរប្រាប់ថា) ទុក្ខទាំងមួយឡើយទាំងអស់ តែងកើតឡើង ព្រោះព្យាយាម (ដ៏សម្បយុត្តដោយកម្ម) ជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះលេតដោយប្រាសចាកតម្រេក មិនមានសេសសល់នៃព្យាយាម នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញស្មើយ ៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ៗ បេ ៗ ព្រះសាស្តា ទ្រង់ត្រាស់គាថាព័ន្ធដទៃតទៅទៀតថា

ទុក្ខទាំងមួយ ទាំងអស់ តែងកើតឡើង ព្រោះព្យាយាម ជាបច្ច័យ

ការមិនកើតឡើងនៃទុក្ខ ព្រោះលេតនូវព្យាយាម ៗ អ្នកប្រាជ្ញ

ជ្រាបនូវទោសនុះថា ទុក្ខកើតឡើង ព្រោះព្យាយាម ជាបច្ច័យ

សព្វារម្ភំ បដិនិស្សជ្ជ អនារម្ភេ វិមុត្តិនោ
ឧច្ឆិន្នភវតណ្ហស្ស សន្តចិត្តស្ស ភិក្ខុនោ
វិក្ខីណោ(១) ជាតិសំសារោ នត្ថិ តស្ស បុនព្ភវោតិ ។

(៨៨) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អាហារប្បច្ចយាតិ អយមេកានុបស្សនា អាហារានំ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ អាហារបច្ចយា
អាហារានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ ។
ឯតមាទីនវំ ញត្វា ទុក្ខំ អាហារបច្ចយា

---

១ ឱ. វិកិណ្ណោ ។

ហើយកិលេសទាល់នូវព្យាយាមទាំងពួងចេញ កាលភិក្ខុស្ងប់ក្នុងព្រះនិព្វានជាដែនមិនមានព្យាយាម បានផ្តាច់ផ្តិលនូវតណ្ហាក្នុងភព មានចិត្តស្ងប់រម្ងាប់ហើយ ការអន្ទោលទៅកាន់ជាតិក៏អស់ហើយ ភិក្ខុនោះមិនមានភពថ្មីទៀតឡើយ ។

(៤៨) ដោយបរិយាយដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្តេច (គួរប្រាប់ថា) ទុក្ខមួយទាំងអស់ តែងកើតឡើង ព្រោះអាហារជាបច្ច័យ នេះជាអនុបស្សនា ទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃអាហារ នេះជាអនុបស្សនា ទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗនូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

ទុក្ខមួយទាំងអស់ តែងកើតឡើង ព្រោះអាហារជាបច្ច័យ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់អាហារ ។ អ្នកប្រាជ្ញលុះជ្រាបនូវទោសនុ៎ះថា ទុក្ខ (កើតឡើង) ព្រោះអាហារជាបច្ច័យ

សព្ពាហារេ(១) បរិញ្ញាយ សព្ពាហារេ អនិស្សិតោ

អារោគ្យំ សម្មទញ្ញាយ អាសវានំ បរិក្ខយា

សង្ខាយ សេវី ធម្មដ្ឋោ សង្ខ្យំ នោបេតិ វេទគូតិ ។

(៨៩) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។

កថញ្ច សិយា យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ ឥញ្ជិតបច្ចយាតិ អយមេកានុបស្សនា ឥញ្ជិតានំ ត្វេវ អសេសវិរាគនិរោធា នត្ថិ ទុក្ខស្ស សម្ភវោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

យំ កិញ្ចិ ទុក្ខំ សម្ភោតិ សព្វំ ឥញ្ជិតបច្ចយា(២)

ឥញ្ជិតានំ និរោធេន នត្ថិ ទុក្ខស្ស សម្ភវោ ។

---

១ ឱ. ម. សព្ពាហារំ ។ ២ ប. ឥញ្ជិតប្បច្ចយា ។

ហើយមិនអាស្រ័យនូវអាហារទាំងពួង ព្រោះកំណត់ដឹងនូវអាហារ ទាំងពួង ជាអ្នកពិចារណាហើយទើបសេព (បច្ច័យ ៤) តាំងនៅក្នុងសច្ចធម៌ មិនដល់នូវការរាប់ (ថាជាមនុស្សឬទេវតា) ព្រោះជ្រាបច្បាស់ដោយប្រពៃ នូវព្រះនិព្វាន ជាដែនមិនមានរោគ ព្រោះអស់នៃអាសវៈទាំងឡាយ ។

(៨៩) ដោយបរិយាយដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្តេច (ត្រូវប្រាប់ថា) ទុក្ខនីមួយទាំងអស់ តែងកើតឡើងព្រោះធម៌ជាគ្រឿងញាប់ញ័រជាបច្ច័យ នេះជាអនុបស្សនាទី ១ ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់ដោយប្រាសចាកតម្រេក មិនមានសេសសល់នៃធម៌ជាគ្រឿងញាប់ញ័រ នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃ យ៉ាងនេះឯង ។ បេ ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

ទុក្ខនីមួយទាំងអស់ តែងកើតឡើង ព្រោះសេចក្តីញាប់ញ័រជាបច្ច័យ
ការកើតឡើងនៃទុក្ខមិនមាន ព្រោះរលត់នៃសេចក្តីញាប់ញ័រ ។

ឯតមាទីនវំ ញត្វា ទុក្ខំ ឥញ្ជិតបច្ចយា
តស្មា ហិ ឯជំ វោសជ្ជ សង្ខារេ ឧបរុន្ធិយា(១)
អនេជោ អនុបាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

(៩០) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។
កថញ្ច សិយា និស្សិតស្ស ចលិតំ ហោតីតិ អ-
យមេកានុបស្សនា អនិស្សិតោ ន ចលតីតិ អយំ
ទុតិយានុបស្សនា ឯវំ សម្មាទ្វយតានុបស្សិនោ ។ បេ ។
អថាបរំ ឯតទវោច សត្ថា

អនិស្សិតោ ន ចលតិ និស្សិតោ ច ឧបាទិយំ
ឥត្ថភាវញ្ញថាភាវំ សំសារំ នាតិវត្តតិ ។
ឯតមាទីនវំ ញត្វា និស្សយេសុ មហព្ភយំ
អនិស្សិតោ អនុបាទានោ សតោ ភិក្ខុ បរិព្វជេតិ ។

---

១ ម. ឧបរុន្ធិយ ។

ភិក្ខុដឹងនូវទោសនុ៎ះថា ទុក្ខ (កើតឡើង) ព្រោះសេចក្តីញាប់ញ័រជាបច្ច័យ ព្រោះហេតុនោះ ភិក្ខុគប្បីលះបង់តណ្ហា រំលត់សង្ខារទាំងឡាយ ជាអ្នកមិនមានតណ្ហា មិនមានឧបាទាន វៀរស្រឡះចាកសេចក្តីញាប់ញ័រនោះ ។

(៩០) ដោយបរិយាយដទៃទៀត មានដែរឬ ។ បេ ។ តើមានដូចម្តេច (គួរប្រាប់ថា) សភាពញ័ររន្ធត់ តែងមានដល់បុគ្គលដែលអាស្រ័យ (តណ្ហា មានះ ទិដ្ឋិ) នេះជាអនុបស្សនា ទី ១ បុគ្គលដែលមិនអាស្រ័យ (តណ្ហា មានះ ទិដ្ឋិ) រមែងមិនរន្ធត់ឡើយ នេះជាអនុបស្សនា ទី ២ ភិក្ខុអ្នកពិចារណាឃើញហើយ ។ នូវសភាពធម៌ដែលជាគូនឹងគ្នាដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធដទៃ តទៅទៀតថា

បុគ្គលមិនអាស្រ័យ (តណ្ហា មានះ ទិដ្ឋិ) រមែងមិនរន្ធត់ បុគ្គលអ្នកអាស្រ័យនូវការប្រកាន់ រមែងមិនប្រព្រឹត្តកន្លងនូវការអន្ទោលទៅកាន់អត្តភាពនេះនឹងអត្តភាពដទៃ ។ ភិក្ខុដឹងនូវទោសនុ៎ះថាជាភ័យធំ ព្រោះការអាស្រ័យ (តណ្ហា មានះ ទិដ្ឋិ) គប្បីជាបុគ្គលមិនអាស្រ័យ (តណ្ហា មានះ ទិដ្ឋិ) មិនមានឧបាទាន មានសតិ វៀរស្រឡះ ។

(៩១) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា រូបេហិ ភិក្ខវេ អរូបា សន្តតរាតិ អយមេកានុបស្សនា អរូបេហិ(១) និរោធោ សន្តតរោតិ អយំ ទុតិយានុបស្សនា ឯវំ សម្មា ទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

យេ ច រូបូបគា សត្តា យេ ច អរូបដ្ឋាយិនោ(២)
និរោធំ អប្បជានន្តា អាគន្តារោ បុនព្ភវំ
យេ ច រូបេ បរិញ្ញាយ អរូបេសុ សុសណ្ឋិតា(៣)
និរោធេ យេវ មុច្ចន្តិ(៤) តេ ជនា មច្ចុហាយិនោតិ ។

(៩២) សិយា អញ្ញេនបិ បរិយាយេន ។ បេ ។ កថញ្ច សិយា យំ ភិក្ខវេ សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ឥទំ សច្ចន្តិ ឧបនិជ្ឈាយិតំ

១ ឧ. អារូបេហិ ។ ម. រូបេហិ ។ ២ ឧ. អារូបវាសិនោ ។ ៣ ម. អសណ្ឋិតា ។
៤ ឧ. និរោធេ យេ វិមុច្ចន្តិ ។

(៩១) ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្តេច ម្នាលភិក្ខុទាំងឡាយ ពួកអរូបល្អិតជាងពួករូប នេះជាអនុបស្សនាទី ១ ព្រះនិព្វានជាធម៌ល្អិតជាងពួកអរូប នេះជាអនុបស្សនាទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវសភាពធម៌ ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។បេ។ ព្រះសាស្តាទ្រង់ត្រាស់គាថា-ព័ន្ធដទៃ តទៅទៀតថា

ពួកសត្វណា តាំងនៅក្នុងរូបភពក្តី ពួកសត្វណា តាំងនៅក្នុងអរូបភពក្តី ពួកសត្វទាំងនោះ មិនស្គាល់ច្បាស់ នូវព្រះនិព្វាន ជាអ្នកត្រឡប់មក កាន់ភពថ្មីទៀត មួយទៀត ពួកជនណា កំណត់ដឹងក្នុងរូប ឋិតនៅក្នុងអរូប មានចិត្តជឿស៊ប់ក្នុងព្រះនិព្វាន ជនទាំងនោះឈ្មោះថា មានមច្ចុសាបសូន្យហើយ ។

(៩២) ដោយបរិយាយដទៃទៀត មានដែរឬ ។បេ។ តើមានដូចម្តេច ម្នាលភិក្ខុទាំងឡាយ នាមនិងរូបណា ដែលលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ពិនិត្យឃើញថា នេះជារបស់ពិត

តទមរិយានំ ឯតំ មុសាតិ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ អយមេកានុបស្សនា យំ កិញ្ចិ សទេវកស្ស ។ បេ ។ សទេវមនុស្សាយ ឥទំ មុសាតិ ឧបនិជ្ឈាយិតំ តទមរិយានំ ឯតំ សច្ចន្តិ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ អយំ ទុតិយានុបស្សនា ឯវំ សម្មាទ្វយតានុបស្សិនោ ។ បេ ។ អថាបរំ ឯតទវោច សត្ថា

អនត្តនិ អត្តមានី(១) បស្ស លោកំ សទេវកំ
និវិដ្ឋំ នាមរូបស្មឹ ឥទំ សច្ចន្តិ មញ្ញតិ ។
យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថា
តញ្ហិ តស្ស មុសា ហោតិ មោសធម្មញ្ហិ ឥត្តរំ ។

---

១ ខ. ម. អត្តមានំ ។

តែនាមនិងរូបនោះ ព្រះអរិយៈទាំងឡាយ ឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជារបស់មិនពិត នេះជាអនុបស្សនា ទី ១ ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានណា ដែលលោកព្រមទាំងទេវលោក ។បេ។ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេសពិនិត្យឃើញថា នេះជារបស់មិនពិត តែព្រះនិព្វាននោះ ព្រះអរិយៈទាំងឡាយ ឃើញច្បាស់ដោយចក្ខុដ៏ប្រពៃតាមពិតថា នុ៎ះជារបស់ពិត នេះជាអនុបស្សនា ទី ២ ភិក្ខុអ្នកពិចារណាឃើញរឿយ ៗ នូវសភាពធម៌ដែលជាគូនឹងគ្នា ដោយប្រពៃយ៉ាងនេះឯង ។ បេ ។ ព្រះសាស្តាទ្រង់ត្រាស់គាថាព័ន្ធតទៅទៀតថា

អ្នកចូរមើលនូវលោក ព្រមទាំងទេវលោក ដែលតាំងនៅក្នុងនាម
និងរូប បុគ្គលមានសេចក្តីសំគាល់ថា ខ្លួនក្នុងរបស់ដែលមិនមែនខ្លួន
តែងសំគាល់ថា នេះទៀង ៗ ពួកសត្វតែងសំគាល់ដោយរូប
ជាដើមណា ៗ ថា (រូបរបស់អញ វេទនារបស់អញ) នាមនិងរូបនោះ
ទៅជារបស់ដទៃអំពីការសំគាល់នោះ ព្រោះនាមនិងរូបនោះ
របស់សត្វនោះ ជារបស់មិនពិត ជាធម៌សោះសូន្យទទេ ។

អមោសធម្មំ និព្វានំ តទរិយា សច្ចតោ វិទូ

តេ វេ សច្ចាភិសមយា និច្ឆាតា បរិនិព្វុតាតិ ។

(៩៣) សិយា អញ្ញេនបិ បរិយាយេន សម្មាទ្វ-
យតានុបស្សនាតិ ឥតិ ចេ ភិក្ខវេ បុច្ឆិតារោ
អស្សុ សិយាតិស្សុ វចនីយា កថញ្ច សិយា យំ
ភិក្ខវេ សទេវកស្ស លោកស្ស សមារកស្ស
សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ
សទេវមនុស្សាយ ឥទំ សុខន្តិ ឧបនិជ្ឈាយិតំ
តទមរិយានំ ឯតំ ទុក្ខន្តិ យថាភូតំ សម្មប្បញ្ញាយ
សុទិដ្ឋំ អយមេកានុបស្សនា យំ ភិក្ខវេ សទេវកស្ស
លោកស្ស ។បេ។ សទេវមនុស្សាយ ឥទំ ទុក្ខន្តិ
ឧបនិជ្ឈាយិតំ តទមរិយានំ ឯតំ សុខន្តិ យថាភូតំ
សម្មប្បញ្ញាយ សុទិដ្ឋំ អយំ ទុតិយានុបស្សនា

ព្រះអរិយៈទាំងឡាយ ដឹងច្បាស់នូវព្រះនិព្វាននោះ ដែលជាធម៌មិនសោះសូន្យដោយពិត ទើបព្រះអរិយៈ ទាំងនោះ មិនមានតណ្ហា បានដល់ព្រះនិព្វាន ព្រោះបានត្រាស់ដឹងនូវសច្ចធម៌ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ ប្រសិនបើគេសួរថា ការពិចារណាឃើញរឿយ ៗ នូវសភាពធម៌ ដែលជាគូនឹងគ្នា ដោយប្រការដទៃទៀត មានដែរឬ ត្រូវប្រាប់ថា មាន តើមាន ដូចម្តេច ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ទាំង ៦ ប្រការ មានរូបារម្មណ៍ជាដើមណា ដែលលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស ពិនិត្យឃើញថា នេះជាសុខ ឯអារម្មណ៍នោះ ព្រះអរិយៈទាំងឡាយឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាទុក្ខវិញ នេះជាអនុបស្សនាទី ១ ម្នាលភិក្ខុទាំងឡាយ ព្រះនិព្វានណា ដែលលោកព្រមទាំងទេវលោក ។ បេ ។ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្សដ៏សេស ពិនិត្យឃើញថា នេះជាទុក្ខ ឯព្រះនិព្វាននោះ ព្រះអរិយៈទាំងឡាយ ឃើញច្បាស់ ដោយបញ្ញាដ៏ប្រពៃតាមពិតថា នេះជាសុខវិញ នេះជាអនុបស្សនា ទី ២

ឯវំ សម្មាទ្វយតានុបស្សិនោ ខោ ភិក្ខវេ ភិក្ខុ-
នោ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហ-
រតោ ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ
ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ
អនាគាមិតាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន
សុគតោ អថាបរំ ឯតទវោច សត្ថា

រូបា សទ្ទា គន្ធា រសា    ផស្សា ធម្មា ច កេវលា
ឥដ្ឋា កន្តា មនាបា ច    យាវតត្ថីតិ វុច្ចតិ
សទេវកស្ស លោកស្ស    ឯតេ វោ សុខសម្មតា
យត្ថ ចេតេ និរុជ្ឈន្តិ    តំ នេសំ ទុក្ខសម្មតំ ។
សុខន្តិ ទិដ្ឋមរិយេហិ    សក្កាយស្សុបរោធនំ
បច្ចនីកមិទំ ហោតិ    សព្វលោកេន(១) បស្សតំ ។

---
១ ម. បស្សលោកេន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកពិចារណាឃើញរឿយ ៗ នូវសភាវធម៌ ដែលជាគូគ្នា ដោយប្រពៃ យ៉ាងនេះហើយ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បណ្ដាផលទាំងពីរ ផលណាមួយនឹងកើតប្រាកដ គឺនឹងបាននូវអរហត្តផល ក្នុងបច្ចុប្បន្ន ឬមួយបើខន្ធដ៏សេសដែលគប្បីកើតតទៅទៀត នៅមាន នឹងបានដល់នូវអនាគាមិផល ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះ លុះព្រះសុគត ជាសាស្ដាទ្រង់ត្រាស់ពាក្យនេះហើយ ទើបទ្រង់ត្រាស់គាថាព័ន្ធ តទៅទៀតថា

រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ ទាំងអស់ ជាទីប្រាថ្នា ជាទីស្រឡាញ់ ទីងជាទីគាប់ចិត្ត លោកពោលថាមាននៅដរាបណា អារម្មណ៍ទាំងនុ៎ះ សត្វលោកព្រមទាំងទេវលោកសន្មតថាជាសុខ (ដរាបនោះ) អារម្មណ៍ទាំងនោះតែងរលត់ទៅ ក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ពួកសត្វលោកទាំងនោះ សន្មតថាជាទុក្ខវិញ ។ ការរលត់នូវសក្កាយគឺខន្ធទាំង ៥ ព្រះអរិយៈទាំងឡាយ ឃើញថាជាសុខពិត ការឃើញ (របស់ព្រះអរិយៈ) អ្នកយល់នេះ ជាទីទាស់នឹងសត្វលោកទាំងពួង ។

យំ បរេ សុខតោ អាហុ  តទរិយា អាហុ ទុក្ខតោ

យំ បរេ ទុក្ខតោ អាហុ  តទរិយា សុខតោ វិទូ

បស្ស ធម្មំ ទុរាជានំ  សម្មូឡ្ហេត្ថ អវិទ្ទសុ ។

និវុតានំ តមោ ហោតិ  អន្ធការោ អបស្សតំ

សតញ្ច វិវដំ ហោតិ  អាលោកោ បស្សតាមិវ

សន្តិកេ ន វិជានន្តិ  មគា ធម្មស្ស កោវិទា ។

ភវរាគបរេតេហិ  ភវសោតានុសារិហិ

មារធេយ្យានុបន្នេហិ  នាយំ ធម្មោ សុសម្ពុធោ ។

កោ នុ អញ្ញត្រ អរិយេហិ  បទំ សម្ពុទ្ធមរហតិ

យំ បទំ សម្មទញ្ញាយ  បរិនិព្វន្តិ អនាសវា ។

ពួកជនពាលដទៃ ពោលនូវវត្ថុកាមណាថាជាសុខ ព្រះអរិយៈទាំងឡាយ ពោលនូវវត្ថុកាមនោះថាជាទុក្ខ ពួកជនពាលដទៃ ពោលនូវព្រះនិព្វានណាថា ទុក្ខ ព្រះអរិយៈទាំងឡាយដឹងច្បាស់នូវព្រះនិព្វាននោះថាជាសុខ អ្នកចូរឃើញនូវនិព្វានធម៌ ដែលដឹងបានដោយក្រ ពួកអ្នកមិនដឹងវង្វេងហើយក្នុងធម៌នុ៎ះ ៗ សេចក្តីងងឹតធ្វើនូវភាពខ្វាក់ តែងប្រាកដដល់ពួកជនពាល ដែលអវិជ្ជាបិទបាំង មិនឃើញនូវព្រះនិព្វាន ឯព្រះនិព្វានដូចជាពន្លឺ រមែងបើកបង្ហាញដល់ពួកសប្បុរសអ្នកឃើញ ពួកជនអ្នកមិនឈ្លាសវៃនូវធម៌គឺព្រះនិព្វាន រមែងមិនដឹងច្បាស់ (នូវព្រះនិព្វាន សូម្បីមាន) ក្នុងទីជិតឡើយ ៗ ព្រះនិព្វាននេះ ពួកជនពាលដែលមានភវរាគៈ គ្របសង្កត់ហើយ កំពុងអន្ទោលទៅ តាមខ្សែក្នុងភព កើតហើយក្នុងកន្ទ្វង់របស់មារ មិនងាយនឹងត្រាស់ដឹងបានឡើយ ៗ នរណាហ្ន៎ វៀរលែងតែព្រះអរិយៈចេញ គួរនឹងត្រាស់ដឹងនូវព្រះនិព្វានបាន ព្រះអរហន្តទាំងឡាយ មិនមានអាសវធម៌ បរិនិព្វានហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ នូវព្រះនិព្វាន ៗ

(៩៤) ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ សដ្ឋិមត្តានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ ។

ទ្វយតានុបស្សនាសុត្តំ ទ្វាទសមំ ។

## តត្រុទ្ទានំ

សច្ចំ ឧបធិ អវិជ្ជា ច សង្ខារវិញ្ញាណបញ្ចមំ
ផស្សវេទនិយា តណ្ហា ឧបាទានារម្ភអាហារា
ឥញ្ជិតំ ផន្ទិតំ រូបំ សច្ចំ ទុក្ខេន សោឡសាតិ ។

មហាវគ្គោ តតិយោ ។

## តស្សុទ្ទានំ

បព្វជ្ជា ច បធានា ច សុភា ច សុន្ទរី តថា
មាឃសុត្តសភិយោ ច សេលោ សល្លំ បវុច្ចតិ
វាសេដ្ឋោ ចាបិ កោកាលិ នាឡកោ ទ្វយតានុបស្សនំ
ទ្វាទសេតានិ សុត្តានិ មហាវគ្គោតិ វុច្ចតីតិ ។

[៩៤] ព្រះមានព្រះភាគទ្រង់ត្រាស់សូត្រនេះរួចហើយ ។ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគទ្រង់ពោលវេយ្យាករណ៍នេះ ពួកភិក្ខុប្រមាណ ៦០ រូប មានចិត្តរួចស្រឡះចាកអាសវធម៌ ព្រោះមិនមានឧបាទាន ។

ចប់ ទ្វយតានុបស្សនាសូត្រទី ១២ ។

## ឧទ្ទានក្នុងទ្វយតានុបស្សនាសូត្រនោះគឺ

និយាយអំពីចតុរារិយសច្ច ១ ឧបធិ ១ អវិជ្ជា ១ សង្ខារ ១ វិញ្ញាណ ១ ជាគម្រប់ប្រាំ ផស្សៈ ១ វេទនា ១ តណ្ហា ១ ឧបាទាន ១ អារម្ភៈ (ព្យាយាម) ១ អាហារ ១ សេចក្តីញាប់ញ័រ ១ ការរន្ធត់ ១ រូប ១ សច្ច ១ ទុក្ខ ១ ជា ១៦ ។

ចប់ មហាវគ្គ ទី ៣ ។

## ឧទ្ទាននៃមហាវគ្គនោះគឺ

និយាយអំពីបព្វជ្ជាសូត្រ ១ បធានសូត្រ ១ សុភាសិតសូត្រ ១ សុន្ទរិកភារទ្វាជសូត្រ ១ មាឃសូត្រ ១ សភិយសូត្រ ១ សេលសូត្រ ១ សល្លសូត្រ ១ សេដ្ឋសូត្រ ១ កោកាលិកសូត្រ ១ នាឡកសូត្រ ១ ទ្វយតានុបស្សនាសូត្រ ១ សូត្រទាំង ១២ នុ៎ះហៅថា មហាវគ្គ ។

# បឋមំ កាមសុត្តំ

[៩៤] កាមំ កាមយមានស្ស តស្ស ចេ តំ សមិជ្ឈតិ
អទ្ធា បីតិមនោ ហោតិ លទ្ធា មច្ចោ យទិច្ឆតិ ។
តស្ស ចេ កាមយានស្ស(១) ឆន្ទជាតស្ស ជន្តុនោ
តេ កាមា បរិហាយន្តិ សល្លវិទ្ធោវ រុប្បតិ ។
យោ កាមេ បរិវជ្ជេតិ សប្បស្សេវ បទា សិរោ
សោមំ វិសត្តិកំ លោកេ សតោ សមតិវត្តតិ ។
ខេត្តំ វត្ថុំ ហិរញ្ញំ វា គវស្សំ ទាសបោរិសំ
ថិយោ ពន្ធូ បុថូ កាមេ យោ នរោ អនុគិជ្ឈតិ
អពលា(២) នំ ពលីយន្តិ មទ្ទន្តេ នំ បរិស្សយា
តតោ នំ ទុក្ខមន្វេតិ នាវំ ភិន្នមិវោទកំ ។
តស្មា ជន្តុ សទា សតោ កាមានិ បរិវជ្ជយេ
តេ បហាយ តរេ ឱឃំ នាវំ សិត្វាវ(៣) បារគូតិ ។

កាមសុត្តំ បឋមំ ។

---

១ ម. កាមយមានស្ស ។ ២ ឱ. អពលាវ នំ ។ ៣ ឱ. សិញ្ចិត្វា ។

# កាមសូត្រ ទី ១

(៩៥) កាលសត្វ ប្រាថ្នាកាមណា បើកាមនោះសម្រេច ដល់សត្វនោះ លុះសត្វ (នោះ) បានតាមប្រាថ្នាហើយ រមែងមានចិត្តប្រកបដោយបីតិ ដោយពិត ។ កាលបើ សត្វនោះប្រាថ្នា មានឆន្ទៈកើតហើយ កាមនោះសាបសូន្យទៅ សត្វក៏សុបសៅទៅ ដូចជាមុតដោយសរ ។ សត្វណា វៀរស្រឡះចាកកាមទាំងឡាយ ដូចជាបុរសគេចនឹងក្បាលពស់ ដោយជើងរបស់ខ្លួន សត្វនោះ ជាអ្នកមានសតិ ប្រព្រឹត្តកន្លងនូវតណ្ហាជាគ្រឿងផ្សាយទៅនេះ ក្នុងលោកបាន ។ មួយទៀត ជនណាជាប់ចំពាក់នឹងស្រែ ចំការ កន្លែង ប្រាក់ គោ សេះ នឹងបុរសជាខ្ញុំ ពួកស្ត្រី ពួកផៅពង្សនឹងកាមដ៏ច្រើន ពួកកិលេសយ៉ាងខ្សោយ រមែងគ្របសង្កត់ជននោះ អន្តរាយទាំងឡាយ ញាំញីជននោះ តពីនេះទៅ ទុក្ខនឹងជាប់ជននោះ ដូចជាទឹកហូរចូលទូកដែលបែកធ្លាយ ។ ព្រោះហេតុនោះ សត្វអ្នកមានសតិសព្វកាល គួរវៀរចាកកាមទាំងឡាយ លុះលះកាមទាំងនោះហើយ ទើបឆ្លងអន្លង់បាន ដូចជាបុរសស្តារទូក ហើយទៅដល់ត្រើយខាងនាយ ។

ចប់ កាមសូត្រ ទី ១ ។

## ទុតិយំ គុហដ្ឋកសុត្តំ

(៩៦) សត្តោ គុហាយំ ពហុនាភិឆន្នោ
តិដ្ឋំ នរោ មោហនស្មឹ បគាឡ្ហោ
ទូរេ វិវេកា ហិ តថាវិធោ សោ
កាមា ហិ លោកេ ន ហិ សុប្បហាយា ។
ឥច្ឆានិទានា ភវសាតពទ្ធា
តេ ទុប្បមុញ្ចា ន ហិ អញ្ញមោក្ខា
បច្ឆា បុរេ វាបិ អបេក្ខមានា
ឥមេវ កាមេ បុរិមេវ ជប្បំ ។
កាមេសុ គិទ្ធា បសុតា បមូឡ្ហា(១)
អវទានិយា តេ វិសមេ និវិដ្ឋា
ទុក្ខូបនីតា បរិទេវយន្តិ
កឹសូ ភវិស្សាម ឥតោ ចុតាសេ ។
តស្មា ហិ សិក្ខេថ ឥធេវ ជន្តុ

---

១ ម. សម្មូឡ្ហា ។

# គុហដ្ឋកសូត្រ ទី ២

[៩៦] ជនជាប់ចំពាក់ក្នុងគូហាគឺរាងកាយ ស្រោបដោយកិលេសច្រើនប្រការ ធ្លាក់ចុះក្នុងមោហៈគឺកាមគុណហើយបិតនៅ ជនមានសភាពដូច្នោះឈ្មោះថា ឆ្ងាយអំពីវិវេក ព្រោះថាកាមទាំងឡាយក្នុងលោក បុគ្គលមិនងាយនឹងលះបានឡើយ ៗ សត្វទាំងនោះ ជាប់ចំពាក់ដោយសេឆ្ងាញ់ក្នុងភព ព្រោះសេចក្តីប្រាថ្នាជាហេតុអា-ឡោះអាល័យនូវកាមទាំងឡាយក្នុងអនាគតផង ក្នុងអតីតផងប្រាថ្នានូវកាមទាំងឡាយ ជាបច្ចុប្បន្ននេះនឹងអតីត អនាគត ជាសត្វរួចបានដោយក្រ មិនរួចដោយហេតុដទៃបាន ៗ សត្វទាំងនោះ ជាប់ចំពាក់ខ្វល់ខ្វាយវង្វេង ក្នុងកាមទាំងឡាយ មិនកាន់យកពុទ្ធវចនៈ តាំងនៅមាំក្នុងធម៌មិនស្មើ គឺកាយទុច្ចរិត ដល់នូវសេចក្តីទុក្ខ តែងខ្សឹកខ្សួលថា ឱហ្ន៎ អាត្មាអញច្យុតអំពីអត្តភាពនេះ នឹងទៅកើតក្នុងទីណាអេះ ៗ ព្រោះហេតុនោះសត្វគប្បីសិក្សាក្នុងសាសនានេះ

យំ កិញ្ចិ ជញ្ញា វិសមន្តិ លោកេ
ន តស្ស ហេតុ វិសមំ ចរេយ្យ
អប្បញ្ហិ ទំ ជីវិតមាហុ ធីរា ។
បស្សាមិ លោកេ បរិផន្ទមានំ
បជំ ឥមំ តណ្ហាគតំ(១) ភវេសុ
ហីនា នរា មច្ចុមុខេ លបន្តិ
អវីតតណ្ហាសេ ភវាភវេសុ ។
មមាយិតេ បស្សថ ផន្ទមានេ
មច្ឆេវ អប្បោទកេ ខីណសោតេ
ឯតម្បិ ទិស្វា អមមោ ចរេយ្យ
ភវេសុ អាសត្តិមកុព្វមានោ ។
ឧភោសុ អន្តេសុ វិនេយ្យ ឆន្ទំ
ផស្សំ បរិញ្ញាយ អនានុគិទ្ធោ
យទត្តគរហី តទកុព្វមានោ(២)
ន លិម្បតី ទិដ្ឋសុតេសុ ធីរោ ។

---

១ ន. ម. តណ្ហាគតំ ។ ២ ម ក្រុព្វមានោ ។

អ្នកប្រាជ្ញគប្បីដឹងនូវកម្មទីមួយ ថាជាកម្មមិនរាបទាបក្នុងលោក មិនគប្បីប្រព្រឹត្តធម៌មិនរាបទាប ព្រោះហេតុនៃកម្មនោះ អ្នកប្រាជ្ញទាំងឡាយតែងពោលនូវជីវិតនោះ ថាជារបស់មានប្រមាណតិច ៗ តថាគតឃើញនូវពពួកសត្វនេះដែលកំពុងអន្ទះអន្ទែងក្នុងលោក លុះក្នុងអំណាចតណ្ហាក្នុងភពទាំងឡាយ ពួកជនអ្នកថោកថយ មិនប្រាសចាកតណ្ហា ក្នុងភពតូចភពធំទាំងឡាយ រមែងខ្សឹកខ្សួលក្នុងមាត់នៃមច្ចុ ៗ អ្នកទាំងឡាយ ចូរមើលពួកសត្វកំពុងអន្ទះអន្ទែងក្នុងវត្ថុជាកំណាន់ ដូចជាមច្ឆជាតិដែលកំពុងអន្ទះអន្ទែង ក្នុងទីមានទឹកតិចមានទឹករីងអស់ហើយ អ្នកប្រាជ្ញមិនមានសេចក្ដីប្រកាន់ លុះឃើញទោសនុ៎ះហើយ មិនគប្បីសន្សំនូវតណ្ហាគ្រឿងជាប់ចំពាក់ក្នុងភពហើយត្រាច់ទៅ ៗ អ្នកប្រាជ្ញកំណត់ដឹងនូវផស្សៈ ហើយលះបង់នូវឆន្ទរាគៈ ក្នុងផស្សៈ ទាំងពីរប្រការគឺ ផស្សៈដែលកើតហើយ និងហេតុដែលនាំឲ្យកើតផស្សៈដ៏លាមក មិនជាប់ចំពាក់(ក្នុងផស្សៈទាំងនោះ) អ្នកប្រាជ្ញមិនតិះដៀលអាត្មាឯងដោយកម្មណា មិនធ្វើនូវកម្មនោះ មិនជាប់នៅក្នុងអារម្មណ៍ដែលបានឃើញបានឮ ៗ

សញ្ញំ បរិញ្ញា វិតរេយ្យ ឱឃំ
បរិគ្គហេសុ មុនិ នោបលិត្តោ
អព្ពូឡ្ហសល្លោ ចរមប្បមត្តោ
នាសីសតិ លោកមិមំ បរញ្ចាតិ ។

គុហដ្ឋកសុត្តំ ទុតិយំ ។

## តតិយំ ទុដ្ឋដ្ឋកសុត្តំ

(៩៧) វទន្តិ វេ ទុដ្ឋមនាបិ ឯកេ
អថោបិ វេ សច្ចមនា វទន្តិ
វាទញ្ច ជាតំ មុនិ នោ ឧបេតិ
តស្មា មុនី នត្ថិ ខិលោ កុហិញ្ចិ ។
សកញ្ហិ ទិដ្ឋិំ កថមច្ចយេយ្យ
ឆន្ទានុនីតោ រុចិយា និវិដ្ឋោ
សយំ សមត្តានិ បកុព្ពមានោ
យថា ហិ ជានេយ្យ តថា វទេយ្យ ។
យោ អត្តនោ សីលវតានិ ជន្តុ
អនានុបុដ្ឋោ ច បរេស បាវ[១]

១ ម- អននុបុដ្ឋោ ច បរស្ស បាវ ។

អ្នកប្រាជ្ញកំណត់ដឹងនូវកាមសញ្ញា ហើយឆ្លងបាកអន្លង់ មានចិត្តមិនជាប់ចំពាក់ ក្នុងបរិគ្គហធម៌ គឺតណ្ហានិងទិដ្ឋិទាំងឡាយឡើយ ដកចោលនូវសរ គឺរាគាទិក្កិលេស មិនមានសេចក្តីប្រមាទត្រាច់ទៅ ទាំងមិនមានសេចក្តីប្រាថ្នាក្នុងលោកនេះ នឹងលោកខាងមុខ ៗ

ចប់ គុហដ្ឋកសូត្រ ទី ២ ។

## ទុដ្ឋដ្ឋកសូត្រ ទី ៣

(៩៧) តិរ្ថិយ១ពួក មានចិត្តប្រទូស្ត ពោលតិះដៀល (ព្រះមានព្រះភាគនឹងភិក្ខុសង្ឃ) មិនតែប៉ុណ្ណោះ តិរ្ថិយដទៃទៀតដែលមានសេចក្តីសំគាល់ថាមែនក៏ពោលតិះដៀលដែរ ឯអក្កោសវាទដែលកើតហើយមិនចូលទៅដល់ព្រះមុនី ព្រោះហេតុនោះ ត្រូវដឹងថាព្រះមុនីមិនមានសសរខឿន គឺរាគាទិក្កិលេស ក្នុងសន្តានតិចតួចសោះឡើយ ៗ បុគ្គលកន្លងនូវទិដ្ឋិរបស់ខ្លួនដូចម្តេចបាន បុគ្គលត្រូវឆន្ទៈដឹកនាំហើយតាំងនៅមាំហើយតាមគាប់ចិត្ត ធ្វើនូវទិដ្ឋិឲ្យពេញដោយខ្លួនឯងដឹងយ៉ាងណា ពោលយ៉ាងនោះ ៗ សត្វណាគេមិនទាន់សាកសួរ ស្រាប់តែសំដែងប្រាប់នូវសីលនិងវត្តរបស់ខ្លួន ដល់ជនដទៃ

អនរិយធម្មំ(១) កុសលា តមាហុ
យោ អាតុមានំ សយមេវ បាវ ។
សន្តោ ច ភិក្ខុ អភិនិព្វុតត្តោ
ឥតិហន្តិ សីលេសុ អកត្ថមានោ
តមរិយធម្មំ កុសលា វទន្តិ
យស្សុស្សទា នត្ថិ កុហិញ្ចិ លោកេ ។
បកប្បិតា សង្ខតា យស្ស ធម្មា
បុរក្ខតា សន្តិ អវីវទាតា(២)
យទត្តនិ បស្សតិ អានិសំសំ
តំ និស្សិតោ កុប្បបដិច្ចសន្តឹ ។
ទិដ្ឋីនិវេសា ន ហិ ស្វាតិវត្តា
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្មា នរោ តេសុ និវេសនេសុ
និរស្សតី អាទិយតិច្ច ធម្មំ ។

---

១ ម. អនរិយធម្មា ។ ២ ម. អវីវទាតា ។

សត្វណាពោលសរសើរខ្លួនដោយខ្លួនឯង អ្នកឈ្លាសទាំងឡាយ ពោលនូវវចៈរបស់សត្វនោះ ថាជាធម៌មិនប្រសើរឡើយ ។ មួយទៀត ភិក្ខុអ្នកស្ងប់រម្ងាប់ហើយ មានខ្លួនរលត់ហើយ មិនពោលអួតព្រោះសីល (ទប់ខ្លួន) ថាអាត្មាអញមានសីល ដូច្នេះៗ ឬមួយធម៌ជាបំហាយ គឺកគាទិក្កិលេស ក្នុងលោកនីមួយ មិនមានដល់ភិក្ខុណា អ្នកឈ្លាសទាំងឡាយ ពោលនូវការមិនពោលអួត របស់ភិក្ខុនោះ ថាជាធម៌ដ៏ប្រសើរ ។ ធម៌គឺទិដ្ឋិ ៦២ ដែលបច្ច័យកំណត់តាក់តែងធ្វើខាងមុខ មិនដូរផង់មានដល់សត្វណាមួយ (ជាទិដ្ឋិគតិកៈ) បុគ្គលនោះ ឃើញអានិសង្សណា ក្នុងខ្លួន ក៏អាស្រ័យអានិសង្សនោះ នឹងកុប្បបដិច្ចសន្តិទិដ្ឋិ(១) ។ សេចក្តីប្រកាន់ទិដ្ឋិ គឺសត្វមិនងាយប្រព្រឹត្តកន្លងបាន ព្រោះចូលចិត្តនូវទិដ្ឋិដែលខ្លួនប្រកាន់ហើយ ក្នុងទិដ្ឋិធម៌ ៦២ ព្រោះហេតុនោះ ជនរលាស់ចោលខ្លះ កាន់យកខ្លះ នូវធម៌គឺទិដ្ឋិ ក្នុងការប្រកាន់យកនូវទិដ្ឋិទាំងនោះ ។

---

១ ទិដ្ឋិ បានដល់កិរិយាកំរើក ការអាស្រ័យហើយកើតឡើង កិរិយាស្ងប់ដោយការសន្មតិ ។ អដ្ឋកថា ។

ធោនស្ស ហិ នត្ថិ(១) កុហិញ្ចិ លោកេ
បកប្បិតា ទិដ្ឋិ ភវាភវេសុ
មាយញ្ច មានញ្ច បហាយ ធោនោ
ស កេន គច្ឆេយ្យ អនូបយោ សោ ។
ឧបយោ ហិ ធម្មេសុ ឧបេតិ វាទំ
អនូបយំ កេន កថំ វទេយ្យ
អត្តំ និរត្តំ(២) ន ហិ តស្ស អត្ថិ
អធោសិ សោ ទិដ្ឋិមិធេវ សព្វន្តិ(៣) ។

ទុដ្ឋដ្ឋកសុត្តំ តតិយំ ។

## ចតុត្ថំ សុទ្ធដ្ឋកសុត្តំ

(៩៨) បស្សាមិ សុទ្ធំ បរមំ អរោគំ
ទិដ្ឋេន សំសុទ្ធិ នរស្ស ហោតិ
ឯវាភិជានំ(៤) បរមន្តិ ញត្វា
សុទ្ធានុបស្សីតិ បច្ចេតិ ញាណំ ។

---

១ ម. កេនស្សុចិ នត្ថីតិ ទិស្សតិ ។ ២ ម. អត្តំ និរត្តំ ។ ៣ ខ. ម. សព្វាតិ ។
៤ ខ. ឯតាភិជានំ ។

ព្រះអរហន្តក្នុងលោក មិនមានទិដ្ឋិដែលបុគ្គលកំណត់ ក្នុងភពតូច ភពធំ ក្នុងលោកតិចតួចឡើយ ព្រះអរហន្តនោះលះបង់មាយាផង មានះផង គប្បីទៅដោយគតិវិសេសដូចម្តេច ព្រះអរហន្តនោះ មិនផ្តេកផ្តិតនូវតណ្ហានិងទិដ្ឋិទៀតទេ ។ ព្រោះបុគ្គលអ្នកផ្តេកផ្តិត នូវតណ្ហានិងទិដ្ឋិ តែងចូលទៅជិតកាន់វាទៈ ក្នុងទិដ្ឋិធម៌ទាំងឡាយ បុគ្គលគប្បីពោលទោស ចំពោះបុគ្គល អ្នកមិនផ្តេកផ្តិតនូវតណ្ហានិង ទិដ្ឋិ ដោយកថាទោស ដូចម្តេចបាន ឯអត្តទិដ្ឋិនិងឧច្ឆេទទិដ្ឋិ របស់ព្រះអរហន្តនោះ មិនមានឡើយ ព្រះអរហន្តនោះកំចាត់បង់ ហើយនូវទិដ្ឋិទាំងអស់ ក្នុងលោក ។

ចប់ ទុដ្ឋដ្ឋកសូត្រ ទី ៣ ។

## សុទ្ធដ្ឋកសូត្រ ទី ៤

(៩៨) ជនពាលតែងដឹងថា អាត្មាអញឃើញ (នូវរូប) ស្អាតប្រសើរ មិនមានរោគ ការស្អាត តែងមានដល់សត្វ ដោយរូបដែល ឃើញហើយ ការដឹងយ៉ាងនេះថា ប្រសើរដូច្នេះ ហើយជាអ្នក ពិចារណាឃើញរឿយៗ ថាស្អាត រមែងជឿថា ជាញាណ ។

ទិដ្ឋេន ចេ សុទ្ធិ នរស្ស ហោតិ
ញាណេន វា សោ បជហាតិ ទុក្ខំ
អញ្ញេន សោ សុជ្ឈតិ សោបធីកោ
ទិដ្ឋី ហិ នំ បាវ តថា វទានំ ៗ

ន ព្រាហ្មណោ អញ្ញតោ សុទ្ធិមាហ
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
បុញ្ញេ ច បាបេ ច អនូបលិត្តោ
អត្តញ្ជហោ(១) ន ឥធ បកុព្ពមានោ ៗ

បុរិមំ បហាយ អបរំ សិតាសេ
ឯជានុគា តេ ន តរន្តិ(២) សង្គំ
តេ ឧគ្គហាយន្តិ និរស្សជន្តិ(៣)
កបីវ សាខំ បមុខំ គហាយ(៤) ៗ

សយំ សមាទាយ វតានិ ជន្តុ

---

១ ម. អត្តញ្ជហោ ។ ២ ម. តេ តរន្តិ ។ ៣ ម. និស្សជន្តិ ។ ៤ ឱ. បមុញ្ចំ គហាយ ។
ម. បមុញ្ច គហាយ ។

ប្រសិនបើការស្អាត មានដល់សត្វព្រោះរូបដែលឃើញហើយមែន សត្វនោះគង់នឹងលះបង់នូវកង់ទុក្ខ ដោយញាណបាន ឬសត្វដែលប្រកបដោយឧបធិនោះ គង់នឹងស្អាតដោយមគ្គមិនស្អាតដោយគុណដទៃ ព្រោះទិដ្ឋិ រមែងប្រាប់បុគ្គលអ្នកមានទិដ្ឋិនោះ កាលពោលយ៉ាងនោះ ៗ ខីណាសវព្រាហ្មណ៍ មិនពោលសរសើរនូវការស្អាត ត្រង់អារម្មណ៍ដែលបានឃើញបានឮបានប៉ះពាល់ ឬត្រង់សីលនិងវត្តដាច់អរិយមគ្គញាណទេ (លោក) មិនប្រឡាក់នឹងបុណ្យបាប លះបង់នូវសេចក្តីយល់ថា ខ្លួនមានធ្វើនូវកម្មក្នុងលោកនេះ ៗ ពួកអ្នកសុទ្ធិវាទៈ អ្នកលុះក្នុងអំណាចតណ្ហា លះបង់នូវលទ្ធិមុនហើយអាស្រ័យនូវលទ្ធិខាងក្រោយទៀត ពួកសុទ្ធិវាទៈនោះ រមែងឆ្លងនូវកិលេសគ្រឿងជាប់មិនរួចឡើយ សុទ្ធិវាទៈទាំងនោះ តែងកាន់យកខ្លះ លះចោលវិញខ្លះ ដូចពានរចាប់យកមែកឈើដែលនៅចំពោះមុខ ៗ សត្វកាន់យកនូវវត្តទាំងឡាយ ដោយខ្លួនឯង

ឧច្ចាវចំ គច្ឆតិ សញ្ញសត្តោ
វិទ្វា ច វេទេហិ សមេច្ច ធម្មំ
ន ឧច្ចាវចំ គច្ឆតិ ភូរិបញ្ញោ ។
ស សព្វធម្មេសុ វិសេនិភូតោ
យំ កិញ្ចិ ទិដ្ឋំ វ សុតំ មុតំ វា
តមេវ ទស្សឹ វិវដំ ចរន្តំ
កេនីធ លោកស្មឹ វិកប្បយេយ្យ ។
ន កប្បយន្តិ ន បុរេក្ខរោន្តិ[១]
អច្ចន្តសុទ្ធីតិ ន តេ វទន្តិ
អាទានគន្ថំ គថិតំ វិសជ្ជ
អាសំ ន កុព្វន្តិ កុហិញ្ចិ លោកេ ។
សីមាតិគោ[២] ព្រាហ្មណោ តស្ស នត្ថិ
ញត្វា វ ទិស្វា វ សមុគ្គហីតំ

១ ឱ. ម. បុរក្ខរោន្តិ ។ ២ ម. សមាតិគោ ។

ជាសត្វជាប់ល្អិតក្នុងកាមសញ្ញាហើយ តែងទៅគប់រកគ្រូខ្ពស់ទីងទាប អ្នកប្រាជ្ញមានបញ្ញាក្រាស់ដូចផែនដី ត្រាស់ដឹងនូវសច្ចធម៌ដោយវេទ គឺមគ្គញាណទាំង ៤ មិនបានទៅគប់រកគ្រូខ្ពស់ទីងទាបឡើយ ។ អ្នកប្រាជ្ញនោះ កំចាត់បង់មារសេនាហើយ ឋិតនៅទីងទួន ក្នុងអារម្មណ៍ទាំងពួង នោះអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ណាមួយក្តី (អ្នកណាមួយ) គប្បីកំណត់នូវអ្នកប្រាជ្ញអ្នកឃើញ (ដ៏បរិសុទ្ធ) មានគ្រឿងប្រក់គឺកិលេសបើកហើយនោះឯង ដោយគ្រឿងកំណត់ណាក្នុងលោកបាន ។ អ្នកប្រាជ្ញទាំងឡាយបែបនោះមិនកំណត់ មិនធ្វើតណ្ហានិងទិដ្ឋិ ឲ្យជាប្រធាន ទាំងមិនពោលសរសើរនូវទិដ្ឋិ ថាជារបស់ស្អាតម៉ត់ចត់ទេ តែងផ្តាច់ចោលនូវចំណងគឺសេចក្តីប្រកាន់ ដែលចងក្នុងចិត្តសន្តាន របស់ខ្លួន តែងមិនធ្វើសេចក្តីប្រាថ្នា ក្នុងសន្តានឯណានីមួយក្នុងលោកទេ ។ (អ្នកប្រាជ្ញនោះ) ប្រព្រឹត្តកន្លងនូវខេត្រដែន (កិលេស) បន្សាត់បង់បាប លោកមិនមានសេចក្តីប្រកាន់ ព្រោះជ្រាប ព្រោះឃើញទេ

ន រាគរាគី ន វិរាគរត្តោ

តស្សីធ នត្ថិ បរមុគ្គហីតន្តិ ។

សុទ្ធដ្ឋកសុត្តំ ចតុត្ថំ ។

# បញ្ចមំ បរមដ្ឋកសុត្តំ

(៩៩) បរមន្តិ ទិដ្ឋីសុ បរិព្វសានោ

យទុត្តរិ កុរុតេ ជន្តុ លោកេ

ហីនាតិ អញ្ញេ តតោ សព្វមាហ

តស្មា វិវាទានិ អវីតិវត្តោ ។

យទត្តនី បស្សតិ អានិសំសំ

ទិដ្ឋេ សុតេ សីលវតេ មុតេ វា

តទេវ សោ តត្ថ សមុគ្គហាយ

និហីនតោ បស្សតិ សព្វមញ្ញំ ។

តំ វាបិ គន្ថំ កុសលា វទន្តិ

យំ និស្សិតោ បស្សតិ ហីនមញ្ញំ

តស្មា ហិ ទិដ្ឋំ វ សុតំ មុតំ វា

សីលព្វតំ ភិក្ខុ ន និស្សយេយ្យ ។

លោកមិនត្រេកអរក្នុងកាមភព មិនរីករាយក្នុងរូបភពនិងអរូបភព អ្នកប្រាជ្ញនោះ មិនមានសេចក្តីប្រកាន់ថា នេះជារបស់ប្រសើរ ក្នុងលោកនេះឡើយ ។

ចប់ សុទ្ធដ្ឋកសូត្រ ទី ៤ ។

## បរមដ្ឋសូត្រ ទី ៥

(៩៩) សត្វនៅក្នុងទិដ្ឋិទាំងឡាយថា នេះប្រសើរ តែងលើក (គោរព) គ្រូណាថា វិសេសផុតក្នុងលោក បានពោលបន្អាប់ពួកគ្រូទាំងអស់ដទៃអំពីគ្រូខ្លួននោះថា ថោកទាប ព្រោះហេតុនោះ បានជាសត្វប្រព្រឹត្តកន្លងនូវវិវាទទាំងឡាយមិនរួច ។ សត្វឃើញនូវអានិសង្សណា ក្នុងខ្លួន ត្រង់អារម្មណ៍ដែលបានឃើញ បានឮ បានប៉ះពាល់ ឬត្រង់សីលនិងវ័ត សត្វនោះប្រកាន់ភ្ជាប់នូវអានិសង្សនោះ ក្នុងសកាយទិដ្ឋិនោះ ហើយឃើញនូវគ្រូដទៃទាំងអស់ថាថោកថយ ។ សត្វអាស្រ័យគ្រូរបស់ខ្លួន ហើយឃើញគ្រូដទៃថា ថោកថយ អ្នកប្រាជ្ញទាំងឡាយ ពោលនូវការឃើញនោះថាជាបំណងពិត ព្រោះហេតុនោះ ភិក្ខុមិនគប្បីអាស្រ័យអារម្មណ៍ដែលបានឃើញ បានឮ បានប៉ះពាល់ ឬសីលនិងវ័តឡើយ ។

ទិដ្ឋិម្បិ លោកស្មឹ ន កប្បយេយ្យ
ញាណេន វា សីលវតេន វាបិ
សមោតិ អត្តានមនូបនេយ្យ
ហីនោ ន មញ្ញេថ វិសេសិ វាបិ ។
អត្តំ បហាយ អនុបាទិយានោ
ញាណេបិ សោ និស្សយំ នោ ករោតិ
ស វេ វិយត្តេសុ ន វគ្គសារី
ទិដ្ឋិម្បិ សោ ន បច្ចេតិ កិញ្ចិ ។
យស្សូភយន្តេ បណិធីធ នត្ថិ
ភវាភវាយ ឥធ វា ហុរំ វា
និវេសនា តស្ស ន សន្តិ កេចិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្សីធ ទិដ្ឋេ វ សុតេ មុតេ វា
បកប្បិតា នត្ថិ អណូបិ សញ្ញា

ភិក្ខុមិនគប្បីធ្វើទិដ្ឋិឲ្យកើតឡើងក្នុងលោក ដោយញាណឬដោយសីលនឹងវ័តទេ មិនគប្បីប្រៀបធៀបខ្លួនថា អាត្មាអញជាអ្នកស្មើ (នឹងគេ)ទេ មិនគប្បីសំគាល់ខ្លួនថា អាត្មាអញជាអ្នកថោកថយទេ ឬថាអាត្មាអញជាអ្នកវិសេសជាងគេទេ ។ កាលភិក្ខុនោះលះបង់នូវអត្តទិដ្ឋិហើយ មិនប្រកាន់មាំ ទាំងមិនសន្សំនូវនិស្ស័យ ក្នុងញាណ កាលបើសត្វបែកផ្សេងគ្នា ភិក្ខុនោះក៏មិនប្រព្រឹត្តជាពួក ភិក្ខុនោះមិនត្រឡប់មកកាន់ទិដ្ឋិទីមួយទេ ។ ព្រះខីណាស្រពណា មិនមានតណ្ហា ដើម្បីនឹងកើតរឿយ ៗ ក្នុងលោកនេះ ឬលោកខាងមុខ ត្រង់ទីបំផុតទាំងពីរ(១) ទៀតទេ ព្រះខីណាស្រពណា មិនមានទីអាស្រ័យនៅទីមួយឡើយ ព្រះខីណាស្រពនោះ (មិនមាន) សេចក្តីប្រកាន់ ព្រោះពិចារណាឃើញ ក្នុងពួកទិដ្ឋិធម៌ទាំងឡាយ សូម្បីសញ្ញាតិចតួច ដែលកំណត់ក្នុងអារម្មណ៍ បានឃើញ បានឮ បានប៉ះពាល់ក្នុងលោកនេះរបស់ព្រះខីណាស្រពនោះក៏មិនមានឡើយ

---

១ ទីបំផុតខាងដើមតណ្ហា មានផស្សៈជាដើម ទីបំផុតខាងចុងតណ្ហាគឺឧបាទាន ។ អដ្ឋកថា ។

តំ ព្រាហ្មណំ ទិដ្ឋិមនាទិយានំ
កេនីធ លោកស្មឹ វិកប្បយេយ្យ ។
ន កប្បយន្តិ ន បុរេក្ខរោន្តិ
ធម្មាបិ តេសំ ន បដិច្ឆិតាសេ
ន ព្រាហ្មណោ សីលវតេន នេយ្យោ
បារំ គតោ ន បច្ចេតិ តាទី ។

បរមដ្ឋកសុត្តំ បញ្ចមំ ។

## ឆដ្ឋំ ជរាសុត្តំ

(១០០) អប្បំ វត ជីវិតំ ឥទំ ឱរំ វស្សសតាបិ មិយ្យតិ
សចេបិ(១) អតិច្ច ជីវតិ អថខោ សោ ជរសាបិ មិយ្យតិ ។
សោចន្តិ ជនា មមាយិតេ ន ហិ សន្តិ និច្ចា បរិគ្គហា
វិនាភាវសន្តមេវិទំ ឥតិ ទិស្វា នាគារមាវសេ ។

---

១ ឱ. យោ ចេបិ ។ ម. សោ ចេបិ ។

បុគ្គលណា គប្បីកំណត់នូវខីណាសវព្រាហ្មណ៍នោះ អ្នកមិនប្រកាន់នូវទិដ្ឋិដោយសេចក្តីកំណត់ ដូចម្តេច ក្នុងលោកនេះបាន ។ ព្រះខីណាស្រពទាំងឡាយមិនកំណត់ មិនធ្វើតណ្ហានិងទិដ្ឋិឲ្យជាប្រធានទេ ធម៌ទាំងឡាយគឺទិដ្ឋិមិនបិទបាំង (បញ្ញា) របស់ព្រះខីណាស្រពទាំងអម្បាលនោះបានឡើយ ព្រះខីណាសវព្រាហ្មណ៍ មិនប្រព្រឹត្តទៅតាមសីលនិងវត្ត (ដទៃ)ទេ បានដល់ត្រើយគឺព្រះនិព្វាន មានសភាពជាតាទិបុគ្គល មិនត្រឡប់មកកាន់កត (ថ្មី) ទៀតឡើយ ។

ចប់ បរមដ្ឋកសូត្រទី ៥ ។

## ជរាសូត្រ ទី ៦

(១០០) ជីវិតនេះមានប្រមាណតិចហ្ន៎ សត្វតែងស្លាប់ថយអំពី ១០០ ឆ្នាំ ប្រសិនបើរស់ហួសពី ១០០ ឆ្នាំ សត្វនោះនឹងស្លាប់ដោយជរាជាប្រាកដ ។ ជនទាំងឡាយតែងសោក ព្រោះវត្ថុដែលប្រកាន់ថា របស់យើង សេចក្តីប្រកាន់ថារបស់ទៀងទាត់មិនមានឡើយ ជីវិតនេះមានការព្រាត់ប្រាសចាករបស់ដែលមានជាធម្មតា អ្នកប្រាជ្ញលុះឃើញដូច្នេះហើយ រមែងមិននៅគ្រប់គ្រងផ្ទះឡើយ ។

មរណេនបិ តំ បហិយ្យតិ យំ បុរិសោ មមយិទន្តិ(១) មញ្ញតិ

ឯវម្បី(២) វិទិត្វា បណ្ឌិតោ ន មមត្តាយ នមេថ មាមកោ ។

សុបិនេន យថាបិ សង្គតំ បដិពុទ្ធោ បុរិសោ ន បស្សតិ

ឯវម្បិ បិយាយិតំ ជនំ បេតំ កាលកតំ ន បស្សតិ ។

ទិដ្ឋាបិ សុតាបិ តេ ជនា យេសំ នាមមិទំ បវុច្ចតិ

នាមមេវាវសិស្សតិ អក្ខេយ្យំ បេតស្ស ជន្តុនោ ។

សោកបរិទេវមច្ឆរំ ន ជហន្តិ គិទ្ធា មមាយិតេ

តស្មា មុនយោ បរិគ្គហំ ហិត្វា អចរិំសុ ខេមទស្សិនោ ។

បដិលីនចរស្ស ភិក្ខុនោ ភជមានស្ស វិវិត្តមាសនំ(៣)

សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ ។

---

១ ម. មមាយន្តិ ។ ២ ឱ. ឯវម្បិ ។ ៣ ឱ. វិវិត្តមានសំ ។

បុរសសំគាល់របស់ណាថា នេះជារបស់អញ រមែងលះរបស់នោះ ដោយមរណៈ ឯអ្នកប្រាជ្ញដ៏កប់អានព្រះរតនត្រ័យ ជ្រាបច្បាស់នូវទោសនុ៎ះ ហើយមិនបង្អោន (ចិត្ត) ទៅ ដើម្បីសេចក្តីប្រកាន់ថារបស់យើងឡើយ ។ បុរសអ្នកភ្ញាក់ (ពីដេក) រមែងមិនឃើញប្រារម្មណ៍ជាដើមដែលមកជួបប្រទះ ដោយយល់សប្តិ យ៉ាងណាមិញ បុគ្គល មិនឃើញជនជាទីស្រឡាញ់ ដែលធ្វើកាលកិរិយាទៅកាន់លោកខាងមុខ ក៏យ៉ាងនោះដែរ ។ ជនទាំងនោះដែលគេឃើញហើយ ឮហើយ គេតែងហៅឈ្មោះ កាលលះលោកនេះទៅ នៅសល់តែឈ្មោះសម្រាប់ហៅប៉ុណ្ណោះ ។ ពួកសត្វមានសេចក្តីលោភ តែងមិនលះបង់ នូវសេចក្តីសោកខ្សឹកខ្សួលនឹងសេចក្តីកំណាញ់ ក្នុងវត្ថុដែលជាទីកប់អានបានឡើយ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយដែលឃើញព្រះនិព្វានថាជាទីក្សេមហើយ រមែងលះបង់សេចក្តីប្រកាន់បាន ។ ភិក្ខុណា មិនសំដែងខ្លួនក្នុងភព (ថ្មីទៀត) អ្នកប្រាជ្ញទាំងឡាយហៅអំពើនោះ របស់ភិក្ខុនោះ អ្នកប្រព្រឹត្តវៀក អ្នកគប់ប្រសព្វអាសនៈស្ងាត់ ថាជាសភាពសមរម្យហើយ ។

សព្ពត្ថ មុនី អនិស្សិតោ ន បិយំ កុព្វតិ នោបិ អកប្បិយំ

តស្មឹ បរិទេវមច្ឆរំ បណ្ណេ វារិ យថា ន លិម្បតិ ។

ឧទកពិន្ទុ យថាបិ បោក្ខរេ បទុមេ វារិ យថា ន លិម្បតិ

ឯវំ មុនី នោបលិម្បតិ យទិទំ ទិដ្ឋំ សុតំ មុតេសុ វា ។

ធោនោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋំ សុតំ មុតេសុ វា

នាញ្ញេន វិសុទ្ធិមិច្ឆតិ ន ហិ សោ រជ្ជតិ នោ វិរជ្ជតីតិ ។

ជរាសុត្តំ ឆដ្ឋមំ ។

## សត្តមំ តិស្សមេត្តេយ្យសុត្តំ

(១០១) មេថុនមនុយុត្តស្ស (ឥច្ចាយស្មា តិស្សមេត្តេយ្យោ)

វិឃាតំ ព្រូហិ មារិស

អ្នកប្រាជ្ញមិនបានអាស្រ័យ ក្នុងអាយតនៈទាំងអស់ឡើយ មិនធ្វើសត្វនិងសង្ខារឲ្យជាទីស្រឡាញ់ ទាំងមិនធ្វើសត្វនិងសង្ខារឲ្យមិនជាទីស្រឡាញ់ សេចក្ដីខ្សឹកខ្សួលនិងសេចក្ដីកំណាញ់ មិនជាប់ក្នុងសន្ដាន របស់ព្រះខីណាស្រពនោះ ដូចទឹកមិនប្រឡាក់លើស្លឹកឈូកដូច្នោះដែរ ។ ដំណក់ទឹកមិនដក់នៅលើស្លឹកឈូក ដូចម្ដេចក្ដី ទឹកមិនទទឹកនាផ្កាឈូកដូចម្ដេចក្ដី អ្នកប្រាជ្ញមិនជាប់នៅក្នុងអារម្មណ៍ទីមួយ សូម្បីអារម្មណ៍បានឃើញ បានប៉ះពាល់ ក៏ដូច្នោះដែរ ។ មួយទៀត ព្រះអរហន្តមិនសំគាល់ក្នុងអារម្មណ៍ទីមួយ សូម្បីអារម្មណ៍ដែលឃើញ ដែលឮ ដែលប៉ះពាល់ ដោយវត្ថុនោះៗ ឡើយ ទាំងមិនប្រាថ្នាការស្អាតដោយវត្ថុដទៃទេ ព្រោះព្រះអរហន្តនោះមិនត្រេកត្រអាល មិនប្រាសតម្រេក (ដូចកល្យាណបុថុជ្ជននិងសេក្ខៈ)។

ចប់ ជរាសូត្រ ទី ៦ ។

## តិស្សមេត្តេយ្យសូត្រ ទី ៧

[១០១] ព្រះតិស្សមេត្តេយ្យ ដ៏មានអាយុ (អារាធនាថា) បពិត្រព្រះអង្គ និរទុក្ខ សូមព្រះអង្គ សំដែងសេចក្ដីចង្អៀតចង្អល់ របស់បុគ្គល អ្នកប្រកបមេថុនធម្មរឿយ ៗ យើងខ្ញុំ

សុត្វាន តវ សាសនំ   វិវេកេ សិក្ខិស្សាមសេ ។
មេថុនមនុយុត្តស្ស   (មេត្តេយ្យាតិ ភគវា)
មុស្សតេ វាបិ សាសនំ
មិច្ឆា ច បដិបជ្ជតិ   ឯតំ តស្មិំ អនារិយំ ។
ឯកោ បុព្វេ ចរិត្វាន   មេថុនំ យោ និសេវតិ
យានំ ភន្តំវ តំ លោកេ   ហីនមាហុ បុថុជ្ជនំ ។
យសោ កិត្តិ ច យា បុព្វេ   ហាយតេ វាបិ តស្ស សា
ឯតម្បិ ទិស្វា សិក្ខេថ   មេថុនំ វិប្បហាតវេ ។
សង្កប្បេហិ បរេតោ សោ   កបណោ វិយ ឈាយតិ
សុត្វា បរេសំ និគ្ឃោសំ   មង្កុ ហោតិ តថាវិធោ ។
អថ សត្ថានិ កុរុតេ   បរវាទេហិ ចោទិតោ
ឯស ខ្វស្ស មហាគេធោ   មោសវជ្ជំ បគាហតិ ។

បានស្តាប់ពាក្យប្រដៅព្រះអង្គហើយ ទឹងសិក្សានូវវិវេកទាំងឡាយៗ

(ព្រះមានព្រះភាគ ត្រាស់ថា ម្នាលមេត្តេយ្យ) បុគ្គលអ្នកប្រកបមេថុនរឿយ ៗ រមែងភ្លេចពាក្យប្រដៅផង ប្រតិបត្តិខុសផង ការប្រព្រឹត្តិខុសនុ៎ះ ជាអំពើមិនប្រសើរចំពោះបុគ្គលនោះទេ ៗ បុគ្គលណាប្រព្រឹត្តម្នាក់ឯង គឺទ្រង់ភេទបព្វជិតក្នុងកាលពីមុន (លុះខាងក្រោយ) ត្រឡប់សេពមេថុនធម្មវិញ អ្នកប្រាជ្ញហៅបុគ្គលនោះថាជាបុថុជ្ជន អ្នកថោកថយក្នុងលោក ដូចជាយានលឿនទៅដូច្នោះឯង ៗ យសនិងសេចក្តីសរសើរណាក្នុងកាលពីមុន យសនិងសេចក្តីសរសើរនោះ របស់បុគ្គលនោះរមែងសាបសូន្យទៅ បុគ្គលឃើញការចំរើននិងការសាបសូន្យយសសរសើរនុ៎ះហើយ គប្បីសិក្សាដើម្បីលះបង់ នូវមេថុនធម្មចេញ ៗ បុគ្គលនោះត្រូវសង្កប្បៈទាំងឡាយគ្របសង្កត់ហើយ រមែងជ្រប់ទៅ ដូចមនុស្សកំព្រាបុគ្គលបែបនោះ ឮពាក្យជនដទៃហើយ រមែងអៀនខ្មាស ៗ មួយទៀត បុគ្គលនោះត្រូវវាទៈអ្នកដទៃដាស់តឿនហើយ រមែងធ្វើគ្រឿងសស្ត្រាគឺមុសាវាទ សេចក្តីសាំញ៉ាំធំនោះឯង របស់បុគ្គលនោះ រមែងធ្លាក់ចុះកាន់មុសាវាទ ៗ

បណ្ឌិតោតិ សមញ្ញាតោ ឯកចរិយំ អធិដ្ឋិតោ
អថាបិ មេថុនេ យុត្តោ មន្ទោវ បរិកិស្សតិ ។
ឯតមាទីនវំ ញត្វា មុនិ បុព្វាបរេ ឥធ
ឯកចរិយំ ទឡ្ហំ កយិរា ន និសេវេថ មេថុនំ ។
វិវេកញ្ញេវ សិក្ខេថ ឯតទរិយានមុត្តមំ
តេន សេដ្ឋោ ន មញ្ញេថ ស វេ និព្វានសន្តិកេ ។
រិត្តស្ស មុនិនោ ចរតោ កាមេសុ អនបេក្ខិនោ
ឱឃតិណ្ណស្ស បិហយន្តិ កាមេសុ គធិតា(១) បជាតិ ។

តិស្សមេត្តេយ្យសុត្តំ សត្តមំ ។

## អដ្ឋមំ បសូរសុត្តំ

(១០២) ឥធេវ សុទ្ធី ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
យំ និស្សិតា តត្ថ សុភំ វទានា

១ ឱ. គថិតា ។

បុគ្គលដែលគេដឹងសុះសាយថាជាបណ្ឌិត តាំងផ្ដើមការប្រព្រឹត្តិម្នាក់ឯង លុះកាលខាងក្រោយមក បែរទៅជាប្រកប ក្នុងមេថុនធម្មវិញ បណ្ឌិតនោះ នឹងសៅហ្មងដូចជនពាលដែរ ។ អ្នកប្រាជ្ញលុះជ្រាបទោសនុ៎ះហើយ គួរធ្វើនូវការប្រព្រឹត្តិម្នាក់ឯងឲ្យមាំ ក្នុងសាសនានេះ តាំងមុនតាំងក្រោយ កុំគប្បីសេពនូវមេថុនឡើយ ។ បុគ្គលគប្បីសិក្សានូវវិវេកតែម្យ៉ាង ព្រោះវិវេកនុ៎ះ ប្រសើរផុតរបស់ព្រះអរិយៈទាំងឡាយ ប៉ុន្តែបុគ្គលមិនគប្បីសំគាល់ ថាអាត្មាអញប្រសើរដោយវិវេកនោះទេ បុគ្គលនោះឯង ឈ្មោះថា ប្រតិស្ឋានទៅក្នុងទីជិតនៃព្រះនិព្វាន ។ ពួកសត្វអ្នកជាប់នៅក្នុងកាមទាំងឡាយតែងស្រឡាញ់អ្នកប្រាជ្ញដែលមានសេចក្ដីស្ងប់ស្ងាត់ មិនអាឡោះអាល័យក្នុងកាមទាំងឡាយ ឆ្លងនូវអន្លង់បាន ។

ចប់ តិស្សមេត្តេយ្យសូត្រ ទី ៧ ។

## បសូរសូត្រ ទី ៨

(១០២) ពួកសមណព្រាហ្មណ៍ដទៃក្នុងលោកនេះ តែងពោលសរសើរថា បរិសុទ្ធិ (សំដៅទិដ្ឋិរបស់ខ្លួន) តែមិនពោលថាបរិសុទ្ធិចំពោះលទ្ធិដទៃ (ក្រៅអំពីគ្រូរបស់ខ្លួន) សមណព្រាហ្មណ៍ជាច្រើនអាស្រ័យនឹងលទ្ធិណា តែងសរសើរថា ល្អក្នុងលទ្ធិនោះ

បច្ចេកសច្ចេសុ បុថូ និវិដ្ឋា ។
តេ វាទកាមា បរិសំ វិគយ្ហ
ពាលំ ទហន្តិ មិថុ អញ្ញមញ្ញំ
វទន្តិ(១) តេ អញ្ញសិតា កថោជ្ជំ
បសំសកាមា កុសលា វទានា ។
យុត្តោ កថាយំ បរិសាយ មជ្ឈេ
បសំសមិច្ឆំ វិនិឃាតិ ហោតិ
អបាហតស្មឹ បន មង្កុ ហោតិ
និន្ទាយ សោ កុប្បតិ រន្ធមេសី ។
យមស្ស វាទំ បរិហីនមាហុ
អបាហតំ បញ្ហវីមំសកា សេ
បរិទេវតិ សោចតិ ហីនវាទោ
ឧបច្ចគា មន្តិ អនុត្ថុនាតិ ។
ឯតេ វិវាទា សមណេសុ ជាតា
ឯតេសុ ឧគ្ឃាតិ និគ្ឃាតិ(២) ហោតិ

---

១ ឱ. វទេន្តិ ។ ២ ម. ឧគ្ឃាដិ និឃាដិ ។

តាំងនៅ ក្នុងបច្ចេកសច្ចៈ (សេចក្តីពិតដោយឡែក) ។ សមណ-
ព្រាហ្មណ៍ទាំងនោះ ប្រាថ្នានូវវាទៈ ចូលទៅកាន់បរិសទ្យហើយ
ទាំង ២ នាក់ ឃើញគ្នានឹងគ្នាថាជាពាល ទាំងអស់ សមណព្រាហ្មណ៍
ទាំងនោះអាស្រ័យនឹងគ្រូដទៃ ក៏ពោលដម្លោះ ប្រាថ្នានូវការសរសើរ
ក៏សំគាល់ថា យើងវាងវៃក្នុងវាទៈ ។ បុគ្គលអ្នកខ្វល់ខ្វាយក្នុងការ
និយាយជជែក ប្រាថ្នានូវការសរសើរក្នុងកណ្តាលបរិសទ្យ រមែង
ទញ់តុះ នឹងជាបុគ្គលអៀនខ្មាសក្នុងវាទៈ (របស់ខ្លួន) ដែលគេផ្ចាត់
ពោល បុគ្គលស្វែងរកទោសនោះ រមែងខឹង ព្រោះពាក្យនិន្ទា ។
អ្នកពិចារណានូវបញ្ហាទាំងឡាយ ពោលនូវវាទៈរបស់បុគ្គលនោះ
ថាជាវាទៈថោកទាប ថាគេផ្ចាត់ពោលហើយ បុគ្គលអ្នកមានវាទៈ
ថោកទាប តែងខ្សឹកខ្សួល សោក ថ្ងូរថា អ្នកនោះកន្លងអាត្មា
អញ (ដោយវាទៈ) ។ វិវាទទាំងនុ៎ះ កើតឡើងក្នុងពួកសមណៈ
សភាពត្រេកអរនឹងការអាក់អន់ចិត្ត រមែងកើតឡើង ព្រោះវាទៈទាំងនុ៎ះ

ឯតម្បិ ទិស្វា វិរមេ កថោជ្ជំ
ន ហញ្ញទត្ថត្ថិ បសំសលាភា ។
បសំសិតោ វា បន តត្ថ ហោតិ
អក្ខាយ វាទំ បរិសាយ មជ្ឈេ
សោ ហស្សតិ ឧណ្ណមតិច្ច(១) តេន
បប្បុយ្យ តំ អត្ថ(២) យថា មនោ អហុ ។
យា ឧណ្ណតី សាស្ស វិឃាតភូមិ
មានាតិមានំ វទតេ បនេសោ
ឯតម្បិ ទិស្វា វិរមេ កថោជ្ជំ
ន តេន(៣) សុទ្ធឹ កុសលា វទន្តិ ។
សូរោ យថា រាជខាទាយ(៤) បុដ្ឋោ
អភិគជ្ជមេតិ បដិសូរមិច្ឆំ
យេនេវ សោ តេន បលេហិ សូរ
បុព្វេវ នត្ថិ យទិទំ យុធាយ ។

---

១ ម. សោ ហំសតិ ឧណ្ណមតិ ច ។ ២ ម. បព្ពុយ្ហ តមត្ថំ ។ ឱ. បប្បុយ្យ តមត្ថំ ។
៣ ឱ. ឯតម្បិ ទិស្វា ន វិវាទយេថ ន ហិ តេន ។ ម. ឯតំបិ ទិស្វា វិរមេ កថោជ្ជំ ន តេន ។
៤ ឱ. ម. រាជខាទាយ ។

អ្នកប្រាជ្ញឃើញទោសនុ៎ះហើយ គប្បីចៀសវាងនូវការជម្លោះបេញ ប្រយោជន៍ជនដទៃ អំពីការសរសើរនឹងលាភមិនមានឡើយ ៗ មួយទៀត បុគ្គលដែលគេសរសើរក្នុងរឿងនោះហើយ ក៏ពោលនូវវាទៈ (របស់ខ្លួន) ក្នុងកណ្តាលបរិសទ្យ បុគ្គលនោះរីករាយផង ឡើងដោរផង ព្រោះសំរេចប្រយោជន៍គឺជ័យជំនះដូចចិត្ត ៗ ការឡើងដោរជាហេតុនៃសេចក្តីចង្អៀតចង្អល់របស់បុគ្គល បុគ្គលនុ៎ះតែងពោលនូវមានះទឹងអតិមានះ បុគ្គលឃើញទោសនេះហើយ គប្បីចៀសវាងការជម្លោះ អ្នកឈ្លាសវៃទាំងឡាយ មិនពោលសរសើរថាបរិសុទ្ធដោយជម្លោះនោះឡើយ ៗ ប្រៀបដូចបុគ្គលអ្នកអង់អាចដែលស្តេចចិញ្ចឹមហើយដោយពជរស្ញាន់ កាលប្រាថ្នាគម្រាមទៅរកបុគ្គលអ្នកអង់អាចតប អ្នកអង់អាចតបនោះមានក្នុងទីណា នៃអ្នកអង់អាច អ្នកបូរទៅក្នុងទីនោះចុះ កិលេសគប្បីមានដោយចម្បាំងមិនមានតាំងពីមុនមកៗ

យេ ទិដ្ឋិមុគ្គយ្ហ(១) វិវាទយន្តិ
ឥទមេវ សច្ចន្តិ ច វាទយន្តិ
តេ ត្វំ វទស្សុ ន ហិ តេធ អត្ថិ
វាទម្ហិ ជាតេ បដិសេនិកត្តា ។
វិសេនិកត្វា បន យេ ចរន្តិ
ទិដ្ឋីហិ ទិដ្ឋឹ អវិរុជ្ឈមានា
តេសុ ត្វំ កឹ លភេថោ បសូរ(២)
យេសីធ នត្ថី បរមុគ្គហីតំ ។
អថ ត្វំ បវិតក្កមាគមា
មនសា ទិដ្ឋិគតានិ ចិន្តយន្តោ
ធោនេន យុគំ សមាគមា
ន ហិ ត្វំ សក្ខសិ(៣) សម្បយាតវេ ។

បសូរសុត្តំ អដ្ឋមំ ។

## នវមំ មាគន្ទិយសុត្តំ

(១០៣) ទិស្វាន តណ្ហំ អរតិញ្ច រគំ
នាហោសិ ឆន្ទោ អបិ មេថុនស្មឹ

១ ម. យេ ទិដ្ឋីវិគយ្ហ ។ ២ ម. លភេថ បសូរ ។ ៣ ម. អក្ខសិ ។

ជនទាំងឡាយដែលប្រកាន់ទិដ្ឋិ ហើយពោលជជែកផង ពោលថា នេះឯងជារបស់ពិតផង អ្នកចូរជជែកនឹងជនទាំងនោះចុះ ជនអ្នកធ្វើទំនាស់ ក្នុងកាលៈដែលកើតហើយ ក្នុងទីនេះ មិនមានដល់អ្នកទេ ។ បុគ្គលទាំងឡាយណា ធ្វើសេនារបស់កិលេសឲ្យវិនាស មិនថ្នាំងថ្នាក់នឹងទិដ្ឋិដោយទិដ្ឋិទាំងឡាយឡើយ ការប្រកាន់ទិដ្ឋិដ៏ក្រៃលែងមិនមានក្នុងបុគ្គលណា ក្នុងលោកនេះ ម្នាលបសូរៈ អ្នកគប្បីបាននូវការតបតដូចម្តេច ក្នុងបុគ្គលទាំងនោះ ។ មួយទៀត អ្នកកាលត្រិះរិះ គិតនូវទិដ្ឋិទាំងឡាយ ដោយចិត្ត ហើយមកប្រណាំងប្រជែង (នឹងព្រះសម្មាសម្ពុទ្ធ) ដែលមានកិលេសលាងហើយ អ្នកមិនអាចនឹងជជែកបានឡើយ ។

ចប់ បសូរសូត្រ ទី ៨ ។

## មាគន្ទិយសូត្រ ទី ៩

(១០៣) (ព្រះសម្ពុទ្ធទ្រង់ត្រាស់នឹងមាគន្ទិយព្រាហ្មណ៍ថា) អើក៏សេចក្តីប្រាថ្នាក្នុងមេថុនមិនមាន (ដល់តថាគត) ព្រោះឃើញនាងតណ្ហា នាងអរតីនឹងនាងរាគា (ដែលជាធីតានៃមារ) សោះទៅហើយ

កិមេវិទំ មុត្តករីសបុណ្ណំ

បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេ ។

ឯតាទិសញ្ចេ រតនំ ន ឥច្ឆសិ

នារឹ នរិន្ទេហិ ពហូហិ បត្ថិតំ

ទិដ្ឋិគតំ សីលវតំ នុ[1] ជីវិតំ

ភវូបបត្តិញ្ច វទេសិ កីទិសំ ។

ឥទំ វទាមីតិ ន តស្ស ហោតិ (មាគន្ទិយាតិ ភគវា)

ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ

បស្សញ្ច ទិដ្ឋីសុ អនុគ្គហាយ

អជ្ឈត្តសន្តឹ បចិនំ អទ្ទសំ[2] ។

វិនិច្ឆយា យានិ បកប្បិតានិ (ឥតិ មាគន្ទិយោ)

តេ[3] វេ មុនី ព្រូសិ អនុគ្គហាយ

---

១ ឱ. ម. សីលវតានុ ។ ២ ម. បវិចិនមទ្ទសំ ។ ម. ត្វេ វេ ។

ធ្វើម្ដេចឡើយ តថាគតនឹងមានសេចក្ដីប្រាថ្នា ក្នុងមេថុន ព្រោះឃើញរូបរបស់ធីតា ដែលពោរពេញ ដោយមូត្រនិងករីសនេះ តថាគត មិនគួរត្រូវការដើម្បីប៉ះពាល់នូវធីតារបស់អ្នកនោះ សូម្បីតែដោយជើងឡើយ ។

(មាគន្ទិយព្រាហ្មណ៍ទូលតបថា) បើព្រះអង្គមិនត្រូវការនារីរតន៍បែបនេះ ដែលពួកក្សត្រធំជាច្រើននរៈ ប្រើទន្ទាប្រាថ្នាទេ តើព្រះអង្គនឹងពោលនូវទិដ្ឋិផង សីលផង វត្តផង ជីវិតផង ការកើតឡើងក្នុងភព (របស់ព្រះអង្គ) ផង ជាដូចម្ដេច ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាគន្ទិយៈ) តថាគតនោះមិនប្រកាន់ថា តថាគតវិនិច្ឆ័យក្នុងធម៌ទាំងឡាយ គឺទិដ្ឋិ៦២ ហើយនឹងសំដែងនូវពាក្យនេះដូច្នេះទេ ព្រោះតថាគតឃើញ (ទោស) ក្នុងទិដ្ឋិទាំងឡាយផង មិនប្រកាន់មាំ (នូវទិដ្ឋិណាមួយ) ផង ពិចារណា (នូវសច្ចៈទាំងឡាយ) ផង ក៏បានឃើញនូវសេចក្ដីស្ងប់ក្នុងសន្ដាន គឺព្រះនិព្វាន ។

( មាគន្ទិយព្រាហ្មណ៍ ទូលសួរថា ) បពិត្រព្រះមុនី ទិដ្ឋិទាំងឡាយណា ដែលសត្វបានវិនិច្ឆ័យ កំណត់ទុកហើយ ព្រះអង្គមិនប្រកាន់មាំ នូវទិដ្ឋិទាំងនោះ សំដែង

អជ្ឈត្តសន្តីតិ យមេតមត្ថំ
កថំ នុ ធីរេហិ បវេទិតន្តំ ។

ន ទិដ្ឋិយា ន សុតិយា ន ញាណេន (មាគណ្ឌិយាតិ ភគវា)

សីលព្វតេនាបិ ន សុទ្ធិមាហ
អទិដ្ឋិយា អស្សុតិយា អញាណា
អសីលតា អព្វតា នោបិ តេន
ឯតេ ច និស្សជ្ជ អនុគ្គហាយ
សន្តោ អនិស្សាយ ភវំ ន ជប្បេ ។

នោ ចេ កិរ ទិដ្ឋិយា ន សុតិយា ន ញាណេន (ឥតិ មាគណ្ឌិយោ)

សីលព្វតេនាបិ ន សុទ្ធិមាហ (១)
អទិដ្ឋិយា អស្សុតិយា អញាណា
អសីលតា អព្វតា នោបិ តេន

១ ឱ. សីលព្វតេនាបិ វិសុទ្ធិមាហ ។

នូវបរមត្ថធម៌ណា មានសេចក្តីសុខ ក្នុងសន្តានដូច្នេះ បរមត្ថធម៌នោះ តើអ្នកប្រាជ្ញទាំងឡាយ សំដែងដោយប្រការដូចម្តេច ។

(ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលមាគន្ទិយៈ) អ្នកប្រាជ្ញមិនពោលថា សេចក្តីបរិសុទ្ធិព្រោះការយល់ឃើញ ព្រោះការស្តាប់ឮ ព្រោះការដឹងច្បាស់ ព្រោះសីលនិងវត្តទេ ទាំងមិនពោលថា សេចក្តីបរិសុទ្ធិ ព្រោះមិនមានការយល់ឃើញ ព្រោះមិនមានការស្តាប់ឮ ព្រោះមិនមានការដឹងច្បាស់ ព្រោះមិនមានសីល ព្រោះមិនមានវត្តទាំងនោះទេ បំណែកបុគ្គលជាសប្បុរស តែងលះនូវធម៌មានទិដ្ឋិជាដើមនុ៎ះ ហើយមិនប្រកាន់ មិនអាស្រ័យ (នូវធម៌ណាមួយ) រមែងមិនប្រាថ្នាទៅកើតក្នុងភពទៀតឡើយ ។

(មាគន្ទិយព្រាហ្មណ៍ ក្រាបទូលថា) បើអ្នកប្រាជ្ញមិនពោលថា សេចក្តីបរិសុទ្ធិព្រោះការយល់ឃើញ ព្រោះការស្តាប់ឮ ព្រោះការដឹងច្បាស់ព្រោះសីលនិងវត្តទេ ទាំងមិនពោលថា សេចក្តីបរិសុទ្ធិ ព្រោះមិនមានការយល់ឃើញ ព្រោះមិនមានការស្តាប់ឮ ព្រោះមិនមានការដឹងច្បាស់ ព្រោះមិនមានសីល ព្រោះមិនមានវត្តទាំងនោះទេ

មញ្ញាមហំ(១) មោមុហមេវ ធម្មំ
ទិដ្ឋិយា ច ឯកេ បច្ចេន្តិ សុទ្ធឹ ។

ទិដ្ឋីសុ និស្សាយ អនុបុច្ឆមានោ(២) (មាគន្ទិយាតិ ភគវា)

សមុគ្គហីតេសុ សមោហមាគា
ឥតោ ច នាទ្ទក្ខិ អណុម្បិ សញ្ញំ
តស្មា តុវំ មោមុហតោ ទហាសិ
សមោ វិសេសី ឧទ វា និហីនោ
យោ មញ្ញតី សោ វិវទេថ តេន
តីសុ វិធាសុ អវិកម្បមានោ
សមោ វិសេសីតិ ន តស្ស ហោតិ ។
សច្ចន្តិ សោ ព្រាហ្មណោ កឹ វទេយ្យ

១ ឱ. មញ្ញាមហំ ។ ២ ម. អបុច្ឆមានោ ។

ខ្ញុំព្រះអង្គសំគាល់នូវធម៌ នាំសត្វឲ្យវង្វេងក្រៃពេក មានសមណ-ព្រាហ្មណ៍ពួកខ្លះ ដឹងនូវសេចក្តីបរិសុទ្ធិ ព្រោះការយល់ឃើញដែរ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលមាគន្ទិយៈ) អ្នកអាស្រ័យនូវទិដ្ឋិបានជាចំដដែលសួរ (តថាគត) អ្នកដល់នូវសេចក្តីកាន់ប្រកាន់ក្នុងទិដ្ឋិទាំងឡាយដែលអ្នកប្រកាន់មាំហើយ ហើយមិនបានឃើញនូវសេចក្តីសំគាល់សូម្បីបន្តិចបន្តួច អំពីធម្មទេសនាដែលតថាគតសំដែងនេះឡើយ ព្រោះហេតុនោះ អ្នកទើបយល់ឃើញនូវធម៌នេះថាជាធម៌នាំសត្វឲ្យវង្វេងក្រៃពេក បុគ្គលណាសំគាល់ខ្លួនថាជាបុគ្គលស្មើនឹងគេជាបុគ្គលវិសេសជាងគេ ឬជាបុគ្គលថោកទាបជាងគេ បុគ្គលនោះនឹងនិយាយទទឹងទាស់ដោយសេចក្តីសំគាល់នោះ (បើបុគ្គលណា) មិនញាប់ញ័រក្នុងមានៈទាំង ៣ សេចក្តីសំគាល់ខ្លួនថា អញជាបុគ្គលស្មើនឹងគេ អញជាបុគ្គលវិសេសជាងគេ (ឬថាអញជាបុគ្គលថោកទាបជាងគេ) មិនមានដល់បុគ្គលនោះឡើយ ។ បុគ្គលដែលមានបាបគឺមានៈនឹងទិដ្ឋិ លះបង់ហើយនោះ នឹងនិយាយថាសេចក្តីយល់នោះឯង ជាសេចក្តីយល់ត្រូវពិត ដូចម្តេចកើត

មុសាតិ វា សោ វិវទេថ កេន

យស្មឹ សមំ វិសមំ វាបិ នត្ថិ

ស កេន វាទំ បដិសំយុជេយ្យ (១) ។

ឱកំ បហាយ អនិកេតសារី

គាមេ អកុព្វំ មុនិ សន្ថវានិ

កាមេហិ រិត្តោ អបុរេក្ខរានោ

កថំ ន វិគ្គយ្ហ ជនេន កយិរា ។

យេហិ វិវិត្តោ វិចរេយ្យ លោកេ

ន តានិ ឧគ្គយ្ហ វទេយ្យ(២) នាគោ

ឯលម្ពុជំ(៣) កណ្ឌកំ វារិជំ យថា

ជលេន បង្កេន ច នូបលិត្តំ

ឯវំ មុនី សន្តិវាទោ(៤) អគិទ្ធោ

កាមេ ច លោកេ ច អនូបលិត្តោ ។

---

១ ម. បដិសំយុញ្ជេយ្យ ។ ២ ម. ចរេយ្យ ។ ៣ ម. ជលម្ពុជំ ។ ៤ ឱ. ម. សន្តិវាទេ ។

បុគ្គលនោះ មិននិយាយទទឹងទាស់ថា (ពាក្យខ្ញុំពិត ពាក្យអ្នកឯង) មិនពិតដូច្នេះ ជាមួយនឹងបុគ្គលណាបាន មួយទៀត សេចក្ដីសំគាល់ថា ស្មើឬមិនស្មើ មិនមានក្នុងបុគ្គលណា បុគ្គលនោះ មិនផ្សាយវាទៈជាមួយអ្នកណាបាន ។ អ្នកប្រាជ្ញបានលះបង់ឱកៈ (១) ហើយ ជាអ្នកមិនរឭកនូវអារម្មណ៍ជាគ្រឿងកំណត់ មិនធ្វើសេចក្ដីស្និទ្ធស្នាល (នឹងគ្រហស្ថ) ក្នុងស្រុក ជាអ្នកវៀរចាកកាមទាំងឡាយ មិនធ្វើអត្តភាពឲ្យកើតតទៅទៀត អ្នកប្រាជ្ញនោះ មិនគប្បីធ្វើពាក្យពោលជំទាស់នឹងជន (ណា) ឡើយ ។ បុគ្គលប្រសើរ ជាអ្នកស្ងប់ស្ងាត់ ចាកបាបធម៌ (មានការយល់ខុសជាដើម) ណា ហើយត្រាច់ទៅ ក្នុងលោក មិនគប្បីលើកឡើងនូវបាបធម៌ទាំងនោះមកហើយនិយាយជជែកគេ ផ្កាឈូក ដុះនៅក្នុងទឹក មិនប្រឡាក់ដោយទឹកផង ដោយភក់ផង យ៉ាងណាមិញ អ្នកប្រាជ្ញជាអ្នកពោលនូវសេចក្ដីស្ងប់ មានសន្ដានមិនជាប់ចំពាក់ រមែងជាអ្នកមិនជក់ជាប់នៅ ក្នុងកាមផង ក្នុងលោកផង យ៉ាងនោះឯង ៗ

---

១ ឱកៈ ពាក្យនេះ សំដៅយកក្រុមនឹងវត្ថុជាដើម ដែលជាកន្លែងសម្រាប់វិញ្ញាណជ្រក ។ អដ្ឋកថា ។

ន វេទគូ ទិដ្ឋិយា ន មុតិយា
ស មានមេតិ ន ហិ តម្មយោ សោ
ន កម្មុនា នោបិ សុតេន នេយ្យោ
អនូបនីតោ ស និវេសនេសុ ។
សញ្ញាវិរត្តស្ស ន សន្តិ គន្ថា
បញ្ញាវិមុត្តស្ស ន សន្តិ មោហា
សញ្ញញ្ច ទិដ្ឋិញ្ច យេ អគ្គហេសុំ
តេ ឃដ្ដមានា(១) វិចរន្តិ លោកេ ។

មាគន្ទិយសុត្តំ នវមំ ។

# ទសមំ បុរាភេទសុត្តំ

(១០៤) កថំទស្សី កថំសីលោ ឧបសន្តោតិ វុច្ចតិ
តំ មេ គោតម បព្រូហិ បុច្ឆិតោ ឧត្តមំ នរំ ។

---

១ ឱ. ឃដិយន្តា ។ ម. ឃដមានា ។

បុគ្គលអ្នកដល់ នូវវេទ គឺមគ្គ ៤ តែងមិនប្រព្រឹត្តទៅតាមទិដ្ឋិទេ បុគ្គលនោះ មិនត្រឡប់មកកាន់មានះ ដោយការប៉ះពាល់ទេ បុគ្គលនោះ មិនប្រព្រឹត្តទៅតាមអំណាចនៃតណ្ហាទិដ្ឋិនោះទេ បុគ្គលនោះ មិនងាយអ្នកណា ដឹកនាំដោយកម្ម ឬដោយអារម្មណ៍ដែលឮបានឡើយ បុគ្គលនោះ មិនចូលទៅនៅអាស្រ័យក្នុងនិវេសនៈគឺតណ្ហា និងទិដ្ឋិទេ ។ កិលេសគ្រឿងរួបរឹតទាំងឡាយ តែងមិនមានដល់បុគ្គលអ្នកប្រាសចាកកាមសញ្ញា (ជាដើម) មោហៈ ( សេចក្តីកាន់ច្រឡំ ) តែងមិនមានដល់បុគ្គលអ្នកផុតស្រឡះ (ចាកកិលេសទាំងពួង) ព្រោះវិបស្សនាបញ្ញា បុគ្គលទាំងឡាយណា ប្រកាន់មាំនូវកាមសញ្ញាជាដើមក្តី ប្រកាន់មាំនូវទិដ្ឋិក្តី បុគ្គលពួកនោះ រមែងព្យាយាមប្រព្រឹត្តនូវកាមាធិករណ៍ ឬធម្មាធិករណ៍ នូវគ្នានឹងគ្នាក្នុងលោក ។

ចប់ មាគន្ទិយសូត្រ ទី ៩ ។

## បុរាភេទសូត្រ ទី ១០

(១០៤) (ព្រះពុទ្ធនិម្មិត ត្រាស់សួរព្រះសម្ពុទ្ធថា) បុគ្គលអ្នកមានទស្សនៈដូចម្តេច មានសីលដូចម្តេច ដែលព្រះអង្គត្រាស់ហៅថាអ្នកស្ងប់រម្ងាប់ បពិត្រព្រះគោតម ព្រះអង្គ ដែលខ្ញុំសួរហើយ សូមប្រាប់នូវឧត្តមជននោះ ។

វីតតណ្ហោ បុរា ភេទា (ឥតិ ភគវា) បុព្វមន្តមនិស្សិតោ
វេមជ្ឈេ នុបសង្ខេយ្យោ(១) តស្ស នត្ថិ បុរេក្ខតំ ។
អក្កោធនោ អសន្តាសី អវិកត្ថី អកុក្កុច្ចោ
មន្តភាណី(២) អនុទ្ធតោ ស វេ វាចាយតោ មុនិ ។
និរាសត្តិ អនាគតេ អតីតំ នានុសោចតិ
វិវេកទស្សី ផស្សេសុ ទិដ្ឋីសុ ច ន និយ្យតិ
បដិលីនោ អកុហកោ អបិហាលុ អមច្ឆរី
អប្បគព្ភោ អជេគុច្ឆោ បេសុណេយ្យេ ច នោ យុតោ
សាតិយេសុ អនស្សាវី អតិមានេ ច នោ យុតោ
សណ្ហោ ច បដិភាណវា ន សទ្ធោ ន វិរជ្ជតិ
លាភកម្យា ន សិក្ខតិ អលាភេ ច ន កុប្បតិ(៣)
អវិរុទ្ធោ ច តណ្ហាយ រសេសុ នានុគិជ្ឈតិ

---

១ ឱ. នូបសង្ខេយ្យោ ។ ២ ឱ. មត្តភាណី ។ ៣ ឱ. អលោភេ ន ច កុប្បតិ ។ ម. អលាភេ ន កុប្បតិ ។

(ព្រះមានព្រះភាគត្រាស់ថា) មុនទីបែកធ្លាយរាងកាយទៅ បុគ្គលណា ប្រាសចាកតណ្ហា មិនអាស្រ័យនូវកាលខាងដើមទីបំផុត គឺកាលជាអតីតនិងអនាគត ជាបុគ្គលដែលអ្នកប្រាជ្ញមិនគប្បីពោលថាជាអ្នកត្រេកអរ ក្នុងបច្ចុប្បន្ន ការធ្វើនូវតណ្ហានិងទិដ្ឋិឲ្យជាប្រធាននៃបុគ្គលនោះមិនមានឡើយ ។ បុគ្គលនោះឯង មិនក្រោធ មិនតក់ស្លុត មិនពោលអួត មិនរពិស ជាអ្នកពោលដោយបញ្ញា មិនរាយមាយ សង្រួមដោយវាចា ជាអ្នកប្រាជ្ញ ។ បុគ្គលមិនមានតណ្ហាក្នុងអារម្មណ៍ជាអនាគត មិនសោកស្តាយ នូវអារម្មណ៍អតីត ជាអ្នកឃើញសេចក្តីស្ងប់ស្ងាត់ ក្នុងផស្សៈទាំងឡាយ មិនបង្អោនចិត្តទៅក្នុងមិច្ឆាទិដ្ឋិទាំងឡាយ ជាអ្នកពួនសម្ងំ មិនបំភាន់គេ មិនមានសេចក្តីប្រាថ្នាជាប្រក្រតី មិនមានសេចក្តីកំណាញ់ មិនឃ្នើសឃ្នង ជាបុគ្គលដែលគេមិនស្អប់ខ្ពើម ជាអ្នកមិនប្រកប ក្នុងការញុះញង់ មិនទឹកនា ទៅរកវត្ថុជាទីត្រេកអរ មិនប្រកបក្នុងការមើលងាយគេ ជាអ្នកមានការហ៊ាល្អិតល្អ មានបដិភាណ មិនជឿអ្នកដទៃ មិនត្រេកអរ មិនសិក្សា ព្រោះប្រាថ្នាលាភ មិនក្រេវក្រោធ ព្រោះមិនមានលាភ ជាអ្នកមិនទទឹង មិនជាប់ចិត្ត ក្នុងរស ព្រោះតណ្ហា

ឧបេក្ខកោ សទា សតោ ន លោកេ មញ្ញតេ សមំ

ន វិសេសី ន នីចេយ្យោ(1) តស្ស នោ សន្តិ ឧស្សទា ។

យស្ស និស្សយតា ន ត្ថិ(2) ញត្វា ធម្មំ អនិស្សិតោ

ភវាយ វិភវាយ វា តណ្ហា យស្ស ន វិជ្ជតិ

តំ ព្រូមិ ឧបសន្តោតិ កាមេសុ អនបេក្ខិនំ

គន្ថា តស្ស ន វិជ្ជន្តិ អតារី សោ វិសត្តិកំ ។

ន តស្ស បុត្តា បសវោ(3) ខេត្តំ វត្ថុញ្ច វិជ្ជតិ

អត្តំ វាបិ និរត្តំ វា ន តស្មឹ ឧបលព្ភតិ ។

យេន នំ វជ្ជុំ បុថុជ្ជនា អថោ សមណព្រាហ្មណា

តំ តស្ស អបុរក្ខតំ តស្មា វាទេសុ នេជតិ(4) ។

---

១ ម. ន វិសេសំ ន នីចេយ្យុ ។ ២ ម. និស្សយតា ។ ៣ ឱ. ម. បសវោ វា ។
៤ ម. ឯជតិ ។

ជាបុគ្គលមានឧបេក្ខា មានស្មារតីសព្វពេល មិនសំគាល់ថា ស្មើនឹងគេក្នុងលោក មិនលើកខ្លួនថា វិសេសជាងគេ មិនដាក់ខ្លួនថាថោកទាបជាងគេ កិលេសគ្រឿងពុះពោរមិនមាន ដល់បុគ្គលនោះឡើយ ។ បុគ្គលណា មិនមាននិស្សយធម៌ គឺតណ្ហានិងទិដ្ឋិ បុគ្គលណា ដឹងនូវធម៌ ហើយមិនអាស្រ័យ នូវតណ្ហានិងទិដ្ឋិ បុគ្គលមិនមានតណ្ហាក្នុងសេចក្តីចំរើននិងសេចក្តីវិនាស (១) តថាគតហៅបុគ្គលអ្នកមិនអាឡោះអាល័យក្នុងកាមទាំងឡាយនោះ ថាជាអ្នកស្ងប់រម្ងាប់ កិលេសគ្រឿងជាក់ស្រែះរបស់បុគ្គលនោះមិនមាន បុគ្គលនោះបានឆ្លងនូវតណ្ហាដែលផ្សាយទៅហើយ ។ កូនទាំងឡាយសត្វចិញ្ចឹមទាំងឡាយ និងស្រែចម្ការ ទីលំនៅរបស់បុគ្គលនោះមិនមានឡើយ សេចក្តីប្រកាន់ថាជារបស់ខ្លួនគឺសស្សតទិដ្ឋិ សេចក្តីប្រកាន់ថាមិនមែនជារបស់ខ្លួនគឺឧច្ឆេទទិដ្ឋិ មិនមានក្នុងបុគ្គលនោះទេ ។ ពួកទេវតានិងមនុស្សជាបុថុជ្ជនឬពួកសមណព្រាហ្មណ៍ គប្បីពោលទោសចំពោះបុគ្គលនោះដោយកិលេសមានរាគៈជាដើមណា កិលេសមានរាគៈជាដើមនោះ បុគ្គលនោះមិនធ្វើឲ្យជាប្រធានឡើយ ព្រោះហេតុនោះបុគ្គលមិនញាប់ញ័រ ព្រោះពាក្យពោលទាំងឡាយឡើយ ។

---

១ សស្សតៈ ប្រព្រឹត្តទៅក្នុងរូបភព. ឧច្ឆេទ ប្រព្រឹត្តទៅក្នុងអរូបភព ។ អដ្ឋកថា ។

វីតគេធោ អមច្ឆរី ន ឧស្សេសុ(១) វទតេ មុនិ
ន សមេសុ ន ឱមេសុ កប្បំ នេតិ អកប្បិយោ ។
យស្ស លោកេ សកំ នត្ថិ អសតា ច ន សោចតិ
ធម្មេសុ ច ន គច្ឆតិ ស វេ សន្តោតិ វុច្ចតីតិ ។

បុរាភេទសុត្តំ ទសមំ ។

## ឯកាទសមំ កលហវិវាទសុត្តំ

(១០៨) កុតោ បហូតា កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច
មានាតិមានា សហបេសុណា ច
កុតោ បហូតា តេ តទិង្ឃ ព្រូហិ ។
បិយប្បហូតា(២) កលហា វិវាទា
បរិទេវសោកា សហមច្ឆរា ច

១ ម. ឧស្សុស្សេសុ ។ ២ ឱ. បិយាបហូតា ។

អ្នកប្រាជ្ញប្រាសចាកសេចក្តីជាប់ចំពាក់ (ក្នុងរូបជាដើម) មិនមានសេចក្តីកំណាញ់ មិននិយាយលើកខ្លួន ក្នុងគុណដ៏ខ្ពង់ខ្ពស់ មិននិយាយប្រកបខ្លួន ក្នុងគុណដ៏ស្មើ ។ មិននិយាយបន្ទាបខ្លួន ក្នុងគុណដ៏ថោកថយ មិនដល់នូវកប្ប: គឺមិនមានតណ្ហានិងទិដ្ឋិ ព្រោះជាបុគ្គលមិនមានកប្ប: ។ បុគ្គលណា មិនមានសេចក្តីប្រកាន់ថា របស់ខ្លួនក្នុងលោក បុគ្គលនោះមិនសោក ព្រោះរបស់ដែលមិនមាន មិនលុះក្នុងអគតិធម៌ទាំងឡាយ បុគ្គលនោះឯងហៅថា អ្នកស្ងប់រម្ងាប់ ។

ចប់ បុរាភេទសូត្រ ទី ១០ ។

## កលហវិវាទសូត្រ ទី ១១

(១០៩) (ព្រះពុទ្ធនិម្មិត ត្រាស់សួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គ) ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោកស្តាយ និងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ និងការញុះញង់ កើតមកអំពីណា កិលេសធម៌ទាំងនោះ បណ្តាលមកអំពីណា សូមព្រះអង្គសំដែងសេចក្តីនោះឲ្យបាន ។ (ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា) ការឈ្លោះ ការទាស់ទែងគ្នា ការខ្សឹកខ្សួល ការសោកស្តាយ និងសេចក្តីកំណាញ់

មានាតិមានា សហបេសុណា ច
មច្ឆេរយុត្តា(១) កលហា វិវាទា
វិវាទជាតេសុ ច បេសុណានិ ។
បិយា(២) នុ លោកស្មឹ កុតោនិទានា
យេ ចាបិ លោភា វិចរន្តិ លោកេ
អាសា ច និដ្ឋា ច កុតោនិទានា
យេ សម្បរាយាយ នរស្ស ហោន្តិ ។
ឆន្ទានិទានានិ បិយានិ លោកេ
យេ ចាបិ លោភា វិចរន្តិ លោកេ
អាសា ច និដ្ឋា ច ឥតោនិទានា
យេ សម្បរាយាយ នរស្ស ហោន្តិ ។
ឆន្ទោ នុ លោកស្មឹ កុតោនិទានោ

១ ម. មច្ឆរិយយុត្តា ។ ២ ឱ. ម. បិយា សុ ។

ការប្រកាន់ ការមើលងាយ និងការញុះញង់ កើតមកអំពីរបស់ជាទីស្រឡាញ់ ឯកិលេសធម៌ មានការឈ្លោះនឹងការជជែកគ្នា (ជាដើម) ប្រកបក្នុងសេចក្ដីកំណាញ់ កាលបើសេចក្ដីទាស់ទែងគ្នាកើតឡើងហើយ ពាក្យញុះញង់ក៏កើតឡើងដែរ។ (ព្រះពុទ្ធនិម្មិតសួរថា) សេចក្ដីស្រឡាញ់ក្នុងលោក ឬលោភៈ របស់ពួកសត្វ ដែលត្រូវលោភៈគ្របសង្កត់ ត្រាច់ទៅក្នុងលោក កើតមកអំពីអ្វី សេចក្ដីប៉ុនប៉ងនិងការសម្រេច (នៃសេចក្ដីប៉ុនប៉ង) និងធម៌ដែលមានក្នុងបរលោករបស់សត្វ កើតមកអំពីអ្វី ។ (ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា) សេចក្ដីស្រឡាញ់ក្នុងលោក ឬលោភៈរបស់ពួកសត្វ ដែលត្រូវលោភៈគ្របសង្កត់ កើតមកអំពីឆន្ទៈ សេចក្ដីប៉ុនប៉ង និងការសម្រេច (នៃសេចក្ដីប៉ុនប៉ង) និងធម៌ដែលមានក្នុងបរលោក របស់ពួកសត្វ ក៏កើតអំពីឆន្ទៈនេះដែរ ។ (ព្រះពុទ្ធនិម្មិតសួរថា) ឆន្ទៈក្នុងលោក កើតមកអំពីអ្វី

វិនិច្ឆយា ចាបិ កុតោ បហូតា

កោធោ មោសវជ្ជញ្ច កថង្កថា ច

យេ ចាបិ ធម្មា សមណេន វុត្តា ។

សាតំ អសាតន្តិ យមាហុ លោកេ

តមូបនិស្សាយ បហោតិ ឆន្ទោ

រូបេសុ ទិស្វា វិភវំ ភវញ្ច

វិនិច្ឆយំ កុព្វតេ ជន្តុ លោកេ ។

កោធោ មោសវជ្ជញ្ច កថង្កថា ច

ឯតេបិ ធម្មា ទ្វយមេវ សន្តេ

កថង្កថី ញាណបថាយ សិក្ខេ

ញត្វា បវុត្តា សមណេន ធម្មា ។

មួយទៀត វិនិច្ឆ័យ (ការចូលចិត្តកន្លែងណាទីនិវិដ្ឋ) កើតមកអំពីអ្វី ការក្រេវក្រោធ ការនិយាយមោសា និងសេចក្ដីសង្ស័យ ឬអកុសលធម៌ទាំងឡាយ ដែល (ប្រកបដោយការក្រេវក្រោធជាដើម) តើព្រះសមណៈសំដែងហើយថាកើតអំពីអ្វី ។ (ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា) អ្នកប្រាជ្ញទាំងឡាយ ក្នុងលោក បានសំដែងហើយនូវអារម្មណ៍ណាថាជាទីត្រេកអរ(១) និងមិនជាទីត្រេកអរ (២) ឆន្ទៈតែងកើតឡើង ព្រោះអាស្រ័យអារម្មណ៍នោះ សត្វក្នុងលោកឃើញសេចក្ដីវិនាសនិងសេចក្ដីចំរើន ក្នុងរូបទាំងឡាយ ទើបធ្វើនូវវិនិច្ឆ័យ (ក្នុងកន្លែងណាទីនិវិដ្ឋ) ។ ការក្រេវក្រោធ ការពោលពាក្យមោសា សេចក្ដីសង្ស័យ ធម៌ទាំង ៣ នេះឯង កាលបើអារម្មណ៍ជាទីត្រេកអរនិងមិនជាទីត្រេកអរទាំង ២ ប្រការនោះនៅមាន ទើបកើតមានឡើងបាន បុគ្គលអ្នកមានសេចក្ដីសង្ស័យ គប្បីសិក្សាក្នុងគន្លងនៃការដឹង ឯធម៌ទាំងឡាយ ព្រះសមណៈសំដែងហើយ ព្រោះដឹង ។

---

១ បានដល់សុខវេទនានឹងវត្ថុដែលគួរប្រាថ្នា ។ ២ បានដល់ទុក្ខវេទនានឹងវត្ថុដែលមិនគួរប្រាថ្នា ។ អដ្ឋកថា ។

សាតំ អសាតញ្ច កុតោនិទានា
កិស្មឹ(១) អសន្តេ ន ភវន្តិ ហេតេ
វិភវំ ភវញ្ចាបិ យមេតមត្ថំ
ឯតម្មេ បព្រូហិ យតោនិទានំ ។
ផស្សនិទានំ សាតំ អសាតំ ។
ផស្សេ អសន្តេ ន ភវន្តិ ហេតេ
វិភវំ ភវញ្ចាបិ យមេតមត្ថំ
ឯតន្តេ បព្រូមិ ឥតោនិទានំ ។
ផស្សោ នុ លោកស្មឹ កុតោនិទានោ
បរិគ្គហា ចាបិ កុតោ បហូតា
កិស្មឹ អសន្តេ ន មមត្តមត្ថិ
កិស្មឹ វិភូតេ ន ផុសន្តិ ផស្សា ។
នាមញ្ច រូបញ្ច បដិច្ច ផស្សា
ឥច្ឆានិទានានិ បរិគ្គហានិ

---

១ ម. កស្មិ ។

(ព្រះពុទ្ធនិម្មិតសួរថា) អារម្មណ៍ជាទីត្រេកអរ នឹងមិនជាទីត្រេកអរ កើតមកអំពីអ្វី កាលបើអ្វីមិនមាន ទើបអារម្មណ៍ទាំងនុ៎ះមិនមានដែរ អត្ថនៃសេចក្តីវិនាស នឹងសេចក្តីចំរើន (នៃអារម្មណ៍ជាទីត្រេកអរនឹងមិនជាទីត្រេកអរ)ណា អត្ថនោះ កើតមកអំពីធម៌ណា សូមព្រះអង្គសំដែងប្រាប់ដល់ខ្ញុំឲ្យបាន ៗ (ព្រះសម្ពុទ្ធត្រាស់តបថា) អារម្មណ៍ជាទីត្រេកអរនឹងមិនជាទីត្រេកអរ កើតមកអំពីផស្សៈ កាលបើផស្សៈ មិនមាន ទើបអារម្មណ៍ទាំងនុ៎ះមិនមាន អត្ថនៃសេចក្តីវិនាស នឹងសេចក្តីចំរើន (នៃអារម្មណ៍ជាទីត្រេកអរនឹងមិនជាទីត្រេកអរ) ណា អត្ថនោះកើតមកអំពីផស្សៈនេះ តថាគតសំដែងប្រាប់ដល់អ្នក (ដូច្នេះ) ៗ (ព្រះពុទ្ធនិម្មិតសួរថា) ចុះផស្សៈក្នុងលោក កើតមកអំពីអ្វី មួយទៀត សេចក្តីហួងហែង កើតមកអំពីអ្វី កាលបើអ្វីមិនមាន សេចក្តីប្រកាន់ថា របស់អញៗ ទើបមិនមាន កាលបើអ្វីមិនមាន ផស្សៈទាំងឡាយ ទើបមិនពាល់ត្រូវ ៗ (ព្រះសម្ពុទ្ធត្រាស់តបថា) ផស្សៈ (កើតឡើង) ព្រោះអាស្រ័យនាមនឹងរូប សេចក្តីហួងហែង កើតមកអំពីតណ្ហា

ឥច្ឆាយ អសន្ត្យា(១) ន មមត្តមត្ថិ

រូបេ វិភូតេ ន ផុសន្តិ ផស្សា ។

កថំសមេតស្ស វិភោតិ រូបំ

សុខំ ទុក្ខំ វាបិ កថំ វិភោតិ

ឯតម្មេ ព្រូហិ យថា វិភោតិ

តំ ជានិយាម ឥតិ មេ មនោ អហុ ។

ន សញ្ញសញ្ញី ន វិសញ្ញសញ្ញី

នោបិ អសញ្ញី ន វិភូតសញ្ញី

១ ឱ. ឥច្ឆាន សន្ត្យា ។ ម. ឥច្ឆាយ សន្ត្យា ។

កាលបើឥច្ឆា មិនមាន សេចក្តីប្រកាន់ថា របស់អញ ។ ក៏មិនមាន កាលបើរូប មិនមាន ផស្សៈទាំងឡាយ ក៏មិនពាល់ត្រូវ ។ (ព្រះពុទ្ធនិម្មិតសួរថា) កាលបុគ្គលប្រតិបត្តិដូចម្តេច ទើបរូបវិនាសទៅ មួយទៀត រូបជាសុខ (រូបគួរប្រាថ្នា) នឹងរូបជាទុក្ខ (រូបដែលមិនជាទីប្រាថ្នា) វិនាសទៅវិញ ដោយប្រការដូចម្តេច សូមព្រះអង្គសំដែងនូវរូបដែលជាសុខនឹងជាទុក្ខនោះដល់ខ្ញុំ រូបដែលជាសុខនឹងជាទុក្ខវិនាសទៅដោយហេតុណា ខ្ញុំដឹងនូវហេតុនោះ ខ្ញុំមានចិត្តត្រិះរិះដូច្នេះ ។ (ព្រះសម្ពុទ្ធត្រាស់តបថា) បុគ្គលមិនមែនជាសញ្ញាសញ្ញី (១) បុគ្គលមិនមែន ជាវិសញ្ញាសញ្ញី (២) បុគ្គលមិនមែន ជាអសញ្ញី (៣) បុគ្គលមិនមែន ជាវិភូតសញ្ញី (៤)

---

១ បុគ្គលមានសញ្ញាដោយសញ្ញាជាប្រក្រតី គឺបុគ្គលមានសញ្ញាជាធម្មតា ហៅថា សញ្ញាសញ្ញីបុគ្គល ។ ២ បុគ្គលមានសញ្ញាដោយខុសសញ្ញា គឺបុគ្គលឆ្កួត ឬមានចិត្តរាយមាយ ( ហៅថា វិសញ្ញាសញ្ញីបុគ្គល ។ ៣ បុគ្គលមិនមែនជាមិនមានសញ្ញា គឺបុគ្គលដែលចូលនិរោធសមាបត្តិ ឬអសញ្ញីសត្វ ហៅថា អសញ្ញីបុគ្គល ។ ៤ បុគ្គលដែលមានសញ្ញាក្នុងរូបដែលស្ងប់ គឺបុគ្គលដែលបានអរូបជ្ឈាន ហៅថា វិភូតសញ្ញីបុគ្គល ។ អដ្ឋកថា ។

ឯវំសមេតស្ស វិភោតិ រូបំ

សញ្ញានិទានា ហិ បបញ្ចសង្ខា ។

យន្តំ អបុច្ឆិម្ហ អកិត្តយី នោ

អញ្ញន្តំ បុច្ឆាម តទិង្ឃ ព្រូហិ

ឯត្តាវតគ្គំ នោ វទន្តិ ហេកេ

យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ

ឧទាហុ អញ្ញម្បិ វទន្តិ ឯត្តោ ។

ឯត្តាវតគ្គម្បិ វទន្តិ ហេកេ

យក្ខស្ស សុទ្ធឹ ឥធ បណ្ឌិតាសេ

តេសំ បុនេកេ សមយំ វទន្តិ

អនុបាទិសេសេ កុសលា វទានា ។

ឯតេ ច ញត្វា ឧបនិស្សិតាតិ

ញត្វា មុនី និស្សយេ សោ វិមំសី

កាលបុគ្គលប្រតិបត្តិយ៉ាងនេះ រូបទើបវិនាសបាន ព្រោះធម៌ជាបំណែកនៃសេចក្តីយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ។ (ព្រះពុទ្ធនិម្មិតពោលថា) ខ្ញុំបានសួរនូវធម៌ណា ព្រះអង្គក៏បានសំដែងធម៌នោះ ដល់ខ្ញុំរួចហើយ ខ្ញុំសូមសួរធម៌ផ្សេងទៀត សូមព្រះអង្គសំដែងធម៌នោះដល់ខ្ញុំឲ្យទាន (បពិត្រព្រះអង្គ) ចុះសមណ-ព្រាហ្មណ៍ ជាបណ្ឌិតពួកខ្លះ ក្នុងលោកនេះ សំដែងនូវសេចក្តីបរិសុទ្ធិដ៏ប្រសើររបស់សត្វថា បំផុតត្រឹមប៉ុណ្ណោះឬ ឬក៏សំដែងនូវសេចក្តីបរិសុទ្ធិដទៃ ជាងអរូបសមាបត្តិនេះទៅទៀត ។ (ព្រះសម្ពុទ្ធត្រាស់តបថា) ពួកសមណព្រាហ្មណ៍ជាបណ្ឌិតពួកខ្លះសំដែងនូវអរូបសមាបត្តិទាំងឡាយនោះ ថាជាធម៌ដ៏បរិសុទ្ធិប្រសើរ របស់សត្វតែប៉ុណ្ណោះ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណ-ព្រាហ្មណ៍ពួកខ្លះទៀត (ជាឧច្ឆេទវាទ) ជាអ្នកពោលលើកខ្លួនថា ឆ្លៀវឆ្លាស ក្នុងអនុបាទិសេសនិព្វាន តែងប្រកាន់ពោលនូវលទ្ធិគឺសេចក្តីដាច់សូន្យ ថា (ជាធម៌ដ៏បរិសុទ្ធប្រសើររបស់សត្វ) ។ ព្រះពុទ្ធជាវីមំសីបណ្ឌិត ទ្រង់ជ្រាបនូវពួកសមណព្រាហ្មណ៍ទាំងនោះថាជាអ្នកអាស្រ័យនូវសស្សតទិដ្ឋិ ទាំងឧច្ឆេទទិដ្ឋិផង ទ្រង់ជ្រាបនូវធម៌គ្រឿងអាស្រ័យនៅ (របស់ពួកសមណព្រាហ្មណ៍ទាំងនោះ) ផង

ញត្វា វិមុត្តោ ន វិវាទមេតិ

ភវាភវាយ ន សមេតិ ធីរោតិ ។

កលហវិវាទសុត្តំ ឯកាទសមំ ។

## ទ្វាទសមំ ចូឡព្យូហសុត្តំ

(១០៦) សកំ សកំ ទិដ្ឋិបរិព្វសានា

វិគ្គយ្ហ នានា កុសលា វទន្តិ

យោ ឯវំ ជានាតិ ស វេទិ ធម្មំ

ឥទំ បដិក្កោសមកេវលី សោ ។

ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ

ពាលោ បរោ អក្កុសលោតិ ចាហុ

សច្ចោ នុ វាទោ កតមោ ឥមេសំ

សព្វេវ ហីមេ កុសលា វទានា ។

ប្រាប (នូវធម៌ទាំងឡាយ ថាជាទុក្ខមិនទៀងជាដើម) ហើយបាន រួបរួមស្រឡះផង ទើបមិនដល់នូវការទាស់ទែង អ្នកប្រាជ្ញ តែងមិនមក ដើម្បីកើតរឿយ ៗ ទៀយ ៗ

ចប់ កលហវិវាទសូត្រ ទី ១១ ។

## ចូឡវិយូហសូត្រ ទី ១២

(១០៦) (ព្រះពុទ្ធនិម្មិត ត្រាស់សួរព្រះសម្ពុទ្ធថា) សមណព្រាហ្មណ៍ទាំងឡាយ កាលជំអក់នៅក្នុងទិដ្ឋិ (សេចក្តីយល់ឃើញ) របស់ខ្លួនរៀងៗខ្លួន ប្រកាន់មាំ ប្រជាថាខ្លួនជាអ្នកឆ្លៀវឆ្លាស (ក្នុងទិដ្ឋិនោះ) ហើយនិយាយផ្សេងៗគ្នា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថា ដឹងនូវធម៌ពិត បុគ្គលណាបដិសេធធម៌នេះ បុគ្គលនោះឈ្មោះថាមិនមានគុណបរិបូណ៌ឡើយ ៗ លុះសមណព្រាហ្មណ៍ទាំងឡាយប្រកាន់មាំយ៉ាងនេះហើយ តែងទាស់ទែងគ្នា ទាំងពោលតិះដៀលថាបុគ្គលដទៃៗ ជាបុគ្គលពាល ជាបុគ្គលមិនឈ្លាសវៃ ពាក្យរបស់សមណព្រាហ្មណ៍ទាំងឡាយនេះ បែបណាជាពាក្យពិត ព្រោះសមណព្រាហ្មណ៍ទាំងនេះ ជាអ្នកពោលលើកខ្លួនថា ឆ្លៀវឆ្លាស ។

បរស្ស វេ ធម្មមនានុជានំ
ពាលោ មគោ ហោតិ និហីនបញ្ញោ
សព្វេវ ពាលា សុនិហីនបញ្ញា
សព្វេវិមេ ទិដ្ឋិបរិព្វសានា ។
សន្ទិដ្ឋិយា វេ បន វីវទាតា(១)
សំសុទ្ធបញ្ញា កុសលា មតីមា(២)
ន តេសំ កោចិ និហីនបញ្ញោ
ទិដ្ឋី ហិ តេសម្បិ តថា សមត្តា ។
ន វាហមេតំ តថិវន្តិ(៣) ព្រូមិ
យមាហុ ពាលោ មិថុ អញ្ញមញ្ញំ
សកំ សកំ ទិដ្ឋិមកំសុ សច្ចំ
តស្មា ហិ ពាលោតិ បរំ ទហន្តិ ។
យមាហុ សច្ចំ តថិវន្តិ ឯកេ

---

១ ម. វិវាទា ។ ២ ឱ. មុតីមា ។ ម. មុតីមា ។ ៣ ឱ. តថិយន្តិ ។ ម. តថិវន្តិ ។

(ព្រះសម្ពុទ្ធត្រាស់ថា) សមណព្រាហ្មណ៍ កាលបើមិនយល់ឃើញនូវធម៌របស់ជនដទៃ ឈ្មោះថាជាបុគ្គលពាល ជាបុគ្គលថោកទាប មានប្រាជ្ញាទន់ទាប សមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែជាបុគ្គលពាល មានប្រាជ្ញាថោកទាប ឈ្មោះថា សមណព្រាហ្មណ៍ទាំងនេះ ជាអ្នកដំអក់នៅក្នុងទិដ្ឋិ ។ មួយទៀត បើសមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកជ្រួតផង់ក្នុងទិដ្ឋិរបស់ខ្លួន ជាអ្នកមានប្រាជ្ញាដ៏បរិសុទ្ធ ជាអ្នកឈ្លាសវៃ ជាអ្នកមានប្រាជ្ញា បណ្តាសមណព្រាហ្មណ៍ទាំងនោះ គេអ្នកណាមួយ មានប្រាជ្ញាថោកទាបគ្មានទេ ព្រោះថា សមណព្រាហ្មណ៍ទាំងនោះ មានទិដ្ឋិស្មើ ៗ គ្នា ៗ ជនទាំងឡាយ (អ្នកធ្វើនូវជំលោះ) ជួបគ្នាជាគូ ៗ បានពោលសង្កត់សង្កិននូវគ្នានឹងគ្នាដោយពាក្យណាថា អ្នកនេះជាបុគ្គលពាលដូច្នេះ តថាគត មិនបានពោលនូវពាក្យនុ៎ះថាជាពាក្យពិតឡើយ ព្រោះថា ជនទាំងនោះ បានធ្វើនូវសេចក្តីយល់ឃើញរបស់ខ្លួនៗ ថាជារបស់ពិត ព្រោះហេតុនោះ បានជាជនទាំងនោះ ដុតកំដៅបុគ្គលដទៃ ដោយពាក្យថា បុគ្គលពាល ៗ (ព្រះពុទ្ធនិមិត្តសួរថា) សមណ-ព្រាហ្មណ៍ពួកខ្លះ បានសរសើរទិដ្ឋិណា ថាជារបស់ពិត ទៀងទាត់

តមាហុ អញ្ញេបិ តុច្ឆំ មុសាតិ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
កស្មា ន ឯកំ សមណា វទន្តិ ។

ឯកំ ហិ សច្ចំ ន ទុតីយមត្ថិ
យស្មឹ បជា នោ វិវទេ បជានំ
នានា តេ សច្ចានិ សយំ ថុនន្តិ(១)
តស្មា ន ឯកំ សមណា វទន្តិ ។

កស្មា នុ សច្ចានិ វទន្តិ នានា
បវាទិយាសេ កុសលា វទានា
សច្ចានិ សុតានិ ពហូនិ នានា
ឧទាហុ តេ តក្កមនុស្សរន្តិ ។

ន ហេវ សច្ចានិ ពហូនិ នានា
អញ្ញត្រ សញ្ញាយ និច្ចានិ(២) លោកេ

---

១ ម. ធុនន្តិ ។ ២ សញ្ញាទីតិ អដ្ឋកថាយំ ទិស្សតិ ។

ចំណែកសមណព្រាហ្មណ៍ពួកដទៃ តិះដៀលទិដ្ឋិនោះ ថាជារបស់ខាង កុហកវិញ លុះសមណព្រាហ្មណ៍ទាំងនោះ ប្រកាន់ផ្សេង ៗ យ៉ាងនេះហើយ ក៏ទាស់ទែងគ្នា ចុះសមណព្រាហ្មណ៍ទាំងឡាយ មិននិយាយមូលមាត់គ្នាតែមួយ តើព្រោះហេតុអ្វី ៗ (ព្រះសម្ពុទ្ធត្រាស់ថា) ព្រោះថាបុគ្គលកាលដឹងច្បាស់ក្នុងសច្ចៈណា ទើបមិនទាស់ទែងគ្នា ឯសច្ចៈនោះមានតែមួយ មិនមែនមានពីរឡើយ ប៉ុន្តែជនទាំងឡាយ តែងសរសើរសច្ចៈរបស់ខ្លួនផ្សេងៗ គ្នា ហេតុនោះ បានជាពួកសមណព្រាហ្មណ៍ មិននិយាយមូលមាត់គ្នាតែមួយ ៗ (ព្រះពុទ្ធនិម្មិតសួរថា) ព្រោះហេតុអ្វីហ្ន៎ បានជាសមណព្រាហ្មណ៍ទាំងឡាយ ដែលពោលលើកខ្លួនថាជាអ្នកឆ្លៀវឆ្លាស ជាអ្នកពោលតាមបំណងរបស់ខ្លួន តែងពោលសច្ចៈផ្សេង ៗ គ្នា ចុះសមណព្រាហ្មណ៍ទាំងនោះបានឮមកថា សច្ចៈមានច្រើនផ្សេងៗ គ្នាឬ ឬក៏សមណព្រាហ្មណ៍ទាំងនោះ នឹកតែដោយសេចក្ដីត្រិះរិះរបស់ខ្លួនទេ ៗ (ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា) សច្ចៈទាំងឡាយច្រើនផ្សេងៗគ្នា ក្នុងលោកមិនមានទេ លើកលែងតែសេចក្ដីប្រកាន់ថា ទៀងដោយសញ្ញាចេញ គឺមានតែបរមត្ថសច្ចៈមួយប៉ុណ្ណោះ

តក្កញ្ច ទិដ្ឋីសុ បកប្បយិត្វា
សច្ចំ មុសាតិ ទ្វយធម្មមាហុ ។
ទិដ្ឋេ សុតេ សីលវតេ មុតេ វា
ឯតេ ច និស្សាយ វិមានទស្សី
វិនិច្ឆយេ ឋត្វា បហស្សមានោ
ពាលោ បរោ អក្កុសលោតិ ចាហ ។
យេនេវ ពាលោតិ បរំ ទហាតិ
តេនាតុមានំ កុសលោតិ ចាហ
សយមត្តនា(១) សោ កុសលោ វទានោ
អញ្ញំ វិមានេតិ តទេវ(២) បាវ ។
អតិសារទិដ្ឋិយា សោ(៣) សមត្តោ
មានេន មត្តោ បរិបុណ្ណមានី
សយមេវ សាមំ មនសាភិសិត្តោ
ទិដ្ឋី ហិ សា តស្ស តថា សមត្តា ។

១ ម. សយមត្តនោ ។ ២ ឱ. តវេវ ។ ៣ ឱ. អតិសារំ ទិដ្ឋិយា សោ ។ ម. អតិសារទិដ្ឋិយាវ សោ ។

មួយទៀត សមណព្រាហ្មណ៍ទាំងឡាយ កំណត់ទុកនូវសេចក្តីត្រិះរិះឲ្យប្រជុំចុះ ក្នុងទិដ្ឋិទាំងឡាយ ហើយនិយាយនូវហេតុមួយគូជាធម្មតា គឺសេចក្តីពិត ១ មុសា ១ ៗ បុគ្គលពួកមួយ អាស្រ័យនូវទិដ្ឋិធម៌ទាំងនេះ គឺ អារម្មណ៍ដែលខ្លួនឃើញហើយ ឬឮហើយ ដែលខ្លួនពាល់ត្រូវហើយ ឬសីលវ័ត ជាអ្នកឃើញនូវសេចក្តីប្រកាន់ធំ គឺសន្តិកាព លុះឋិតនៅ ក្នុងវិនិច្ឆយធម៌គឺទិដ្ឋិ ៦២ ហើយរីករាយក៏ពោលតិះដៀលថា បុគ្គលដទៃជាបុគ្គលពាលមិនឈ្លៀវឈ្លាស ៗ មួយទៀត បុគ្គលនោះតែងដុតកំដៅបុគ្គលដទៃថាជាបុគ្គលពាល ៗ ដូច្នេះ ដោយហេតុណា ក៏បានពោលលើកខ្លួនឯង ថាជាអ្នកឈ្លៀវឈ្លាស ដោយហេតុនោះ បុគ្គលនោះ ពោលលើកខ្លួនឯងថាជាអ្នកឈ្លៀវឈ្លាសចំពោះខ្លួនដោយខ្លួនឯង រមែងតិះដៀលបុគ្គលដទៃ ហើយពោលប្រកាន់ទិដ្ឋិនោះ ៗ បុគ្គលនោះបរិបូណ៌ហើយដោយទិដ្ឋិ គឺការយល់ឃើញ ថាមានខ្លឹមសារក្រៃពេកទឹងដោយមានះ មានមានះដ៏បរិបូណ៌ ប្រស់ព្រំសន្តានខ្លួនដោយមានះ គឺប្រកាន់ថាខ្លួនជាបណ្ឌិត ទិដ្ឋិនោះរបស់បុគ្គលនោះ បរិបូណ៌ហើយ ដោយប្រការដូច្នោះ ៗ

បរស្ស ចេ ហិ វចសា និហីនោ
តុមោ(១) សហា ហោតិ និហីនបញ្ញោ
អថ ចេ(២) សយំ វេទគូ ហោតិ ធីរោ
ន កោចិ ពាលោ សមណេសុ អត្ថិ ។
អញ្ញំ ឥតោ យាភិវទន្តិ ធម្មំ
អបរទ្ធា សុទ្ធិមកេវលី តេ
ឯវម្បិ តិត្ថ្យា បុថុសោ វទន្តិ
សន្ទិដ្ឋិរាគេន ហិ ត្យាភិរត្តា ។
ឥធេវ សុទ្ធឹ ឥតិ វាទយន្តិ
នាញ្ញេសុ ធម្មេសុ វិសុទ្ធិមាហុ
ឯវម្បិ តិត្ថ្យា បុថុសោ និវិដ្ឋា
សកាយនេ តត្ថ ទឡ្ហំ វទានា ។

១ ម. តុម្ហោ ។ ម. អបិស្ស ចេ ។

ប្រសិនបើមានបុគ្គលអ្នកថោកទាប ដោយសារពាក្យតិះដៀល របស់បុគ្គលដទៃ បុគ្គលដែលតិះដៀលគេនោះ នឹងទៅជាបុគ្គលមានប្រាជ្ញាថោកទាប ស្មើនឹងបុគ្គលថោកទាបនោះ មួយទៀត បើបុគ្គលនោះ ជាអ្នកដល់នូវវេទ ជាអ្នកប្រាជ្ញមានប្រាជ្ញាខ្ជាប់ខ្ជួន ចំពោះខ្លួនឯង ក៏គេបុគ្គលណាមួយ ជាមនុស្សល្ងង់ក្នុងពួកសមណៈ មិនមាន ៗ ពួកបុគ្គលណា សរសើរធម៌ គឺទិដ្ឋិដទៃក្រៅពីនេះ ពួកបុគ្គលនោះ ជាអ្នកមានគុណមិនបរិបូណ៌ ឈ្មោះថា ប្រទូស្ត ចំពោះផ្លូវដ៏បរិសុទ្ធ ពួកតិរ្ថិយតែងនិយាយតិះដៀលគ្នាដោយច្រើនយ៉ាងនេះឯង ព្រោះថា តិរ្ថិយទាំងនោះ ត្រេកអរស៊ប់ហើយដោយតម្រេក ក្នុងទិដ្ឋិរបស់ខ្លួន ៗ លុះពួកតិរ្ថិយ (ត្រេកអរយ៉ាងនេះហើយ) ទើបនាំគ្នានិយាយសរសើរសេចក្ដីបរិសុទ្ធិ ក្នុងធម៌ (របស់ខ្លួន) នេះតែម្យ៉ាង មិននិយាយសរសើរសេចក្ដីបរិសុទ្ធិ ក្នុងធម៌ទាំងឡាយដទៃឡើយ ពួកតិរ្ថិយ តែងចូលចិត្តដោយច្រើនយ៉ាងនេះ ហើយពោលប្រកាន់មាំ ក្នុងផ្លូវនៃទិដ្ឋិរបស់ខ្លួននោះ ៗ

សកាយនេ វាបិ ទឡ្ហំ វទានោ
កមេត្ថ ពាលោតិ បរំ ទហេយ្យ
សយមេវ សោ មេធគំ អាវហេយ្យ
បរំ វទំ ពាលមសុទ្ធិ ធម្មំ ។
វិនិច្ឆយេ ឋត្វា សយំ បមាយ
ឧទ្ធំ សោ លោកស្មឹ វិវាទមេតិ
ហិត្វាន សព្វានិ វិនិច្ឆយានិ
ន មេធគំ កុព្វតិ ជន្តុ លោកេតិ ។

ចូឡវិយូហសុត្តំ ទ្វាទសមំ ។

## តេរសមំ មហាវិយូហសុត្តំ[១]

(១០៧) យេ កេចិមេ ទិដ្ឋិបរិព្វសានា
ឥទមេវ សច្ចន្តិ វិវាទយន្តិ
សព្វេវ តេ និន្ទមន្វានយន្តិ
អថោ បសំសម្បិ លភន្តិ តត្ថ ។

---

១ ម. មហាព្យូហសុត្តំ ។

មិនត្រឹមតែប៉ុណ្ណោះឡើយ ពួកតិរ្ថិយទាំងនោះ សូម្បីតែមួយនាក់ កាលពោលប្រកាន់មាំក្នុងផ្លូវនៃទិដ្ឋិរបស់ខ្លួនហើយ មុខជាដុតកំដៅបុគ្គលដទៃថាជាមនុស្សពាល ព្រោះទិដ្ឋិរបស់ខ្លួនដូច្នេះ លុះតិរ្ថិយពោលនូវបុគ្គលដទៃថា ជាមនុស្សពាល ថាជាអ្នកមានធម៌មិនបរិសុទ្ធិហើយ គប្បីនាំមកនូវជម្លោះបំពោះខ្លួនឯង ។ តិរ្ថិយនោះ តាំងនៅក្នុងវិនិច្ឆ័យធម៌ (ដោយតណ្ហានិងទិដ្ឋិ) តាំងលទ្ធិដោយខ្លួនឯងហើយ រមែងដល់នូវការទាស់ទែងគ្នា ដ៏ក្រៃលែងលើសលុបក្នុងលោក ចំណែកសត្វ ដែលលះបង់នូវវិនិច្ឆ័យធម៌ ទាំងអស់ (ដោយអរិយមគ្គ) រមែងមិនធ្វើនូវជម្លោះ ក្នុងលោកឡើយ ។

ចប់ ចូឡវិយូហសូត្រ ទី ១២ ។

## មហាវិយូហសូត្រ ទី ១៣

(១០៧) (ព្រះពុទ្ធនិម្មិតសួរថា) សមណព្រាហ្មណ៍ណាមួយត្រាំនៅក្នុងទិដ្ឋិ (របស់ខ្លួន) តែងជជែកគ្នាថា នេះឯងជារបស់ពិត តើពួកសមណព្រាហ្មណ៍ទាំងអស់នោះ នឹងនាំមករឿយៗ នូវពាក្យនិន្ទា ឬបាននូវពាក្យសរសើរព្រោះទិដ្ឋិរបស់ខ្លួននោះដែរឬ ។

អប្បញ្ហិ ឯតំ ន អលំ សមាយ

ទុវេ វិវាទស្ស ផលានិ ព្រូមិ

ឯតម្បិ ទិស្វា ន វិវាទយេថ

ខេមាភិបស្សំ អវិវាទភូមឹ ។

យា កាចិមា សម្មុតិយោ បុថុជ្ជា

សព្វា វ ឯតា ន ឧបេតិ វិទ្វា

អនូបយោ សោ ឧបយំ កិមេយ្យ

ទិដ្ឋេ សុតេ ខន្តិមកុព្វមានោ ។

សីលុត្តមា សញ្ញមេនាហុ សុទ្ធឹ

វតំ សមាទាយ ឧបដ្ឋិតាសេ

ឥធេវ សិក្ខេម អថស្ស សុទ្ធឹ

ភវូបនីតា កុសលា វទានា ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា) ផលនៃវាទៈ គឺសេចក្ដីសរសើរនុ៎ះ មានបន្តិចបន្តួចទេ មិនគួរដើម្បីសេចក្ដីស្ងប់រម្ងាប់ (រាគៈជាដើម) បានឡើយ តថាគតពោលនូវផលនៃការជជែកគ្នា ព្រោះទិដ្ឋិមានពីរប្រការ គឺនិន្ទានិងសរសើរ ចំណែកជនជាបណ្ឌិតឃើញទោសក្នុងការជជែកគ្នានុ៎ះ ហើយឃើញច្បាស់នូវព្រះនិព្វានជាភូមិមិនទាស់ទែងគ្នាថាជាទីដ៏ក្សេមក្សាន្ត ទើបមិនទាស់ទែងគ្នា ។ ទិដ្ឋិទាំងឡាយឯណាមួយដែលកើតច្រើន អ្នកប្រាជ្ញរមែងមិនប្រកាន់នូវទិដ្ឋិទាំងនុ៎ះ បើលោកមិនមានសេចក្ដីប្រកាន់ (នូវទិដ្ឋិ) មិនធ្វើសេចក្ដីស្រឡាញ់អារម្មណ៍ដែលឃើញហើយ ឮហើយ ធ្វើម្ដេចឡើយនឹងប្រកាន់នូវអារម្មណ៍ដែលគួរប្រកាន់ ។ សមណព្រាហ្មណ៍ពួកមួយប្រកាន់ពោលថា សីលជាគុណដ៏ខ្ពង់ខ្ពស់ ហើយសំដែងនូវសេចក្ដីបរិសុទ្ធិដោយគុណត្រឹមតែការសង្រួម ជនទាំងឡាយនោះ សមាទាននូវវត្តហើយប្រកាន់មាំ (ក្នុងវត្តដែលខ្លួនសមាទាននោះ) ដោយគិតឃើញថា យើងទាំងឡាយ នឹងសិក្សានូវសេចក្ដីបរិសុទ្ធិរបស់វត្តនោះ ក្នុងទិដ្ឋិរបស់ខ្លួននេះតែម្យ៉ាង ព្រោះជនទាំងឡាយនោះមានភពគឺកម្មនាំចូលទៅជិតហើយ តែងពោលនូវខ្លួនថាជាអ្នកឈ្លាស ។

សចេ ចុតោ សីលវតាតោ ហោតិ
បវេធតី កម្ម វិរាធយិត្វា
បជប្បតី បត្ថយតី ច សុទ្ធឹ
សត្ថាវ ហីនោ បវសំ ឃរម្ហា ។
សីលព្វតំ វាបិ បហាយ សព្វំ
កម្មញ្ច សាវជ្ជនវជ្ជមេតំ
សុទ្ធឹ អសុទ្ធិន្តិ អបត្ថយានោ
វិរតោ ចរេ សន្តិមនុគ្គហាយ ។
តមូបនិស្សាយ(២) ជិគុច្ឆិតំ វា
អថ វាបិ ទិដ្ឋំ វ សុតំ មុតំ វា
ឧទ្ធំសរា សុទ្ធិមនុត្ថុនន្តិ
អវីតតណ្ហាសេ ភវាភវេសុ ។
បត្ថយមានស្ស ហិ ជប្បិតានិ
បវេធិតំ វាបិ(៣) បកប្បិតេសុ
ចុតូបបាតោ ឥធ យស្ស នត្ថិ
ស កេន វេធេយ្យ កុហិញ្ចិ ជប្បេ ។

---

១ ឱ. សីលវតំ កម្មំ ។ ២ ឱ. តបូបនិស្សាយ ។ ៣ ឱ. បវេធិតំ ចាបិ ។

បើបុគ្គលណា ឃ្លាតចាកសីលនិងវត្តហើយ បុគ្គលនោះ រមែងញាប់ញ័រព្រោះខុសចាកកម្ម បុគ្គលនោះឯងតែងចង់បានផង ប្រាថ្នាផងនូវសេចក្តីបរិសុទ្ធិ ដូចបុគ្គលកាលព្រាត់ប្រាសចាកផ្ទះ ហើយសាបសូន្យចាកពួក ។ មួយទៀត អរិយសាវ័ក លះបង់សីលនិងវត្ត (ដ៏បរិសុទ្ធិ) ទាំងអស់ផង កម្មមានទោសផង មិនមានទោសទុះផង ចេញហើយ មិនប្រាថ្នានូវសេចក្តីបរិសុទ្ធិ និងសេចក្តីមិនបរិសុទ្ធិផង ឈ្មោះថាជាអ្នកវៀរស្រឡះ ព្រោះមិនប្រកាន់នូវទិដ្ឋិ ។ មានសមណព្រាហ្មណ៍ពួកមួយ តែងអាស្រ័យទិដ្ឋិនោះដែលគួរខ្ពើម មួយទៀត តែងអាស្រ័យទិដ្ឋិ (សេចក្តីយល់ឃើញ) ថា បរិសុទ្ធិព្រោះឃើញ បរិសុទ្ធិព្រោះស្តាប់ បរិសុទ្ធិព្រោះពាល់ត្រូវ ជាខ្ទុំសរសើរ ជាអ្នកមានតណ្ហា ក្នុងភពតូចភពធំ មិនទាន់ទៅប្រាស រមែងពោលនូវសេចក្តីបរិសុទ្ធិ ។ ជប្បនៈគឺតណ្ហាទាំងឡាយ ក៏កើតឡើងដល់បុគ្គលអ្នកប្រាថ្នា ឬសេចក្តីរន្ធត់ញាប់ញ័រ ក៏កើតឡើងក្នុងធម៌ទាំងឡាយ ដែលខ្លួនកំណត់ហើយ ការច្យុតិនិងការកើតឡើង របស់បុគ្គលណា មិនមានក្នុងលោកនេះ បុគ្គលនោះគប្បីញាប់ញ័រដោយហេតុអ្វី គប្បីប្រាថ្នាក្នុងអ្វីទៀត ។

យមាហុ ធម្មំ បរមន្តិ ឯកេ
តមេវ ហីនន្តិ បនាហុ អញ្ញេ
សច្ចោ នុ វាទោ កតមោ ឥមេសំ
សព្វេវ ហីមេ កុសលា វទានា ។
សកញ្ហិ ធម្មំ បរិបុណ្ណមាហុ
អញ្ញស្ស ធម្មំ បន ហីនមាហុ(១)
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
សកំ សកំ សម្មតិមាហុ សច្ចំ ។
បរស្ស ចេ វម្ភយិតេន ហីនោ
ន កោចិ ធម្មេសុ វិសេសិ អស្ស
បុថូ ហិ អញ្ញស្ស វទន្តិ ធម្មំ
និហីនតោ សម្ហិ ទឡ្ហំ វទានា ។
សទ្ធម្មបូជា ច បនា តថេវ(២)
យថា បសំសន្តិ សកាយនានិ

---

១ ម. តមេវ ហីនន្តិ បនាហុ អញ្ញេ ។ ២ ឱ. សទ្ធម្មបូជាបិ នេសំ តថេវ ។

(ព្រះពុទ្ធនិម្មិតសួរថា) សមណព្រាហ្មណ៍ពួកមួយ បាននិយាយធម៌ណា ថាជាធម៌ដ៏ឧត្តម សមណព្រាហ្មណ៍ពួកឯទៀត បាននិយាយធម៌នោះ ថាជាធម៌ថោកទាបវិញ ចុះពាក្យរបស់សមណព្រាហ្មណ៍ទាំងពីរពួក តើពាក្យណាជាពាក្យពិតត្រង់ ព្រោះសមណព្រាហ្មណ៍ទាំងអស់នេះ តែងពោលលើកខ្លួនថាជាអ្នកឈ្លាស ។ (ព្រះសម្ពុទ្ធត្រាស់ថា) សមណព្រាហ្មណ៍ពួកមួយ បានពោលធម៌របស់ខ្លួន ថាជាធម៌បរិបូណ៌ (ល្អពេញទី) ពោលធម៌របស់ជនដទៃ ថាជាធម៌ថោកទាប សមណព្រាហ្មណ៍ទាំងឡាយប្រកាន់យ៉ាងនេះ រមែងបង្កជម្លោះ ឲ្យកើតឡើង បានសរសើរទិដ្ឋិរបស់ខ្លួនៗ ថាជាធម៌ពិត ។ បើបុគ្គលនោះនឹងទៅជាអ្នកថោកទាប ព្រោះដំទៀលរបស់បុគ្គលដទៃ មិនមានអ្នកណាមួយ ដែលវិសេសក្នុងធម៌ទាំងឡាយបានទេ ព្រោះថា បុគ្គលច្រើននាក់ ជាអ្នកប្រកាន់មាំក្នុងធម៌របស់ខ្លួន តែងតិះដៀលធម៌ របស់ជនដទៃ ថាជាធម៌ថោកទាប ។ ជនទាំងឡាយ តែងសរសើរនូវផ្លូវជាគ្រឿងប្រព្រឹត្តទៅ នៃសេចក្តីប្រតិបត្តិ គឺធម៌របស់ខ្លួន យ៉ាងណា ការបូជាធម៌របស់ខ្លួន ក៏យ៉ាងនោះ

សព្វេវ វាទា តថិវា(១) ភវេយ្យុំ
សុទ្ធី ហិ នេសំ បច្ចត្តមេវ ។
ន ព្រាហ្មណស្ស បរនេយ្យមត្ថិ
ធម្មេសុ និច្ឆេយ្យ សមុគ្គហីតំ
តស្មា វិវាទានិ ឧបាតិវត្តោ
ន ហិ សេដ្ឋតោ បស្សតិ ធម្មមញ្ញំ ។
ជានាមិ បស្សាមិ តថេវ ឯតំ
ទិដ្ឋិយា ឯកេ បច្ចេន្តិ សុទ្ធឹ
អទ្ទក្ខិ ចេ កិញ្ហិ តុមស្ស តេន
អតិសិត្វា អញ្ញេន វទន្តិ សុទ្ធឹ ។
បស្សំ នរោ ទក្ខតិ នាមរូបំ
ទិស្វាន វា ញស្សតិ តានិ មេវ(២)
កាមំ ពហុំ បស្សតុ អប្បកំ វា
ន ហិ តេន សុទ្ធឹ កុសលា វទន្តិ ។

---

១ ឱ. សព្វេវាទា តថិយា ។ ម. សព្វេវ វាទា តថិយា ។ ២ ឱ. ម. តានិមេវ ។

(កាលបើយ៉ាងនេះ) ពាក្យទាំងពួង គប្បីជារបស់ពិតមែន សេចក្តីបរិសុទ្ធិ ទឹងមានចំពោះខ្លួននៃសមណព្រាហ្មណ៍ទាំងនោះពិត ៗ ញាណដែលបុគ្គលដទៃគប្បីដឹកនាំ ទឹងសេចក្តីប្រកាន់ព្រោះវិនិច្ឆ័យ ក្នុងទិដ្ឋិធម៌ទាំងឡាយ មិនមាន ដល់ខីណាសវព្រាហ្មណ៍ ព្រោះហេតុនោះ ខីណាសវព្រាហ្មណ៍នោះ ទើបចូងពាក្យវិវាទទាំងឡាយបាន ទាំងមិនយល់ឃើញធម៌ដទៃថា ប្រសើរទេ ៗ សមណព្រាហ្មណ៍ពួកមួយពោលកាងបរិសុទ្ធិ ដោយទិដ្ឋិ ថាខ្ញុំដឹង ខ្ញុំឃើញ របស់នុ៎ះពិតមែន បើទុកជាមានសមណព្រាហ្មណ៍ខ្លះ បានឃើញ ដោយបរចិត្តញ្ញាណជាដើម ទឹងមានប្រយោជន៍អ្វី ដោយការឃើញរបស់សមណព្រាហ្មណ៍នោះ ( បានជា ) ពួកសមណព្រាហ្មណ៍ខ្លះ គន្លង (នូវអរិយមគ្គ) ហើយសំដែងនូវសេចក្តីបរិសុទ្ធិ ដោយឧបាយដទៃវិញ ៗ នរជនកាលឃើញ រមែងឃើញតែនាមរូប លុះឃើញហើយរមែងដឹងនូវនាមរូបនោះប៉ុណ្ណោះ កាលបើឃើញដោយវិបល្លាសសញ្ញាយ៉ាងនេះ ចង់ឃើញច្រើន ឬតិចក៏ដោយ អ្នកប្រាជ្ញទាំងឡាយមិនពោលនូវសេចក្តីបរិសុទ្ធិ ដោយការឃើញត្រឹមប៉ុណ្ណោះទេ ៗ

និវិស្សវាទី ន ហិ សុទ្ធិនាយោ
បកប្បិតំ(១) ទិដ្ឋិ បុរេក្ខរានោ
យន្និស្សិតោ តត្ថ សុភំវទានោ
សុទ្ធឹវទោ តត្ថ តថទ្ទសា សោ ។

ន ព្រាហ្មណោ កប្បមុបេតិ សង្ខំ
ន ទិដ្ឋិសារី នបិ ញាណពន្ធុ
ញត្វា ច សោ សម្មុតិយោ បុថុជ្ជា
ឧបេក្ខតិ ឧគ្គហណន្តិ មញ្ញេ ។

វិសជ្ជ គន្ថានិ មុនីធ លោកេ
វិវាទជាតេសុ ន វគ្គសារី
សន្តោ អសន្តេសុ ឧបេក្ខកោ សោ
អនុគ្គហោ ឧគ្គហណន្តិ មញ្ញេ ។

---

១ ម· បកប្បិតោ ។

បុគ្គលអ្នកពោលប្រកាន់មាំ មិនងាយគេប្រដៅបានទេ បុគ្គលអ្នកធ្វើទិដ្ឋិដែលខ្លួនកំណត់ហើយ ឲ្យជាប្រធាន អាស្រ័យនូវសាស្តាណា រមែងជាអ្នកពោលសរសើរថា ល្អក្នុងសាស្តានោះ បុគ្គលនោះជាអ្នកពោលនូវសេចក្តីបរិសុទ្ធិ បានឃើញថាជាធម៌ពិត ក្នុងវាទៈរបស់សាស្តានោះ ៗ ខីណាសវព្រាហ្មណ៍ ដឹងច្បាស់ (នូវសង្ខារធម៌ទាំងពួង) រមែងមិនប្រកាន់នូវការកំណត់ ដោយតណ្ហានិងទិដ្ឋិ ជាអ្នកមិនប្រព្រឹត្តទៅក្នុងទិដ្ឋិ ទាំងមិនមានផៅពន្ធ គឺតណ្ហានិងទិដ្ឋិ ដោយមិច្ឆាញាណទេ មួយទៀត ខីណាសវព្រាហ្មណ៍នោះ បានដឹងហើយនូវទិដ្ឋិទាំងឡាយ ដែលកើតហើយអំពីជនច្រើននាក់ ក៏ព្រងើយកន្តើយ គឺមិនប្រកាន់មាំដោយអំណាចតណ្ហានិងទិដ្ឋិ ចំណែកជនទាំងឡាយដទៃ រមែងប្រកាន់ស្អិត ៗ អ្នកប្រាជ្ញក្នុងលោកនេះ លះបង់នូវកិលេសគ្រឿងចងក្រង កាលជនទាំងឡាយ មានការទាស់ទែងកើតហើយ លោកជាអ្នកមិនប្រព្រឹត្តជាពួក កាលជនទាំងឡាយមិនស្ងប់ លោកជាអ្នកស្ងប់ លោកជាអ្នកព្រងើយកន្តើយ មិនប្រកាន់ ចំណែកជនទាំងឡាយដទៃ រមែងប្រកាន់ស្អិត ៗ

បុព្វាសវេ ហិត្វា នវេ អកុព្វំ
ន ឆន្ទគូ នោបិ(១) និវិស្សវាទោ(២)
ស វិប្បមុត្តោ ទិដ្ឋិគតេហិ ធីរោ
ន លិម្បតិ លោកេ អនត្តគរហី ។
ស សព្វធម្មេសុ វិសេនិភូតោ
យំ កិញ្ចិ ទិដ្ឋំ វ សុតំ មុតំ វា
ស បន្នភារោ មុនិ វិប្បមុត្តោ
ន កប្បិយោ នូបរតោ ន បត្ថិយោតិ ភគវាតិ ។

មហាវិយូហសុត្តំ តេរសមំ ។

## ចុទ្ទសមំ តុវដកសុត្តំ

(១០៨) បុច្ឆាមិ តំ អាទិច្ចពន្ធុំ
វិវេកំ សន្តិបទញ្ច មហេសឹ
កថំ ទិស្វា និព្វាតិ ភិក្ខុ
អនុបាទិយានោ លោកស្មិំ កិញ្ចិ ។

---

១ ឱ. នោបិ ។ ២ ម. និវិស្សវាទី ។

ទីណាសព្វព្រាហ្មណ៍ លះបង់នូវអាសវៈមុន មិនធ្វើអាសវៈថ្មី ជាអ្នកមិនលុះក្នុងឆន្ទាគតិ (ជាដើម) ទាំងមិនបរោហាតាមសេចក្តីប្រកាន់ស្អិត ទីណាសព្វព្រាហ្មណ៍នោះ ជាអ្នកប្រាជ្ញ រួចស្រឡះចាកទិដ្ឋិទាំងឡាយ ជាអ្នកមិនតិះដៀលខ្លួនឯង មិនជាប់នៅក្នុងលោក ។ ទីណាសព្វព្រាហ្មណ៍នោះ លោកជាអ្នកមិនមានមារសេនា ក្នុងធម៌ទាំងពួង មិនមានមារសេនា ក្នុងអារម្មណ៍ណាមួយ ដែលឃើញហើយ ឮហើយ ប៉ះពាល់ហើយ ទីណាសព្វព្រាហ្មណ៍នោះ ជាអ្នកប្រាជ្ញ មានភារៈដាក់ចុះហើយ រួចស្រឡះចាកកគាទក្កិលេស មិនមានគ្រឿងកំណត់ដោយតណ្ហានិងទិដ្ឋិ មិនត្រេកអរ មិនមានកិលេសជាតិគ្រឿងប្រាថ្នាឡើយ ។

ចប់ មហាវិយូហសូត្រ ទី ១៣ ។

## តុវដកសូត្រ ទី ១៤

(១០៨) (ព្រះពុទ្ធនិម្មិតសួរថា) ខ្ញុំសូមសួរ នូវសេចក្តីស្ងាត់ផង នូវចំណែកនៃសេចក្តីស្ងប់ផង នឹងព្រះអង្គ ជាផៅពង្សនៃព្រះអាទិត្យ អ្នកស្វែងរកគុណដ៏ធំ ចុះភិក្ខុឃើញ ដោយប្រការដូចម្តេច មិនប្រកាន់មាំនូវអ្វីមួយក្នុងលោក ទើបរលត់កិលេសបាន ។

មូលំ បបញ្ចសង្ខាយា(១) [ ឥតិ ភគវា ]
មន្តា អស្មីតិ សព្វមុបរុន្ធេ
យា កាចិ តណ្ហា អជ្ឈត្តំ
តាសំ វិនយា សទា សតោ សិក្ខេ ។

យំ កិញ្ចិ ធម្មំ អភិជញ្ញា
អជ្ឈត្តំ អថ វាបិ ពហិទ្ធា
ន តេន ថាមំ(២) កុព្វេថ
ន ហិ សា និព្វុតិ សតំ វុត្តា ។

សេយ្យោ ន តេន មញ្ញេយ្យ
នីចេយ្យោ អថ វាបិ សរិក្ខោ(៣)
ផុដ្ឋោ អនេករូបេហិ
នាតុមានំ(៤) វិកប្បយំ តិដ្ឋេ ។

អជ្ឈត្តមេវ ឧបសមេ
ន អញ្ញតោ ភិក្ខុ សន្តិមេសេយ្យ

---

១ ម. បបញ្ចសង្ខាភ ។ ២ ម. មានំ ។ ៣ ម. សរិក្ខកោ ។ ៤ ម. នាតិមានំ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់តបថា) ភិក្ខុគប្បីបំបាត់នូវឫសនៃបបញ្ចសញ្ញា (ធម៌ជាគ្រឿងធ្វើសត្វឲ្យយឺតយូរគឺតណ្ហាទិដ្ឋិ)ផង នូវអស្មិមានះទាំងពួងផង ដោយប្រាជ្ញា តណ្ហាទាំងឡាយណាមួយ មានខាងក្នុងសន្តានសត្វ ភិក្ខុជាអ្នកមានស្មារតីគ្រប់ពេល គប្បីសិក្សាដើម្បីកំចាត់បង់តណ្ហាទាំងនោះចេញ ។ ភិក្ខុគប្បីដឹងនូវគុណធម៌ណាមួយ ជាខាងក្នុង ឬខាងក្រៅ មិនគប្បីធ្វើនូវកម្លាំង (ការលើកដំកើង) ដោយគុណធម៌នោះ ព្រោះការរំលត់នោះ សប្បុរសទាំងឡាយ មិនបានប្រកាសឡើយ ។ ភិក្ខុមិនគប្បីសំគាល់ថា អញជាបុគ្គលប្រសើរជាងគេ អញជាបុគ្គលថោកទាបជាងគេ ឬថា ជាបុគ្គលស្មើ ៗ នឹងគេ ដោយសារគុណធម៌នោះឡើយ ភិក្ខុប្រកបដោយគុណធម៌ មានសភាពច្រើនយ៉ាង មិនគប្បីតាំងខ្លួនតំកើងខ្លួនទេ ។ ភិក្ខុគប្បីរម្ងាប់ (ពពួកកិលេស) ក្នុងសន្តាន ភិក្ខុមិនគប្បីស្វែងរកសេចក្ដីស្ងប់ ដោយឧបាយដទៃទេ

អជ្ឈត្តំ ឧបសន្តស្ស
នត្ថិ អត្តា កុតោ និរត្តំ វា(១) ។
មជ្ឈេ យថា សមុទ្ទស្ស
ឩមិ នោ ជាយតិ ឋិតោ ហោតិ
ឯវំ ឋិតោ អនេជស្ស
ឧស្សទំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ ។
អកិត្តយិ វិវដចក្ខុ
សក្ខិធម្មំ បរិស្សយវិនយំ
បដិបទំ វទេហិ ភទ្ទន្តេ
បាតិមោក្ខំ អថ វាបិ សមាធឹ ។
ចក្ខូហិ នេវ លោលស្ស
គាមកថាយ អាវរយេ សោតំ
រសេ ច នានុគិជ្ឈេយ្យ
ន ច មមាយេថ កិញ្ចិ លោកស្មឹ ។
ផស្សេន យទា ផុដ្ឋស្ស

---

១ ម. និរត្តំ វា ។

កាលបើលោករម្ងាប់ នូវរាគាទិកិលេស ក្នុងសន្តានហើយ សេចក្តី
យល់ឃើញថា ខ្លួនគឺសស្សតទិដ្ឋិ រមែងមិនមាន សេចក្តីយល់
ឃើញថា មិនមែនខ្លួនគឺឧច្ឆេទទិដ្ឋិ នឹងមានមកអំពីណា ៗ រលក
រមែងមិនកើតឡើងត្រង់ជំរៅពាក់កណ្តាលសមុទ្ទ ទឹកត្រង់កណ្តាល
នោះ រមែងតាំងនៅនឹង មានឧបមា យ៉ាងណាមិញ មានឧបមេយ្យ
ដូចភិក្ខុអ្នកតាំងនៅនឹងនួន ជាអ្នកមិនមានតណ្ហាជាគ្រឿងញាប់ញ័រ
ដូច្នោះឯង មិនគប្បីធ្វើកិលេសឲ្យពុះពោរក្នុងទីណាមួយ ៗ (ព្រះពុទ្ធ
និម្មិតសួរថា) ព្រះអង្គមានចក្ខុ បើកហើយ បានសំដែងធម៌
ចំពោះភ្នែកគឺធម៌ ដែលព្រះអង្គឃើញច្បាស់ហើយ ដោយព្រះអង្គឯង
ជាធម៌កំចាត់ នូវសេចក្តីអន្តរាយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះ
អង្គសំដែង នូវបដិបទាផង នូវបាតិមោក្ខសីលផង នូវសមាធិចិត្ត
ផង ៗ (ព្រះមានព្រះភាគត្រាស់ថា) ភិក្ខុគប្បីជាអ្នកមិនរឡេម
រឡាមដោយចក្ខុទាំងឡាយផង គប្បីបិទខ្ទប់នូវត្រចៀកក្នុងពាក្យនៃ
អ្នកស្រុកផង មិនគប្បីជាប់នៅក្នុងរសផង មិនគប្បីប្រកាន់នូវរបស់
ណាមួយក្នុងលោកផង ៗ កាលណាភិក្ខុត្រូវផស្សៈប៉ះពាល់ហើយ

បរិទេវំ ភិក្ខុ ន ការយេ
កុហិញ្ចិ ភវញ្ច នាភិជប្បេយ្យ
ភេរវេសុ ច ន សម្បវេធេយ្យ ។
អន្នានមថោ បានានំ
ខាទនីយានំ អថោបិ វត្ថានំ
លទ្ធា ន សន្និធឹ កយិរា
ន ច បរិត្តសេ តានិ អលភមានោ ។
ឈាយី ន បាទលោលស្ស
វិរមេ កុក្កុច្ចា(១) នប្បមជ្ជេយ្យ
អថ ក អាសនេសុ សយនេសុ(២)
អប្បសទ្ទេសុ ភិក្ខុ វិហរេយ្យ ។
និទ្ទំ ពហុលំ ន(៣) ការយេ
ជាគរិយំ ភជេយ្យ អាតាបី
តន្ទឹ មាយំ ហស្សំ ខិឌ្ឌំ
មេថុនំ វិប្បជហេ សវិភូសំ ។

---

១ ឱ. អ. កុក្កុច្ចំ ។ ២ ឱ. អថ អាសនេសុ សាយនេសុ ។ ម. អថាសនេសុ វិវិត្តេសុ ។
៣ ឱ. និទ្ទំ ន ពហុលី ។

ភិក្ខុមិនគប្បីធ្វើ នូវសេចក្តីខ្ជឹកខ្ជិលផង មិនគប្បីប្រាថ្នា នូវភពណាមួយផង មិនគប្បីញាប់ញ័រក្នុងសត្វសាហាវដែលគួរស្ញប់ស្ញែងផង ៗ មួយទៀត ភិក្ខុបើបាននូវបាយ ទឹក ខាទនីយៈ ឬសំពត់ទាំងឡាយហើយ មិនគប្បីធ្វើនូវសន្និធិ (ការសន្សំទុក) ឡើយ កាលបើមិនបានវត្ថុទាំងនោះទេ ក៏មិនគប្បីអន្ទះសារ ៗ ភិក្ខុគប្បីជាអ្នកអភិរម្យក្នុងឈាន គប្បីជាអ្នកមិនពើសដើង គប្បីវៀរចាកសេចក្តីពើស (មានពើសដៃជាដើម) មិនគប្បីធ្វេសប្រហែស មួយទៀត គប្បីនៅក្នុងទីអង្គុយ ទីដេក ដែលមានសំឡេងតិច ៗ ភិក្ខុមានសេចក្តីព្យាយាម មិនគប្បីធ្វើការដេកលក់ឲ្យច្រើនទេ គប្បីគប់រកនូវសេចក្តីភ្ញាក់រឭក គប្បីលះបង់សេចក្តីខ្ជិលច្រអូស មាយា ល្បែងសើច ល្បែងមេថុន ព្រមទាំងការស្អិតស្អាងខ្លួនចេញ ៗ

អាថព្វណំ សុបិនំ លក្ខណំ
នោ វិទហេ អថោបិ នក្ខត្តំ
វិរុតញ្ច គព្ភករណំ
តិកិច្ឆំ មាមកោ ន សេវេយ្យ ។

និន្ទាយ នប្បវេធេយ្យ
ន ឧណ្ណមេយ្យ បសំសិតោ ភិក្ខុ
លោភំ សហ មច្ឆរិយេន
កោធំ បេសុណិយញ្ច បនុទេយ្យ ។

កយវិក្កយេ ន តិដ្ឋេយ្យ
ឧបវាទំ ភិក្ខុ ន ករេយ្យ កុហិញ្ចិ
គាមេ ច នាភិសជ្ជេយ្យ
លាភកម្យា ជនំ ន លបយេយ្យ[១] ។

ន ច កត្ថិតា សិយា ភិក្ខុ
ន ច វាចំ បយុត្តំ ភាសេយ្យ
បាគព្ភិយំ ន សិក្ខេយ្យ
កថំ វិគ្គាហិកំ ន កថេយ្យ ។

---

១ ឱ. ន លាបយេយ្យ ។ ម. ន លបេយ្យ ។

ភិក្ខុអ្នកកាន់តាមព្រះរតនត្រ័យ មិនគប្បីប្រកបអាថព្វណមន្ត (មន្តសម្រាប់ឲ្យឧបទ្រវៈកើតឡើងក្នុងបច្ចាមិត្ត) មន្តសម្រាប់ទាយសុបិន មន្តសម្រាប់ទាយលក្ខណៈ មន្តសម្រាប់សំដែងឫក្សមង្គល មិនគប្បីសេពគប់មន្តសម្រាប់ទាយសម្រែកសត្វផង ថ្នាំសម្រាប់ធ្វើគភ៌ឲ្យតាំងនៅផង ការរក្សារោគផង ។ ភិក្ខុមិនគប្បីញាប់ញ័រនឹងពាក្យនិន្ទា បើមានគេសរសើរ ក៏មិនគប្បីឡើងដោរផង គប្បីបន្ទោបង់លោភៈ មច្ឆរិយៈ សេចក្តីក្រេវក្រោធនឹងពាក្យញុះញង់ ។ ភិក្ខុមិនគប្បីតាំងនៅក្នុងការលក់ចេញទិញចូល មិនគប្បីធ្វើការពោលតិះដៀលក្នុងទីណាមួយ មិនគប្បីជាប់ចិត្តក្នុងស្រុក មិនគប្បីបបោនឹងជន ព្រោះប្រាថ្នាលាភ ។ មួយទៀត ភិក្ខុមិនគប្បីពោលវាចាលើកខ្លួន មិនគប្បីពោលវាចាផ្សេងផ្សំ មិនគប្បីសិក្សានូវសេចក្តីឃ្លើសឃ្លងការឈ្លោះវាចាចិត្ត មិនគប្បីពោលពាក្យប្រណាំងប្រជែង ។

មោសវជ្ជេ ន និយ្យេថ

សម្បជានោ សឋានិ ន កយិរា

អថ ជីវិតេន បញ្ញាយ

សីលព្វតេន នាញ្ញមតិមញ្ញេ ។

សុត្វា រុសិតោ ពហុំ វាចំ

សមណានំ វា បុថុវចនានំ

ផរុសេន នប្បដិវជ្ជា

ន ហិ សន្តោ បដិសេនិករោន្តិ ។

ឯតញ្ច ធម្មមញ្ញាយ

វិចិនំ ភិក្ខុ សទា សតោ សិក្ខេ

សន្តីតិ និព្វុតឹ ញត្វា

សាសនេ គោតមស្ស នប្បមជ្ជេយ្យ ។

អភិភូ ហិ សោ អនភិភូតោ

សក្ខិធម្មំ អនីតិហមទស្សី

---

១ ម. បុថុជ្ជនានំ ។

ភិក្ខុមិនគប្បីដឹកនាំ ក្នុងពាក្យមុសាវាទ មិនគប្បីធ្វើការអួតអាងទាំង ដឹងខ្លួន មួយទៀត មិនគប្បីមើលងាយអ្នកដទៃ ដោយអាជីវៈ (ការចិញ្ចឹមជីវិត) នឹងបញ្ញា នឹងសីលវ័ត ។ ភិក្ខុកាលបើបានឮពាក្យ ( មិនជាទីគាប់ចិត្ត ) ដ៏ច្រើន របស់សមណៈ ទាំងឡាយ ឬរបស់បុថុជ្ជនទាំងឡាយ មិនគប្បីប្រទូស្តទៅរក មិនគប្បីពោលតប ដោយពាក្យអាក្រក់ ព្រោះថា លោកអ្នកស្ងប់រម្ងាប់ទាំងឡាយ រមែងមិនធ្វើការឈ្លោះតបតឡើយ ។ ភិក្ខុ កាលបានដឹង បានពិចារណាធម៌នុ៎ះ គប្បីជាអ្នកត្រេកសិក្សាសព្វកាល បើបានដឹងសេចក្តីរលត់ពកគាទិក្កិលេស ថាជាសេចក្តីស្ងប់ហើយ មិនគប្បីប្រហែសធ្វេស ក្នុងសាសនានៃព្រះគោតមឡើយ ។ ភិក្ខុនោះជាអ្នកគ្របសង្កត់រូបជាដើម ជាអ្នកដែលរូបជាដើម គ្របសង្កត់មិនបាន ជាអ្នកឃើញធម៌ ចំពោះខ្លួនឯង មិនកាន់គេថា ដូច្នេះៗ

តស្មា ហិ តស្ស ភគវតោ សាសនេ

អប្បមត្តោ សទា នមស្សមនុសិក្ខេតិ ភគវាតិ ។

តុវដកសុត្តំ ចុទ្ទសមំ ។

## បណ្ណរសមំ អត្តទណ្ឌសុត្តំ

(៦០៩) អត្តទណ្ឌា ភយំ ជាតំ ជនំ បស្សថ មេធគំ  
សំវេគំ កិត្តយិស្សាមិ យថា សំវិជិតំ មយា ។  
ផន្ទមានំ បជំ ទិស្វា មច្ឆេ អប្បោទកេ យថា  
អញ្ញមញ្ញេហិ ព្យារុទ្ធេ ទិស្វា មំ ភយមាសិវ៍(១) ។  
សមន្តមសារោ លោកោ ទិសា សព្វា សមេរិតា  
ឥច្ឆំ ភវនមត្តនោ នាទ្ទសាសី(២) អនោសិតំ  
ឱសានេ ត្វេវ ព្យារុទ្ធេ ទិស្វា មេ អរតី អហុ

---

១ ឱ. ម. ភយមាវិសិ ។ ២ ម. នាទ្ទសាសិំ ។

ព្រោះហេតុនោះ ភិក្ខុគប្បីជាអ្នកមិនប្រហែស គប្បីនមស្ការសិក្ខា ក្នុងសាសនានៃព្រះមានព្រះភាគនោះ សព្វៗ កាល ។

ចប់ តុវដកសូត្រ ទី ១៤ ។

## អត្តទណ្ឌសូត្រ ទី ១៥

(១០៩) (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ភ័យកើតមកពីអាជ្ញារបស់ខ្លួន (សេចក្តីប្រព្រឹត្តកាយអាក្រក់របស់ខ្លួន) អ្នកទាំងឡាយ ចូរមើលជនអ្នកទាស់ទែងគ្នា តថាគត (កាលនៅជាពោធិសត្វ) បានតក់ស្លុតហើយ យ៉ាងណា តថាគតនឹងសំដែងនូវសេចក្តីតក់ស្លុត យ៉ាងនោះ (ដល់អ្នកទាំងឡាយ) ។ ភ័យមកកាន់តថាគត ព្រោះឃើញនូវពពួកសត្វ កំពុងញាប់ញ័រ (ដោយតណ្ហាជាដើម) ដូចពពួកមច្ឆជាតិ ក្នុងទឹកមានទឹកតិច ព្រោះឃើញសត្វលោកបៀតបៀនគ្នានឹងគ្នា ។ លោកមិនមានខ្លឹមសារ ដោយជុំវិញទិសទាំងពួង រមែងញាប់ញ័រ តថាគត កាលប្រាថ្នានូវភព (ជាទីពឹង) របស់ខ្លួន ក៏មិនបានឃើញភពណាមួយ ដែលជរាធម៌ជាដើម ជះជាន់មិនបាន សេចក្តីមិនរីករាយ បានកើតមាន ដល់តថាគតហើយ ព្រោះបានឃើញសត្វទាំងឡាយ ត្រូវជរាធម៌ជាដើម បៀតបៀនហើយ ក្នុងកាលជាទីបំផុត

អវេច្ច សល្លមទ្ទក្ខឹ(១) ទុទ្ទសំ ហទយនិស្សិតំ ។
យេន សល្លេន ឱតិណ្ណោ ទិសា សព្វា វិធាវតិ
តមេវ សល្លំ អព្វុយ្ហ ន ធាវតិ ន សីទតិ ។
តត្ថ សិក្ខានុកីយន្តិ
(យានិ លោកេ គធិតានិ) ន តេសុ បសុតោ សិយា
និព្វិជ្ឈ(២) សព្វសោ កាមេ សិក្ខេ និព្វានមត្តនោ ។
សច្ចោ សិយា អប្បគព្ភោ អមាយោ រិត្តបេសុណោ
អក្កោធនោ លោភបាបំ វេវិច្ឆំ វិតរេ មុនិ ។
និទ្ទំ តន្ទឹ សហេ ថីនំ បមាទេន ន សំវសេ
អតិមានេ ន តិដ្ឋេយ្យ និព្វានមនសោ នរោ ។

---

១ ម. សល្លមទ្ទក្ខិ ។ ២ ឱ. ម. និព្វិជ្ឈ ។

តពីនោះមក តថាគតបានឃើញសរ ដែលគេឃើញបានដោយកម្រ អាស្រ័យនៅក្នុងហឫទ័យ ក្នុងសត្វទាំងឡាយនោះ ។ សត្វលោក ដែលសរដោតជាប់ហើយ រមែងស្ទុះទៅកាន់ទិសផ្សេងៗ បុគ្គលជាបណ្ឌិត ដកសរនោះបាន ទើបមិនស្ទុះទៅ មិនលិចចុះ ។ (អារម្មណ៍ជាទីស្រឡាញ់ គឺ បញ្ចកាមគុណណា មានក្នុងលោក) ប្រជុំជន តែងសំដែងនូវការសិក្សាជាគ្រឿងសិក្សា (មានការសិក្សាដំរីជាដើម) ដើម្បីឲ្យបានអារម្មណ៍ជាទីស្រឡាញ់នោះ បណ្ឌិតមិនគួរខ្វល់ខ្វាយក្នុងបញ្ចកាមគុណ ឬក្នុងកិច្ចសិក្សានោះឡើយ គប្បីនឿយណាយ ក្នុងកាមារម្មណ៍ ដោយប្រការទាំងពួង គប្បីសិក្សានូវព្រះនិព្វាន បម្រុងខ្លួន ។ បុគ្គលជាអ្នកប្រាជ្ញ គប្បីជាអ្នកមានសច្ចៈ(១) ជាបុគ្គលមិនឃ្លើសឃ្លង មិនមានមាយា លះបង់ពាក្យញុះញង់ មិនក្រេវក្រោធ ធ្លងឲ្យរួចនូវលោភៈដ៏លាមក និងមច្ឆរិយៈ ។ នរជនមានចិត្តឱនទៅរកព្រះនិព្វាន គប្បីគ្របសង្កត់នូវការដេកលក់ សេចក្តីខ្ជិលច្រអូស ការរួញរា មិនគប្បីជំអក់នៅដោយសេចក្តីប្រហែសធ្វេស មិនគប្បីតាំងខ្លួនក្នុងមានះដ៏ក្រៃលែង ។

---

១ សច្ចៈ ៣ យ៉ាងគឺ វាចាសច្ចៈ ញាណសច្ចៈ មគ្គសច្ចៈ ។ អដ្ឋកថា ។

មោសវជ្ជេ ន និយ្យេថ    រូបេ ស្នេហំ ន កុព្វយេ
មានញ្ច បរិជានេយ្យ    សាហសា វិរតោ ចរេ ។

បុរាណំ នាភិនន្ទេយ្យ    នវេ ខន្តិមកុព្វយេ
ហិយ្យមានេ ន សោចេយ្យ អាកាសំ ន សិតោ សិយា ។

គេធំ ព្រូមិ មហោឃោតិ    អាជវំ ព្រូមិ ជប្បនំ
អារម្មណំ បកប្បនំ(១)    កាមបង្កោ ទុរច្ចយោ ។

សច្ចា អវោក្កម្ម មុនិ    ថលេ តិដ្ឋតិ ព្រាហ្មណោ
សព្វសោ បដិនិស្សជ្ជ    ស វេ សន្តោតិ វុច្ចតិ ។

ស វេ វិទ្វា ស វេទគូ    ញត្វា ធម្មំ អនិស្សិតោ

---

១ កប្បនំ អដ្ឋកថា ។

បុគ្គលអ្នកបង្អោនចិត្តទៅរកព្រះនិព្វាន មិនគប្បីដឹកនាំ ក្នុងពាក្យមុសាវាទ មិនគប្បីធ្វើសេចក្តីស្នេហាក្នុងរូប ត្រូវកំណត់ដឹងនូវមានះ ហើយគប្បីវៀរចេញចាកអំពើដ៏រួសរាន់ ។ មិនគប្បីស្រើបស្រាល ទៅរកបញ្ចក្ខន្ធ ដែលជារបស់ចាស់គឺជាអតីត មិនគប្បីធ្វើសេចក្តី ពេញចិត្តនឹងបញ្ចក្ខន្ធ ដែលជារបស់ថ្មីគឺជាបច្ចុប្បន្ន មិនត្រូវសោក ស្តាយនឹងបញ្ចក្ខន្ធ ដែលសាបរលាបទៅហើយ មិនត្រូវជាប់ស្អិត នៅក្នុងតណ្ហា ។ តថាគតពោលនូវសេចក្តីជាប់ចិត្ត គឺតណ្ហា ថា ជាអន្លង់ធំ តថាគតពោលនូវសេចក្តីជក់ចិត្ត គឺតណ្ហា ថាជាគ្រឿង លឿនទៅនៃចិត្ត ថាជាគ្រឿងជាប់ញ៉ាមនៅនៃចិត្ត ថាជាអា-រម្មណ៍នៃចិត្ត ថាជាគ្រឿងត្រិះរិះ (ព្រោះ) កាមតណ្ហាដូចជាភក់ សត្វទាំងឡាយ អាចឆ្លងបានដោយលំបាក ។ អ្នកប្រាជ្ញ ជា ព្រាហ្មណ៍ មិនគេចចេញចាកសច្ចៈ រមែងតាំងនៅលើទីទួលគឺព្រះ និព្វាន តថាគតហៅបុគ្គលនោះថាជាអ្នកស្ងប់ ព្រោះលះអាយតនៈ ទាំងអស់ ។ បុគ្គលនោះជាអ្នកប្រាជ្ញ បុគ្គលនោះ ជាអ្នកដល់នូវ វេទ ជាបុគ្គលដែលតណ្ហានឹងទិដ្ឋិមិនអាស្រ័យនៅហើយ ព្រោះ ឃើញសង្ខារធម៌ (ថាជារបស់មិនទៀង ជាទុក្ខ មិនមែនខ្លួន)

សម្មា សោ លោកេ ឥរិយានោ ន បិហេតីធ កស្សចិ ។

យោ ច កាមេ អច្ចតរិ សង្គំ លោកេ ទុរច្ចយំ

ន សោ សោចតិ នាជ្ឈេតិ ឆិន្នសោតោ អពន្ធនោ ។

យំ បុព្ពេ តំ វិសោសេហិ(១) បច្ឆា តេ មាហុ កិញ្ចនំ

មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។

សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ

អសតា ច ន សោចតិ ស វេ លោកេ ន ជិយ្យតិ ។

យស្ស នត្ថិ ឥទំ មេតិ បរេសំ វាបិ កិញ្ចនំ

មមត្តំ សោ អសំវិន្ទំ(២) នត្ថិ មេតិ ន សោចតិ ។

---

១ ម. វិសោសេតិ ។ ២ ម. មមត្តំ សោ អសំធិន្ទំ ។

បុគ្គលនោះ រមែងប្រព្រឹត្តទៅក្នុងលោកដោយប្រពៃ មិនជាប់ចិត្តនឹងបុគ្គលណាមួយឡើយ ។ បុគ្គលណា បានឆ្លងផុតនូវកាមផង នូវកិលេសគ្រឿងជាប់ ដែលឆ្លងបានដោយកម្រ ក្នុងលោកផង បុគ្គលនោះ ឈ្មោះថា កាត់ខ្សែតណ្ហា មិនមានបំណង រមែងមិនសោក មិនសុបសៅ ។ កិលេសជាតណាកើតឡើង (ព្រោះប្រារព្ធ) សង្ខារជាអតីត អ្នកចូរធ្វើកិលេសនោះ ឲ្យរីងស្ងួតទៅ កិលេសគ្រឿងកង្វល់ (មានរាគៈជាដើមកើតឡើងព្រោះប្រារព្ធ) សង្ខារដែលនឹងមានទៅខាងក្រោយ ចូរកុំមានដល់អ្នកឡើយ បើអ្នកមិនប្រកាន់ក្នុងធម៌ជាកណ្តាល (មានរូបជាដើមដែលជាបច្ចុប្បន្ន) អ្នកនឹងទៅជាបុគ្គលស្ងប់ ។ បុគ្គលណា មិនមានសេចក្តីប្រកាន់ក្នុងនាមនឹងរូប ថាជារបស់អញសព្វកន្លែងទេ បុគ្គលនោះឯង រមែងមិនសោក ព្រោះនាមរូបដែលមិនមានផង មិនទ្រុឌទ្រោមទៅក្នុងលោកផង ។ កង្វល់ថា នេះរបស់អញ នុះជារបស់ជនដទៃ មិនមាន ដល់បុគ្គលណា បុគ្គលនោះ កាលមិនបាននូវវត្ថុដែលប្រកាន់ថា របស់អញ រមែងមិនសោកថា អញគ្មានដូច្នេះឡើយ ។

អនុដ្ឋុរិ អនុគិទ្ធោ អនេជោ សព្វធិ សមោ
តមានិសំសំ បព្រូមិ បុច្ឆិតោ អវិកម្បិនំ ។
អនេជស្ស វិជានតោ នត្ថិ កាចិ និសង្ខតិ
វិរតោ សោ វិយារម្ភា(១) ខេមំ បស្សតិ សព្វធិ ។
ន សមេសុ ន ឱមេសុ ន ឧស្សេសុ វទតេ មុនិ
សន្តោ សោ វីតមច្ឆរោ នាទេតិ ន និរស្សតីតិ ភគវាតិ ។

អត្តទណ្ឌសុត្តំ បណ្ណរសមំ ។

១ ម. វីរយារម្ភា ។

## សុត្តនិបាត អដ្ឋកវគ្គ ទី ៤ អត្តទណ្ឌសូត្រ ទី ១៥

បុគ្គលដែលមិនមានឫស្សា មិនមានសេចក្តីត្រេកអរ ជាអ្នកមិនញាប់ញ័រ ជាអ្នកស្ងប់រម្ងាប់ ក្នុងអាយតនៈខាងក្នុង ខាងក្រៅទាំងអស់ តថាគត កាលបើមានបុគ្គលចូលមកសួរអានិសង្សរបស់បុគ្គលអ្នកមិនញាប់ញ័រនោះ ក៏នឹងសំដែង (អានិសង្សទាំង ៤ មានមិនឫស្សាជាដើមនោះ) ។ (បណ្តាសង្ខារទាំង ៣ មានបុញ្ញាភិសង្ខារជាដើម) សង្ខារណាមួយ មិនមានដល់បុគ្គលអ្នកមិនញាប់ញ័រ អ្នកដឹងច្បាស់ (នូវត្រៃលក្ខណ៍) បុគ្គលនោះវៀរស្រឡះចាកសង្ខារទាំង ៣ នោះ រមែងឃើញសេចក្តីក្សេមក្នុងទីទាំងពួង ។ អ្នកប្រាជ្ញ រមែងមិននិយាយអួតខ្លួន (ដោយមានះថា អញជាបុគ្គលស្មើគ្នា) ក្នុងពួកបុគ្គលស្មើគ្នា (ថាអញជាបុគ្គលថោកទាប) ក្នុងពួកបុគ្គលដែលថោកទាប (ថាអញជាបុគ្គលប្រសើរ) ក្នុងពួកបុគ្គលដែលប្រសើរ បុគ្គលនោះ ជាអ្នកស្ងប់ប្រាសចាកសេចក្តីកំណាញ់ រមែងមិនប្រកាន់ មិនអន្ទះសារ ។

ចប់ អត្តទណ្ឌសូត្រ ទី ១៥ ។

# សោឡសមំ សារីបុត្តសុត្តំ

(១១០) ន មេ ទិដ្ឋោ ឥតោ បុព្វេ (ឥច្ចាយស្មា សារិបុត្តោ)

ន សុតោ ឧទ កស្សចិ

ឯវំ វគ្គុវទោ សត្ថា តុសិតា គណិមាគតោ ។

សទេវកស្ស លោកស្ស យថា ទិស្សតិ ចក្ខុមា

សព្វំ តមំ វិនោទេត្វា ឯកោវ រតិមជ្ឈគា ។

តំ ពុទ្ធំ អសិតំ តាទិំ អកុហំ គណិមាគតំ

ពហូនមិធ ពទ្ធានំ អត្ថិ បញ្ហេន អាគមំ(១)

ភិក្ខុនោ វិជិគុច្ឆតោ ភជតោ រិត្តមាសនំ

រុក្ខមូលំ សុសានំ វា បព្វតានំ គុហាសុ វា

---

១ ឱ. អាគមី ។

សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត

# សារីបុត្តសូត្រ ទី ១៦

(១១០) (ព្រះសារីបុត្តដ៏មានអាយុបានពោលថា) ព្រះមានព្រះភាគ ជាសាស្តាចារ្យ ព្រះអង្គចុះចាកតុសិត មកជាគណាចារ្យ ព្រះអង្គមានព្រះវាចាពីរោះយ៉ាងនេះ ខ្ញុំព្រះអង្គ មិនដែលឃើញ មិនដែលឮ អំពីសំណាក់អ្នកណាមួយ ក្នុងកាលមុនអំពីកាលដែលព្រះអង្គស្តេចចុះមក កាន់ក្រុងសង្កស្សៈនោះឡើយ ។ ព្រះសាស្តា ព្រះអង្គមានចក្ខុ (ដ៏ឧត្តម) រមែងប្រាកដ ដល់មនុស្សលោក ព្រមទាំងទេវលោក ព្រះអង្គជាបុគ្គលឯក បានបន្ទោបង់នូវងងឹតទាំងអស់ ហើយបានលុះធម៌ដ៏វិសេស ដែលជាទីត្រេកអរ ។ ខ្ញុំព្រះអង្គមានសេចក្តីត្រូវការនឹងសួរប្រស្នា ដើម្បីសាវ័កទាំងឡាយ ច្រើននាក់ ទើបមកគាល់ព្រះអង្គ ជាព្រះពុទ្ធ មានសន្តានបរិសុទ្ធ ប្រាសចាកតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ព្រះអង្គជាបុគ្គល មិនញាប់ញ័រ ជាបុគ្គលមិនកុហក ជាគណាចារ្យ ស្តេចមកក្នុងក្រុងសង្កស្សៈនេះ កាលបើភិក្ខុខ្ពើម ( អំពីជាតិជាដើម ) ជាអ្នកគប់រក នូវសេនាសនៈស្ងាត់ក្តី នៅទីជិតនៃដើមឈើក្តី នូវព្រៃស្មសានក្តី ឬក៏អ្នកនៅអាស្រ័យ ក្នុងល្អាងភ្នំទាំងឡាយក្តី

ឧច្ចាវចេសុ សយនេសុ កីវន្តោ តត្ថ ភេរវា

យេហិ ភិក្ខុ ន វេធេយ្យ(១) និគ្ឃោសេ សយនាសនេ

កតី បរិស្សយា លោកេ គច្ឆតោ អគតំ(២) ទិសំ

យេ ភិក្ខុ អភិសម្ភវេ បន្តម្ហិ សយនាសនេ ។

ក្យាស្ស ព្យបថយោ អស្សុ ក្យាស្សស្សុ(៣)ឥធ គោចរា

កានិ សីលព្វតានស្សុ(៤) បហិតត្តស្ស ភិក្ខុនោ

កំ សោ សិក្ខំ សមាទាយ ឯកោទិ និបកោ សតោ

កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោ ។

វិជិគុច្ឆមានស្ស យទិទំ ផាសុ (សារិបុត្តាតិ ភគវា)

---

១ ម. វេទេយ្យ ។ ២ ឱ. ម. អបតំ ។ ៣ ម. កានស្សុ ។ ៤ ឱ. សីលព្វតា-នស្សុ ។ ម. សីលព្វតា អស្សុ ។

ភិក្ខុកាលនៅក្នុងសេនាសនៈស្ងាត់ ប្រាសចាកសំឡេងគឹកកង មិនគប្បីញាប់ញ័រ ដោយហេតុគួរឲ្យភ័យណា ហេតុគួរឲ្យភ័យក្នុងសេនាសនៈ ជាតាបទីន៍ទុត្តមនោះ មានប៉ុន្មាន ភិក្ខុនៅក្នុងសេនា-សនៈស្ងាត់ គប្បីគ្របសង្កត់សេចក្តីអន្តរាយ ទាំងឡាយណា សេចក្តីអន្តរាយទាំងឡាយនោះ មានប៉ុន្មាន ដែលនឹងមានដល់ភិក្ខុកាលទៅកាន់ទិស ដែលគេមិនធ្លាប់ទៅ គឺព្រះនិព្វាន ក្នុងលោកនេះ ៗ ពាក្យពេចន៍ របស់ភិក្ខុអ្នកមានខ្លួនបញ្ជូនទៅ តើជាអ្នកមានព្យាយាមតឹងតែងតើដូចម្តេច គោចរទាំងឡាយក្នុងលោកនេះរបស់លោកតើដូចម្តេច សីលនិងវ័តទាំងឡាយ របស់លោក តើដូចម្តេច ភិក្ខុនោះគប្បីសមាទាន នូវសិក្ខាដូចម្តេច ទើបជាអ្នកមានសតិ មានចិត្តមូល ក្នុងអារម្មណ៍តែមួយ ជាអ្នកមានប្រាជ្ញាគប្បីបន្ទោបង់កិលេស ជាមន្ទិលរបស់ខ្លួនបាន ដូចជាងមាសដេញអាចម៍មាស ឲ្យអស់ចេញបាន ៗ ( ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ) ផាសុវិហារធម៌ ( គ្រឿងនៅសុខសម្រាន្ត ) ណា របស់ភិក្ខុអ្នកខ្ពើម ( អំពីជាតិជាដើម )

រិត្តាសនំ សយនំ សេវតោ ចេ
សម្ពោធិកាមស្ស យថានុធម្មំ
តន្មេ បព្រូហិ យថា បជានំ ។
បញ្ចន្ន(១) ធីរោ ភយានំ ន ភាយេ
ភិក្ខុ សតោ ស បរិយន្តចារី
ឌំសាធិបាតានំ សិរីសបានំ
មនុស្សផស្សានំ ចតុប្បទានំ
បរធម្មិកានម្បិ ន សន្តសេយ្យ
ទិស្វាបិ តេសំ ពហុភេរវានិ
អថាបរានិ អភិសម្ភវេយ្យ
បរិស្សយានិ កុសលានុឯសី ។
អាតង្កផស្សេន ខុទាយ ផុដ្ឋោ
សីតំ អច្ចុណ្ហំ(២) អធិវាសយេយ្យ
សោ តេហិ ផុដ្ឋោ ពហុធា អនោកោ(៣)
វិរិយំ បរក្កម្ម ទឡ្ហំ ករេយ្យ ។

---

១ ម. បញ្ចន្នំ ។ ២ ម. អច្ចុណ្ហំ ។ ៣ ម. អនោកោ ។

អ្នកប្រាថ្នានូវការត្រាស់ដឹង សេពនូវសេនាសនៈស្ងាត់ តថាគតនឹងពោលនូវផាសុវិហារធម៌នោះ ធម៌ដ៏សមគួរដល់អ្នកតាមដឹង ។ ភិក្ខុជាអ្នកប្រាជ្ញ មានស្មារតី ប្រព្រឹត្តក្នុងគុណមានទីបំផុតដោយជុំវិញ (១) មិនគប្បីខ្លាចនូវភ័យទាំង ៥ យ៉ាង គឺមិនខ្លាចសត្វរបោម ១ ស្រួយ ១ ពស់តូចពស់ធំ ១ ផស្សៈនៃមនុស្សជាចោរ ១ ពួកសត្វជើងបួន ១ ភិក្ខុអ្នកប្រាជ្ញនោះ ជាអ្នកស្វះស្វែងរកកុសលធម៌ សូម្បីបានឃើញជនដែលក្រៅអំពីសហធម្មិកៈ ឬបានឮសំឡេងដែលខ្លួនគួរខ្លាចដ៏ច្រើន របស់ជនទាំងនោះ ឬអន្តរាយយ៉ាងដទៃៗ គប្បីគ្របសង្កត់ មិនគប្បីតក់ស្លុតរន្ធត់ឡើយ ។ ភិក្ខុអ្នកប្រាជ្ញនោះ បើផស្សៈនៃរោគ ឬសេចក្ដីស្រេកឃ្លាន ឬក៏ត្រជាក់នឹងក្ដៅពាល់ត្រូវហើយ គប្បីអំអត់សង្កត់ ភិក្ខុនោះដែលផស្សៈនៃរោគ នឹងសេចក្ដីស្រេកឃ្លាន(ជាដើមនោះ) ពាល់ត្រូវហើយ (ដោយអាការផ្សេងៗ) សូម្បីច្រើនយ៉ាងណា ក៏មិនបានធ្វើឱកាស (ឲ្យដល់វិញ្ញាណ ដែលប្រកបដោយសង្ខារ គឺចិត្តដែលសម្បយុត្តដោយកុសលាកុសលចេតនា) គប្បីធ្វើសេចក្ដីព្យាយាមប្រឹងប្រែងមុតមាំ ។

---

១ សំដៅយកបារិសុទ្ធិសីល ៤ ។ ខុទ្ទកនិកាយ មហានិទ្ទេស ។

ថេយ្យំ ន ការេយ្យ ន មុសា ភណេយ្យ
មេត្តាយ ផស្សេ តសថាវរានិ
យទាវិលត្តំ មនសោ វិជញ្ញា
កណ្ហស្ស បក្ខោតិ វិនោទយេយ្យ ។
កោធាតិមានស្ស វសំ ន គច្ឆេ
មូលម្បិ តេសំ បលិខញ្ញ តិដ្ឋេ
អថប្បិយំ វា បន អប្បិយំ វា
អទ្ធា ភវន្តោ អភិសម្ភវេយ្យ ។
បញ្ញំ(១) បុរក្ខត្វា កល្យាណបីតិ
វិក្ខម្ភយេ តានិ បរិស្សយានិ
អរតឹ សហេថ សយនម្ហិ បន្តេ(២)
ចតុរោ សហេថ បរិទេវធម្មេ

១ បុញ្ញំ (អដ្ឋកថា) ។ ២ ម. សន្តេ ។

ភិក្ខុមិនគប្បីធ្វើការលួច មិនគប្បីពោលពាក្យកុហក គប្បីផ្សាយមេត្តាចិត្ត ចំពោះពួកសត្វ ដែលមានចិត្តតក់ស្លុតនឹងមានចិត្តរឹងប៉ឹង គឺពួកសត្វ ដែលមានចិត្តប្រកបដោយតណ្ហា នឹងប្រាសចាកតណ្ហា ក្នុងកាលណា ភិក្ខុបើដឹងនូវភាពនៃចិត្តកករល្អក់ ក្នុងកាលនោះ គប្បីបន្ទោបង់នូវភាព នៃចិត្តកករល្អក់នោះចេញ ដោយគិតថា នោះជាពួកប័ក្ខនៃធម៌ខ្មៅ ។ ភិក្ខុមិនគួរលុះអំណាច នៃសេចក្តីក្រោធនឹងសេចក្តីប្រកាន់ខ្លួនហួសហេតុ មួយទៀត គប្បីគាស់រំលើងឫសនៃសេចក្តីក្រោធ នឹងសេចក្តីប្រកាន់ហួសហេតុទាំងនោះចេញ មួយវិញទៀត គប្បីទម្រុឌទម្រោមគ្របសង្កត់សេចក្តីស្រឡាញ់ នឹងសេចក្តីស្អប់ ឲ្យជ្រះស្រឡះ ។ ភិក្ខុអ្នកមានបីតិដ៏ល្អ គប្បីធ្វើប្រាជ្ញាឲ្យប្រព្រឹត្តទៅ ក្នុងខាងមុខ ហើយគប្បីសង្កត់សង្កិនសេចក្តីអន្តរាយនោះ គប្បីអត់សង្កត់សេចក្តីមិនត្រេកអរ ក្នុងសេនាសនៈស្ងាត់ គប្បីអត់សង្កត់ធម៌ជាទីតាំងនៃសេចក្តីខ្សឹកខ្សួល ៤ យ៉ាង

កឹសូ អសិស្សាមិ កុវំ វា(១) អសិស្សំ
ទុក្ខំ វត សេត្ថ(២) កុវជ្ជ សេស្សំ
ឯតេ វិតក្កេ បរិទេវនេយ្យេ
វិនយេថ សេខោ អនិកេតសារី ។

អន្នញ្ច លទ្ធា វសនញ្ច កាលេ
មត្តំ សោ ជញ្ញា ឥធ តោសនត្ថំ
សោ តេសុ គុត្តោ យតចារី គាមេ
រុសិតោបិ វាចំ ផរុសំ ន វជ្ជា ។

ឱក្ខិត្តចក្ខុ ន ច បាទលោលោ
ឈានានុយុត្តោ ពហុជាគរស្ស
ឧបេក្ខមារព្ភ សមាហិតត្តោ
តក្កាសយំ កុក្កុច្ចិយូបឆិន្ទេ ។

---

១ ម. កុវ វា ។ ២ ម. បេត្ថ កុវជ្ជសេស្សំ ។

ភិក្ខុអ្នកសិក្សា ក្នុងត្រៃសិក្ខា ជាអ្នកមិនមានកង្វល់ គ្រាប់ទៅ គប្បីបន្ទោបង់សេចក្តីត្រេកអរ ៤ យ៉ាង ដែលជាទីតាំងនៃសេចក្តីខ្សឹកខ្សួល គឺត្រេកអរថា អញនឹងបានរបស់អ្វីបរិភោគ ១ ជាអញនឹងបរិភោគក្នុងទីណា ១ ជាអញដេកជាទុក្ខក្នុងរាត្រីនេះ ១ ជាអញនឹងដេកក្នុងទីណា ( ទើបជាសុខសប្បាយ ) ១ ។ ភិក្ខុក្នុងធម្មវិន័យនេះ បានទទួលបាយផង ទទួលសំពត់ស្លៀកដណ្តប់ផងក្នុងកាលគួរ ភិក្ខុនោះគប្បីដឹងប្រមាណ ( ក្នុងការទទួលឬការប្រើប្រាស់នូវបច្ច័យ៤) ដើម្បីសន្តោស ភិក្ខុនោះគប្បីជាអ្នកគ្រប់គ្រងក្នុងបច្ច័យទាំង៤នោះ គប្បីជាអ្នកមានការប្រព្រឹត្តសង្រួមក្នុងស្រុកទេស សូម្បីត្រូវអ្នកណាៗ ប្រទូស្តហើយ ក៏មិនគប្បីពោលពាក្យអាក្រក់ ( ទៅរកអ្នកនោះ ) ។ ភិក្ខុគប្បីជាអ្នកមានចក្ខុដាក់ចុះមួយទៀត មិនគប្បីជាអ្នករពឹសជើង គប្បីជាអ្នកប្រកបរឿយ ៗ ក្នុងឈាន ជាអ្នកភ្ញាក់ពេកច្រើន ជាអ្នកប្រារព្ធឧបេក្ខា ហើយមានចិត្តដំកល់មាំ គប្បីកាត់អកុសលវិតក្កៈ ទាំងធម៌ជាទីអាស្រ័យនៅ នៃអកុសលវិតក្កៈ នឹងការរពឹស (មានរពឹសដៃជាដើម) ។

សុត្តនិបាតេ ចតុត្ថស្ស អដ្ឋកវគ្គស្ស សោឡសមំ សារីបុត្តសុត្តំ

ចុទិតោ វចីភិ សតិមាភិនន្ទេ
សព្រហ្មចារីសុ ខិលំ បភិន្ទេ
វាចំ បមុញ្ចេ កុសលំ នាតិវេលំ
ជនវាទធម្មាយ ន ចេតយេយ្យ ។

អថាបរំ បញ្ច រជានិ លោកេ
យេសំ សតិមា វិនយាយ សិក្ខេ
រូបេសុ សទ្ទេសុ អថោ រសេសុ
គន្ធេសុ ផស្សេសុ សហេថ រាគំ ។

ឯតេសុ ធម្មេសុ វិនេយ្យ ឆន្ទំ
ភិក្ខុ សតិមា សុវិមុត្តចិត្តោ
កាលេន សោ សម្មាធម្មំ បរិវីមំសមានោ
ឯកោទិភូតោ វិហនេ តមំ សោតិ ភគវាតិ ។

សារីបុត្តសុត្តំ សោឡសមំ ។

អដ្ឋកវគ្គោ ចតុត្ថោ ។

ភិក្ខុកាលគេដាស់តឿន ដោយពាក្យទាំងឡាយ គប្បីជាអ្នកមានស្មារតី ទទួលត្រេកអរ គប្បីជាអ្នកទំលាយចិត្តរឹងរូស ក្នុងសព្រហ្មចារីទាំងឡាយចេញ គប្បីបញ្ចេញវាចាជាកុសល មិនគប្បីបញ្ចេញវាចាហួសកំណត់ កុំគិតគូរក្នុងពាក្យគរហានិន្ទារបស់ពួកជន ។ មួយទៀត ភិក្ខុអ្នកមានស្មារតី គប្បីសិក្សា ក្នុងត្រៃសិក្ខា ដើម្បីកំចាត់បង់ធូលីណា ធូលីនោះមាននៅក្នុងលោក ៥ យ៉ាង គឺរូបរាគៈ ១ សទ្ទរាគៈ ១ គន្ធរាគៈ ១ រសរាគៈ ១ ផស្សរាគៈ ១ ភិក្ខុនោះ គប្បីអត់សង្កត់នូវសេចក្ដីត្រេកអរ ក្នុងរូប សំឡេង ក្លិន រស ផស្សៈទាំងនោះចេញ ។ ភិក្ខុជាអ្នកមានស្មារតី មានចិត្តផុតស្រឡះហើយដោយប្រពៃ គប្បីកំចាត់បង់សេចក្ដីប៉ុនប៉ង ក្នុងកាមារម្មណ៍ទាំងឡាយនោះចេញ (គ្រាសមាធិចិត្តកើតឡើងហើយ) ភិក្ខុនោះ (មិនបានឈប់នៅត្រឹមប៉ុណ្ណោះ) ទំរិះរិះពិចារណាធម៌ ដោយត្រឹមត្រូវតាមកាល តទៅទៀត ភិក្ខុនោះគប្បីជាអ្នកមានចិត្តជាឯកគ្គតា កំចាត់បង់ងងឹតគឺកិលេសចេញ ។

ចប់ សារីបុត្តសូត្រ ទី ១៦ ។

ចប់ អដ្ឋកវគ្គ ទី ៤ ។

## តស្សុទ្ទានំ

កាមគុហដ្ឋ ទុដ្ឋា ច   សុទ្ធដ្ឋ បរមំ ដកា(១)
មេត្តេយ្យោ ច បសូរោ ច   មាគន្ទី បុរាភេទនំ
កលហំ ទ្វេ ច ព្យូហានិ   បុនរេវ តុវដ្ដកំ
អត្តទណ្ឌវរំ សុត្តំ   តេន សារីបុត្តេន(២) សោឡស
ឥតិ ឯតានិ សុត្តានិ   សព្វានដ្ឋកវគ្គិកាតិ ។

---

១ ឱ.ប. បរមា ជិន ។ ២ ម. ថេរបុច្ឆេន ។ ឱ. ថេរបញ្ហេន ។

# ឧទ្ទាននៃអដ្ឋកវគ្គ ទី ៤ នោះគឺ

និយាយអំពីកាមសូត្រ ១ គុហដ្ឋកសូត្រ ១ ទុដ្ឋដ្ឋកសូត្រ ១ សុទ្ធដ្ឋកសូត្រ ១ បរមដ្ឋកសូត្រ ១ ជរាសូត្រ ១ តិស្សមេត្តេយ្យសូត្រ ១ បសូរសូត្រ ១ មាគន្ទិយសូត្រ ១ បុរាភេទសូត្រ ១ កលហវិវាទសូត្រ ១ វិយូហសូត្រ ២ តុវដកសូត្រ ១ អត្តទណ្ឌសូត្រ ១ សារីបុត្តសូត្រ ១ សូត្រទាំង ១៦ នុ៎ះ មានក្នុងអដ្ឋកវគ្គទាំងអស់ ដោយប្រការដូច្នេះ ។

# សុត្តនិបាតេ បញ្ចមោ បារាយនវគ្គោ

## វត្ថុគាថា

(១១១) កោសលានំ បុរា រម្មា អគមា ទក្ខិណាបថំ
អាកិញ្ចញ្ញំ បត្ថយានោ ព្រាហ្មណោ មន្តបារគូ ។
សោ អស្សកស្ស វិសយេ មុឡ្ឡកស្ស(១) សមាសនេ
វសី គោធាវរីកូលេ ឧញ្ឆេន ច ផលេន ច ។
តស្សេវ ឧបនិស្សាយ គាមោ ច វិបុលោ អហុ
តតោ(២) ជាតេន អាយេន មហាយញ្ញមកប្បយិ
មហាយញ្ញំ យជិត្វាន បុន បាវិសិ អស្សមំ ។
តស្មឹ បតិបវិដ្ឋម្ហិ អញ្ញោ អាគញ្ឆិ ព្រាហ្មណោ
ឧគ្ឃដ្ដបាទោ តសិតោ បង្កទន្តោ រជស្សិរោ
សោ ច នំ ឧបសង្កម្ម សតានិ បញ្ច យាចតិ ។

---

១ ឱ. អឡ្ឡកស្ស ។ ម. មុឡ្ហកស្ស ។ ២ ម. តយោ ។

# សុត្តនិបាត បារាយនវគ្គទី ៥

## វត្ថុកថា

(១១១) (ព្រះអានន្ទដ៏មានអាយុ បានលើករឿងនេះ មកកាន់ទីប្រជុំ ក្នុងកាលធ្វើសង្គាយនាថា ព្រាហ្មណ៍ឈ្មោះពាវរី) ជាអ្នកដល់នូវត្រើយនៃមន្ត ប្រាថ្នានូវភាពជាអ្នកមិនកង្វល់ បានចេញអំពីបុរីនៃដែនកោសល ជាបុរីដ៏សប្បាយរីករាយ ទៅកាន់ទក្ខិណាបថជនបទ ។ ពាវរីព្រាហ្មណ៍នោះ នៅអាស្រ័យទៀបប្រាំងស្ទឹងគោធាវរី ជិតដែនអស្សកៈ និងជិតដែនមុឡ្ហកៈ ចិញ្ចឹមជីវិតដោយការស្វះស្វែងរក ( ស្វមរក ) ផង ដោយមើមឈើនិងផ្លែឈើផង ។ ស្រុកនោះបានរីកធំទូលាយ ព្រោះអាស្រ័យពាវរីព្រាហ្មណ៍នោះឯង ឯពាវរីព្រាហ្មណ៍នោះ បានបរិច្ចាគនូវមហាយញ្ញ ដោយសារអាករសួយារ ដែលកើតឡើងអំពីស្រុកនោះ លុះពាវរីព្រាហ្មណ៍ បានបូជានូវមហាយញ្ញរួចហើយ ក៏ចូលទៅកាន់អាស្រមវិញ ។ កាលពាវរីព្រាហ្មណ៍នោះ ចូលទៅកាន់អាស្រមវិញហើយ មានព្រាហ្មណ៍ដទៃទៀត មានជើងញាប់ទ្នាន់ សរស្វើតសស្វុក មានធ្មេញពណ៌ដូចភក់ មានក្បាលប្រឡាក់ដោយធូលី ព្រាហ្មណ៍នោះបានដើរចូលទៅរកពាវរីព្រាហ្មណ៍នោះ ហើយសូមវត្ថុ ៥០០ ។

តមេនំ ពាវរី ទិស្វា អាសនេន និមន្តយិ
សុខញ្ច កុសលំ បុច្ឆិ ឥទំ វចនមព្រវិ
យំ ខោ មមំ ទេយ្យធម្មំ(១) សព្វំ វិស្សជ្ជិតម្មយា
អនុជានាហិ មេ ព្រហ្មេ នត្ថិ បញ្ចសតានិ មេ ។
សចេ មេ យាចមានស្ស ភវំ នានុបទស្សតិ
សត្តមេ ទិវសេ តុយ្ហំ មុទ្ធា ផលតុ សត្តធា ។
អភិសង្ខរិត្វា កុហកោ ភេរវំ សោ អកិត្តយិ
តស្ស តំ វចនំ សុត្វា ពាវរី ទុក្ខិតោ អហុ
ឧស្សុស្សតិ អនាហារោ សោកសល្លសមប្បិតោ
អថោបិ ឯវំចិត្តស្ស ឈានេ ន រមតី មនោ ។
ឧត្រសតំ(២) ទុក្ខិតំ ទិស្វា ទេវតា អត្ថកាមិនី
ពាវរឹ ឧបសង្កម្ម ឥទំ វចនមព្រវិ
ន សោ មុទ្ធំ បជានាតិ កុហកោ សោ ធនត្ថិកោ
មុទ្ធនិ មុទ្ធាធិបាតេ វា ញាណំ តស្ស ន វិជ្ជតិ ។

---

១ ម. យំ មេ អត្ថិ ទេយ្យធម្មំ ។ ២ ខ. ម. ឧត្រស្តំ ។

ពាវរីព្រាហ្មណ៍ បានឃើញព្រាហ្មណ៍នោះហើយ ក៏អញ្ជើញដោយអាសនៈ សាកសួរសេចក្តីសុខផង កុសលផង ហើយបានពោលពាក្យនេះថា ទេយ្យធម៌ណារបស់ខ្ញុំ ទេយ្យធម៌ទាំងអស់នោះ ខ្ញុំបានបរិច្ចាគអស់ហើយ ម្នាលព្រាហ្មណ៍ អ្នកចូរជឿខ្ញុំចុះ ខ្ញុំមិនមានទៀត ៥០០ ទេ ។

(ព្រាហ្មណ៍នោះនិយាយថា) កាលខ្ញុំសូមហើយ បើអ្នកដ៏ចំរើនមិនឲ្យទេ ក្បាលរបស់អ្នកចូរបែក ៧ ភាគក្នុងថ្ងៃទី ៧ ។ ព្រាហ្មណ៍កុហកនោះ បានធ្វើកលឧបាយ ហើយសំដែងនូវហេតុដែលគួរខ្លាចដ៏ពន្លឹក ដល់ពាវរីព្រាហ្មណ៍នោះ លុះពាវរីព្រាហ្មណ៍ ឮពាក្យព្រាហ្មណ៍នោះហើយ ក៏ដល់នូវសេចក្តីទុក្ខព្រួយ មិនបរិភោគអាហារ ទៅជាស្គាំងស្គម ចុកណែនដោយសរគឺសេចក្តីសោក កាលបើពាវរីព្រាហ្មណ៍មានចិត្តយ៉ាងនេះ ចិត្តក៏មិនត្រេកអរក្នុងឈាន ។ ទេវតាអ្នកប្រាថ្នាប្រយោជន៍ បានឃើញពាវរីព្រាហ្មណ៍ មានសេចក្តីតក់ស្លុត ដល់នូវសេចក្តីទុក្ខព្រួយ ដូច្នោះហើយ ក៏ចូលទៅរកពាវរីព្រាហ្មណ៍ និយាយដូច្នេះថា ព្រាហ្មណ៍នោះ មិនដឹងក្បាលទេ គាត់ជាអ្នកកុហក ជាអ្នកត្រូវការ ដោយទ្រព្យ គាត់មិនមានការដឹងនូវក្បាល ទាំងការធ្លាក់ចុះនៃក្បាលទេ ។

កោតី ចរហិ ជានាតិ តម្មេ អក្ខាហិ បុច្ឆិតា[១]
មុទ្ធំ មុទ្ធាធិបាតញ្ច តំ សុណោម វចោ តវ ។
អហម្បេតំ ន ជានាមិ ញាណមេត្ថ ន វិជ្ជតិ
មុទ្ធំ មុទ្ធាធិបាតោ[២] ច ជិនានំ ហេត ទស្សនំ ។
អថ កោ ចរហិ ជានាតិ អស្មឹ បឋវិមណ្ឌលេ
មុទ្ធំ មុទ្ធាធិបាតញ្ច តំ មេ អក្ខាហិ ទេវតេ ។
បុរា កបិលវត្ថុម្ហា និក្ខន្តោ លោកនាយកោ
អបច្ចោ ឱក្កាករាជស្ស សក្យបុត្តោ បភង្ករោ
សោ ហិ ព្រាហ្មណ សម្ពុទ្ធោ សព្វធម្មាន បារគូ
សព្វាភិញ្ញាពលប្បត្តោ សព្វធម្មេសុ ចក្ខុមា
សព្វកម្មក្ខយំ[៣] បត្តោ វិមុត្តោ ឧបធិក្ខយេ

---

១ ម. បុច្ឆិតោ ។ ២ ម. មុទ្ធំ មុទ្ធាធិបាតេ ច ។ ៣ ខ. សព្វធម្មក្ខយំ ។

(ពាវរីព្រាហ្មណ៍សួរថា) ម្នាលអ្នកដ៏ចំរើន ឥឡូវនេះ អ្នកណាដឹងនូវក្បាលនឹងការធ្លាក់ចុះនៃក្បាល ខ្ញុំសូមសួរអ្នក ចូរអ្នកប្រាប់នូវអ្នកដែលដឹងនោះ ដល់ខ្ញុំចុះ ខ្ញុំនឹងចាំស្តាប់ពាក្យរបស់អ្នកនោះ ។

(ទេវតាតបថា) ខ្ញុំមិនដឹងនូវក្បាលនឹងការធ្លាក់ចុះនៃក្បាលនុ៎ះទេ ខ្ញុំមិនមានការដឹង ក្នុងហេតុទាំងពីរនោះឡើយ ក្បាលក្តី ការធ្លាក់ចុះនៃក្បាលក្តី មានតែព្រះជិនស្រីទេ ទើបឃើញបាន ។

(ពាវរីព្រាហ្មណ៍សួរថា) លើមណ្ឌលប្រថពីនោះ តើឥឡូវនេះ មានអ្នកណា អាចដឹងនូវក្បាលនឹងការធ្លាក់ចុះនៃក្បាល ម្នាលទេវតា អ្នកចូរប្រាប់នូវអ្នកនោះ ដល់ខ្ញុំ ។

(ទេវតាប្រាប់ថា) ព្រះលោកនាយក ព្រះអង្គជាពូជពង្សនៃព្រះបាទឧក្កាកៈ ជាសក្យបុត្រ ព្រះអង្គមានពន្លឺរស្មី ទ្រង់ចេញចាកមហាបុរី ឈ្មោះកបិលពស្តុ (ទៅទ្រង់ព្រះផ្នួស) ។ ម្នាលព្រាហ្មណ៍ ព្រោះព្រះលោកនាយកនោះ ព្រះអង្គត្រាស់ដឹងឯង ទ្រង់ដល់ត្រើយនៃធម៌ទាំងពួង បរិបូណ៌ដោយកំឡាំង នៃអភិញ្ញាទាំងពួង មានចក្ខុក្នុងធម៌ទាំងពួង បានដល់នូវការអស់ទៅនៃកម្មទាំងអស់ មានហឫទ័យចុះស៊ប់ ក្នុងធម៌ជាគ្រឿងអស់ទៅ នៃឧបធិក្កិលេស

ពុទ្ធោ សោ ភគវា លោកេ ធម្មំ ទេសេតិ ចក្ខុមា
តំ ត្វំ គន្ត្វាន បុច្ឆស្សុ សោ តេ តំ ព្យាករិស្សតិ ។
សម្ពុទ្ធោតិ វចោ សុត្វា ឧទគ្គោ ពាវរី អហុ
សោកស្ស តនុកោ អាសិ បីតិញ្ច វិបុលំ លភិ ។

សោ ពាវរី អត្តមនោ ឧទគ្គោ
តំ ទេវតំ បុច្ឆតិ វេទជាតោ
កតមម្ហិ គាមេ និគមម្ហិ វា បន
កតមម្ហិ វា ជនបទេ លោកនាថោ
យត្ថ គន្ត្វា នមស្សេមុ
សម្ពុទ្ធំ ទិបទុត្តមំ ។
សាវត្ថិយំ កោសលមន្ទិរេ ជិនោ
បហូតបញ្ញោ វរភូរិមេធសោ
សោ សក្យបុត្តោ វិធុរោ អនាសវោ
មុទ្ធាធិបាតស្ស វិទូ នរាសភោ ។

តតោ អាមន្តយិ សិស្សេ ព្រាហ្មណេ មន្តបារគេ(១)

---

១ ម. មន្តធារកេ ។

ព្រះសម្ពុទ្ធមានជោគអង្គនោះ មានបក្ខ សំដែងធម៌ក្នុងលោក អ្នកចូរអញ្ជើញទៅសួរព្រះអង្គចុះ ព្រះអង្គនឹងសំដែងហេតុនោះដល់អ្នក ។ ពាវរីព្រាហ្មណ៍ គ្រាន់តែឮពាក្យថាព្រះសម្ពុទ្ធ ក៏មានចិត្តរីករាយ មានសេចក្តីសោកស្រាលស្តើង តាំងបានទទួលបីតិដ៏ធំទូលាយ ។

លុះពាវរីព្រាហ្មណ៍នោះពេញចិត្ត មានចិត្តត្រេកអរ មានចិត្តរីករាយហើយ ក៏សួរទេវតានោះថា ព្រះលោកនាថព្រះអង្គគង់នៅក្នុងស្រុកណា និគមណា ឬជនបទណា យើងនឹងទៅថ្វាយបង្គំព្រះសម្ពុទ្ធ ឧត្តមជាងសត្វមានជើងពីរ ក្នុងទីណា ។

(ទេវតាប្រាប់ថា) ព្រះជិនស្រី មានប្រាជ្ញាច្រើន មានប្រាជ្ញាដ៏ប្រសើរ ដូចផែនដី គង់នៅក្នុងកោសលមន្ទីរ ក្នុងក្រុងសាវត្ថី ព្រះមានបុណ្យនោះ ជាសក្យបុត្រ មានធុរៈដាក់ចោលអស់ហើយ មិនមានអាសវៈទេ ប្រសើរជាងនរជន ទើបដឹងនូវក្បាលនឹងការធ្លាក់ចុះនៃក្បាល ។ លំដាប់នោះ ពាវរីព្រាហ្មណ៍បានហៅពួកព្រាហ្មណ៍ជាសិស្ស ដែលដល់នូវត្រើយនៃមន្ត (ចេះចប់មន្ត) មកថា

ឯថ មាណវា អក្ខិស្សំ  សុណោថ វចនំ មម
យស្សេសោ ទុល្លភោ លោកេ  បាតុភាវោ អភិណ្ហសោ
ស្វាជ្ជ លោកម្ហិ ឧប្បន្នោ  សម្ពុទ្ធោ ឥតិ វិស្សុតោ
ខិប្បំ គន្ត្វាន សាវត្ថិំ  បស្សវ្ហោ ទ្វិបទុត្តមំ ។
កថំ ចរហិ ជានេមុ  ទិស្វា ពុទ្ធោតិ ព្រាហ្មណ
អជានតំ នោ បព្រូហិ  យថា ជានេមុ តំ មយំ ។
អាគតានិ ហិ មន្តេសុ  មហាបុរិសលក្ខណា
ទ្វត្តឹសា ច ព្យាក្ខាតា  សមត្តា អនុបុព្វសោ ។
យស្សេតេ ហោន្តិ គត្តេសុ  មហាបុរិសលក្ខណា
ទុវេវ តស្ស គតិយោ  តតិយា ហិ ន វិជ្ជតិ
សចេ អគារំ អាវសតិ(១)  វិជេយ្យ បឋវឹ ឥមំ
អទណ្ឌេន អសត្ថេន  ធម្មេនមនុសាសតិ

---

១ ឱ. ម. អជ្ឈាវសតិ ។

ម្នាលមាណពទាំងឡាយ អ្នករាល់គ្នាចូរមកនេះ យើងនឹងប្រាប់ ចូរអ្នកទាំងឡាយ ស្តាប់ពាក្យយើងចុះ ការកើតឡើងប្រាកដរឿយៗនៃព្រះសម្ពុទ្ធណា ដែលគេបានដោយក្រក្នុងលោក ថ្ងៃនេះព្រះសម្ពុទ្ធអង្គនោះ ខ្ញុំបានឮប្រាកដហើយថា ព្រះសម្ពុទ្ធកើតឡើងហើយ ក្នុងលោក អ្នកទាំងឡាយ ចូរនាំគ្នាទៅកាន់ក្រុងសាវត្ថី ឲ្យឆាប់ៗ ហើយចូលទៅគាល់ព្រះអង្គ ដែលឧត្តមជាងសត្វមានជើងពីរ ។ ពួកព្រាហ្មណ៍ជាសិស្សសួរថា បពិត្រព្រាហ្មណ៍ ពួកយើងឃើញហើយ គប្បីស្គាល់ថា អ្នកនោះ ជាព្រះពុទ្ធបាន ដោយប្រការដូចម្តេច សូមលោកប្រាប់ ដល់យើងទាំងឡាយដែលជាអ្នកមិនស្គាល់ ឲ្យទាល់តែយើងទាំងឡាយស្គាល់ព្រះអង្គ ។ ពាវរីព្រាហ្មណ៍និយាយថា មហាបុរិសលក្ខណៈទាំង ៣២ ប្រការ មានមកក្នុងមន្តទាំងឡាយ ដែលពួកហោរបានព្យាករបរិបូណ៌ហើយដោយលំដាប់ ។ មហាបុរិសលក្ខណៈទាំងនោះ មានក្នុងខ្លួននៃបុគ្គលណា បុគ្គលនោះមានគតិតែពីរគត់ គតិជាគំរប់៣មិនមានឡើយ គឺបើនៅគ្រប់គ្រងគេហដ្ឋាន នឹងគប្បីឈ្នះនូវផែនដីនេះ ដោយមិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ គ្រាន់តែប្រៀនប្រដៅ ដោយធម៌

សចេ ច សោ បព្វជតិ អគារា អនគារិយំ
វិវដច្ឆទោ សម្ពុទ្ធោ អរហា ភវតិ អនុត្តរោ ។
ជាតិគោត្តញ្ច លក្ខណំ មន្តេ សិស្សេ បុនាបរេ
មុទ្ធំ មុទ្ធាធិបាតញ្ច មនសា យេវ បុច្ឆថ ។
អនាវរណទស្សាវី យទិ ពុទ្ធោ ភវិស្សតិ
មនសា បុច្ឆិតេ បញ្ហេ វាចាយ វិសជ្ជេស្សតិ ។
ពាវរិស្ស វចោ សុត្វា សិស្សា សោឡស ព្រាហ្មណា
អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្បា ទុភយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច បោសាលោ ចាបិ ព្រាហ្មណោ
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ
បច្ចេកគណិនោ សព្វេ សព្វលោកស្ស វិស្សុតា

បើបុគ្គលនោះចេញចាកផ្ទះ ចូលទៅកាន់ផ្នួស រមែងជាបុគ្គល មានដំបូល គឺកិលេសបើកហើយ បានជាព្រះអរហន្តសម្ពុទ្ធ ដ៏ប្រសើរ ។ អ្នកទាំងឡាយចូរសួរ ដោយចិត្ត នូវជាតិផង នូវគោត្រផង នូវលក្ខណៈផង (របស់យើង) នូវមន្តដែលយើងបាននិយាយផង នូវពួកសិស្ស (របស់យើង) ដទៃទៀតផង នូវក្បាលផង នូវការធ្លាក់ចុះនៃក្បាលផង ។ បើបុគ្គលនោះ ប្រាកដជាព្រះពុទ្ធ អ្នកឃើញកាលទាំងពួង ដោយអនាវរណញ្ញាណមែន កាលបើប្រស្នាដែលអ្នកទាំងឡាយសួរហើយ ដោយចិត្ត ព្រះអង្គនឹងដោះស្រាយដោយវាចា ។ ឯពួកព្រាហ្មណ៍ជាសិស្សទាំងអស់ ១៦ នាក់ គឺ អជិតមាណព ១ តិស្សមេត្តេយ្យ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យនឹងកប្បៈជាពីរនាក់ ជតុកណ្ណីបណ្ឌិត ១ ភទ្រាវុធៈ ១ ឧទយៈ ១ បោសាលព្រាហ្មណ៍ ១ មោឃរាជមេធាវី ១ បិង្គិយមហាឥសី ១ ព្រាហ្មណ៍ទាំងអស់នេះ សុទ្ធតែជាមេគណៈផ្សេង ៗ គ្នា ល្បីល្បាញពាសពេញ ក្នុងលោក

ឈាយី ឈានរតា ធីរា បុព្វវាសនវាសិតា
ពាវរឹ អភិវាទេត្វា កត្វា ច នំ បទក្ខិណំ
ជដាជិនធរា សព្វេ បក្កាមុំ ឧត្តរាមុខា
មុឡ្ហកស្ស បតិដ្ឋានំ បុរំ មាហិស្សតី តទា(១)
ឧជ្ជេនឹ ចាបិ គោនទ្ធំ វេទិសំ វនសវ្ហយំ
កោសម្ពឹ ចាបិ សាកេតំ សាវត្ថិញ្ច បុរុត្តមំ
សេតព្យំ កបិលវត្ថុំ កុសិនារញ្ច មន្ទិរំ
បាវញ្ច ភោគនគរំ វេសាលឹ មាគធំ បុរំ
បាសាណកំ ចេតិយញ្ច រមណីយំ មនោរមំ
តសិតោវ ឧទកំ សីតំ មហាលាភំវ វាណិជោ
ឆាយំ ឃម្មាភិតត្តោវ តុរិតា បព្វតមារុហុំ ។
ភគវា ច តម្ហិ សមយេ ភិក្ខុសង្ឃបុរក្ខតោ
ភិក្ខូនំ ធម្មំ ទេសេតិ សីហោវ នទតី វនេ ។

---

១ ឱ. បុរិមំ មាហិស្សតី តទា ។ ម. បុរិមា ហឹសតិ តទា ។

ជាអ្នកមានឈាន ត្រេកអរក្នុងឈាន មានប្រាជ្ញាមុតមាំ បានអប់-
រំវាស្នាទុកមក ពីក្នុងជាតិមុនៗ លុះបានស្តាប់ពាក្យពាវរីព្រាហ្មណ៍
ហើយ ក៏ក្រាបថ្វាយបង្គំពាវរីព្រាហ្មណ៍ រួចធ្វើប្រទក្សិណពាវរី-
ព្រាហ្មណ៍នោះ ទាំងអស់គ្នា សុទ្ធតែទ្រទ្រង់នូវក្នួងសក់និងស្បែក
ខ្លា ឈមមុខទៅទិសខាងជើង ហើយដើរចេញទៅ កាន់ទី
ប្រតិស្ឋាននៃក្រុងមុឡ្ហក: កាន់ក្រុងមាហិស្សតី ក្រុងឧជ្ជេនី ក្រុង
គោនទ្ធា ក្រុងវេទិស ក្រុងវនស: ក្រុងកោសម្ពី ក្រុងសាកេត
ក្រុងសាវត្ថី ដ៏ឧត្តម ក្រុងសេតព្យ: ក្រុងកបិលវត្ថុ ក្រុងកុសិនារា
ក្រុងបាវា ក្រុងភោគ: ក្រុងវេសាលី ក្រុងមគធ: និងបាសាណក-
ចេតិយ ដែលជាទីសប្បាយរីករាយចិត្ត ពួកព្រាហ្មណ៍ទាំងអស់នោះ
បានឡើងទៅកាន់ភ្នំ គឺចេតិយ ដោយប្រញាប់ប្រញាល់ ដូចបុរស
ស្រេកទឹក ដើរទៅរកទឹកត្រជាក់ ឬដូចពាណិជ ដើរទៅរក
លាភធំ ពុំនោះសោត ដូចបុរសត្រូវរដូវក្តៅ គ្របសង្កត់
ដើរទៅរកម្លប់ឈើ ដោយប្រញាប់ប្រញាល់ ដូច្នោះឯង ។ គាប់
ចួនសម័យនោះ ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម កំពុង
សំដែងធម៌ ដល់ភិក្ខុទាំងឡាយ ដូចជាសីហៈបន្លឺ ក្នុងព្រៃ ។

អជិតោ អទ្ទស សម្ពុទ្ធំ វិតរំសីវ(១) ភាណុមំ
ចន្ទំ យថា បណ្ណរសេ បារិបូរឹ ឧបាគតំ ។
អថស្ស គត្តេ ទិស្វាន បរិបូរំ វិយញ្ជនំ
ឯកមន្តំ ឋិតោ ហដ្ឋោ មនោបញ្ហេ អបុច្ឆថ
អាទិស្ស ជម្មនំ ព្រូហិ គោត្តំ ព្រូហិ សលក្ខណំ
មន្តេសុ បារមឹ ព្រូហិ កតិ វាចេតិ ព្រាហ្មណោ ។
វីសំ វស្សសតំ អាយុ សោ ច គោត្តេន ពាវរី
តីណិស្ស លក្ខណា គត្តេ តិណ្ណំ វេទាន បារគូ
លក្ខណេ ឥតិហាសេ ច សនិឃណ្ឌុសកេដុភេ(២)
បញ្ច សតានិ វាចេតិ សធម្មេ បារមឹ គតោ ។

---

១ ម. សតរំសីវ ។ ២ ម. សនិគណ្ឌុសកេដុភេ ។

អជិតមាណព (ជាសិស្សច្បង) បានឃើញព្រះសម្ពុទ្ធ (មានរស្មីដ៏រុងរឿង) ដូចព្រះអាទិត្យ មានរស្មីផ្សាយចេញ ពុំនោះសោត ដូចព្រះចន្ទ្រពេញវង់រះឡើងក្នុងថ្ងៃ ១៥ កើត ។ បន្ទាប់ពីនោះមក អជិតមាណព បានឃើញព្យញ្ជនៈដ៏បរិបូណ៌ ក្នុងសរីរៈរបស់ព្រះអង្គ ហើយឋិតនៅក្នុងទីដ៏សមគួរ មានចិត្តរីករាយ បានសួរនូវប្រស្នាទាំងឡាយក្នុងចិត្តថា សូមព្រះអង្គសំដែងប្រាប់នូវជន្មាយុ (របស់អាចារ្យនៃខ្ញុំ) សូមព្រះអង្គសំដែងប្រាប់នូវគោត្រ ព្រមទាំងលក្ខណៈ សូមព្រះអង្គសំដែងនូវបារមី (ការសម្រេច) ក្នុងមន្តទាំងឡាយ ព្រាហ្មណ៍ជាអាចារ្យរបស់ខ្ញុំ ប្រៀនប្រដៅសិស្ស មានប៉ុន្មាននាក់ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា អាចារ្យរបស់អ្នកនោះ មានអាយុ ១២០ ឆ្នាំ ឈ្មោះពាវរី តាមគោត្រ លក្ខណៈក្នុងខ្លួនរបស់គាត់មាន ៣ ប្រការ គាត់ចេះចប់នូវត្រៃវេទ គាត់បង្រៀននូវមហាបុរិសលក្ខណៈផង នូវគម្ពីរឥតិហាសៈ ព្រមទាំងគម្ពីរនិឃណ្ឌុនិងគម្ពីរកេដុភៈផង នូវមន្ត ៥០០ ផង ដល់នូវបារមីគឺការសម្រេច ក្នុងព្រាហ្មណធម៌របស់ខ្លួន ។

សុត្តនិបាតេ បារាយនវគ្គស្ស វត្ថុគាថា

លក្ខណានំ បវិចយំ  ពាវរិស្ស នរុត្តម
តណ្ហច្ឆិទ បកាសេហិ  មា នោ កង្ខាយិតំ អហុ ។
មុខំ ជិវ្ហាយ ឆាទេតិ  ឧណ្ណាស្ស ភមុកន្តរេ
កោសោហិតំ វត្ថគុយ្ហំ  ឯវំ ជានាហិ មាណវ ។
បុច្ឆំ ហិ កិញ្ចិ(១) អសុណន្តោ  សុត្វា បញ្ហេ ព្យាកតេ
វិចិន្តេតិ ជនោ សព្វោ  វេទជាតោ កតញ្ជលី
កោ នុ ទេវោ វា ព្រហ្មា វា  ឥន្ទោ វាបិ សុជម្បតិ
មនសា បុច្ឆិតេ បញ្ហេ  កមេតំ បដិភាសតិ ។
មុទ្ធំ មុទ្ធាធិបាតញ្ច  ពាវរី បរិបុច្ឆតិ
តំ ព្យាករោហិ ភគវា  កង្ខំ វិនយ នោ ឥសេ ។

---

១ ម. បុច្ឆំ ហិ កិញ្ចិ ។ ឯ. បុច្ឆញ្ហិ តំ ។

អជិតមាណព ក្រាបទូលថា បពិត្រព្រះអង្គជាបុគ្គលឧត្តមជាងនរជន អ្នកកាត់ផ្តាច់នូវតណ្ហា សូមព្រះអង្គពិចារណានូវលក្ខណៈរបស់ពាវរីព្រាហ្មណ៍ រួបសំដែងកុំឲ្យយើងខ្ញុំមានសេចក្តីសង្ស័យ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ពាវរីព្រាហ្មណ៍ យកអណ្តាតបាំងមុខបាន មានឧណ្ណាណោម នៅត្រង់ចន្លោះចិញ្ចើម វត្ថគុយ្ហៈ (លិង្គ) របស់គាត់បិទបាំងដោយស្រោម ម្នាលមាណព អ្នកចូរដឹងយ៉ាងនេះចុះ ។ មែនពិត ពួកជនទាំងអស់គ្នា មិនដែលបានឮពាក្យបុច្ឆាណាមួយ លុះឮប្រស្នាទាំងឡាយ ដែលព្រះអង្គឆ្លើយហើយ ក៏កើតសេចក្តីរីករាយ ធ្វើប្រណាម្យអញ្ជលី ហើយត្រិះរិះដូច្នេះថា នរណាហ្ន៎ ទោះទេវតាក្តី ព្រហ្មក្តី ឬក៏ព្រះឥន្ទ្រឈ្មោះសុជម្បតីក្តី កាលគេសួរប្រស្នាដោយចិត្តហើយ នឹងដោះស្រាយប្រស្នាដូចម្តេចបាន ។ អជិតមាណព ទូលថា ពាវរីព្រាហ្មណ៍ សាកសួរនូវក្បាលផង នូវការធ្លាក់ចុះនៃក្បាលផង បពិត្រព្រះមានព្រះភាគ សូមព្រះអង្គឆ្លើយនូវប្រស្នានុ៎ះឲ្យធាន បពិត្រព្រះអង្គជាអ្នកស្វះស្វែងគុណ សូមព្រះអង្គកំចាត់បង់នូវសេចក្តីសង្ស័យ របស់យើងខ្ញុំទាំងឡាយ ។

អវិជ្ជា មុទ្ធាតិ វិជានាហិ វិជ្ជា មុទ្ធាធិបាតិនី
សទ្ធាសតិសមាធីហិ ឆន្ទវីរិយេន សំយុតា ។
តតោ វេទេន មហតា សន្ថម្ភិត្វាន មាណវោ
ឯកំសំ អជិនំ កត្វា បាទេសុ សិរសា បតិ
ពាវរី ព្រាហ្មណោ ភោតោ សហ សិស្សេហិ មារិស
ឧទគ្គចិត្តោ សុមនោ បាទេ វន្ទតិ ចក្ខុម ។
សុខិតោ ពាវរី ហោតុ សហ សិស្សេហិ ព្រាហ្មណោ
ត្វំ ចាបិ សុខិតោ ហោហិ ចិរំ ជីវាហិ មាណវ ។
ពាវរិស្ស ច តុយ្ហំ វា សព្វេសំ សព្វសំសយំ
កតាវកាសា បុច្ឆវ្ហោ យំ កិញ្ចិ មនសិច្ឆថ ។
សម្ពុទ្ធេន កតោកាសោ និសីទិត្វាន បញ្ជលី
អជិតោ បឋមំ បញ្ហំ តត្ថ បុច្ឆិ តថាគតំ ។

វត្ថុគាថា និដ្ឋិតា ។

ព្រះសម្ពុទ្ធត្រាស់ថា អ្នកចូរដឹងចុះថា អវិជ្ជា ទុកជាក្បាល វិជ្ជាដែលប្រកបដោយសទ្ធា សតិ សមាធិ ឆន្ទៈ និងវិរិយៈ ទុកជាការធ្លាក់ចុះនៃក្បាល ។ លំដាប់នោះ អជិតមាណព ខំទប់ទល់ ដោយសេចក្តីត្រេកអរច្រើន ហើយយកស្បែកខ្លាព័ទ្ធ ឆៀងស្មាម្ខាង រួចក្រាបសិរ្សៈ ទៀបព្រះបាទទាំងគូ ក្រាបទូលថា បពិត្រព្រះអង្គនិទ្ទុក្ខ ព្រះអង្គមានចក្ខុ ពាវរីព្រាហ្មណ៍ដ៏ចំរើន ព្រមទាំងពួកសិស្ស មានចិត្តរីករាយ ស្រោះស្រាយ ថ្វាយបង្គំព្រះបាទ (របស់ព្រះអង្គ) ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមាណព សូមឲ្យពាវរីព្រាហ្មណ៍ព្រមទាំងពួកសិស្ស បានដល់នូវសេចក្តីសុខចុះ ទាំងរូបអ្នកសោត ក៏ចូរជាបុគ្គល ដល់នូវសេចក្តីសុខ រស់នៅអស់កាលយូរចុះ ។ អ្នកទាំងឡាយ តថាគតបើកឱកាសឲ្យហើយ ចូរសួរនូវសេចក្តីសង្ស័យទាំងអស់ របស់ពាវរីព្រាហ្មណ៍ផង របស់អ្នកផង របស់ពួកជនទាំងអស់ផង ចូរប្រាថ្នាទុកក្នុងចិត្តនូវហេតុណាមួយចុះ ។ លុះព្រះសម្ពុទ្ធបើកឱកាសឲ្យហើយ អជិតមាណព អង្គុយប្រណម្យអញ្ជលី សួរប្រស្នាទី ១ នឹងព្រះតថាគត ក្នុងទីនោះឯង ។

ចប់ វត្ថុកថា ។

# បឋមា អជិតបញ្ហា

(១១២) កេនស្សុ និវុតោ លោកោ (ឥច្ចាយស្មា អជិតោ)

កេនស្សុ នប្បកាសតិ

កិស្សាភិលេបនំ ព្រូសិ កឹសុ តស្ស មហព្ភយំ ។

អវិជ្ជាយ និវុតោ លោកោ (អជិតាតិ ភគវា)

វេវិច្ឆា (បមាទា) នប្បកាសតិ

ជប្បាភិលេបនំ ព្រូមិ ទុក្ខមស្ស[១] មហព្ភយំ ។

សវន្តិ សព្វធិ សោតា (ឥច្ចាយស្មា អជិតោ)

សោតានំ កឹ និវារណំ

សោតានំ សំវរំ ព្រូហិ កេន សោតា បិធិយ្យរេ ។

យានិ សោតានិ លោកស្មឹ (អជិតាតិ ភគវា)

សតិ តេសំ និវារណំ

សោតានំ សំវរំ ព្រូមិ បញ្ញាយេតេ បិធិយ្យរេ ។

---

១ ម. ទុក្ខស្ស ប ។

# អជិតប្បញ្ហា ទី ១

(១១៦) (អជិតមាណពដ៏មានអាយុ ទូលសួរថា) សត្វលោក ត្រូវអ្វីបិទបាំង រមែងមិនជាក់ច្បាស់ ព្រោះអ្វី ព្រះអង្គត្រាស់ថា អ្វីជាគ្រឿងប្រឡាក់ អ្វីជាភ័យធំ របស់សត្វលោកនោះ ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលអជិតៈ)សត្វលោក ត្រូវអវិជ្ជាបិទបាំង រមែងមិនជាក់ច្បាស់ ព្រោះសេចក្ដីកំណាញ់ផង (សេចក្ដីប្រមាទ) តថាគតពោលថា តណ្ហាជាគ្រឿងប្រឡាក់ ទុក្ខជាភ័យធំ របស់សត្វលោកនោះ ។

(អជិតមាណពដ៏មានអាយុ ទូលសួរថា ) ខ្សែតណ្ហាទាំងឡាយ រមែងហូរទៅក្នុងអាយតនៈទាំងពួង អ្វីជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយ សូមព្រះអង្គត្រាស់ប្រាប់នូវធម៌ជាគ្រឿងរាំងនូវខ្សែតណ្ហាទាំងឡាយ ខ្សែតណ្ហាទាំងឡាយ ត្រូវបិទដោយអ្វី ។

( ព្រះមានព្រះភាគដោះស្រាយថា ម្នាលអជិតៈ) សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះ ដោយបញ្ញា ។

បញ្ញា ចេវ សតី ច (ឥច្ចាយស្មា អជិតោ)
នាមរូបញ្ច មារិស
ឯតម្មេ បុដ្ឋោ បព្រូហិ កត្ថេតំ ឧបរុជ្ឈតិ ។
យមេតំ បញ្ហំ អបុច្ឆិ អជិត តំ វទាមិ តេ
យត្ថ នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ
វិញ្ញាណស្ស និរោធេន ឯត្ថេតំ ឧបរុជ្ឈតិ ។
យេ ច សង្ខាតធម្មាសេ យេ ច សេក្ខា បុថូ ឥធ
តេសំ មេ និបកោ ឥរិយំ បុដ្ឋោ បព្រូហិ មារិស ។
កាមេសុ នាភិគិជ្ឈេយ្យ មនសានាវិលោ សិយា
កុសលោ សព្វធម្មានំ សតោ ភិក្ខុ បរិព្វជេ ។

អជិតមាណវកបញ្ហា បឋមា ។

(អជិតមាណព ដ៏មានអាយុ ទូលសួរថា) បពិត្រព្រះអង្គនិទុក្ខ បញ្ញាផង សតិផង នាមនិងរូបផង ធម៌នុ៎ះដែលខ្ញុំព្រះអង្គសួរហើយ សូមព្រះអង្គសំដែង តើធម៌នុ៎ះ រលត់ទៅក្នុងទីណា ។

ម្នាលអជិតៈ អ្នកបានសួរនូវបញ្ហាណា បំពោះតថាគត តថាគតនឹងសំដែង នូវបញ្ហានោះដល់អ្នក នាមនឹងរូប រលត់មិនសល់ក្នុងទីណា សតិនឹងបញ្ញានេះ ក៏រលត់ទៅក្នុងទីនោះ ព្រោះរលត់វិញ្ញាណ ។

ពួកអសេក្ខបុគ្គល អ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខបុគ្គលជាច្រើនណា ក្នុងសាសនានេះ បពិត្រព្រះអង្គនិទុក្ខ ខ្ញុំព្រះអង្គសួរនូវសេចក្តីប្រព្រឹត្តទៅ នៃបុគ្គលទាំងនោះ ព្រះអង្គមានបញ្ញាចាស់ក្លា សូមសំដែងប្រាប់ដល់ខ្ញុំព្រះអង្គ ។

បុគ្គលមិនគប្បីជាប់ជំពាក់ ក្នុងកាមទាំងឡាយ គប្បីជាអ្នកមានចិត្តមិនល្អក់ ជាអ្នកឈ្លាសវៃ បំពោះធម៌ទាំងអស់ ជាភិក្ខុមានសតិ គប្បីវៀរស្រឡះ (ចាកកាមទាំងឡាយ) ។

ចប់ អជិតមាណវកបញ្ហា ទី ១ ។

# ទុតិយា តិស្សមេត្តេយ្យបញ្ហា

(១១៣) កោធ សន្តុសិតោ លោកេ (ឥច្ចាយស្មា
តិស្សមេត្តេយ្យោ)
កស្ស នោ សន្តិ ឥញ្ជិតា
កោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតិ
កំ(១) ព្រូសិ មហាបុរិសោតិ កោ ឥធ សិព្វិនិមច្ចគា ។
កាមេសុ ព្រហ្មចរិយវា (មេត្តេយ្យាតិ ភគវា)
វីតតណ្ហោ សទា សតោ
សង្ខាយ និព្វុតោ ភិក្ខុ តស្ស នោ សន្តិ ឥញ្ជិតា
សោ ឧភន្តមភិញ្ញាយ មជ្ឈេ មន្តា ន លិម្បតិ
តំ ព្រូមិ មហាបុរិសោតិ សោ ឥធ សិព្វិនិមច្ចគាតិ ។

តិស្សមេត្តេយ្យមាណវកបញ្ហា ទុតិយា ។

---

១ ម. តំ ។

# តិស្សមេត្តេយ្យបញ្ហា ទី ២

(១១៣) (តិស្សមេត្តេយ្យមាណព ដ៏មានអាយុ ទូលសួរថា) អ្នកណា ឈ្មោះថាជាអ្នកសន្តោស ក្នុងលោកនេះ សេចក្តីញាប់ញ័រ រមែងមិនមាន ដល់បុគ្គលណា អ្នកណា ដឹងនូវចំណែកនៃខន្ធទាំងពីរ (ខន្ធអតីតនិងអនាគត) ដោយបញ្ញា ហើយរមែងមិនជាប់នៅក្នុងខន្ធកណ្តាល (ខន្ធបច្ចុប្បន្ន) ព្រះអង្គត្រាស់ថា អ្នកណាជាមហាបុរស អ្នកណា ឆ្លងតណ្ហាជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះបាន ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលមេត្តេយ្យ) ភិក្ខុមានព្រហ្មចរិយៈ(សង្រួម) ក្នុងកាមទាំងឡាយ ប្រាសចាកសេចក្តីប្រាថ្នា មានសតិរលឹកឃើញសព្វកាល ភិក្ខុជាអ្នករលត់ទុក្ខ ព្រោះពិចារណាឃើញច្បាស់ (ឈ្មោះថាជាអ្នកសន្តោស) សេចក្តីញាប់ញ័រ រមែងមិនមានដល់ភិក្ខុនោះឡើយ ភិក្ខុនោះ ដឹងនូវចំណែកនៃខន្ធទាំងពីរ ដោយបញ្ញាហើយ រមែងមិនជាប់នៅក្នុងខន្ធកណ្តាល តថាគតពោលនូវភិក្ខុនោះថា ជាមហាបុរស ភិក្ខុនោះ ឈ្មោះថា ឆ្លងនូវតណ្ហាគ្រឿងចាក់ស្រែះក្នុងលោកនេះបាន ។

ចប់ តិស្សមេត្តេយ្យមាណវកបញ្ហា ទី ២ ។

# តតិយា បុណ្ណកប្បញ្ហា

(១១៤) អនេជំ មូលទស្សាវឹ (ឥច្ចាយស្មា បុណ្ណកោ)

អត្ថិ បញ្ហេន អាគមំ(១)

កឹ និស្សិតា ឥសយោ មនុជា

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្បយឹសុ បុថូធ លោកេ

បុច្ឆាមិ តំ ភគវា ព្រូហិ មេតំ ។

យេ កេចិមេ ឥសយោ មនុជា (បុណ្ណកាតិ ភគវា)

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្បយឹសុ បុថូធ លោកេ

អាសឹសមានា បុណ្ណក ឥត្ថត្តំ

ជរំ(២) សិតា យញ្ញមកប្បយឹសុ ។

---

១ ប. អាគមឹ ។ ២ បោរាណបោត្ថកេ ឧរត្តំបិ ទិស្សតិ ។

# បុណ្ណកប្បញ្ហា ទី ៣

(១១៤) (បុណ្ណកមាណព ដ៏មានអាយុ ទូលសួរថា) ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយបញ្ហា ទើបមកសួរព្រះអង្គ អ្នកមិនញាប់ញ័រ ទ្រង់ឃើញនូវធម៌ជាឫសគល់ ពួកមនុស្ស ជាច្រើន ក្នុងលោកនេះ គឺឥសី ក្សត្រិយ៍ ព្រាហ្មណ៍ អាស្រ័យនូវអ្វី ទើបរៀបចំនូវយញ្ញ ដល់ពួកទេវតា ខ្ញុំព្រះអង្គ ទូលសួរនូវដំណើរនោះ សូមព្រះអង្គត្រាស់ប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គឲ្យបាន ៗ

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលបុណ្ណកៈ) ពួកមនុស្សទាំងនេះ ជាច្រើន ក្នុងលោកនេះ គឺឥសី ក្សត្រិយ៍ ព្រាហ្មណ៍ បានរៀបចំនូវយញ្ញ ដល់ពួកទេវតា ម្នាលបុណ្ណកៈ ពួកមនុស្សទាំងនេះ កាលប្រាថ្នានូវភាពនៃហេតុនេះ ៗ សុទ្ធតែអាស្រ័យនូវធម៌ ដែលទ្រុឌទ្រោម ទើបបានរៀបចំយញ្ញ ៗ

យេ កេចិមេ ឥសយោ មនុជា (ឥច្ចាយស្មា បុណ្ណកោ)

ខត្តិយា ព្រាហ្មណា ទេវតានំ

យញ្ញមកប្បយិំសុ បុថូធ លោកេ

កច្ចិស្សុ(១) តេ ភគវា (យញ្ញបថេ) អប្បមត្តា

អតារុ ជាតិញ្ច ជរញ្ច មារិស

បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។

អាសីសន្តិ ថោមយន្តិ (អភិជប្បន្តិ)

ជុហន្តិ (បុណ្ណកាតិ ភគវា)

កាមាភិជប្បន្តិ បដិច្ច លាភំ

តេ យាជយោគា ភវរាគរត្តា

នាតរិំសុ ជាតិជរន្តិ ព្រូមិ ។

តេ ចេ នាតរិំសុ យាជយោគា (ឥច្ចាយស្មា បុណ្ណកោ)

យញ្ញេហិ ជាតិញ្ច ជរញ្ច មារិស

---

១ ម. កិច្ចស្សុ ។

(បុណ្ណមាណព ដ៏មានអាយុ ទូលសួរថា) ពួកមនុស្សបំពួកខ្លះ ជាច្រើន ក្នុងលោកនេះ គឺឥសី ក្សត្រិយ៍ ព្រាហ្មណ៍ បានរៀបបំបួងយ័ញ្ញ ដល់ពួកទេវតា បពិត្រព្រះអង្គនិទ្ទុក្ខ ពួកមនុស្សអម្បាលនោះ បើមិនប្រមាទ (ក្នុងគន្លងនៃយ័ញ្ញ) តើបានឆ្លងផុតជាតិនឹងជរាដែរឬ ខ្ញុំព្រះអង្គ សូមទូលសួរដំណើរនោះ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យបាន ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលបុណ្ណកៈ) ពួកមនុស្សអម្បាលនោះ ប្រកបក្នុងការបូជា ត្រេកអរដោយអំណាចនៃភវរាគៈ ទើបប៉ុនប៉ង សរសើរ (ជាប់ចំពាក់) បូជា ជ្រុលជ្រប់ក្នុងកាម ព្រោះអាស្រ័យលាភ តថាគតពោលថា អ្នកបូជាយ័ញ្ញអម្បាលនោះ មិនបានឆ្លងជាតិនឹងជរាទៅបានឡើយ ។

(បុណ្ណមាណពដ៏មានអាយុ ទូលសួរថា) បពិត្រព្រះអង្គនិទ្ទុក្ខ បើពួកអ្នកបូជាយ័ញ្ញទាំងនោះ ឆ្លងជាតិជរាដោយយ័ញ្ញទាំងឡាយមិនរួចទេ

អថ កោ ចរហិ ទេវមនុស្សលោកេ
អតារិ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។
សង្ខាយ លោកស្មឹ បរោវរានិ(១) (បុណ្ណកាតិ ភគវា)
យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ
សន្តោ វិធូមោ អនីឃោ និរាសោ
អតារិ សោ ជាតិជរន្តិ(២) ព្រូមីតិ ។

បុណ្ណកមាណវកបញ្ហា តតិយា ។

## ចតុត្ថំ មេត្តគូបញ្ហា

(៦១៥) បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ (ឥច្ចាយស្មា មេត្តគូ)
មញ្ញាមិ តំ វេទគុំ ភាវិតត្តំ
កុតោ នុ ទុក្ខា សមុទាគតា ឥមេ(៣)
យេ កេចិ លោកស្មឹ អនេករូបា ។

---

១ ម. បរោបរានិ ។ ២ ឱ. ម. ជាតិជរន្តិ ។ ៣ ឱ. ម. សមុទាគតាមេ ។

ដូច្នេះ តើនរណាក្នុងទេវលោក មនុស្សលោក ទើបឆ្លងជាតិនិងជរា ទៅបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទូលសួរដំណើរនោះ សូមព្រះអង្គត្រាស់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យបាន ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលបុណ្ណកៈ) បុគ្គលណាមិនមានកិលេសជាគ្រឿងញាប់ញ័រ ក្នុងលោកណាមួយ ព្រោះពិចារណាឃើញនូវធម៌ដ៏ខ្ពស់និងទាប ក្នុងលោក តថាគត ពោលថាបុគ្គលនោះ ជាអ្នកស្ងប់ ប្រាសចាកផ្សែងគឺទុច្ចរិត មិនមានសេចក្តីតានតឹង មិនមានសេចក្តីប្រាថ្នា តែងឆ្លងជាតិនិងជរាផុតបាន ។

ចប់ បុណ្ណកមាណវកបញ្ហា ទី ៣ ។

## មេត្តគូបញ្ហា ទី ៤

(១១៥) (មេត្តគូមាណពដ៏មានអាយុ ទូលសួរថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមទូលសួរព្រះអង្គ សូមព្រះអង្គត្រាស់ប្រាប់សេចក្តីនោះ ដល់ខ្ញុំព្រះអង្គឲ្យបាន ខ្ញុំព្រះអង្គសំគាល់ឃើញថា ព្រះអង្គជាអ្នកដល់វេទ ជាអ្នកមានខ្លួនបានអប់រំហើយ សេចក្តីទុក្ខទាំងឡាយណាមួយ ជាច្រើនប្រការ ក្នុងលោកនេះ កើតមកអំពីអ្វី ។

ទុក្ខស្ស វេ(១) មំ បភវំ អបុច្ឆសិ (មេត្តគូតិ ភគវា)

តន្តេ បវក្ខាមិ យថា បជានំ

ឧបធិនិទានា បភវន្តិ ទុក្ខា

យេ កេចិ លោកស្មិំ អនេករូបា

យោ វេ អវិទ្វា ឧបធឹ ករោតិ

បុនប្បុនំ ទុក្ខមុបេតិ មន្ទោ

តស្មា បជានំ ឧបធឹ ន កយិរា

ទុក្ខស្ស ជាតិប្បភវានុបស្សី ។

យំ តំ អបុច្ឆិម្ហ អកិត្តយី នោ

អញ្ញំ តំ បុច្ឆាម(២) តទិង្ឃ ព្រូហិ

កថំ នុ ធីរា វិតរន្តិ ឱឃំ

ជាតិជរំ សោកបរិទ្ទវញ្ច(៣)

តំ មេ មុនី សាធុ វិយាករោហិ

តថា ហិ តេ វិទិតោ ឯស ធម្មោ ។

---

១ ម· ចេ ។ ២ ឱ. អញ្ញំតំ បុច្ឆាមិ ។ ម. អញ្ញន្តំ បុច្ឆាម ។ ៣ ម. សោកបរិទេវញ្ច ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលមេត្តគូ) អ្នកបានសួរអំពីដែនកើតនៃទុក្ខ ចំពោះតថាគត តថាគតនឹងប្រាប់ដែនកើតនៃទុក្ខនោះដល់អ្នក តាមដែលបានដឹងច្បាស់ សេចក្តីទុក្ខទាំងឡាយណាមួយច្រើនប្រការ ក្នុងលោកនេះ រមែងកើតឡើងព្រោះឧបធិ បុគ្គលណា ជាអ្នកល្ងង់ខ្លៅ មិនចេះដឹង តែងធ្វើឧបធិឲ្យកើតឡើង បុគ្គលនោះ រមែងបានទុក្ខរឿយ ៗ ព្រោះហេតុនោះបុគ្គលកាលដឹងច្បាស់ ពិចារណាឃើញរឿយ ៗ នូវកំណើតជាដែនកើតនៃទុក្ខ មិនត្រូវធ្វើឧបធិឡើយ ។

ពួកខ្ញុំព្រះអង្គបានទូលសួរបញ្ហាណា ព្រះអង្គក៏បានដោះស្រាយបញ្ហានោះ ពួកខ្ញុំព្រះអង្គ សូមទូលសួរបញ្ហាដទៃទៀត សូមព្រះអង្គសំដែង អ្នកប្រាជ្ញទាំងឡាយ រមែងឆ្លងផុតឱឃៈផង ជាតិនិងជរាផង សោកនិងសេចក្តីខ្សឹកខ្សួលផង ដោយហេតុដូចម្តេច សូមព្រះអង្គ ជាព្រះមុនី ដោះស្រាយបញ្ហានោះ ដល់ខ្ញុំព្រះអង្គ ព្រោះថា ធម៌នុ៎ះ ព្រះអង្គជ្រាបច្បាស់ហើយ ។

កិត្តយិស្សាមិ តេ ធម្មំ(មេត្តគូតិ ភគវា) ទិដ្ឋេ ធម្មេ អនីតិហំ

យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

តញ្ចាហំ អភិនន្ទាមិ មហេសិ ធម្មមុត្តមំ

យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

យំ កិញ្ចិ(១) សម្បជានាសិ (មេត្តគូតិ ភគវា)

ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ

ឯតេសុ នន្ទិញ្ច និវេសនញ្ច

បនុជ្ជ វិញ្ញាណំ ភវេ ន តិដ្ឋេ

ឯវំវិហារី សតោ អប្បមត្តោ

ភិក្ខុ ចរំ ហិត្វា មមាយិតានិ

ជាតិជរំ សោកបរិទ្ទវញ្ច

ឥធេវ វិទ្វា បជហេយ្យ ទុក្ខំ ។

---

១ ម. ឥ យំ កិញ្ចិ ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលមេត្តគូ) បុគ្គលមានសតិ គួរដឹងច្បាស់នូវធម៌ណា ហើយឆ្លងតណ្ហា ដែលផ្សាយទៅផ្សេង ៗ ក្នុងលោកបាន តថាគតនឹងសំដែងនូវធម៌នោះ ដែលតថាគត ជាក់ច្បាស់ ក្នុងខន្ធ ក្នុងបច្ចុប្បន្ននេះ ដល់អ្នក ។

បពិត្រព្រះអង្គអ្នកស្វែងរកនូវគុណដ៏ធំ បុគ្គលអ្នកមានសតិ គួរដឹងច្បាស់នូវធម៌ណា ហើយឆ្លងតណ្ហាដែលផ្សាយទៅផ្សេង ៗ ក្នុងលោកបាន ខ្ញុំព្រះអង្គត្រេកអរចំពោះធម៌ដ៏ឧត្តមនោះ ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលមេត្តគូ) អ្នកដឹងនូវហេតុណាមួយ ក្នុងចំណែកខាងលើ (អនាគត) ក្នុងចំណែកខាងក្រោម(អតីត) ក្នុងចំណែកទទឹងឬកណ្តាល (បច្ចុប្បន្ន) អ្នកចូរបន្ទោបង់សេចក្តីត្រេកអរនឹងសេចក្តីប្រកាន់មាំ ក្នុងចំណែកនៃហេតុនោះចេញ ទើបវិញ្ញាណ (របស់អ្នក) មិនតាំងនៅក្នុងភព ភិក្ខុមានធម៌ជាគ្រឿងនៅយ៉ាងនេះ មានសតិ មិនធ្វេសប្រហែស លះបង់កិលេសដែលប្រកាន់ថាជារបស់អញ ដឹងច្បាស់ ក្នុងអត្តភាពនេះ ហើយ ទើបលះបង់នូវទុក្ខ គឺជាតិ ជរានឹងសោកខ្សឹកខ្សួលបាន ។

សុត្តនិបាតេ បញ្ចមស្ស បារាយនវគ្គស្ស ចតុត្ថំ មេត្តគូបញ្ហា

ឯតាភិនន្ទាមិ វចោ មហេសិនោ

សុកិត្តិតំ គោតម នូបធីកំ

អទ្ធា ហិ ភគវា បហាសិ ទុក្ខំ

តថា ហិ តេ វិទិតោ ឯស ធម្មោ ។

តេ ចាបិ នូន បជហេយ្យុ ទុក្ខំ

យេ ត្វំ មុនី អដ្ឋិតំ ឱវទេយ្យ

តំ តំ នមស្សាមិ(១) សមេច្ច នាគ

អប្បេវ មំ (ភគវា) អដ្ឋិតំ ឱវទេយ្យ ។

យំ ព្រាហ្មណំ វេទគុំ អភិជញ្ញា(២)

អកិញ្ចនំ កាមភវេ អសត្តំ

អទ្ធា ហិ សោ ឱឃមិមំ អតារិ

តិណ្ណោ ច បារំ អខិលោ អកង្ខោ

វិទ្វា ច សោ(៣) វេទគូ នរោ ឥធ

ភវាភវេ សង្គមិមំ វិសជ្ជ

---

១ ម. ន បស្សាមិ ។ ២ ឱ. វេទគុំ អាភិជញ្ញា ។ ម. វេទគុមភិជញ្ញា ។ ៣ ម. យោ ។

បពិត្រព្រះគោតម ខ្ញុំព្រះអង្គត្រេកអរនឹងព្រះវាចានោះ របស់ព្រះអង្គជាអ្នកស្វែងរកនូវគុណដ៏ធំ ព្រះនិព្វាន ដែលមិនមានឧបធិ ព្រះអង្គទ្រង់សំដែងប្រពៃហើយ បពិត្រព្រះមានព្រះភាគ ព្រះអង្គលះទុក្ខបានដោយពិត ព្រោះធម៌នោះ ព្រះអង្គជ្រាបច្បាស់ហើយ ។ បពិត្រព្រះមុនី ព្រះអង្គប្រដៅពួកជនណា ដោយមាំមួន សូម្បីពួកជនទាំងនោះ ក៏លះទុក្ខនោះ បានដោយពិត បពិត្រព្រះពុទ្ធនាគ ព្រោះហេតុនោះ ខ្ញុំព្រះអង្គទើបបានមក នមស្ការចំពោះព្រះអង្គ សូម (ព្រះមានព្រះភាគ) ប្រដៅខ្ញុំព្រះអង្គ ដោយមាំមួនចុះ ។

អ្នកស្គាល់ច្បាស់ នូវព្រាហ្មណ៍ណា ដល់នូវវេទ មិនមានកិលេសគ្រឿងកង្វល់ មិនជាប់ចំពាក់ ក្នុងកាមភព ព្រាហ្មណ៍នោះ ឈ្មោះថា បានឆ្លងឱឃៈនេះដោយពិត ជនណាមិនមានសេចក្តីរឹងត្អឹង មិនមានសេចក្តីសង្ស័យ បានឆ្លងនូវត្រើយ គឺកិលេស ជននោះឈ្មោះថាជាអ្នកដឹងច្បាស់ អ្នកដល់នូវវេទ ក្នុងអត្តភាពនេះ ឈ្មោះថា លះធម៌ដែលជាហេតុជាប់ចំពាក់ ក្នុងភពតូចភពធំ

សោ វីតតណ្ហោ អនីឃោ និរាសោ
អតារិ សោ ជាតិជរន្តិ ព្រូមីតិ ។

មេត្តគូមាណវកបញ្ហា ចតុត្ថា ។

## បញ្ចមី ធោតកបញ្ហា

(១១៦) បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ (ឥច្ចាយស្មា ធោតកោ)
វាចាភិកង្ខាមិ មហេសិ តុយ្ហំ
តវ សុត្វាន និគ្ឃោសំ សិក្ខេ និព្វានមត្តនោ ។
តេនហាតប្បំ ករោហិ (ធោតកាតិ ភគវា)
ឥធេវ និបកោ សតោ
ឥតោ សុត្វាន និគ្ឃោសំ សិក្ខេ និព្វានមត្តនោ ។
បស្សាមហំ ទេវមនុស្សលោកេ
អកិញ្ចនំ ព្រាហ្មណំ ឥរិយមានំ
តំ តំ នមស្សាមិ សមន្តចក្ខុ

ជាអ្នកប្រាសចាកតណ្ហា មិនមានសេចក្តីតានតឹង មិនមានសេចក្តីប្រាថ្នា តថាគតពោលថា អ្នកនោះបានឆ្លងផុតជាតិជរាហើយ ។

ចប់ មេត្តគូមាណវកបញ្ហា ទី ៤ ។

# ធោតកបញ្ហា ទី ៥

(១១៦) (ធោតកមាណពដ៏មានអាយុ ទូលសួរថា) បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ក្រាបទូលសួរព្រះអង្គ សូមព្រះអង្គសំដែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គស្វែងរកគុណដ៏ធំ ខ្ញុំព្រះអង្គប្រាថ្នា (ស្តាប់)ព្រះវាចា របស់ព្រះអង្គ បុគ្គលបានស្តាប់ព្រះពុទ្ធដីកា ជាសូរសីហនាទ របស់ព្រះអង្គហើយ នឹងសិក្សាធម៌ជាគ្រឿងរំលត់កិលេសរបស់ខ្លួន ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលធោតកៈ) បើដូច្នោះអ្នកចូរជាបុគ្គលមានបញ្ញាចាស់ខ្លួន មានស្មារតី ធ្វើសេចក្តីព្យាយាមក្នុងសាសនានេះចុះ បុគ្គលបានស្តាប់ពាក្យ អំពីសំណាក់នៃតថាគតនេះហើយ គប្បីសិក្សាធម៌ជាគ្រឿងរំលត់កិលេសរបស់ខ្លួន ។

ខ្ញុំព្រះអង្គ បានឃើញព្រះអង្គ ជាព្រាហ្មណ៍ ឥតមានកង្វល់ ត្រាច់ទៅ ក្នុងទេវលោកនិងមនុស្សលោក បពិត្រព្រះអង្គ មានចក្ខុជុំវិញ ខ្ញុំព្រះអង្គ សូមនមស្ការព្រះអង្គ

បមុញ្ច មំ សក្ក កថង្កថាហិ ។
នាហំ សមិស្សាមិ(១) បមោចនាយ
កថង្កថី(២) ធោតក កញ្ចិ លោកេ
ធម្មញ្ច សេដ្ឋំ អាជានមានោ(៣)
ឯវំ តុំ(៤) ឱឃមិមំ តរេសិ ។

អនុសាស ព្រហ្មេ ការុណាយមានោ
វិវេកធម្មំ យមហំ វិជញ្ញំ
យថាហំ អាកាសោ ច អព្យាបជ្ជមានោ
ឥធេវ សន្តោ អសិតោ ចរេយ្យំ ។

កិត្តយិស្សាមិ តេ សន្តិំ (ធោតកាតិ ភគវា)
ទិដ្ឋេ ធម្មេ អនីតិហំ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។
តញ្ចាហំ អភិនន្ទាមិ មហេសិ សន្តិមុត្តមំ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

---

១ ឱ. សហិស្សាមិ ។ ម. សហិស្សាមិ ។ ២ ម. កថំកថី ។ ៣ ម. អភិជា-នមានោ ។ ៤ ខ. ម. តុវំ ។

បពិត្រព្រះអង្គជាសក្យពង្ស សូមព្រះអង្គដោះខ្ញុំព្រះអង្គ ចេញចាកសេចក្តីសង្ស័យទាំងឡាយ ។

ម្នាលធោតកៈ តថាគត មិនអាច ដើម្បីនឹងដោះអ្នកណាមួយក្នុងលោក ដែលមានសេចក្តីសង្ស័យបានទេ ប៉ុន្តែកាលបើអ្នក ដឹងធម៌ដ៏ប្រសើរ យ៉ាងនេះ នឹងឆ្លងឱឃៈនេះបាន ។

បពិត្រព្រះអង្គ ជាព្រហ្ម សូមព្រះអង្គទ្រង់ព្រះករុណាប្រៀនប្រដៅវិវេកធម៌ឲ្យខ្ញុំព្រះអង្គដឹងច្បាស់ ដើម្បីខ្ញុំព្រះអង្គមិនទើសទាល់ដូចអាកាស ជាអ្នកស្ងប់ មិនអាស្រ័យដោយកិលេស ក្នុងពេលនេះ ។

(ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាល ធោតកៈ) បុគ្គលមានសតិគួរដឹងច្បាស់នូវសន្តិបទណា ហើយឆ្លងតណ្ហាដែលផ្សាយទៅក្នុងលោកបាន តថាគត នឹងសំដែងនូវសន្តិបទនោះ ដែលតថាគតជាក់ច្បាស់ក្នុងខ្លួន ក្នុងបច្ចុប្បន្ន ដល់អ្នក ។

បពិត្រព្រះអង្គអ្នកស្វែងរកនូវគុណដ៏ធំ បុគ្គលមានសតិ គួរដឹងច្បាស់នូវសន្តិបទណា ហើយឆ្លងតណ្ហា ដែលផ្សាយទៅផ្សេងៗ ក្នុងលោកបាន ខ្ញុំព្រះអង្គត្រេកអរ ចំពោះសន្តិបទដ៏ស្ងប់ឧត្តមនោះ ។

យំកិញ្ចិ សម្បជានាសិ (ធោតកាតិ ភគវា)
ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ
ឯតំ(១) វិទិត្វា សង្គោតិ លោកេ
ភវាភវាយ មាកាសិ តណ្ហន្តិ ។

ធោតកមាណវកបញ្ហា បញ្ចមី ។

## ឆដ្ឋី ឧបសីវបញ្ហា

(១១៧) ឯកោ អហំ សក្ក មហន្តមោឃំ (ឥច្ចាយស្មា ឧបសីវោ)

អនិស្សិតោ នោ វិសហាមិ តារិតុំ
អារម្មណំ ព្រូហិ សមន្តចក្ខុ
យំ និស្សិតោ ឱឃមិមំ តរេយ្យំ ។

អាកិញ្ចញ្ញំ បេក្ខមានោ សតិមា (ឧបសីវាតិ ភគវា)
នត្ថីតិ និស្សាយ តរស្សុ ឱឃំ
កាមេ បហាយ វិរតោ កថាហិ
តណ្ហក្ខយំ រត្តមហាភិបស្ស(២) ។

---

១ ឱ. ប. ឯតំ ។ ២ ឱ. នត្តមហោភិបស្ស ។ ប. រត្តមហំ វិបស្ស ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលធោតកៈ) អ្នកដឹងច្បាស់អារម្មណ៍ណាមួយ ក្នុងចំណែកខាងលើ(អនាគត)ក្នុងចំណែកខាងក្រោម (អតីត) និងក្នុងចំណែកទទឹងឬកណ្ដាល (បច្ចុប្បន្ន) ដឹងច្បាស់ថាជាអារម្មណ៍ជាប់ចំពាក់ នៅក្នុងលោក យ៉ាងនេះហើយ អ្នកកុំធ្វើតណ្ហា ក្នុងភពតូចភពធំ ទៀតឡើយ ។

ចប់ ធោតកមាណវកបញ្ហា ទី ៥ ។

## ឧបសីវមាណវកបញ្ហា ទី ៦

(១១៧) (ឧបសីវមាណពដ៏មានអាយុ ទូលសួរថា)បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គម្នាក់ឯង មិនអាស្រ័យ (ធម៌ ឬបុគ្គល) ទើបមិនអាចឆ្លងនូវឱឃៈដ៏ធំបាន បពិត្រព្រះអង្គមានចក្ខុជុំវិញ សូមព្រះអង្គសំដែងនូវអារម្មណ៍ គឺនិស្ស័យ ដែលនាំឲ្យខ្ញុំព្រះអង្គអាស្រ័យ ហើយឆ្លងឱឃៈនេះ ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ)អ្នកចូរមានសតិសម្លឹងអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យដោយបរិកម្មថា មិនមានៗ ហើយឆ្លងឱឃៈចុះ អ្នកចូរលះកាមទាំងឡាយ វៀរចាកសេចក្ដីសង្ស័យចេញ ចូរពិចារណាធម៌ជាទីអស់ទៅនៃតណ្ហា ទាំងយប់ទាំងថ្ងៃចុះ ។

សព្វេសុ កាមេសុ យោ វីតរាគោ (ឥច្ចាយស្មា ឧបសីវោ)
អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ
សញ្ញាវិមោក្ខេ បរមេធិមុត្តោ
តិដ្ឋេ នុ សោ តត្ថ អនានុយាយី(១) ។

សព្វេសុ កាមេសុ យោ វីតរាគោ (ឧបសីវាតិ ភគវា)
អាកិញ្ចញ្ញំ និស្សិតោ ហិត្វមញ្ញំ
សញ្ញាវិមោក្ខេ បរមេធិមុត្តោ
តិដ្ឋេយ្យ សោ តត្ថ អនានុយាយី ។

តិដ្ឋេ ចេ សោ តត្ថ អនានុយាយិ
បូគម្បិ វស្សានំ សមន្តចក្ខុ
តត្ថេវ សោ សីតិ សិយាធិមុត្តោ
ភវេថ(២) វិញ្ញាណំ តថាវិធស្ស(៣) ។

១ ឱ. អនានុយាយី ។ ២ ម. ចវេថ ។ ៣ ម. តថាវិស្ស ។

(ឧបសីវមាណពដ៏មានអាយុ ទូលសួរថា) អ្នកណាប្រាសចាកតម្រេក ក្នុងកាមទាំងឡាយទាំងពួង លះបង់ឈានដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ អ្នកនោះមិនសាបសូន្យ ឋិតនៅក្នុងអាកិញ្ចញ្ញាយតនៈនោះបានដែរឬ ។

(ព្រះមានព្រះភាគត្រាស់ថា ម្នាលឧបសីវៈ) អ្នកណាប្រាសចាកតម្រេកក្នុងកាមទាំងឡាយទាំងពួង លះឈានដទៃ អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន ចុះចិត្តស៊ប់ក្នុងសញ្ញាវិមោក្ខដ៏ប្រសើរ បុគ្គលនោះជាអ្នកមិនសាបសូន្យ គប្បីឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានបាន ។

បពិត្រព្រះអង្គមានចក្ខុជុំវិញ បើអ្នកនោះជាអ្នកមិនសាបសូន្យ គប្បីឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ អស់ប្រជុំនៃឆ្នាំ ជាច្រើន អ្នកនោះ ជាអ្នកមានចិត្តចុះស៊ប់ត្រជាក់ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ឬវិញ្ញាណ របស់បុគ្គលមានសភាពដូច្នោះ គប្បីឃ្លាតទៅឬ ។

អច្ចិ យថា វាតវេគេន ខិត្តំ[១] (ឧបសីវាតិ ភគវា)
អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។
ឯវំ មុនី នាមកាយា វិមុត្តោ
អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។

អត្ថង្គតោ សោ ឧទ វា សោ នត្ថិ
ឧទាហុ វេ សស្សតិយា អរោគោ
តម្មេ មុនី សាធុ វិយាករោហិ
តថា ហិ តេ វិទិតោ ឯស ធម្មោ ។

អត្ថង្គតស្ស ន បមាណមត្ថិ (ឧបសីវាតិ ភគវា)
យេន នំ វជ្ជុំ តំ តស្ស[២] នត្ថិ
សព្វេសុ ធម្មេសុ សមូហតេសុ
សមូហតា វាទបថាបិ សព្វេតិ ។

ឧបសីវមាណវកប្បញ្ហា ឆដ្ឋំ ។

---

១ ខ. ខិត្តោ ។ ប. ខិត្តា ។ ២ ប. វជ្ជុន្តិ តស្ស ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ) អណ្តាតភ្លើងដែលត្រូវកំឡាំងខ្យល់បក់ រមែងរលត់ទៅ មិនដល់នូវការរាប់ (ថាទៅកាន់ទីណាទេ) យ៉ាងណាមិញ មុនីរួចស្រឡះហើយ ចាកនាមកាយ រមែងរលត់ទៅ មិនដល់នូវការរាប់ (ថាទៅកាន់ទីណា) យ៉ាងនោះដែរ ។

បុគ្គលនោះរលត់ទៅ លែងមាន ឬថា ឥតមានមោះមៃ ដោយការតាំងនៅទៀងទាត់ សូមព្រះមុនី សំដែងសេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ព្រោះថា ធម៌នោះ ព្រះអង្គជ្រាបច្បាស់ហើយ ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ) បុគ្គលដែលរលត់ទៅហើយ នឹងប្រមាណពុំបានទេ ពួកជនពោលចំពោះបុគ្គលនោះ ព្រោះកិលេសណា កិលេសនោះ របស់បុគ្គលនោះមិនមានទេ កាលធម៌ទាំងឡាយ ដែលបុគ្គលនោះកំចាត់អស់ហើយ សូម្បីគន្លងនៃពាក្យទាំងអស់ ក៏បុគ្គលនោះកំចាត់អស់ហើយ ។

ចប់ ឧបសីវមាណវកបញ្ហាទី ៦ ។

## សត្តមា នន្ទបុច្ឆា

(១១៨) សន្តិ លោកេ មុនយោ (ឥច្ចាយស្មា នន្ទោ)

ជនា វទន្តិ តយិទំ កថំសុ

ញាណូបបន្នំ មុនិ នោ(១) វទន្តិ

ឧទាហុ វេ ជីវិតេនូបបន្នំ ។

ន ទិដ្ឋិយា ន សុតិយា ន ញាណេន (ន សីលព្វតេន)

មុនីធ នន្ទ កុសលា វទន្តិ

វិសេនិកត្វា អនីឃា និរាសា

ចរន្តិ(២) យេ តេ មុនយោតិ ព្រូមិ ។

យេ កេចិមេ សមណព្រាហ្មណាសេ (ឥច្ចាយស្មា នន្ទោ)

ទិដ្ឋេ សុតេនាបិ វទន្តិ សុទ្ធិំ

សីលព្វតេនាបិ វទន្តិ សុទ្ធិំ

---

១ ឱ. នោ មុនី ។ ២ ឱ. ម. ចរន្តិ ។

# នន្ទបញ្ហា ទី ៧

(១១៨) (នន្ទមាណពដ៏មានអាយុ ទូលសួរថា) ជនទាំងឡាយតែងពោលថា ពួកមុនី រមែងមាននៅក្នុងលោក ដំណើរនោះតើយ៉ាងណា ជនទាំងនោះ ហៅបុគ្គលដែលប្រកបដោយញាណថា មុនី ឬហៅបុគ្គល ដែលប្រកបដោយការចិញ្ចឹមជីវិត ថាជា មុនី ។

(ព្រះមានព្រះភាគដោះស្រាយថា ម្នាលនន្ទ) ពួកជនអ្នកឈ្លាសវៃ ក្នុងលោកនេះ មិនហៅថា មុនី ព្រោះការឃើញ ព្រោះការស្ដាប់ ព្រោះការដឹង ឬព្រោះសីលនិងវ័ត) តែប៉ុណ្ណោះទេ ជនទាំងឡាយណា ធ្វើខ្លួនឲ្យប្រាសចាកមារសេនា ជាអ្នកមិនតានតឹង មិនមានសេចក្ដីប្រាថ្នា តថាគត ហៅជនទាំងនោះថា មុនី ។

(នន្ទមាណពដ៏មានអាយុ ទូលសួរថា) សមណព្រាហ្មណ៍ពួកខ្លះទាំងនេះ តែងពោលសេចក្ដីបរិសុទ្ធិ ព្រោះអារម្មណ៍ដែលឃើញខ្លះ ដែលស្ដាប់ខ្លះ ពោលសេចក្ដីបរិសុទ្ធិ ព្រោះសីលវ័តខ្លះ

អនេករូបេន វទន្តិ សុទ្ធិំ ។
កច្ចិស្សុ(១) តេ (ភគវា) តត្ថ យតា ចរន្តា
អតារុ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។
យេ កេចិមេ សមណព្រាហ្មណាសេ (នន្ទាតិ ភគវា)
ទិដ្ឋេ សុតេនាបិ វទន្តិ សុទ្ធិំ
សីលព្វតេនាបិ វទន្តិ សុទ្ធិំ
អនេករូបេន វទន្តិ សុទ្ធិំ
កិញ្ចាបិ តេ តត្ថ យតា ចរន្តិ(២)
នាតរិំសុ ជាតិជរន្តិ ព្រូមិ ។
យេ កេចិមេ សមណព្រាហ្មណាសេ (ឥច្ចាយស្មា នន្ទោ)
ទិដ្ឋេ សុតេនាបិ វទន្តិ សុទ្ធិំ
សីលព្វតេនាបិ វទន្តិ សុទ្ធិំ

---

១ ឱ. កច្ចិំសុ ។ ២ ម. មេ តត្ថ យតា វទន្តិ ។

ពោលសេចក្តីបរិសុទ្ធិ ព្រោះវិធីច្រើនយ៉ាងខ្លះ ។ (បពិត្រព្រះមានព្រះភាគ) អ្នកទិដ្ឋិក ពួកសមណព្រាហ្មណ៍ទាំងនោះ កាលបើប្រព្រឹត្តក្នុងវត្ត ដែលឃើញថាជាគ្រឿងបរិសុទ្ធិនោះ តើបានឆ្លងផុតជាតិនិងជរាបានដែរឬ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ សូមព្រះអង្គសំដែងប្រាប់ សេចក្តីនោះ ដល់ខ្ញុំព្រះអង្គ ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលនន្ទ) សមណ-ព្រាហ្មណ៍ទាំងឡាយពួកខ្លះទាំងនេះ ពោលថា សេចក្តីបរិសុទ្ធិ ព្រោះអារម្មណ៍ដែលឃើញ និងអារម្មណ៍ដែលស្តាប់ខ្លះ ពោលថា សេចក្តីបរិសុទ្ធិ ព្រោះសីលនិងវត្តខ្លះ ពោលថាសេចក្តីបរិសុទ្ធិ ព្រោះវិធីជាច្រើនយ៉ាងខ្លះ សមណព្រាហ្មណ៍ទាំងនោះរមែងប្រព្រឹត្តក្នុងវត្ត ដែលឃើញថាជាគ្រឿងបរិសុទ្ធិនោះក៏មែនពិតហើយ ប៉ុន្តែតថាគតពោលថា សមណព្រាហ្មណ៍ទាំងនោះមិនបានឆ្លងផុតជាតិនិងជរាបានឡើយ ។

(នន្ទមាណពដ៏មានអាយុ ទូលសួរទៀតថា) សមណ-ព្រាហ្មណ៍ទាំងឡាយ ពួកខ្លះទាំងនេះ ពោលថា សេចក្តីបរិសុទ្ធិ ព្រោះអារម្មណ៍ ដែលឃើញ និងអារម្មណ៍ ដែលស្តាប់ខ្លះ ពោលថា សេចក្តីបរិសុទ្ធិ ព្រោះសីលនិងវត្តខ្លះ

អនេករូបេន វទន្តិ សុទ្ធឹ
តេ(១) ចេ មុនិ ព្រូសិ អនោឃតិណ្ណេ
អថ កោ ចរហិ ទេវមនុស្សលោកេ
អតារិ ជាតិញ្ច ជរញ្ច មារិស
បុច្ឆាមិ តំ ភគវា ព្រូហិ មេ តំ ។
នាហំ សព្វេ សមណព្រាហ្មណាសេ (នន្ទាតិ ភគវា)
ជាតិជរាយ និវុតាតិ ព្រូមិ
យេ សីធ ទិដ្ឋំ វ សុតំ មុតំ វា
សីលព្វតំ វាបិ បហាយ សព្វំ
អនេករូបម្បិ បហាយ សព្វំ
តណ្ហំ បរិញ្ញាយ អនាសវា យេ(២)
តេ វេ នរា ឱឃតិណ្ណាតិ ព្រូមិ ។
ឯតាភិនន្ទាមិ វចោ មហេសិនោ
សុកិត្តិតំ គោតម នូបធីកំ

---

១ ឧ. ស ។ ២ ឧ. ម. សេ ។

ពោលថា សេចក្ដីបរិសុទ្ធិ ព្រោះវិធីជាច្រើនយ៉ាងនេះ បពិត្រព្រះអង្គជាព្រះមុនី បើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងឱឃៈមិនបានទេ បពិត្រព្រះអង្គនិទ្ទុក្ខ កាលបើដូច្នេះ តើនរណាក្នុងទេវលោក ឬមនុស្សលោក ទើបឆ្លងផុតជាតិនិងជរា ទៅបាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ សូមទូលសួរព្រះអង្គ សូមព្រះអង្គ សំដែងប្រាប់សេចក្ដីនោះ ដល់ខ្ញុំព្រះអង្គ ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលនន្ទ) តថាគតមិនបាន ពោលថាពួកសមណព្រាហ្មណ៍ទាំងអស់ ត្រូវជាតិជរាគ្របសង្កត់ទេ តថាគត ពោលថា ពួកសមណព្រាហ្មណ៍ណា ក្នុងលោកនេះ លះអារម្មណ៍ដែលខ្លួនបានឃើញ បានឮ បានប៉ះពាល់ទាំងសីល-វ័ត លះបង់វិធី ជាច្រើនទាំងអស់ចេញ ឬពួកសមណព្រាហ្មណ៍ណាកំណត់ដឹងនូវតណ្ហា មិនមានអាសវៈ ពួកជននោះឯង ឈ្មោះថា ឆ្លងផុតឱឃៈបាន ។

ខ្ញុំព្រះអង្គ ត្រេកអរ ចំពោះព្រះវាចានុ៎ះ របស់ព្រះអង្គ
អ្នកស្វែងរកគុណដ៏ធំ បពិត្រព្រះគោតម ព្រះនិព្វាន
ដែលមិនមានឧបធិ ដែលព្រះអង្គបានសំដែងទុកល្អហើយ

យេសីធ ទិដ្ឋំ វ សុតំ មុតំ វា
សីលព្វតំ វាបិ បហាយ សព្វំ
អនេករូបម្បិ បហាយ សព្វំ
តណ្ហំ បរិញ្ញាយ អនាសវា យេ[១]
អហម្បិ តេ ឱឃតិណ្ណាតិ ព្រូមីតិ ។

នន្ទមាណវកបញ្ហា សត្តមា ។

## អដ្ឋមា ហេមកបញ្ហា

(១០៨៤) យេ មេ បុព្វេ វិយាកំសុ (ឥច្ចាយស្មា ហេមកោ)
(ហុរំ គោតមសាសនា)
ឥច្ចាសិ ឥតិ ភវិស្សតិ សព្វំ តំ ឥតិហីតិហំ
សព្វំ តំ តក្កវឌ្ឍនំ
(នាហំ តត្ថ អភិរមឹ)
ត្វញ្ច មេ ធម្មមក្ខាហិ តណ្ហានិគ្ឃាតនំ មុនិ
យំ វិទិត្វា សតោ ចរំ តរេ លោកេ វិសត្តិកំ ។

---

១ ឱ. ម. សេ ។

ព្រះអង្គពោលថា កាលពួកសមណព្រាហ្មណ៍ណា លះអារម្មណ៍ ដែលខ្លួនបានឃើញ បានឮ បានប៉ះពាល់ នឹងសីលវ័ត លះបង់ វិធីជាច្រើនយ៉ាង ទាំងអស់ចេញ ឬពួកជនណា កំណត់ដឹង នូវតណ្ហា មិនមានអាសវៈ ទើបតថាគត ពោលថា ជនទាំងនោះ ឆ្លងផុតឱឃៈបាន ។

ចប់ នន្ទមាណវកបញ្ហា ទី ៧ ។

## ហេមកបញ្ហា ទី ៨

(១១៩) (ហេមកមាណព ដ៏មានអាយុ ទូលសួរថា) ក្នុងកាល ពីដើម មុនសាសនានៃព្រះគោតម អាចារ្យទាំងឡាយ បានពោល យ៉ាងជាក់ច្បាស់ថា ពាក្យនោះ ធ្លាប់មានមកហើយ យ៉ាងនេះ ពាក្យ នោះ នឹងមានតទៅ ពាក្យទាំងអស់នោះ ជាពាក្យមិនជាក់ច្បាស់ ពាក្យទាំងអស់នោះ ជាគ្រឿងចំរើននៃសេចក្តីត្រិះរិះ (ខ្ញុំព្រះអង្គមិន ទាន់ពេញចិត្តក្នុងពាក្យនោះឡើយ) បពិត្រព្រះអង្គជាព្រះមុនី សូមព្រះ អង្គសំដែងធម៌ សម្រាប់ដកចេញនូវតណ្ហា ដែលនាំឲ្យខ្ញុំព្រះអង្គដឹង ច្បាស់ មានសតិ ឆ្លងតណ្ហាដែលផ្សាយទៅផ្សេង ៗ ដល់ខ្ញុំព្រះអង្គ ។

ឥធ ទិដ្ឋសុតមុតំ(១) (វិញ្ញាតេសុ) បិយរូបេសុ ហេមក
ឆន្ទរាគវិនោទនំ          និព្វានបទមច្ចុតំ
ឯតទញ្ញាយ យេ សតា     ទិដ្ឋធម្មាភិនិព្វុតា
ឧបសន្តា ច តេ សតា(២)  តិណ្ណា លោកេ វិសត្តិកន្តិ ។

ហេមកមាណវកបញ្ហា អដ្ឋមា ។

## នវមា តោទេយ្យបញ្ហា

(១៦០) យស្មឹ កាមា ន វសន្តិ (ឥច្ចាយស្មា តោទេយ្យោ)
តណ្ហា យស្ស ន វិជ្ជតិ
កថង្កថា ច យោ តិណ្ណោ វិមោក្ខោ តស្ស កីទិសោ ។
យស្មឹ កាមា ន វសន្តិ (តោទេយ្យាតិ ភគវា)
តណ្ហា យស្ស ន វិជ្ជតិ
កថង្កថា ច យោ តិណ្ណោ វិមោក្ខោ តស្ស នាបរោ ។

---

១ ឱ. ទិដ្ឋសុតមុតេ ។ ២ ឱ. សទា ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា)ម្នាលហេមកៈ ជនទាំងឡាយណា ដឹងច្បាស់នូវព្រះនិព្វាន ជាទីបន្ទោបង់នូវឆន្ទរាគ ជាគុណជាតមិនច្យុត ដែលបានឃើញ បានស្តាប់ បានប៉ះពាល់ហើយ ចំពោះរូបជាទីស្រឡាញ់(ដែលគេដឹងច្បាស់ហើយ) ជាអ្នកមានសតិ រលត់កិលេស ក្នុងបច្ចុប្បន្នហើយ ជនអ្នកមានសតិស្ងប់កិលេសទាំងនោះ ឈ្មោះថា ឆ្លងតណ្ហាដែលផ្សាយទៅផ្សេងៗ ក្នុងលោកបានហើយ ។

ចប់ ហេមកមាណវកបញ្ហា ទី ៨ ។

## តោទេយ្យបញ្ហា ទី ៩

(១២០) (តោទេយ្យមាណព ដ៏មានអាយុ ទូលសួរថា) កាមារម្មណ៍ទាំងឡាយ មិនមានទៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណា មិនមាន ទាំងបុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌ (ការរួចផុត) របស់បុគ្គលនោះ តើដូចម្តេច ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលតោទេយ្យ) កាមារម្មណ៍ទាំងឡាយ មិនមានទៅក្នុងបុគ្គលណា តណ្ហារបស់បុគ្គលណា មិនមាន ទាំងបុគ្គលណា ឆ្លងសេចក្តីសង្ស័យបាន វិមោក្ខធម៌ របស់បុគ្គលនោះ មិនមែនទៅជាយ៉ាងដទៃទេ ។

និរាសសោ(១) សោ ឧទ អាសសានោ
បញ្ញាណវា សោ ឧទ បញ្ញកប្បី
មុនឹ អហំ សក្ក យថា វិជញ្ញំ
តម្មេ វិយាចិក្ខ សមន្តចក្ខុ ។
និរាសសោ សោ ន ច(២) អាសសានោ
បញ្ញាណវា សោ ន ច(៣) បញ្ញកប្បី
ឯវម្បិ តោទេយ្យ មុនឹ វិជាន
អកិញ្ចនំ កាមភវេ អសត្តន្តិ ។

តោទេយ្យមាណវកបញ្ហា នវមា ។

## ទសមា កប្បប្បញ្ហា

(១៦១) មជ្ឈេ សរស្មិំ តិដ្ឋតំ (ឥច្ចាយស្មា កប្បោ)
ឱឃេ ជាតេ មហព្ភយេ
ជរាមច្ចុបរេតានំ ទីបំ បព្រូហិ មារិស

---

១ ខ. និរាសយោ ។ ម. និរាសកោ ។ ២ ៣ ម. ចសទ្ទោ នត្ថិ ។

(បុគ្គលនោះ នឹងត្រូវព្យាយាម ដើម្បីធ្វើខ្លួនឲ្យរួចផុតទៅ ក្រៅអំពីនេះទៀតមិនមានទេ ) បុគ្គលនោះ ជាអ្នកប្រាសចាកសេចក្ដីប្រាថ្នា ឬនៅប្រកបដោយសេចក្ដីប្រាថ្នា ជាបុគ្គលមានប្រាជ្ញា ឬជាអ្នកគ្រាន់តែកំណត់ថាមានបញ្ញា បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គគប្បីស្គាល់បាននូវមុនី ដោយប្រការដូចម្ដេច បពិត្រព្រះអង្គមានបញ្ញាចក្ខុ ឃើញធម៌ដោយជុំវិញ សូមព្រះអង្គត្រាស់ប្រាប់ នូវមុនីនោះ ដល់ខ្ញុំព្រះអង្គ ។

(ព្រះអង្គទ្រង់ដោះស្រាយថា) បុគ្គលនោះប្រាសចាកសេចក្ដីប្រាថ្នា ទាំងជាអ្នកប្រកបដោយសេចក្ដីប្រាថ្នាក៏ទេ ជាអ្នកមានបញ្ញា ទាំងជាអ្នកគ្រាន់តែកំណត់ថាមានបញ្ញាក៏ទេ ម្នាលតោទេយ្យ អ្នកចូរដឹងបុគ្គលនោះ ថាជាមុនី ជាអ្នកមិនមានកង្វល់ មិនជាប់នៅ ក្នុងកាមភព យ៉ាងនេះចុះ ។

ចប់ តោទេយ្យមាណវកបញ្ហា ទី ៩ ។

## កប្បបញ្ហា ទី ១០

(១៦១) (កប្បមាណពដ៏មានអាយុ ទូលសួរថា) ពួកសត្វឋិតនៅក្នុងកណ្ដាល នៃសង្សារវដ្ដ ត្រូវជលពទឹងមហុគ្របសង្កត់ ក្នុងកាលដែលឱឃៈ ជាភ័យធំ កើតឡើងហើយ បពិត្រព្រះអង្គនិទ្ទុក្ខ សូមព្រះអង្គ ត្រាស់ប្រាប់ នូវទីពឹងឲ្យបាន

ត្វញ្ច មេ ទីបមក្ខាហិ យថាយិទំ(១) នាបរំ សិយា ។

មជ្ឈេ សរស្មឹ តិដ្ឋតំ (កប្បាតិ ភគវា)

ឱឃេ ជាតេ មហព្ភយេ

ជរាមច្ចុបរេតានំ ទីបំ បព្រូមិ កប្ប តេ ។

អកិញ្ចនំ អនាទានំ ឯតំ ទីបំ អនាបរំ

និព្វានំ ឥតិ នំ ព្រូមិ ជរាមច្ចុបរិក្ខយំ ។

ឯតទញ្ញាយ យេ សតា ទិដ្ឋធម្មាភិនិព្វុតា

ន តេ មារវសានុគា ន តេ មារស្ស បទ្ធគូតិ ។

កប្បមាណវកប្បញ្ហា ទសមា ។

## ឯកាទសមា ជតុកណ្ណីបញ្ហា

(១២២) សុត្វានហំ វីរ អកាមកាមឹ(២) (ឥច្ចាយស្មា

ជតុកណ្ណី)

---

១ ឱ. ម. យថយិទំ ។ ២ ឱ. ម. វីរមកាមកាមឹ ។

សេចក្តីទុក្ខ ក្នុងសង្សារវដ្តនេះ មិនគប្បីមានតទៅទៀត ដោយប្រការណា សូមព្រះអង្គ ត្រាស់ប្រាប់ នូវទីពឹង ដល់ខ្ញុំព្រះអង្គ (ដើម្បីវៀរចាកទុក្ខ) ដោយប្រការនោះ ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលកប្បៈ) ពួកសត្វឋិតនៅ ក្នុងកណ្តាល នៃសង្សារវដ្ត ត្រូវផកទឹងមច្ចុគ្របសង្កត់ ក្នុងកាលដែលឱឃៈជាភ័យធំកើតឡើង ម្នាលកប្បៈ តថាគតនឹងសំដែងប្រាប់នូវទីពឹងដល់អ្នក ។ ការមិនកង្វល់ (ដោយកិលេស) ការមិនប្រកាន់មាំនុះឯង ឈ្មោះថាជាទីពឹងពំនាក់ មិនមានទីពឹងដទៃលើសជាងនេះ តថាគត ហៅទីពឹងនោះថា ព្រះនិព្វាន ជាទីក្ស័យនៃផកទឹងមច្ចុ ។ ជនទាំងឡាយណា ដឹងច្បាស់នូវព្រះនិព្វាននោះ ជាអ្នកមានសតិ រំលត់ទុក្ខក្នុងបច្ចុប្បន្ននេះ ជនទាំងនោះជាអ្នកមិនលុះអំណាចនៃមារ ជនទាំងនោះ មិនដល់នូវភាពជាអ្នកបំរើនៃមារឡើយ ។

ចប់ កប្បមាណវកបញ្ហា ទី ១០ ។

## ជតុកណ្ណិបញ្ហា ទី ១១

(១៦២) (ជតុកណ្ណីមាណពដ៏មានអាយុ ទូលសួរថា) បពិត្រព្រះអង្គជាវីរបុរស ខ្ញុំព្រះអង្គបានឮថា ព្រះអង្គមិនមានសេចក្តីប្រាថ្នាក្នុងកាម

ឱឃាតិគំ បុដ្ឋុមកាមមាគមំ

សន្តិបទំ ព្រូហិ សហាជនេត្ត

យថាតច្ឆំ ភគវា ព្រូហិ មេ តំ ។

ភគវា ហិ កាមេ អភិភុយ្យ ឥរិយតិ

(អាទិច្ចោវ បថវី តេជី តេជសា)

បរិត្តបញ្ញស្ស មេ ភូរិបញ្ញ

អាចិក្ខ ធម្មំ យមហំ វិជញ្ញំ

ជាតិជរាយ ឥធ វិប្បហានំ ។

កាមេសុ វិនយ គេធំ (ជតុកណ្ណីតិ ភគវា)

នេក្ខម្មំ ទដ្ឋុ ខេមតោ

ឧគ្គហិតំ និរត្តំ វា មា តេ វិជ្ជិត្ថ កិញ្ចនំ

ឆ្លងអន្លង់គឺកិលេសបានហើយ ទើបមក ដើម្បីទូលសួរព្រះអង្គ អ្នកមិនមានសេចក្តីប្រាថ្នា បពិត្រព្រះមានព្រះភាគ ព្រះអង្គមានជួនព្រះនេត្រ ឃើញនូវធម្មតាលោក ដែលកើតឡើងព្រម សូមព្រះអង្គ សំដែងនូវសន្តិបទ គឺធម៌ស្ងប់ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គសំដែង នូវសន្តិបទនុ៎ះ តាមសេចក្តីពិត ដល់ខ្ញុំព្រះអង្គឲ្យបាន ។ ព្រោះថា ព្រះមានព្រះភាគ តែងប្រព្រឹត្តគ្របសង្កត់នូវកាម (ដូចព្រះអាទិត្យ មានតេជះគឺរស្មី គ្របសង្កត់នូវប្រថពីមណ្ឌល ដោយតេជះដូច្នោះ) បពិត្រព្រះអង្គមានព្រះបញ្ញាធំទូលាយ ដូចផែនដី សូមព្រះអង្គត្រាស់ប្រាប់ នូវធម៌ដែលខ្ញុំព្រះអង្គគួរដឹង ជាធម៌សម្រាប់លះជាតិនិងជរា ក្នុងអត្តភាពនេះ ដល់ខ្ញុំព្រះអង្គ ជាអ្នកមានបញ្ញាស្តួចស្តើងឲ្យបាន ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលជតុកណ្ណី) អ្នកចូរកំចាត់បង់ នូវតម្រេកក្នុងកាមទាំងឡាយចេញ ចូរឃើញនូវនេក្ខម្មៈដោយសេចក្តីក្សេមក្សាន្ត កិលេសជាតិគ្រឿងខ្វល់ ដែលអ្នកប្រកាន់មាំ (ដោយតណ្ហានិងទិដ្ឋិ) ឬដែលគួរលះបង់ កុំមានដល់អ្នកឡើយ

យំ បុព្វេ តំ វិសោសេហិ បច្ឆា តេ មាហុ កិញ្ចនំ
មជ្ឈេ ចេ នោ គហេស្សសិ ឧបសន្តោ ចរិស្សសិ ។
សព្វសោ នាមរូបស្មឹ វីតគេធស្ស ព្រាហ្មណ
អាសវាស្ស ន វិជ្ជន្តិ យេហិ មច្ចុវសំ វជេតិ ។

ជតុកណ្ណីមាណវកបញ្ហា ឯកាទសមា ។

## ទ្វាទសមា ភទ្រាវុធបញ្ហា

(១២៣) ឱកញ្ជហំ(១) តណ្ហច្ឆិទំ អនេជំ (ឥច្ចាយស្មា ភទ្រាវុធោ)

នន្ទិញ្ជហំ ឱឃតិណ្ណំ វិមុត្តំ
កប្បញ្ជហំ អភិយាចេ សុមេធំ
សុត្វាន នាគស្ស អបនមិស្សន្តិ ឥតោ
នានាជនា ជនបទេហិ សង្គតា
តវ វីរ វាក្យំ អភិកង្ខមានា

---

១ ម. ឱឃំ ជហំ ។

គ្រឿងខ្វល់ណា ដែលមានហើយ ក្នុងកាលមុន អ្នកចូរឲ្យគ្រឿងខ្វល់នោះរីងស្ងួតចុះ គ្រឿងខ្វល់ មានក្នុងខាងក្រោយ កុំមានដល់អ្នកឡើយ បើអ្នកមិនកាន់យក នូវគ្រឿងខ្វល់ ក្នុងកណ្តាល អ្នកនឹងជាមនុស្សស្ងប់គ្រឿងខ្វល់បាន ។ ម្នាលព្រាហ្មណ៍ បុគ្គលតែងលុះ ក្នុងអំណាចនៃមច្ចុ ដោយអាសវៈទាំងឡាយណា អាសវៈទាំងនោះ រមែងមិនមាន ដល់បុគ្គលដែលប្រាសចាកតម្រេកក្នុងនាមរូប ដោយសព្វគ្រប់ ។

ចប់ ជតុកណ្ណីមាណវកបញ្ហាទី ១១ ។

## ភទ្រាវុធបញ្ហា ទី ១២

(១២៣) (ភទ្រាវុធមាណព ដ៏មានអាយុ ទូលសួរថា) ខ្ញុំព្រះអង្គ សូមអារាធនាព្រះអង្គ អ្នកលះអាល័យ កាត់តណ្ហា មិនរំភើប (ព្រោះលោកធម៌) លះសេចក្តីត្រេកអរ ឆ្លងអន្លង់ហើយ រួចផុតស្រឡះហើយ លះធម៌គ្រឿងកំណត់ (ដោយតណ្ហានឹងទិដ្ឋិ) ព្រះអង្គមានព្រះប្រាជ្ញាញាណ បពិត្រព្រះអង្គ ជាវីរបុរស ពួកជនអ្នកនៅក្នុងជនបទផ្សេង ៗ ចង់ស្តាប់ព្រះពាក្យ របស់ព្រះអង្គ ក៏បានមកព្រមគ្នាហើយ អំពីជនបទនោះ ៗ បើបានស្តាប់ព្រះវាចា របស់ព្រះអង្គហើយ ទើបត្រឡប់ អំពីទីនេះវិញ សូមព្រះ

តេសំ តុំ សាធុ វិយាករោហិ

តថាហិ តេ វិទិតោ ឯស ធម្មោ ។

អាទានតណ្ហំ វិនយេថ សព្វំ (ភទ្រាវុធាតិ ភគវា)

ឧទ្ធំ អធោ តិរិយញ្ចាបិ មជ្ឈេ

យំ យញ្ហិ លោកស្មឹ ឧបាទិយន្តិ(១)

តេនេវ មារោ អន្វេតិ ជន្តុំ

តស្មា បជានំ ន ឧបាទិយេថ(២)

ភិក្ខុ សតោ កិញ្ចនំ សព្វលោកេ

អាទានសត្តេ ឥតិ បេក្ខមានោ

បជំ ឥមំ មច្ចុធេយ្យេ(៣) វិសត្តិ ។

ភទ្រាវុធមាណវកបញ្ហា ទ្វាទសមា ។

---

១ ម. ឧបាទិយន្តិ ។ ២ ក. ឧបាទិយេថ ។ ៣ ម. មច្ចុធេយ្យំ ។

អង្គ ទ្រង់ដោះស្រាយបញ្ហា ដើម្បីជនទាំងអម្បាលនោះ ព្រោះធម៌នោះ ព្រះអង្គបានជ្រាបហើយ ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលភទ្រាវុធ) បុគ្គលគួរកំចាត់បង់នូវតណ្ហា ជាគ្រឿងប្រកាន់មាំ ក្នុងចំណែកខាងលើ ក្នុងចំណែកខាងក្រោម និងក្នុងចំណែកទទឹង គឺត្រង់កណ្តាល ឲ្យអស់ទៅ ព្រោះថា ជនទាំងអម្បាលនោះ ប្រកាន់មាំនូវរបស់ណាៗ ក្នុងលោក មាររមែងជាប់តាមសត្វ ដោយរបស់នោះៗវិញដែរ ហេតុនោះ ភិក្ខុកាលដឹង ឃើញនូវពួកសត្វអ្នកជាប់នៅក្នុងអារម្មណ៍ផ្សេងៗ ជាទីតាំងនៃមច្ចុមារនេះថា សត្វជាប់នៅព្រោះសេចក្តីប្រកាន់មាំដូច្នេះ គប្បីជាអ្នកមានសតិ មិនប្រកាន់មាំនូវគ្រឿងខ្វល់ក្នុងលោកទាំងពួង ។

ចប់ ភទ្រាវុធមាណវកបញ្ហា ទី ១២ ។

# តេរសមា ឧទយបញ្ហា

(១២៨) ឈាយឹ វិរជមាសីនំ (ឥច្ចាយស្មា ឧទយោ)

កតកិច្ចំ អនាសវំ

បារគុំ សព្វធម្មានំ អត្ថិ បញ្ហេន អាគមំ

អញ្ញាំ(១) វិមោក្ខំ បព្រូហិ អវិជ្ជាយ បភេទនំ ។

បហានំ កាមច្ឆន្ទានំ (ឧទយាតិ ភគវា)

ទោមនស្សាន ចូភយំ

ថីនស្ស ច បនូទនំ កុក្កុច្ចានំ និវារណំ

ឧបេក្ខាសតិសំសុទ្ធំ ធម្មតក្កបុរេជវំ

អញ្ញាំ(២) វិមោក្ខំ បព្រូមិ អវិជ្ជាយ បភេទនំ ។

កឹសុ សញ្ញោជនោ លោកោ កឹសុ តស្ស វិចារណា(៣)

កិស្សស្ស វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។

នន្ទិសញ្ញោជនោ លោកោ វិតក្កស្ស វិចារណា

---

១-២ ឱ. ម. អញ្ញ ។ ៣ ឱ. វិចារណំ ។

# ឧទយបញ្ហា ទី ១៣

(១២៤) (ឧទយមាណពដ៏មានអាយុ ទូលសួរថា) ខ្ញុំព្រះអង្គ ជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ (ដើម្បីសួរ) ព្រះអង្គ ជាអ្នកបំពេញឈាន មានព្រះសន្ដានប្រាសចាកធូលី គឺកិលេស មិនមានអាសវៈ បានទ្រង់ធ្វើកិច្ច ដែលគួរធ្វើស្រេចហើយ ដល់នូវត្រើយនៃធម៌ទាំងពួង សូមព្រះអង្គទ្រង់សំដែងនូវវិមោក្ខធម៌ គឺព្រះអរហត្ត ជាគ្រឿងទំលាយអវិជ្ជាចេញបាន ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលឧទយៈ) តថាគតពោលនូវការលះនូវកាមច្ឆន្ទៈនឹងទោមនស្ស ទាំងពីរយ៉ាងផង ការបន្ទោបង់ នូវសេចក្ដីព្រួញផង ការឃាត់បង់ នូវកុក្កុច្ចៈផង មានឧបេក្ខានឹងសតិដ៏បរិសុទ្ធ មានសេចក្ដីត្រិះរិះ ក្នុងធម៌ជាប្រធានថា ជាវិមោក្ខធម៌ គឺព្រះអរហត្ត ជាគ្រឿងទំលាយនូវអវិជ្ជាចេញបាន ។

សត្វលោកមានអ្វីជាគ្រឿងចងទុក អ្វីជាគ្រឿងសញ្ចរទៅនៃសត្វលោកនោះ លោកពោលថា និព្វានៗ ដូច្នេះតើ ព្រោះលះអ្វីបានៗ

សត្វលោក មានសេចក្ដីត្រេកត្រអាល ជាគ្រឿងចងទុក មានសេចក្ដីគិតផ្សឹង ជាគ្រឿងសញ្ចរទៅ នៃសត្វលោកនោះ

តណ្ហាយ វិប្បហានេន និព្វានំ ឥតិ វុច្ចតិ ។
កថំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតិ
ភវន្តំ(១) បុដ្ឋុមាគម្ម តំ សុណោម វចោ តវ ។
អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ នាភិនន្ទតោ
ឯវំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតីតិ ។

ឧទយមាណវកបញ្ហា តេរសមា ។

## ចុទ្ទសមា បោសាលបញ្ហា

(១២៥) យោ អតីតំ អាទិសតិ (ឥច្ចាយស្មា បោសាលោ)
អនេជោ ឆិន្នសំសយោ
ភារគូ(២) សព្វធម្មានំ អត្ថិ បញ្ហេន អាគមំ

១ ឱ. ម. ភគវន្តំ ។ ២ ឱ. បារគុំ ។

ដែលលោកពោលថា និព្វាន ព្រោះលះតណ្ហាចេញបាន ។

កាលបុគ្គលមានសតិ ត្រាច់ទៅដូចម្ដេច វិញ្ញាណទើបរលត់ យើងខ្ញុំមកគាល់ ដើម្បីនឹងទូលសួរព្រះអង្គ នឹងបានស្ដាប់ព្រះវាចា របស់ព្រះអង្គ ។

កាលបុគ្គលមិនត្រេកត្រអាលចំពោះវេទនា ទាំងខាងក្នុង ទាំងខាងក្រៅ មានសតិ ត្រាច់ទៅយ៉ាងនេះ វិញ្ញាណទើបរលត់ទៅ ។

ចប់ ឧទយមាណវកប្បញ្ហា ទី ១៣ ។

## បោសាលបញ្ហា ទី ១៤

(១២៥) (បោសាលមាណពដ៏មានអាយុ ទូលសួរថា) ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ ដើម្បីសួរ ព្រះអង្គសំដែងព្រះប្រាជ្ញាញាណក្នុងកាលជាអតីត មិនញាប់ញ័រ (ចំពោះសុខទុក្ខ) មានសេចក្ដីសង្ស័យ កាត់បង់ហើយ ដល់នូវត្រើយនៃធម៌ទាំងពួង

វិភូតរូបសញ្ញិស្ស សព្វកាយប្បហាយិនោ
អជ្ឈត្តញ្ច ពហិទ្ធា ច នត្ថិ កិញ្ចីតិ បស្សតោ
ញាណំ សក្កានុបុច្ឆាមិ កថំ នេយ្យោ តថាវិធោ ។
វិញ្ញាណដ្ឋិតិយោ សព្វា (បោសាលាតិ ភគវា)
អភិជានំ តថាគតោ
តិដ្ឋន្តមេនំ ជានាតិ វិមុត្តំ តប្បរាយណំ
អាកិញ្ចញ្ញសម្ភវំ(១) នន្ទិសញ្ញោជនំ ឥតិ
ឯវមេវំ អភិញ្ញាយ តតោ តត្ថ វិបស្សតិ
ឯវំ(២) ញាណំ តថំ តស្ស ព្រាហ្មណស្ស វុសីមតោតិ ។

បោសាលមាណវកបុច្ឆា ចុទ្ទសមា ។

---

១· ឱ. ប. អាកិញ្ចញ្ញសម្ភវំ ។ ២· ឱ. ឯតំ ។

បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គ សូមទូលសួរ ញាណរបស់បុគ្គល មានសេចក្ដីកំណត់ កត់សំគាល់ក្នុងរូប បានដាក់ច្បាស់ (បានសម្រេចដល់រូបជ្ឈានហើយ) លះបង់រូបារម្មណ៍ទាំងអស់បានហើយ (កន្លងរូបជ្ឈានហើយ) ឃើញទាំងខាងក្នុង ទាំងខាងក្រៅថា វត្ថុបន្តិចបន្តួចមិនមាន (សម្រេចអរូបជ្ឈាន ដែលហៅថា អាកិញ្ចញ្ញាយតនៈ) បុគ្គលមានសភាពដូច្នោះ តើព្រះអង្គគប្បីប្រៀនប្រដៅ ដោយប្រការ ដូចម្ដេចទៀត ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលពោសាលៈ) តថាគត ជ្រាបវិញ្ញាណដ្ឋិតិ (ភូមិជាទីតាំងនៃវិញ្ញាណ) ទាំងអស់ ទើបជ្រាបបុគ្គលនោះ កំពុងឋិតនៅ មានចិត្តចុះស៊ប់ ក្នុង (អាកិញ្ចញ្ញាយតនៈ) មានអាកិញ្ចញ្ញាយតនៈនោះ ប្រព្រឹត្តទៅខាងមុខ មានអាកិញ្ចញ្ញាយតនៈជាដែនកើត មានសេចក្ដីត្រេកត្រអាលជាគ្រឿងប្រកបដូច្នេះ លុះតថាគត ជ្រាបច្បាស់ យ៉ាងនេះហើយ លំដាប់អំពីអាកិញ្ចញ្ញាយតនជ្ឈាននោះ ក៏រមែងពិចារណាឃើញច្បាស់ ក្នុងសហជាតធម៌នោះ នេះឯងជាញាណ ដ៏ពិតប្រាកដ របស់ព្រាហ្មណ៍នោះ ជាអ្នកប្រព្រឹត្តចប់ព្រហ្មចរិយធម៌ ។

ចប់ ពោសាលមាណវកបញ្ហា ទី ១៤ ។

# បណ្ណរសមា មោឃរាជប្បញ្ហា

(១២៦) ទ្វាហំ សក្ក អបុច្ឆិស្សំ (ឥច្ចាយស្មា មោឃរាជា)

ន មេ ព្យាកាសិ ចក្ខុមា

យាវតតិយញ្ច ទេវីសិ ព្យាករោតីតិ(១) មេ សុតំ

អយំ លោកោ បរោ លោកោ ព្រហ្មលោកោ សទេវកោ

ទិដ្ឋិំ តេ នាភិជានាមិ(២) គោតមស្ស យសស្សិនោ

ឯវំ អភិក្កន្តទស្សាវឹ អត្ថិ បញ្ហេន អាគមំ

កថំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

សុញ្ញតោ លោកំ អវេក្ខស្សុ មោឃរាជា(៣) សទា សតោ

អត្តានុទិដ្ឋឹ ឩហច្ច ឯវំ មច្ចុតរោ សិយា

ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតីតិ ។

មោឃរាជមាណវកបញ្ហា បណ្ណរសមា ។

---

១ ឱ. វ្យាករោតីតិ ។ ២ ម. នាភិជានាតិ ។ ៣ ឱ. មោឃរាជ ។

# មោឃរាជប្បញ្ហា ទី ១៥

(១៦៦) (មោឃរាជមាណពដ៏មានអាយុ ទូលសួរថា) បពិត្រព្រះអង្គជាសក្យពង្ស ខ្ញុំព្រះអង្គទូលសួរ អស់វារៈ ២ ដងហើយ ព្រះអង្គមានចក្ខុ ក៏មិនទាន់បានដោះស្រាយ ដល់ខ្ញុំព្រះអង្គនៅឡើយ បពិត្រព្រះអង្គជាទេពឥសី ខ្ញុំព្រះអង្គបានឮថា បើគេទូលសួរអស់វារៈ ៣ ដង ព្រះមានព្រះភាគគង់ដោះស្រាយ លោកនេះ លោកដទៃ ព្រហ្មលោក ព្រមទាំងទេវលោក រមែងមិនទាន់ដឹង នូវសេចក្តីយល់របស់ព្រះអង្គ ជាព្រះគោតមដ៏ទ្រង់យសទេ ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបញ្ហា ទើបមកគាល់ (ដើម្បីសួរ) ព្រះអង្គជាអ្នកឃើញដ៏លើសលុប យ៉ាងនេះ បុគ្គលកាលពិចារណា នូវខន្ធលោកដូចម្តេច មច្ចុរាជ ទើបមិនឃើញ ។

ម្នាលមោឃរាជ អ្នកចូរជាអ្នកមានសតិ សព្វកាល ចូរពិចារណាលោក ដោយសភាពជារបស់សូន្យ បុគ្គលដកអត្តានុទិដ្ឋិ គឺសេចក្តីឃើញថាជាខ្លួនប្រាណចេញ ទើបឆ្លងមច្ចុរាជចេញបាន យ៉ាងនេះ បុគ្គលកាលពិចារណាលោកយ៉ាងនេះ មច្ចុរាជទើបមិនឃើញ ។

ចប់ មោឃរាជមាណវកប្បញ្ហា ទី ១៥ ។

# សោឡសមា បិង្គិយបុច្ឆា

(១៤៧) ជិណ្ណោហមស្មិ អពលោ វិវណ្ណោ(១) (ឥច្ចាយស្មា បិង្គិយោ)

នេត្តា ន សុទ្ធា សវនំ ន ផាសុ
មាហម្បនស្សំ(២) មោមុហោ អន្តរាយ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជរាយ ឥធ វិប្បហានំ ។

ទិស្វាន រូបេសុ វិហញ្ញមានេ (បិង្គិយាតិ ភគវា)

រុប្បន្តិ រូបេសុ ជនា បមត្តា
តស្មា តុវំ បិង្គិយ អប្បមត្តោ
ជហស្សុ រូបំ អបុនព្ភវាយ ។
ទិសា ចតស្សោ វិទិសា ចតស្សោ
ឧទ្ធំ អធោ ទស ទិសា(៣) ឥមាយោ

---

១- ឱ. ម. វីតវណ្ណោ ។ ២- ឱ. មាហំ នស្សំ ។ ម. មាហ នស្ស ។ ៣- ឱ. ទិសតា ។

# បិង្គិយបញ្ហា ទី ១៦

(១៤៧) (បិង្គិយមាណពជាមានកាយ ទូលសួរថា) ខ្ញុំព្រះអង្គជាមនុស្សចាស់ មិនសូវមានកំឡាំង មានពណ៌សម្បុរកាប់អន់ ភ្នែកក៏មិនសូវភ្លឺ ត្រចៀកសម្រាប់ស្តាប់ ក៏មិនសូវឮ សូមកុំឲ្យខ្ញុំព្រះអង្គវង្វេងវង្វាន់វិនាសក្នុងចន្លោះ សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលខ្ញុំព្រះអង្គគួរដឹង ជាគ្រឿងលះជាតិនិងជរា ក្នុងអត្តភាពនេះឲ្យបាន ។

(ព្រះមានព្រះភាគទ្រង់ដោះស្រាយថា ម្នាលបិង្គិយៈ) អ្នកបូរឃើញថា ជនទាំងឡាយ ជាអ្នកប្រមាទ រមែងលំបាកព្រោះរូបជាហេតុ រមែងឈឺចាប់ ក៏ព្រោះរូបជាហេតុ ម្នាលបិង្គិយៈព្រោះដូច្នោះអ្នកកុំប្រមាទ ចូរលះរូបចោលចេញ ដើម្បីមិនកើតតទៅទៀត ។

ទិសទាំងឡាយនេះ គឺទិសធំ ៤ ទិសតូច ៤ ទាំងទិសខាងលើ ១ និងទិសខាងក្រោម ១ រួមត្រូវជា ១០ ទិស

ន តុយ្ហំ អទិដ្ឋំ អសុតាមុតំ[១] វា
អថោ អវិញ្ញាតំ កិញ្ចិមត្ថិ[២] លោកេ
អាចិក្ខ ធម្មំ យមហំ វិជញ្ញំ
ជាតិជរាយ ឥធ វិប្បហានំ ។

តណ្ហាធិបន្នេ មនុជេ បេក្ខមានោ (បិង្គិយាតិ ភគវា)
សន្តាបជាតេ ជរសា បរេតេ
តស្មា តុវំ បិង្គិយ អប្បមត្តោ
ជហស្សុ តណ្ហំ អបុនព្ភវាយាតិ ។

បិង្គិយមាណវកបញ្ហា សោឡសមា ។

(១៦៨) ឥទមវោច ភគវា មគធេសុ វិហរន្តោ បាសាណាចេតិយេ[៣] បរិចារិកសោឡសន្នំ ព្រាហ្មណានំ អជ្ឈិដ្ឋោ បញ្ហំ[៤] ព្យាកាសិ ។ ឯកមេកស្សចេបិ បញ្ហស្ស អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជេយ្យ គច្ឆេយ្យេវ ជរាមរណស្ស បារំ គមនីយា[៥] ឥមេ ធម្មាតិ

---

១ ឱ. អសុតំ មុតំ វា ។ ២ ឱ. កិញ្ចនមត្ថិ ។ ៣ ឱ. ម. បាសាណកេ ចេតិយេ ។ ៤ ឱ. អជ្ឈិដ្ឋោ បុដ្ឋោ បុដ្ឋោ បញ្ហេតិ ទិស្សន្តិ ។ ៥ ប. ធារំ បារំ គមនីយំ ។

វត្ថុណាមួយ ក្នុងលោក ដែលព្រះអង្គមិនធ្លាប់ឃើញ មិនធ្លាប់ឮមិនធ្លាប់ប៉ះពាល់ ឬមិនធ្លាប់ជ្រាប មិនមានទេ សូមព្រះអង្គត្រាស់ប្រាប់ធម៌ដែលខ្ញុំព្រះអង្គគួរដឹង សម្រាប់លះជាតិនិងជរា ក្នុងអត្តភាពនេះ ។

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលបិង្គិយៈ) កាលបើ អ្នកឃើញនូវពួកមនុស្ស ដែលត្រូវតណ្ហាកំពុងគ្របសង្កត់ ជាសត្វមានសេចក្ដីក្ដៅក្រហាយ កើតឡើងហើយ ត្រូវជរារួបរឹតហើយ ម្នាលបិង្គិយៈ ហេតុដូច្នោះ អ្នកកុំប្រមាទ ចូរលះតណ្ហាចោលចេញ ដើម្បីមិនឲ្យកើតតទៅទៀត ។

ចប់ បិង្គិយមាណវកបញ្ហា ទី ១៦ ។

(៣២៨) កាលព្រះមានព្រះភាគ ទ្រង់គង់នៅ នាបាសាណចេតិយ ក្នុងដែនមគធៈ ទ្រង់បានសំដែងសូត្រនេះ កាលពួកព្រាហ្មណ៍ ១៦នាក់ ជាអ្នកបំរើ(របស់ពាវរីព្រាហ្មណ៍) អារាធនាហើយ ទើបព្រះអង្គទ្រង់ដោះស្រាយបញ្ហា ។ បើបុគ្គល បានដឹងនូវអត្ថ បានដឹងនូវធម៌ នៃបញ្ហាមួយៗហើយ គប្បីប្រតិបត្តិនូវធម៌ ដ៏សមគួរតាមធម៌ បុគ្គលនោះ មុខជាដល់នូវត្រើយ នៃជរានិងមរណៈ ពុំខាន ធម៌ទាំងនេះជាធម៌គួរនាំសត្វទៅ (កាន់ត្រើយគឺព្រះនិព្វាន)

តស្មា ឥមស្ស ធម្មបរិយាយស្ស បារាយនន្តេវ អធិវចនំ ។

(១៦៩) អជិតោ តិស្សមេត្តេយ្យោ បុណ្ណកោ អថ មេត្តគូ
ធោតកោ ឧបសីវោ ច នន្ទោ ច អថ ហេមកោ
តោទេយ្យកប្បា ទុភយោ ជតុកណ្ណី ច បណ្ឌិតោ
ភទ្រាវុធោ ឧទយោ ច បោសាលោ ចាបិ ព្រាហ្មណោ
មោឃរាជា ច មេធាវី បិង្គិយោ ច មហាឥសិ
ឯតេ ពុទ្ធមុបាគច្ឆុំ សម្បន្នចរណំ ឥសឹ
បុច្ឆន្តា និបុណេ បញ្ហេ ពុទ្ធសេដ្ឋំ ឧបាគមុំ ។
តេសំ ពុទ្ធោ ព្យាកាសិ[១] បញ្ហេ បុដ្ឋោ យថាតថំ
បញ្ហានំ វេយ្យាករណេន តោសេសិ ព្រាហ្មណេ មុនិ ។
តេ តោសិតា ចក្ខុមតា ពុទ្ធេនាទិច្ចពន្ធុនា
ព្រហ្មចរិយមចរិំសុ វរបញ្ញស្ស សន្តិកេ ។

---

១ ម. បព្យាកាសិ ។ វិបកាសីតិ បុត្ថកំ ។

ព្រោះហេតុនោះ ពាក្យថា បារាយនៈ (ការប្រព្រឹត្តទៅកាន់ត្រើយ) នេះជាឈ្មោះនៃធម្មបរិយាយនេះឯង ។

(១២៩) (ព្រាហ្មណមាណព ១៦ នាក់ ដែលបានក្រាបទូលសួរបញ្ហា) នុ៎ះ គឺ មាណពឈ្មោះអជិត ១ តិស្សមេត្តេយ្យ ១ បុណ្ណកៈ ១ មេត្តគូ ១ ធោតកៈ ១ ឧបសីវៈ ១ នន្ទៈ ១ ហេមកៈ ១ តោទេយ្យ ១ កប្បៈ ១ ជតុកណ្ណីមាណពជាបណ្ឌិត ១ ភទ្រាវុធ ១ ឧទយៈ ១ ព្រាហ្មណពោសាល ១ មោឃរាជ ជាអ្នកប្រាជ្ញ ១ បិង្គិយៈជាមហាឥសី ១ ព្រាហ្មណ៍ទាំង ១៦ នាក់នុ៎ះ បានទៅគាល់ព្រះពុទ្ធ ជាអ្នកស្វែងរកនូវគុណ មានចរណៈគឺធម៌ជាគ្រឿងប្រព្រឹត្តដ៏បរិបូណ៌ បានចូលទៅក្រាបទូលសួរបញ្ហាដ៏ល្អិត ចំពោះព្រះពុទ្ធ ជាបុគ្គលប្រសើរ ។ ព្រះពុទ្ធជាព្រះមុនី បានដោះស្រាយនូវបញ្ហាទាំងឡាយ ដែលពួកព្រាហ្មណ៍ទូលសួរ តាមសេចក្តីពិត បានញុំាងពួកព្រាហ្មណ៍ ឲ្យត្រេកអរដោយការដោះស្រាយបញ្ហា ។ ព្រាហ្មណ៍ទាំង ១៦ នាក់នោះ កាលបើព្រះពុទ្ធ ជាអាទិច្ចវង្ស មានចក្ខុ គឺប្រាជ្ញាញាណ បានឲ្យត្រេកអរហើយ ក៏បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះសាស្តា មានបញ្ញាដ៏ប្រសើរ ។

ឯកមេកស្ស បញ្ហស្ស យថា ពុទ្ធេន ទេសិតំ ។

តថា យោ បដិបជ្ជេយ្យ គច្ឆេ បារំ អបារតោ

អបារា បារំ គច្ឆេយ្យ ភាវេន្តោ មគ្គមុត្តមំ ។

មគ្គោ សោ បារគមនាយ តស្មា បារាយនំ ឥតិ ។

(១៣០) បារាយនមនុគាយិស្សំ (ឥច្ចាយស្មា បិង្គិយោ)

(យថា អទ្ទក្ខិ តថា អក្ខាសិ[១]) វិមលោ ភូរិមេធសោ

និក្កាមោ និព្វុតោ នាគោ[២] កិស្ស ហេតុ មុសា ភណេ ។

បហីនមលមោហស្ស មានមក្ខប្បហាយិនោ

ហន្ទាហំ កិត្តយិស្សាមិ គិរំ វណ្ណូបសញ្ហិតំ ។

---

១ ឱ. អក្ខាសិ ។ ២ ឱ. និក្កាមោ និព្វុតោ នាថោ ។ ម. និក្កាមោ និព្ពនោ នាគោ ។

ព្រះពុទ្ធវចនៈ ដែលព្រះពុទ្ធទ្រង់សំដែងហើយ ចំពោះបញ្ហាមួយ ៗ ដោយប្រការយ៉ាងណា ៗ បើបុគ្គលណា ប្រតិបត្តិតាមដូច្នោះ បុគ្គលនោះគប្បីទៅអំពីទីមិនមែនជាត្រើយ កាន់ត្រើយបាន ព្រោះហេតុនោះ បុគ្គលកាលចំរើនមគ្គដ៏ឧត្តមគឺអដ្ឋង្គិកមគ្គ គប្បីចេញចាកទីមិនមែនត្រើយ ទៅកាន់ត្រើយគឺព្រះនិព្វាន ៗ មគ្គនោះតែងប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រើយ គឺព្រះនិព្វាន ព្រោះហេតុនោះ ទើបឈ្មោះថា បារាយនៈ ដោយប្រការដូច្នេះ ៗ

(១៣០) (បិង្គិយៈ ដ៏មានអាយុ ពោលសរសើរព្រះមានព្រះភាគ ក្នុងទីជិតពាវរីព្រាហ្មណ៍ ដូច្នេះថា) ខ្ញុំនឹងប្រៀងតាមបារាយនធម៌ (ព្រះមានព្រះភាគ បានឃើញ យ៉ាងណា ទ្រង់សំដែងយ៉ាងនោះ) ព្រះមានព្រះភាគប្រាសចាកមន្ទិល ព្រះអង្គមានប្រាជ្ញាញាណដូចជាផែនដី ព្រះអង្គមានសេចក្តីប្រាថ្នាលះចេញហើយ មានទុក្ខលត់ហើយ ព្រះអង្គជាបុគ្គលប្រសើរ គប្បីពោលពាក្យមុសាវាទ ដោយហេតុដូចម្តេចកើត ៗ បើដូច្នោះ ខ្ញុំនឹងសូមសំដែងវាចា ដែលប្រកបដោយគុណ គួរសរសើររបស់ព្រះមានព្រះភាគ ព្រះអង្គមានមន្ទិលនិងមោហៈ លះបង់ហើយ ទាំងមានះ និងមក្ខៈ គឺព្រះអង្គលះបង់បានដាច់ស្រឡះហើយ ៗ

តមោនុទោ ពុទ្ធោ សមន្តចក្ខុ
លោកន្តគូ(១) សព្វភវាតិវត្តោ
អនាសវោ សព្វទុក្ខប្បហានោ(២)
សច្ចវ្ហយោ ព្រហ្មុបាសិតោ(៣) មេ ។
ទិជោ យថា កុព្វនកំ បហាយ
ពហុប្ផលំ កាននំ អាវសេយ្យ(៤)
ឯវម្បហំ អប្បទស្សេ បហាយ
មហោទធឹ ហំសរិវជ្ឈបត្តោ ។

យេមេ បុព្វេ វិយាកំសុ (ហុរំ គោតមសាសនា)
ឥច្ចាសិ ឥតិ ភវិស្សតិ សព្វំ តំ ឥតិហីតិហំ
សព្វំ តក្កវឌ្ឍនំ

(នាហំ តត្ថ អភិរមឹ)

ឯកោ តមនុទាសីនោ ជុតិមា(៥) សោ បភង្ករោ ។

---

១- ម. លោកន្តូ ។ ២- ឱ. ម. សព្វទុក្ខប្បហីនោ ។ ៣- ឱ. ម. ព្រហ្មេ ឧបាសិ-
តោ ។ ៤- ម. កាននមាវសេយ្យ ។ ៥ ឱ. ម. ជាតិមា ។

សុត្តនិបាត បារាយនានុសង្គីតិគាថា

ព្រះពុទ្ធមានចក្ខុជុំវិញ គឺសព្វញ្ញុតញ្ញាណ បន្ទោបង់នូវសេចក្តីងងឹត ដល់នូវទីបំផុតនៃលោក កន្លងផុតនូវភពទាំងពួង ព្រះអង្គមិនមានអាសវៈ លះបង់នូវទុក្ខទាំងពួង មានព្រះនាមជាសច្ចបុគ្គល ខ្ញុំក៏បានចូលទៅរកព្រះមានព្រះភាគដ៏ប្រសើររួចហើយ ។ បក្សីលះបង់ព្រៃតូច(មានផ្លែឈើតិច) មកអាស្រ័យព្រៃធំ មានផ្លែឈើច្រើន ដូចម្តេចមិញ ខ្ញុំលះបង់គណាចារ្យដែលមានសេចក្តីឃើញតិច (មកប្រសព្វព្រះមានព្រះភាគ) មានព្រះប្រាជ្ញាដ៏ច្រើន ដូចហង្សហើរមកចុះក្នុងស្រះធំ ។ ពួកអាចារ្យណា មុន (សាសនាព្រះគោតម) អាចារ្យទាំងនោះ បានព្យាករហើយ ដោយអាងគោលការណ៍ថា ដំណើរនោះ តែងមានមកហើយដូច្នោះ ។ នឹងមានតទៅខាងមុខដូច្នេះ ។ (នេះជាពាក្យប្រដៅក្រៅចាកពាក្យប្រដៅព្រះគោតម) សេចក្តីព្យាករណ៍ទាំងអស់នោះ (មិនទាន់ប្រាកដទេ) គ្រាន់តែពោលថាដូច្នេះ ។ សេចក្តីព្យាករណ៍ទាំងអស់នោះ ជាគ្រឿងធ្វើសេចក្តីត្រិះរិះឲ្យចំរើនឡើង (ខ្ញុំមិនពេញចិត្តក្នុងពាក្យនោះឡើយ) ព្រះមានព្រះភាគតែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់បន្ទោបង់នូវងងឹត គង់នៅជាសុខ ព្រះអង្គមានរស្មីរុងរឿង ទ្រង់ធ្វើនូវពន្លឺ (ដល់លោក)៕

គោតមោ ភូរិបញ្ញាណោ គោតមោ ភូរិមេធសោ

យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ

តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចិ ។

កិន្នុ តម្ហា វិប្បវសសិ មុហុត្តមបិ បិង្គិយ

គោតមា ភូរិបញ្ញាណា គោតមា ភូរិមេធសា

យោ តេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ

តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចិ ។

នាហំ តម្ហា វិប្បវសាមិ មុហុត្តមបិ ព្រាហ្មណ

គោតមា ភូរិបញ្ញាណា គោតមា ភូរិមេធសា

ព្រះគោតម មានញាណដ៏ច្រាស់ដូចផែនដី ព្រះគោតម ព្រះអង្គប្រកបដោយប្រាជ្ញាច្រាស់ ដូចផែនដី ទ្រង់សំដែងធម៌ (ជាដំណើរទៅកាន់ព្រះនិព្វាន) ប្រកបដោយផលគួរឃើញជាក់ច្បាស់ មិនមានកំណត់កាល ជាគ្រឿងអស់តណ្ហា មិនមានឧបទ្រវៈ គឺកិលេស ដល់ខ្ញុំ នឹងរកសេចក្តីឧបមាចំពោះព្រះនិព្វាន ក្នុងទីណាមួយ មិនបានឡើយ ។

(ពាវរីព្រាហ្មណ៍សួរបិង្គិយមាណពថា) ម្នាលបិង្គិយៈ អ្នកដែលនៅឃ្លាត អំពីព្រះគោតមមានញាណច្រាស់ដូចផែនដី អំពីព្រះគោតម ប្រកបដោយប្រាជ្ញាច្រាស់ដូចផែនដីនោះ សូម្បីមួយរំពេចដែរឬ ព្រះគោតមដែលបានសំដែងធម៌ ប្រកបដោយផលគួរឃើញជាក់ច្បាស់ មិនមានកំណត់កាល ជាគ្រឿងអស់ទៅនៃតណ្ហា មិនមានឧបទ្រវៈ ដល់អ្នក នឹងរកសេចក្តីឧបមា ចំពោះព្រះនិព្វាន ក្នុងទីណាមួយ មិនមានមែនទេឬ ។

(បិង្គិយមាណពតបថា) បពិត្រពាវរីព្រាហ្មណ៍ ខ្ញុំមិនដែលឃ្លាត អំពីព្រះគោតម អ្នកមានញាណច្រាស់ ដូចផែនដី អំពីព្រះគោតម អ្នកប្រកបដោយប្រាជ្ញាច្រាស់ ដូចផែនដីនោះ សូម្បីមួយរំពេចទេ

យោ មេ ធម្មមទេសេសិ សន្ទិដ្ឋិកមកាលិកំ
តណ្ហក្ខយមនីតិកំ យស្ស នត្ថិ ឧបមា ក្វចិ ។

បស្សាមិ នំ មនសា ចក្ខុនាវ
រត្តិន្ទិវំ ព្រាហ្មណ អប្បមត្តោ
នមស្សមានោ វិវសាមិ រត្តឹ
តេនេវ មញ្ញាមិ អវិប្បវាសំ ។

សទ្ធា ច បីតិ ច មនោ សតិ ច
នាបេន្តិ មេ(១) គោតមសាសនម្ហា
យំ យំ ទិសំ វជតិ ភូរិបញ្ញោ
ស តេន តេនេវ នតោហមស្មិ ។

ជិណ្ណស្ស មេ ទុព្វលថាមកស្ស
តេនេវ កាយោ ន បលេតិ តត្ថ
សង្កប្បយត្តាយ(២) វជាមិ និច្ចំ
មនោ ហិ មេ ព្រាហ្មណ តេន យុត្តោ ។

---

១ ឱ. នាបេន្តិ ។ ម. នាបេតិ ។ ២ ឱ. សង្កប្បយន្តាយ ។

ព្រះគោតមសំដែងធម៌ ប្រកបដោយផលគួរឃើញជាក់ច្បាស់ មិនមានកំណត់កាល ជាគ្រឿងអស់ទៅនៃតណ្ហា មិនមានឧបទ្ទវៈដល់ខ្ញុំ ទីនឹងរកសេចក្តីឧបមាចំពោះព្រះនិព្វាន ក្នុងទីណាមួយ មិនមានពិតមែន ៗ បពិត្រពាវរីព្រាហ្មណ៍ ខ្ញុំមិនប្រមាទ ទាំងយប់ទាំងថ្ងៃ ឃើញព្រះគោតម មានព្រះភាគអង្គនោះ ដោយចិត្ត ហាក់បីដូចជាឃើញ ដោយចក្ខុ ខ្ញុំនមស្ការ (ព្រះគោតម) នៅរហូតរាត្រី ខ្ញុំសំគាល់ឃើញ នូវការមិននៅប្រាសចាកព្រះគោតមនោះឯង ៗ ធម៌ ៤ យ៉ាងនេះ គឺសទ្ធា ១ បីតិ ១ មនៈ ១ សតិ ១ (ដែលមានក្នុងសន្តានរបស់ខ្ញុំ) រមែងមិនប្រាសចាកសាសនានៃព្រះគោតមទេ ព្រះគោតមអ្នកមានបញ្ញា ដូចផ្ទៃផែនដី ស្តេចទៅកាន់ទិសណា ៗ ខ្ញុំនោះ ក៏ជាអ្នកបង្អោនចិត្តទៅហើយ ដោយទិសាភាគនោះៗឯង ៗ បពិត្រពាវរីព្រាហ្មណ៍ ខ្ញុំជាបុគ្គលចាស់ មានកំឡាំងថយហើយ ហេតុនោះ កាយទៅក្នុងទីនោះមិនបានទេ ខ្ញុំទៅអស់កាលជានិច្ច ដោយដំណើរគឺសេចក្តីត្រិះរិះ ព្រោះថា ចិត្តខ្ញុំប្រកបហើយ ដោយការលើកព្រះគោតមនោះ ៗ

បន្តេ (សយានោ) បរិជុន្នមានោ ចីតាចីបំ ឧបស្សីរ(១)

អជ្ឈាសាសិ សម្ពុទ្ធំ ខិយតិណ្ណាមជាសរំ ។

យថា អហុ វក្កលិ មុត្តសទ្ធោ

ភទ្រាវុធោ អាឡវិគោតមោ ច

ឯវមេវ ត្វម្បិ បមុញ្ចស្សុ សទ្ធំ

គមិស្សសិ ត្វំ បិង្គិយ មច្ចុធេយ្យស្ស បារំ ។

ឯស ភិយ្យោ បសីទាមិ សុត្វាន មុនិនោ វចោ

វិវដច្ឆទោ សម្ពុទ្ធោ អខិលោ បដិភាណវា

អធិទេវេ អភិញ្ញាយ សព្វំ វេទិ បរោវរំ(២)

---

១ ឱ. ម. ឧបបូរំ ។ ២ ម. វរោវរំ ។

(ពាវរីព្រាហ្មណ៍តបថា) ខ្ញុំ(ដេកនៅ) ក្នុងភក់គឺកាម អន្ទះអន្ទែង(ព្រោះតណ្ហា) សាត់អណ្តែតទៅអំពីកោះ ទៅកាន់កោះ គឺចេញអំពីសំណាក់សាស្តាមួយ ទៅកាន់សំណាក់សាស្តាមួយ ខ្ញុំក៏បានជួបប្រទះ នឹងព្រះសម្ពុទ្ធព្រះអង្គមិនមានអាសវៈ ឆ្លងផុតឱឃៈហើយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា វក្កលិ ១ ភទ្រាវុធ ១ និងអាឡវិគោតម ១ សុទ្ធតែជាអ្នកមានសទ្ធាចុះស៊ប់ យ៉ាងណាមិញ សូម្បីអ្នកក៏ចូរបញ្ចេញនូវសទ្ធាមកចុះ ក៏យ៉ាងនោះដែរ ម្នាលបិង្គិយៈ អ្នកនឹងដល់នូវត្រើយនៃសង្សារ ជាទីតាំងនៃមច្ចុមារ ។

(ព្រះបិង្គិយៈ ទូលសរសើរព្រះមានព្រះភាគថា) ខ្ញុំព្រះអង្គនេះជ្រះថ្លាដោយក្រៃពេក ព្រោះបានស្តាប់ព្រះវាចានៃព្រះអង្គ ជាព្រះមុនីព្រះអង្គត្រាស់ដឹងហើយ ដោយព្រះអង្គឯង ព្រះអង្គមានដំបូលគ្រឿងប្រក់បើកហើយ មិនមានកិលេសគ្រឿងរឹងត្អឹង ទ្រង់មានបដិភាណ ទ្រង់ជ្រាបនូវអធិទេវៈទាំងឡាយ គឺធម៌សម្រាប់ធ្វើសត្វឲ្យជាទេវតា ដ៏ក្រៃលែង ទ្រង់ជ្រាបនូវធម្មជាតទាំងពួង ជាធម៌ដ៏ប្រសើរនិងថោកទាប (ដល់ខ្លួននិងអ្នកដទៃ) ។

បញ្ហានន្តករោ សត្ថា កង្ខីនំ បដិជានតំ
អសំហីរំ អសង្កុប្បំ យស្ស នត្ថិ ឧបមា ក្វចិ ។
អទ្ធា គមិស្សាមិ ន មេត្ថ កង្ខា
ឯវំ មំ ធារេហិ អធិមុត្តចិត្តន្តិ ។

បារាយនវគ្គោ បញ្ចមោ ។

## សុត្តនិបាតេ សុត្តុទ្ទានំ

(១៣១) ឧរគោ ធនិយោ ច ខគ្គវិសាណោ កសិ
ចុន្ទោ ភវោ បុនទេវ វសលោ ច ករណីយញ្ច
ហេមវតោ អថ យក្ខោ វិជយំ សុត្តវរំ មុនិ ។
សេដ្ឋោ បឋមកដ្ឋបវរោ វគ្គោ
ទ្វាទសសុត្តធរោ សុវិភត្តោ
ទេសិតោ ចក្ខុមតា វិមលេន
សុយ្យតិ វគ្គវរោ ឧរគោតិ ។

ព្រះសាស្ដាទ្រង់ឆ្លើយនូវទីបំផុតនៃបញ្ហាទាំងឡាយ ដល់ពួកជនដែលប្ដេជ្ញាថាជាអ្នកមានសេចក្ដីសង្ស័យ ព្រះនិព្វាន ជាគុណជាតមិនកក្រើក មិនញាប់ញ័រ សេចក្ដីឧបមា ចំពោះព្រះនិព្វាន ក្នុងទីណាមួយ មិនមានឡើយ ។ ខ្ញុំព្រះអង្គនឹងដល់ (នូវអនុបាទិសេស-និព្វានធាតុ) ដោយពិត សេចក្ដីសង្ស័យ ក្នុងព្រះនិព្វាននោះមិនមានដល់ខ្ញុំព្រះអង្គទេ សូមព្រះមានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាអ្នកមានចិត្តជឿស៊ប់ (ក្នុងព្រះនិព្វាន) ដោយប្រការដូច្នេះ ។

ចប់ បារាយនវគ្គ ទី ៥ ។

## ឧទ្ទាននៃសូត្រ ក្នុងសុត្តនិបាត

(១៣១) ឧរគសូត្រ ១ ធនិយសូត្រ ១ ខគ្គវិសាណសូត្រ ១ កសិភារទ្វាជសូត្រ ១ ចុន្ទសូត្រ ១ បរាភវសូត្រ ១ វសលសូត្រ១ ករណីយមេត្តសូត្រ ១ ហេមវតសូត្រ ១ អាឡវកយក្ខសូត្រ ១ វិជយសូត្រ ១ មុនិសូត្រ ជាសូត្រដ៏ប្រសើរ ១ ។

វគ្គដ៏ប្រសើរថ្លៃថ្លាតាំងនៅជាដំបូង ជាវគ្គទ្រទ្រង់នូវសូត្រ ១២ លោកចែកទុកល្អហើយ ព្រះមានព្រះភាគទ្រង់មានចក្ខុប្រាសចាកមន្ទិល ទ្រង់សំដែងទុកហើយ យើងឮមកថា ឧរគវគ្គជាវគ្គដ៏ប្រសើរ ។

រតនាមគន្ធោ ហិរិមង្គលនាមោ
សូចិលោមកបិលោ ច ព្រាហ្មណធម្មោ
នាវា កឹសីលឧដ្ឋានោ ច
រាហុលោ ច បុនបិ វង្គីសោ
សម្មាបរិព្វាជនិយោ ច ឥធ
ធម្មិកសុត្តវរោ សុវិចិត្តោ
ចុទ្ទសសុត្តគតោ ទុតិយម្ហិ
ចូឡកវគ្គវរោតិ តមាហុ ។
បព្វជ្ជំ បធានសុភាសិតនាមោ
បុរឡាសោ បុនេវ មាឃោ ច
សភិយកេណិយមេវ សល្លនាមោ
វាសេដ្ឋវរោ កោកាលិកោបិ ច
នាឡកសុត្តវរោ សុវិចិត្តោ
តំ អនុបស្សី តថា បុនេវ
ទ្វាទសសុត្តគតោ តតិយម្ហិ
សុយ្យតិ វគ្គវរោ មហានាមោ ។

រតនសូត្រ ១ អាមគន្ធសូត្រ ១ ហិរិសូត្រ ១ មង្គលសូត្រ ១ សូចិលោមសូត្រ ១ កបិលសូត្រ ឬ ធម្មចរិយសូត្រ ១ ព្រាហ្មណធម្មិកសូត្រ ១ នាវាសូត្រ ១ កឹសីលសូត្រ ១ ឧដ្ឋានសូត្រ ១ រាហុលសូត្រ ១ វង្គីសសូត្រ ១ សម្មាបរិព្វាជនីយសូត្រ ១ ធម្មិកសូត្រដ៏ប្រសើរ ១ លោកថែកទុកល្អហើយ ក្នុងវគ្គនោះ បណ្ឌិតទាំងឡាយ ពោលនូវវគ្គនោះ ថាជាចូឡកវគ្គដ៏ប្រសើរ ប្រុប្រួលនូវសូត្រ ១៤ ក្នុងលើកទី ២ ។

បព្វជ្ជាសូត្រ ១ បធានសូត្រ ១ សុភាសិតសូត្រ ១ បុរាឡាស ឬ សុន្ទរិកសូត្រ ១ មាឃសូត្រ ១ សភិយសូត្រ ១ កេណិយសូត្រ ឬ សេលសូត្រ ១ សល្លសូត្រ ១ វាសេដ្ឋសូត្រដ៏ប្រសើរ ១ កោកាលិកសូត្រ ១ នាឡកសូត្រដ៏ប្រសើរ ១ លោកថែកទុកល្អហើយ ទ្វយតានុបស្សនាសូត្រ ១ យើងពោលថា មហាវគ្គជាវគ្គដ៏ប្រសើរ ប្រុប្រួលនូវសូត្រ ១២ ក្នុងលើកទី ៣ ។

## សុត្តនិបាតេ សុត្តុទ្ទានំ

កាមគុហដ្ឋកទុដ្ឋដ្ឋកជាមោ

សុទ្ធដ្ឋកេ បរមដ្ឋកជាមោ

ជរាមេត្តិយសុត្តកេ សុរិកត្តា

បសូរមាគន្ទិយោ ច បូរភេទោ

កលហវិវាទោ ឧកោ វិយុហា ច

តុវដ្ដកអត្តទណ្ឌសារីបុត្តា ច

សោឡសសុត្តជកេ ចតុត្តិម្ហា

អដ្ឋកវគ្គិកេតិ តមាហុ ៗ

មគេច ជឧបេឧ រមណីយេ

ទេសរេ កាតបុញ្ញធិរេសេ

ចាសាណកចេតិយរេ សុរិកត្តេ

វសី ករក គណសេដ្ឋោ

ឧកយំ ភ បុណ្ណសមាគតំ យម្ហិ

ត្វាឧសយោជធិយា បរិសាយ

សោឡសព្រាហ្មណានំ គតិរ បុដ្ឋោ

## ឧទ្ទាននៃព្រះសូត្រ ក្នុងសុត្តនិបាត

កាមសូត្រ ១ គុហដ្ឋកសូត្រ ១ ទុដ្ឋដ្ឋកសូត្រ ១ សុទ្ធដ្ឋកសូត្រ ដ៏ប្រសើរ ១ បរមដ្ឋកសូត្រ ១ ជរាសូត្រ ១ តិស្សមេត្តេយ្យសូត្រ ដ៏ប្រសើរ លោកបែកទុកល្អហើយ ១ បសូរសូត្រ ១ មាគន្ទិយ-សូត្រ ១ បុរាភេទសូត្រ ១ កលហវិវាទសូត្រ ១ វិយូហសូត្រ ២ គឺ ចុល្លវិយូហសូត្រនឹងមហាវិយូហសូត្រ តុវដ្តកសូត្រ ១ អត្តទណ្ឌ-សូត្រ ១ សារីបុត្តសូត្រ ១ បណ្ឌិតទាំងឡាយ ពោលនូវវគ្គនោះថា អដ្ឋកវគ្គ ជាវគ្គដ៏ប្រសើរ ទ្រទ្រង់នូវសូត្រ ១៦ ក្នុងលោកទី ៤ ។

ដូចបានពោលថា ព្រះមានព្រះភាគ ជាបុគ្គលប្រសើរ ក្នុងគណៈ ទ្រង់គង់ក្នុងបាសាណកចេតិយដ៏ប្រសើរ ដែលបុគ្គលតាក់តែងល្អហើយ ក្នុងប្រទេសដ៏ប្រសើរ ជាប្រទេស ជាទីនៅនៃបុគ្គលអ្នកមានបុណ្យបានធ្វើហើយ ក្នុងមគធជនបទ ជារមណីយ-ដ្ឋាន ដែលព្រាហ្មណ៍ទាំង ១៦ នាក់ ទូលសួរហើយ នូវធម៌ណាទាំងពីរដ៏បរិបូណ៌គ្រប់គ្រាន់ ក្នុងបរិសទ្យ មានយោជន៍ ១២

បុច្ឆាយ សោឡសបញ្ហាកម្មនិយា
ទិប្បកាសយិ ធម្មមទាសិ
អត្ថបកាសកព្យញ្ជនបុណ្ណំ
ធម្មមទេសេសិ បរខេមជនិយំ
លោកហិតាយ ជិនោ ទិបទគ្គោ ៗ
សុត្តវរំ ពហុធម្មវិចិត្រំ
សព្វកិលេសមោចនហេតុំ
ទេសយិ សុត្តវរំ ទិបទគ្គោ ៗ
ព្យញ្ជនមត្ថបទសមយុត្តំ
អក្ខរសញ្ញិតឱបមគ្គាឡ្ហំ
លោកវិចារណញាណបភគ្គំ
ទេសយិ សុត្តវរំ ទិបទគ្គោ ៗ
រាគមលេ អមលំ វិមលគ្គំ
ទោសមលេ អមលំ វិមលគ្គំ
មោហមលេ អមលំ វិមលគ្គំ
លោកវិចារណញាណបភគ្គំ
ទេសយិ សុត្តវរំ ទិបទគ្គោ ៗ

ទ្រង់ប្រកាសប្រទាននូវធម៌ តាមពាក្យបុច្ឆា គួរដល់បញ្ហាកម្ម ១៦ ព្រះជិនស្រី ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់ប្រកាសនូវអត្ថបរិបូណ៌ដោយព្យញ្ជនៈ ជាទីកើតនៃសេចក្តីក្សេមក្សាន្ត ដល់សត្វដទៃ ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងនូវសូត្រដ៏ប្រសើរ ដ៏វិចិត្រដោយធម៌ច្រើនយ៉ាង ទ្រង់សំដែងសូត្រដ៏ប្រសើរ ជាហេតុរួចចាកកិលេសទាំងពួង ។

ព្រះសម្មាសម្ពុទ្ធ ប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរ ប្រកបព្រម ដោយព្យញ្ជនៈនឹងអត្ថនឹងបទ ដែលគួរសំគាល់បាន ដោយអក្ខរៈដែលបុះកាន់សេចក្តីឧបមា ជាពន្លឺដ៏ប្រសើរ គឺញាណ ជាគ្រឿងពិចារណានូវលោក ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរមិនមានមន្ទិល ព្រោះចាកមន្ទិលដ៏ប្រសើរ ក្នុងមន្ទិលគឺរាគៈ មិនមានមន្ទិល ព្រោះចាកមន្ទិលដ៏ប្រសើរក្នុងមន្ទិលគឺទោសៈ មិនមានមន្ទិល ព្រោះចាកមន្ទិលដ៏ប្រសើរ ក្នុងមន្ទិលគឺមោហៈ ជាពន្លឺដ៏ប្រសើរ គឺញាណជាគ្រឿងពិចារណានូវលោក ។

សុត្តនិបាតេ សុត្តន្តានំ

ក្លេសមលេ អមលំ វិមលត្តំ

ទុច្ចរិតមលេ អមលំ វិមលត្តំ

លោកាវិចារណាញាណាបកត្តំ

ទេសយិ សុត្តានំ និបនេត្តោ ៗ

អាសវតណ្ហយោគកិលេសំ

ធីរណានិ ច តីណិ ច មលានិ

តស្ស កិលេសបមោចនហេតុំ

ទេសយិ សុត្តានំ និបនេត្តោ ៗ

និម្មលសព្វកិលេសបទូនំ

រាគវិរាគមនេជមសោកំ

សន្តបណីតសុទុទ្ទសធម្មំ

ទេសយិ សុត្តានំ និបនេត្តោ ៗ

រាគញ្ច ទោសញ្ច កញ្ចិតសន្តិំ

យោនិំ ច ទុក្ខិតបញ្ចវិញ្ញាណំ

តណ្ហាតលរតេន្ទធនតាណាបមោក្ខំ

ទេសយិ សុត្តានំ និបនេត្តោ ៗ

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលដ៏ប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរមិនមានមន្ទិល ប្រាសចាកមន្ទិលដ៏ប្រសើរ ក្នុងមន្ទិលគឺកិលេស ប្រាសចាកមន្ទិលដ៏ប្រសើរ ក្នុងមន្ទិលគឺទុច្ចរិត ជាពន្លឺដ៏ប្រសើរ គឺញាណជាគ្រឿងពិចារណានូវលោក ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងនូវកិលេស ជាគ្រឿងត្រាំ គ្រឿងចង គ្រឿងប្រកបផង នូវនីវរណៈទាំងឡាយផង នូវមន្ទិល ៣ ផង នូវសូត្រដ៏ប្រសើរ ជាហេតុនៃកិរិយារួចចាកកិលេសផង ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរ ជាគ្រឿងបន្ទោបង់នូវកិលេសទាំងពួង មិនឲ្យមានមន្ទិល ប្រាសចាកកិលេសគ្រឿងត្រេកអរ មិនញាប់ញ័រ មិនសោកស្តាយ ជាធម៌ល្អិតសុខុមដែលបុគ្គលឃើញបានដោយកម្រក្រៃលែង ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងនូវសូត្រ ដ៏ប្រសើរ ជាប្រធាននៃទីពឹងជាទីកាត់បង់នូវផ្លូវនៃតណ្ហានិងតម្រេក ដែលបំបាក់បង់នូវរាគៈនិងទោសៈឲ្យស្ងប់រម្ងាប់ និងកំណើត ទុគ្គតិ វិញ្ញាណ ៥ ។

គម្ភីរធម្មស្ស សណ្ហា និបុណំ
បណ្ឌិតវេទនិយំ និបុណត្ថំ
លោកវិចារណាញាណបកត្តិំ
ទេសយិ សុត្តវរំ និបនត្ថោ ៗ
ធវត្តកុ សុមធុរលេករណំ
ឥន្ទ្រិយ ជល្លា ធរិមោ ក្ខរិកត្តិំ
អដ្ឋង្គិកមគ្គវរំ វរយានំ
ទេសយិ សុត្តវរំ និបនត្ថោ ៗ
សោមុបមំ វិមលំ បរិសុទ្ធំ
អណ្ណវមុបមា រតនសុចិត្តំ
បុប្ផសមំ រវិមុបមតេជំ
ទេសយិ សុត្តវរំ និបនត្ថោ ៗ
ខេមសិវំ សុខសីតលសន្តិំ
មច្ចុតាណាបរមត្ថំ
តស្ស សុនិព្វុតទស្សនហេតុំ
ទេសយិ សុត្តវរំ និបនត្ថោ ៗ

សុត្តនិបាតោ និដ្ឋិតោ ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរ គ្រប់គ្រាន់ដោយអត្ថដ៏ជ្រាលជ្រៅ ទឹងអត្ថដ៏ល្អិតដែលបុគ្គលឃើញបានដោយក្រ មានអត្ថដ៏ល្អិតដែលបណ្ឌិតគប្បីដឹងបាន ជាពន្លឺដ៏ប្រសើរគឺញាណជាគ្រឿងពិចារណានូវលោក ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរ បែកនូវឥន្ទ្រិយ ឈានទឹងវិមោក្ខ ប្រកបដោយមគ្គមានអង្គ ៨ ដ៏ប្រសើរ ជាយានដ៏ប្រសើរ ដូចគ្រឿងប្រដាប់នៃផ្កាឈើមានពណ៌សគឺនវង្គសត្ថុសាសនា ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរ ដ៏បរិសុទ្ធឥតមានមន្ទិល មានឧបមាដូចព្រះចន្ទ្រវិចិត្រល្អដោយរតនៈ មានឧបមាដូចមហាសមុទ្រ ឧបមាដូចបុប្ផជាតិ មានតេជះ ឧបមាដូចព្រះអាទិត្យ ។

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរជាងសត្វមានជើងពីរ ទ្រង់សំដែងសូត្រដ៏ប្រសើរជាទីដល់នូវព្រះនិព្វានដ៏ក្សេម ជាសុខដ៏ត្រជាក់ស្ងប់រម្ងាប់ មានអត្ថដ៏ប្រសើរ ជាទីការពារនូវមច្ចុរាជ ជាហេតុឃើញនូវសេចក្ដីស្ងប់ដ៏ប្រពៃ នៃអ្នកប្រតិបត្តិតាម ។

ចប់ សុត្តនិបាត ។

# សុត្តន្តបិដកេ
# ខុទ្ទកនិកាយស្ស សុត្តនិបាតោ
# តតិយោ ភាគោ

---

មាតិកា អង្កេ


បឋមស្ស ឧរគវគ្គស្ស បឋមំ ឧរគសុត្តំ . . ១

ទុតិយំ ធនិយសុត្តំ . . . . . ៧

តតិយំ ខគ្គវិសាណសុត្តំ . . . . ១៣

ចតុត្ថំ កសិភារទ្វាជសុត្តំ . . . . ២៦

បញ្ចមំ ចុន្ទសុត្តំ . . . . ៣៣

ឆដ្ឋំ បរាភវសុត្តំ . . . . . ៣៦

សត្តមំ វសលសុត្តំ . . . . . ៤២

អដ្ឋមំ មេត្តសុត្តំ . . . . . ៥០

នវមំ ហេមវតសុត្តំ . . . . . ៥៣

ទសមំ អាឡវកសុត្តំ . . . . ៦០

ឯកាទសមំ វិជយសុត្តំ . . . . ៦៤

ទ្វាទសមំ មុនិសុត្តំ . . . . . ៦៨

# សុត្តន្តបិដក
# ខុទ្ទកនិកាយ សុត្តនិបាត
# តតិយភាគ

---

មាតិកា ទំព័រ


| | |
|---|---|
| ឧរគវគ្គ ទី ១ ឧរគសូត្រ ទី ១ | ១ |
| ធនិយសូត្រ ទី ២ | ៧ |
| ខគ្គវិសាណសូត្រ ទី ៣ | ១៣ |
| កសិភារទ្វាជសូត្រ ទី ៤ | ២៦ |
| ចុន្ទសូត្រ ទី ៥ | ៣៣ |
| បរាភវសូត្រ ទី ៦ | ៣៦ |
| វសលសូត្រ ទី ៧ | ៤២ |
| មេត្តសូត្រ ទី ៨ | ៥០ |
| ហេមវតសូត្រ ទី ៩ | ៥៣ |
| អាឡវកសូត្រ ទី ១០ | ៦០ |
| វិជយសូត្រ ទី ១១ | ៦៥ |
| មុនិសូត្រ ទី ១២ | ៦៨ |

# មាតិកាបត្តានិ


| មាតិកា | អង្កៃ |
|---|---|
| ទុតិយស្ស ចូឡវគ្គស្ស បឋមំ រតនសុត្តំ | ៧៣ |
| ទុតិយំ អាមគន្ធសុត្តំ | ៧៩ |
| តតិយំ ហិរិសុត្តំ | ៨៣ |
| ចតុត្ថំ មង្គលសុត្តំ | ៨៥ |
| បញ្ចមំ សូចិលោមសុត្តំ | ៨៨ |
| ឆដ្ឋំ ធម្មចរិយសុត្តំ | ៩១ |
| សត្តមំ ព្រាហ្មណធម្មិកសុត្តំ | ៩៣ |
| អដ្ឋមំ នាវសុត្តំ | ១០១ |
| នវមំ កឹសីលសុត្តំ | ១០៤ |
| ទសមំ ឧដ្ឋានសុត្តំ | ១០៦ |
| ឯកាទសមំ រាហុលសុត្តំ | ១០៧ |
| ទ្វាទសមំ វង្គីសសុត្តំ | ១០៩ |
| តេរសមំ សម្មាបរិព្វាជនីយសុត្តំ | ១១៦ |
| ចុទ្ទសមំ ធម្មិកសុត្តំ | ១២១ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| ចូឡវគ្គទី ២ រតនសូត្រ ទី ១ | ៧៣ |
| អាមគន្ធសូត្រ ទី ២ | ៧៩ |
| ហិរិសូត្រ ទី ៣ | ៨៣ |
| មង្គលសូត្រ ទី ៤ | ៨៥ |
| សូចិលោមសូត្រ ទី ៥ | ៨៨ |
| ធម្មចរិយសូត្រ ទី ៦ | ៩១ |
| ព្រាហ្មណធម្មិកសូត្រ ទី ៧ | ៩៣ |
| នាវាសូត្រ ទី ៨ | ១០១ |
| កឹំសីលសូត្រ ទី ៩ | ១០៤ |
| ឧដ្ឋានសូត្រ ទី ១០ | ១០៦ |
| រាហុលសូត្រ ទី ១១ | ១០៧ |
| វង្គីសសូត្រ ទី ១២ | ១០៩ |
| សម្មាបរិព្វាជនីយសូត្រ ទី ១៣ | ១១៦ |
| ធម្មិកសូត្រ ទី ១៤ | ១២១ |

# មាតិកាបត្តានិ


| មាតិកា | ពេង្ក |
| --- | --- |
| តតិយស្ស មហាវគ្គស្ស បឋមំ បព្វជ្ជាសុត្តំ . | ១៣១ |
| ទុតិយំ បធានសុត្តំ . . . . | ១៣៥ |
| តតិយំ សុភាសិតសុត្តំ . . . | ១៤០ |
| ចតុត្ថំ សុន្ទរិកសុត្តំ . . . . | ១៤៣ |
| បញ្ចមំ មាឃសុត្តំ . . . | ១៥៦ |
| ឆដ្ឋំ សភិយសុត្តំ . . . . | ១៦៥ |
| សត្តមំ សេលសុត្តំ . . . . | ១៨៥ |
| អដ្ឋមំ សល្លសុត្តំ . . . . | ២០២ |
| នវមំ វាសេដ្ឋសុត្តំ . . . . | ២០៦ |
| ទសមំ កោកាលិកសុត្តំ . . . | ២២២ |
| ឯកាទសមំ នាលកសុត្តំ . . . | ២៣៥ |
| ទ្វាទសមំ ទ្វយតានុបស្សនាសុត្តំ . . | ២៤៦ |
| ចតុត្ថស្ស អដ្ឋកវគ្គស្ស បឋមំ កាមសុត្តំ . | ២៦៥ |
| ទុតិយំ គុហដ្ឋកសុត្តំ . . . . | ២៦៦ |
| តតិយំ ទុដ្ឋដ្ឋកសុត្តំ . . . . | ២៦៨ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|
| មហាវគ្គទី ៣ | បព្វជ្ជាសូត្រ ទី ១ | ១៣១ |
| | បធានសូត្រ ទី ២ | ១៣៥ |
| | សុភាសិតសូត្រ ទី ៣ | ១៤០ |
| | សុន្ទរិកសូត្រ ទី ៤ | ១៤៣ |
| | មាឃសូត្រ ទី ៥ | ១៥៦ |
| | សភិយសូត្រ ទី ៦ | ១៦៥ |
| | សេលសូត្រ ទី ៧ | ១៨៥ |
| | សល្លសូត្រ ទី ៨ | ២០២ |
| | វាសេដ្ឋសូត្រ ទី ៩ | ២០៦ |
| | កោកាលិកសូត្រ ទី ១០ | ២២២ |
| | នាលកសូត្រ ទី ១១ | ២៣៥ |
| | ទ្វយតានុបស្សនាសូត្រ ទី ១២ | ២៤៦ |
| អដ្ឋកវគ្គទី ៤ | កាមសូត្រ ទី ១ | ២៦៥ |
| | គុហដ្ឋកសូត្រ ទី ២ | ២៦៦ |
| | ទុដ្ឋដ្ឋកសូត្រ ទី ៣ | ២៦៨ |

# មាតិកាបត្តាធិ


| មាតិកា | អង្កៃ |
|---|---|
| ចតុត្ថស្ស អដ្ឋកវគ្គស្ស ចតុត្ថំ សុទ្ធដ្ឋកសុត្តំ | ២៧០ |
| បញ្ចមំ បរមដ្ឋកសុត្តំ . . . . | ២៧៣ |
| ឆដ្ឋំ ជរាសុត្តំ . . . . | ២៧៥ |
| សត្តមំ តិស្សមេត្តេយ្យសុត្តំ . . . | ២៧៧ |
| អដ្ឋមំ បសូរសុត្តំ . . . . | ២៧៩ |
| នវមំ មាគន្ទិយសុត្តំ . . . . | ២៨២ |
| ទសមំ បុរាភេទសុត្តំ . . . | ២៨៧ |
| ឯកាទសមំ កលហវិវាទសុត្តំ . . | ២៩០ |
| ទ្វាទសមំ ចូឡវិយូហសុត្តំ . . . | ២៩៦ |
| តេរសមំ មហាវិយូហសុត្តំ . . . | ៣០១ |
| ចុទ្ទសមំ តុវដកសុត្តំ . . , | ៣០៧ |
| បណ្ណរសមំ អត្តទណ្ឌសុត្តំ . . . | ៣១៣ |
| សោឡសមំ សារីបុត្តសុត្តំ . . . | ៣១៨ |
| បញ្ចមស្ស បារាយនវគ្គស្ស វត្ថុគាថា . . | ៣២៥ |
| បឋមា អជិតបញ្ហា . . . . | ៣៣៥ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| អដ្ឋកវគ្គទី៤ សុទ្ធដ្ឋកសូត្រ ទី ៤ | ២៧០ |
| បរមដ្ឋកសូត្រ ទី ៥ | ២៧៣ |
| ជរាសូត្រ ទី ៦ | ២៧៥ |
| តិស្សមេត្តេយ្យសូត្រ ទី ៧ | ២៧៧ |
| បសូរសូត្រ ទី ៨ | ២៧៩ |
| មាគន្ទិយសូត្រ ទី ៩ | ២៨២ |
| បុរាភេទសូត្រ ទី ១០ | ២៨៧ |
| កលហវិវាទសូត្រ ទី ១១ | ២៩០ |
| ចូឡវិយូហសូត្រ ទី ១២ | ២៩៦ |
| មហាវិយូហសូត្រ ទី ១៣ | ៣០១ |
| តុវដកសូត្រ ទី ១៤ | ៣០៧ |
| អត្តទណ្ឌសូត្រ ទី ១៥ | ៣១៣ |
| សារីបុត្តសូត្រ ទី ១៦ | ៣១៨ |
| បារាយនវគ្គទី ៥ វត្ថុគាថា | ៣២៥ |
| អជិតបញ្ហា ទី ១ | ៣៣៥ |

# មាតិកាបត្ថានិ

| មាតិកា | អង្ក |
|---|---|

**បញ្ចមស្ស បារាយនវគ្គស្ស ទុតិយា**


| | |
|---|---|
| តិស្សមេត្តេយ្យបញ្ហា . . . | ៣៣៧ |
| តតិយា បុណ្ណកបញ្ហា . . . | ៣៣៨ |
| ចតុត្ថី មេត្តគូបញ្ហា . . . . | ៣៤០ |
| បញ្ចមី ធោតកបញ្ហា . . . . | ៣៤៤ |
| ឆដ្ឋី ឧបសីវបញ្ហា . . . . | ៣៤៦ |
| សត្តមា នន្ទបញ្ហា . . . . | ៣៤៩ |
| អដ្ឋមា ហេមកបញ្ហា . . . . | ៣៥២ |
| នវមា តោទេយ្យបញ្ហា . . . | ៣៥៣ |
| ទសមា កប្បបញ្ហា . . . . | ៣៥៤ |
| ឯកាទសមា ជតុកណ្ណីបញ្ហា . . . | ៣៥៥ |
| ទ្វាទសមា ភទ្រាវុធបញ្ហា . . . | ៣៥៧ |
| តេទសមា ឧទយបញ្ហា . . . | ៣៥៩ |
| ចុទ្ទសមា បោសាលបញ្ហា . . . | ៣៦០ |
| បណ្ណរសមា មោឃរាជបញ្ហា . . | ៣៦២ |
| សោឡសមា បិង្គិយបញ្ហា . . . | ៣៦៣ |

# សន្លឹកប្រាប់មាតិកា

| មាតិកា | ទំព័រ |
| --- | --- |
| បារាយនវគ្គ ទី ៥ តិស្សមេត្តយ្យប្បញ្ហា ទី ២ . . . | ៣៣៧ |
| បុណ្ណកប្បញ្ហា ទី ៣ . . . . | ៣៣៨ |
| មេត្តគូបញ្ហា ទី ៤ . . . . | ៣៤០ |
| ធោតកប្បញ្ហា ទី ៥ . . . . | ៣៤៤ |
| ឧបសីវប្បញ្ហា ទី ៦ . . . . | ៣៤៦ |
| នន្ទប្បញ្ហា ទី ៧ . . . . . | ៣៤៩ |
| ហេមកប្បញ្ហា ទី ៨ . . . . | ៣៥២ |
| តោទេយ្យប្បញ្ហា ទី ៩ . . . . | ៣៥៣ |
| កប្បប្បញ្ហា ទី ១០. . . . . | ៣៥៤ |
| ជតុកណ្ណីបញ្ហា ទី ១១ . . . . | ៣៥៥ |
| ភទ្រាវុធប្បញ្ហា ទី ១២ . . . . | ៣៥៧ |
| ឧទយប្បញ្ហា ទី ១៣ . . . . | ៣៥៩ |
| បោសាលប្បញ្ហា ទី ១៤ . . . . | ៣៦០ |
| មោឃរាជប្បញ្ហា ទី ១៥ . . . . | ៣៦២ |
| បិង្គិយប្បញ្ហា ទី ១៦ . . . . | ៣៦៣ |

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| បារាយនានុសង្គីតិគាថា . . . . | ៣៦៤ |
| សុត្តនិបាតេ សុត្តុទ្ទានំ . . . . | ៣៧១ |

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

ព្យាករណានុសន្ធិកថា . . . . ៣៦៤
ឧទ្ទាននៃសូត្រ ក្នុងសុត្តន្តបិដក . . . ៣៧១

# វិរុទ្ធាវិរុទ្ធបត្តិ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រជ្ជុលេខាយំ |
|---|---|---|---|
| សន្ទាបេក្ខមានោ | សន្ទ៏បេក្ខមានោ | ១៣ | ១២ |
| សេរិតំ | សេរិតំ | ១៤ | ៨ |
| ,, | ,, | ,, | ១២ |
| សង្គណិកាតេស្ស | សង្គណិកាតេស្ស | ១៩ | ២ |
| និបំ ធាសោ | និប្បិបាសោ | ,, | ១០ |
| ព្រូហ | ព្រូហិ | ៣៤ | ១ |
| យថាហ | យថាហំ | ៤៣ | ៤ |
| ទិដ្ឋេ | ទិដ្ឋេវ | ៤៨ | ៧ |
| វិជ្ជាចរណសម្បទិ | វិជ្ជាចរណសម្បន្នំ | ៥៥ | ១៨ |
| លោកោ | លោកោ | ៥៦ | ១១ |
| នា សត្ថា | នោ សត្ថា | ៥៩ | ៥ |
| បញ្ញាធិរំ | បញ្ញាធីរី | ៦២ | ៩ |
| ជាតំ និកេតតោ | ជាតំ និកេតតោ | ៦៨ | ២ |
| ទុតិយំ អាមគន្ធសុត្តំ | តតិយំ ហិរិសុត្តំ | ៨៣ | ១ |
| បញ្ចមំ សូចិលោមសុត្តំ | ចតុត្ថំ មង្គលសុត្តំ | ៨៧ | ,, |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| មនោ វិតក្កា | មនោវិតក្កា | ៨៩ | ១៤ |
| • | • | ៩០ | ៤ |
| សុត្តនិបាតេ ទុតិយស្ស | សុត្តន្តបិដកេ | | |
| ចូឡវគ្គស្ស ធដ្ឋំ | ខុទ្ទកនិកាយស្ស | | |
| ធម្មបរិយសុត្តំ | សុត្តនិបាតោ | ៩២ | ៤ |
| សុត្តនិបាតេ ទុតិយស្ស | សុត្តន្តបិដកេ | | |
| ចូឡវគ្គស្ស សត្តមំ | ខុទ្ទកនិកាយស្ស | | |
| ព្រាហ្មណធម្មិកសុត្តំ | សុត្តនិបាតោ | ៩៤ | ៤ |
| សុត្តន្តបិដកេ ខុទ្ទ- | សុត្តនិបាតេ ទុតិយស្ស | | |
| កនិកាយស្ស | ចូឡវគ្គស្ស សត្តមំ | | |
| សុត្តនិបាតោ | ព្រាហ្មណធម្មិកសុត្តំ | ៩៥ | ៤ |
| សុត្តនិបាតេ ទុតិយស្ស | សុត្តន្តបិដកេ | | |
| ចូឡវគ្គស្ស សត្តមំ | ខុទ្ទកនិកាយស្ស | | |
| ព្រាហ្មណធម្មិកសុត្តំ | សុត្តនិបាតោ | [illegible] | [illegible] |
| សុត្តន្តបិដកេ | សុត្តនិបាតេ ទុតិយស្ស | | |
| ខុទ្ទកនិកាយស្ស | ចូឡវគ្គស្ស សត្តមំ | | |
| សុត្តនិបាតោ | ព្រាហ្មណធម្មិកសុត្តំ | ៩៧ | ៤ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| សុត្តនិបាតេ ទុតិយស្ស | សុត្តន្តបិដកេ | | |
| ចូឡវគ្គស្ស សត្តមំ | ខុទ្ទកនិកាយស្ស | | |
| ព្រាហ្មណធម្មិកសុត្តំ | សុត្តនិបាតោ | ៩៨ | ៤ |
| សុត្តន្តបិដកេ | សុត្តនិបាតេ ទុតិយស្ស | | |
| ខុទ្ទកនិកាយស្ស | ចូឡវគ្គស្ស សត្តមំ | | |
| សុត្តនិបាតោ | ព្រាហ្មណធម្មិកសុត្តំ | ៩៩ | ៤ |
| យជស្សុ | យជស្សូ | ៩៩ | ៤ |
| សត្តមំ ព្រាហ្មណធម្មិកសុត្តំ | អដ្ឋមំ នាវាសុត្តំ | ១០១ | ១ |
| ខេតា | ខេត្តា | ១១១ | ៤ |
| សុណន្តុ | សុណន្តិ | ១២៤ | ៨ |
| បរិសេ | បរីសេ | ១២៥ | ៩ |
| អដ្ឋង្កិក | អដ្ឋង្គិក | ១២៩ | ២ |
| អដ្ឋង្គុ | អដ្ឋង្គុ | 〃 | ៧ |
| បត្តំ សុន្ទរិកសុត្តំ | តតិយំ សុភាសិតសុត្តំ | ១៤១ | ១ |
| សុន្ទរកសុត្តំ | សុន្ទរិកសុត្តំ | ១៥៥ | ១ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| សស្សមណព្រាហ្មណំ | សស្សមណព្រាហ្មណី | ១៨៦ | ៨ |
| បតិដ្ឋាប្យេន្តិ | បតិដ្ឋាបេន្តិ | ១៨៩ | ៩ |
| បេច្ចស្សោសិ | បច្ចស្សោសិ | ២០៨ | ១១ |
| ហោកេហិច្ចន | ហុោកេហិច្ចន | ២១៤ | ៤ |
| កាមករាវក្តីណំ | កាមករាវកិ្ខីណំ | ២១៨ | ១៣ |
| មោនមជ្ឈត្តាតិ | មោនមជ្ឈគាតិ | ២៤៦ | ៣ |
| មុនមជ្ឈត្តាតិ | មុនមជ្ឈគាតិ | „ | ១៤ |
| សត្តន្តបិដកេ | សុត្តន្តបិដកេ | ២៥៤ | ១ |
| សាកេត្យ | សាកេត្យំ | ២៥៧ | ៣ |
| នាមមេឃរសិស្សតិ | នាមមេឃវសិស្សតិ | ២៧៦ | ៧ |
| ខេមទស្សនោ | ខេមទស្សិនោ | „ | ៩ |
| តេ(៣)វេ | តេ វេ | ២៨៣ | ១៣ |
| បវេធតិ កម្ម | បវេធតិ កម្ម(១) | ៣០៣ | ៣ |
| សារបុត្តសុត្តំ | សារីបុត្តសុត្តំ | ៣១៨ | ២ |
| អត្ថិសំ | អត្ថិស្សំ | ៣២៩ | „ |
| វិដ្ឋិត | វិដិត្ត | ៣៦៩ | ១២ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| កាជន៍មាសម្លៃ | កាជន៍មាសតម្លៃ | ២៨ | ១៨ |
| សុកសម្ភៈ | សុក្កសម្ភារៈ | ៤៣ | ១៧ |
| ព្រសង្ឃ | ព្រះសង្ឃ | ៧៦ | ៤ |
| បគ្គឈូល | បគ្គឃូល | ៧៩ | ៣ |
| ខ្វាក | ខ្វារក | ,, | ១០ |
| ខ្យន | ខៀន | ៨២ | ១០ |
| អាមគន្ធសូត្រទី ២ | ហិរិសូត្រទី ៣ | ៨៣ | ១ |
| សុត្តនិបាត ចូឡវគ្គទី២ ហិរិសូត្រទី៣ | សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត | ៨៤ | ១ |
| សុត្តនិបាត ចូឡវគ្គទី២ មង្គលសូត្រទី៤ | សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត | ៨៦ | ១ |
| ឧត្តម | ឧត្តម | ,, | ៩ |
| ,, | ,, | ,, | ១៤ |
| ការប្រព្រឹត្ត | ការប្រព្រឹត្តិ | ,, | ១៦ |
| សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត | សុត្តនិបាត ចូឡវគ្គ មង្គលសូត្រទី ៤ | ៨៧ | ១ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| សុត្តន្តបិដកខុទ្ទកនិកាយ | សុត្តនិបាត ចូឡវគ្គទី ២ | | |
| សុត្តនិបាត | សូចិលោមសូត្រ ទី ៥ | ៨៩ | ១ |
| សុត្តនិបាត ចូឡវគ្គទី ២ | សុត្តន្តបិដក ខុទ្ទក- | | |
| សូចិលោមសូត្រទី ៥ | និកាយ សុត្តនិបាត | ៩០ | ,, |
| សុត្តនិបាត ចូឡវគ្គទី ២ | សុត្តន្តបិដក ខុទ្ទក- | | |
| ធម្មចរិយសូត្រទី ៦ | និកាយ សុត្តនិបាត | ៩២ | ,, |
| សុត្តនិបាត ចូឡវគ្គទី ២ | សុត្តន្តបិដក ខុទ្ទកនិកាយ | | |
| ព្រាហ្មណធម្មិកសូត្រទី ៧ | សុត្តនិបាត | ៩៤ | ១ |
| សុត្តន្តបិដក ខុទ្ទកនិកាយ | សុត្តនិបាត ចូឡវគ្គទី ២ | | |
| សុត្តនិបាត | ព្រាហ្មណធម្មិកសូត្រទី ៧ | ៩៥ | ,, |
| ប្រព្រឹត្តិ | ប្រព្រឹត្ត | ,, | ៨ |
| សុត្តនិបាត ចូឡវគ្គទី ២ | សុត្តន្តបិដក ខុទ្ទកនិកាយ | | |
| ព្រាហ្មណធម្មិកសូត្រទី៧ | សុត្តនិបាត | ៩៦ | ១ |
| សុត្តន្តបិដក ខុទ្ទកនិកាយ | សុត្តនិបាត ចូឡវគ្គទី ២ | | |
| សុត្តនិបាត | ព្រាហ្មណធម្មិកសូត្រទី ៧ | ៩៧ | ១ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| សេចក្តិ | សេចក្តី | ៩៧ | ៦ |
| សុត្តនិបាត ចូឡវគ្គទី ២ | សុត្តនបិដក ខុទ្ទក- | | |
| ព្រាហ្មណធម្មិកសូត្រទី ៧ | និកាយ សុត្តនិបាត | ៩៨ | ១ |
| សុត្តនបិដក ខុទ្ទកនិកាយ | សុត្តនិបាត ចូឡវគ្គទី ២ | | |
| សុត្តនិបាត | ព្រាហ្មណធម្មិកសូត្រទី ៧ | ៩៩ | ១ |
| ព្រាហ្មណធម្មិកសូត្រទី ៧ | នាវាសូត្រ ទី ៨ | ១០១ | ១ |
| ទី ១៩ | ទី ១៣ | ១១៧ | ១ |
| បានស្លាប់ | ស្លាប់ | ១២៤ | ៩ |
| អ្នកបូមានចិត្ត | ជនអ្នកមានចិត្ត | ១២៩ | ៥ |
| រក្សាឧបោសថ | រក្សាហើយនូវឧបោសថ | | " |
| ព្រនិព្វាន | ព្រះនិព្វាន | ១៣៦ | ១៤ |
| សុន្ទរិកសូត្រទី ៤ | សុភាសិតសូត្រទី ៣ | ១៤១ | ១ |
| សុន្ទិ- | សុន្ទរិ- | ១៤៣ | ៩ |
| បរិភោក | បរិភោគ | ១៤៦ | ១៧ |
| មនមាន | មិនមាន | ១៥០ | ៤ |
| មួយ ទាក់ | មួយរយនាក់ | ១៥៧ | ១១ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ពីរយេ | ពីររយ | ១៨៤ | ៥ |
| ព្រាហ្មណ៍ | គ្រានោះឯង សេលព្រាហ្មណ៍ | ១៩០ | ៦ |
| សត្តនិបាត | សុត្តនិបាត | ២១៣ | ១ |
| ព្រះរាជាកុមារ | ព្រះរាជកុមារ | ២៣៨ | ៨ |
| រេបបួល | រួបបួល | ២៤៣ | ៧ |
| ទរលេត់ទុក | ទីរលេត់ទុក | ២៤៧ | ៩ |
| សម្ពស្ស | ផស្សៈ | ២៦២ | ១០ |
| រាបទាម | រាបទាប | ២៦៧ | ២ |
| ទិឋ្ឋដិ | ទិដ្ឋិ | ២៨៣ | ១៨ |
| សេក្តី | សេចក្តី | ២៨៥ | ៥ |
| មិនគប្ប | មិនគប្បី | ៣០៨ | ៧ |
| ឧបសីវមាវគប្បញ្ហា | ឧបសីវប្បញ្ហា | ៣៤៦ | ៨ |
| សុត្តនីបាតេ | សុត្តនិបាត | [illegible] | [illegible] |
| សុត្តនិបាត បាកយ-នាទុសត្តីគិកថា | ឧទ្ធានខៀនសុត្រ គ្គុនសុត្តនិបាត | ៣៧១ | ,, |
| សារិបត្ត | សារីបុត្ត | ៣៧៣ | ៧ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

Yoshio Hirano, Fusae Hirano, Aya Hirano, Takaaki Hirano
917-47, Kounosudai, Nagareyama-shi, Chiba.

この本は次の方によって復刻されました。

平野義夫・平野英江・平野　綾・平野隆明
〒270-01　千葉県流山市こうのす台917-47
☎0471-54-9861

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

**TRIPITAKA VOL. 54 (of 110 volumes total)**
**"SUTTANTA PITAKA"**
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

**トリピタカ（南伝大蔵経）全110巻・第54巻スッタンタピタカ（経部）**

---

**発　　行：プノンペン仏教研究所**
復刻救援：カンボジア版トリピタカ（南伝大蔵経）復刻救援委員会
発　　行：1994年12月8日

---

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE